អេស៊ីលីដា
ACLEDA BANK

# របាយការណ៍ប្រចាំឆ្នាំ ២០២៣

# ទស្សនៈ

ជាធនាគារពាណិជ្ជនាំមុខដែលលោកអ្នកជឿទុកចិត្តបំផុតនៅប្រទេសកម្ពុជា ក្នុងការផ្តល់ និងបម្រើសេវាកម្មហិរញ្ញវត្ថុ ជូនដល់សាធារណជនគ្រប់មជ្ឈដ្ឋានក្នុងសហគមន៍។

# បេសកកម្ម

ធនាគារ អេស៊ីលីដា ភីអិលស៊ី ផ្តល់ជូនអតិថិជននូវផលិតផល និងសេវាកម្មប្រកបដោយនវានុវត្តន៍ និងសុវត្ថិភាព ដើម្បីជាមធ្យោបាយក្នុងការគ្រប់គ្រង ចាត់ចែងធនធានហិរញ្ញវត្ថុឱ្យមានប្រសិទ្ធភាពខ្ពស់។ យើងប្រកាន់ខ្ជាប់ជានិច្ចនូវគោលការណ៍សីលធម៌ វិជ្ជាជីវៈ សង្គម ច្បាប់ និងបរិស្ថានប្រកបដោយកម្រិតខ្ពស់បំផុត ក្នុងគោលបំណងលើកស្ទួយជីវភាពរស់នៅឱ្យប្រសើរឡើង និងបង្កើនអត្ថប្រយោជន៍ជូនដល់គ្រប់ភាគីពាក់ព័ន្ធ ព្រមទាំងគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិទាំងមូលប្រកបដោយនិរន្តរភាព។

# គតិពេចន៍

គតិពេចន៍របស់ធនាគារគឺ៖ ប្រជាធនាគារដែលលោកអ្នកជឿទុកចិត្ត!

គតិពេចន៍អេស៊ីលីដាម៉ូបាល៖ ធនាគារពិតស្ថិតនៅក្នុងដៃលោកអ្នក!

របាយការណ៍នេះរៀបចំ និងចេញផ្សាយដោយ ធនាគារ អេស៊ីលីដា ភីអិលស៊ី ។ សម្រាប់ព័ត៌មានបន្ថែម និងចម្ងល់ផ្សេងៗ សូមទាក់ទងមក ៖

ការិយាល័យកណ្តាល ៖

អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក
ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ។
ប្រអប់សំបុត្រលេខ ៖ ១១៤៩
ទូរស័ព្ទ ៖ ០២៣ ៩៩៨ ៧៧៧ / ៤៣០ ៩៩៩
ទូរសារ ៖ ០២៣ ៤៣០ ៥៥៥
អ៊ីម៉ែល ៖ acledabank@acledabank.com.kh
វេបសាយ ៖ www.acledabank.com.kh
SWIFT Code: ACLBKHPP

ការិយាល័យទំនាក់ទំនងអតិថិជន
(បម្រើ ២៤ម៉ោង ក្នុងមួយថ្ងៃ និង៧ថ្ងៃ ក្នុងមួយសប្តាហ៍) ៖

ទូរស័ព្ទ ៖ ០២៣ ៩៩៤ ៤៤៤, ០១៥ ៩៩៩ ២៣៣
អ៊ីម៉ែល ៖ inquiry@acledabank.com.kh

# ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| បរិយាយ | ២០២៣ | ២០២២ | ២០២១ |
|---|---|---|---|
| ស្ថានភាពហិរញ្ញវត្ថុ (គិតជាលានរៀល) | | | |
| ទ្រព្យសកម្មសរុប | ៣៩.៨០៤.៤០៥ | ៣៧.១៨១.២៩៩ | ៣២.០០២.២៩៨ |
| បំណុលសរុប | ៣៤.១៥៨.៨៥០ | ៣១.៧៦០.៦៦០ | ២៧.០៩២.៩៨៥ |
| មូលធនសរុប | ៥.៦៤៥.៥៥៥ | ៥.៤២០.៦៣៩ | ៤.៩០៩.៣១៣ |
| លទ្ធផលហិរញ្ញវត្ថុ (គិតជាលានរៀល) | | | |
| ចំណូលសរុប | ៣.៤០៣.១១៤ | ៣.០៤០.០៣៨ | ២.៥៩០.០៨៦ |
| ចំណេញ/(ខាត) មុនបង់ពន្ធ | ៧៥៧.២១៦ | ៩៣៣.០៩៥ | ៨៣២.៩៣៧ |
| ចំណេញ/(ខាត)សុទ្ធ ក្នុងការិយបរិច្ឆេទ | ៦០៨.៣៥៦ | ៧៤៣.០៧៧ | ៦៧៨.០៣១ |
| លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ | ៥២២.៩៧០ | ៧៥០.២៥៤ | ៦៣៥.៦៨៥ |
| អនុបាតហិរញ្ញវត្ថុ | | | |
| អនុបាតសាធនភាព | ១៨,៤៥% | ១៩,២៥% | ២២,៣៦% |
| អនុបាតបំណុលធៀបនឹងមូលធន | ៦០៥,០៦% | ៥៨៥,៩២% | ៥៥១,៨៧% |
| អនុបាតក្រុបខ័ណ្ឌសន្ទនីយភាព | ១៨០,១៣% | ១៥៤,៩៦% | ១៥៥,៦៥% |
| អនុបាតឥណទានមិនដំណើរការ | (*) ៥,៧៧% | ២,៩០% | ២,៣៣% |
| អនុបាតឥណទានធៀបនឹងប្រាក់បញ្ញើ | ៩២,១១% | ១០០,៥១% | ៩៤,៩៧% |
| អនុបាតចំណេញធៀបនឹងទ្រព្យសកម្មមធ្យម (ROAA) (**) | ១,៥៨% | ២,១៥% | ២,៣២% |
| អនុបាតចំណេញធៀបនឹងមូលធនមធ្យម (ROAE) (**) | ១១,០៥% | ១៤,៤៥% | ១៤,៦១% |
| អនុបាតលទ្ធភាពបង់ការប្រាក់ (ដង) | ១,៥៦ | ២,០៣ | ២,១៩ |
| តម្លៃចុះបញ្ជីក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (រៀល) | ១២.៩៧៧ | ១២.៤៥៦ | ១១.២៧៧ |
| ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (រៀល) | ១.៤០៥ | ១.៧១៥ | ១.៥៦៨ |
| ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (រៀល) | - | ៦៨៦ | ៥៤៩ |
| អនុបាតហិរញ្ញវត្ថុសំខាន់ៗផ្សេងទៀត | - | - | - |

(*) អនុបាតឥណទានមិនដំណើរការ = សមតុល្យប្រាក់ដើមតាមកិច្ចសន្យារបស់ឥណទានមិនដំណើរការ / សមតុល្យប្រាក់ដើមឥណទានតាមកិច្ចសន្យាសរុប

(**) អនុបាតទាំងនេះត្រូវបានគណនាដោយប្រើតួលេខប្រាក់ចំណេញដែលផ្តល់ជូនដល់ភាគហ៊ុនិករបស់ធនាគារ។

. ចំណេញធៀបនឹងមូលធនមធ្យម = ប្រាក់ចំណេញដែលផ្តល់ជូនដល់ភាគហ៊ុនិករបស់ធនាគារ / មូលធនសរុបមធ្យមរបស់ភាគហ៊ុនិករបស់ធនាគារ

. ចំណេញធៀបនឹងទ្រព្យសកម្មមធ្យម = ប្រាក់ចំណេញដែលផ្តល់ជូនដល់ភាគហ៊ុនិករបស់ធនាគារ / ទ្រព្យសកម្មមធ្យម

# ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប និងស្ថិតិសង្ខេបប្រចាំឆ្នាំពីលទ្ធផលប្រតិបត្តិការ (Charts)













៣.៤០៣.១១៤
៣.០៤០.០៣៨
២.៩៩០.០៨៦
៣.១០៥.៦៤៤
២.៧៤១.៣៦៩
២.៣៣៤.២១៧
១.៣៥២.១៩៦
៩០២.៥០១
៧០១.២០៤
ចំណូលសរុប
ចំណូលការប្រាក់
ចំណាយការប្រាក់
គិតជាលានរៀល
២០២៣
២០២២
២០២១


គិតជាលានរៀល
២០២៣
២០២២
២០២១
២៧.១៩៥.១២០
២៦.៤៣៧.៩២៨
២២.១១៦.០១៣
២៩.៥២៥.៦១៦
២៦.៣០៣.៤៧៥
២៣.២៨៧.០៦៤
សមតុល្យឥណទានសរុប
ចំនួនទឹកប្រាក់បញ្ញើសរុប


៦៦១.៩៤១
៥៩១.៤៩៤
៥៤១.១៨៤
៤.៥៥០.៥៨២
៣.៨៦៥.៧៤៩
៣.២៩៨.៣៨២
ចំនួនឥណទានសកម្ម
ចំនួនគណនីប្រាក់បញ្ញើសរុប
២០២៣
២០២២
២០២១


២០២៣
២០២២
២០២១
១២.៩៧៧
១២.៤៥៦
១១.២៧៧
១.៤០៥
១.៧១៥
១.៥៦៨
តម្លៃចុះបញ្ជីក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (រៀល)
ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (រៀល)

# សមាសភាពក្រុមប្រឹក្សាភិបាល

សមាជិក-សមាជិកាក្រុមប្រឹក្សាភិបាល ត្រូវបានតែងតាំងដោយភាគហ៊ុនិកសម្រាប់អាណត្តិ ៣ឆ្នាំ ដើម្បីធ្វើសកម្មភាពតំណាងឱ្យពួកគេផ្ទាល់។ តាមលក្ខន្តិកៈបានបញ្ជាក់ថា សមាសភាពក្រុមប្រឹក្សាភិបាលត្រូវមាន ៩រូប ដែល៖

- ក្រុមប្រឹក្សាភិបាល ទទួលខុសត្រូវលើការកំណត់យុទ្ធសាស្ត្រ របស់ធនាគារ និងគ្រប់គ្រងរាល់ប្រតិបត្តិការអាជីវកម្ម។ សមាជិក-សមាជិកាក្រុមប្រឹក្សាភិបាលទាំងអស់ ត្រូវធ្វើកិច្ចការ ដើម្បីជាប្រយោជន៍ខ្ពស់បំផុតសម្រាប់ធនាគារ។
- អំណាចរបស់ក្រុមប្រឹក្សាភិបាលត្រូវអនុវត្តរួមគ្នា ហើយគ្មានសមាជិក-សមាជិកាណាម្នាក់មានអំណាចក្នុងការផ្តល់ការណែនាំ ឬការបង្គាប់បញ្ជាតែឯកឯងលើថ្នាក់ដឹកនាំ ឬបុគ្គលិកណាម្នាក់របស់ធនាគារ ឬចុះហត្ថលេខាលើកិច្ចសន្យា ឬការដឹកនាំគ្រប់គ្រងប្រតិបត្តិការរបស់ធនាគារបានឡើយ លើកលែងតែមានការផ្ទេរអំណាចដាក់លាក់ឱ្យអនុវត្ត តាមរយៈសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល។
- សមាជិក-សមាជិកាម្នាក់ៗ អាចពិនិត្យដោយគ្មានកំណត់ ចំពោះឯកសារ និងកំណត់ត្រាផ្សេងៗរបស់ធនាគារ គ្រប់ពេលម៉ោងធ្វើការ។

ក្រុមប្រឹក្សាភិបាល ធ្វើការជ្រើសតាំងនូវសមាជិកម្នាក់ ឱ្យធ្វើជាប្រធានក្រុមប្រឹក្សាភិបាល តាមរយៈការបោះឆ្នោត ដោយយកតាមសំឡេងភាគច្រើនហើយបុគ្គលនោះជាអ្នកដឹកនាំនូវរាល់ កិច្ចប្រជុំក្រុមប្រឹក្សាភិបាល ក៏ដូចជាមហាសន្និបាតប្រចាំឆ្នាំ។

ក្រុមប្រឹក្សាភិបាល ទទួលខុសត្រូវលើអភិបាលកិច្ចសាជីវកម្ម និងជំរុញអភិវឌ្ឍន៍ជោគជ័យរបស់ធនាគារ តាមរយៈការដឹកនាំរាល់ប្រតិបត្តិការការងារ និងអាជីវកម្ម។ ក្រុមប្រឹក្សាភិបាលជាអ្នកតែងតាំង និងអាចដកតំណែងរបស់ប្រធាននាយកប្រតិបត្តិ។ ក្រុមប្រឹក្សាភិបាលក៏ធានាផងដែរថាធនធានមនុស្ស ដែលចាំបាច់មានគ្រប់គ្រាន់ក្នុងការបង្កើតយុទ្ធសាស្ត្រ និងគោលដៅហិរញ្ញវត្ថុជាមួយថ្នាក់គ្រប់គ្រង ដើម្បីដាក់ឱ្យថ្នាក់គ្រប់គ្រងអនុវត្ត ព្រមទាំងត្រួតពិនិត្យលើការអនុវត្តរបស់ថ្នាក់គ្រប់គ្រងដោយផ្ទាល់ និងតាមរយៈគណៈកម្មាធិការក្រុមប្រឹក្សាភិបាល។

ក្រុមប្រឹក្សាភិបាលបានបង្កើតគណៈកម្មាធិការចំនួន៣ មានដូចជា គណៈកម្មាធិការសវនកម្ម គណៈកម្មាធិការតែងតាំង និងលាភការ គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងព័ត៌មានវិទ្យា ព្រមទាំងបង្កើតនូវ គណៈកម្មាធិការផ្សេងទៀត អាស្រ័យទៅតាមតម្រូវការចាំបាច់ ដើម្បីដំណើរការប្រតិបត្តិការអាជីវកម្មរបស់ធនាគារ។ គណៈកម្មាធិការរបស់ក្រុមប្រឹក្សាភិបាលទាំងនេះ ត្រូវបង្កើតឡើងអាស្រ័យទៅនឹងក្រុមប្រឹក្សាភិបាល ហើយសមាជិក-សមាជិកាទាំងអស់នៅក្នុងគណៈកម្មាធិការនឹងត្រូវអនុម័តដោយក្រុមប្រឹក្សាភិបាល។ គណៈកម្មាធិការទាំងនេះ មិនអនុវត្តអំណាចរបស់ក្រុមប្រឹក្សាភិបាលឡើយ លើកលែងតែមានការផ្ទេរសិទ្ធិអំណាចជាផ្លូវការ តែត្រូវផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាភិបាលចំពោះសកម្មភាពរួមរបស់ពួកគេ។ គួរបញ្ជាក់ផងដែរថា សមាជិកភាពនៃគណៈកម្មាធិការមិនកំណត់ថា ត្រូវតែជាសមាជិក-សមាជិកាក្រុមប្រឹក្សាភិបាលនោះទេ ពោលគឺអាចជាអ្នកគ្រប់គ្រង ឬបុគ្គលណាផ្សេងទៀត ដែលសមស្របក្នុងតួនាទីរបស់គណៈកម្មាធិការនីមួយៗ។ ប៉ុន្តែប្រធាននៃគណៈកម្មាធិការក្រុមប្រឹក្សាភិបាល គឺចាំបាច់ត្រូវតែជាសមាជិក-សមាជិការបស់ក្រុមប្រឹក្សាភិបាល ដែលអាចអញ្ជើញគណៈគ្រប់គ្រង និងភាគីពាក់ព័ន្ធផ្សេងៗ ដើម្បីផ្តល់ព័ត៌មានប្រតិបត្តិការ និងពន្យល់នៅពេលចាំបាច់។ គណៈកម្មាធិការទាំងអស់ត្រូវមានប្រធានជាអភិបាលឯករាជ្យ។



## លោក ឆាយ សឿន
ប្រធានក្រុមប្រឹក្សាភិបាល

## បណ្ឌិត អ៊ិន ចាន់នី
អភិបាលប្រតិបត្តិ





## លោក Kyosuke Hattori
អភិបាលមិនប្រតិបត្តិ



## បណ្ឌិត Albertus Bruggink
អភិបាលមិនប្រតិបត្តិ



## លោក Stéphane Mangiavacca
អភិបាលមិនប្រតិបត្តិ

## លោក កាយ ឡូត
អភិបាលមិនប្រតិបត្តិ





## បណ្ឌិត ហេង ឌីណា
អភិបាលឯករាជ្យ



## លោក Pieter Kooi
អភិបាលឯករាជ្យ



## លោកស្រី ភូរិ រតនា
អភិបាលឯករាជ្យ



## លោក ឆាយ សឿន

ប្រធានក្រុមប្រឹក្សាភិបាល

# សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល

តាងនាមឱ្យធនាគារ អេស៊ីលីដា ភីអិលស៊ី និងក្រុមប្រឹក្សាភិបាល ខ្ញុំបាទមានកិត្តិយស និងសេចក្តីសោមនស្សរីករាយ សូមធ្វើការបង្ហាញជូននូវរបាយការណ៍ប្រចាំឆ្នាំ២០២៣ របស់ធនាគារ។

នៅក្នុងឆ្នាំ២០២៣ សេដ្ឋកិច្ចពិភពលោកបានបង្ហាញនូវភាពធន់ ដែលគាំទ្រយ៉ាងខ្លាំងដោយសេដ្ឋកិច្ចសហរដ្ឋអាមេរិក និងបណ្ដាប្រទេសដែលទីផ្សារកំពុងរីកចម្រើនលេចធ្លោ និងសេដ្ឋកិច្ចកំពុងអភិវឌ្ឍន៍ ព្រមទាំងគោលនយោបាយគាំទ្រសារពើពន្ធរបស់ចិន។ ទោះជាយ៉ាងណាក៏ដោយ កំណើនសេដ្ឋកិច្ចពិភពលោកប្រកបដោយចីរភាពនៅតែថមថយពេញមួយឆ្នាំ ដោយសារអត្រាអតិផរណាបានឈានដល់កម្រិតខ្ពស់ ដែលបណ្ដាលមកពីកត្តាសង្គ្រាមអ៊ុយក្រែន និងការរំខាននៃជំងឺរាតត្បាតដែលកំពុងបន្ត ប៉ុន្តែបានថយចុះវិញនៅចុងឆ្នាំ២០២៣ និងមួយផ្នែករងឥទ្ធិពលពីគោលនយោបាយរូបិយវត្ថុកាន់តែតឹងតែងរបស់ធនាគារកណ្ដាល។ សេដ្ឋកិច្ចពិភពលោកកំពុងងើបឡើងវិញបន្តិចម្ដងៗពីបញ្ហាប្រឈមដែលបង្កឡើងដោយជំងឺរាតត្បាត សង្គ្រាមរុស្ស៊ី-អ៊ុយក្រែន អតិផរណា ភាពតានតឹងភូមិសាស្ត្រនយោបាយ និងគោលនយោបាយរឹតបន្តឹងទូទាំងពិភពលោករបស់ធនាគារកណ្ដាល។ យោងតាមរបាយការណ៍ចុងក្រោយរបស់ IMF កំណើនសេដ្ឋកិច្ចសកលដែលបានប៉ាន់ប្រមាណសម្រាប់ឆ្នាំ២០២៣ គឺ ៣,១% ធ្លាក់ចុះពី ៣,៥% ក្នុងឆ្នាំ២០២២ និងទាបជាងមធ្យមភាគជាប្រវត្តិសាស្ត្រ ៣,៨% ពីឆ្នាំ២០០០ ដល់ឆ្នាំ២០១៩។ ទន្ទឹមនឹងនោះ អតិផរណាបានថយចុះមកនៅត្រឹម៦,៨% ក្នុងឆ្នាំ២០២៣ ពី៨,៧% នៅឆ្នាំ២០២២។ សេដ្ឋកិច្ចអាមេរិកមានកំណើនលើសពីការរំពឹងទុកចំនួន ២,៥% នៅឆ្នាំ២០២៣ កើនឡើងពី ១,៩%។ កំណើនសេដ្ឋកិច្ចតំបន់អឺរ៉ូមានកម្រិតទាបត្រឹម ០,៥% ក្នុងឆ្នាំ២០២៣ ទាបជាងឆ្នាំ២០២២ ដែលមានកំណើនរហូតដល់ ២,៤%។ ផ្ទុយទៅវិញ សេដ្ឋកិច្ចចិនមានកំណើន ៥,២% ប្រឈមមុខនឹងហានិភ័យជាបន្តបន្ទាប់ពីការធ្លាក់ចុះទីផ្សារអចលនទ្រព្យ និងសេដ្ឋកិច្ចពិភពលោក។ សេដ្ឋកិច្ចជប៉ុនត្រូវបានប៉ាន់ប្រមាណថាកើនឡើងពី ១% ក្នុងឆ្នាំ២០២២ ដល់ ១,៩% ក្នុងឆ្នាំ២០២៣ ខណៈពេលដែលសេដ្ឋកិច្ចអាស៊ានជួបប្រទះនឹងកំណើនយឺតនៅត្រឹម ៤,៤% ក្នុងឆ្នាំ២០២៣ ស្របពេលមានការប្រកួតប្រជែងសេដ្ឋកិច្ចពិភពលោក។

ខណៈពេលដែលសេដ្ឋកិច្ចសកលមានបញ្ហាប្រឈម សេដ្ឋកិច្ចកម្ពុជារក្សាបានស្ថិរភាព ដោយមានកំណើន ៥,៥% ក្នុងឆ្នាំ២០២៣ កើនឡើងពី ៥,២% ក្នុងឆ្នាំ២០២២ យោងតាមធនាគារជាតិ នៃ កម្ពុជា។ កំណើននេះបានគាំទ្រដោយការស្ទុះងើបឡើងវិញនៃតម្រូវការប្រើប្រាស់ក្នុងស្រុក ការលើកកម្ពស់ការងារ ការបន្ធូរបន្ថយអតិផរណា ការស្ទុះងើបឡើងវិញដ៏រឹងមាំនៅក្នុងវិស័យសេវាកម្មគាំទ្រដោយទេសចរណ៍ កំណើនការវិនិយោគថ្មី និងការនាំចេញផលិតផលមិនមែនកាត់ដេរ។ ទោះជាយ៉ាងនេះក្ដី វិស័យអចលនទ្រព្យ និងសំណង់នៅតែបន្តមានការថយចុះ នៅពេលដែលវិស័យកសិកម្មមានកំណើនយឺត។

ក្នុងឆ្នាំ២០២៣ ប្រព័ន្ធធនាគារបន្តគ្របដណ្ដប់វិស័យហិរញ្ញវត្ថុ និងបានដើរតួនាទីយ៉ាងសកម្មក្នុងការគាំទ្រដល់វិស័យសេដ្ឋកិច្ចចម្បងៗ បើទោះបីល្បឿនកំណើនឥណទានបានថមថយក៏ដោយ។ ប្រាក់បញ្ញើអតិថិជនមានកំណើនខ្ពស់ ១៣,១% ដល់ ៤៧,៩ ប៊ីលានដុល្លារអាមេរិក ស្របពេលដែលឥណទានមានកំណើនយឺត ៤,៨% ដល់ ៥៧,៦ ប៊ីលានដុល្លារអាមេរិក ដែលជាអត្រាកំណើនទាបបំផុតក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយនេះ បណ្ដាលមកពីការងើបឡើងវិញយឺតនៃវិស័យមួយចំនួន។ ក្នុងស្ថានភាពនេះ បទប្បញ្ញត្តិប្រុងប្រយ័ត្នមួយចំនួនត្រូវបានអនុគ្រោះ ដើម្បីផ្ដល់លទ្ធភាពបន្ថែមដល់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ក្នុងការជួយទ្រទ្រង់វិស័យដែលត្រូវការហិរញ្ញប្បទាន ដើម្បីរក្សានិរន្តរភាព និងពង្រីកការវិនិយោគ។

នៅក្នុងកំឡុងឆ្នាំ២០២៣ ធនាគារ អេស៊ីលីដា បានផ្ដល់នូវជម្រើសនៃការទូទាត់ជាច្រើនជូនអតិថិជនទាំងក្នុង និងក្រៅប្រទេស ប្រកបដោយភាពងាយស្រួល រហ័ស សុវត្ថិភាព និងសម្បូរបែប។ ធនាគារ បានទទួលការអនុញ្ញាតពី ធនាគារជាតិ នៃ កម្ពុជា ជាធនាគារទូទាត់ នៅក្នុងប្រព័ន្ធប្រតិបត្តិការទូទាត់ឆ្លងដែន រវាងប្រទេសកម្ពុជា ជាមួយប្រទេសជិតខាងរួមមាន ថៃ វៀតណាម និងឡាវ ព្រមទាំងកំពុងដំណើរការរៀបចំជាជំហានបន្ទាប់ទៅប្រទេសជាសមាជិកអាស៊ាន និងបណ្ដាប្រទេសអាស៊ីផ្សេងទៀត ដូចជា ឥណ្ឌា ចិន ជប៉ុន និងកូរ៉េ ជាដើម។ ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធនេះ គឺក្នុងគោលបំណងដើម្បីរួមចំណែកលើកកម្ពស់ការទូទាត់រូបិយវត្ថុជាតិ ជំរុញបរិយាបន្នហិរញ្ញវត្ថុ សម្រួលការធ្វើពាណិជ្ជកម្មឆ្លងដែន និងកំណើនភ្ញៀវទេសចរផងដែរ។ ធនាគារ បានសហការជាមួយក្រុមហ៊ុនម៉ាស្ទ័រកាត ដាក់ឱ្យដំណើរការជាផ្លូវការនូវ ប័ណ្ណឡេឌីម៉ាស្ទ័រកាត អេស៊ីលីដា ក្នុងប្រទេសកម្ពុជា។ ប័ណ្ណឡេឌីម៉ាស្ទ័រកាត អេស៊ីលីដា សម្រាប់អតិថិជនជាសុភាពនារីនឹងផ្ដល់ឱ្យពួកគាត់នូវមធ្យោបាយទូទាត់តាមបែបឌីជីថល និងបានចាប់ដៃគូជាមួយ RIA Money Transfer ក្នុងការពង្រីកសេវាកម្មផ្ទេរប្រាក់ ហើយភាពជាដៃគូនេះ បានបន្ថែមទីតាំងដកប្រាក់ និងទូទាត់ប្រាក់ជាច្រើនកន្លែង តាមរយៈបណ្ដាញរបស់ RIA នៅក្នុងប្រទេសកម្ពុជា។ លើសពីនេះ ធនាគារ បានសហការជាមួយស្ថាប័ន Global Loyalty Network "GLN International Inc." ដែលជាក្រុមហ៊ុនបណ្ដាញឌីជីថលសកល សម្រាប់ទូទាត់ឆ្លងដែន តាមរយៈទូរស័ព្ទចល័ត។ សមិទ្ធផលនេះនឹងអនុញ្ញាតឱ្យអ្នកប្រើប្រាស់ទូរស័ព្ទចល័តនៅក្នុងបណ្ដាញ GLN មកពីសាធារណរដ្ឋកូរ៉េ និងនៅជុំវិញពិភពលោក អាចទូទាត់ថ្លៃទំនិញ និងសេវាកម្មផ្សេងៗ នៅក្នុងប្រទេសកម្ពុជា។

បន្ថែមពីនេះទៀត ធនាគារបានបន្តធ្វើឱ្យប្រសើរឡើងនូវមុខងារស្វ័យប្រតិបត្តិការជាច្រើនលើអេស៊ីលីដាម៉ូបាយ ឃ្យូអរកូដ ម៉ាស៊ីនអេធីអឹម និងម៉ាស៊ីនឆូតកាត ស្របតាមតម្រូវការរបស់អតិថិជន និងវិវឌ្ឍនាការបច្ចេកវិទ្យាឌីជីថល។ ទន្ទឹមនឹងនេះ ធនាគារបានពង្រីកសេវាកម្មធនាគារស្វ័យប្រវត្តិចំនួន១៧៧ទីតាំង (រាជធានីភ្នំពេញចំនួន៦១ទីតាំង និងបណ្ដាខេត្តសរុបចំនួន១១៦ទីតាំង) បន្ថែមលើសាខាធនាគារទាំង២៦៤សាខា ព្រមទាំងបានបំពាក់ម៉ាស៊ីនអេធីអឹមចំនួន ១.៣៩៣គ្រឿង ម៉ាស៊ីនឆូតកាតចំនួន៤.៧២៨គ្រឿង និងឃ្យូអរកូដតាមសំណើសុំរបស់អតិថិជន សម្រាប់ប្រតិបត្តិការនៃការផ្ទេរ និងការទូទាត់នៅតាមបណ្ដាផ្សារ ហាងទំនិញ សណ្ឋាគារ ភោជនីយដ្ឋាន គ្រឹះស្ថានសិក្សា មន្ទីរពេទ្យ ទីភ្នាក់ងារទេសចរណ៍ ស្ថានីយប្រេងឥន្ធនៈ និងអាជីវកម្មនានា នៅទូទាំងប្រទេស។ គិតត្រឹមដំណាច់ខែធ្នូ ឆ្នាំ២០២៣នេះ ធនាគារ មានដៃគូអាជីវកម្មសរុបជាង ០,៣៣លាន និងមានអ្នកប្រើប្រាស់អេស៊ីលីដាម៉ូបាយសរុបចំនួន ៣,៣ លាននាក់។

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ប្រាក់បញ្ញើសរុបបានកើនឡើងចំនួន ៨៣៨,៨២ លានដុល្លារអាមេរិក សមតុល្យឥណទានសរុបបានកើនឡើងចំនួន ២៣៥,៦៦លានដុល្លារអាមេរិក បើធៀបនឹងដំណាច់ឆ្នាំ២០២២។ បើធៀបលទ្ធផលប្រចាំឆ្នាំ២០២៣ ទៅនឹងលទ្ធផលឆ្នាំ២០២២ សម្ព័ន្ធធនាគារទទួលបានប្រាក់ចំណេញចំនួន ១៤៨,០៥លានដុល្លារអាមេរិក ថយចុះ ១៨,៥៣% ស្មើនឹង ៣៣,៦៨លានដុល្លារអាមេរិក។

យើងខ្ញុំសូមថ្លែងអំណរគុណ និងសំដែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅចំពោះភាគហ៊ុនិក អតិថិជន និយោជិត និងជាពិសេសអាជ្ញាធរពាក់ព័ន្ធទាំងអស់ដែលតែងតែផ្ដល់ការគាំទ្រចំពោះធនាគារដើម្បីទទួលបាននូវលទ្ធផលល្អប្រសើរលើសពីផែនការជាពិសេសក្នុងឆ្នាំ២០២៣។

ធនាគារ អេស៊ីលីដា ភីអិលស៊ី
ACLEDA BANK PLC.

លោក ឆាយ សឿន
*ប្រធានក្រុមប្រឹក្សាភិបាល*
*ធនាគារ អេស៊ីលីដា ភីអិលស៊ី*
ថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៤



**បណ្ឌិត អ៊ិន ចាន់នី**

ប្រធាននាយកប្រតិបត្តិ

# សេចក្តីថ្លែងរបស់ប្រធាននាយកប្រតិបត្តិ

ធនាគារមានការប្តេជ្ញាចិត្តខ្ពស់ក្នុងការផ្តល់សេវាកម្មជូនដល់អតិថិជនប្រកបដោយប្រសិទ្ធភាព និងនវានុវត្តន៍។ ដោយការផ្តល់អាទិភាពក្នុងការបំពេញតម្រូវការអតិថិជន ធនាគារទទួលបានជោគជ័យក្នុងការធ្វើទំនើបកម្ម និងដំណើរការប្រព័ន្ធធនាគារ ដើម្បីកាត់បន្ថយចំណាយក្នុងការប្រើប្រាស់សេវាកម្មធនាគារប្រកបដោយប្រសិទ្ធភាពខ្ពស់ ដែលផ្តល់អត្ថប្រយោជន៍ជូនគ្រប់ភាគីពាក់ព័ន្ធ។ ជាងនេះទៅទៀត ធនាគារបន្តវិនិយោគក្នុងការធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដែលអាចគ្រប់គ្រង និងផ្ទុកទិន្នន័យដ៏ច្រើន ប្រកបដោយប្រសិទ្ធភាព ព្រមទាំងអាចផ្សព្វផ្សាយបញ្ជ្រាប ពង្រីកទីផ្សារ និងផ្តល់យុទ្ធសាស្ត្រលក់ដល់អតិថិជន។ យុទ្ធសាស្ត្រសមស្របទាំងនេះ បានបង្កើតឱកាសយ៉ាងច្រើន សម្រាប់អតិថិជន។

បន្ថែមពីលើវត្តមាននៅទីផ្សារក្នុងប្រទេស ធនាគារបានពង្រីកទីផ្សាររបស់ខ្លួនទៅបរទេស តាមរយៈការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធទូទាត់ឆ្លងដែន ដែលបានដាក់ឱ្យដំណើរការជាលើកដំបូងនៅក្នុងប្រទេសថៃ ហើយទទួលបានជោគជ័យលើការពង្រីកប្រតិបត្តិការទូទាត់ទៅកាន់ប្រទេសឡាវ និងវៀតណាម ជាមួយនឹងផែនការពង្រីកបន្ថែមទៀតទៅក្នុងប្រទេសមួយចំនួនទៀត។ កិច្ចខិតខំប្រឹងប្រែងរបស់ធនាគារ ស្របតាមគោលដៅ និងយុទ្ធសាស្ត្រនឹងត្រួសត្រាយផ្លូវបន្តភាពជោគជ័យទាំងនៅទីផ្សារក្នុងស្រុក និងអន្តរជាតិ។

# សមិទ្ធផលសម្រេចបានក្នុងឆ្នាំ២០២៣

## ស្ថានភាពប្រកួតប្រជែង

ឆ្នាំ២០២៣ អង្គការសុខភាពពិភពលោក (WHO) បានប្រកាសស្តីពីការបញ្ចប់ជំងឺរាតត្បាតកូវីដ-១៩។ បច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត (AI) កំពុងមានទំនោរកើនឡើង និងសក្តានុពលកាន់តែខ្លាំង ក្នុងការធ្វើការងារ ឬសកម្មភាពផ្សេងៗ ជំនួសមនុស្ស។ នៅទូទាំងពិភពលោក អត្រាការប្រាក់បានកើនឡើងខ្ពស់គួរឱ្យកត់សម្គាល់ មុនពេលវាមានទំនោរធ្លាក់ចុះបន្តិចនៅចុងឆ្នាំ ដោយរំពឹងថា វានឹងបន្តធ្លាក់ចុះបន្ថែមទៀតនៅកំលុងឆមាសទី១ ឆ្នាំ២០២៤។ នេះគឺជាពេលវេលា សម្រាប់ប្រជាជាតិទាំងអស់លើសកលលោក រួមគ្នាដោះស្រាយបញ្ហាចម្បងៗ ដូចជា បម្រែបម្រួលអាកាសធាតុ ការអភិវឌ្ឍប្រកបដោយចីរភាព ការគាំពារសុខុមាលភាព និងបរិវត្តកម្មឌីជីថល។

ក្នុងយុគសម័យឌីជីថលនេះ ខណៈដែលអតិថិជនកំពុងអភិវឌ្ឍ និងសម្របខ្លួនបន្តិចម្តងៗ ទៅនឹងបរិការណ៍នៃសេដ្ឋកិច្ច និងសង្គមឌីជីថល ព្រមទាំងកំពុងទទួលយកយ៉ាងឆាប់រហ័សនូវផលិតផល និងសេវាកម្មធនាគារឌីជីថល គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនានាក្នុងប្រទេសកម្ពុជា បាន និងកំពុងប្រកួតប្រជែង គ្នាយ៉ាងខ្លាំងក្លា ដោយប្រើប្រាស់វិធីសាស្ត្រផ្សេងៗ ដូចជា បណ្តាញទីផ្សារ យុទ្ធសាស្ត្រជំរុញ និងផ្សព្វផ្សាយ ការផ្តល់រង្វាន់លើកទឹកចិត្ត ការពង្រីកបណ្តាញ ប្រតិបត្តិការរូបវន្ត និងឌីជីថល និងយុទ្ធសាស្ត្រកំណត់ថ្លៃ ជាដើម។ ជាក់ស្តែង អតិថិជនកាន់តែមានភាពងាយស្រួល និងប្រសិទ្ធភាពខ្ពស់ ក្នុងការប្រើប្រាស់ផលិតផល និងសេវាកម្មហិរញ្ញវត្ថុ បង្កើនអានុភាពហិរញ្ញវត្ថុយ៉ាងធំធេង ព្រមទាំងអភិវឌ្ឍចំណេះដឹង និងបរិយាបន្នផ្នែកហិរញ្ញវត្ថុ ឱ្យកាន់តែប្រសើរឡើង។

ធនាគារ អេស៊ីលីដា បន្តធ្វើទំនើបកម្មសាខា និងការិយាល័យ ឱ្យទៅជាមជ្ឈមណ្ឌលសេវាកម្មធនាគារស្វ័យប្រវត្តិ ដែលផ្តល់ជម្រើសសេវាកម្មហិរញ្ញវត្ថុចម្រុះ។ ក្របខ័ណ្ឌឌីជីថលនេះ មិនត្រឹមតែបានលើកកម្ពស់ស័ក្តិសិទ្ធិភាព សុវត្ថិភាព ប្រសិទ្ធភាពចំណាយ និងពន្លឿនប្រព័ន្ធសេដ្ឋកិច្ចប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានប្រែក្លាយទៅជាកម្លាំងចលករដ៏សំខាន់ ក្នុងការជំរុញកំណើនសេដ្ឋកិច្ច។ បន្ថែមលើនេះទៀត ក្របខ័ណ្ឌនេះក៏បានសម្របសម្រួល និងជួយជំរុញឱ្យមានបរិយាបន្នកាន់តែប្រសើរឡើង ដោយតភ្ជាប់ទំនាក់ទំនងសហគមន៍ទូទាំងប្រទេស និងពង្រីកទៅកាន់ក្រៅប្រទេសជាសកល។ កម្មវិធីសេវាកម្មធនាគារតាមទូរស័ព្ទ (Mobile App.) បានក្លាយជាឧបករណ៍ទូទាត់ដ៏មានប្រជាប្រិយភាព និងការប្រកួតប្រជែងយ៉ាងផុលផុស ដោយធនាគារជាង២ភាគ៣ បានដាក់ឱ្យប្រើប្រាស់កម្មវិធីសេវាកម្មធនាគារ។ អេស៊ីលីដាម៉ូបាល “ធនាគារពិតស្ថិតនៅក្នុងដៃលោកអ្នក” គឺជាកម្មវិធីសេវាកម្មធនាគារឈានមុខ ដែលបាន និងកំពុងបម្រើសេវាកម្មជូនអ្នកប្រើប្រាស់/ដៃគូចុះឈ្មោះជាង៣,៣៤លាននាក់។ អតិថិជនអាចប្រើប្រាស់ អេស៊ីលីដាម៉ូបាល បាននៅគ្រប់កាលៈទេសៈទូទាំងពិភពលោក ឱ្យតែមានសេវាវ៉ាយហ្វាយ/អ៊ីនធឺណិត ជាពិសេសសម្រាប់ស្កេន KHQR/QR នៅទូទាំងប្រទេសកម្ពុជា និងធ្វើការទូទាត់ឆ្លងដែនជាមួយនឹង QR Code នៅក្នុងប្រទេសថៃ វៀតណាម និងឡាវ ផងដែរ។ ទំហំប្រតិបត្តិការឌីជីថលរហូតដល់ពេលនេះបានកើនឡើងរហូតដល់៩៧% នៃប្រតិបត្តិការសរុបរបស់ធនាគារ ដោយមានការផ្ទេរប្រាក់តាមប្រព័ន្ធឌីថលសរុប៩៨%។

## ចំណុចសំខាន់ៗនៃប្រតិបត្តិការក្នុងឆ្នាំ២០២៣

- សមតុល្យឥណទានសរុបនៅដំណាច់ឆ្នាំ២០២៣ មានចំនួន៦.៦៥៧,៣១លានដុល្លារអាមេរិក ក្នុងនោះមានឥណទានចំនួន១.៤១៤,៦៨លានដុល្លារអាមេរិក ស្មើនឹង ២១,២៥% បានផ្តល់ទៅឱ្យវិស័យកសិកម្ម។ ក្នុងឆ្នាំ២០២២ ការផ្តល់ឥណទានក្នុងវិស័យកសិកម្មមានចំនួន១.៣៩២,១១លានដុល្លារអាមេរិក។ គិតត្រឹមដំណាច់ខែធ្នូឆ្នាំ២០២៣ ចំនួនអតិថិជនឥណទានអាជីវកម្មខ្នាតតូចរបស់សម្ព័ន្ធធនាគារបានកើនដល់៤៧៨.៦៥៦នាក់។
- ឥណទានមិនដំណើរការស្ថិតក្នុងអត្រា៥,៧៧% ដែលជាអត្រាអាចគ្រប់គ្រងបាននៅក្នុងបរិបទនៃសេដ្ឋកិច្ចក្រោយវិបត្តិជំងឺកូវីដ-១៩ និងលក្ខខណ្ឌប្រភពហិរញ្ញវត្ថុកាន់តែតឹងតែង។
- ប្រាក់បញ្ញើ-សន្សំមានចំនួន៧.២៧៧,៨១លានដុល្លារអាមេរិក ដែលមានគណនីចំនួន៤,៥៥លានគណនី។
- សម្ព័ន្ធធនាគារទទួលបានប្រាក់ចំណេញដែលផ្តល់ជូនភាគហ៊ុនិករបស់ធនាគារចំនួន១៤៨,០៥លានដុល្លារអាមេរិក។
- ធនាគារនៅតែបន្តខិតខំកាត់បន្ថយចំណាយ និងហានិភ័យជាប្រចាំ ដើម្បីទទួលបានប្រាក់ចំណេញខ្ពស់បំផុត។
- ផលិតផលបច្ចេកវិទ្យាហិរញ្ញវត្ថុ (Fintech) ត្រូវបានដាក់បញ្ចូលទៅក្នុងហេដ្ឋារចនាសម្ព័ន្ធធនាគារអេឡិចត្រូនិករបស់ធនាគារ ដើម្បីផ្តល់ជម្រើសជាច្រើនជូនអតិថិជនក្នុងការគ្រប់គ្រងធនធានហិរញ្ញវត្ថុរបស់ពួកគេ។

## សេវាកម្មហិរញ្ញវត្ថុ និងឥណទានសហគ្រាសខ្នាតតូច

ឥណទានខ្នាតតូចបានកើនឡើង៤,៩៥% ឬស្មើនឹង១៤២,០៣លានដុល្លារអាមេរិក។ ឥណទានសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន និងផ្សេងៗ បានកើនឡើង៨៤,១១% ឬស្មើនឹង២២០,៩០លានដុល្លារអាមេរិក។ ឥណទានគេហដ្ឋានមានចំនួន១៨៥,៤១លានដុល្លារអាមេរិក។ សមតុល្យឥណទានសរុបមានចំនួន៦.៦៥៧,៣១លានដុល្លារអាមេរិក នៅដំណាច់ឆ្នាំ២០២៣។

សម្ព័ន្ធធនាគារមានសមតុល្យប្រាក់បញ្ញើ-សន្សំសរុបចំនួន៧.២៧៧,៨១លានដុល្លារអាមេរិក (កើនឡើង១៣,១៣% ឬស្មើនឹង៨៣៨,៨២លានដុល្លារអាមេរិក) និងមានគណនីសរុបប្រមាណ៤.៥៥០.៥៨២គណនី។ វិស័យលក់រាយគឺជាផ្នែកដែលធំជាងគេបំផុតនៃកំណើនប្រាក់បញ្ញើសរុប ដែលភាគច្រើនបានមកពីអតិថិជនដាក់ប្រាក់បញ្ញើដំបូង ដូចជាកម្មករនិយោជិត តាមរយៈសេវាបើកប្រាក់បៀវត្ស និងអតិថិជននៅតាមជនបទ ដែលពួកគាត់បានប្រើប្រាស់គណនីវ៉លឡេត របស់អេស៊ីលីដាម៉ូបាល។ ផលិតផល និងសេវាកម្មហិរញ្ញវត្ថុ តាមរយៈបច្ចេកវិទ្យាហិរញ្ញវត្ថុ បានចូលរួមចំណែកធ្វើឱ្យមានកំណើនយ៉ាងខ្លាំងក្លានេះ។

សម្ព័ន្ធធនាគារ បាន និងកំពុងបន្តអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឱ្យកាន់តែទូលំទូលាយ សម្រាប់ផ្តល់ជម្រើសដ៏សម្បូរបែប ដែលមានសាខា៣១៨ទីតាំង (ឬការិយាល័យ) សេវាកម្មធនាគារស្វ័យប្រវត្តិចំនួន១៧៧ទីតាំង ម៉ាស៊ីនអេធីអឹមចំនួន១.៤៥៣គ្រឿង និងម៉ាស៊ីនឆូតកាតចំនួន៤,៧២៨គ្រឿង។ ចំណុចគួរជាទីមោទនភាព គឺសម្ព័ន្ធធនាគារបានបោះពុម្ពប័ណ្ណឥណពន្ធចំនួន១,៩១លានប័ណ្ណជូនដល់អតិថិជន។ បន្ថែមលើនេះ អេស៊ីលីដាម៉ូបាល (ACLEDA mobile App.) ទទួលបានប្រជាប្រិយភាពយ៉ាងខ្លាំង ដោយមានអ្នកចុះឈ្មោះប្រើប្រាស់ច្រើនជាង៣,៤៥លាននាក់ នៅដំណាច់ឆ្នាំ២០២៣នេះ។

## ឥណទានខ្នាតមធ្យម និងសាជីវកម្ម

ក្នុងឆ្នាំ២០២៣ សេវាចាត់ចែងសាច់ប្រាក់បានកើនឡើងយ៉ាងខ្លាំង តាមរយៈដៃគូជាមួយនឹងវិស័យសាធារណៈ រួមមាន បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស.) សេវាបើកប្រាក់បៀវត្សសម្រាប់មន្ត្រីរាជការ សេវាប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ។ល។ តម្រូវការប្រើប្រាស់សេវាបើកប្រាក់បៀវត្សបានកើនឡើងនៅក្នុងឆ្នាំ២០២៣ ដោយមានស្ថាប័នជាតិ ព្រមទាំងសាជីវកម្ម នៅក្នុង និងក្រៅប្រទេស រួមទាំងស្ថាប័ននានា បានចូលរួមប្រើប្រាស់ ដែលជាឱកាសដ៏ល្អ សម្រាប់ការលក់ផលិតផល និងសេវាកម្មផ្សេងៗទៀត។

បន្ថែមលើនេះ ការផ្តល់ជូនសេវាកម្មដ៏ល្អ តាមរយៈបណ្តាញប្រតិបត្តិការទូទាំងប្រទេសរបស់ធនាគារ បានទាក់ទាញ និងជំរុញក្រុមហ៊ុនអាជីវកម្មខ្នាតមធ្យម និងសាជីវកម្មយ៉ាងខ្លាំង ឱ្យទទួលស្គាល់គុណភាពខ្ពស់ មានភក្តីភាព និងជ្រើសរើសធនាគារ ជាអ្នកសម្របសម្រួលដ៏មានប្រសិទ្ធភាព ជាអាទិភាពទីមួយ សម្រាប់ការចាត់ចែង និងប្រភពហិរញ្ញវត្ថុ សម្រាប់គាំទ្រការទូទាត់ និងប្រតិបត្តិអាជីវកម្មរបស់ពួកគេ។ សេវាកម្មចម្រុះសម្បូរបែបទាំងនេះ ផ្តល់អត្ថប្រយោជន៍ និងមានឥទ្ធិពលជាវិជ្ជមានដ៏យ៉ាងធំធេងលើលំហូរសាច់ប្រាក់ជារូបិយវត្ថុជាតិរបស់ធនាគារ និងបានធ្វើឱ្យធនាគារមានលទ្ធភាពប្រមូលប្រភពធនធានហិរញ្ញវត្ថុជារូបិយវត្ថុរៀល ដើម្បីពង្រឹង និងពង្រីកការផ្តល់ឥណទានជាប្រាក់រៀលបានកាន់តែច្រើនផងដែរ។ ទន្ទឹមនឹងនេះ ឥណទានអាជីវកម្មខ្នាតមធ្យម និងសាជីវកម្ម បានថយចុះ៩,៧៥% បើធៀបនឹងឆ្នាំ២០២២ ដែលមានចំនួនស្មើនឹង៣៥,៥០% នៃសមតុល្យឥណទានសរុប។

លើសពីនេះទៅទៀត ធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួន នៅតែបន្តកិច្ចសហប្រតិបត្តិការជាមួយនឹងដៃគូយុទ្ធសាស្ត្ររយៈពេលវែង ដែលមានបទពិសោធន៍ដ៏សម្បូរបែប ដែលមានសក្តានុពលភាពច្រើន ក្នុងការជួយអតិថិជនឱ្យអាចគ្រប់គ្រងធនធានហិរញ្ញវត្ថុរបស់ខ្លួន ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។ ជាមួយគ្នានេះ ភាពជាដៃគូទាំងនេះ បានរួមចំណែកយ៉ាងសំខាន់ ក្នុងការផ្តល់ប្រភពមូលនិធិរយៈពេលវែងដល់ធនាគារ និងជាប្រភពនៃប្រាក់ចំណូលក្រៅតារាងតុល្យការ ហើយទន្ទឹមគ្នានោះ ក៏បានលើកកម្ពស់ជំនាញ និងបទពិសោធន៍អន្តរជាតិ សម្រាប់ថ្នាក់គ្រប់គ្រង និងបុគ្គលិករបស់ធនាគារ។

## រតនាភិបាល ក្នុងប្រទេស និងអន្តរជាតិ

ធនាគារក៏ជាស្ថាប័នផ្តល់សេវាប្តូរប្រាក់ដ៏លេចធ្លោមួយជូនសាធារណជនគ្រប់វិស័យ ដែលចំណូលពីសេវាប្តូរប្រាក់នេះបានបន្តកើនឡើងបន្តបន្ទាប់ ដោយបានចូលរួមចំណែកដ៏សំខាន់ក្នុងការបង្កើនចំណូលមិនមែនការប្រាក់របស់ធនាគារ។ ដោយប្រកាន់ខ្ជាប់នូវគោលការណ៍គ្រប់គ្រងហានិភ័យ ធនាគារមិនភ្ជាប់អាជីវកម្មរបស់ខ្លួនក្នុងការជួញដូរសេវាប្តូរប្រាក់ ដើម្បីរំពឹងទុកផលចំណេញនាពេលអនាគតនោះទេ ដោយផ្តោតតែលើការគាំទ្រដល់អាជីវកម្មរបស់អតិថិជនតែប៉ុណ្ណោះ។ ធនាគាររក្សានូវវិធីសាស្ត្រដែលមានហានិភ័យទាប ដោយគ្រប់គ្រងការចាត់ចែងស្ថានភាពរូបិយប័ណ្ណចំហសុទ្ធរបស់ខ្លួននៅកម្រិតអនុបាតប្រុងប្រយ័ត្នដាក់លាក់មួយអនុលោមតាមការកំណត់ផ្ទៃក្នុង និងបទប្បញ្ញត្តិពាក់ព័ន្ធ។ សេវាកម្មនេះជាប្រភពចំណូលដែលមានស្ថិរភាព ដោយមានកំណើនជាលំដាប់ ផ្តល់កម្រិតផលចំណេញសមរម្យ និងរក្សាបានទំនាក់ទំនងយូរអង្វែងជាមួយអតិថិជន និងដៃគូរបស់ធនាគារ។

តារាងតុល្យការរបស់ធនាគារត្រូវបានពង្រឹង និងគាំទ្រដោយលំហូរដ៏រឹងមាំនៃប្រាក់បញ្ញើរបស់អតិថិជន និងបំណុលរយៈពេលវែង ដែលជួយសម្រួលដល់កំណើនឥណទានក្នុងអំឡុងពេលពេញមួយឆ្នាំ។ ហើយក៏បានចូលរួមចំណែកបង្ហាញប្រភពនៃរចនាសម្ព័ន្ធហិរញ្ញវត្ថុដ៏រឹងមាំ ដើម្បីគាំទ្រដល់សន្ទុះនៃការរីកចម្រើនអាជីវកម្ម និងប្រតិបត្តិការរបស់ធនាគារ។

ធនាគារបានចូលរួមចំណែកផ្សព្វផ្សាយយ៉ាងសកម្មក្នុងការលើកស្ទួយការប្រើប្រាស់ប្រាក់រៀល តាមរយៈការពង្រីកផ្តល់ឥណទានជារូបិយវត្ថុដល់អតិថិជន និងបានចូលរួមចំណែកលើកស្ទួយទីផ្សារហិរញ្ញវត្ថុរបស់កម្ពុជាតាមរយៈការវិនិយោគលើមូលបត្ររដ្ឋ ដែលមានផលបត្រសរុបច្រើនជាង១៧% នៃទំហំឥណទានសរុប ដែលលើសពីបញ្ញត្តិតម្រូវត្រឹមតែ១០%ប៉ុណ្ណោះ។ បន្ថែមពីនេះទៀតដើម្បីបង្កើនការគាំទ្រប្រភពមូលនិធិរយៈពេលវែងរបស់ខ្លួន ធនាគារបានធ្វើពិពិធកម្មមូលនិធិដោយមានជម្រើសច្រើនតាមស្ថានភាព និងពង្រីកទំនាក់ទំនងល្អជាមួយនឹងដៃគូយុទ្ធសាស្ត្រទូទាំងសកលលោក ជាពិសេស នៅអឺរ៉ុប សហរដ្ឋអាមេរិក និងអាស៊ី។

ធនាគារនៅតែបន្តពង្រឹងទំនាក់ទំនងយ៉ាងខ្ជាប់ខ្ជួនជាមួយស្ថាប័នហិរញ្ញវត្ថុជាច្រើន និងបានបង្កើនធនាគារដៃគូក្រៅប្រទេសថ្មីៗ ជាច្រើនបន្ថែមទៀត ដើម្បីពង្រីកបណ្តាញប្រតិបត្តិការរបស់ខ្លួន។ គិតត្រឹមដំណាច់ឆ្នាំ២០២៣ ធនាគារមានធនាគារដៃគូចំនួន២៥៤ នៅក្នុងចំណោម៤៤ប្រទេស។ លើសពីនេះទៀត ធនាគារមានចំណែកទីផ្សារលើសលុបក្នុងការគ្រប់គ្រងគណនីរបស់ធនាគារ និងស្ថាប័នហិរញ្ញវត្ថុក្នុងស្រុក ព្រមទាំងផ្តល់សេវាផ្ទេរប្រាក់ដល់ស្ថាប័នទាំងនោះនៅទូទាំងប្រទេស។ ធនាគារបានរៀបចំ និងអនុវត្តបានទាំងស្រុងតាមគោលការណ៍គ្រប់គ្រងហានិភ័យផ្ទៃក្នុង តម្រូវការបទប្បញ្ញត្តិ និងកិច្ចព្រមព្រៀងជាមួយនឹងម្ចាស់បំណុលនានា។

## យុទ្ធសាស្ត្រអាទិភាពសម្រាប់ឆ្នាំ២០២៤

**ប្រជាធនាគារ ដែលលោកអ្នកជឿទុកចិត្ត!**

ដើម្បីកំណត់គោលដៅរយៈពេលវែងជាមូលដ្ឋាន និងរៀបចំផែនការសកម្មភាព ព្រមទាំងបែងចែកធនធានដែលចាំបាច់ សម្រាប់ការអនុវត្តឱ្យសម្រេចគោលដៅទាំងនេះ និងសម្រាំងជ្រើសរើសសំណុំសកម្មភាពពាក់ព័ន្ធនានា ដើម្បីសម្រេចឱ្យបាននូវការបង្កើតតម្លៃចម្រុះដ៏វិសេសនានា ធនាគារ អេស៊ីលីដា ភីអិលស៊ី បានរៀបចំ និងដាក់ចេញនូវយុទ្ធសាស្ត្រដ៏សមស្របបំផុត ដែលពណ៌នាបង្ហាញអំពីរបៀប ដែលធនាគារត្រូវអនុវត្ត សំដៅសម្រេចឱ្យបាននូវចក្ខុវិស័យ បេសកកម្ម ចំណុចដៅ គោលដៅ និងផែនការជំនួញរបស់ខ្លួន។ យុទ្ធសាស្ត្រទាំងនេះរួមមាន អាទិភាពសេវាធនាគារតាមទូរស័ព្ទ ឌីជីថលូបនីយកម្មធនធានមនុស្ស ការផ្តល់មូលនិធិ ការកសាងកេរ្តិ៍ឈ្មោះ/រូបភាព/អត្តសញ្ញាណ/យីហោសហគមន៍អេស៊ីលីដា បច្ចេកវិទ្យាព័ត៌មានល្អប្រសើរឈានមុខ ភាពជាដៃគូបរិយាបន្ន បរិស្ថាន សង្គម និងអភិបាលកិច្ច និងក្រុមហ៊ុនបុត្រសម្ព័ន្ធ។

ធនាគារមានគោលបំណងលើកស្ទួយជីវភាពរស់នៅឱ្យប្រសើរឡើង និងបង្កើនអត្ថប្រយោជន៍ជូនដល់គ្រប់ភាគីពាក់ព័ន្ធ ព្រមទាំងគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិទាំងមូលប្រកបដោយនិរន្តរភាព។

## បញ្ហាចម្បងក្នុងឆ្នាំ២០២៤

ធនាគារ អេស៊ីលីដា ដែលជាធនាគារពាណិជ្ជដំបូងគេ បានចុះបញ្ជីក្នុងផ្សារមូលបត្រកម្ពុជា (ផមក) ដោយអនុវត្តអនុលោមតាមបទប្បញ្ញត្តិនានា ជាពិសេសរបស់និយ័តករចម្បងចំនួន២៖ ធនាគារជាតិ នៃ កម្ពុជា និងនិយ័តករមូលបត្រកម្ពុជា (ន.ម.ក.)។ ទន្ទឹមនឹងនេះ ធនាគារក៏មានទំនួលខុសត្រូវចំពោះអតិថិជន និងវិនិយោគិនផងដែរ។ នៅក្នុងអំឡុងពេលជាងបីទសវត្សរ៍នៃប្រវត្តិរីកចម្រើនរបស់ខ្លួន ធនាគារទទួលបានជំនឿទុកចិត្តពីសាធារណជន តាមរយៈអភិបាលកិច្ចសាជីវកម្មល្អ គណៈគ្រប់គ្រងដែលមានបទពិសោធន៍ច្រើន និងយូរឆ្នាំ ព្រមទាំងប្រកាន់ខ្ជាប់វប្បធម៌តម្លាភាព។

ក្នុងបរិបទដែលមានការវិវត្តឥតឈប់ឈរ នៃបច្ចេកវិទ្យាហិរញ្ញវត្ថុ ជាពិសេសក្នុងយុគសម័យធនាគារឌីជីថល (ធនាគារ ៤,០) អេស៊ីលីដាម៉ូបាល បានបំពាក់បច្ចេកវិទ្យាជំនាន់ចុងក្រោយបំផុត និងនៅរក្សាបន្តអភិវឌ្ឍបន្ថែមជាប្រចាំ ដើម្បីរក្សាបានភាពឈានមុខ ភាពងាយស្រួល សុវត្ថិភាពខ្ពស់ និងភាពទាន់សម័យគួរឱ្យទាក់ទាញ។

ទោះបីជាសេដ្ឋកិច្ចកម្ពុជានៅបន្តជួបនឹងបញ្ហាប្រឈមមួយចំនួន ដូចជា ហានិភ័យភាពនៃភូមិសាស្ត្រនយោបាយកាន់តែតានតឹង ភាពចាំបាច់ក្នុងការពន្លឿនការកាត់បន្ថយឧស្ម័នកាបូនក្នុងសេដ្ឋកិច្ច ការកើនឡើងនៃហានិភ័យទាក់ទងនឹងអាកាសធាតុ បរិវត្តកម្មឌីជីថលយ៉ាងលឿនរហ័ស ក៏ដូចជាកំណើននៅមានកម្រិតទាប និងយឺតយ៉ាវ នៃវិស័យអចលនទ្រព្យ សំណង់ និងកាត់ដេរសម្លៀកបំពាក់ក៏ដោយ ក៏ទស្សនវិស័យសេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ២០២៤ ត្រូវបានប្រមើល និងរំពឹងទុកថានឹងនៅតែមានសុទិដ្ឋិនិយម និងភាពរឹងមាំបើធៀបនឹងឆ្នាំមុន។ ឈរលើមូលដ្ឋានដ៏រឹងមាំនៃសន្តិភាព និងស្ថិរភាពនយោបាយ សេដ្ឋកិច្ចកម្ពុជា ត្រូវបានព្យាករថានឹងកើនឡើងពី៥,៥% ក្នុងឆ្នាំ២០២៣ រហូតដល់ជាង៦% ក្នុងឆ្នាំ២០២៤ ដែលបណ្តាលមកពីការកើនឡើងបន្ថែមទៀត ក្នុងវិស័យទេសចរណ៍ និងសេវាកម្ម រួមទាំងវិស័យកសិកម្មដែលមានភាពធន់ និងការគ្រប់គ្រងអតិផរណាបានល្អ។

ផ្អែកលើការព្យាករ និងសេណារីយ៉ូនៃសេដ្ឋកិច្ចកម្ពុជាសម្រាប់ឆ្នាំ២០២៤នេះ ធនាគារ អេស៊ីលីដា ភីអិលស៊ី មើលឃើញឱកាស ដើម្បីបន្ត និងពង្រឹងថែមទៀតនូវយុទ្ធសាស្ត្រជោគជ័យ ដែលមានស្រាប់របស់ខ្លួន ទន្ទឹមនឹងការបន្តដាក់ចេញទិសដៅយុទ្ធសាស្ត្រថ្មីៗ សម្រាប់ឆ្នាំ២០២៤ និងឆ្នាំបន្តបន្ទាប់ ដើម្បីធានាបាននូវកំណើន ជោគជ័យ និងវិបុលភាពរបស់ធនាគារ រួមគ្នាជាមួយនឹងអតិថិជន និងគ្រប់ភាគីពាក់ព័ន្ធរបស់យើង។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះអតិថិជន ក្រុមប្រឹក្សាភិបាល ថ្នាក់គ្រប់គ្រង និងបុគ្គលិក ជាពិសេសរាជរដ្ឋាភិបាលកម្ពុជា ធនាគារជាតិ នៃ កម្ពុជា និងនិយ័តករមូលបត្រកម្ពុជា សម្រាប់ការជឿទុកចិត្តជាប់ជានិច្ច ការជឿជាក់ ការគាំទ្រ និងការចូលរួមចំណែកដ៏មានសារៈសំខាន់ ព្រមទាំងការខិតខំប្រឹងប្រែង ឆន្ទៈ និងការប្តេជ្ញាចិត្តខ្ពស់ សាមគ្គីភាព និងសហថាមពល ក្នុងឆ្នាំ២០២៣ រួមជាមួយនឹងការជឿជាក់យ៉ាងមុតមាំ និងការរំពឹងថា ឆ្នាំ២០២៤ នឹងនាំមកនូវសិរីសួស្តី និងវិបុលភាព។

**បណ្ឌិត អ៊ិន ចាន់នី**

*ប្រធាននាយកប្រតិបត្តិ*

*ធនាគារ អេស៊ីលីដា ភីអិលស៊ី*

**ថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៤**

# អក្សរកាត់សម្រាប់ប្រើប្រាស់នៅក្នុងរបាយការណ៍ប្រចាំឆ្នាំ

| អក្សរកាត់ | ពាក្យពេញ |
|---|---|
| ធនាគារ អេស៊ីលីដា/ ធនាគារ | ធនាគារ អេស៊ីលីដា ភីអិលស៊ី |
| សម្ព័ន្ធធនាគារ | ធនាគារ អេស៊ីលីដា ភីអិលស៊ី និងក្រុមហ៊ុនបុត្រសម្ព័ន្ធ |
| ន.ម.ក. | និយ័តករមូលបត្រកម្ពុជា (ពីមុនជា គណៈកម្មការមូលបត្រកម្ពុជា “គ.ម.ក.”) |
| ផមក | ផ្សារមូលបត្រកម្ពុជា |
| វ.ធ.ហ | វិទ្យាស្ថាន ធនាគារ និងហិរញ្ញវត្ថុ |
| ABL | ធនាគារ អេស៊ីលីដា ឡាវ លីមីតធីត |
| ACS | អេស៊ីលីដា ស៊ីឃ្យូរិធី ភីអិលស៊ី |
| AFT | អេស៊ីលីដា ហ្វាយណាន់ហ្សល់ ត្រាស់ |
| AGM | កិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកសាមញ្ញ |
| AIB | វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា (ពីមុនជា អេស៊ីលីដា ត្រេននីង សេនធ័រ) |
| AMM | ស្ថាប័នមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា មីយ៉ាន់ម៉ា |
| ASA Plc. | ក្រុមហ៊ុន អេ អេស អេ ភីអិលស៊ី |
| EDF | Entrepreneurship Development Fund |
| EGM | កិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកវិសាមញ្ញ |
| FIPED | ស្ថាប័នហិរញ្ញវត្ថុសម្រាប់អភិវឌ្ឍន៍សហគ្រាសឯកជន |
| GAICD | វិទ្យាស្ថានអូស្ត្រាលីសម្រាប់អភិបាលក្រុមហ៊ុន |
| IMF | មូលនិធិរូបិយវត្ថុអន្តរជាតិ |
| SMBC | Sumitomo Mitsui Banking Corporation (ពីមុនជា Sumitomo Bank) |

# មាតិកា


ទំព័រ

១ ទស្សនៈ បេសកកម្ម គតិពេចន៍

២ ព័ត៌មានហិរញ្ញវត្ថុសង្ខេប

៣ ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប និង ស្ថិតិសង្ខេបប្រចាំឆ្នាំពីលទ្ធផលប្រតិបត្តិការ (Charts)

៥ សមាសភាពក្រុមប្រឹក្សាភិបាល

៩ សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល

១១ សេចក្តីថ្លែងរបស់ប្រធាននាយកប្រតិបត្តិ

**១៧ ផ្នែកទី១ ព័ត៌មានទូទៅពាក់ព័ន្ធនឹងធនាគារ អេស៊ីលីដា**

១៨ ក. អត្តសញ្ញាណធនាគារ អេស៊ីលីដា

១៨ ខ. លក្ខណៈធុរកិច្ច

១៩ គ. សម្ព័ន្ធភាពធនាគារ អេស៊ីលីដា

២០ ឃ. ព្រឹត្តិការណ៍សំខាន់ៗរបស់ធនាគារ អេស៊ីលីដា

២៣ ង. ស្ថានភាពទីផ្សារ

២៣ ច. ស្ថានភាពប្រកួតប្រជែង

២៣ ឆ. ផែនការអនាគត

២៤ ជ. កត្តាហានិភ័យ

**២៥ ផ្នែកទី២ ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច**

២៦ ក. លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក

២៨ ខ. រចនាសម្ព័ន្ធចំណូល

**២៩ ផ្នែកទី៣ ព័ត៌មានអំពីអភិបាលកិច្ចសាជីវកម្ម**

៣០ ក. អង្គការលេខ

៣១ ខ. ក្រុមប្រឹក្សាភិបាល

៣១ គ. គណៈកម្មាធិការប្រតិបត្តិ

**៣២ ផ្នែកទី៤ ព័ត៌មានអំពីការជួញដូរមូលបត្រ និងភាគហ៊ុនរបស់ធនាគារ អេស៊ីលីដា**

៣៣ ក. ព័ត៌មានអំពីមូលបត្រ

៣៣ ខ. ថ្លៃ និងបរិមាណជួញដូរមូលបត្រ

៣៤ គ. ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ (ចាប់ពី ៣០% ឡើងទៅ)

៣៤ ឃ. ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើន (ចាប់ពី ៥% ដល់តិចជាង ៣០%)

៣៤ ង. ព័ត៌មានអំពីការបែងចែកភាគលាភក្នុងរយៈពេល ៣ឆ្នាំចុងក្រោយ

**៣៥ ផ្នែកទី៥ របាយការណ៍សវនកម្មរបស់សវនករផ្ទៃក្នុងលើការត្រួតពិនិត្យផ្ទៃក្នុង**

**៣៨ ផ្នែកទី៦ របាយការណ៍ហិរញ្ញវត្ថុដែលធ្វើសវនកម្មដោយសវនករឯករាជ្យ**

**៣៩ ផ្នែកទី៧ ព័ត៌មានអំពីប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធនឹងទំនាស់ផលប្រយោជន៍**

៤០ ក. ប្រតិបត្តិការសំខាន់ៗជាមួយភាគហ៊ុនិកដែលមានភាគហ៊ុនចាប់ពី៥ (ប្រាំ) ភាគរយឡើងទៅ នៃមូលបត្រកម្មសិទ្ធិកំពុងធ្វើចរាចរលើទីផ្សារ

៤១ ខ. ប្រតិបត្តិការសំខាន់ៗជាមួយអភិបាល និងបុគ្គលិកជាន់ខ្ពស់

៤១ គ. ប្រតិបត្តិការជាមួយអភិបាល និងភាគហ៊ុនិកពាក់ព័ន្ធនឹងការទិញ-លក់ទ្រព្យសកម្ម និងសេវាកម្ម

៤១ ឃ. ប្រតិបត្តិការសំខាន់ៗជាមួយសមាជិកគ្រួសារផ្ទាល់របស់អភិបាល បុគ្គលិកជាន់ខ្ពស់ និងភាគហ៊ុនិកដែលមានភាគហ៊ុនចាប់ពី ៥ (ប្រាំ) ភាគរយឡើងទៅ

៤២ ង. ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលិកដែលមានទំនាក់ទំនងជាមួយអភិបាលរបស់បុគ្គលចុះបញ្ជីលក់មូលបត្រក្រុមហ៊ុនសម្ព័ន្ធឬក្រុមហ៊ុនហូលឌីងរបស់បុគ្គលចុះបញ្ជីលក់មូលបត្រដែលទំនាក់ទំនងរបស់បុគ្គលទាំងនោះកើតមាននៅក្នុងប្រតិបត្តិការ ឬការចាត់ចែងណាមួយដែលបានធ្វើឡើងដោយបុគ្គលចុះបញ្ជីលក់មូលបត្រ

៤៣ ច. ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលធ្លាប់ជាអភិបាល ឬបុគ្គលជាប់ពាក់ព័ន្ធជាមួយបុគ្គលធ្លាប់ជាអភិបាល

៤៣ ឆ. ប្រតិបត្តិការសំខាន់ៗជាមួយអភិបាលដែលបានកាន់មុខដំណែងណាមួយនៅក្នុងសមាគម ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ឬនៅក្នុងក្រុមហ៊ុនណាមួយផ្សេងទៀតក្រៅពីបុគ្គលចុះបញ្ជីលក់មូលបត្រ

៤៣ ជ. ប្រតិបត្តិការសំខាន់ៗជាមួយអភិបាលដែលទទួលបានផលប្រយោជន៍ពីបុគ្គលចុះបញ្ជីលក់មូលបត្រទោះជាហិរញ្ញវត្ថុ ឬមិនមែនហិរញ្ញវត្ថុ

**៤៤ ផ្នែកទី៨ ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង**

៤៥ ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

៤៨ ខ. កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ

៤៩ គ. ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល

៤៩ ឃ. ផលប៉ះពាល់នៃការប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ

៤៩ ង. ផលប៉ះពាល់នៃអតិផរណា

៤៩ ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល

**៥២ ហត្ថលេខាអភិបាល**

**៥៣ ឧបសម្ព័ន្ធ៖ របាយការណ៍ស្តីពីអភិបាលកិច្ចសាជីវកម្មតាមទម្រង់កំណត់ដោយអគ្គនាយកនៃ ន.ម.ក.**

**៩២ ឧបសម្ព័ន្ធ៖ របាយការណ៍ចីរភាព ឆ្នាំ២០២៣**

# ផ្នែកទី ១

## ព័ត៌មានទូទៅពាក់ព័ន្ធនឹង ធនាគារ អេស៊ីលីដា

# ក. អត្តសញ្ញាណធនាគារ អេស៊ីលីដា

| | |
|---|---|
| ឈ្មោះក្រុមហ៊ុនជាអក្សរខ្មែរ | **ធនាគារ អេស៊ីលីដា ភីអិលស៊ី** |
| ឈ្មោះក្រុមហ៊ុនជាអក្សរឡាតាំង | ACLEDA BANK PLC. |
| លេខកូដស្តង់ដារ | KH១០០០១០០០០៣ |
| ទីស្នាក់ការ | អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា |
| លេខទូរស័ព្ទ | +៨៥៥ (០)២៣ ៩៩៨ ៧៧៧ / ៤៣០ ៩៩៩ |
| លេខទូរសារ | +៨៥៥ (០)២៣ ៤៣០ ៥៥៥ |
| គេហទំព័រ | www.acledabank.com.kh |
| អ៊ីម៉ែល | acledabank@acledabank.com.kh |
| លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម | ០០០០៣០៧៧ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០០០ ចេញដោយក្រសួងពាណិជ្ជកម្ម |
| លេខអាជ្ញាប័ណ្ណអាជីវកម្ម | ធ.ព.០៦ ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២៣ ចេញដោយ ធនាគារជាតិ នៃ កម្ពុជា |
| សេចក្តីសម្រេចអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានលេខ | លេខ០៥៣/២០គ.ម.ក./ស.ស.រ. ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២០ ចេញដោយគណៈកម្មការមូលបត្រកម្ពុជា (បច្ចុប្បន្នជា និយ័តករមូលបត្រកម្ពុជា "ន.ម.ក.") |
| ឈ្មោះបុគ្គលតំណាងបុគ្គលចុះបញ្ជីលក់មូលបត្រ | **បណ្ឌិត អ៊ិន ចាន់នី** |

# ខ. លក្ខណៈធុរកិច្ច

ធនាគារ អេស៊ីលីដា ភីអិលស៊ី គឺជាធនាគារពាណិជ្ជដែលមានសាខា និងបណ្តាញការិយាល័យធំជាងគេបង្អស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ធនាគារបានចុះបញ្ជីនៅក្នុងផមក ចាប់តាំងពីថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០។ បច្ចុប្បន្ននេះធនាគារមានក្រុមហ៊ុនបុត្រសម្ព័ន្ធចំនួន៤ រួមមាន៖ **ធនាគារ អេស៊ីលីដា ឡាវ លីមីតធីត ក្រុមហ៊ុន អេស៊ីលីដា ស៊ីឃ្យួរីធី ភីអិលស៊ី វិទ្យាស្ថានពាណិជ្ជសាស្ត្រ អេស៊ីលីដា** និង**ស្ថាប័នមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា មីយ៉ាន់ម៉ា** ព្រមទាំងមានការិយាល័យតំណាងចំនួន១ នៅប្រទេសមីយ៉ាន់ម៉ាផងដែរ។

# គ. សម្ព័ន្ធភាពធនាគារ អេស៊ីលីដា

| លរ | ឈ្មោះក្រុមហ៊ុន | ប្រភេទនៃទំនាក់ទំនង | ភាគរយនៃការកាន់កាប់ភាគហ៊ុន | អាជីវកម្មចម្បង | កាលបរិច្ឆេទចុះបញ្ជីពាណិជ្ជកម្ម | ទីតាំងអាជីវកម្ម |
|---|---|---|---|---|---|---|
| ១ | ABL | ក្រុមហ៊ុនបុត្រសម្ព័ន្ធ | ធនាគារ អេស៊ីលីដា កាន់កាប់ភាគហ៊ុន ៩៩,៩០% និង AIB កាន់កាប់ភាគហ៊ុន ០,១០% | ធ្វើប្រតិបត្តិការជាធនាគារពាណិជ្ជទូទាំងប្រទេសឡាវដោយផ្តល់សេវាកម្មធនាគារ និងហិរញ្ញវត្ថុ | ១៩ មិថុនា ២០០៨ | #398, Corner of Dongpalane and Dongpaina Road, Unit 20, PhonesavanhNeua Village, Sisattanak District, Vientiane Capital Lao PDR. |
| ២ | ACS | ក្រុមហ៊ុនបុត្រសម្ព័ន្ធ | ធនាគារ អេស៊ីលីដា កាន់កាប់ភាគហ៊ុន ១០០% | ធ្វើប្រតិបត្តិការផ្តល់សេវាលើអាជីវកម្មឈ្មួញជើងសាមូលបត្រ និងអាជីវកម្មបន្ទាប់បន្សំដទៃផ្សេងទៀត | ០១ មីនា ២០១០ | ជាន់ទី៥ អគារអេស៊ីលីដា លេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា |
| ៣ | AIB | ក្រុមហ៊ុនបុត្រសម្ព័ន្ធ | ធនាគារ អេស៊ីលីដា កាន់កាប់ភាគហ៊ុន ៧៦,១០៩០% និង អេស៊ីលីដា ហ្វាយណាន់ហ្សល់ត្រាស់ កាន់កាប់ ភាគហ៊ុន ២៣,៣៩១០% | ធ្វើប្រតិបត្តិការផ្តល់សេវាកម្មអប់រំបណ្តុះបណ្តាល កម្រិតបរិញ្ញាបត្ររង កម្រិតបរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ | ០៨ មិថុនា ២០១១ | អគារលេខ ១៣៩៧ មហាវិថីមិត្តភាពភ្នំពេញ-ហាណូយ ភូមិអន្លង់ក្ងាន សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា |
| ៤ | AMM | ក្រុមហ៊ុនបុត្រសម្ព័ន្ធ | ធនាគារ អេស៊ីលីដា កាន់កាប់ភាគហ៊ុន ១០០% | ធ្វើប្រតិបត្តិការជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ផ្តល់ប្រាក់កម្ចី និងសេវាកម្មមីក្រូហិរញ្ញវត្ថុ | ០៦ កញ្ញា ២០១២ | Building No.186(B) Shwe Gone Taing Road, Yae Tar Shae Block, Bahan Township, Yangon Region, Myanmar. |
| ៥ | ការិយាល័យតំណាង ធនាគារ អេស៊ីលីដា | ការិយាល័យតំណាង | ធនាគារ អេស៊ីលីដា កាន់កាប់ភាគហ៊ុន ១០០% | ផ្សព្វផ្សាយផលិតផល និងសេវាកម្ម ធនាគារ អេស៊ីលីដា | ០៦ ឧសភា ២០១៦ | Building No.186(B) Shwe Gone Taing Road, Yae Tar Shae Block, Bahan Township, Yangon Region, Myanmar. |

# ឃ. ព្រឹត្តិការណ៍សំខាន់ៗរបស់ធនាគារ អេស៊ីលីដា

ក្នុងកំលុងឆ្នាំ២០២៣ ធនាគារកំពុងពង្រីកសេវាស្វ័យប្រតិបត្តិការធនាគាររបស់ខ្លួន ដែលជាផ្នែកមួយនៃការយកចិត្តទុកដាក់លើឌីជីថលរូបនីយកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ តាមរយៈការពង្រីកនេះ ធនាគារបានកាត់បន្ថយតម្រូវការបន្ថែមបុគ្គលិកនៅបញ្ជរដែលនឹងជំរុញឱ្យបុគ្គលិកដែលមានស្រាប់របស់យើងអាចបង្កើនផលិតភាពការងារបានច្រើនជាងមុន។ ដើម្បីបំពេញតម្រូវការរបស់អតិថិជនឱ្យកាន់តែល្អប្រសើរជាងមុននោះ ធនាគារបានផ្លាស់ប្តូររូបរាងថ្មីនៃ ម៉ូបាលអ៊េប របស់ខ្លួន ដើម្បីលើកកម្ពស់សមត្ថភាព គួបផ្សំនឹងការអភិវឌ្ឍចុងក្រោយបំផុតនៅក្នុងបច្ចេកវិទ្យាហិរញ្ញវត្ថុជាសកល។ រូបរាងថ្មី នៃ អេស៊ីលីដាម៉ូបាល នេះបានផ្តល់ភាពងាយស្រួល រហ័សទាន់ចិត្ត និងសុវត្ថិភាពក្នុងការធ្វើប្រតិបត្តិការធនាគារ ហើយធនាគារក៏បានកាត់បន្ថយថ្លៃដើម និងជួយឱ្យអតិថិជនសន្សំសំចៃពេលវេលា ពីព្រោះពួកគាត់មិនត្រូវចំណាយពេលយូរក្នុងការធ្វើដំណើរទៅកាន់សាខាធនាគារផ្ទាល់ ដើម្បីធ្វើប្រតិបត្តិការជាច្រើនរបស់ពួកគាត់។ ប្រសិនយើងមាន អេស៊ីលីដាម៉ូបាល គឺប្រៀបដូចជាយើងមានធនាគារតូចមួយនៅក្នុងដៃរបស់យើងដែរ។ បន្ថែមលើនេះ ធនាគារបានអភិវឌ្ឍ កែលម្អ និងដាក់ឱ្យដំណើរការនូវមុខងារថ្មីៗ ជាច្រើននៅក្នុងកម្មវិធី អេស៊ីលីដាម៉ូបាល ដែលមានដូចខាងក្រោម៖

- ទទួលបានប្រាក់កម្ចីភ្លាមៗ
- បើកគណនីធនាគារ និងគណនីប្រាក់បញ្ញើមានកាលកំណត់
- បង្កើតប័ណ្ណនិម្មិត
- បង់ពន្ធលើអចលនទ្រព្យ និងយានយន្តគ្រប់ប្រភេទ
- ទាញយករបាយការណ៍គណនីសង្ខេប
- ទាញយកកាលវិភាគបង់ប្រាក់
- បង់ប្រាក់សំណងឥណទានរបស់ស្ថាប័នហិរញ្ញវត្ថុ
- ទទួលសារជូនដំណឹងពេលទទួលប្រាក់ពីអ្នកទិញ
- បង់បុព្វលាភធានារ៉ាប់រង
- ភ្ជាប់គណនីបាគង
- កំណត់ឈ្មោះគណនីធនាគារ
- បន្ថែមគោលបំណងលើប្រតិបត្តិការផ្ទេរប្រាក់រវាងគណនីផ្ទាល់ខ្លួន
- ផ្ញើសារជូនដំណឹងឱ្យរក្សាទុកសមតុល្យគណនីសម្រាប់ទូទាត់ប្រាក់សំណងឥណទាន
- ដាក់ចំណាត់ថ្នាក់លើកម្មវិធីអេស៊ីលីដាម៉ូបាល
- ទូទាត់វិក្កយបត្ររបស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់
- កំណត់លេខសម្ងាត់ និងផ្លាស់ប្តូរលេខសម្ងាត់ថ្មីដោយខ្លួនឯង
- ភ្ជាប់គណនីជួញដូរ និងផ្ទេរប្រាក់រវាងគណនីជួញដូរ
- ទទួលប្រាក់ តាមរយៈ Pay Me
- ស្កេនទូទាត់តាមយូអរកូដ (KHQR, QR Cross Border)
- ស្នើបោះពុម្ព KHQR
- បង្កើត KHQR របស់ខ្ញុំ
- ពិនិត្យមើលប្រតិបត្តិការទូទាត់តាម QR
- ស្នើទទួលប្រាក់
- ទូទាត់ប្រាក់តាម Tap to Pay
- រក្សាទុកប្រតិបត្តិការក្នុងកំណត់ត្រា
- ផ្ទេរ និងទទួលប្រាក់ក្រៅប្រទេស បានភ្លាមៗ តាម MoneyGram, Western Union, និង Thunes

សម្រាប់ព័ត៌មានលម្អិតបន្ថែមអំពីមុខងារនីមួយៗ ខាងលើនេះ សូមចូលទៅកាន់តំណភ្ជាប់៖ https://www.acledabank.com.kh/qr/toanchet

- នៅថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៣ ធនាគារ អេស៊ីលីដាបានទទួលវិញ្ញាបនបត្រ ដែលទទួលស្គាល់ជាធនាគារ ដែលមានសុវត្ថិភាពទិន្នន័យស្តង់ដារឧស្សាហកម្មប័ណ្ណទូទាត់ (PCI DSS) ជំនាន់ ៣.២.១ ពីស្ថាប័ន Control Case LLC ដែលជាភ្នាក់ងារវាយតម្លៃសុវត្ថិភាព ដ៏ល្បីល្បាញ និងទទួលស្គាល់ជាអន្តរជាតិ និងមានការិយាល័យស្ថិតនៅក្នុងសហរដ្ឋអាមេរិក។
- នៅថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៣ ធនាគារបានទទួលពានរង្វាន់ឈានមុខគេប្រចាំឆ្នាំ២០២១ និង២០២២ សរុបចំនួន៩ពានរង្វាន់ពីស្ថាប័នវីសា ដែលជាក្រុមហ៊ុននាំមុខគេក្នុងបច្ចេកវិទ្យាទូទាត់សាច់ប្រាក់តាមរយៈប្រព័ន្ធឌីជីថល។ នេះជាសក្ខីភាពសបញ្ជាក់ថាធនាគារ អេស៊ីលីដា ជាធនាគារដែលឆ្នើមឈានមុខគេក្នុងប្រទេសកម្ពុជា ដែលបានទទួលពានរង្វាន់ភាពជាអ្នកដឹកនាំឆ្នើមចំនួន៩ រួមមាន៖ (១) Leadership in Spend Per Active Card (For Visa Debit In Affluent Segment 2021), (២) Leadership in Domestic Merchant (Sales Volume 2021), (៣) Leadership in Ecommerce Merchant (Sales Volume 2021), (៤) Leadership in Transaction Per Active (Terminal 2021), (៥) Leadership in Active Caids 2021, (៦) Leadership in Credit Card Issurance 2021, (៧) Leadership in Domestic Merchant (Sales Volume 2022), (៨) Leadership in Ecommerce Merchant (Sales Volume 2022) និង (៩) Leadership in Active Caids 2022។
- នៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២៣ ធនាគារបានទទួលលិខិតកោតសរសើរ និងថ្លែងអំណរគុណ ពីមូលនិធិគន្ធបុប្ផាកម្ពុជា ចំពោះការចូលរួមបរិច្ចាគដ៏សំខាន់ និងជាបន្តបន្ទាប់ជូនមូលនិធិគន្ធបុប្ផាកម្ពុជា ក្នុងការរួមគ្នារក្សានិរន្តរភាពនៃកិច្ចដំណើរការរបស់មន្ទីរពេទ្យគន្ធបុប្ផា។

- នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២៣ គណៈប្រតិភូមកពីធនាគារកណ្តាលហ្វីជី និងធនាគារកណ្តាលកោះសូឡូម៉ូនបានមកទស្សនកិច្ចសិក្សាផ្ទាល់នៅធនាគារ អេស៊ីលីដា។ ធនាគារអេស៊ីលីដា ជាធនាគារពាណិជ្ជមួយ ដែលផ្តល់សេវាធនាគារបែបឌីជីថលដ៏សម្បូរបែប ជាពិសេសសេវាធនាគារតាមប្រព័ន្ធបាគងឈានមុខមួយក្នុងវិស័យធនាគារនៅកម្ពុជា។
- នៅថ្ងៃទី១ ខែមីនា ឆ្នាំ២០២៣ ធនាគារបានទទួលលិខិតថ្លែងអំណរគុណ និងកោតសរសើរពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលធនាគារបានចូលរួមបំពេញកាតព្វកិច្ចបង់ពន្ធដារផ្ទៃក្នុងជូនរដ្ឋ និងជាសហគ្រាសជាប់ "ចំណាត់ថ្នាក់លេខ៣" ក្នុងចំណោមសហគ្រាស ដែលបានបង់ពន្ធច្រើនជាងគេ និងទទួលបានអនុលោមភាពសារពើពន្ធប្រភេទ "មាស" ក្នុងឆ្នាំ២០២២។
- នៅថ្ងៃទី១ ខែមីនា ឆ្នាំ២០២៣ ធនាគារបានទទួលពាន និងបណ្ណសរសើរ ជាធនាគារឆ្នើម ពីនិយ័តករបរធនបាលកិច្ច (ន.ប.ធ.) ដែលជាប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកក្នុងវិស័យបរធនបាលកិច្ច ដែលបានចុះបញ្ជីបរធនបាលកិច្ច ច្រើនជាងគេ ក្នុងឆ្នាំ២០២២ បន្ទាប់ពីធនាគារទទួលបានការអនុញ្ញាតពី ន.ប.ធ. ធ្វើជាប្រតិបត្តិករបរធនបាល។
- នៅថ្ងៃទី៦ ខែមីនា ឆ្នាំ២០២៣ ថ្នាក់ដឹកនាំ និងកម្មករនិយោជិតធនាគារ អេស៊ីលីដា គ្រប់លំដាប់ថ្នាក់នៅការិយាល័យកណ្តាល និងសាខាជុំវិញរាជធានីភ្នំពេញ បានចូលរួមបរិច្ចាគឈាមដោយស្ម័គ្រចិត្ត ដើម្បីជួយសង្គ្រោះជនរងគ្រោះ និងអ្នកជំងឺ ដែលត្រូវការឈាម។ នេះសបញ្ជាក់ឱ្យឃើញថា ធនាគារបានចូលរួមចំណែកក្នុងសកម្មភាពសង្គម និងមនុស្សធម៌ សម្រាប់បំពេញតម្រូវការកង្វះឈាមក្នុងការជួយសង្គ្រោះអាយុជីវិតជូនដល់មជ្ឈមណ្ឌលជាតិផ្តល់ឈាម។
- នៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ធនាគារបានទទួលលិខិតថ្លែងអំណរគុណពីគណៈកម្មការអន្តរក្រសួងរៀបចំពិធីបុណ្យទន្លេ ដែលធនាគារបានចូលរួមឧបត្ថម្ភថវិកាសម្រាប់ទ្រទ្រង់ដល់ការរៀបចំ **ពិធីបុណ្យទន្លេលើកទី៧** ប្រារព្ធធ្វើឡើងនៅខេត្តកំពង់ធំ ក្រោមប្រធានបទ **"ទន្លេរបស់យើង ដើម្បីបច្ចុប្បន្ន និងអនាគត"** ដែលរៀបចំដោយ **ក្រសួងទេសចរណ៍** ដើម្បីរួមចំណែកដល់ការអភិវឌ្ឍវិស័យទេសចរណ៍កម្ពុជាឱ្យទទួលបានការរីកចម្រើនជាបន្តបន្ទាប់។
- នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៣ ធនាគារបានចុះអនុស្សរណៈយោគយល់គ្នាជាមួយ **សមាគមគ្រូពេទ្យស្ម័គ្រចិត្តយុវជនសម្តេចតេជោ** (TYDA) ក្នុងគោលបំណងដើម្បីសហការគ្នាក្នុងការផ្តល់សេវាពិនិត្យ និងព្យាបាលជំងឺដោយឥតគិតថ្លៃជូនប្រជាពលរដ្ឋក្រីក្រទូទាំងព្រះរាជាណាចក្រកម្ពុជា។ នេះសបញ្ជាក់ឱ្យឃើញថា ធនាគារបានចូលរួមក្នុងសកម្មភាពមនុស្សធម៌ ក្នុងបុព្វហេតុប្រជាពលរដ្ឋ និងសង្គម ដើម្បីគាំទ្រដល់សុខុមាលភាពសាធារណៈ ព្រមទាំងចូលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ និងសម្រាលបន្ទុកចំណាយជូនប្រជាពលរដ្ឋ។
- នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៣ ធនាគារបានទទួលបណ្ណថ្លែងអំណរគុណ ពី**សមាគមគ្រូពេទ្យស្ម័គ្រចិត្តយុវជនសម្តេចតេជោ** (TYDA) ដែលធនាគារបានឧបត្ថម្ភថវិកាសម្រាប់ចូលរួមចំណែកក្នុងការផ្តល់សេវាថែរក្សាសុខភាព ក្នុងការពិនិត្យ និងការព្យាបាលជំងឺនៅតាមមូលដ្ឋានដោយឥតគិតថ្លៃ ក្នុងបុព្វហេតុលើកកម្ពស់សុខុមាលភាពជូនដល់ប្រជាពលរដ្ឋនៅទូទាំងប្រទេស។
- នៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៣ ធនាគារបានចាប់ដៃគូជាមួយ RIA Money Transfer ក្នុងការពង្រីកសេវាកម្មផ្ទេរប្រាក់នៅកម្ពុជា។ ការពង្រីកបណ្តាញរបស់ RIA រួមមានសេវាកម្មមានភាពងាយស្រួល ដូចជាការទូទាត់សាច់ប្រាក់ ការប្រមូលសាច់ប្រាក់ទាំងប្រាក់រៀល (ប្រាក់រៀលកម្ពុជា) និងដុល្លារអាមេរិក (ដុល្លារសហរដ្ឋអាមេរិក) និងគណនីបញ្ញើ។
- នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៣ ធនាគារបានទទួលវិញ្ញាបនបត្រឧត្តមភាពអាជីវកម្មក្នុងវិស័យធនាគារ និងពានរង្វាន់ឧត្តមភាពអាជីវកម្ម សម្រាប់ឆ្នាំ២០២៣ ពីស្ថានកុងស៊ុលកិត្តិយសកម្ពុជា។
- នៅថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២៣ ធនាគារបានទទួលលិខិតថ្លែងអំណរគុណពីក្រសួងព័ត៌មាន ដែលធនាគារបានឧបត្ថម្ភថវិកាក្នុងមូលនិធិ ដើម្បីជួយដល់មន្ទីរពេទ្យគន្ធបុប្ផាកម្ពុជា និងអង្គការគ្រួសារថ្មី ដែលជាការងារមនុស្សធម៌មួយក្នុងការរួមចំណែកជាមួយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីកាត់បន្ថយភាពក្រីក្រ។
- នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៣ ធនាគារបានទទួលប័ណ្ណថ្លែងអំណរគុណពីកាកបាទក្រហមកម្ពុជា សម្រាប់ការឧបត្ថម្ភថវិកាចំនួន៨០០លានរៀល ក្នុងពិធីអបអរខួបទី១៦០ ទិវាពិភពលោកកាកបាទក្រហម និងអឌ្ឍចន្ទក្រហមថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២៣ ក្រោមប្រធានបទ **"រួមគ្នាជាមួយកាកបាទក្រហមកម្ពុជា ដើម្បីបរិយាបន្នសង្គម"**។
- នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៣ ធនាគារបានទទួលវិញ្ញាបនបត្របញ្ជាក់សមាជិកភាព របស់ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា។ តាមរយៈវិញ្ញាបនបត្រនេះ ធនាគារបានក្លាយជាសមាជិកផ្លូវការរបស់ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា។ ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (Cambodia Data Exchange/CamDX) ឬហៅកាត់ថា ថ.ផ.ទ. ជាថ្នាលបច្ចេកវិទ្យាព័ត៌មានរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលត្រូវបានដាក់ឱ្យដំណើរការដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលត្រូវបានបង្កើតឡើងសម្រាប់ផ្លាស់ប្តូរទិន្នន័យដោយប្រើប្រាស់សន្ទានកម្មនៃកម្មវិធីកុំព្យូទ័រ (Application Programming Interface-API) រវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយ និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយទៀតក្នុងវិស័យសាធារណៈ និងជាមួយវិស័យឯកជន ដែលជាសមាជិក ថ.ផ.ទ. ដោយសុវត្ថិភាពតាមរយៈប្រព័ន្ធអ៊ីនធើណែត ឬបណ្តាញតភ្ជាប់ឌីជីថលផ្សេងៗ។
- នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៣ ធនាគារបានទទួលប័ណ្ណសរសើរពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលធនាគារបានប្រកាស និងបង់ពន្ធលើប្រាក់ចំណូលជូនរដ្ឋជាប់លំដាប់ទី៤ ក្នុងចំណោមសហគ្រាសដែលបង់ពន្ធច្រើនជាងគេ ក្នុងឆ្នាំ២០២២។
- នៅថ្ងៃទី១ ខែឧសភា ឆ្នាំ២០២៣ ធនាគារ បានទទួលលិខិតថ្លែងអំណរគុណ ពីបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) ដែលធនាគារ បានឧបត្ថម្ភថវិកាក្នុងកម្មវិធី "សមាជិក ប.ស.ស. ឆ្នើម ២០២៣"។
- នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៣ ធនាគារបានទទួលពានរង្វាន់ដៃគូទូទាត់ និងបម្រើអតិថិជនល្អឥតខ្ចោះ ឆ្នាំ២០២១-២០២២ ពីធនាគារ Wells Fargo។
- នៅថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២៣ **ធនាគារជាតិ នៃ កម្ពុជា និងធនាគារជាតិថៃ** បានប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការ សេវាទូទាត់ឆ្លងដែនរវាងកម្ពុជា និងថៃ ដំណាក់កាលទី២ ដែលអនុញ្ញាតឱ្យ ជនជាតិថៃ ដែលធ្វើដំណើរមកប្រទេសកម្ពុជា អាចស្កេនទូទាត់ទិញទំនិញ ឬសេវាកម្មផ្សេងៗ តាមរយៈ QR បានដូចគ្នានឹងជនជាតិខ្មែរ ដែលធ្វើដំណើរទៅកាន់ប្រទេសថៃដែរ។ កម្រៃសេវាសម្រាប់ប្រតិបត្តិការស្កេនទូទាត់ឆ្លងដែន រវាងប្រទេសទាំងពីរ គឺមិនគិតថ្លៃសេវាឡើយ។ ធនាគារ អេស៊ីលីដា ជាធនាគារទំនាក់ទំនង ដូច្នេះអ្នកប្រើប្រាស់**អេស៊ីលីដា**ម៉ូបាល អាច**ស្កេន** QR ទូទាត់ថ្លៃទំនិញ និងសេវាកម្មផ្សេងៗ ជាប្រាក់រៀល នៅក្នុង**ប្រទេសថៃ**បានជាមួយពាណិជ្ជករ (អ្នកលក់) ដែលមានស្លាកសញ្ញា ThaiQR/PromptPay របស់ធនាគារចំនួនប្រាំនៅប្រទេសថៃ មានដូចជា៖ Kasikorn Bank, KrungThai Bank, Bangkok Bank, Bank of Ayudhya និង Siam Commercial Bank ក្នុងចំនួនទឹកប្រាក់រហូតដល់ទៅ **៥២លានរៀល ក្នុងមួយថ្ងៃ** (កាត់ពីគណនីវ៉ាលេឡេត៖ ១២លានរៀល និងគណនីធនាគារ៖ ៤០លានរៀល)។

- នៅថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២៣ ធនាគារបានចុះកិច្ចព្រមព្រៀងជាមួយ ក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (ខេមបូឌា) ខូ អិលធីឌី (ស៊ីប៊ីស៊ី) ជាក្រុមហ៊ុនឈានមុខគេក្នុងការផ្តល់នូវសេវាចែករំលែកព័ត៌មានឥណទាននៅកម្ពុជា ក្នុងគោលបំណងដើម្បីដាក់ឱ្យដំណើរការ**សេវាពិនិត្យសុខភាពហិរញ្ញវត្ថុ** លើកម្មវិធីទូរស័ព្ទ **អេស៊ីលីដាម៉ូបាល** ដែលជាមធ្យោបាយកាន់តែងាយស្រួល និងលឿនឆាប់រហ័សជាងមុន សម្រាប់អតិថិជនអាចស្នើសុំរបាយការណ៍ឥណទានរបស់ពួកគាត់ បានគ្រប់ពេលវេលា គ្រប់ទីកន្លែង ជាមួយនឹងថ្លៃសេវាសមរម្យ។ **មុខងាររបស់ស៊ីប៊ីស៊ី** ដែលមាននៅក្នុង**អេស៊ីលីដាម៉ូបាល** នឹងបង្ហាញប្រវត្តិនៃការខ្ចីប្រាក់ និងការទូទាត់សងប្រាក់របស់អតិថិជន ជាមួយនឹងធនាគារ អេស៊ីលីដា ឬគ្រឹះស្ថានធនាគារ និងស្ថាប័នហិរញ្ញវត្ថុដទៃទៀត។
- នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៣ ធនាគារបានសហការជាមួយស្ថាប័ន Global Loyalty Network "GLN International Inc." ដែលជាក្រុមហ៊ុនបណ្តាញឌីជីថលសកលសម្រាប់ទូទាត់ឆ្លងដែន តាមរយៈទូរស័ព្ទចល័ត។ សមិទ្ធផលនេះនឹងអនុញ្ញាតឱ្យអ្នកប្រើប្រាស់ទូរស័ព្ទចល័តនៅក្នុងបណ្តាញ GLN មកពីសាធារណរដ្ឋកូរ៉េ និងនៅជុំវិញពិភពលោក អាចទូទាត់ថ្លៃទំនិញ និងសេវាកម្មផ្សេងៗ នៅក្នុងប្រទេសកម្ពុជា តាមរយៈទូរស័ព្ទចល័ត ដោយគ្រាន់តែបង្ហាញនូវឃ្យូអរកូដ ដើម្បីស្កេនជាមួយម៉ាស៊ីន POS បានកាន់តែមានភាពងាយស្រួល រហ័ស សុវត្ថិភាព និងសម្បូរបែប។
- នៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២៣ ធនាគារបានទទួលពានរង្វាន់ ជាស្ថាប័នវិនិយោគ និងអភិវឌ្ឍន៍សហគ្រាស ខ្នាតតូចបំផុត ខ្នាតតូច និងមធ្យម ពីសមាគមយុវជនសេដ្ឋកិច្ចកម្ពុជា នៅក្នុងវេទិកាសេដ្ឋកិច្ច ឆ្នាំ២០២៣ លើកទី១។
- នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៣ ធនាគារបានទទួលប័ណ្ណថ្លែងអំណរគុណ ពីក្រសួងសុខាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ដែលធនាគារ បានផ្តល់សេវាកម្មបានល្អប្រសើរក្នុងអំឡុងចូលរួមអនុវត្តការងារប្រយុទ្ធនឹងជំងឺកូវីដ-១៩ នាពេលកន្លងមក។
- នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២៣ ធនាគារបានប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការ **ប្រព័ន្ធទូទាត់តាម QR Code ឆ្លងដែន នៅក្នុងប្រទេសឡាវ ដំណាក់កាលទី១ កម្ពុជាស្កេនឡាវ QR Code** ក្នុងគោលបំណង ដើម្បីលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល សម្រាប់ការទូទាត់នៅក្នុងតំបន់អាស៊ាន និងបរិយាបន្នហិរញ្ញវត្ថុស្របតាមសមាហរណកម្មសហគមន៍សេដ្ឋកិច្ចអាស៊ាន។ ធនាគារ អេស៊ីលីដា ភីអិលស៊ី និងធនាគារ អេស៊ីលីដា ឡាវ លីមីតធីត ត្រូវបានជ្រើសរើសជាធនាគារទូទាត់ សម្រាប់ការទូទាត់ឆ្លងដែនរវាងកម្ពុជា និងឡាវ សម្រាប់ប្រតិបត្តិការទទួលយកការទូទាត់ជារូបិយប័ណ្ណក្នុងស្រុក (ប្រាក់រៀល និងឡាវគីប)។ ការទូទាត់ឆ្លងដែនតាមរយៈ QR Code អនុញ្ញាតឱ្យអតិថិជន និងសាធារណជន អាចទិញទំនិញ និងធ្វើការទូទាត់ថ្លៃទំនិញ នៅពេលធ្វើដំណើរទៅកាន់ប្រទេសជិតខាង ដោយគ្រាន់តែស្កេន QR Code បានកាន់តែមានភាពងាយស្រួល និងមានសុវត្ថិភាព។ ក្រោយពីបញ្ចប់ការដាក់ឱ្យប្រើប្រាស់ជាផ្លូវការរួច គណៈប្រតិភូជាន់ខ្ពស់ធនាគារជាតិ នៃ កម្ពុជា ដឹកនាំដោយ **លោកជំទាវ ជា សិរី អគ្គទេសាភិបាល និងគណៈប្រតិភូជាន់ខ្ពស់ធនាគារកណ្តាលឡាវ** បានអញ្ជើញធ្វើទស្សនកិច្ចជាផ្លូវការនៅ ធនាគារ អេស៊ីលីដា ឡាវ លីមីតធីត។
- នៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២៣ ធនាគារបានទទួលលិខិតថ្លែងអំណរគុណ ពីសមាគមធនាគារនៅកម្ពុជា ដែលធនាគារ បានចូលរួមចំណែកជាអ្នកឧបត្ថម្ភធំគាំទ្រ ក្នុងកម្មវិធីសន្និសីទធនាគារនៅកម្ពុជាប្រចាំឆ្នាំ២០២៣។
- នៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២៣ ធនាគារបានទទួលពានរង្វាន់ ប្រភេទមាស ជា **"ធនាគារដ៏ល្អបំផុតក្នុងការផ្តល់ហិរញ្ញប្បទានដល់សហគ្រិនស្ត្រី"** ពីវេទិកាហិរញ្ញប្បទានសហគ្រាសធុនតូច និងមធ្យម (SME Finance Forum) ព្រមទាំងទទួលការកោតសរសើរជា **"ធនាគារដែលផ្តល់ហិរញ្ញប្បទានដល់សហគ្រាសធុនតូច និងមធ្យមប្រចាំឆ្នាំក្នុងតំបន់អាស៊ី"** នៅក្នុងកម្មវិធីផ្តល់ពានរង្វាន់ហិរញ្ញប្បទានសហគ្រាសធុនតូច និងមធ្យម សកលលោក ឆ្នាំ២០២៣។ ពានរង្វាន់នេះ បានរៀបចំដោយស្ថាប័នសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ជាសមាជិកនៃក្រុមធនាគារពិភពលោក និងវេទិកាហិរញ្ញប្បទានសហគ្រាសធុនតូច និងមធ្យម ព្រមទាំងមានការគាំទ្រដោយ GPFI (Global Partnership for Financial Inclusion) របស់ G20។
- នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៣ ធនាគារបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាដៃគូសហការឧបត្ថម្ភជាមួយសហព័ន្ធកីឡាបាល់ទាត់កម្ពុជា (FFC) ក្នុងគោលបំណងឧបត្ថម្ភគាំទ្រថវិកាចំនួន ២០០.០០០ ដុល្លារអាមេរិក ដើម្បីចូលរួមចំណែកក្នុងការគាំទ្រ ជំរុញការអភិវឌ្ឍ និងលើកកម្ពស់វិស័យបាល់ទាត់នៅកម្ពុជា សម្រាប់ឆ្នាំ២០២៣-២០២៤។
- នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ធនាគារបានសហការជាមួយក្រុមហ៊ុនម៉ាស្ទ័រកាត ដាក់ឱ្យដំណើរការជាផ្លូវការនូវ **ប័ណ្ណឡេឌីម៉ាស្ទ័រកាត** អេស៊ីលីដា ក្នុងប្រទេសកម្ពុជា។ **ប័ណ្ណឡេឌីម៉ាស្ទ័រកាត** អេស៊ីលីដាផ្តល់ជូនបទពិសោធន៍គួរឱ្យចាប់អារម្មណ៍ជាច្រើន រួមទាំងអត្ថប្រយោជន៍ពិសេស សិទ្ធិ និងភាពជាដៃគូជាច្រើន។ អត្ថប្រយោជន៍ទាំងនេះ គឺផ្តោតសំខាន់លើប្រភេទចំណាយដ៏ពេញនិយមបំផុតចំពោះម្ចាស់ប័ណ្ណ ជាពិសេស គឺសុភាពនារី សម្រាប់ចំណាយក្នុងការទិញទំនិញតាមអនឡាញ ការធ្វើដំណើរ សុខភាព គ្រួសារ ការកម្សាន្តផ្សេងៗ និងការដឹកជញ្ជូន។ **ប័ណ្ណឡេឌីម៉ាស្ទ័រកាត** អេស៊ីលីដា សម្រាប់អតិថិជន ជាសុភាពនារីនឹងផ្តល់ឱ្យពួកគាត់នូវមធ្យោបាយទូទាត់តាមបែបឌីជីថល កាន់តែរហ័សទាន់ចិត្ត សុវត្ថិភាព និងងាយស្រួលជាងមុន និងជួយបង្កើនជីវិតប្រចាំថ្ងៃរបស់ពួកគាត់ឱ្យកាន់តែប្រសើរឡើង។
- នៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៣ ធនាគារបានទទួលពានរង្វាន់ ចំនួន ២ ជា**ធនាគារឈានមុខក្នុងតំបន់អាស៊ី** ក្នុងការផ្តួចផ្តើមបរិយាបន្នហិរញ្ញវត្ថុ និងជាធនាគារ ដែលបំពាក់បច្ចេកវិទ្យាសេវាធនាគារតាមទូរស័ព្ទដៃខ្ពស់បំផុត ក្នុងការបម្រើសេវាកម្មហិរញ្ញវត្ថុ។
- នៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២៣ ធនាគារបានទទួលពានរង្វាន់ ជាដៃគូប្រតិបត្តិការទូទាត់ឆ្នើម ប្រចាំឆ្នាំ២០២២ ពីស្ថាប័ន BNY Mellon។
- នៅថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០២៣ ធនាគារទទួលបានរបាយការណ៍វាយតម្លៃពីភ្នាក់ងារអន្តរជាតិ Standard & Poor's (S&P) Global Ratings ដោយរក្សានូវចំណាត់ថ្នាក់ "B+/Stable/B" ដដែល។ ការរក្សាបាននូវចំណាត់ថ្នាក់នេះ សបញ្ជាក់អំពីភាពរឹងមាំ និងការរក្សាបាននូវស្ថិរភាពប្រវត្តិហិរញ្ញវត្ថុរបស់ធនាគារ អេស៊ីលីដា ក្នុងរយៈពេលវែងជាមួយនឹងទ្រនាប់ដើមទុនគ្រប់គ្រាន់ និងរក្សាបាននូវស្ថិរភាពដើមទុនរបស់ខ្លួនសម្រាប់បង្ការនូវគ្រប់ស្ថានភាពនៃសេដ្ឋកិច្ច ពីវិបត្តិកូវីដ-១៩ និងឧបសគ្គផ្សេងៗ ជាច្រើន ក្នុងវិស័យម៉ាក្រូសេដ្ឋកិច្ច។
- នៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២៣ ធនាគារ បានទទួលលិខិតថ្លែងអំណរគុណពី សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលធនាគារបានឧបត្ថម្ភក្នុងកម្មវិធី "ពិព័រណ៍អប់រំឆ្នាំ២០២៣"។
- នៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២៣ ធនាគារបានទទួលលិខិតថ្លែងអំណរគុណ ពីសមាគមសហគ្រិនស្ត្រីកម្ពុជា ដែលធនាគារបានឧបត្ថម្ភក្នុងកម្មវិធី "ទិវាសហគ្រិនស្ត្រីកម្ពុជា" ក្រោមប្រធានបទ៖ បញ្ហាប្រឈមរបស់សហគ្រិនស្ត្រីលើកាតព្វកិច្ចពន្ធ និងទស្សនៈវិស័យនាពេលអនាគត។
- នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៣ ធនាគារ អេស៊ីលីដា និងសមាគមកម្ពុជា-ជប៉ុន (JCA) បានរៀបចំកម្មវិធីជំនួបធុរកិច្ច រវាងវិនិយោគិនកម្ពុជា និងជប៉ុន ដែលកម្មវិធីនេះ គឺជាវេទិកាមួយ ដើម្បីផ្លាស់ប្តូរចំណេះដឹងអំពីការគ្រប់គ្រងហិរញ្ញវត្ថុ ចំណេះដឹងបច្ចេកទេស និងការច្នៃប្រឌិតសំខាន់ៗ សម្រាប់ភាពជោគជ័យនៃអាជីវកម្ម ហើយវានឹងបើកឱកាសសម្រាប់វិនិយោគិនកម្ពុជា និងជប៉ុន ណែនាំគ្នាទៅវិញទៅមក។ ព្រឹត្តិការណ៍ដ៏សំខាន់នេះ មានការចូលរួមប្រមាណ ៦០ ក្រុមហ៊ុន ទាំងវិនិយោគិនក្នុងស្រុក និងវិនិយោគិនជប៉ុន រួមមាន សហគ្រាសធុនតូច និងមធ្យម, ឧស្សាហកម្ម, អ្នកបច្ចេកទេសជួសជុល និងថែទាំយានយន្ត, សាលាកែសម្ផស្ស, បច្ចេកវិទ្យាព័ត៌មាន, អ្នកទីផ្សារ និងអ្នកផ្សព្វផ្សាយការលក់, វេជ្ជសាស្ត្រ, កសិកម្ម, អចលនទ្រព្យ, ហិរញ្ញវត្ថុ, ទេសចរណ៍ និងបដិសណ្ឋារកិច្ច ជាដើម។

- នៅថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២៣ ធនាគារបានទទួលពានរង្វាន់ជាធនាគារដៃគូឈានមុខគេ ក្នុងឆ្នាំ២០២៣ ពីស្ថាប័ន Mastercard ដូចជាពានរង្វាន់ជាស្ថាប័នដែលមានកំណើនខ្ពស់សម្រាប់ប័ណ្ណឥណទាន និងប័ណ្ណឥណពន្ធ និងមានការទូទាត់អន្តរជាតិច្រើនជាងគេ។
- នៅថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២៣ ធនាគារជាតិ នៃកម្ពុជា និងធនាគារកណ្តាលវៀតណាម បានប្រកាសដាក់ឱ្យដំណើរការជាផ្លូវការនូវប្រព័ន្ធទូទាត់តាមយូអរកូដឆ្លងដែន រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម។ ជាមួយនឹងប្រតិបត្តិការទូទាត់ឆ្លងដែន រវាងសាធារណរដ្ឋសង្គមនិយមវៀតណាម និងព្រះរាជាណាចក្រកម្ពុជា ធនាគារ អេស៊ីលីដា និងធនាគារ Bank for Investment and Development of Vietnam (BIDV) ត្រូវបានជ្រើសរើស ជាធនាគារទំនាក់ទំនង (Sponsoring Bank) សម្រាប់ការទូទាត់ឆ្លងដែនតាមយូអរកូដ (QR Code) នៅប្រទេសកម្ពុជា និងវៀតណាម ដើម្បីសម្រួលដល់ការទូទាត់ថ្លៃទំនិញ និងសេវាកម្មផ្សេងៗ និងលើកកម្ពស់ការទូទាត់រូបិយវត្ថុជាតិ (ប្រាក់រៀល) ឱ្យកាន់តែទូលំទូលាយ និងជំរុញបរិយាបន្នហិរញ្ញវត្ថុនៅក្នុងតំបន់ស្របតាមសមាហរណកម្មសហគមន៍សេដ្ឋកិច្ចអាស៊ាន។
- នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២៣ ថ្នាក់ដឹកនាំ និងកម្មករនិយោជិតធនាគារ អេស៊ីលីដា គ្រប់លំដាប់ថ្នាក់ នៅការិយាល័យកណ្តាល និងសាខាជុំវិញរាជធានីភ្នំពេញ បានចូលរួមបរិច្ចាគឈាមដោយស្ម័គ្រចិត្ត ដើម្បីជួយសង្គ្រោះជនរងគ្រោះ និងអ្នកជំងឺដែលត្រូវការឈាម។ ការបរិច្ចាគឈាមពិតជាមានសារៈសំខាន់ខ្លាំងណាស់ក្នុងការជួយសង្គ្រោះជនរងគ្រោះ និងអ្នកជំងឺដែលត្រូវការឈាម ដើម្បីព្យាបាលជំងឺ។ ការចូលរួមចំណែកក្នុងកិច្ចការសង្គមដ៏មានសារៈសំខាន់មួយនេះ ថ្នាក់ដឹកនាំ និងកម្មករនិយោជិត ធនាគារ បានចូលរួមបរិច្ចាគឈាមដោយស្ម័គ្រចិត្តចំនួន ៧ ដង រួចមកហើយ ដើម្បីរួមចំណែកក្នុងសកម្មភាពសង្គម និងមនុស្សធម៌ សម្រាប់បំពេញតម្រូវការកង្វះឈាមក្នុងការជួយសង្គ្រោះអាយុជីវិតជូនដល់មជ្ឈមណ្ឌលជាតិផ្តល់ឈាម សម្រាប់ជួយសង្គ្រោះជនរងគ្រោះ និងអ្នកជំងឺដែលត្រូវការឈាមជាចាំបាច់ ជាពិសេសសម្រាប់ជួយជីវិតមនុស្ស ដែលត្រូវការសង្គ្រោះបន្ទាន់។
- នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២៣ ធនាគារបានទទួលលិខិតថ្លែងអំណរគុណ ដែលធនាគារ បានឧបត្ថម្ភក្នុងកម្មវិធី CSX Fun Run ដែលរៀបចំដោយផ្សារមូលបត្រកម្ពុជា ក្នុងគោលបំណងបំផុសចលនាចូលរួមលេងកីឡា និងកៀរគរថវិកាបរិច្ចាគជូនមូលនិធិគន្ធបុប្ផាកម្ពុជា។

# ង. ស្ថានភាពទីផ្សារ

គិតមកត្រឹមដំណាច់ឆ្នាំ២០២៣ ធនាគារ អេស៊ីលីដា ភីអិលស៊ី នៅបន្តរក្សាចំណែកទីផ្សារប្រមាណ ១៥,៣៧% និង ១២,៤៩% រៀងគ្នាសម្រាប់សមតុល្យប្រាក់បញ្ញើ និងសមតុល្យឥណទាន។ ដោយការបើកទូលាយសកម្មភាពសេដ្ឋកិច្ចក្នុងស្រុកឡើងវិញក្នុងឆ្នាំ២០២២ ធនាគារ អេស៊ីលីដា ភីអិលស៊ីនៅតែបន្តរក្សាកំណើននៃសេវាប្រាក់បញ្ញើសន្សំ ដោយក្នុងនោះចំនួនគណនីសរុប បានកើនឡើង ៦៦២.៩៤៤ គណនី និងសមតុល្យប្រាក់បញ្ញើសរុបកើនឡើង ប្រមាណជា ៣,២៥ ទ្រីលានរៀល ស្មើនឹង ៧៩៥,៨៨ លានដុល្លារអាមេរិក ខណៈដែលសេវាឥណទានក៏កើនឡើងផងដែរ ដោយក្នុងនោះចំនួនគណនីសរុបបានកើនឡើង ៧២,២៣៤ គណនី ដែលសមតុល្យឥណទានកើនឡើងប្រមាណជា ០,៨៦ ទ្រីលានរៀល ស្មើនឹង ២១១,៣២ លានដុល្លារអាមេរិក បើប្រៀបធៀបទៅនឹងឆ្នាំ២០២២។

រីឯស្ថានភាពថ្លៃសម្រាប់គ្រឹះស្ថានធនាគារ អត្រាការប្រាក់ឥណទានជារៀល និងជាដុល្លារអាមេរិកបានថយចុះមកវិញបន្តិច ដោយមានអត្រា ១៣,៣៩% និង ១១,០៨% រៀងគ្នាធៀបនឹងឆ្នាំ២០២២ (១៣,៥១% និង ១១,២៤% រៀងគ្នា) ខណៈអត្រាការប្រាក់ ឥណទានជាមធ្យមជារៀលនិងជាដុល្លារអាមេរិក ក៏បានកើនឡើងផងដែរ ដល់ ១៧,៤៤% និង ១៦,២% រៀងគ្នា ពី ១៦,៨% និង ១៥,០៥% នៅឆ្នាំ២០២២។ ចំពោះអត្រាការប្រាក់បញ្ញើក្នុងវិស័យធនាគារ បានកើនឡើង ដោយប្រាក់បញ្ញើជារៀលនិងជា ដុល្លារអាមេរិក ត្រូវបានប៉ាន់ស្មានថាមានអត្រា ៧,៧% និង ៦,៤៧% រៀងគ្នា ខ្ពស់ជាងអត្រា ក្នុងឆ្នាំ២០២២ (៦,៨៨% និង ៥,៣៦% រៀងគ្នា) ខណៈដែល វិស័យមីក្រូហិរញ្ញវត្ថុបានកើនឡើងដល់ ៨,៣៩% និង ៨,២៥% រៀងគ្នា ធៀបនឹងឆ្នាំ២០២២ (៧,៤២% និង ៧,៣៨% រៀងគ្នា)។ (១)

# ច. ស្ថានភាពប្រកួតប្រជែង

ចំនួនធនាគារ និងស្ថាប័នមីក្រូហិរញ្ញវត្ថុនៅកម្ពុជា នៅតែបន្តរីកចម្រើន។ ត្រឹមដំណាច់ខែធ្នូ ឆ្នាំ២០២៣ ធនាគារពាណិជ្ជមានចំនួន ៥៨ (ធនាគារក្នុងស្រុកចំនួន២៩, បុត្រសម្ព័ន្ធធនាគារបរទេសចំនួន១៨, និងសាខាធនាគារបរទេសចំនួន១១), ធនាគារឯកទេសចំនួន ០៩ (ធនាគារក្នុងស្រុកចំនួន០៤ និងធនាគារបរទេសចំនួន០៥), គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ៨៧ (គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើចំនួន០៤ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើចំនួន៨៣), ក្រុមហ៊ុនភតិសន្យាចំនួន១៦, ការិយាល័យតំណាងធនាគារបរទេសចំនួន០៦, គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ចំនួន៣៣, គ្រឹះស្ថានឥណទានជនបទចំនួន១១៤ និង ភ្នាក់ងារប្តូរប្រាក់ចំនួន២.៩១៥។ (Source: NBC Report, CMA Report, and Actually Updated)

ស្របគ្នានេះដែរ អតិថិជនឥណទានកើនឡើង ៤,៨% ដល់ ២៣៧,២ ទ្រីលានរៀល (៥៧,៦ ប៊ីលានដុល្លារអាមេរិក) ក្នុងនោះវិស័យធនាគារកើនឡើង ១៤,៨% ធៀបនឹងឆ្នាំមុន (១៨,២%) ដល់ ២១៣,១ ទ្រីលានរៀល (៥១,៨ ប៊ីលានដុល្លារអាមេរិក) ដោយមាន ចំនួនសរុប ២,២លានគណនី វិស័យមីក្រូហិរញ្ញវត្ថុ អតិថិជនបានធ្លាក់ចុះ -៤២,៦% ធៀបនឹងឆ្នាំមុន (២២,៧%) ដល់ ២២,៤ ទ្រីលានរៀល (៥,៤ ប៊ីលានដុល្លារអាមេរិក) ដោយមាន ១,៦ លានគណនី វិស័យភតិសន្យាហិរញ្ញវត្ថុបានធ្លាក់ចុះ -៣,៤% ដល់ ១,៧ ទ្រីលានរៀល (៤២១,៥ លានដុល្លារអាមេរិក) ដោយមាន ៩៣.៣១៨ គណនី និងគ្រឹះស្ថានឥណទានជនបទ បានផ្តល់ឥណទានសរុប ២១៣,២ ប៊ីលានរៀល (៥១,៣ លានដុល្លារអាមេរិក) ទៅដល់ ១១៦.០៤៤ គណនីអតិថិជន។ រីឯប្រាក់បញ្ញើរអតិថិជនមានកំណើន ១៣,១% ដល់ ១៩៧,២ ទ្រីលានរៀល (៤៧,៩ ប៊ីលានដុល្លារអាមេរិក) ក្នុងនោះវិស័យធនាគារមាន ប្រាក់បញ្ញើបានកើនឡើង ២១.៣% ដល់ ១៨៨,១ ទ្រីលានរៀល (៤៥,៧ ប៊ីលានដុល្លារអាមេរិក) និងមាន ចំនួន ១៦,៧ លានគណនី និង វិស័យមីក្រូហិរញ្ញវត្ថុបានកេណ្ឌប្រមូលប្រាក់បញ្ញើ ៩,២ ទ្រីលានរៀល (២,២ ប៊ីលានដុល្លារអាមេរិក) ស្មើនឹង ១,៩ លានគណនី។ (១)

ស្ថានភាពអតិថិជន ទីផ្សារ ថ្លៃ និងការប្រកួតប្រជែងនៅក្នុងវិស័យធនាគារ មានការប្រែប្រួលគួរឲ្យកត់សម្គាល់ ក៏ប៉ុន្តែធនាគារ អេស៊ីលីដា នៅតែបន្តរក្សាបានឧត្តមភាពប្រកួតប្រជែង លើគ្រប់ផលិតផល-សេវាកម្ម បណ្តាញប្រតិបត្តិការ ប្រភពទុន និងធនធានបច្ចេកទេស ព្រមទាំងបន្តភាពរីកចម្រើនបានយ៉ាងល្អប្រសើរ។ គិតត្រឹមដំណាច់ខែធ្នូឆ្នាំ២០២៣ សេវាឥណទានរបស់ធនាគារ អេស៊ីលីដា មានកំណើនរៀងគ្នា ១៣,០៤% (ខ្ពស់ជាងឆ្នាំ២០២២ ដែលមានចំនួន ១១,២៨%) និង ៣,៣៨% (ទាបជាងឆ្នាំ២០២២ ដែលមានចំនួន ១៩,៣១%) ទាំងចំនួនឥណទាន និងសមតុល្យឥណទានសរុប ស្របគ្នានឹងសេវាបញ្ញើរសន្សំមានកំណើន ១៥,៩០% និង ១២,៧៨% ទាំងចំនួនគណនី និងសមតុល្យប្រាក់បញ្ញើរសរុប ខ្ពស់ជាងឆ្នាំ២០២២ដែលមានកំណើន ១៥,៧២% និង ១២,៤៥%។

## ឆ. ផែនការអនាគត

ធនាគារ អេស៊ីលីដា រៀបចំផែនការបន្តពង្រីកសក្តានុពលរបស់ខ្លួន និងកំណត់លក្ខណៈពិសេសរបស់ខ្លួនឱ្យខុសប្លែកពីស្ថាប័នធនាគារផ្សេងទៀត ក្នុងនាមជាធនាគារពាណិជ្ជឈានមុខគេ ដែលលោកអ្នកជឿទុកចិត្តបំផុតនៅប្រទេសកម្ពុជា តាមរយៈនវានុវត្តន៍ផលិតផល, បច្ចេកវិទ្យា ជឿនលឿន, ភាពជាដៃគូអាជីវកម្មរឹងមាំ, បណ្តាញសាខា, សេវាកម្មពិសេស, ធនធានមនុស្សដែលមានការបណ្តុះបណ្តាលយ៉ាងល្អ ព្រមទាំងមានក្រមសីលធម៌ វិជ្ជាជីវៈ និងការធ្វើឱ្យកាន់តែប្រសើរឡើងនូវសេវាកម្មធនាគារឌីជីថល។ លើសពីនេះ ផែនការធនាគារ អេស៊ីលីដា គឺផ្តោតលើហ្វីជីថល (Phygital) មានន័យថា ធនាគារនៅតែប្រើប្រាស់សាខារូបវ័ន្ត និងឌីជីថល (និម្មិត) ដែលពាក់ព័ន្ធនឹងសេវាកម្មធនាគារស្វ័យប្រវត្តិ (SSB), ការិយាល័យរូបវ័ន្ត, ម៉ាស៊ីនអេធីអឹម (ATM), ម៉ាស៊ីនដក-ដាក់ប្រាក់ (CRM), ម៉ាស៊ីនបើកគណនីមានកាលកំណត់ (TDM), ម៉ាស៊ីនបើកគណនីធនាគារ (VTM), ម៉ាស៊ីនឆូតកាត (POS) និងសេវាកម្មឌីជីថលផ្សេងទៀត។ (Source: Strategic Planning Division (SPD)

## ជ. កត្តាហានិភ័យ

### ១. ការវិភាគ

អាជីវកម្ម លទ្ធផលប្រតិបត្តិការ ស្ថានភាពហិរញ្ញវត្ថុ និងស្ថានភាពអនាគតរបស់ធនាគារ អេស៊ីលីដា អាស្រ័យលើស្ថានភាពម៉ាក្រូសេដ្ឋកិច្ចសកល និងប្រទេសទូទៅ។ ហានិភ័យ និងបញ្ហាប្រឈមជាចម្បងដូចជា៖ ១) ការថមថយកំណើនសេដ្ឋកិច្ចនៅបណ្តាប្រទេសដៃគូពាណិជ្ជកម្ម សំខាន់ៗ ២) ការរឹតត្បិតនៃទីផ្សារហិរញ្ញវត្ថុអន្តរជាតិ និងការបន្តតម្លើងអត្រាការប្រាក់គោល ៣) សង្គ្រាមរុស្ស៊ី-អ៊ុយក្រែន ដែលធ្វើឲ្យអត្រាអតិផរណាកើនឡើងខ្ពស់ និងការថយតម្រូវការ ៤) បញ្ហាសេដ្ឋកិច្ច-សង្គមបន្សល់ទុកដោយវិបត្តិកូវីដ-១៩ ជាពិសេសការបន្តប៉ះពាល់ចំពោះវិស័យទេសចរណ៍ និងសេវាគាំទ្រ ៥) ការថយល្បឿនកំណើនក្នុងវិស័យសំណង់ និងអចលនទ្រព្យ ៦) ភាពតានតឹងភូមិសាស្ត្រនយោបាយ និង ៧) ការប្រែប្រួលអាកាសធាតុដែលបង្កភាពរាំងស្ងួត គ្រោះទឹកជំនន់ និងគ្រោះមហន្តរាយផ្សេងៗ ។ កត្តាហានិភ័យជាសារវន្តពាក់ព័ន្ធនឹងអាជីវកម្មរបស់ធនាគារ អេស៊ីលីដា មានដូចតទៅ ៖

#### ១-១ ហានិភ័យឥណទាន

ធនាគារ អេស៊ីលីដា ធានាឱ្យមាននូវដើមទុន និងសន្ទនីយភាពក្នុងការផ្តល់មូលនិធិដល់សកម្មភាពអាជីវកម្មរបស់ខ្លួន ហើយសន្ទនីយភាពគឺជាហានិភ័យមួយដែលអាចមានផលប៉ះពាល់ជាសារវន្តដល់កំណើនអាជីវកម្ម លទ្ធផលប្រតិបត្តិការ និងចំណាយ កេរ្តិ៍ឈ្មោះ និងការអនុលោមបទប្បញ្ញត្តិរបស់ធនាគារ ។ បញ្ហាសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន ការបន្តតម្លើងអត្រាការប្រាក់គោលនៅទីផ្សារអន្តរជាតិ និងហានិភ័យពាក់ព័ន្ធ អាចប៉ះពាល់ដល់លំហូរប្រភពមូលនិធិពីខាងក្រៅមានតម្លៃថ្លៃ និងមានកម្រិត ។

#### ១-២ ហានិភ័យសន្ទនីយភាព

អតិថិជនឥណទាន ឬសមភាគី មិនអាចបំពេញកាតព្វកិច្ចហិរញ្ញវត្ថុក្នុងការទូទាត់សង ធ្វើឱ្យមានផលប៉ះពាល់ជាសារវន្តដល់ប្រាក់ចំណេញ និងស្ថានភាពអនាគតរបស់ធនាគារ ។ ផលប៉ះពាល់ចំពោះវិស័យទេសចរណ៍ និងសេវាគាំទ្រ ដែលបន្សល់ពីវិបត្តិជំងឺកូវីដ-១៩កន្លងមក និងការថយល្បឿនកំណើនក្នុងវិស័យសំណង់ និងអចលនទ្រព្យ ធ្វើឱ្យឥណទានមានកំណើនយឺត ស្របជាមួយនឹងការបញ្ចប់នៃវិធានការរៀបចំឥណទានឡើងវិញ ធ្វើឱ្យឥណទានមិនដំណើរការ (NPL) មានការកើនឡើង។ ។

### ២. ទស្សនៈអ្នកគ្រប់គ្រង និងវិធានការទប់ស្កាត់

ធនាគារ អេស៊ីលីដា យល់យ៉ាងច្បាស់អំពីហានិភ័យដែលបានកំណត់ និងជឿជាក់ថាកត្តាហានិភ័យទាំងនេះអាចគ្រប់គ្រង ចាត់វិធានការកាត់បន្ថយ ព្រមទាំងប្រែក្លាយវាជាកាលានុវត្តភាពផងដែរ ៖

#### ២-១ វិធានការគ្រប់គ្រងហានិភ័យសន្ទនីយភាព

- ដាក់ចេញនូវវិធានការគ្រប់គ្រងហានិភ័យដើម្បីកាត់បន្ថយហានិភ័យសន្ទនីយភាព និងរក្សានិរន្តរភាពអាជីវកម្ម ដោយបានត្រៀមបម្រុងមូលនិធិ ស្ថិតនៅកម្រិតខ្ពស់ដែលអាចគាំទ្រដល់កំណើនអាជីវកម្ម និងឆ្លើយតបបានទាន់ពេលទៅនឹងហេតុការណ៍ហានិភ័យដែលមិនអាចរំពឹងទុកនានា ។
- បន្តស្វែងរកប្រភពមូលនិធិតាមរយៈរក្សាការទំនាក់ទំនង និងចុះកិច្ចព្រមព្រៀងជាមួយអ្នកផ្តល់មូលនិធិ ដៃគូរ និងអតិថិជនជាសក្តានុពល និងធ្វើពិពិធកម្មមូលនិធិ សំដៅធានាដំណើរការអាជីវម្មប្រកបដោយចីរភាព ។

#### ២-២ វិធានការគ្រប់គ្រងហានិភ័យឥណទាន

- អនុវត្តយ៉ាងខ្ជាប់ខ្ជួននូវសារាចរណែនាំនានារបស់ធនាគារជាតិ នៃ កម្ពុជា ជាពិសេសកាតព្វកិច្ចធ្វើចំណាត់ថ្នាក់ និងសំវិធានធនចំពោះឥណទានរៀបចំឡើងវិញ ក្នុងគោលបំណងកាត់បន្ថយហានិភ័យឥណទាន សំដៅរក្សាស្ថិរភាពហិរញ្ញវត្ថុ និងគាំទ្រការងើបឡើងវិញនៃសកម្មភាពសេដ្ឋកិច្ច ។
- ពង្រឹង និងបង្កើនសមត្ថភាពលើកិច្ចការអភិបាលកិច្ច គោលនយោបាយ នីតិវិធី ការត្រួតពិនិត្យផ្ទៃក្នុងទាក់ទងនឹងការវាយតម្លៃ និងត្រួតពិនិត្យឥណទានឡើងវិញ សំដៅធានាថា ឥណទានដែលឲ្យអតិថិជនត្រូវបានវាយតម្លៃអំពី ប្រភពចំណូលស្នូល លំហូរសាច់ប្រាក់អតិថិជន សមត្ថភាពសង ទ្រព្យធានា ផលប៉ះពាល់បរិស្ថាន និងសង្គម សំដៅធានាថា ហានិភ័យឥណទាននិងការខាតបង់នានា ត្រូវបានកាត់បន្ថយជាអតិបរមា ។
- រក្សាភាពទន់ភ្លន់ និងពិនិត្យតាមលទ្ធភាពជាក់ស្តែង ក្នុងការដោះស្រាយបំណុលដែលយឺតយ៉ាវជាមួយនិងការលើកទឹកចិត្តភ្នាក់ងារឥណទាន ធ្វើការទាក់ទង និងដោះស្រាយជាមួយអតិថិជនប្រកបដោយសីលធម៌វិជ្ជាជីវៈខ្ពស់ ។

**ឯកសារយោង:**

(១) https://www.nbc.gov.kh/download_files/publication/annual_rep_kh/Annual_Report_2023_KHM.pdf

# ផ្នែកទី ២

## ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

# ក. លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក

គិតនៅត្រឹមដំណាច់ខែធ្នូ ឆ្នាំ២០២៣ ធនាគារ អេស៊ីលីដា និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួនទទួលបានលទ្ធផលល្អលើការលក់ ដូចខាងក្រោម៖

| លទ្ធផលសំខាន់ៗ | លទ្ធផលសម្រេចបាន | | |
|---|---|---|---|
| | ២០២៣ | ២០២២ | ២០២១ |
| **សេវាឥណទាន** | | | |
| ចំនួនឥណទានសកម្ម | ៦៦១.៩៤១ | ៥៩១.៤៩៤ | ៥៤១.១៨៤ |
| សមតុល្យឥណទានសរុប (លានរៀល) | ២៧.១៩៥.១២០ | ២៦.៤៣៧.៩២៨ | ២២.១១៦.០១៣ |
| **សេវាបញ្ញើ-សន្សំ** | | | |
| ចំនួនគណនីសរុប | ៤.៥៥០.៥៨២ | ៣.៨៦៥.៧៤៩ | ៣.២៩៨.៣៨២ |
| ចំនួនទឹកប្រាក់សរុប (លានរៀល) | ២៩.៥២៥.៦១៦ | ២៦.៣០៣.៤៧៥ | ២៣.២៨៧.០៦៤ |
| **សេវាធនាគារអេឡិចត្រូនិក** | | | |
| **ប័ណ្ណអេធីអឹម អេស៊ីលីដា** | | | |
| ចំនួនប័ណ្ណបោះផ្សាយសរុប | ១.៩៣៩.០៩៨ | ១.៧៩៩.៩០៩ | ១.៥៨៥.៤៤៩ |
| ចំនួនប្រតិបត្តិការសរុប | ១៩.៨៥១.៨០១ | ២១.០៥៨.៦០៩ | ១៩.៤៤៨.៨៣៧ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ១៧.១៤៥.៤១១ | ១៨.៦៨៣.៣៣៥ | ១៦.១៧៣.៩៩០ |
| **អេស៊ីលីដាម៉ូបាល** | | | |
| ចំនួនអ្នកប្រើប្រាស់សរុប | ៣.៤៥១.៦០៦ | ២.៨៤៥.៨៨៦ | ២.២៧៨.២២០ |
| ចំនួនប្រតិបត្តិការសរុប | ៣៧៣.០៣៦.៣៣៦ | ១៤៨.៧៩៩.៦៦១ | ៧៨.៧២៦.៨៩៥ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ៣៨៣.០៤៣.៥៩៦ | ២០៦.៦៦០.២៦២ | ១១៥.២៤២.៦៣៨ |
| **សេវាអេស៊ីលីដាអ៊ីនធើណែត** | | | |
| ចំនួនអ្នកប្រើប្រាស់សរុប | ២៤.៨២៥ | ២២.១៦៤ | ១៣.៥៥៧ |
| ចំនួនប្រតិបត្តិការសរុប | ៣.៥២៩.២០៩ | ២.៣១៨.៧៨៩ | ១.៤៦៦.៨២២ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ២៦.៥២៩.៣៨១ | ២៦.១៥៨.៧០៥ | ១៩.៧៩៩.៨៦៤ |
| **សេវាអេស៊ីលីដាអ៊ីខុមមើស** | | | |
| ចំនួនដៃគូអាជីវកម្មសរុប | ៨៨ | ៧៣ | ៥៩ |
| ចំនួនប្រតិបត្តិការសរុប | ៣.៩៨៣.១៦៧ | ៣.៦១៩.៩៣៦ | ៣.២១៥.២០៧ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ២.០១៩.០០១ | ១.៨០៤.១៣៦ | ១.២០៦.៥២៩ |
| **ម៉ាស៊ីនអេធីអឹម អេស៊ីលីដា** | | | |
| ចំនួនម៉ាស៊ីនសរុប | ១.៣១៤ | ១.១១៤ | ៩០១ |
| ចំនួនប្រតិបត្តិការសរុប | ៤១.៥៥៤.៩៩៣ | ៣៥.២៩៨.២១៤ | ២៧.១២៩.២៥២ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ៤៦.៨០១.៩៨២ | ៣៩.១៦០.៩៧៦ | ២៦.៤៧៧.៣៤១ |

| លទ្ធផលសំខាន់ៗ | លទ្ធផលសម្រេចបាន | | |
|---|---|---|---|
| | ២០២៣ | ២០២២ | ២០២១ |
| **ម៉ាស៊ីនដាក់ប្រាក់បញ្ញើមានកាលកំណត់** | | | |
| ចំនួនម៉ាស៊ីនសរុប | ២៦ | ២៦ | ២៦ |
| ចំនួនប្រតិបត្តិការសរុប | ៣០៤ | ១.៤៨៧ | ៤.១២០ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ១៦.១៤៣ | ១១១.១៣៤ | ៣៤៣.១៥៨ |
| **ម៉ាស៊ីនបើកគណនី និងបោះពុម្ពប័ណ្ណអេធីអឹម** | | | |
| ចំនួនម៉ាស៊ីនសរុប | ៩៦ | ៤៣ | ២៥ |
| ចំនួនប្រតិបត្តិការសរុប | ១៣០.៩៨៧ | ៤៣.០៨៩ | ៣៤.០៩២ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ៥ | ១៦ | ៧០ |
| **ម៉ាស៊ីនទទួលកាបូបប្រាក់** | | | |
| ចំនួនម៉ាស៊ីនសរុប | ១៧ | ១៧ | ១៤ |
| ចំនួនប្រតិបត្តិការសរុប | ៨៨.៩០៨ | ៧៥.០២០ | ៩៤.៧១៣ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ៥០៦.៥៥០ | ៥៧១.០៩៨ | ៥៥៥.២៥៧ |
| **ម៉ាស៊ីនឆូតកាត អេស៊ីលីដា** | | | |
| ចំនួនម៉ាស៊ីនឆូតកាតសរុប | ៤.៧២៨ | ៤.៣៥៨ | ៤.៩៦២ |
| ចំនួនប្រតិបត្តិការសរុប | ១.៩០០.៤០០ | ២.១៥៩.១៧៥ | ២.០៣៣.២៨៣ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ៦១៤.៤០៣ | ៥៩១.៦០៣ | ៤៧៩.៦១៣ |
| **កូដ QR នៅតាមហាងទំនិញនានា** | | | |
| ចំនួនពាណិជ្ជករបំពាក់កូដ QR | ៣៨២.២១៧ | ២៣៩.៧៥១ | ១២៥.៣០៩ |
| ចំនួនប្រតិបត្តិការសរុប | ១១០.១៤៨.៨៤៨ | ១៦.៤៥៩.៣៧៧ | ៣.១៩៤.៤៤៣ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ៦៣.១៧៥.៧២០ | ៧.៧៧៧.៤៩១ | ៦៣៨.២៤០ |
| **ប័ណ្ណនិម្មិតអេស៊ីលីដា** | | | |
| ចំនួនប័ណ្ណនិម្មិត | ២៧.១០៦ | ៨.៨៩៨ | ៣.៦៨៤ |
| ចំនួនប្រតិបត្តិការសរុប | ១៨២.៣៧៦ | ៣៤.៩០៧ | ២.៤៩១ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ១៨.៨១៨ | ៣.០១៨ | ១៦១ |

| លទ្ធផលសំខាន់ៗ | លទ្ធផលសម្រេចបាន | | |
|---|---|---|---|
| | ២០២៣ | ២០២២ | ២០២១ |
| **ខ្សែអាយប៉ែង** | | | |
| ចំនួនខ្សែបោះផ្សាយសរុប | ១០.៦០៣ | ៤.៩៦០ | - |
| ចំនួនប្រតិបត្តិការសរុប | ១២.៧១០ | ១៨.៧៤២ | - |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ១៤.៥១១ | ៣១.៧៦២ | - |
| **បណ្តាញប្រតិបត្តិការ និង បុគ្គលិក** | | | |
| **ធនាគារ អេស៊ីលីដា** | | | |
| ចំនួនការិយាល័យសរុប | ២៦៤ | ២៦៤ | ២៦២ |
| ចំនួនធនាគារស្វ័យប្រវត្តិសរុប | ១៧៧ | ១២៥ | ៧៣ |
| ចំនួនបុគ្គលិកសរុប | ១២.០៤៥ | ១២.០៨៣ | ១២.០៨១ |
| **ក្រុមហ៊ុនបុត្រសម្ព័ន្ធ (ក្នុង និង ក្រៅប្រទេស)** | | | |
| ចំនួនការិយាល័យសរុប | ៥៦ | ៥៦ | ៥៧ |
| ចំនួនបុគ្គលិកសរុប | ១.៤៥៨ | ១.៤៩៩ | ១.៥៩៣ |

## ខ. រចនាសម្ព័ន្ធចំណូល

| ប្រភពចំណូល (លានរៀល) | ២០២៣ | | ២០២២ | | ២០២១ | |
|---|---|---|---|---|---|---|
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| ចំណូលការប្រាក់ | ៣.១០៥.៦៤៤ | ៩១,២៦% | ២.៧៤១.៣៦៩ | ៩០,១៨% | ២.៣៣៤.២១៧ | ៩០,១២% |
| ចំណូលកម្រៃ និងជើងសា | ១៩១.៨៤៩ | ៥,៦៤% | ១៩៣.៩៤៩ | ៦,៣៨% | ១៧៤.៦៦៥ | ៦,៧៤% |
| ចំណូលផ្សេងៗសុទ្ធ | ១០៥.៦២១ | ៣,១០% | ១០៤.៧២០ | ៣,៤៤% | ៨១.២០៤ | ៣,១៤% |
| **ចំណូលសរុប** | **៣.៤០៣.១១៤** | **១០០%** | **៣.០៤០.០៣៨** | **១០០%** | **២.៥៩០.០៨៦** | **១០០%** |

# ផ្នែកទី ៣

## ព័ត៌មានអំពីអភិបាលកិច្ចសាជីវកម្ម



# ក. អង្គការលេខ


ភាគទុនិក
ក្រុមប្រឹក្សាភិបាល
គណៈកម្មាធិការសវនកម្ម
គណៈកម្មាធិការតែងតាំង និងលាភការ
គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងព័ត៌មានវិទ្យា
ប្រធាននាយកប្រតិបត្តិ
គណៈកម្មាធិការប្រតិបត្តិ
អេស៊ីលីដា ការិយាល័យតំណាង
អេស៊ីលីដា មីក្រូហិរញ្ញវត្ថុ មីយ៉ាន់ម៉ា លីមីធីត
ធនាគារ អេស៊ីលីដា ឡាវ លីមីធីត
អេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី
វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា
គណៈកម្មាធិការឥណទានកម្រិតប្រតិបត្តិ
គណៈកម្មាធិការធនធានមនុស្ស ទទួលខុសត្រូវបញ្ហាអេដស៍ និងការប្រយុទ្ធប្រឆាំងគ្រឿងញៀន
គណៈកម្មាធិការលទ្ធកម្ម
គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងអកម្ម
គណៈកម្មាធិការគ្រប់គ្រងវិនិយោគ
គណៈកម្មាធិការដឹកនាំ និងគ្រប់គ្រងបច្ចេកវិទ្យាព័ត៌មាន
គណៈកម្មាធិការគ្រប់គ្រងយុទ្ធសាស្ត្របច្ចេកវិទ្យាព័ត៌មាន
អនុប្រធាននាយកប្រតិបត្តិជាន់ខ្ពស់ និងជាគណៈប្រធាននាយកប្រតិបត្តិហិរញ្ញវត្ថុ និងគណៈប្រធាននាយកប្រតិបត្តិប្រតិបត្តិការ
នាយកដ្ឋានប្រតិបត្តិការ
នាយកដ្ឋានគ្រប់គ្រងសេវាឥណទាន
នាយកដ្ឋានទីផ្សារ
នាយកដ្ឋានអភិវឌ្ឍន៍ផលិតផល
នាយកដ្ឋានសេវាហិរញ្ញវត្ថុ
នាយកដ្ឋានផែនការយុទ្ធសាស្ត្រ
ការិយាល័យហិរញ្ញប្បទានពាណិជ្ជកម្ម
នាយកដ្ឋានហិរញ្ញវត្ថុ
នាយកដ្ឋានរៀបចំ និងត្រួតពិនិត្យផែនការថវិកា
នាយកដ្ឋានវិនិយោគសាធារណៈ
ការិយាល័យគណនេយ្យគ្រប់គ្រង
អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិរតនាភិបាល
នាយកដ្ឋានប្រតិបត្តិការហិរញ្ញវត្ថុ
ការិយាល័យរតនាភិបាល
ការិយាល័យប្រាក់កម្ចី និងអត្រាប្តូរប្រាក់
ការិយាល័យរតនាពាណិជ្ជកម្ម
អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិអភិបាលកិច្ច
នាយកដ្ឋានធនធានមនុស្ស
នាយកដ្ឋានរដ្ឋបាល
អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិនីតិកម្ម និងលេខាធិការក្រុមហ៊ុន
នាយកដ្ឋាននីតិកម្ម
នាយកដ្ឋានលេខាធិការក្រុមហ៊ុន និងបង្ហាញព័ត៌មាន
ការិយាល័យប្រឹក្សាច្បាប់
ការិយាល័យគ្រប់គ្រងវិវាទ
អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិព័ត៌មានវិទ្យា
នាយកដ្ឋានគ្រប់គ្រងសេវាកម្មផ្ទេរប្រាក់
នាយកដ្ឋានសន្តិសុខព័ត៌មានវិទ្យា
នាយកដ្ឋានប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ
នាយកដ្ឋានរៀបចំយុទ្ធសាស្ត្រ និងអភិបាលព័ត៌មានវិទ្យា
នាយកដ្ឋានគ្រប់គ្រងសេវាកម្មឌីជីថល
ការិយាល័យសេវាកម្មព័ត៌មានវិទ្យា
អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិហានិភ័យ
នាយកដ្ឋានគ្រប់គ្រងហានិភ័យ
នាយកដ្ឋានឥណទាន
នាយកដ្ឋានវិភាគទិន្នន័យឥណទាន
ការិយាល័យត្រួតពិនិត្យឥណទាន
គណៈប្រធាននាយកប្រតិបត្តិជាន់ខ្ពស់សវនកម្មផ្ទៃក្នុង
នាយកដ្ឋានអភិវឌ្ឍន៍សវនកម្មផ្ទៃក្នុង
នាយកដ្ឋានសវនកម្មប្រព័ន្ធព័ត៌មានវិទ្យា
ការិយាល័យសវនកម្មឥណទាន
ការិយាល័យសវនកម្មហិរញ្ញវត្ថុ
ការិយាល័យសវនកម្មប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម
ការិយាល័យរបាយការណ៍សវនកម្ម
នាយកដ្ឋានអនុលោមភាពបញ្ញត្តិ
២៦៤ សាខា គ្របដណ្តប់ទូទាំងប្រទេស

# ខ. ក្រុមប្រឹក្សាភិបាល

## សមាសភាពក្រុមប្រឹក្សាភិបាល

| ល.រ | ឈ្មោះអភិបាល | តំណែង | កាលបរិច្ឆេទក្លាយជាអភិបាល | កាលបរិច្ឆេទបញ្ចប់អាណត្តិ |
|---|---|---|---|---|
| ១ | **លោក ឆាយ សឿន** | ប្រធានក្រុមប្រឹក្សាភិបាល | ១៨ សីហា ២០១៤ | ១៨ សីហា ២០២៦ |
| ២ | **បណ្ឌិត អ៊ិន ចាន់នី** | អភិបាលប្រតិបត្តិ | ១៨ សីហា ២០១៤ | ១៨ សីហា ២០២៦ |
| ៣ | **លោក Pieter Kooi** | អភិបាលឯករាជ្យ | ១២ មករា ២០០៤ | ១២ មករា ២០២៥ |
| ៤ | **បណ្ឌិត ហេង ឌីណា** | អភិបាលឯករាជ្យ | ១១ ធ្នូ ២០២៣ | ១១ ធ្នូ ២០២៦ |
| ៥ | **លោកស្រី ភូរិ រតនា** | អភិបាលឯករាជ្យ | ០៨ វិច្ឆិកា ២០២១ | ០៨ វិច្ឆិកា ២០២៤ |
| ៦ | **លោក Stéphane Mangiavacca** | អភិបាលមិនប្រតិបត្តិ | ២២ មេសា ២០២០ | ២១ សីហា ២០២៤ |
| ៧ | **លោក Kyosuke Hattori** | អភិបាលមិនប្រតិបត្តិ | ០៨ វិច្ឆិកា ២០២១ | ០៦ ធ្នូ ២០២៥ |
| ៨ | **បណ្ឌិត Albertus Bruggink** | អភិបាលមិនប្រតិបត្តិ | ១២ ឧសភា ២០២១ | ១០ មករា ២០២៥ |
| ៩ | **លោក កាយ ឡូត** | អភិបាលមិនប្រតិបត្តិ | ១២ ឧសភា ២០២១ | ១២ ឧសភា ២០២៤ |

សម្គាល់៖ លោក វ៉ាន់ ស៊ូអៀង ដែលជាអភិបាលឯករាជ្យរបស់ ធនាគារ អេស៊ីលីដា បានចូលនិវត្តន៍នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៣។

ឈ្មោះលេខាធិការ ធនាគារ អេស៊ីលីដា ភីអិលស៊ី៖ លោកស្រី ប៊ុត ប៊ុនសីហា, លោក សេន សុខឡា, លោកស្រី ទេព សរចិន្តា

# គ. គណៈកម្មាធិការប្រតិបត្តិ

| ល.រ | ឈ្មោះ | ភេទ | តំណែង |
|---|---|---|---|
| ១ | **បណ្ឌិត អ៊ិន ចាន់នី** | ប្រុស | ប្រធាននាយកប្រតិបត្តិ |
| ២ | **បណ្ឌិត សូ ផនណារី** | ស្រី | អនុប្រធាននាយកប្រតិបត្តិជាន់ខ្ពស់ និងជាគណៈប្រធាននាយិកាប្រតិបត្តិប្រតិបត្តិការ (បានចូលនិវត្តន៍នៅថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០២៣) |
| ៣ | **លោកស្រី ម៉ារ អមរា** | ស្រី | អនុប្រធាននាយកប្រតិបត្តិជាន់ខ្ពស់ និងជាគណៈប្រធាននាយិកាប្រតិបត្តិហិរញ្ញវត្ថុ និងគណៈប្រធាននាយិកាប្រតិបត្តិប្រតិបត្តិការ (បានតែងតាំងនៅថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០២៣) |
| ៤ | **លោក ឃិន វីរៈ** | ប្រុស | អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិរតនាភិបាល |
| ៥ | **លោក លី ថៃ** | ប្រុស | អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិអភិបាលកិច្ច |
| ៦ | **លោកស្រី ប៊ុត ប៊ុនសីហា** | ស្រី | អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយិកាប្រតិបត្តិនីតិកម្ម និងលេខាធិការក្រុមហ៊ុន |
| ៧ | **លោក ម៉ាច់ ធារី** | ប្រុស | អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិព័ត៌មានវិទ្យា |
| ៨ | **បណ្ឌិត ឡឹង សុភាព** | ប្រុស | អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិហានិភ័យ |

សម្គាល់៖ ព័ត៌មានលម្អិតពាក់ព័ន្ធអភិបាលកិច្ចសាជីវកម្មមានភ្ជាប់ជាឧបសម្ព័ន្ធ។

# ផ្នែកទី ៤

## ព័ត៌មានអំពីការជួញដូរមូលបត្រ
## និងភាគហ៊ុនរបស់ធនាគារ អេស៊ីលីដា



# ក. ព័ត៌មានអំពីមូលបត្រ

## ១. ព័ត៌មានអំពីមូលបត្រកម្មសិទ្ធិ (ករណីចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ)

| | |
|---|---|
| ឈ្មោះមូលបត្រកម្មសិទ្ធិ | មូលបត្រកម្មសិទ្ធិធម្មតា |
| និមិត្តសញ្ញាមូលបត្រកម្មសិទ្ធិ | ធអភ (ABC) |
| ចំណាត់ថ្នាក់នៃមូលបត្រកម្មសិទ្ធិ | មូលបត្រកម្មសិទ្ធិដែលមានសិទ្ធិបោះឆ្នោត |
| តម្លៃចារឹកក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ | ៤.០០០ រៀល |
| ថ្លៃលក់ក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (IPO Price) | ១៦.២០០ រៀល |
| បរិមាណមូលបត្រកម្មសិទ្ធិសរុបទាំងអស់ដែលកំពុងធ្វើចរាចរលើទីផ្សារ | ៤៣៣.១៦៣.០១៩ ភាគហ៊ុន |
| មូលធនូបនីយកម្មទីផ្សារ (គិតជាលានរៀល) | ៤.៣៥៧.៦២០ |
| ឈ្មោះទីផ្សារមូលបត្រប្រតិស្រុត | ផ្សារមូលបត្រកម្ពុជា កាលបរិច្ឆេទនៃការចុះបញ្ជីលក់មូលបត្រ៖ ២៥ ឧសភា ២០២០ |

## ២. ព័ត៌មានអំពីមូលបត្របំណុល (ករណីចុះបញ្ជីលក់មូលបត្របំណុល)៖ មិនមាន

# ខ. ថ្លៃ និងបរិមាណជួញដូរមូលបត្រ

| មូលបត្រកម្មសិទ្ធិ (២០២៣) | | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ថ្លៃជួញដូរ | អតិបរមា | ១០.៨៦០ | ១១.៥២០ | ១១.៤០០ | ១១.៦០០ | ១១.៤០០ | ១០.២៦០ | ១០.២៦០ | ១០.១២០ | ១០.០២០ | ១០.០០០ | ៩.៧០០ | ១០.២០០ |
| | មធ្យម | ១០.៨៤៣ | ១១.០៥៥ | ១១.១៦៨ | ១១.៣០៦ | ១០.៤១១ | ១០.២១៧ | ១០.១២៩ | ១០.០៥០ | ១០.០១៥ | ៩.៨៣៨ | ៩.៦១៨ | ៩.៧៦៩ |
| | អប្បបរមា | ១០.៧៦០ | ១០.៨២០ | ១០.៧៨០ | ១១.០២០ | ១០.២០០ | ១០.១៤០ | ១០.០៤០ | ៩.៩៨០ | ៩.៩៨០ | ៩.១៤០ | ៩.៤៦០ | ៩.៥៤០ |
| បរិមាណជួញដូរ | អតិបរមា | ៧៣.៦១៣ | ១៦៦.៧១០ | ២៤៦.៦១២ | ៣១៩.៩៦៨ | ៣១៩.៤០៩ | ១២៧.៨៤១ | ១១៥.២៩៧ | ១៥១.១០៨ | ៧៨.០៧៥ | ១៨៤.៦៣៦ | ៧៦.២៦២ | ១១៣.១៣៥ |
| | មធ្យម | ៤៣.៨៨៣ | ៥៥.៥៥៥ | ៧៦.១២៥ | ៨៨.៧៨៧ | ១០៥.៧៩២ | ៥៦.៦៥៦ | ៤៩.២៣៣ | ៥៨.១១៥ | ៣៩.២៦៨ | ៥៤.១៤៨ | ២៩.៥២៥ | ៣៧.៩៨៦ |
| | អប្បបរមា | ១៤.៣៣៩ | ១៨.៥២៣ | ១១.៦១៩ | ២២.០៨០ | ២៦.១១៩ | ២០.៣៦៥ | ២៣.៣៧០ | ២០.៩៣៩ | ៨.១០១ | ៧.៨០៤ | ៧.៤៧៤ | ១០.២២៩ |

## គ. ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ (ចាប់ពី ៣០% ឡើងទៅ)៖ មិនមាន

## ឃ. ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើន (ចាប់ពី ៥% ដល់តិចជាង ៣០%)

| ឈ្មោះ | សញ្ជាតិ | ចំនួនមូលបត្រ | ភាគរយ |
|---|---|---|---|
| អេស៊ីលីដា ហ្វាយណាន់ហ្សល់ ត្រាស់ | ខ្មែរ | ១១៨.២៨៨.៩៩២ | ២៧,២៩៩០% |
| Sumitomo Mitsui Banking Corporation | ជប៉ុន | ៧៨.២៥៩.៣១០ | ១៨,០៦៦៩% |
| COFIBRED | បារាំង | ៥២.៥៣០.២២៣ | ១២,១២៧១% |
| ORIX Corporation | ជប៉ុន | ៥២.៥៣០.២២៣ | ១២,១២៧១% |
| ភាគហ៊ុនិកដែលធ្វើនិយ័តកម្មពីក្រុមហ៊ុន អេ អេស អេ ភីអិលស៊ី | ខ្មែរ | ២៤.៩១៦.៨០៨ | ៥,៧៥២៣% |
| **សរុប** | | **៣២៦.៤៨៥.៥៥៦** | **៧៥,៣៧២៤%** |

## ង. ព័ត៌មានអំពីការបែងចែកភាគលាភក្នុងរយៈពេល ៣ឆ្នាំចុងក្រោយ

| ពិពណ៌នាលម្អិតអំពីការបែងចែកភាគលាភ | ២០២២ | ២០២១ | ២០២០ |
|---|---|---|---|
| ប្រាក់ចំណេញដែលផ្តល់ជូនដល់ភាគហ៊ុនិករបស់ធនាគារ (លានរៀល) | ៧៤២.៧៦៥ | ៦៧៩.០០២ | ៥៧៦.៨៦៥ |
| ភាគលាភជាសាច់ប្រាក់សរុប (លានរៀល) | ២៩៧.១០៦ | ២៣៧.៦៥១ | ១៧២.៩៤៨ |
| ភាគលាភជាមូលបត្រកម្មសិទ្ធិសរុប (លានរៀល) | - | - | - |
| ភាគលាភផ្សេងទៀត | - | - | - |
| អនុបាតនៃការបែងចែកភាគលាភ (%) | ៤០% | ៣៥% | ៣០% |
| ទិន្នផលភាគលាភ (%) | *៦,៣៤% | ៥,២២% | ២,៣៣% |
| ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (រៀល) | ៦៨៦ | ៥៤៩ | ៣៩៩ |

* ថ្លៃបិទទីផ្សារប្រចាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ គឺ១០.៨២០រៀល
* ថ្លៃបិទទីផ្សារប្រចាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ គឺ១០.៥២០រៀល
* ថ្លៃបិទទីផ្សារប្រចាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ គឺ១៧.១០០រៀល

. ទិន្នផលភាគលាភ = ភាគលាភក្នុងមួយភាគហ៊ុន/តម្លៃបច្ចុប្បន្នរបស់ភាគហ៊ុន (៣១/១២/២០XX)

. អនុបាតនៃការបែងចែកភាគលាភ = ភាគលាភក្នុងមួយភាគហ៊ុន/ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ

# ផ្នែកទី ៥

## របាយការណ៍សវនកម្ម របស់សវនករ ផ្ទៃក្នុងលើការត្រួតពិនិត្យផ្ទៃក្នុង

# I. សេចក្តីផ្តើម

ប្រសិទ្ធភាពនៃអភិបាលកិច្ចការគ្រប់គ្រងហានិភ័យ និងការត្រួតពិនិត្យផ្ទៃក្នុងត្រូវបានធានាមានគោលបំណងច្បាស់លាស់ប្រកបដោយឯករាជ្យភាព តាមរយៈការធ្វើសវនកម្មផ្ទៃក្នុង ផ្តល់នូវការពិគ្រោះយោបល់ ដ៏មានគុណតម្លៃ ក្នុងការកែលម្អប្រតិបត្តិការធនាគារ។ ដើម្បីគាំទ្រធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធឱ្យសម្រេចបាននូវគោលបំណង វិធីសាស្រ្តជាប្រព័ន្ធ វាយតម្លៃដ៏ច្បាស់លាស់ និងបង្កើនប្រសិទ្ធភាពលើការគ្រប់គ្រងហានិភ័យ ការគ្រប់គ្រង និងអភិបាលកិច្ច មុខងារសវនកម្មផ្ទៃក្នុងត្រូវបានរៀបចំឡើង និងដឹកនាំដោយគណៈប្រធាននាយិការប្រតិបត្តិជាន់ខ្ពស់សវនកម្មផ្ទៃក្នុង ត្រូវបានចាត់តាំង និងធ្វើការទំនាក់ទំនង ព្រមទាំងរាយការណ៍ដោយផ្ទាល់ជូនគណៈកម្មាធិការសវនកម្ម ។

# II. វិសាលភាពនៃមុខងារសវនកម្មផ្ទៃក្នុង

វិសាលភាពនៃសកម្មភាពសវនកម្មផ្ទៃក្នុង រួមមានការងារស្នូលចំនួនបី ប្រភេទដែលប្រកបដោយវិធីសាស្រ្តអនុវត្តលក្ខណៈជាប្រព័ន្ធ និងមាននិយមន័យច្បាស់លាស់ក្នុងការត្រួតពិនិត្យ និងវាយតម្លៃប្រព័ន្ធត្រួតពិនិត្យគ្រប់គ្រងផ្ទៃក្នុង ទស្សនវិស័យនៃការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិការធនាគារ មានដូចជា៖

- **ត្រួតពិនិត្យការអនុវត្តគោលការណ៍**: គឺការធ្វើសវនកម្មលើការអនុវត្តន៍គោលការណ៍ គោលការណ៍ប្រតិបត្តិ នីតិវិធី និងសេចក្តីណែនាំផ្សេងៗ តាមរយៈការធ្វើតេស្តប៉ាន់គំរូសវនកម្មដើម្បីផ្តល់នូវការធានាដ៏មានប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងប្រតិបត្តិតាមបទប្បញ្ញត្តិ អោយបានត្រឹមត្រូវ និងគ្រប់ជ្រុងជ្រោយ ដែលជាមូលដ្ឋានគ្រឹះទប់ស្កាត់ កាត់បន្ថយហានិភ័យ ។

- **សវនកម្មប្រព័ន្ធព័ត៌មាន**: គឺជាការធ្វើសវនកម្មលើទិន្នន័យ និងសុវត្ថិភាពប្រព័ន្ធព័ត៌មានវិទ្យា រួមមានការប្រើប្រាស់ការរក្សាការសម្ងាត់ និងភាពទូលំទូលាយនៃទិន្នន័យ ដើម្បីផ្តល់ការធានានូវភាពជឿទុកចិត្ត និងប្រសិទ្ធភាពនៃការគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា និងអនុវត្តគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងហានិភ័យព័ត៌មានវិទ្យា របស់ធនាគារជាតិ នៃកម្ពុជា ។

- **សវនកម្មអង្កេតប្រតិបត្តិការ**: គឺជាការត្រួតពិនិត្យលម្អិតឱ្យបានហ្មត់ចត់លើប៉ាន់គំរូសវនកម្ម ដែលមានសញ្ញាណនៃការក្លែងបន្លំទាំងខាងក្នុង និងខាងក្រៅដើម្បីផ្តល់ការធានានូវការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព និងរឹងមាំការពារការក្លែងបន្លំ ទំនាស់ផលប្រយោជន៍ និងការពារធនធនទ្រព្យសកម្មរបស់ធនាគារ ។

# III. សេចក្តីសង្ខេបនៃការអនុវត្តកិច្ចការសវនកម្មផ្ទៃក្នុង ឆ្នាំ២០២៣

ការប្រតិបត្តិសវនកម្មផ្ទៃក្នុង ត្រូវបានកំណត់ដោយផែនការសកម្មភាពដាក់ជូនគណៈកម្មាធិការសវនកម្ម ដើម្បីអនុម័តការអនុវត្ត ផែនការសវនកម្ម ការទំនាក់ទំនងពិភាក្សាលទ្ធផលសវនកម្ម ការផ្តល់របាយការណ៍សវនកម្ម និងតាមដានវិធានការកែតម្រូវរបស់ ថ្នាក់គ្រប់គ្រង ។

ផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ ២០២៣ ត្រូវបានបង្កើតឡើងដោយផ្អែកលើវិធីសាស្រ្តវាយតម្លៃហានិភ័យដ៏ទូលំទូលាយ ដើម្បីស្របតាមយុទ្ធសាស្រ្តធនាគារ ដើម្បីកំណត់ឱ្យបានច្បាស់នូវគោលបំណងសវនកម្ម និងវិសាលភាពនៃគម្រោងកិច្ចនីមួយៗ។ គណៈកម្មាធិការសវនកម្មបានអនុម័តផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ គួបផ្សំដោយថវិកាសមស្របដើម្បីគាំទ្រដល់សកម្មភាពសវនកម្ម រួមទាំងធនធានមនុស្ស និងការអភិវឌ្ឍន៍ចំណេះដឹងជំនាញ ។

ផែនការសកម្មភាពសវនកម្មឆ្នាំ២០២៣ ត្រូវបានអនុម័តដោយគណៈកម្មាធិការសវនកម្ម រួមមានគម្រោងកិច្ចសវនកម្មត្រួតពិនិត្យការអនុវត្តគោលការណ៍ចំនួន ៧០ សវនកម្មអង្កេតប្រតិបត្តិការចំនួន ៣២ និងសវនកម្មសន្តិសុខព័ត៌មានវិទ្យាចំនួន ១៦ ត្រូវប្រតិបត្តិគ្រប់សវនដ្ឋានទាំងអស់ក្នុងធនាគាររួមមានការិយាល័យកណ្តាល និងកម្រិតសាខា ដោយអនុវត្តទៅតាមប្រធានបទសវនកម្មដូចជា សវនកម្មគ្រប់គ្រងហានិភ័យ សវនកម្មធនធានមនុស្ស សវនកម្មគ្រប់គ្រងការិយាល័យ សវនកម្មឥណទាន សវនកម្មធនាគារឌីជីថល សវនកម្មកោសល្យវិច្ច័យ សវនកម្មសន្តិសុខព័ត៌មានវិទ្យា សវនកម្មហិរញ្ញវត្ថុ សវនកម្មហានិភ័យទីផ្សារ សវនកម្មក្របខ័ណ្ឌគ្រប់គ្រងហានិភ័យសន្ទនីយភាព សវនកម្មប្រតិបត្តិការ និងសវនកម្មប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។

បញ្ហាសំខាន់ៗត្រូវបានកំណត់ច្បាស់លាស់នៅក្នុងរបាយការណ៍សវនកម្មផ្ទៃក្នុង ដើម្បីផ្តល់យោបល់ជូនថ្នាក់គ្រប់គ្រង រៀបចំកែលម្អរឲ្យបានសមស្រប និងទាន់ពេលវេលា ដូចជាការអភិវឌ្ឍគោលការណ៍ គោលការណ៍ប្រតិបត្តិ និងនីតិវិធី ព្រមទាំងពង្រឹង និងហ្វឹកហ្វឺនដល់ថ្នាក់គ្រប់គ្រង និងបុគ្គលិកដែលពាក់ព័ន្ធ ។

របាយការណ៍សវនកម្មផ្ទៃក្នុងសរុបប្រចាំខែត្រូវបានរាយការណ៍ជូនគណៈកម្មាធិការសវនកម្ម និងចម្លងជូនទៅថ្នាក់ដឹកនាំជាន់ខ្ពស់ ដែលខ្លឹមសារនៃរបាយការណ៍រួមមាន ផែនការសកម្មភាពក្នុងការពង្រឹងដោយថ្នាក់គ្រប់គ្រង ដើម្បីធ្វើការតាមដានការកែតម្រូវការរកឃើញ។

# IV. សេចក្តីសន្និដ្ឋាន

ផែនការគម្រោងកិច្ចសវនកម្មផ្ទៃក្នុងឆ្នាំ២០២៣ បានសម្រេចជោគជ័យ ដោយអនុវត្តបានយ៉ាងតឹងរឹងនូវ មូលដ្ឋានហានិភ័យគ្រប់ប្រធានបទ និងសវនដ្ឋាន ដើម្បីផ្តល់នូវយោបល់ស្តីពីការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាពលើការគ្រប់គ្រងហានិភ័យ ដំណើរការត្រួតពិនិត្យផ្ទៃក្នុងនិងនីតិវិធី និងការគ្រប់គ្រងទៅតាមបទប្បញ្ញត្តិ ។

ជាការឆ្លើយតបនឹងអនុសាសន៍សវនកម្ម ថ្នាក់គ្រប់គ្រងបានយល់ស្រប និងរៀបចំផែនការសកម្មភាពកែលម្អដើម្បីបង្កើនប្រសិទ្ធភាពប្រព័ន្ធត្រួតពិនិត្យ ប្រតិបត្តិការធនាគារពីមួយថ្ងៃទៅមួយថ្ងៃ ។

ផ្អែកលើសមិទ្ធិផលនៃការអនុវត្តកិច្ចការសវនកម្មផ្ទៃក្នុងឆ្នាំ២០២៣ យើងសន្និដ្ឋានបានថាក្របខ័ណ្ឌអភិបាលកិច្ច ការគ្រប់គ្រងហានិភ័យ និងការគ្រប់គ្រងលើការត្រួតពិនិត្យ ត្រូវបានរៀបចំឡើងប្រកបដោយប្រសិទ្ធភាពស្របតាម បទប្បញ្ញត្តិនានា គោលការណ៍ផ្ទៃក្នុង និងនីតិវិធីរបស់ធនាគារ ។

បានអាន និងឯកភាព
ភ្នំពេញ ថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២៤



លោកស្រី ភូរិ រតនា
ប្រធានគណៈកម្មាធិការសវនកម្ម



លោកស្រី គឹម សុធារី
គណៈប្រធាននាយិកាប្រតិបត្តិជាន់ខ្ពស់សវនកម្មផ្ទៃក្នុង

# ផ្នែកទី ៦

## របាយការណ៍ហិរញ្ញវត្ថុ ដែលធ្វើសវនកម្ម ដោយសវនករឯករាជ្យ

សូមពិនិត្យមើលឧបសម្ព័ន្ធដែលបានភ្ជាប់មកជាមួយ
របាយការណ៍ហិរញ្ញវត្ថុដែលធ្វើសវនកម្មដោយសវនករឯករាជ្យ

# ផ្នែកទី ៧

## ព័ត៌មានអំពីប្រតិបត្តិការជាមួយភាគី
## ជាប់ពាក់ព័ន្ធនឹងទំនាស់ផលប្រយោជន៍



បុគ្គលចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិត្រូវបង្ហាញពីព័ត៌មានប្រតិបត្តិការសំខាន់ៗជាមួយភាគីជាប់ពាក់ព័ន្ធនៅក្នុងរយៈពេល ២ (ពីរ) ឆ្នាំចុងក្រោយ ដោយបញ្ជាក់ពីឈ្មោះ ទំនាក់ទំនងរវាងបុគ្គលចុះបញ្ជីលក់មូលបត្រ និងភាគីជាប់ពាក់ព័ន្ធ ទំហំនៃប្រតិបត្តិការ និងប្រភេទនៃផលប្រយោជន៍ដែលកើតចេញពីទំនាក់ទំនងនោះ ដូចខាងក្រោម៖

## ក. ប្រតិបត្តិការសំខាន់ៗជាមួយភាគហ៊ុនិកដែលមានភាគហ៊ុនចាប់ពី ៥ (ប្រាំ) ភាគរយ ឡើងទៅ នៃមូលបត្រកម្មសិទ្ធិកំពុងធ្វើចរាចរលើទីផ្សារ

មានភាគហ៊ុនិកចំនួន ៥ ដែលកាន់កាប់ភាគហ៊ុនយ៉ាងតិច ៥% ឡើងទៅនៃមូលបត្រកម្មសិទ្ធិកំពុងធ្វើចរាចរលើទីផ្សារ ក្នុងនោះរួមមាន៖ (១) AFT (២) SMBC (៣) COFIBRED (៤) ORIX Corporation និង (៥) ភាគហ៊ុនិកដែលធ្វើនិយ័តកម្មពីក្រុមហ៊ុន អេ អេស អេ ភីអិលស៊ី។

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ធនាគារ អេស៊ីលីដា មានប្រតិបត្តិការសំខាន់ៗជាមួយភាគហ៊ុនិកដែលមានភាគហ៊ុនចាប់ពី ៥ (ប្រាំ) ភាគរយឡើងទៅ នៃមូលបត្រកម្មសិទ្ធិកំពុងធ្វើចរាចរលើទីផ្សារដូចខាងក្រោម៖

| បរិយាយ | ២០២៣ | | ២០២២ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **សមតុល្យជាមួយសម្ព័ន្ធញាតិ** | **៦៥៥.៩៩១** | **២.៦៧៩.៧២៣** | **៧២៥.៣៨៨** | **២.៩៨៦.៤២២** |
| SMBC | ៦៥៥.៩៩១ | ២.៦៧៩.៧២៣ | ៧២៥.៣៨៨ | ២.៩៨៦.៤២២ |
| **គណនីត្រូវទូទាត់** | **(៧៥៥.៩០៣)** | **(៣.០៨៧.៨៦៤)** | **(៤៨៨.៩៣០)** | **(២.០១២.៩២៤)** |
| AFT | (១២៦.៨៤៣) | (៥១៨.១៥៤) | (៥១.៧០៥) | (២១២.៨៦៩) |
| ASA Plc. | (៦២៩.០៦០) | (២.៥៦៩.៧១០) | (៤៣៧.២២៥) | (១.៨០០.០៥៥) |
| **ប្រាក់បញ្ញើ** | **៤.២៥៨.១៨២** | **១៧.៣៩៤.៦៧៤** | **១០.១៦៧.៦២៣** | **៤១.៨៦០.១០៣** |
| AFT | **៤.២០៦.៥៧១** | **១៧.១៨៣.៨៤៣** | **៩.៩៥៥.៦៩៩** | **៤០.៩៨៧.៦១២** |
| គណនីចរន្ត | ២.៦៣៧.១១៧ | ១០.៧៧២.៦២៣ | ៦.២៦១.៩២២ | ២៥.៧៨០.៣៣៣ |
| គណនីបញ្ញើសំចៃ | ៦៨.០៣១ | ២៧៧.៩០៧ | ៧២៧.៣២៩ | ២.៩៩៤.៤១៣ |
| ប្រាក់បញ្ញើមានកាលកំណត់ | ១.៥០១.៤២៣ | ៦.១៣៣.៣១៣ | ២.៩៦៦.៤៤៨ | ១២.២១២.៨៦៦ |
| ASA Plc. | - | - | **១៧៥.២៧៦** | **៧២១.៦១៣** |
| គណនីបញ្ញើសំចៃ | - | - | ១៧៥.២៧៦ | ៧២១.៦១៣ |
| SMBC | **៥១.៦១១** | **២១០.៨៣១** | **៣៦.៦៤៨** | **១៥០.៨៨០** |
| គណនីចរន្ត | ៥១.៦១១ | ២១០.៨៣១ | ៣៦.៦៤៨ | ១៥០.៨៨០ |
| **ប្រាក់កម្ចីពីភាគហ៊ុនិក** | **៦៤.៥៨៥.៨៦៧** | **២៦៣.៨៣៣.២៦៧** | **៤៨.៨៤៧.៥២៨** | **២០១.១០៥.២៧៣** |
| SMBC | ៤៩.៤៩១.៦៥៩ | ២០២.១៧៣.៤២៧ | ៤៨.៨៤៧.៥២៨ | ២០១.១០៥.២៧៣ |
| AFT | ១៥.០៩៤.២០៨ | ៦១.៦៥៩.៨៤០ | - | - |
| **ចំណូលកម្រៃនិងជើងសា** | **១១៥** | **៤៧២** | **៤៥.៥១០** | **១៨៦.០០០** |
| AFT | ២២ | ៩០ | ៤០.៤០១ | ១៦៥.១១៩ |
| ASA Plc. | - | - | ៥.០៧៣ | ២០.៧៣៤ |
| SMBC | ៩៣ | ៣៨២ | ៣៦ | ១៤៧ |
| **ចំណាយការប្រាក់** | **៦.០៩២.៧០០** | **២៥.០៤០.៩៩៧** | **១.៨៨០.៥៤៥** | **៧.៦៨៥.៧៨៧** |
| AFT | ៧៩៥.៥៦៣ | ៣.២៦៩.៧៦៤ | ២៧២.១៣៨ | ១.១១២.២២៨ |
| ASA Plc. | - | - | ៩០៨ | ៣.៧១១ |
| SMBC | ៥.២៩៧.១៣៧ | ២១.៧៧១.២៣៣ | ១.៦០៧.៤៩៩ | ៦.៥៦៩.៨៤៨ |

## ខ. ប្រតិបត្តិការសំខាន់ៗជាមួយអភិបាល និងបុគ្គលិកជាន់ខ្ពស់

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ធនាគារ អេស៊ីលីដា មានប្រតិបត្តិការសំខាន់ៗជាមួយអភិបាល និងបុគ្គលិកជាន់ខ្ពស់ដូចខាងក្រោម៖

| បរិយាយ | ២០២៣ | | ២០២២ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ឥណទាននិងបុរេប្រទាន | ១០.៤៩៦.៧៧១ | ៤២.៨៧៩.៣០៩ | ១១.៥២៧.៥៥៤ | ៤៧.៤៥៨.៩៣៨ |
| ចំណូលការប្រាក់ | ៨៩៦.០១៩ | ៣.៦៨២.៦៣៨ | ៩០៤.១៥៤ | ៣.៦៩៥.២៧៧ |
| ប្រាក់បញ្ញើ | ៥.៤១៧.២៨៧ | ២២.១២៩.៦១៨ | ៤.២៦៥.០១៥ | ១៧.៥៩៩.០៦៧ |
| ចំណាយការប្រាក់ | ១១៨.៣០១ | ៤៨៦.២១៧ | ៤៩.០៣៤ | ២០០.៤០២ |
| ការប្រាក់ត្រូវបង់ | (៦២.៤៧៣) | (២៥៥.២០២) | (៤៦.១១៥) | (១៨៩.៨៥៦) |
| ចំណាយកម្រៃនិងជើងសា | ១១.៣៨៣.៣៥៨ | ៤៦.៦២១.២០២ | ១០.០៦៥.១៥៦ | ៤១.១៣៦.២៩២ |

## គ. ប្រតិបត្តិការជាមួយអភិបាល និងភាគហ៊ុនិកពាក់ព័ន្ធនឹងការទិញ-លក់ទ្រព្យសកម្ម និងសេវាកម្ម

គិតត្រឹមការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ធនាគារ អេស៊ីលីដា ពុំមានប្រតិបត្តិការជាមួយអភិបាល និងភាគហ៊ុនិកពាក់ព័ន្ធនឹងការទិញ-លក់ទ្រព្យសកម្ម និងសេវាកម្ម។

## ឃ. ប្រតិបត្តិការសំខាន់ៗជាមួយសមាជិកគ្រួសារផ្ទាល់របស់អភិបាល បុគ្គលិកជាន់ខ្ពស់ និងភាគហ៊ុនិកដែលមានភាគហ៊ុនចាប់ពី ៥ (ប្រាំ) ភាគរយឡើងទៅ

គិតត្រឹមការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ធនាគារ អេស៊ីលីដា មានប្រតិបត្តិការសំខាន់ៗជាមួយសមាជិកគ្រួសារផ្ទាល់របស់អភិបាល បុគ្គលិកជាន់ខ្ពស់ និងភាគហ៊ុនិកដែលមានភាគហ៊ុនចាប់ពី ៥ (ប្រាំ) ភាគរយឡើងទៅដូចខាងក្រោម៖

| បរិយាយ | ២០២៣ | | ២០២២ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ឥណទាននិងបុរេប្រទាន | ២.៥៧៧.៥៦២ | ១០.៥២៩.៣៤១ | ២.៦៤៤.២៩៩ | ១០.៨៨៦.៥៨១ |
| ប្រាក់បញ្ញើ | ២.៥៥២.២១៣ | ១០.៤២៥.៧៩០ | ១.៤៦៥.២៩៣ | ៦.០៣២.៦១១ |
| ការប្រាក់ត្រូវបង់ | (៣១.៤១០) | (១២៨.៣១០) | (១០.៧០៥) | (៤៤.០៧២) |

### ង. ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលិកដែលមានទំនាក់ទំនងជាមួយអភិបាលរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនហូលឌីងរបស់បុគ្គលចុះបញ្ជីលក់មូលបត្រដែលទំនាក់ទំនងរបស់បុគ្គលទាំងនោះកើតមាននៅក្នុងប្រតិបត្តិការ ឬការចាត់ចែងណាមួយដែលបានធ្វើឡើងដោយបុគ្គលចុះបញ្ជីលក់មូលបត្រ

គិតត្រឹមការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ធនាគារ អេស៊ីលីដា មានប្រតិបត្តិការសំខាន់ៗជាមួយក្រុមហ៊ុនបុត្រសម្ព័ន្ធដូចខាងក្រោម៖

| បរិយាយ | ២០២៣ | | ២០២២ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **សមតុល្យជាមួយសម្ព័ន្ធញាតិ** | **១៥.៨៧១** | **៦៤.៨៣៣** | - | - |
| ABL | ១៥.៨៧១ | ៦៤.៨៣៣ | - | - |
| **ចំណូលការប្រាក់** | **១៨.២៤៧** | **៧៤.៩៩៥** | **៦.២១៧** | **២៥.៤០៩** |
| ABL | ១៨.២៤៧ | ៧៤.៩៩៥ | ៦.២១៧ | ២៥.៤០៩ |
| **គណនីត្រូវទទួល** | **៤៤៩.៣៧៧** | **១.៨៣៥.៧០៥** | **២៥៩.៩១០** | **១.០៧០.០៤៩** |
| AMM | ២៤៦.៥៤២ | ១.០០៧.១២៤ | ២៥៩.៩១០ | ១.០៧០.០៤៩ |
| AIB | ២០២.៨៣៥ | ៨២៨.៥៨១ | - | - |
| **គណនីត្រូវទូទាត់** | **(១៨.៩៦០)** | **(៧៧.៤៥១)** | **(២៨.៧០៩)** | **(១១៨.១៩៥)** |
| ACS | (១៨.៩៤៥) | (៧៧.៣៩០) | (១៤.០៥៦) | (៥៧.៨៦៩) |
| AIB | (១៥) | (៦១) | (១៤.៦៥៣) | (៦០.៣២៦) |
| **ប្រាក់បញ្ញើ** | **៦.២១០.៥២៥** | **២៥.៣៦៩.៩៩៦** | **៧.៩៨៧.៤៨៤** | **៣២.៨៨៤.៤៧០** |
| ABL | **៣.៧៨៨.៦៥៤** | **១៥.៤៧៦.៦៥២** | **៤.២០៨.៩០០** | **១៧.៣២៨.០៤១** |
| គណនីចរន្ត | ៣.៧៨៨.៦៥៤ | ១៥.៤៧៦.៦៥២ | ៤.២០៨.៩០០ | ១៧.៣២៨.០៤១ |
| ACS | **២.៣១១.១៨៩** | **៩.៤៤១.២០៨** | **២.៥២៨.២៦១** | **១០.៤០៨.៨៥០** |
| គណនីបញ្ញើសំចៃ | ២៥១.២៨៩ | ១.០២៦.៥១៦ | ២៥៨.៣៨៨ | ១.០៦៣.៧៨៣ |
| បញ្ញើមានកាលកំណត់ | ២.០៥៩.៩០០ | ៨.៤១៤.៦៩២ | ២.២៦៩.៨៧៣ | ៩.៣៤៥.០៦៧ |
| AIB | **១១០.៦៨២** | **៤៥២.១៣៦** | **១.២៥០.៣២៣** | **៥.១៤៧.៥៧៩** |
| គណនីចរន្ត | ៥២.៤០៥ | ២១៤.០៧៤ | ៦៥.៦៧០ | ២៧០.៣៦៣ |
| បញ្ញើមានកាលកំណត់ | ៥៨.២៧៧ | ២៣៨.០៦២ | ១.១៨៤.៦៥៣ | ៤.៨៧៧.២១៦ |
| **ចំណូលកម្រៃនិងជើងសា** | **២៦.៩៧៤** | **១១០.៨៦២** | **៩៨៨** | **៤.០៣៧** |
| ABL | **១៣** | **៥៣** | **១៣** | **៥៣** |
| កម្រៃសេវាធនាគារ | ១៣ | ៥៣ | ១៣ | ៥៣ |
| ACS | **២.៩២១** | **១២.០០៥** | **៦០៣** | **២.៤៦៤** |
| កម្រៃសេវាធនាគារ | ២.៩២១ | ១២.០០៥ | ៦០៣ | ២.៤៦៤ |
| AIB | **២៤.០៤០** | **៩៨.៨០៤** | **៣៧២** | **១.៥២០** |
| កម្រៃសេវាធនាគារ | ២៤.០៤០ | ៩៨.៨០៤ | ៣៧២ | ១.៥២០ |
| **ចំណាយការប្រាក់** | **២០៨.១០១** | **៨៥៥.២៩៥** | **២២២.៧៦៦** | **៩១០.៤៤៤** |
| ACS | ១៦៤.២០១ | ៦៧៤.៨៦៦ | ១៥៣.១៤៣ | ៦២៥.៨៩៥ |
| AIB | ៤៣.៩០០ | ១៨០.៤២៩ | ៦៩.៦២៣ | ២៨៤.៥៤៩ |
| **ចំណាយកម្រៃនិងជើងសា** | **១.៩៦៣.១២៦** | **៨.០៦៨.៤៤៨** | **៣.១៤៧.៧៤៧** | **១២.៨៦៤.៨៤២** |
| AIB | ១.៩៦៣.១២៦ | ៨.០៦៨.៤៤៨ | ៣.១៤៧.៧៤៧ | ១២.៨៦៤.៨៤២ |
| **កិច្ចសន្យាផ្សេងៗ** | **(១៧.៦៧៥)** | **(៧២.៦៤៤)** | **(៦៤.១១៤)** | **(២៦២.០៣៤)** |
| AIB | (១៧.៦៧៥) | (៧២.៦៤៤) | (៦៤.១១៤) | (២៦២.០៣៤) |

## ច. ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលធ្លាប់ជាអភិបាល ឬបុគ្គលជាប់ពាក់ព័ន្ធជាមួយបុគ្គលធ្លាប់ជាអភិបាល

គិតត្រឹមការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ធនាគារ អេស៊ីលីដា មានប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលធ្លាប់ជាអភិបាល ឬបុគ្គលជាប់ពាក់ព័ន្ធជាមួយបុគ្គលធ្លាប់ជាអភិបាលដូចខាងក្រោម៖

| បរិយាយ | ២០២៣ | | ២០២២ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ឥណទាននិងបុរេប្រទាន | ៤៣៣.៤៨៦ | ១.៧៧០.៧៩០.៣១០ | - | - |
| ប្រាក់បញ្ញើ | ១.៦៤១.៦៨០ | ៦.៧០៦.២៦២.៨០០ | - | - |
| ការប្រាក់ត្រូវបង់ | ៤.៨៣០ | ១៩.៧៣០.៥៥០ | - | - |
| ចំណាយការប្រាក់ | ៩៦.៥២៧ | ៣៩៤.៣១២.៧៩៥ | - | - |
| ចំណូលការប្រាក់ | ២២.៦៣៥ | ៩២.៤៦៣.៩៧៥ | - | - |
| ចំណាយកម្រៃនិងជើងសា | ៥៨.០២២ | ២៣៧.០១៩.៨៧០ | - | - |

## ឆ. ប្រតិបត្តិការសំខាន់ៗជាមួយអភិបាលដែលបានកាន់មុខតំណែងណាមួយនៅក្នុងសមាគម ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ឬនៅក្នុងក្រុមហ៊ុនណាមួយផ្សេងទៀតក្រៅពីបុគ្គលចុះបញ្ជីលក់មូលបត្រ

គិតត្រឹមការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ធនាគារ អេស៊ីលីដា មានប្រតិបត្តិការសំខាន់ៗជាមួយអភិបាលដែលកាន់មុខតំណែងណាមួយនៅក្នុងសមាគម ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ឬនៅក្នុងក្រុមហ៊ុនណាមួយផ្សេងទៀតក្រៅពីបុគ្គលចុះបញ្ជីលក់មូលបត្រដូចខាងក្រោម៖

| បរិយាយ | ២០២៣ | | ២០២២ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ឥណទាននិងបុរេប្រទាន | ១២ | ៤៩ | - | - |
| ប្រាក់បញ្ញើ | ៤៨៩.៧៧៤ | ២.០០០.៧២៧ | - | - |
| ការប្រាក់ត្រូវបង់ | ៣.៨៨៧ | ១៥.៨៧៨ | - | - |
| ចំណាយការប្រាក់ | ៥០១ | ២.០៤៧ | - | - |
| ចំណាយកម្រៃនិងជើងសា | ២៨៧.១០៦ | ១.១៧២.៨២៨ | - | - |

## ជ. ប្រតិបត្តិការសំខាន់ៗជាមួយអភិបាលដែលទទួលបានផលប្រយោជន៍ពីបុគ្គលចុះបញ្ជីលក់មូលបត្រទោះជាហិរញ្ញវត្ថុ ឬមិនមែនហិរញ្ញវត្ថុ

គិតត្រឹមការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ មានអភិបាលប្រតិបត្តិ អភិបាលមិនប្រតិបត្តិ និងអភិបាលឯករាជ្យ ដែលទទួលបានផលប្រយោជន៍ ទោះជាហិរញ្ញវត្ថុ ឬមិនមែនហិរញ្ញវត្ថុពីធនាគារ មានដូចខាងក្រោម៖

| បរិយាយ | ២០២៣ | | ២០២២ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ឥណទាននិងបុរេប្រទាន | ១២ | ៤៩ | ៦២.៣៤៨ | ២៥៦.៦៨៧ |
| ប្រាក់បញ្ញើ | ២.៣៧៧.២៨៩ | ៩.៧១១.០១១ | ២.៧២៣.៣៨៥ | ១១.២១២.០១១ |
| ការប្រាក់ត្រូវបង់ | (១៧.២៤៦) | (៧០.៤៥០) | (១២.៦៨៣) | (៥២.២១៨) |
| ចំណាយកម្រៃនិងជើងសា | ៥៨៩.៥៧៨ | ២.៤២៣.១៦៦ | ៥០៣.០៧៣ | ២.០៥៦.០៥៩ |

# ផ្នែកទី ៨

## ការពិភាក្សា និងការវិភាគរបស់ គណៈគ្រប់គ្រង



ការពិភាក្សា និងការវិភាគខាងក្រោមនេះផ្តោតសំខាន់លើលទ្ធផលប្រតិបត្តិការ និងលទ្ធផលហិរញ្ញវត្ថុដោយផ្អែកលើរបាយការណ៍ហិរញ្ញវត្ថុគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ដែលត្រូវបានធ្វើសវនកម្មរួចរាល់ ដោយសវនករឯករាជ្យ។ របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរៀបចំឡើងដោយអនុលោមតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("ស.រ.ទ.ហ.អ.ក")។ មានតែសមាសធាតុសំខាន់ៗនៃរបាយការណ៍ហិរញ្ញវត្ថុ និងកត្តាសំខាន់ៗដែលប៉ះពាល់ដល់ប្រាក់ចំណេញរបស់សម្ព័ន្ធធនាគារប៉ុណ្ណោះត្រូវបានយកមកធ្វើការពិភាក្សា និងការវិភាគ។

# ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

## ១. ការវិភាគចំណូល

សម្ព័ន្ធធនាគារ មានប្រភពចំណូលធំៗចំនួនបីគឺ ចំណូលការប្រាក់ ចំណូលកម្រៃនិងជើងសា និងចំណូលផ្សេងៗសុទ្ធ។

- ចំណូលការប្រាក់៖ រួមមានចំណូលការប្រាក់ពីឥណទាននិងបុរេប្រទាន ចំណូលការប្រាក់ពីប្រាក់បញ្ញើនៅធនាគារផ្សេងៗ និងការវិនិយោគហិរញ្ញវត្ថុ។
- ចំណូលកម្រៃនិងជើងសា៖ រួមមានកម្រៃជើងសា កម្រៃជើងសាបានពីភ្នាក់ងារធានារ៉ាប់រង កម្រៃពីម៉ាស៊ីនអេធីអឹម កម្រៃពីការសងឥណទានមុនកាលកំណត់ កម្រៃពីសេវាប្រាក់បញ្ញើ កម្រៃពីសេវាធានា និងកម្រៃពីការបណ្តុះបណ្តាល។
- ចំណូលផ្សេងៗសុទ្ធ៖ រួមមានចំណេញពីការប្តូររូបិយប័ណ្ណ-សុទ្ធ ចំណេញពីការលក់ទ្រព្យនិងបរិក្ខារ ភាគលាភលើការវិនិយោគហិរញ្ញវត្ថុ និងចំណូលផ្សេងៗ។

## ២. ការវិភាគចំណូលតាមផ្នែក

| ប្រភពចំណូល (គិតជាលានរៀល) | ២០២៣ | | ២០២២ | | ២០២១ | |
|---|---|---|---|---|---|---|
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| ចំណូលការប្រាក់ | ៣.១០៥.៦៤៤ | ៩១,២៦% | ២.៧៤១.៣៦៩ | ៩០,១៨% | ២.៣៣៤.២១៧ | ៩០,១២% |
| ចំណូលកម្រៃនិងជើងសា | ១៩១.៨៤៩ | ៥,៦៤% | ១៩៣.៩៤៩ | ៦,៣៨% | ១៧៤.៦៦៥ | ៦,៧៤% |
| ចំណូលផ្សេងៗសុទ្ធ | ១០៥.៦២១ | ៣,១០% | ១០៤.៧២០ | ៣,៤៤% | ៨១.២០៤ | ៣,១៤% |
| **ចំណូលសរុប** | ៣.៤០៣.១១៤ | ១០០% | ៣.០៤០.០៣៨ | ១០០% | ២.៥៩០.០៨៦ | ១០០% |

ចំណូលសរុបក្នុងឆ្នាំ២០២៣ បានកើនឡើងចំនួន ៣៦៣,០៨ ប៊ីលានរៀល ឬ ១១,៩៤% បើប្រៀបធៀបទៅនឹងចំណូលសរុបក្នុងឆ្នាំ២០២២ ដែលការកើនឡើងទាំងនេះគឺដោយសារប្រសិទ្ធភាពនៃផលិតផល និងសេវាកម្មដ៏សម្បូរបែបរបស់ធនាគារក្នុងយុគសម័យឌីជីថល និងកំណើនអតិថិជន។

## ៣. ការវិភាគគម្លាតចំណេញដុល

របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗរបស់សម្ព័ន្ធធនាគារ បានរៀបចំក្នុងទម្រង់ជារបាយការណ៍ដែលមិនបង្ហាញពីគម្លាតចំណេញដុលទេ។ ចំណូលការប្រាក់សុទ្ធដែលទទួលបានមកពីចំណូលការប្រាក់សរុបដកនឹងចំណាយការប្រាក់សរុប នឹងត្រូវយកមកបង្ហាញនៅក្នុងការវិភាគចំណេញ/(ខាត) មុនបង់ពន្ធ ដូចខាងក្រោម។

## ៤. ការវិភាគចំណេញ/(ខាត) មុនបង់ពន្ធ

| របាយការណ៍ចំណេញ ឬខាត (លានរៀល) | ២០២៣ | ២០២២ | គម្លាត | |
|---|---|---|---|---|
| | | | ចំនួន | ភាគរយ |
| ចំណូលការប្រាក់ | ៣.១០៥.៦៤៤ | ២.៧៤១.៣៦៩ | ៣៦៤.២៧៥ | ១៣,២៩% |
| ចំណាយការប្រាក់ | (១.៣៥២.១៩៦) | (៩០២.៥០១) | (៤៤៩.៦៩៥) | ៤៩,៨៣% |
| **ចំណូលការប្រាក់សុទ្ធ** | **១.៧៥៣.៤៤៨** | **១.៨៣៨.៨៦៨** | **(៨៥.៤២០)** | **(៤,៦៥%)** |
| ចំណូលកម្រៃនិងជើងសា | ១៩១.៨៤៩ | ១៩៣.៩៤៩ | (២.១០០) | (១,០៨%) |
| ចំណាយកម្រៃនិងជើងសា | (១៦.២៦៥) | (១៨.៦៥៤) | ២.៣៨៩ | (១២,៨១%) |
| **ចំណូលកម្រៃនិងជើងសាសុទ្ធ** | **១៧៥.៥៨៤** | **១៧៥.២៩៥** | **២៨៩** | **០,១៦%** |
| សំវិធានធននៃការខាតបង់ឱនភាពនៃតម្លៃរបស់ឥណទាននិងបុរេប្រទាន ប្រាក់បញ្ញើនៅធនាគារផ្សេងៗ គណនីត្រូវទទួល និងមូលបត្រវិនិយោគផ្សេងៗ | (១៧១.៣២០) | (៨៤.១១៥) | (៨៧.២០៥) | ១០៣,៦៧% |
| (សំវិធានធន)/ការកត់ត្រាត្រឡប់នៃការខាតបង់ឱនភាពនៃតម្លៃកិច្ចសន្យាក្រៅតារាងតុល្យការ | (៩) | ១១ | (២០) | ១៨១,៨២% |
| **ការខាតបង់ឱនភាពនៃតម្លៃសុទ្ធ** | **(១៧១.៣២៩)** | **(៨៤.១០៥)** | **(៨៧.២២៤)** | **១០៣,៧១%** |
| **ចំណូលបន្ទាប់ពីការខាតបង់ឱនភាពនៃតម្លៃ** | **១.៧៥៧.៧០៣** | **១.៩៣០.០៥៩** | **(១៧២.៣៥៦)** | **(៨,៩៣%)** |
| ចំណូលផ្សេងៗសុទ្ធ | ១០៥.៦២១ | ១០៤.៧២០ | ៩០១ | ០,៨៦% |
| ចំណាយទូទៅនិងរដ្ឋបាល | (១.១០៦.១០៨) | (១.១០១.៦៨៣) | (៤.៤២៥) | ០,៤០% |
| **ចំណេញមុនចំណាយពន្ធលើប្រាក់ចំណេញ** | **៧៥៧.២១៦** | **៩៣៣.០៩៥** | **(១៧៥.៨៧៩)** | **(១៨,៨៥%)** |

ការកើនឡើងនូវភាពជឿជាក់របស់អតិថិជនមកលើសម្ព័ន្ធធនាគារ ធ្វើឱ្យប្រាក់បញ្ញើនៅដំណាច់ខែធ្នូ ឆ្នាំ២០២៣ កើនឡើងដល់ ២៩,៥៣ ទ្រីលានរៀល ដែលបានកើនឡើងចំនួន ៣,២២ ទ្រីលានរៀល ឬ ១២,២៥% ពីដំណាច់ខែធ្នូ ឆ្នាំ២០២២។ ដោយអនុវត្តតាមបទប្បញ្ញត្តិទាក់ទងនឹងការធ្វើចំណាត់ថ្នាក់ឥណទាន និងដើម្បីភាពរឹងមាំ និងការទប់ទល់រាល់ហានិភ័យ ដែលអាចជះឥទ្ធិពលដល់ឥណទាននិងបុរេប្រទានដល់អតិថិជន ជាពិសេសហានិភ័យដែលអាចកើតចេញពីកូវីដ-១៩ សម្ព័ន្ធធនាគារបានបង្កើននូវសំវិធានធននៃការខាតបង់ឱនភាពនៃតម្លៃចំនួន ៨៧,២១ ប៊ីលានរៀល ឬ ១០៣,៦៧% ធៀបនឹងឆ្នាំ២០២២។

## ៥. ការវិភាគចំណេញ/(ខាត) ក្នុងការិយបរិច្ឆេទ

| របាយការណ៍ចំណេញ ឬខាត (លានរៀល) | ២០២៣ | ២០២២ | គម្លាត | |
|---|---|---|---|---|
| | | | ចំនួន | ភាគរយ |
| **ចំណេញមុនចំណាយពន្ធលើប្រាក់ចំណេញ** | **៧៥៧.២១៦** | **៩៣៣.០៩៥** | **(១៧៥.៨៧៩)** | **(១៨,៨៥%)** |
| ចំណាយពន្ធលើប្រាក់ចំណេញ | (១៤៨.៨៦១) | (១៩០.០១៨) | ៤១.១៥៧ | (២១,៦៦%) |
| **ប្រាក់ចំណេញក្នុងឆ្នាំ** | **៦០៨.៣៥៦** | **៧៤៣.០៧៧** | **(១៣៤.៧២១)** | **(១៨,១៣%)** |

## ៦. ការវិភាគលទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ

| លទ្ធផលលម្អិតសរុប (លានរៀល) | ២០២៣ | ២០២២ | គម្លាត | |
|---|---|---|---|---|
| | | | ចំនួន | ភាគរយ |
| **ប្រាក់ចំណេញក្នុងឆ្នាំ** | **៦០៨.៣៥៦** | **៧៤៣.០៧៧** | **(១៣៤.៧២១)** | **(១៨,១៣%)** |
| **លទ្ធផលលម្អិតផ្សេងៗ៖** | | | | |
| **ធាតុដែលនឹងមិនត្រូវបានធ្វើចំណាត់ថ្នាក់ឡើងវិញទៅចំណេញឬខាត៖** | | | | |
| ការវាស់វែងឡើងវិញនៃកាតព្វកិច្ចអត្ថប្រយោជន៍និយោជិត | - | (១២.៧៧៤) | ១២.៧៧៤ | ១០០% |
| លម្អៀងពីអត្រាប្តូរប្រាក់ | (៤៥.៤៣៩) | ៥៤.០៥៥ | (៩៩.៤៩៤) | (១៨៤,០៦%) |
| **ធាតុដែលត្រូវឬអាចត្រូវបានចាត់ថ្នាក់ឡើងវិញនៅការិយបរិច្ឆេទបន្ទាប់ទៅចំណេញ ឬខាត៖** | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ-ក្រុមហ៊ុនបុត្រសម្ព័ន្ធបរទេស | (២៣.៩៨៤) | (៧៥.៥៣៣) | ៥១.៥៤៩ | ៦៨,២៥% |
| ការវាស់វែងឡើងវិញលើផ្នែកដែលមានប្រសិទ្ធភាពរបស់ឧបករណ៍និស្សន្ទ ដែលកើតឡើងពីការការពារហានិភ័យលំហូរសាច់ប្រាក់ | (១៥.៩៦៣) | ៤១.៤២៩ | (៥៧.៣៩២) | (១៣៨,៥៣%) |
| **លទ្ធផលលម្អិតផ្សេងៗក្នុងការិយបរិច្ឆេទ** | **(៨៥.៣៨៦)** | **៧.១៧៧** | **(៩២.៥៦៣)** | **(១.២៨៩,៧២%)** |
| **លទ្ធផលលម្អិតសរុបក្នុងឆ្នាំសរុប** | **៥២២.៩៧០** | **៧៥០.២៥៤** | **(២២៧.២៨៤)** | **(៣០,២៩%)** |

## ៧. ការវិភាគពីកត្តា និងនិន្នាការដែលប៉ះពាល់ស្ថានភាព និងលទ្ធផលហិរញ្ញវត្ថុ

ធនាគារ អេស៊ីលីដា មានទំនុកចិត្តក្នុងការធ្វើឱ្យប្រសើរឡើងនូវប្រតិបត្តិការរបស់ខ្លួន ចំពេលការព្យាករកំណើនសេដ្ឋកិច្ចមានសញ្ញាល្អប្រសើរឡើង បន្ទាប់ពីបានកសាងកេរ្តិ៍ដំណែលដ៏រឹងមាំអស់រយៈពេលច្រើនជាង៣០ឆ្នាំកន្លងមកនេះ ធនាគារ អេស៊ីលីដា បានត្រៀមខ្លួនរួចជាស្រេចសម្រាប់ពេលអនាគត ហើយនឹងនៅតែបន្តចាក់គ្រឹះឱ្យកាន់តែរឹងមាំដើម្បីផ្តល់ជូននូវដំណោះស្រាយក្នុងវិស័យធនាគារឱ្យកាន់តែសម្បូរបែប ដើម្បីឆ្លើយតបទៅនឹងការផ្លាស់ប្តូរតម្រូវការផ្នែកហិរញ្ញវត្ថុរបស់អតិថិជនទាំងនៅក្នុង និងក្រៅប្រទេសកម្ពុជា។

បន្ទាប់ពីបំបែកព្រំដែនភូមិសាស្ត្រ ដោយការដាក់បញ្ចូលនូវហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងរូបវន្ត ធនាគារដែលបានបង្កើតឡើងនៅក្នុងស្រុកមួយនេះ កំពុងផ្តល់ជូននូវសេវាកម្មធនាគារសម្រាប់មូលដ្ឋានអតិថិជនចម្រុះដោយជោគជ័យ ដែលមានរាប់ចាប់តាំងពីសេវាធនាគារបុគ្គល និងសម្រាប់សាជីវកម្ម ទាំងនៅក្នុងទីក្រុង រហូតដល់តំបន់ជនបទ។ ជាមួយនឹងភាពលេចធ្លោក្នុងការផ្តល់ជូននូវសេវាកម្មហិរញ្ញវត្ថុដ៏សម្បូរបែប ដូចជាផ្តល់ប្រាក់កម្ចី ផ្ទេរប្រាក់ ប្រាក់បញ្ញើ ហិរញ្ញប្បទានពាណិជ្ជកម្ម អេស៊ីលីដា អ៊ីនធើណែត អេស៊ីលីដាម៉ូបាល និងសេវាសំខាន់ជាច្រើនទៀត គាំទ្រដោយហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងការិយាល័យរូបវន្តរបស់ខ្លួន ធនាគារ អេស៊ីលីដា កំពុងចូលរួមយ៉ាងសកម្មក្នុងការជួយដល់កសិករ តាមរយៈការផ្តល់ដើមទុនសម្រាប់ធ្វើស្រែចម្ការរបស់គាត់ ឬផ្តល់ទុនសម្រាប់សហគ្រាសធុនតូច និងមធ្យមជាដើម។ តាមរយៈការបង្រួមគម្លាតចំពោះការទទួលបានហិរញ្ញប្បទាន សព្វថ្ងៃនេះប្រជាជនកម្ពុជាច្រើនជាងកន្លះលាននាក់ មានលទ្ធភាពប្រើប្រាស់សេវារបស់ធនាគារ អេស៊ីលីដា ដែលជាការជំរុញនិងលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុនៅព្រះរាជាណាចក្រកម្ពុជា។

បន្ទាប់ពីរយៈពេលច្រើនជាង៣០ឆ្នាំមកនេះ គេនឹងមើលឃើញ ធនាគារ អេស៊ីលីដា គឺជា ធនាគារឌីជីថល ដែលមានវិស្វកម្មគ្រប់គ្រងទិន្នន័យទំនើបទាន់សម័យ (Data Lakehouse) ប្រកបដោយគុណភាព សុវត្ថិភាព និងទំនុកចិត្ត។ ប្រព័ន្ធអេកូនៃបណ្តាញប្រកបដោយប្រសិទ្ធភាពរបស់ធនាគារនៅទូទាំងប្រទេស រួមមានម៉ាស៊ីន ATM ទីតាំងធនាគារស្វ័យប្រវត្តិ ម៉ាស៊ីនដក-ដាក់ប្រាក់ ម៉ាស៊ីនបើកគណនីនិងបោះពុម្ពប័ណ្ណអេធីអឹម ម៉ាស៊ីនដាក់ប្រាក់បញ្ញើមានកាលកំណត់ កំពុងដើរតួជាកាតាលីករដ៏មានឥទ្ធិពលមួយសម្រាប់រលកនៃកំណើនបន្ទាប់។

អនាគតរបស់ធនាគារនឹងកាន់តែរឹងមាំ ខណៈទំនុកចិត្តរបស់អាជីវកម្មលើកំណើនសេដ្ឋកិច្ចរបស់កម្ពុជានឹងកើនឡើង បន្ទាប់ពីរាជរដ្ឋាភិបាលបានទប់ស្កាត់ការរីករាលដាលនៃជំងឺរាតត្បាតកូវីដ-១៩ ប្រកបដោយប្រសិទ្ធភាពខ្ពស់។ ទស្សនៈវិស័យកំណើនរបស់ប្រទេសកម្ពុជា ត្រូវបានរំពឹងថានឹងងើបឡើងវិញនៅពេលដែលការរឹតបន្តឹងបញ្ហាកូវីដ-១៩ ត្រូវបានដកចេញ។

ការងើបឡើងវិញនៃការនាំចេញផ្នែកផលិតកម្ម និងការពង្រីកការនាំចេញទំនិញកសិកម្ម នឹងមានភាពល្អប្រសើរសម្រាប់ធនាគារ អេស៊ីលីដា ដោយសារអ្នកទទួលកម្ចីភាគច្រើនមានអាជីវកម្មទាក់ទងនឹងកសិផល។ ធនាគារនឹងសម្រេចបានលទ្ធផលកាន់តែល្អប្រសើរនៅក្នុងឆ្នាំ២០២៤ ដោយសារធនាគារបានវិនិយោគយ៉ាងច្រើនទៅលើហេដ្ឋារចនាសម្ព័ន្ធឌីជីថល សាងសង់មជ្ឈមណ្ឌលទិន្នន័យដ៏ធំមួយ ដែលមានសុវត្ថិភាពខ្ពស់ដើម្បីរក្សាទុកទិន្នន័យ។ ការសាងសង់មជ្ឈមណ្ឌលការពារទិន្នន័យ (Disaster Recovery Data Center) នឹងជួយរក្សាទិន្នន័យនៅក្នុងបរិយាកាសដែលមានការការពារខ្ពស់។ ធនាគារមានទំនុកចិត្តចំពោះពេលអនាគត ជាមួយនឹងហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងផលិតផល-សេវាកម្ម ដែលនឹងកាន់តែមានភាពល្អប្រសើរ។

# ខ. កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ

## ១. ការវិភាគពីលក្ខខណ្ឌនៃតម្រូវការ និងការផ្គត់ផ្គង់

សម្ព័ន្ធធនាគារ មានប្រតិបត្តិការល្អប្រសើរ រឹងមាំ និងទទួលបានជោគជ័យនៅលើទីផ្សារអាស្រ័យដោយកត្តាពីរគឺ៖

- កំណើនសំពៀតឥណទាន ដោយសារតម្រូវការខ្ពស់នៅលើទីផ្សារលើផលិតផលឥណទានរបស់សម្ព័ន្ធធនាគារ ជាពិសេសសហគ្រាសធុនតូច និងមធ្យម។
- កំណើនប្រាក់បញ្ញើ-សន្សំ របស់សម្ព័ន្ធធនាគារ រួមជាមួយផលិតផល និងសេវាកម្មផ្សេងទៀត។

កត្តាទាំងពីរនេះត្រូវបានផ្សារភ្ជាប់ជាមួយនឹងការអភិវឌ្ឍឥតឈប់ឈរនៃប្រព័ន្ធឌីជីថលរបស់សម្ព័ន្ធធនាគារ ដែលផ្តល់ជូនអតិថិជននូវផលិតផល និងសេវាកម្មហិរញ្ញវត្ថុប្រកបដោយភាពច្នៃប្រឌិត និងទាន់សម័យ។

សម្ព័ន្ធធនាគារ បាននឹងកំពុងតែអភិវឌ្ឍនូវហេដ្ឋារចនាសម្ព័ន្ធចម្រុះឱ្យកាន់តែទូលំទូលាយសម្រាប់ជាជម្រើសដ៏សម្បូរបែបជាមួយនឹងការិយាល័យទាំង៣២០ តាមរយៈការផ្លាស់ប្តូរបន្តិចម្តងៗទៅជាមជ្ឈមណ្ឌលដែលអាចធ្វើស្វ័យប្រតិបត្តិការដែលមានទីតាំងធនាគារស្វ័យប្រវត្តិចំនួន១៧៧ ព្រមទាំងមាន ម៉ាស៊ីនអេធីអឹមអេស៊ីលីដា ចំនួន១.៣១៤ គ្រឿង ម៉ាស៊ីនដាក់ប្រាក់បញ្ញើមានកាលកំណត់ ចំនួន២៦គ្រឿង ម៉ាស៊ីនបើកគណនី និងបោះពុម្ពប័ណ្ណអេធីអឹម ចំនួន៩៦ គ្រឿង ម៉ាស៊ីនទទួលកាបូបប្រាក់ ចំនួន១៧ គ្រឿង និងម៉ាស៊ីនឆូតកាតចំនួន៤.៧២៨ គ្រឿង។ ចំណុចគួរជាទីមោទនភាពគឺសម្ព័ន្ធធនាគារ បានបោះពុម្ពប័ណ្ណអេធីអឹមអេស៊ីលីដា ចំនួន១,៩៤ លានប័ណ្ណជូនដល់អតិថិជន។ ទន្ទឹមនឹងនេះ អេស៊ីលីដាម៉ូបាល បានទទួលប្រជាប្រិយភាពយ៉ាងខ្លាំង ដែលចំនួននៃអ្នកចុះឈ្មោះប្រើប្រាស់បានកើនដល់ ៣,៤៥ លាននាក់ នៅដំណាច់ខែធ្នូ ឆ្នាំ២០២៣នេះ ដែលអាចជួយឱ្យចរាចរសាច់ប្រាក់បានឆាប់រហ័សនៅក្នុងសេដ្ឋកិច្ច។

ការបង្កើនភាពងាយស្រួលដល់អតិថិជន និងពង្រឹងប្រព័ន្ធសុវត្ថិភាពអ៊ិនធើណែត គឺជាចំណុចដែលសម្ព័ន្ធធនាគារ ផ្តោតការយកចិត្តទុកដាក់បំផុត។ ដើម្បីសម្រេចនូវវឌ្ឍនភាពគោលដៅដ៏រឹងមាំទាំងនេះ សម្ព័ន្ធធនាគារ នឹងបន្តលើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន តាមរយៈការវិនិយោគលើបច្ចេកវិទ្យាទំនើបចុងក្រោយ ពង្រឹងសមត្ថភាពធនធានមនុស្ស ព្រមទាំងពង្រីកនិងកែលម្អដំណើរការអាជីវកម្ម។ ជាយុទ្ធសាស្ត្រ សម្ព័ន្ធធនាគារកំពុងអភិវឌ្ឍប្រព័ន្ធទូទាត់ដែលអាចឱ្យដៃគូទាំងក្នុង និងក្រៅប្រទេសអាចភ្ជាប់ប្រព័ន្ធនេះដើម្បីបម្រើអតិថិជនទៅវិញទៅមក និងឆ្លងព្រំដែន។ ប្រព័ន្ធនេះមិនត្រឹមតែផ្តល់អត្ថប្រយោជន៍ដោយផ្ទាល់ដល់អតិថិជនដ៏ឆ្លាតវៃរបស់យើងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដៃគូអាជីវកម្មរបស់ពួកគាត់ផងដែរ។ យើងខ្ញុំទទួលស្គាល់ថាអតិថិជន និងដៃគូអាជីវកម្មទាំងអស់គឺជាបណ្តាញតភ្ជាប់ដ៏មានសារសំខាន់សម្រាប់ពង្រីកសេវាកម្មរបស់សម្ព័ន្ធធនាគារ និងរីកចម្រើនជាមួយគ្នា។

អេស៊ីលីដាម៉ូបាល ត្រូវបានកែលម្អយ៉ាងទូលំទូលាយ និងផ្លាស់ប្តូររូបរាងថ្មី កាន់តែទំនើប ងាយស្រួល និងមានសុវត្ថិភាពខ្ពស់ ជាមួយនឹងមុខងារពិសេសៗជាច្រើន។ ឥឡូវនេះ អតិថិជនទាំងអស់អាចធ្វើប្រតិបត្តិការប្រាក់បញ្ញើ-សន្សំ (សំចៃ ចរន្ត និងមានកាលកំណត់) តាមរយៈ អេស៊ីលីដាម៉ូបាល បានភ្លាមៗ ថែមទាំងទទួលបានការប្រាក់ខ្ពស់ទៀតផង។

ខេអេចឃ្យូអរកូដ (KHQR Code) ផ្តល់នូវភាពងាយស្រួលជាងមុនជូនដល់អ្នកប្រើប្រាស់ក្នុងការធ្វើប្រតិបត្តិការទូទាត់ថ្លៃទំនិញ និងសេវាកម្មផ្សេងៗប្រកបដោយប្រសិទ្ធភាព សុវត្ថិភាព និងទំនុកចិត្តខ្ពស់ រវាងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ដែលជាសមាជិករបស់កម្មវិធីបាគង (Bakong App)។

ឥឡូវនេះ ជាមួយអេស៊ីលីដាម៉ូបាល ពិតជាងាយស្រួល ដោយលោកអ្នកអាចទូទាត់ផ្សេងៗ តាម QR Code (Scan QR) បានគ្រប់ទីកន្លែង នៅទូទាំងប្រទេសថៃ វៀតណាម និងឡាវ ដោយឥតគិតថ្លៃសេវា។ នេះជាភាពជោគជ័យថ្មីមួយទៀតរបស់ប្រព័ន្ធបាគង និងធនាគារ អេស៊ីលីដា ដែលជាសមាជិករបស់បាគង។

## ២. ការវិភាគការឡើងចុះនៃថ្លៃវត្ថុធាតុដើម

ធនាគារ អេស៊ីលីដា ប្រតិបត្តិការក្នុងវិស័យសេវាកម្ម ដែលការឡើងចុះនៃថ្លៃវត្ថុធាតុដើមមិនអាចអនុវត្តបានចំពោះធនាគារឡើយ។

## ៣. ការវិភាគលើពន្ធ

ធនាគារ អេស៊ីលីដា ភីអិលស៊ី និងក្រុមហ៊ុនបុត្រសម្ព័ន្ធ ស្ថិតនៅក្រោមច្បាប់ស្តីពីពន្ធដារនៃប្រទេសនីមួយៗ ដូច្នេះធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធមានកាតព្វកិច្ចបង់ពន្ធតាមការកំណត់របស់អាជ្ញាធរពន្ធដារនីមួយៗ។

ការបង់ពន្ធជូនអគ្គនាយកដ្ឋានពន្ធដារមិនត្រឹមតែជាកាតព្វកិច្ច និងការទទួលបានវិញ្ញាបនបត្រអនុលោមភាពសារពើពន្ធប្រភេទ "មាស" ពីអគ្គនាយកដ្ឋានពន្ធដារសម្រាប់ឆ្នាំជាប់ពន្ធ២០២២ ដល់២០២៣ ប៉ុណ្ណោះទេ ប៉ុន្តែជាការចូលរួមចំណែកក្នុងសង្គម និងកំណើនសេដ្ឋកិច្ចផងដែរ។

ចំណូលពន្ធគឺជាប្រភពចំណូលដ៏សំខាន់បំផុតសម្រាប់ប្រទេស។ រដ្ឋាភិបាលប្រមូលពន្ធកាន់តែច្រើន ការចូលរួមវិភាគទានកាន់តែច្រើនដល់ការអភិវឌ្ឍប្រទេស។ ធនាគារ អេស៊ីលីដា ភីអិលស៊ី បានបង់ពន្ធច្រើនជាងគេជាប់ចំណាត់ថ្នាក់លេខ៣ និងបង់ពន្ធលើប្រាក់ចំណូលជាប់ចំណាត់ថ្នាក់លេខ៤ ក្នុងចំណោមសហគ្រាសដែលបានបង់ពន្ធច្រើនជាងគេប្រចាំឆ្នាំ២០២២។ ធនាគារ អេស៊ីលីដា ភីអិលស៊ី មានមោទនភាពដែលអាចចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាយើង។

## ៤. ការវិភាគធាតុដែលខុសពីធម្មតា និងធាតុវិសាមញ្ញ

សម្ព័ន្ធធនាគារមិនមានធាតុ ប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលខុសពីធម្មតាជាសារវន្តនោះទេ។ ទោះជាយ៉ាងណាក៏ដោយ លក្ខខណ្ឌសេដ្ឋកិច្ចដែលបានរងផលប៉ះពាល់ដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩ ជាពិសេសវីរុសកូវីដ-១៩ បំប្លែងថ្មី ឆ្លងចូលក្នុងសហគមន៍ អាចជះឥទ្ធិពលដល់សមត្ថភាពសងត្រលប់មកវិញរបស់អតិថិជនដែលគុណភាពឥណទានរបស់សម្ព័ន្ធធនាគារអាចរងផលប៉ះពាល់បន្តិចបន្តួច។

## គ. ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល

ដើម្បីចូលរួមគាំទ្រការរីកលូតលាស់អាជីវកម្មរបស់អតិថិជន សម្ព័ន្ធធនាគារ បានផ្តល់អត្រាការប្រាក់មានភាពប្រកួតប្រជែងខ្លាំងចំពោះការស្នើសុំឥណទានថ្មីគ្រប់ប្រភេទ និងដោយកាន់តែមានភាពងាយស្រួល អតិថិជនទាំងអស់អាចដាក់សំណើសុំឥណទានតាមរយៈ អេស៊ីលីដាម៉ូបាល។ ជាលទ្ធផល សមតុល្យឥណទានដុលសរុបនៅឆ្នាំ២០២៣ មានការកើនឡើងចំនួន ៧៥៧,១៩ ប៊ីលានរៀល ឬ ២,៨៦% ធៀបនឹងដំណាច់ឆ្នាំ២០២២។

## ឃ. ផលប៉ះពាល់នៃការប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ

សម្រាប់ឆ្នាំ ២០២៣ អត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិក នៅតែមានស្ថិរភាពក្នុងរង្វង់ ៤១១១រៀលក្នុងមួយដុល្លារអាមេរិក ដែលតម្លៃរបស់វាបានប្រែប្រួលតិចតួចប៉ុណ្ណោះ ត្រឹមតែ ០,២% ប៉ុណ្ណោះ ធៀបនឹងឆ្នាំមុន ៤១០៣។ ប្រមើលមើលទៅមុខ តម្លៃប្រាក់រៀលត្រូវបានរំពឹងថានឹងនៅតែមានស្ថិរភាព ដោយយោងទៅលើការស្ទុះងើបឡើងវិញនៃសកម្មភាពសេដ្ឋកិច្ច ទំនុកចិត្តសាធារណៈជនលើប្រាក់រៀល និងការបន្តអនុវត្តការផ្សព្វផ្សាយ ជម្រុញការប្រើប្រាស់ប្រាក់រៀលរបស់ធនាគារជាតិនៃកម្ពុជា តាមរយៈការវាស់វែង និងការពង្រឹងគោលនយោបាយគ្រប់គ្រងសាច់ប្រាក់ក្នុងវិស័យហិរញ្ញវត្ថុ ជាពិសេសការបង្កើតយន្តការ និងវិធីសាស្ត្រដើម្បីរក្សាស្ថិរភាពនៃប្រាក់រៀល។

ចំពោះធនាគារអេស៊ីលីដា បានគាំទ្ររាល់គោលនយោបាយដែលបានដាក់ចេញ អនុវត្តតាមតម្រូវការនៃបទបញ្ញត្តិរបស់ធនាគារ ជាតិ នៃកម្ពុជា និងគោលនយោបាយគ្រប់គ្រងហានិភ័យផ្ទៃក្នុងរបស់ខ្លួន។ ទន្ទឹមគ្នានេះ ធនាគារបានធ្វើការវាស់វែង ត្រួតពិនិត្យ និងគ្រប់គ្រងលើមូលដ្ឋានប្រចាំថ្ងៃ ដោយរក្សាស្ថានភាពចំហសុទ្ធនៃរូបិយប័ណ្ណក្នុងកម្រិតតូចល្មម។ ដូចនេះ មិនមានផលប៉ះពាល់ជាសារវន្តដល់ធនាគារឡើយ។

អត្រាការប្រាក់នៃទីផ្សារក្នុងស្រុក និងអន្តរជាតិបានបន្តមានស្ថិរភាព បន្ទាប់ពីការធ្លាក់ចុះនៃអត្រាអតិផរណារបស់សហរដ្ឋអាមេរិក ដែលបានជំរុញឱ្យធនាគារកណ្តាលអាមេរិកបញ្ឈប់ការដំឡើងអត្រាការប្រាក់ចំនួន ៣ លើកជាប់ៗគ្នា គិតត្រឹមកិច្ចប្រជុំគោលនយោបាយប្រចាំខែធ្នូ ឆ្នាំ២០២៣ កន្លងទៅ ។ លើសពីនេះ ក្រុមមន្ត្រីរបស់ធនាគារកណ្តាលអាមេរិក បានផ្តល់សញ្ញាណពីការកាត់បន្ថយអត្រាការប្រាក់សម្រាប់ឆ្នាំ ២០២៤ នេះផងដែរ។

ធនាគារ អេស៊ីលីដា បាននិងកំពុងដំណើរការអាជីវកម្មរបស់ខ្លួនស្ទើរតែទាំងស្រុង ដោយធ្វើការផ្គូផ្គងរវាងទ្រព្យសកម្ម និងបំណុលអកម្ម លើអត្រាការប្រាក់ថេរ។ ដូច្នេះ ផលប៉ះពាល់នៃការប្រែប្រួលអត្រាការប្រាក់លើអាជីវកម្មរបស់ធនាគារមានតិចតួចបំផុត ហើយការប្រែប្រួលនេះត្រូវបានត្រួតពិនិត្យជាប្រចាំ ដើម្បីចាត់វិធានការសមស្រប និងទាន់ពេលវេលា ដើម្បីជៀសវាងផលប៉ះពាល់ដល់អាជីវកម្មរបស់ធនាគារ។

ដោយឡែកចំពោះប្រតិបត្តិការជួញដូរនានា ដែលមានទម្រង់ជាទំនិញ (Commodities) ធនាគារមិនមាន ផ្តល់សេវាបែបនោះទេ។ ដូច្នេះមិនមានផលប៉ះពាល់ដល់ធនាគារឡើយ។

## ង. ផលប៉ះពាល់នៃអតិផរណា

សម្រាប់ឆ្នាំ២០២៣ អត្រាអតិផរណាជាមធ្យមត្រូវបានព្យាករណ៍ថា នឹងមានប្រហែល ២,៥% ដោយសារតែការវិលត្រឡប់មកប្រក្រតីវិញនូវតម្លៃប្រេងអន្តរជាតិ និងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ក៏ដូចជាការទប់ស្កាត់អតិផរណា និងការរក្សាអំណាចទិញ។ ទោះជាយ៉ាងណាក៏ដោយ ប្រតិបត្តិការរបស់ធនាគារមិនពាក់ព័ន្ធដោយផ្ទាល់ទៅនឹងកម្រិតអតិផរណានោះទេ។ ដូច្នេះ ផលប៉ះពាល់គឺតិចតួចបំផុត និងអាចគ្រប់គ្រងបាន។

## ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល

### គោលនយោបាយសេដ្ឋកិច្ច៖

ធនាគារជាតិនៃកម្ពុជា បានផ្តល់ជារបាយការណ៍ថា កំណើនសេដ្ឋកិច្ចកម្ពុជាឆ្នាំ២០២៣ បានត្រូវបានរំពឹងថាមានកំណើន ៥,៥%។ កំណើនថ្មីនេះគាំទ្រដោយការកើនឡើងខ្ពស់នៃវិស័យទេសចរណ៍ និងកំណើនផលិតផលកម្មន្តសាលមិនមែនកាត់ដេរ។ វិស័យទេសចរណ៍មានកំណើនល្អ ដោយចំនួនភ្ញៀវអន្តរជាតិបានកើនឡើង។ វិស័យកម្មន្តសាលបានកើនឡើង ដោយផលិតផលកម្មន្តសាលសម្រាប់បម្រើការនាំចេញកើន ជាពិសេសផលិតផលមិនមែនកាត់ដេរ ដូចជា បរិក្ខារអេឡិចត្រូនិចកើន និងយានយន្តនិងគ្រឿងបន្លាស់សម្រាប់យានយន្តកើន ខណៈផលិតផលកម្មន្តសាលសម្រាប់បម្រើទីផ្សារក្នុងស្រុកថយចុះ។ វិស័យកសិកម្មបានកើនឡើង ដែលគាំទ្រដោយកំណើនបរិមាណផលស្រូវ ដំរកៅស៊ូ និងអនុវិស័យជលផល។ ចំណែកឯវិស័យសំណង់និងអចលនទ្រព្យបន្តមានកំណើនយឺត។ [១]

យោងតាមព័ត៌មានដែលបានចុះផ្សាយរបស់ស្ថាប័នល្បីល្បាញ មួយចំនួននៅបន្តព្យាករ GDP ឆ្នាំ២០២៣របស់កម្ពុជាផងដែរ។ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានព្យាករសេដ្ឋកិច្ចរបស់កម្ពុជាថា កំណើនសេដ្ឋកិច្ចរបស់កម្ពុជាក្នុងឆ្នាំ២០២៣ នឹងមានកម្រិតទាបជាងការព្យាករមុនបន្តិច ពោលគឺធ្លាក់មកត្រឹម ៥,៣% ពី ៥,៥% ភាគច្រើនដោយសារតែកំណើនឧស្សាហកម្មយឺតជាងការរំពឹងទុកនៅក្នុងឆមាសទីមួយ នេះបើយោងតាមការធ្វើបច្ចុប្បន្នភាពនៃរបាយការណ៍សេដ្ឋកិច្ចរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ដែលបានចេញផ្សាយនៅថ្ងៃនេះ។ របាយការណ៍របស់ ADB បានរក្សាការព្យាករណ៍កំណើនឆ្នាំ ២០២៤ របស់ប្រទេសនៅត្រឹម ៦.0% ។ ទស្សនវិស័យអភិវឌ្ឍន៍អាស៊ី (ADO) ខែកញ្ញា ឆ្នាំ ២០២៣ កត់សម្គាល់ថា ការនាំចេញសម្លៀកបំពាក់ ស្បែកជើង និងទំនិញធ្វើដំណើរបានធ្លាក់ចុះ ១៨.៦% ធៀបនឹងឆ្នាំមុននៅឆមាសទីមួយនៃឆ្នាំ ២០២៣។ នេះត្រូវបានប៉ះប៉ូវមួយផ្នែកដោយការកើនឡើង ២២.៩% នៃការនាំចេញផលិតផលផ្សេងទៀតជាងសម្លៀកបំពាក់ដូចជាគ្រឿងបន្លាស់រថយន្ត បន្ទះស្រូបពន្លឺព្រះអាទិត្យ និងគ្រឿងសង្ហារិម។ មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បានព្យាករណ៍ថា GDP សម្រាប់ប្រទេសកម្ពុជាគឺ ៥.៦% សម្រាប់ ២០២៣ និង ៦.១% សម្រាប់ ២០២៤ នេះបើយោងតាមការចុះផ្សាយនៅលើគេហទំព័ររបស់ពួកគេ (World Economic Outlook)។ ធនាគារពិភព (WB) ២០២៤ បានព្យាករណ៍កំណើន GDP សម្រាប់ប្រទេសកម្ពុជាគឺ ៥.៨% សម្រាប់ ២០២៤ និង ៦.១% សម្រាប់ ២០២៥ នេះបើយោងតាមការចុះផ្សាយនៅលើគេហទំព័ររបស់ពួកគេ (Global Economic Prospect)។ [២],[៣],[៤]

ជាលទ្ធផលជាក់ស្តែង កំណើនសេដ្ឋកិច្ចកម្ពុជាឆ្នាំ២០២៣ បានបន្តងើបដែលគាំទ្រដោយការកើនឡើងខ្ពស់នៃវិស័យទេសចរណ៍ និងកំណើនផលិតផលកម្មន្តសាលមិនមែនកាត់ដេរ។ វិស័យទេសចរណ៍មានកំណើនល្អប្រសើរក្នុងអត្រា ១៩,៨% ដោយចំនួនភ្ញៀវអន្តរជាតិបានកើនឡើងដល់ ៥,៥ លាននាក់។ វិស័យកម្មន្តសាលបានកើនឡើងក្នុងអត្រា ៧.៤% ដោយផលិតផលកម្មន្តសាលសម្រាប់បម្រើការនាំចេញកើន ៤,៣% ជាពិសេសផលិតផលមិនមែនកាត់ដេរ ដូចជា បរិក្ខារអេឡិចត្រូនិចកើន ១,៣ដង និង យានយន្តនិងគ្រឿងបន្លាស់សម្រាប់យានយន្តកើន ៣,២ដង ខណៈផលិតផលកម្មន្តសាលសម្រាប់បម្រើទីផ្សារក្នុងស្រុកថយចុះ -៧%។ វិស័យកសិកម្មបានកើនឡើង ១,១% ដែលគាំទ្រដោយកំណើនបរិមាណផលស្រូវ ដំឡូងមី ពោតក្រហម និងអនុវិស័យជលផល។ ចំណែកឯវិស័យសំណង់និងអចលនទ្រព្យបន្តមានកំណើនយឺតក្នុងអត្រា ១,១% និង ០,៥% រៀងគ្នា។ សមតុល្យជញ្ជីងទូទាត់កម្ពុជាត្រូវបានប៉ាន់ស្មានថាមានអតិរេក ២២៦,១លានដុល្លារអាមេរិក ដែលគាំទ្រដោយលំហូរចូលសុទ្ធនៃគណនីហិរញ្ញវត្ថុ ស្របពេលដែលសមតុល្យគណនីចរន្ត និងដើមទុនបានប្តូរពីឱនភាពមកជាអតិរេក។ អតិរេកនេះបានរួមចំណែកបង្កើនទុនបម្រុងអន្តរជាតិដល់ ២០ ប៊ីលានដុល្លារអាមេរិកដែលស្មើនឹង ៧ខែ នៃការនាំចូលទំនិញនិងសេវាសម្រាប់គ្រាបន្ទាប់ខ្ពស់ជាងកម្រិតអប្បបរមាសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ (៣ខែ)។[១]

## គោលនយោបាយសារពើពន្ធ៖

លទ្ធផលប្រមូលពន្ធក្នុងខែធ្នូ ឆ្នាំ២០២៣ បានបង្ហាញនូវចំណូលពន្ធ-អាករគ្រប់ប្រភេទដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបាន ជាក់ស្តែងតាមប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណូលអនឡាញរបស់អគ្គនាយកដ្ឋានពន្ធដារមាន ១.០៧២,៣១ ប៊ីលានរៀល (ប្រមាណជា ២៦៤,៧៧ លានដុល្លារ) ស្មើនឹង ៧,៤១% នៃផែនការច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣។ សរុបរយៈពេល ១២ខែ ឆ្នាំ២០២៣ ចំណូលពន្ធអាករ ដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបាន ជាក់ស្តែងតាមប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណូលអនឡាញរបស់អគ្គនាយកដ្ឋានពន្ធដារ មានចំនួន ១៤.៦២៩,១០ ប៊ីលានរៀល (ប្រមាណជា ៣.៦១២,១២ លានដុល្លារ) ស្មើនឹង ១០១,១៣% នៃផែនការច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំ ឆ្នាំ២០២៣ ធៀបនឹងចំណូលពន្ធអាករក្នុងរយៈពេលដូចគ្នានៃឆ្នាំ២០២២ គឺកើនឡើងចំនួន ៦២៨,២៨ ប៊ីលានរៀល (ប្រមាណជា ១៥៥,១៣ លានដុល្លារ) ស្មើនឹង ៤,៤៩%។ លទ្ធផលដ៏ជោគជ័យ និងជាទីមោទនៈនេះ គឺជាការចូលរួមចំណែកដ៏ សំខាន់ក្នុងការបន្តអភិវឌ្ឍប្រទេសជាតិ។[៥]

សម្រាប់ឆ្នាំ២០២៤ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី បានគាំទ្រលើវិធានការដែលបានដាក់ចេញរបស់អគ្គនាយកដ្ឋានពន្ធដារ សម្រាប់ទិសដៅអនុវត្តបន្ត៖ (១) បន្តពង្រឹងការផ្សព្វផ្សាយនិងការអនុវត្តប្រកបដោយការយកចិត្តទុកដាក់នូវវិធានការលើកទឹកចិត្តនិងសម្រួលផ្នែកពន្ធដារ ជូនវិស័យឯកជននាពេលកន្លងមក និងក្នុងក្របខ័ណ្ឌវេទិកា រាជរដ្ឋាភិបាល-ផ្នែកឯកជនលើកទី១៩ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចធិបតី នាយករដ្ឋមន្ត្រី កាលពីថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៣ (២) បន្តរៀបចំ និងឬធ្វើបច្ចុប្បន្នភាពលិខិតបទដ្ឋានគតិយុត្ត (ប្រកាស សេចក្តីណែនាំ និង/ឬសេចក្តីជូនដំណឹង) ក្នុងការអនុវត្ត នូវវិធានការលើកទឹកចិត្ត និងការសម្រួលផ្នែកពន្ធដារ ដែលរាជរដ្ឋាភិបាលបានដាក់ចេញ ព្រមទាំងបន្តពង្រឹងការអនុវត្ត ប្រកបដោយការយកចិត្ត ទុកដាក់តាមអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់សម្តេចធិបតី នាយករដ្ឋមន្ត្រី បានដាក់ចេញ កន្លងមក ក្នុងការពង្រឹងគុណភាពនៃការផ្តល់សេវា និងប្រសិទ្ធភាពការងារ (៣) បន្តពង្រឹងការយកចិត្តទុកដាក់ខ្ពស់លើគុណភាពនៃការផ្តល់សេវា និងលើកកម្ពស់ប្រសិទ្ធភាពការងាររបស់ខ្លួន ស្របតាម អនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់សម្តេចធិបតី នាយករដ្ឋមន្ត្រី ដោយប្រកាន់ខ្ជាប់នូវអភិក្រមការងារ ៤ ប្រការរបស់ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (៤) រៀបចំនិងដាក់ឱ្យប្រើប្រាស់នូវកម្មវិធី e-Administration ដែលនឹងក្លាយជាឧបករណ៍ទំនើប ដើម្បីគាំទ្ររាល់ការផ្តល់សេវា អ្នកជាប់ពន្ធដែលផ្តល់ភាពងាយស្រួលដល់អ្នកជាប់ពន្ធ និងសាធារណជនក្នុងការដាក់លិខិតរដ្ឋបាលនានាតាមប្រព័ន្ធ អេឡិចត្រូនិកមករដ្ឋបាល សារពើពន្ធដើម្បីដំណើរការឯកសារជូន (៥) បន្តធ្វើទំនើបកម្មរដ្ឋបាលសារពើពន្ធស្របតាមចក្ខុវិស័យរបស់អគ្គនាយកដ្ឋានពន្ធដារ ក្នុងការប្រែក្លាយខ្លួនទៅជារដ្ឋបាល សារពើពន្ធទំនើបជំនាន់ 3.0 (Tax Administration 3.0) ហើយដើម្បីសម្រេចបាននូវចក្ខុវិស័យនេះ អគ្គនាយកដ្ឋានពន្ធដារ សូមគោរពស្នើសុំការគាំទ្រដ៏ខ្ពង់ខ្ពស់ពីឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី ដើម្បីជំរុញឱ្យក្រសួង-ស្ថាប័នពាក់ព័ន្ធចូលរួមធ្វើទំនើបកម្មតាមសមត្ថកិច្ចរៀងៗខ្លួន (៦) បន្តធ្វើទំនើបកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននិងកម្មវិធីប្រកបដោយស្មារតីបុរេសកម្មតាមរយៈការអភិវឌ្ឍនិងធ្វើបច្ចុប្បន្នភាព បន្តវិនិយោគនិងអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រ និងពង្រឹងសមត្ថភាពមុខងារវិភាគទិន្នន័យបន្ថែមទៀត ដើម្បីបន្តជំរុញបង្កើនកម្រិតអនុលោមភាពសារពើពន្ធ ដោយធ្វើយ៉ាងណាឱ្យងាយស្រួលក្នុងការ បំពេញកាតព្វកិច្ចពន្ធដារ ប៉ុន្តែពិបាកក្នុងការគេចវេះតាមរយៈការបន្តអភិវឌ្ឍបន្ថែមនូវមុខងារមួយចំនួន តាមធាតុចូលដែលទទួលបានពីអ្នកប្រើប្រាស់ពីគ្រប់មជ្ឈដ្ឋានដើម្បីឱ្យកាន់តែមាន ភាពគ្រប់ជ្រុងជ្រោយ និងងាយស្រួលក្នុងការប្រើប្រាស់ (៧) បន្តសហការជាមួយក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ដើម្បី ១.រៀបចំនិយាមនីតិវិធីប្រតិបត្តិការងារ (SOP) ស្តីពីការជូនវិញ្ញាបនបត្រសម្គាល់អចលនវត្ថុ ដែលទទួលបានការលើកលែងពន្ធ និង ២.ស្នើសុំទិន្នន័យអចលនទ្រព្យដែល អាចប្រើប្រាស់បានសម្រាប់ប្រមូលពន្ធប្រថាប់ត្រាពន្ធលើអចលនទ្រព្យ និងពន្ធលើចំណេញមូលធន នាពេលខាងមុខក្នុងករណីមានការសម្រេចឱ្យអនុវត្ត (៨) បន្តចូលរួមយ៉ាងសកម្មក្នុងក្របខ័ណ្ឌក្រុមសិក្សាស្រាវជ្រាវ ឬកិច្ចសហការអន្តរជាតិនានា ក្នុងគោលដៅពិភាក្សា ចែករំលែក និងដកស្រង់បទពិសោធន៍ពីបណ្តារដ្ឋបាលសារពើពន្ធ និងស្ថាប័នអន្តរជាតិធំៗនានា ជាពិសេសសិក្សាពីបច្ចេកវិទ្យាថ្មីៗ ក្នុងវិស័យពន្ធដារ និងឧត្តមានុវត្តន៍នៃការប្រមូលចំណូល មានជាអាទិ៍ ក្រុមសិក្សាស្តីពីរដ្ឋបាលសារពើពន្ធអាស៊ីប៉ាស៊ីហ្វិក និងការសិក្សាស្រាវជ្រាវ (SGATAR) ក្រុមការងារគំនិតផ្តួចផ្តើមខ្សែក្រវាត់ និងផ្លូវសម្រាប់កិច្ចសហប្រតិបត្តិការពន្ធដារ (BRITACOM) និងវេទិការដ្ឋបាលសារពើពន្ធ (Forum on Tax Administration - FTA) ជាដើម (៩) បន្តជំរុញរៀបចំឱ្យបានបញ្ចប់នូវឯកសារលិខិតបទដ្ឋានគតិយុត្តគាំទ្រដល់ច្បាប់ស្តីពីសារពើពន្ធឆ្នាំ២០២៣ និងសេចក្តី សម្រេចក្នុងវេទិការាជរដ្ឋាភិបាល និងផ្នែកឯកជនលើកទី១៩ (១០) បន្តពង្រឹងកិច្ចសហការជាមួយវិស័យឯកជន ជាពិសេសក្នុងក្របខ័ណ្ឌនៃកិច្ចសហការជាមួយ វិស័យឯកជន និង សភាពាណិជ្ជកម្មនានា (១១) បន្តជំរុញលើការងាររៀបចំ ចរចា និងពង្រីកវិសាលភាពនៃកិច្ចព្រមព្រៀងស្តីពីការលុបបំបាត់ ការយកពន្ធត្រួតគ្នា (DTA) ជាមួយបណ្តាប្រទេសនានា (១២) បន្តពង្រឹងតម្លាភាព និងគណនេយ្យភាពនៃការបង់ពន្ធរបស់សហគ្រាសក្នុងវិស័យផលិត ស្រាបៀរនិងភេសជ្ជៈគ្មានជាតិសុរាដោយបន្តពង្រឹងអនុវត្តយន្តការបំពាក់កាមេរ៉ាសុវត្ថិភាពនៅតាមរោងចក្រផលិតស្រាបៀរ និងភេសជ្ជៈគ្មានជាតិសុរាឱ្យបានរួចរាល់គ្រប់សហគ្រាស ការចុះត្រួតពិនិត្យឧបករណ៍វាស់ចំណុះ (Flowmeter) ក្នុងខ្សែច្រវាក់ផលិតកម្មដល់ទីតាំងដោយថ្នាក់ដឹកនាំរបស់អគ្គនាយកដ្ឋានពន្ធដារនិងការបន្តពង្រឹងការអនុវត្តការងារនិងវត្តមានរបស់មន្ត្រីប្រចាំការ (១៣) រៀបចំលិខិតបទដ្ឋានគតិយុត្ត និងផែនការសកម្មភាពដើម្បីគាំទ្រការអនុវត្តវិធានការនានាពាក់ព័ន្ធនឹងពន្ធដារ ដូចមាន កំណត់នៅក្នុងយុទ្ធសាស្រ្តជាតិស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ២០២៣-២០២៨របស់រាជរដ្ឋាភិបាល (១៤) បន្តចូលរួមក្នុងក្របខ័ណ្ឌការងារប្រឆាំងនឹងបទល្មើសសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីក សាយភាយអាវុធមហាប្រល័យ ជាមួយគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទាន ភេរវកម្មនិងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ (គ.ស.ហ) និងអនុគណៈកម្មការចំពោះកិច្ចអនុវត្ត ផែនការ

សកម្មភាពការងាររបស់ក្រុមការងារត្រួតពិនិត្យរួម នៃក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកអំពីកិច្ចសហប្រតិបត្តិការអន្តរជាតិ (អ.អ.ផ) (១៥) បន្តផ្សព្វផ្សាយច្បាប់ស្តីពីសារពើពន្ធថ្មីជូនដល់អ្នកជាប់ពន្ធ សាធារណជន ព្រមទាំងក្រុមការងារវិស័យឯកជន និងអង្គការ សមាគមនានាតាមគ្រប់រូបភាព ព្រមទាំងបន្តរៀបចំធ្វើបច្ចុប្បន្នភាពលិខិតបទដ្ឋានគតិយុត្តនានាស្តីពីពន្ធដារឱ្យស្របតាម ច្បាប់ស្តីពីសារពើពន្ធថ្មី (១៦) បន្តការងារកែទម្រង់ធនធានមនុស្ស ដោយជំរុញនិងខិតខំពង្រឹងការអនុវត្តច្បាប់ វិន័យការងារ និងត្រូវមានភាពទន់ភ្លន់តែម៉ឺងម៉ាត់ដោយផ្អែកលើទិដ្ឋភាពច្បាប់ក្នុងការផ្តល់សេវាអ្នកជាប់ពន្ធ និងការគ្រប់គ្រងប្រមូលចំណូលពន្ធ (១៧) បន្តពង្រឹងការផ្តល់សេវាពិគ្រោះយោបល់និងការផ្សព្វផ្សាយច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារតាមគ្រប់រូបភាព ជាពិសេសការផ្តល់សេវាពិគ្រោះយោបល់តាមរយៈទូរស័ព្ទ (Call Center-1277) និងការរៀបចំកម្មវិធី "ពន្ធដារកម្ពុជា" (GDT Facebook Live) ដើម្បីពន្យល់និងដោះស្រាយការលំបាកនិងចម្ងល់នានារបស់ប្រជាពលរដ្ឋ (១៨) បន្តពង្រឹងការងារចុះបញ្ជីពន្ធដារនិងធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាសនិងបន្តសហការ ចូលរួមកែលម្អ និងជំរុញការងារចុះបញ្ជីសហគ្រាសតាមថ្នាលបច្ចេកវិទ្យា ព័ត៌មាន (CamDX) ឱ្យកាន់តែមានប្រសិទ្ធភាព និងមានភាពគ្រប់ជ្រុងជ្រោយ (១៩) បន្តពង្រឹងប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាពរបស់ក្រុមការងារអ្នកនាំពាក្យនិងប្រតិកម្មរហ័សនៃអគ្គនាយកដ្ឋានពន្ធដារ និងការចូលរួមយ៉ាងសកម្មជាមួយក្រុមការងារតាមដានសាធារណមតិ និងប្រតិកម្មរហ័សរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីតាមដានបញ្ហាសាធារណមតិ និងផ្សព្វផ្សាយឱ្យសាធារណជនបានជ្រួតជ្រាបកាន់តែច្បាស់ពីការខិតខំប្រឹងប្រែង និងសមិទ្ធផលយ៉ាងសន្ធឹកសន្ធាប់ដែលរាជរដ្ឋាភិបាលបានសម្រេចជូនជាតិមាតុភូមិ។ (៥)

## គោលនយោបាយរូបិយវត្ថុ៖

សម្រាប់ឆ្នាំ២០២៣ រូបិយវត្ថុទូទៅ (M2) បានកើនឡើងមកវិញបន្តិចក្នុងអត្រា ១២,៥% បន្ទាប់ពីបានថមថយដល់កម្រិតទាបត្រឹម ៨,២% នាឆ្នាំមុន(២០២២)។ ការកើនឡើងនេះគឺដោយសារប្រាក់បញ្ញើជារៀលកើន ១៤,១% ប្រាក់បញ្ញើជារូបិយប័ណ្ណកើន ១៣% និងរូបិយវត្ថុក្នុងចរាចរណ៍កើន ៥,៩%។ ឆ្លើយតបនឹងតម្រូវការ និងដើម្បីរក្សាស្ថេរភាពអត្រាប្តូរប្រាក់ ធនាគារជាតិនៃកម្ពុជា បានធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់ចំនួន ១២ លើកដោយលក់ប្រាក់ដុល្លារអាមេរិកសរុបចំនួន ១៣៩,១ លានដុល្លារអាមេរិកទៅគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងអាជីវករប្តូរប្រាក់ធៀបនឹងការលក់ ៩ លានដុល្លារអាមេរិក។ ទន្ទឹមនឹងនេះ ការផ្តល់សន្ទនីយភាពជាប្រាក់រៀលដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ តាមរយៈប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា LPCO សរុបចំនួន ២,៥ ទ្រីលានរៀល (ប្រមាណ ៦០៥,១ លានដុល្លារអាមេរិក)។ រីឯការស្រូបយកសន្ទនីយភាពពីប្រព័ន្ធធនាគារមកវិញ តាមរយៈការចេញផ្សាយមូលបត្រអាចជួញដូរ (NCD) ក៏អាចប្រើប្រាស់ជាវត្ថុធានាសម្រាប់ប្រតិបត្តិការខ្ចីប្រាក់ពីធនាគារជាតិនៃកម្ពុជា និងទីផ្សារអន្តរធនាគារផងដែរ។ ធនាគារជាតិនៃកម្ពុជាបានបង្កើនការស្រូបយកប្រាក់រៀលពីប្រព័ន្ធធនាគារក្នុងរង្វង់ ១,៣-២,៦ ទ្រីលានរៀលក្នុង១ខែ ធៀបនឹង ៣០០-៥០០ ប៊ីលានរៀលប៉ុណ្ណោះក្នុង១ខែ នៅខែមីនា-កក្កដា ដើម្បីរួមចំណែកកាត់បន្ថយសម្ពាធថយថ្លៃនៃប្រាក់រៀលធៀបនឹងដុល្លារអាមេរិក។ អត្រាការប្រាក់ NCD ជារៀលជាមធ្យមបានថយចុះពី ១.៣៥% នៅឆ្នាំមុន(២០២២) មក ០,៩៤% ក្នុងនោះមាន ពី ០,៨៣% មក ០,៥៦% ពី ០,៩៣% មក ០,៦២% ពី ១,០២% មក ០,៨៦% ពី ១,៥៧% មក ១,៣៣% ពី ១,៧៧% មក ១,០៣% ពី ១,៩៧% មក ១,២៣% និងជាប្រាក់ដុល្លារអាមេរិកបានធ្លាក់ចុះពីជិត ៨០០ លានដុល្លារអាមេរិក នៅខែកុម្ភៈ ឆ្នាំ២០២៣ មកត្រឹមក្រោម ២០០ លានដុល្លារអាមេរិកចាប់ពីខែកញ្ញាមក ដោយមានអត្រាការប្រាក់បានថយចុះ ពី១,៦៥% នៅឆ្នាំ២០២២ មក ១,០៧% ជាមធ្យម ដែលក្នុងនោះ ពី ១,២៨% មក ០,៧៤% ពី១,៣២% មក ០,៧៨% ពី ១,៤០% មក ០,៨៦% ពី ១,៦៧% មក ១,២៩% ពី ១,៩៦% មក ១,៣៧% និង ២,២៧% មក ១,៣៩% រៀងគ្នា។ ជាលទ្ធផល អតិផរណារួមនៅឆ្នាំ២០២៣ មានកម្រិត ២,១% ទាបជាងឆ្នាំមុន (៥,៤%) ដោយសារការថយចុះថ្លៃក្រុមទំនិញនិងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈ និងការថមថយអតិផរណាម្ហូបអាហារ។ ស្របពេលដែលអត្រាប្តូរប្រាក់បន្តមានស្ថិរភាពក្នុងអត្រាមធ្យម ៤.១១០ រៀលក្នុង១ដុល្លារអាមេរិក ធៀបនឹង ឆ្នាំមុន ៤.១០២ រៀល ក្នុង១ដុល្លារអាមេរិក)។ (១)

សម្រាប់ឆ្នាំ២០២៣ ធនាគារជាតិ នៃ កម្ពុជា បានកំណត់អនុវត្តគោលនយោបាយរូបិយវត្ថុចំនួន៧ ដើម្បីគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការស្តារកំណើនសេដ្ឋកិច្ចជាតិ រួមមាន៖ (១) គ្រប់គ្រងការផ្គត់ផ្គង់រូបិយវត្ថុឲ្យស្ថិតក្នុងកម្រិតសមស្រប (២) រក្សាស្ថិរភាពអត្រាប្តូរប្រាក់ ដោយតាមដាននិងធ្វើអន្តរាគមន៍តាមការចាំបាច់ ដើម្បីរួមចំណែករក្សាស្ថិរភាពថ្លៃ និងជំនឿទុកចិត្តរបស់សាធារណជនលើរូបិយវត្ថុជាតិ (៣) លើកកម្ពស់ការប្រើប្រាស់ និងចំណេះដឹងពីប្រាក់រៀល (៤) កែលម្អ និងពង្រឹងប្រសិទ្ធភាពឧបករណ៍នយោបាយរូបិយវត្ថុដែលមាន និងអភិវឌ្ឍឧបករណ៍នយោបាយរូបិយវត្ថុថ្មីៗ (៥) អភិវឌ្ឍក្របខ័ណ្ឌកូរីដ័រអត្រាការប្រាក់ និងអនុវត្តអត្រាការប្រាក់គោល (៦) ជំរុញអភិវឌ្ឍន៍ទីផ្សារអន្តរធនាគារ ក្នុងគោលដៅលើកកម្ពស់ប្រសិទ្ធភាពគោលនយោបាយរូបិយវត្ថុ និង (៧) លើកកម្ពស់ការយល់ដឹងរបស់គ្រឹះស្ថានធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុស្តីពីក្របខ័ណ្ឌនិងឧបករណ៍នយោបាយរូបិយវត្ថុរបស់ធនាគារជាតិនៃកម្ពុជា។ (១)

### ឯកសារយោង:

(១) https://www.nbc.gov.kh/download_files/publication/annual_rep_kh/Annual_Report_2023_KHM.pdf

(២) https://www.adb.org/news/adb-adjusts-2023-growth-forecast-cambodia-maintains-2024-outlook

(៣) https://www.imf.org/en/Publications/WEO/Issues/2023/10/10/world-economic-outlook-october-2023

(៤) https://www.worldbank.org/en/publication/global-economic-prospects

(៥) https://www.tax.gov.kh/u6rhf7ogbi6/gdtstream/2e8790c9-020b-453f-b743-4b1bad3729a8

# ហត្ថលេខាអភិបាល

ថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៤
បានអាន និងឯកភាព

លោក **ឆាយ សឿន**,
ប្រធានក្រុមប្រឹក្សាភិបាល

ថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៤
បានអាន និងឯកភាព

បណ្ឌិត **អ៊ិន ចាន់នី**, អភិបាល

ថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៤
បានអាន និងឯកភាព

លោក Stéphane Mangiavacca,
អភិបាល

ថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៤
បានអាន និងឯកភាព

លោក Kyosuke Hattori, អភិបាល

ថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៤
បានអាន និងឯកភាព

បណ្ឌិត Albertus Bruggink, អភិបាល

ថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៤
បានអាន និងឯកភាព

លោក កាយ ឡូត, អភិបាល

ថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៤
បានអាន និងឯកភាព

លោក **Pieter Kooi**, អភិបាល

ថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៤
បានអាន និងឯកភាព

បណ្ឌិត ហេង ឌីណា, អភិបាល

ថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៤
បានអាន និងឯកភាព

លោកស្រី ភូរី រតនា, អភិបាល

# ឧបសម្ព័ន្ធនៃរបាយការណ៍ ប្រចាំឆ្នាំ២០២៣ របស់ធនាគារ អេស៊ីលីដា

## របាយការណ៍អភិបាលកិច្ចសាជីវកម្មប្រចាំឆ្នាំ

# ផ្នែកទី ១

## ភាគហ៊ុនិក

# ក. រចនាសម្ព័ន្ធភាគហ៊ុនិក (គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣)

## ១. ព័ត៌មានភាគហ៊ុនិក

| បរិយាយ | សញ្ជាតិ | ប្រភេទភាគហ៊ុនិក | ចំនួនភាគហ៊ុនិក | ចំនួនមូលបត្រ | ភាគរយ |
|---|---|---|---|---|---|
| តិចជាង ៥% | សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | ១៦.៦០៤ | ៦៥.៩៩១.៤៦០ | ១៥,២៣៤៨% |
| | | នីតិបុគ្គល | ៥ | ៣.៧២៥.៩៩០ | ០,៨៦០២% |
| | មិនមែនសញ្ជាតិខ្មែរ | រូបវន្តបុគ្គល | ៤៣៤ | ១.៣៦៧.១៥២ | ០,៣១៥៦% |
| | | នីតិបុគ្គល | ៩ | ៣៥.៥៩២.៨៦១ | ៨,២១៧០% |
| ចាប់ពី ៥% ដល់តិចជាង ៣០% | សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | - | - | - |
| | | នីតិបុគ្គល | ២ | ១៤៣.១៦៥.៨០០ | ៣៣,០៥១៣% |
| | មិនមែនសញ្ជាតិខ្មែរ | រូបវន្តបុគ្គល | - | - | - |
| | | នីតិបុគ្គល | ៣ | ១៨៣.៣១៩.៧៥៦ | ៤២,៣២១២% |
| ចាប់ពី ៣០% ឡើងទៅ | សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | - | - | - |
| | | នីតិបុគ្គល | - | - | - |
| | មិនមែនសញ្ជាតិខ្មែរ | រូបវន្តបុគ្គល | - | - | - |
| | | នីតិបុគ្គល | - | - | - |
| សរុប | | | ១៧.០៥៧ | ៤៣៣.១៦៣.០១៩ | ១០០,០០% |

## ២. ភាគហ៊ុនិកជាអភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិត

| ភាគហ៊ុនិក | ចំនួនភាគហ៊ុនិក | ចំនួនមូលបត្រ | ភាគរយ |
|---|---|---|---|
| អភិបាល | ២ | ១.០៣២.៣៤៨ | ២,២០០៤% |
| បុគ្គលិកជាន់ខ្ពស់ | ៧ | ១.៥៥២.៧៥៦ | ៣,៣០៩៦% |
| និយោជិត | ៧.១២៨ | ៤៤.៣៣០.៩៨១ | ៩៤,៤៨៩៩% |
| សរុប | ៧.១៣៧ | ៤៦.៩១៦.០៨៥ | ១០០,០០% |

# ខ. សិទ្ធិរបស់ភាគហ៊ុនិក និងការការពារសិទ្ធិរបស់ភាគហ៊ុនិក

## ១. សិទ្ធិរបស់ភាគហ៊ុនិក

ភាគហ៊ុនិករបស់ធនាគារ ត្រូវទទួលបាននូវ៖

- សិទ្ធិចូលរួមមហាសន្និបាតភាគហ៊ុនិក
- សិទ្ធិបោះឆ្នោតដោយផ្ទាល់ ឬតាមរយៈអ្នកតំណាង ក្នុងមហាសន្និបាតភាគហ៊ុនិក
- សិទ្ធិទទួលបានភាគលាភ ឬផលប្រយោជន៍ដែលបានប្រកាសដោយធនាគារ
- សិទ្ធិទទួលបានទ្រព្យសម្បត្តិ ដែលនៅសល់របស់ធនាគារបន្ទាប់ពីការរំលាយ និងជម្រះបញ្ជី និង
- សិទ្ធិទទួលបានព័ត៌មានគ្រប់ប្រភេទ រួមទាំងព័ត៌មានអំពីអាជីវកម្មរបស់ធនាគារ ព្រមទាំងសៀវភៅ និងកំណត់ត្រាគណនេយ្យរបស់ធនាគារ ព្រមទាំងអាចពិនិត្យបញ្ជីឈ្មោះភាគហ៊ុនិក បាននៅទីស្នាក់ការកណ្តាល របស់ធនាគារនៅក្នុងម៉ោងធ្វើការ ឬនៅពេលមហាសន្និបាតភាគហ៊ុនិក។

## ២. ការការពារសិទ្ធិរបស់ភាគហ៊ុនិក

សិទ្ធិរបស់ភាគហ៊ុនិក គឺត្រូវបានការពារដោយលក្ខន្តិកៈ របស់ធនាគារ អេស៊ីលីដា។ អនុលោមតាមមាត្រា១៤ (១៤.១ ចំណុចទី១) នៃលក្ខន្តិកៈ របស់ធនាគារ បានចែងថា “ភាគហ៊ុននីមួយៗរបស់ធនាគារផ្តល់ដល់អ្នកកាន់កាប់នូវសិទ្ធិបោះឆ្នោត ១ (មួយ) សំឡេងក្នុងមហាសន្និបាតភាគហ៊ុនិក”។

## ៣. ការការពារសិទ្ធិរបស់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនតិច

ភាគហ៊ុននីមួយៗ មានសិទ្ធិបោះឆ្នោត១ (មួយ) សំឡេង។ សិទ្ធិរបស់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនភាគតិច ត្រូវបានការពារដោយលក្ខន្តិកៈ របស់ធនាគារ អេស៊ីលីដា។

# គ. មហាសន្និបាតភាគហ៊ុនិក

## ១. នីតិវិធីនៃការរៀបចំមហាសន្និបាតភាគហ៊ុនិក និងការបោះឆ្នោត

ធនាគារបានអនុម័តនូវគោលការណ៍ស្តីពីការបោះឆ្នោតមហាសន្និបាតភាគហ៊ុនិក ដែលផ្តល់នូវវិធាន និងការណែនាំច្បាស់លាស់ដល់ភាគហ៊ុនិក អំពីដំណើរការបោះឆ្នោតនៅក្នុងមហាសន្និបាតភាគហ៊ុនិក។

### កូរ៉ុម

កូរ៉ុម នៃកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក គឺជាចំនួនភាគហ៊ុនិកដែលចូលរួមដោយផ្ទាល់ និងតាមរយៈការប្រគល់សិទ្ធិ (អ្នកតំណាងដោយអាណត្តិ) ដែលកាន់កាប់ភាគហ៊ុនចំនួនយ៉ាងតិច៥១% នៃចំនួនភាគហ៊ុនសរុបរបស់ធនាគារ។

### ការជូនដំណឹង អំពីកិច្ចប្រជុំ

លិខិតជូនដំណឹងអំពី កិច្ចប្រជុំ នឹងត្រូវផ្ញើជូនភាគហ៊ុនិកតាមមធ្យោបាយផ្សេងៗដូចជា៖ Hard copy និង/ឬ តាមរយៈប្រព័ន្ធអេឡិចត្រូនិក ក្នុងកំឡុងពេលចាប់ពី២០ទៅ៥០ថ្ងៃមុនកាលបរិច្ឆេទប្រជុំ។ លិខិតជូនដំណឹងអំពី កិច្ចប្រជុំ មានបញ្ជាក់ច្បាស់អំពី កាលបរិច្ឆេទ ពេលវេលា និងទីកន្លែង ដែលនឹងត្រូវប្រារព្ធកិច្ចប្រជុំ។

### កំឡុងពេលប្រជុំ និងដំណើរការបោះឆ្នោត

ប្រធានក្រុមប្រឹក្សាភិបាលនឹងចាប់ផ្តើមកិច្ចប្រជុំដោយផ្តល់នូវមតិស្វាគមន៍ និងកំណត់បង្ហាញនូវកូរ៉ុមដែលបានចូលរួម និងប្រកាសអំពី របៀបវារៈនៃកិច្ចប្រជុំ។ ប្រធានក្រុមប្រឹក្សាភិបាលបញ្ជាក់អំពី នីតិវិធីនៃការបោះឆ្នោតជូនដល់ភាគហ៊ុនិកដែលបានចូលរួម មុននឹងប្រកាសចាប់ផ្តើមដំណើរការបោះឆ្នោតលើសេចក្តីសម្រេចណាមួយ។

ធនាគារនឹងចាត់តាំងជាមុននូវបុគ្គលិក សម្រាប់ជួយសម្របសម្រួលដល់ដំណើរការនៃការបោះឆ្នោត។ លទ្ធផលនៃការបោះឆ្នោត នឹងត្រូវប្រកាសក្រោយពេលដែលការរាប់សន្លឹកឆ្នោត និងលិខិតប្រគល់សិទ្ធិ ដោយផ្ទាល់ដៃ ឬដោយប្រព័ន្ធ ត្រូវបានបញ្ចប់។

### ក្រោយកិច្ចប្រជុំ

ធនាគារត្រូវធ្វើការបង្ហាញព័ត៌មាន និងរាយការណ៍ស្របតាមប្រកាសលេខៈ ០០៧/១៨ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨ ស្តីពី ការបង្ហាញព័ត៌មានសាជីវកម្ម ដែលចេញដោយ ន.ម.ក. និងស្របតាមគោលការណ៍ស្តីពី ការបង្ហាញព័ត៌មានរបស់ធនាគារ។

## ២. ព័ត៌មានមហាសន្និបាតភាគហ៊ុនិក

| លរ | កាលបរិច្ឆេទ/ ប្រភេទកិច្ចប្រជុំ | កូរ៉ុមនៃ កិច្ចប្រជុំ | របៀបវារៈ | សេចក្តីសម្រេច |
|---|---|---|---|---|
| ០១ | ២៧ មេសា ២០២៣ AGM | ៨៣,៧១% | បញ្ហាដែលត្រូវសម្រេច៖<br>• អនុម័តការបែងចែកភាគលាភ | ភាគហ៊ុនិកបានសម្រេចដូចខាងក្រោម៖<br>• អនុម័តការបែងចែកភាគលាភជាសាច់ប្រាក់ចំនួន ៤០ភាគរយ នៃប្រាក់ចំណេញ ក្នុងឆ្នាំ២០២២ ដែលផ្តល់ជូនដល់ភាគហ៊ុនិក របស់ធនាគារ អេស៊ីលីដា ចំនួន៧៤២.៧៦៤.៦៧០.០០០រៀល ស្មើនឹង ២៩៧.១០៥.៨៦៨.៩៨៧,៥៨ រៀល ក្នុងអត្រា៦៨៥,៨៩៨៥ រៀល ក្នុង១ភាគហ៊ុន និងរក្សាប្រាក់ចំណេញនៅសល់ ក្នុងខ្ទង់ប្រាក់ចំណេញរក្សាទុករបស់ធនាគារ អេស៊ីលីដា។ ភាគហ៊ុនិក ទាំងអស់បានបោះឆ្នោតគាំទ្រដោយសំឡេង ៩៩,៩៣ ភាគរយ។ |
| | | | • អនុម័តគោលការណ៍ភាគលាភ | • អនុម័តគោលការណ៍ភាគលាភ។ ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រ ដោយសំឡេង ៩៩,៩៣ ភាគរយ។ |
| | | | • អនុម័តការតែងតាំងសមាជិកក្រុមប្រឹក្សាសម្រាប់អាណត្តិថ្មី រយៈពេល៣ឆ្នាំបន្ថែមទៀត | • អនុម័តការតែងតាំង លោក ឆាយ សឿន ជាអភិបាលធនាគារ អេស៊ីលីដា សម្រាប់អាណត្តិថ្មី រយៈពេល៣ឆ្នាំបន្ថែមទៀត។ ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រដោយសំឡេង ៩៩,៩៣ ភាគរយ។<br>• អនុម័តការតែងតាំង បណ្ឌិត អ៊ិន ចាន់នី ជាអភិបាលធនាគារ អេស៊ីលីដា សម្រាប់អាណត្តិថ្មី រយៈពេល៣ឆ្នាំបន្ថែមទៀត។ ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រដោយសំឡេង ៩៩,៩៣ ភាគរយ។<br>• អនុម័តការតែងតាំង លោក វ៉ាន់ ស៊ូអៀង ជាអភិបាលឯករាជ្យ នៅធនាគារ អេស៊ីលីដា រហូតដល់ថ្ងៃចូលនិវត្តន៍ នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៣។ ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រដោយសំឡេង ៩៩,៩២ ភាគរយ។ |
| | | | • អនុម័តការជ្រើសរើសសវនករឯករាជ្យប្រចាំធនាគារ អេស៊ីលីដា សម្រាប់ឆ្នាំហិរញ្ញវត្ថុ ២០២៤ | • អនុម័តការជ្រើសរើស PricewaterhouseCoopers ("PwC") ជាសវនករឯករាជ្យរបស់ធនាគារ អេស៊ីលីដា សម្រាប់ឆ្នាំហិរញ្ញវត្ថុ ២០២៤។ ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រដោយសំឡេង ៩៩,៩២ ភាគរយ។ |
| | | | • អនុម័តការដំឡើងប្រាក់បៀវត្សប្រចាំឆ្នាំសម្រាប់ប្រធានក្រុមប្រឹក្សាភិបាល | • អនុម័តការដំឡើងលាភការជូនប្រធានក្រុមប្រឹក្សាភិបាលដូចខាងក្រោម៖<br>▪ ដំឡើងប្រាក់បៀវត្សជូន លោក ឆាយ សឿន ប្រធានក្រុមប្រឹក្សាភិបាល ដោយទទួលបានចំណាត់ថ្នាក់ "A+" ដែលមានប្រសិទ្ធភាព អនុវត្តប្រតិសកម្ម ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៣។<br>▪ បូកបន្ថែមអត្រាអតិផរណាប្រចាំឆ្នាំ២០២២ ចំនួន ៣% (បីភាគរយ) លើប្រាក់បៀវត្សរបស់ប្រធានក្រុមប្រឹក្សាភិបាល ដែលមានប្រសិទ្ធភាព ចាប់ពីថ្ងៃទី១ ខែមេសា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៤។ ភាគហ៊ុនិកទាំងអស់បានបោះឆ្នោត គាំទ្រដោយសំឡេង ៩៩,៨៩ ភាគរយ។ |
| | | | • អនុម័តការដំឡើងកម្រៃសេវាសម្រាប់ក្រុមប្រឹក្សាភិបាល ៣% ស្របតាមអត្រាអតិផរណាឆ្នាំ២០២២; និង | • អនុម័តកម្រៃសេវា សម្រាប់ក្រុមប្រឹក្សាភិបាលរបស់ធនាគារ អេស៊ីលីដា ស្របតាមអត្រាអតិផរណាប្រចាំឆ្នាំ២០២២ ចំនួន៣% (បីភាគរយ)។ ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រដោយសំឡេង ៩៩,៨៩ ភាគរយ។ |
| | | | • អនុម័តកាលបរិច្ឆេទកំណត់ទុកសម្រាប់ភាគហ៊ុនិក ដែលត្រូវទទួលបានភាគលាភ | • អនុម័តកាលបរិច្ឆេទកំណត់ទុកនៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៣ សម្រាប់ កាលបរិច្ឆេទប្រកាសបញ្ជីឈ្មោះភាគហ៊ុនិក ដែលត្រូវទទួលបានភាគលាភ។ ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រដោយសំឡេង ៩៩,៨៦ ភាគរយ។ |

| លរ | កាលបរិច្ឆេទ/ ប្រភេទកិច្ចប្រជុំ | កូរ៉ុមនៃ កិច្ចប្រជុំ | របៀបវារៈ | សេចក្តីសម្រេច |
|---|---|---|---|---|
| | | | • អនុម័តការធ្វើវិសោធនកម្មលើមាត្រា៨ ឧបសម្ព័ន្ធ១ ឧបសម្ព័ន្ធ៣ និងឧបសម្ព័ន្ធ៤ នៃលក្ខន្តិកៈ ធនាគារ អេស៊ីលីដា | • អនុម័តការធ្វើវិសោធនកម្មលើមាត្រា៨ ("ការទិញភាគហ៊ុន") ឧបសម្ព័ន្ធ១ ("សមាសភាពនៃក្រុមប្រឹក្សាភិបាលរបស់ធនាគារអេស៊ីលីដា") ឧបសម្ព័ន្ធ៣ ("បញ្ជីឈ្មោះភាគហ៊ុនិកសាធារណៈរបស់ ធនាគារ អេស៊ីលីដា") និងឧបសម្ព័ន្ធ៤ ("បញ្ជីឈ្មោះភាគហ៊ុនិកដែលធ្វើនិយ័តកម្មពីក្រុមហ៊ុន អេ អេស អេ ភីអិលស៊ី") នៃលក្ខន្តិកៈ ធនាគារ អេស៊ីលីដា។ ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រ ដោយសំឡេង ៩៩,៨២ ភាគរយ៕ |
| ០២ | ១៨ កញ្ញា ២០២៣ EGM | ៨៤,៦១% | • អនុម័ត និងតែងតាំង បណ្ឌិត ហេង ឌីណា ជាអភិបាលឯករាជ្យ | • អនុម័ត និងតែងតាំង បណ្ឌិត ហេង ឌីណា ជាអភិបាលឯករាជ្យ ធនាគារ អេស៊ីលីដា។ ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រដោយសំឡេង ៩៩,៧៧ភាគរយ។ |
| | | | • អនុម័ត និងទទួលស្គាល់ការតែងតាំង លោក Takeshi Kimoto ជាតំណាងភាគហ៊ុនិកថ្មី មកពីស្ថាប័ន SMBC នៅធនាគារ អេស៊ីលីដា ជំនួសលោក Hideomi Shigematsu | • អនុម័ត និងទទួលស្គាល់ការតែងតាំង លោក Takeshi Kimoto ជាតំណាងភាគហ៊ុនិកថ្មី មកពីស្ថាប័ន SMBC នៅធនាគារ អេស៊ីលីដា ជំនួសលោក Hideomi Shigematsu។ ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រ ដោយសំឡេង ៩៩,៩៦ភាគរយ។ |
| | | | • អនុម័តការធ្វើវិសោធនកម្ម ឧបសម្ព័ន្ធ១ ("សមាសភាពក្រុមប្រឹក្សាភិបាល ធនាគារ អេស៊ីលីដា ភីអិលស៊ី") នៃលក្ខន្តិកៈ ធនាគារ អេស៊ីលីដា។ | • អនុម័តការធ្វើវិសោធនកម្ម ឧបសម្ព័ន្ធ១ ("សមាសភាពក្រុមប្រឹក្សាភិបាល ធនាគារ អេស៊ីលីដា ភីអិលស៊ី") នៃលក្ខន្តិកៈ ធនាគារ អេស៊ីលីដា។ ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រដោយសំឡេង ៩៩,៩២ភាគរយ។ |

# ឃ. ការបែងចែកភាគលាភ

## ១. គោលការណ៍បែងចែកភាគលាភ

ធនាគារបានដាក់ចេញនូវគោលការណ៍ ស្តីពីការបែងចែកភាគលាភ ដើម្បីកំណត់នូវគោលការណ៍ និងការណែនាំ អំពីការបែងចែកភាគលាភជូនភាគហ៊ុនិកប្រកបដោយភាពត្រឹមត្រូវ និងមានប្រសិទ្ធភាព។ ធនាគារចាត់ថ្នាក់ភាគលាភជាប្រភេទដូចខាងក្រោម៖

- ភាគលាភជាសាច់ប្រាក់
- ភាគលាភជាភាគហ៊ុន និង
- ភាគលាភជាទម្រង់ផ្សេងតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល និងភាគហ៊ុនិក ស្របតាម ច្បាប់ បទប្បញ្ញត្តិ និងការអនុវត្តតាមស្តង់ដារអន្តរជាតិ។

## ២. ព័ត៌មានអំពីការបែងចែកភាគលាភក្នុងរយៈពេល ៣ (បី) ឆ្នាំចុងក្រោយ

| លរ | ពិពណ៌នាលម្អិតអំពីការបែងចែកភាគលាភ | ២០២៣ | ២០២២ | ២០២១ |
|---|---|---|---|---|
| ១ | កាលបរិច្ឆេទប្រកាសបែងចែកភាគលាភ | ២៨ មេសា ២០២៣ | ៨ មិថុនា ២០២២ | ដំណាក់កាលទី១៖ ១ មិថុនា ឆ្នាំ២០២១<br>ដំណាក់កាលទី២៖ ២៦ វិច្ឆិកា ឆ្នាំ២០២១<br>ដំណាក់កាលទី៣៖ ២៩ ធ្នូ ឆ្នាំ២០២១ |
| ២ | កាលបរិច្ឆេទកំណត់ទុក | ១០ ឧសភា ២០២៣ | ៦ ឧសភា ២០២២ | ៣ ឧសភា ២០២១ |
| ៣ | កាលបរិច្ឆេទទូទាត់ភាគលាភ | ១៩ ឧសភា ២០២៣ (សាច់ប្រាក់) | ១០ មិថុនា ២០២២ (សាច់ប្រាក់) | ដំណាក់កាលទី១៖ ១០ មិថុនា ២០២១ (សាច់ប្រាក់)<br>ដំណាក់កាលទី២៖ ៦ ធ្នូ ២០២១ (សាច់ប្រាក់)<br>ដំណាក់កាលទី៣៖ ៣០ ធ្នូ ២០២១ (សាច់ប្រាក់) |

# ផ្នែកទី ២

## ក្រុមប្រឹក្សាភិបាល

# ក. ក្រុមប្រឹក្សាភិបាល

## ១. សមាសភាពក្រុមប្រឹក្សាភិបាល

| ល.រ | ឈ្មោះអភិបាល | តំណែង | កាលបរិច្ឆេទក្លាយជាអភិបាល | កាលបរិច្ឆេទបញ្ចប់អាណត្តិ |
|---|---|---|---|---|
| ១ | **លោក ឆាយ សឿន** | ប្រធានក្រុមប្រឹក្សាភិបាល | ១៨ សីហា ២០១៤ | ១៨ សីហា ២០២៦ |
| ២ | **បណ្ឌិត អ៊ិន ចាន់នី** | អភិបាលប្រតិបត្តិ | ១៨ សីហា ២០១៤ | ១៨ សីហា ២០២៦ |
| ៣ | **លោក** Pieter Kooi | អភិបាលឯករាជ្យ | ១២ មករា ២០០៤ | ១២ មករា ២០២៥ |
| ៤ | **បណ្ឌិត ហេង ឌីណា** | អភិបាលឯករាជ្យ | ១១ ធ្នូ ២០២៣ | ១១ ធ្នូ ២០២៦ |
| ៥ | **លោកស្រី ភូរិ រតនា** | អភិបាលឯករាជ្យ | ០៨ វិច្ឆិកា ២០២១ | ០៨ វិច្ឆិកា ២០២៤ |
| ៦ | **លោក** Stéphane Mangiavacca | អភិបាលមិនប្រតិបត្តិ | ២២ មេសា ២០២០ | ២១ សីហា ២០២៤ |
| ៧ | **លោក** Kyosuke Hattori | អភិបាលមិនប្រតិបត្តិ | ០៨ វិច្ឆិកា ២០២១ | ០៦ ធ្នូ ២០២៥ |
| ៨ | **បណ្ឌិត** Albertus Bruggink | អភិបាលមិនប្រតិបត្តិ | ១២ ឧសភា ២០២១ | ១០ មករា ២០២៥ |
| ៩ | **លោក កាយ ឡូត** | អភិបាលមិនប្រតិបត្តិ | ១២ ឧសភា ២០២១ | ១២ ឧសភា ២០២៤ |

សម្គាល់៖ លោក វ៉ាន់ ស៊ូអៀង ដែលជាអភិបាលឯករាជ្យរបស់ ធនាគារ អេស៊ីលីដា បានចូលនិវត្តន៍នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៣។

## ២. ជីវប្រវត្តិសង្ខេបរបស់អភិបាលនីមួយៗ

### លោក ឆាយ សឿន, ប្រធានក្រុមប្រឹក្សាភិបាល

### គណៈកម្មាធិការក្រុមប្រឹក្សាភិបាល ៖ គណៈកម្មាធិការសវនកម្ម

ជនជាតិខ្មែរ កើតក្នុងខែមេសា ឆ្នាំ១៩៥៤ លោកបានចូលរួមក្នុងក្រុមប្រឹក្សាភិបាលនៅខែសីហា ឆ្នាំ២០១៤។ លោកបានចូលបម្រើការជាមួយអេស៊ីលីដា ចាប់តាំងពីខែមករា ឆ្នាំ១៩៩៣ រហូតដល់ចូលនិវត្តន៍នៅខែមេសា ឆ្នាំ២០១៤។ តួនាទីចុងក្រោយមុនចូលនិវត្តន៍របស់លោកនៅក្នុងធនាគារ អេស៊ីលីដា ភីអិលស៊ី ជាអនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិហិរញ្ញវត្ថុ។ លោកធ្លាប់ធ្វើជាគណនេយ្យករ និងជាអនុប្រធានគណនេយ្យករនៃមន្ទីរពាណិជ្ជកម្មខេត្តកំពត ពីឆ្នាំ១៩៨០ ដល់ឆ្នាំ១៩៩២។

បច្ចុប្បន្នលោកជាប្រធានក្រុមប្រឹក្សាភិបាលនៃ ធនាគារ អេស៊ីលីដា ភីអិលស៊ី សមាជិកក្រុមប្រឹក្សាភិបាល ធនាគារ អេស៊ីលីដា ឡាវ និងសមាជិកក្រុមប្រឹក្សាភិបាល ស្ថាប័នមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា មីយ៉ាន់ម៉ា។

លោកបានបញ្ចប់ថ្នាក់អនុបណ្ឌិតប្រតិបត្តិគ្រប់គ្រងពាណិជ្ជកម្ម ជំនាញហិរញ្ញវត្ថុ និងគណនេយ្យ ពីសាកលវិទ្យាល័យ Preston នៅសហរដ្ឋអាមេរិក។ លោកក៏បានបញ្ចប់វគ្គសិក្សាស្តីពីអភិបាលក្រុមហ៊ុន ពីវិទ្យាស្ថានអូស្ត្រាលីសម្រាប់អភិបាលក្រុមហ៊ុន (GAICD)។

### បណ្ឌិត អ៊ិន ចាន់នី, អភិបាល

ជនជាតិខ្មែរ កើតក្នុងខែមិថុនា ឆ្នាំ១៩៦០ លោកបណ្ឌិតជាប្រធាននាយកប្រតិបត្តិ របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ចាប់តាំងពីធនាគារបានបង្កើតឡើងនៅក្នុងឆ្នាំ២០០០។ លោកបណ្ឌិតបានក្លាយជាសមាជិកក្រុមប្រឹក្សាភិបាលរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី នៅខែសីហា ឆ្នាំ២០១៤។ បណ្ឌិត អ៊ិន ចាន់នី ជាសហស្ថាបនិករបស់សមាគមទីភ្នាក់ងារអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា (អេស៊ីលីដា) តាំងពីខែមករា ឆ្នាំ១៩៩៣។ ក្នុងតួនាទីជាប្រធាននាយកប្រតិបត្តិ លោកបណ្ឌិតដឹកនាំគណៈកម្មាធិការប្រតិបត្តិ ដែលទទួលខុសត្រូវរៀបចំផែនការយុទ្ធសាស្ត្ររួម និងដំណើរការអាជីវកម្មប្រចាំថ្ងៃ ព្រមទាំងប្រតិបត្តិផែនការអាជីវកម្មរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី និងក្រុមហ៊ុនបុត្រសម្ព័ន្ធ។ លោកបណ្ឌិតទទួលខុសត្រូវផ្ទាល់ចំពោះក្រុមប្រឹក្សាភិបាល។

ទំនួលខុសត្រូវផ្សេងទៀតរបស់លោកបណ្ឌិត រួមមាន ជាប្រធានក្រុមប្រឹក្សាភិបាលធនាគារ អេស៊ីលីដា ឡាវ និងស្ថាប័នមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា មីយ៉ាន់ម៉ា ព្រមទាំងជាតំណាងភាគហ៊ុនិក របស់ធនាគារ អេស៊ីលីដា ឡាវ អេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា និងស្ថាប័នមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា មីយ៉ាន់ម៉ា។ លោកបណ្ឌិតក៏ជាប្រធានក្រុមបរធនបាល អេស៊ីលីដា ហ្វាយណាន់ហ្សល់ ត្រាស់។

ក្រៅពីធនាគារ អេស៊ីលីដា បណ្ឌិត អ៊ិន ចាន់នី ក៏ជាប្រធានសមាគមធនាគារនៅកម្ពុជាពីរអាណត្តិជាប់គ្នា ពីឆ្នាំ២០១៩ ដល់ខែមីនា ឆ្នាំ២០២២។ បច្ចុប្បន្នលោកបណ្ឌិតជាសមាជិកក្រុមប្រឹក្សានៃសមាគមធនាគារនៅកម្ពុជា និងជាសហប្រធានក្រុមការងារសេវាកម្មធនាគារ និងហិរញ្ញវត្ថុ។

នៅក្នុងឆ្នាំ១៩៩៨ លោកបណ្ឌិតបានបញ្ចប់វគ្គគ្រប់គ្រងស្តីពី ស្ថាប័នហិរញ្ញវត្ថុសម្រាប់អភិវឌ្ឍន៍សហគ្រាសឯកជន (FIPED) ពីសាកលវិទ្យាល័យ Harvard សហរដ្ឋអាមេរិក។ លោកបណ្ឌិតបានបញ្ចប់ការសិក្សាថ្នាក់បណ្ឌិត ផ្នែកគ្រប់គ្រងអាជីវកម្ម និងបានបញ្ចប់វគ្គសិក្សាស្តីពី អភិបាលក្រុមហ៊ុនពីវិទ្យាស្ថានអូស្ត្រាលីសម្រាប់អភិបាលក្រុមហ៊ុន (GAICD)។

### លោក Pieter Kooi, អភិបាល

#### គណៈកម្មាធិការក្រុមប្រឹក្សាភិបាល ៖ គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងព័ត៌មានវិទ្យា (ប្រធាន), គណៈកម្មាធិការតែងតាំង និងលាភការ (ប្រធាន), គណៈកម្មាធិការសវនកម្ម

ជនជាតិហូឡង់ កើតក្នុងឆ្នាំ១៩៥៨ លោក Kooi បានចូលរួមក្នុងក្រុមប្រឹក្សាភិបាលនៅខែតុលា ឆ្នាំ២០០០។ ចាប់ពីឆ្នាំ១៩៩៣ លោកបានធ្វើជាទីប្រឹក្សាមីក្រូហិរញ្ញវត្ថុឱ្យអេស៊ីលីដា រយៈពេលជាង៧ឆ្នាំ ដើម្បីកម្លាយខ្លួនពីកម្មវិធីអភិវឌ្ឍន៍ទៅជាធនាគារពាណិជ្ជ។ ចាប់ពីឆ្នាំ១៩៩៩ លោកបានបម្រើការងារជាទីប្រឹក្សាមីក្រូហិរញ្ញវត្ថុរយៈពេលខ្លីដល់ស្ថាប័នមីក្រូហិរញ្ញវត្ថុ នៅក្នុង១៥ប្រទេស ដែលភាគច្រើនស្ថិតក្នុងទ្វីបអាហ្វ្រិក និងអាស៊ី។ ចាប់ពីខែកញ្ញា ឆ្នាំ២០០២ ដល់ខែធ្នូ ឆ្នាំ២០០៥ លោកមានតួនាទីជានាយកផ្នែកមីក្រូហិរញ្ញវត្ថុរបស់ UNCDF ក្នុងទីក្រុងញូវយ៉ក។ ចាប់ពីខែមីនា ឆ្នាំ២០០៦ រហូតដល់ខែឧសភា ឆ្នាំ២០១១ លោកបានធ្វើជាទីប្រឹក្សាក្រៅម៉ោងឱ្យធនាគារ អេស៊ីលីដា ភីអិលស៊ី ក្នុងការបង្កើតធនាគារ អេស៊ីលីដា ឡាវ អេស៊ីលីដា ត្រេននីង សេនធ័រ (បច្ចុប្បន្នជា វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា) និងអេស៊ីលីដា ស៊ីយូរីធី ភីអិលស៊ី។ បច្ចុប្បន្ន លោកមានតួនាទីជាក្រុមប្រឹក្សាភិបាលជាច្រើននៅធនាគារ អេស៊ីលីដា គ្រុប។

លោកទទួលបានអនុបណ្ឌិតផ្នែកហិរញ្ញវត្ថុសាជីវកម្ម និងសង្គមវិទ្យា នៅសាកលវិទ្យាល័យ Erasmus ក្នុងទីក្រុង Rotterdam ប្រទេសហូឡង់។ លោកក៏បានបញ្ចប់ការសិក្សាពីវិទ្យាស្ថានអូស្ត្រាលីសម្រាប់អភិបាលក្រុមហ៊ុន (GAICD)។

### បណ្ឌិត ហេង ឌីណា, អភិបាល

#### គណៈកម្មាធិការក្រុមប្រឹក្សាភិបាល ៖ គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងព័ត៌មានវិទ្យា

ជាជនជាតិខ្មែរ បណ្ឌិត ហេង ឌីណា បានចូលជាសមាជិកក្រុមប្រឹក្សាភិបាលនៅខែធ្នូ ឆ្នាំ២០២៣ ដោយនាំមកនូវបទពិសោធន៍ជាង ១០ ឆ្នាំជាអ្នកជំនាញផ្នែកហិរញ្ញវត្ថុ និងម៉ាក្រូសេដ្ឋកិច្ច នៅស្ថាប័នអន្តរជាតិ។ លោកបណ្ឌិតមានបទពិសោធន៍យ៉ាងទូលំទូលាយក្នុងការវិភាគហានិភ័យ ការឃ្លាំមើលម៉ាក្រូសេដ្ឋកិច្ច និងការវាយតម្លៃផ្នែកហិរញ្ញវត្ថុ។ បណ្ឌិត ហេង ឌីណា ក៏ធ្លាប់បានដឹកនាំកម្មវិធីជំនួយបច្ចេកទេស និងការបណ្តុះបណ្តាលជាច្រើនដល់មន្ត្រីធនាគារ កណ្តាល និងក្រសួងហិរញ្ញវត្ថុ នៅបណ្តាប្រទេសនៅអាស៊ី អាហ្វ្រិក និងអឺរ៉ុប។ បច្ចុប្បន្ន លោកបណ្ឌិតគឺជាអ្នកវិភាគសេដ្ឋកិច្ច នៅសហរដ្ឋអាមេរិក និងជាសមាជិកក្រុមប្រឹក្សាភិបាលសមាគមសេដ្ឋកិច្ចកម្ពុជា។

បណ្ឌិត ហេង ឌីណា បានបញ្ចប់កម្មវិធីគ្រប់គ្រងទ្រព្យសកម្ម និងផលបត្រ (Asset and Portfolio management Program) នៅសាលា Wharton និងទទួលបានសញ្ញាប័ត្របណ្ឌិតផ្នែកសេដ្ឋកិច្ចពីសាកលវិទ្យាល័យជាតិអូស្ត្រាលី ប្រទេសអូស្ត្រាលីក្នុងឆ្នាំ២០១២។ លោកបណ្ឌិតក៏បានទទួលសញ្ញាប័ត្រអនុបណ្ឌិតផ្នែកសេដ្ឋកិច្ចពីសាកលវិទ្យាល័យ Hitotsubashi ទីក្រុងតូក្យូ ប្រទេសជប៉ុន និងបរិញ្ញាបត្រផ្នែកសេដ្ឋកិច្ចពីសាកលវិទ្យាល័យ Nagoya។ បណ្ឌិត ហេង ឌីណា ក៏បានទទួលជ័យលាភីគណិតវិទ្យាទូទាំងប្រទេស (ចំណាត់ថ្នាក់លេខ ៤) ក្នុងឆ្នាំ២០០០។

### លោកស្រី ភូរិ រតនា, អភិបាល

#### គណៈកម្មាធិការក្រុមប្រឹក្សាភិបាល៖ គណៈកម្មាធិការសវនកម្ម (ប្រធាន)

ជនជាតិខ្មែរ (និងមានសញ្ជាតិបារាំង) កើតនៅឆ្នាំ១៩៧២ លោកស្រី ភូរិ រតនា បានចូលរួមក្នុងក្រុមប្រឹក្សាភិបាល នៅខែវិច្ឆិកា ឆ្នាំ២០២១ ហើយលោកស្រីក៏ជាប្រធានក្រុមប្រឹក្សាភិបាល នៃវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ចាប់តាំងពីខែវិច្ឆិកា ឆ្នាំ២០២២។ លោកស្រីជា CFA Charterholder។ លើសពីនេះ លោកស្រីទទួលបានសញ្ញាបត្រថ្នាក់ក្រោយបរិញ្ញាបត្រ (DEA) និងជាបេក្ខជនបណ្ឌិត ជំនាញឧស្សាហកម្មសេដ្ឋកិច្ច បរិញ្ញាបត្រជាន់ខ្ពស់វិទ្យាសាស្ត្រ ជំនាញពាណិជ្ជកម្មបរទេស និងបរិញ្ញាបត្រជាន់ខ្ពស់សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យប៉ារីស១ Panthéon-Sorbonne។ លោកស្រីបានបញ្ចប់ការសិក្សាពីវិទ្យាស្ថានអូស្ត្រាលី សម្រាប់អភិបាលក្រុមហ៊ុន (GAICD)។

លោកស្រី រតនា មានបទពិសោធន៍២៥ឆ្នាំ ក្នុងវិស័យពាណិជ្ជកម្មអន្តរជាតិ ការវិនិយោគ ការអភិវឌ្ឍវិស័យឯកជន និងហិរញ្ញវត្ថុ។ លោកស្រីមានប្រវត្តិធ្វើមជាទីប្រឹក្សា/អ្នកសេដ្ឋកិច្ច រួមទាំងមានបទពិសោធន៍ផ្ទាល់នៅក្នុងតួនាទីជាអ្នកគ្រប់គ្រងជាន់ខ្ពស់។ បច្ចុប្បន្ន លោកស្រីគឺជាទីប្រឹក្សាជាន់ខ្ពស់ សម្រាប់ការវិនិយោគ និងវិស័យឯកជនឱ្យអង្គការអន្តរជាតិផ្សេងៗ និងជាក្រុមប្រឹក្សាផ្តល់យោបល់ដល់សហគ្រាសខ្មែរ អ៊ីមផែកហាប់ និងស្មួលរើល។ លោកស្រីគឺជាអភិបាលឯករាជ្យនៅធនាគារពាណិជ្ជមួយនៅកម្ពុជា ចាប់ពីឆ្នាំ២០១៤ ដល់២០២១។ លោកស្រីបានលាលែងតំណែងជា អភិបាលឯករាជ្យ នៅ I-Finance Leasing (ដោយក្រុមហ៊ុនបានលក់ទៅ គូកមីន នាចុងឆ្នាំ២០២២) ហើយលោកស្រីបានក្លាយជាប្រធានក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា។ បន្ថែមលើនេះ លោកស្រីគឺជាស្ថាបនិក និងជាប្រធានក្រុមប្រឹក្សាភិបាលនៅ Cambodia Community of Investment Professionals (សមាគមន៍ CFA នៅកម្ពុជា) ដើម្បីបណ្តុះបណ្តាលជំនាញក្នុងស្រុកផ្នែកហិរញ្ញវត្ថុ ដើម្បីលើកកម្ពស់កម្ពុជាឱ្យក្លាយជាគោលដៅវិនិយោគ។ តួនាទីកន្លងមកនៅកម្ពុជារបស់លោកស្រីមានជាអាទិ៍ អភិបាលប្រតិបត្តិ EuroCham Cambodia ពីឆ្នាំ២០១៤ ដល់២០១៨ ទីប្រឹក្សាធុរកិច្ចនៅ DFDL ដៃគូនៅ private equity firm Cambodia Emerald នៅឆ្នាំ២០០៨ និងអភិបាលនៅ CCFC (French Cambodian Chamber of Commerce)។ លោកស្រីធ្លាប់បម្រើការងារនៅប្រទេសស្វីស ក្នុងតួនាទីជាអ្នកគ្រប់គ្រងផលបត្រ នៅធនាគារឯកជនមួយ និងជាអ្នកសេដ្ឋកិច្ចនៅ UNCTAD។

### លោក Stéphane Mangiavacca, អភិបាល

#### គណៈកម្មាធិការក្រុមប្រឹក្សាភិបាល៖ គណៈកម្មាធិការតែងតាំង និងលាភការ

ជនជាតិបារាំង កើតក្នុងឆ្នាំ១៩៧៥ លោក Mangiavacca បានចូលរួមក្នុងក្រុមប្រឹក្សាភិបាល នៅខែមីនា ឆ្នាំ២០២០។ លោកបានចាប់ផ្តើមការងារក្នុងក្រសួងហិរញ្ញវត្ថុបារាំង នៅក្នុងប្រទេសចិន។ បន្ទាប់មក លោកបានចូលរួមជាមួយសវនកម្មផ្ទៃក្នុង នៃក្រុម BPCE ដែលលោកបានក្លាយជានាយកជាន់ខ្ពស់ នៃ Quantitative Audit។ បច្ចុប្បន្ន លោកបម្រើការឱ្យក្រុមហ៊ុន BRED Banque Populaire មានតួនាទីជាសមាជិកក្រុមប្រឹក្សាភិបាលប្រតិបត្តិ និងជាប្រធានក្រុមអន្តរជាតិ ក្រោយមកក្លាយជាសមាជិកក្រុមប្រឹក្សាភិបាល នៃធនាគារជាច្រើននៅក្នុងប្រទេសបារាំង និងអន្តរជាតិ ដែលគ្រប់គ្រងដោយក្រុម BRED។ លោកក៏ជាអតីតប្រធានផ្នែកហានិភ័យ និងអនុលោមបញ្ញត្តិ រហូតដល់ខែមករា ឆ្នាំ២០២០។ លោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រពីសាលា ECOLE NATIONALE SUPERIEURE DES MINES DE SAINT-ETIENNE ជំនាញវិស្វកម្ម និងបានសិក្សានៅ University of New Brunswick ក្នុងប្រទេសកាណាដា។

## លោក Kyosuke Hattori, អភិបាល

### គណៈកម្មាធិការក្រុមប្រឹក្សាភិបាល៖ គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងព័ត៌មានវិទ្យា

ជនជាតិជប៉ុន កើតក្នុងឆ្នាំ១៩៧៥ លោក Kyosuke Hattori បានចូលរួមក្នុងក្រុមប្រឹក្សាភិបាល នៅខែវិច្ឆិកា ឆ្នាំ២០២១។ លោកបានចាប់ផ្តើមការងារជាមួយធនាគារ Sumitomo (បច្ចុប្បន្នជា Sumitomo Mitsui Banking Corporation (SMBC)) ក្រោយបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យ Sophia។ នៅខែមេសា ឆ្នាំ២០០១ លោក Hattori ត្រូវបានតែងតាំងជា Assistant Vice President ការិយាល័យធុរកិច្ចសាជីវកម្ម Shin-Yokohama នៅ SMBC។ នៅខែតុលា ឆ្នាំ២០០២ លោក Hattori ត្រូវបានតែងតាំងជា Assistant Vice President ការិយាល័យសេវាកម្មហិរញ្ញវត្ថុសាជីវកម្ម នៅរាជធានីតូក្យូ។ នៅខែធ្នូ ឆ្នាំ២០០៣ លោកត្រូវបានផ្ទេរទៅបម្រើការងារនៅសាខាសិង្ហបុរី។ នៅខែកក្កដា ឆ្នាំ២០០៥ លោកត្រូវបានដំឡើងតំណែងជា Vice President នៃសាខាសិង្ហបុរី។ នៅខែកក្កដា ឆ្នាំ២០០៩ លោកត្រូវបានតែងតាំងជា Vice President នៃការិយាល័យទំនាក់ទំនងសាធារណៈនៅរាជធានីតូក្យូ។ នៅខែតុលា ឆ្នាំ២០១២ លោកត្រូវបានដំឡើងតំណែងជា Senior Vice President នៃការិយាល័យផែនការសាជីវកម្ម នៅរាជធានីតូក្យូ។ លោកត្រូវបានផ្លាស់ប្តូរកន្លែងបម្រើការងារនៅ នាយកដ្ឋានធុរកិច្ចទីផ្សារកំពុងរីកលូតលាស់ និងការិយាល័យផែនការ ផ្នែកធនាគារអន្តរជាតិ នៅខែមេសា ឆ្នាំ២០១៤ និង២០១៦ ជាបន្តបន្ទាប់។ នៅខែមេសា ឆ្នាំ២០១៧ លោកត្រូវបានដំឡើងតំណែងជា Senior Vice President and Group Head នៃការិយាល័យផែនការ ផ្នែកធនាគារអន្តរជាតិ។ នៅខែមេសា ឆ្នាំ២០២០ លោកត្រូវបានផ្លាស់ប្តូរកន្លែងទៅបម្រើការងារនៅការិយាល័យអភិវឌ្ឍធុរកិច្ច នៅរាជធានីតូក្យូ។ បន្ទាប់មក លោកត្រូវបានផ្លាស់ប្តូរការងារទៅប្រទេសសិង្ហបុរី នៅខែមិថុនា ឆ្នាំ២០២១ ក្នុងតួនាទីជាសហប្រធានគ្រប់គ្រងទូទៅការិយាល័យផែនការ នាយកដ្ឋានអាស៊ីប៉ាស៊ីហ្វិក បច្ចុប្បន្ន លោកមានតួនាទីជាសហប្រធានគ្រប់គ្រងទូទៅនៅការិយាល័យធុរកិច្ចអាស៊ី នាយកដ្ឋានអាស៊ីប៉ាស៊ីហ្វិក។ លោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ឯកទេសច្បាប់ នៅខែមីនា ឆ្នាំ១៩៩៨។

## បណ្ឌិត Albertus Bruggink, អភិបាល

### គណៈកម្មាធិការក្រុមប្រឹក្សាភិបាល៖ គណៈកម្មាធិការតែងតាំង និងលាភការ, គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងព័ត៌មានវិទ្យា

ជនជាតិហូឡង់ កើតក្នុងឆ្នាំ១៩៦៣ លោកបណ្ឌិត Albertus Bruggink បានចូលរួមក្នុងក្រុមប្រឹក្សាភិបាលនៅខែឧសភា ឆ្នាំ២០២១។

ក្រៅពីធនាគារ អេស៊ីលីដា បច្ចុប្បន្ន លោកបណ្ឌិតធ្វើជាទីប្រឹក្សាឯករាជ្យ នៅប្រទេសហូឡង់ និងធ្វើជាអ្នកប្រឹក្សាសាជីវកម្មរបស់ក្រុមហ៊ុន ORIX Corporation នៅតូក្យូ និងជាប្រធានគណៈកម្មាធិការសវនកម្ម នៃ ORIX Europe។ លើសពីនេះទៀត លោកបានចូលរួមជាមួយក្រុមប្រឹក្សាភិបាលមូលនិធិ Westerbork Fund (ប្រទេសហូឡង់) ក្នុងខែមករា ឆ្នាំ២០២២។ លោកក៏បានបម្រើការងារនៅធនាគារ Rabobank អស់រយៈពេល៣០ឆ្នាំ ហើយលោកបានកាន់មុខតំណែងជាច្រើន ដូចជា ហិរញ្ញវត្ថុ គ្រប់គ្រងហានិភ័យ និងរតនាភិបាល ទីផ្សារមូលធន ទាំងក្នុងស្រុក និងអន្តរជាតិ ដែលក្នុងនោះលោកកាន់តួនាទីជាអភិបាលប្រតិបត្តិរយៈពេល១២ឆ្នាំ។ ក្នុងកំលុងពេលបម្រើការងារ លោកបណ្ឌិតជាសមាជិកក្រុមប្រឹក្សាភិបាលជាច្រើន នៅក្នុងប្រទេសហូឡង់ និងកាន់តំណែងជាប្រធានគណៈកម្មាធិការសវនកម្ម នៃក្រុមប្រឹក្សាភិបាលជាច្រើនអាណត្តិផងដែរ។ លោកទទួលបានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ជំនាញ គ្រប់គ្រងពាណិជ្ជកម្ម ពីសាកលវិទ្យាល័យ Twente នៅឆ្នាំ១៩៨៦ និងសញ្ញាបត្របណ្ឌិត ជំនាញវិស្វកម្មហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យ Twente នៅឆ្នាំ១៩៨៩។ បច្ចុប្បន្ន លោកបណ្ឌិតគឺជាសាស្ត្រាចារ្យ ជំនាញវិស្វកម្មហិរញ្ញវត្ថុ និងគ្រប់គ្រងហានិភ័យ នៅសាកលវិទ្យាល័យ Twente។

បន្ថែមលើនេះ លោកបណ្ឌិតក៏មានតួនាទីជាសមាជិកនៃក្រុមប្រឹក្សាភិបាលផ្តល់យោបល់របស់ Medisch Spectrum Twente (ហូឡង់), Ormat Technologies (សហរដ្ឋអាមេរិក), TFG and XAC Bank (ម៉ុងហ្គោលី) និង Gravis Capital Management (ចក្រភពអង់គ្លេស)។

## លោក កាយ ឡូត, អភិបាល

### គណៈកម្មាធិការក្រុមប្រឹក្សាភិបាល៖ គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងព័ត៌មានវិទ្យា

ជនជាតិខ្មែរ កើតក្នុងឆ្នាំ១៩៧០ លោក កាយ ឡូត បានចូលរួមក្នុងក្រុមប្រឹក្សាភិបាលនៅខែឧសភា ឆ្នាំ២០២១។ លោកជាសហគ្រិនម្នាក់ដែលមានបទពិសោធន៍ជាអ្នកគ្រប់គ្រងជាន់ខ្ពស់ ផ្នែកហិរញ្ញវត្ថុ ធនាគារ ផ្សព្វផ្សាយ និងទូរគមនាគមន៍។ កាលពីមុន លោកធ្លាប់បានបម្រើការជាអភិបាលឯករាជ្យ និងជាប្រធានគណៈកម្មាធិការសវនកម្ម របស់ស្ថាប័នមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើធំមួយនៅកម្ពុជា។

បច្ចុប្បន្ន លោកគឺជាប្រធានក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនសិប្បករអង្គរ ដែលមានមូលដ្ឋាននៅខេត្តសៀមរាប និងជាម្ចាស់ភាគហ៊ុននៅក្នុងក្រុមហ៊ុនផ្សព្វផ្សាយឌីជីថល និងក្រុមហ៊ុនសំណង់។លោកក៏ជាអភិបាលឯករាជ្យរបស់ក្រុមហ៊ុន BSP Finance Cambodia និង Digital Divide Data ដែលជាក្រុមហ៊ុនដែលមានលក្ខណៈសង្គម មានមូលដ្ឋាននៅទីក្រុងញូវយ៉ក។

លោកបានទទួលវិញ្ញាបនបត្រ IFRS ពី The Association of Chartered Certified Accountants (ACCA) និងសញ្ញាបត្រថ្នាក់អនុបណ្ឌិតពីសាលា Essec Business School ។ លោកក៏បានបញ្ចប់ការសិក្សាពីវិទ្យាស្ថានអូស្ត្រាលីសម្រាប់អភិបាលក្រុមហ៊ុន (GAICD)។

## ៣. ករណីអភិបាលណាម្នាក់ ជាអភិបាល ជាភាគហ៊ុនិក ឬសហកម្មសិទ្ធិកររបស់ក្រុមហ៊ុនផ្សេងទៀត

| លរ | ឈ្មោះអភិបាល | ឈ្មោះក្រុមហ៊ុនពាក់ព័ន្ធ | អភិបាល ឬភាគហ៊ុនិក ឬសហកម្មសិទ្ធិករ |
|---|---|---|---|
| ១ | លោក ឆាយ សឿន | គ្មាន | គ្មាន |
| ២ | បណ្ឌិត អ៊ិន ចាន់នី | AFT<br>សមាគមធនាគារនៅកម្ពុជា<br>ក្រុមការងារសេវាកម្មធនាគារ និងហិរញ្ញវត្ថុ | ប្រធានក្រុមបរធនបាល<br>សមាជិកក្រុមប្រឹក្សា<br>សហប្រធាន |
| ៣ | លោក Pieter Kooi | Alter Modus MFI in Podgorica, Montenegro | គ្មាន |
| ៤ | លោក Stéphane Mangiavacca | Banque Franco Lao, BRED Vanuatu Limited, BCI Mer Rouge, BRED Bank Fiji Limited<br><br>BRED IT Ltd, BIC BRED – Suisse SA, COFIBRED, BCEL, Foncière de Vanuatu Limited, SOCREDO, Banque Calédonienne d'Investissement, SPIG, and BIC-BRED<br><br>Mines Saint-Étienne Alumni Association<br><br>Institut Mines-Télécom and of Ecole Nationale Supérieure des Mines de Saint-Etienne | ប្រធានក្រុមប្រឹក្សាភិបាល និងអភិបាល<br><br>អភិបាល<br><br>ប្រធានក្រុមប្រឹក្សាភិបាល<br><br>អភិបាល |
| ៥ | លោក Kyosuke Hattori | ការិយាល័យធុរកិច្ចអាស៊ី នាយកដ្ឋានអាស៊ីប៉ាស៊ីហ្វិក | សហប្រធាន |
| ៦ | បណ្ឌិត Albertus Bruggink | Foundation Westerbork Fund<br>MST, Netherlands<br>TFG / XAC Bank, Mongolia<br>Gravis Capital, UK | ប្រធានក្រុមប្រឹក្សាភិបាល<br>សមាជិកក្រុមប្រឹក្សាភិបាល<br>សមាជិកក្រុមប្រឹក្សាភិបាល<br>សមាជិកក្រុមប្រឹក្សាភិបាល |
| ៧ | លោក កាយ ឡូត | ក្រុមហ៊ុនសិប្បករអង្គរ<br>BSP Financial Cambodia Plc.<br>Digital Divide Data, New York.<br>Quantum Publicity Co., Ltd.<br>YellowTree Interior Co., Ltd. | ប្រធានក្រុមប្រឹក្សាភិបាល<br>អភិបាលឯករាជ្យ<br>អភិបាលឯករាជ្យ<br>អភិបាល និងប្រធាន<br>អភិបាល និងប្រធាន |
| ៨ | លោកស្រី ភូរិ រតនា | សហគ្រាសខ្មែរ អ៊ីមផែកហាប់ និងស្មូលវើល<br>សមាគមន៍ CFA នៅកម្ពុជា | ទីប្រឹក្សាជាន់ខ្ពស់<br>ស្ថាបនិក និងប្រធានក្រុមប្រឹក្សាភិបាល |
| ៩ | បណ្ឌិត ហេង ឌីណា | សមាគមសេដ្ឋកិច្ចកម្ពុជា | សមាជិកក្រុមប្រឹក្សាភិបាល |

## ៤. តួនាទី ភារកិច្ច ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល និងការអនុវត្ត

អភិបាលត្រូវបានតែងតាំងដោយភាគហ៊ុនិក សម្រាប់អាណត្តិបំពេញការងារដែលមានរយៈពេល៣ឆ្នាំ។ សមាសភាពក្រុមប្រឹក្សាភិបាលត្រូវមានចំនួន ៩ រូប និងមានតួនាទីដូចខាងក្រោម៖

- ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវក្នុងការកំណត់យុទ្ធសាស្ត្ររបស់ធនាគារ និងអនុវត្ត ឬគ្រប់គ្រងប្រតិបត្តិការ និងកិច្ចការអាជីវកម្ម។ គ្រប់សមាជិកប្រឹក្សាភិបាលត្រូវអនុវត្តការងារដើម្បីបម្រើផលប្រយោជន៍ស្របច្បាប់របស់ធនាគារ។
- អំណាចរបស់ក្រុមប្រឹក្សាភិបាលត្រូវសម្រេចតាមមតិរួម ហើយគ្មានអភិបាលណាម្នាក់មានអំណាចក្នុងការដឹកនាំមន្ត្រី ឬបុគ្គលិកណាម្នាក់របស់ធនាគារ ដើម្បីចុះហត្ថលេខាលើកិច្ចសន្យា ឬដឹកនាំប្រតិបត្តិការរបស់ធនាគារបានឡើយ លើកលែងតែអភិបាលនោះត្រូវបានផ្តល់អំណាចឱ្យអនុវត្តការងារតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល។
- អភិបាលនីមួយៗមានសិទ្ធិក្នុងការទទួលបានរបាយការណ៍ ឬកំណត់ត្រារបស់ធនាគារក្នុងម៉ោងបំពេញការងារ។

ក្រុមប្រឹក្សាភិបាលត្រូវជ្រើសរើសអភិបាល ១រូប ក្នុងចំណោមសមាសភាពក្រុមប្រឹក្សាភិបាលដោយមានសំឡេងឆ្នោតគាំទ្រមតិភាគច្រើនពីសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់

ដើម្បីធ្វើជាប្រធាន ក្រុមប្រឹក្សាភិបាល ដែលត្រូវដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាភិបាល ព្រមទាំងមហាសន្និបាតភាគហ៊ុនិក។

ក្រុមប្រឹក្សាភិបាលមានទំនួលខុសត្រូវក្នុងការអនុវត្តអភិបាលកិច្ចល្អ និងជំរុញនូវភាពជោគជ័យរបស់ធនាគារ តាមរយៈការដឹកនាំ និងការគ្រប់គ្រងប្រតិបត្តិការ និងកិច្ចការអាជីវកម្ម។ ក្រុមប្រឹក្សាភិបាលអាចតែងតាំង និងដកហូតតំណែង ប្រធាននាយកប្រតិបត្តិ គណៈប្រធាននាយក-នាយិកាប្រតិបត្តិជាន់ខ្ពស់សវនកម្មផ្ទៃក្នុង និងនាយក-នាយិកាប្រតិបត្តិអនុលោមបញ្ញត្តិ។ ក្រុមប្រឹក្សាភិបាលត្រូវធានាថាមាន ធនធានមនុស្សសមស្របដើម្បីបំពេញការងារ បង្កើតយុទ្ធសាស្ត្រគ្រប់គ្រង និងគោលដៅហិរញ្ញវត្ថុ ដើម្បីដាក់ឱ្យគណៈគ្រប់គ្រងអនុវត្ត និងតាមដានការអនុវត្ត ដោយផ្ទាល់ និងប្រយោលតាមរយៈគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាភិបាល។

ក្រុមប្រឹក្សាភិបាល មានគណៈកម្មាធិការចំនួន៣គឺ៖ គណៈកម្មាធិការសវនកម្ម គណៈកម្មាធិការតែងតាំង និងលាភការ និងគណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងព័ត៌មានវិទ្យា។ ក្រុមប្រឹក្សាភិបាល អាចបង្កើតគណៈកម្មាធិការផ្សេងៗទៀត តាមការចាំបាច់ ឬតម្រូវការ ដើម្បីដឹកនាំអាជីវកម្ម និងប្រតិបត្តិការរបស់ធនាគារ។ គណៈកម្មាធិការក្រុមប្រឹក្សាភិបាលទាំងនេះ ត្រូវបង្កើតឡើងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ហើយអភិបាលទាំងអស់ នៃគណៈកម្មាធិការក្រុមប្រឹក្សាភិបាលទាំងនេះនឹងត្រូវសម្រេចដោយក្រុមប្រឹក្សាភិបាល។ គណៈកម្មាធិការនីមួយៗនឹងពុំមានសិទ្ធិអំណាចណាមួយលើក្រុមប្រឹក្សាភិបាលឡើយ លើកលែងតែមានការផ្ទេរសិទ្ធិអំណាចទាំងនោះជាផ្លូវការដោយក្រុមប្រឹក្សាភិបាល ក៏ប៉ុន្តែអាចផ្តល់ជាអនុសាសន៍ជូនក្រុមប្រឹក្សាភិបាល សម្រាប់វិធានការរួមរបស់ខ្លួន។ ទន្ទឹមនឹងនោះ សមាជិកភាពក្នុងគណៈកម្មាធិការក្រុមប្រឹក្សាភិបាលត្រូវបានកម្រិតចំពោះអភិបាលផ្ទាល់។ ប្រធានក្រុមប្រឹក្សាភិបាលទាំងអស់អាចអញ្ជើញសមាជិក ថ្នាក់ដឹកនាំ និងភាគីពាក់ព័ន្ធផ្សេងៗ ដើម្បីផ្តល់ព័ត៌មាន និងការពន្យល់ទាក់ទងនឹងប្រតិបត្តិការ នៅពេលដែលមានការចាំបាច់។ គណៈកម្មាធិការក្រុមប្រឹក្សាភិបាលទាំងអស់ត្រូវមានប្រធានជាអភិបាលឯករាជ្យ។

បញ្ជីឈ្មោះពេញលេញនៃគណៈកម្មាធិការក្រុមប្រឹក្សាភិបាលដែលមាន សមាជិក និងសកម្មភាពក្នុងអំឡុងឆ្នាំ២០២៣ បង្ហាញក្នុងទំព័រទី៦៨-៧១ នៃរបាយការណ៍នេះ។

## ៥. កិច្ចប្រជុំក្រុមប្រឹក្សាភិបាល

| ល.រ | កាលបរិច្ឆេទ | ប្រភេទកិច្ចប្រជុំ | ឈ្មោះអភិបាលដែលបានចូលរួម |
|---|---|---|---|
| ១ | ០៧-កុម្ភៈ-២០២៣ | កិច្ចប្រជុំពិសេសតាមរយៈអ៊ីម៉ែល | លោក ឆាយ សឿន<br>បណ្ឌិត អ៊ិន ចាន់នី<br>លោក Pieter Kooi<br>លោក វ៉ាន់ ស៊ូអៀង<br>លោកស្រី ភូរិ រតនា<br>លោក Stéphane Mangiavacca<br>លោក Kyosuke Hattori<br>បណ្ឌិត Albertus Bruggink<br>លោក កាយ ឡូត |
| ២ | ១៤-កុម្ភៈ-២០២៣ | កិច្ចប្រជុំពិសេសតាមរយៈអ៊ីម៉ែល | លោក ឆាយ សឿន<br>បណ្ឌិត អ៊ិន ចាន់នី<br>លោក Pieter Kooi<br>លោក វ៉ាន់ ស៊ូអៀង<br>លោកស្រី ភូរិ រតនា<br>លោក Stéphane Mangiavacca<br>លោក Kyosuke Hattori<br>បណ្ឌិត Albertus Bruggink<br>លោក កាយ ឡូត |
| ៣ | ១៥-កុម្ភៈ-២០២៣ | កិច្ចប្រជុំពិសេសតាមរយៈអ៊ីម៉ែល | លោក ឆាយ សឿន<br>បណ្ឌិត អ៊ិន ចាន់នី<br>លោក Pieter Kooi<br>លោក វ៉ាន់ ស៊ូអៀង<br>លោកស្រី ភូរិ រតនា<br>លោក Stéphane Mangiavacca<br>លោក Kyosuke Hattori<br>បណ្ឌិត Albertus Bruggink<br>លោក កាយ ឡូត |
| ៤ | ២៧-កុម្ភៈ-២០២៣ | កិច្ចប្រជុំពិសេសតាមរយៈអ៊ីម៉ែល | លោក ឆាយ សឿន<br>បណ្ឌិត អ៊ិន ចាន់នី<br>លោក Pieter Kooi<br>លោក វ៉ាន់ ស៊ូអៀង<br>លោកស្រី ភូរិ រតនា<br>លោក Stéphane Mangiavacca<br>លោក Kyosuke Hattori<br>បណ្ឌិត Albertus Bruggink<br>លោក កាយ ឡូត |
| ៥ | ២២-មីនា-២០២៣ | កិច្ចប្រជុំផ្ទាល់ | លោក ឆាយ សឿន<br>បណ្ឌិត អ៊ិន ចាន់នី<br>លោក Pieter Kooi<br>លោក វ៉ាន់ ស៊ូអៀង<br>លោកស្រី ភូរិ រតនា<br>លោក Stéphane Mangiavacca<br>លោក Kyosuke Hattori<br>បណ្ឌិត Albertus Bruggink<br>លោក កាយ ឡូត |

| ល.រ | កាលបរិច្ឆេទ | ប្រភេទកិច្ចប្រជុំ | ឈ្មោះអភិបាលដែលបានចូលរួម |
|---|---|---|---|
| ៦ | ១៣-មេសា-២០២៣ | កិច្ចប្រជុំពិសេសតាមរយៈអ៊ីម៉ែល | លោក ឆាយ សឿន<br>បណ្ឌិត អ៊ុន ចាន់នី<br>លោក Pieter Kooi<br>លោក វ៉ាន់ ស៊ូអៀង<br>លោកស្រី ភូរិ រតនា<br>លោក Stéphane Mangiavacca<br>លោក Kyosuke Hattori<br>បណ្ឌិត Albertus Bruggink<br>លោក កាយ ឡូត |
| ៧ | ០៥-ឧសភា-២០២៣ | កិច្ចប្រជុំពិសេសតាមរយៈអ៊ីម៉ែល | លោក ឆាយ សឿន<br>បណ្ឌិត អ៊ុន ចាន់នី<br>លោក Pieter Kooi<br>លោក វ៉ាន់ ស៊ូអៀង<br>លោកស្រី ភូរិ រតនា<br>លោក Stéphane Mangiavacca<br>លោក Kyosuke Hattori<br>បណ្ឌិត Albertus Bruggink<br>លោក កាយ ឡូត |
| ៨ | ៣០-ឧសភា-២០២៣ | កិច្ចប្រជុំពិសេសតាមរយៈអ៊ីម៉ែល | លោក ឆាយ សឿន<br>បណ្ឌិត អ៊ុន ចាន់នី<br>លោក Pieter Kooi<br>លោក វ៉ាន់ ស៊ូអៀង<br>លោកស្រី ភូរិ រតនា<br>លោក Stéphane Mangiavacca<br>លោក Kyosuke Hattori<br>បណ្ឌិត Albertus Bruggink<br>លោក កាយ ឡូត |
| ៩ | ២៣-មិថុនា-២០២៣ | កិច្ចប្រជុំផ្ទាល់ (នៅរដ្ឋធានីវ៉ាស៊ីនតោន សហរដ្ឋអាមេរិក) | លោក ឆាយ សឿន<br>បណ្ឌិត អ៊ុន ចាន់នី<br>លោក Pieter Kooi<br>លោក វ៉ាន់ ស៊ូអៀង<br>លោកស្រី ភូរិ រតនា<br>លោក Stéphane Mangiavacca<br>លោក Kyosuke Hattori<br>បណ្ឌិត Albertus Bruggink<br>លោក កាយ ឡូត |
| ១០ | ៣១-កក្កដា-២០២៣ | កិច្ចប្រជុំពិសេសតាមរយៈអ៊ីម៉ែល | លោក ឆាយ សឿន<br>បណ្ឌិត អ៊ុន ចាន់នី<br>លោក Pieter Kooi<br>លោក វ៉ាន់ ស៊ូអៀង<br>លោកស្រី ភូរិ រតនា<br>លោក Stéphane Mangiavacca<br>លោក Kyosuke Hattori<br>បណ្ឌិត Albertus Bruggink<br>លោក កាយ ឡូត |

| លរ | | ប្រភេទកិច្ចប្រជុំ | ឈ្មោះអភិបាលដែលបានចូលរួម |
|---|---|---|---|
| ១១ | ០៧-សីហា-២០២៣ | កិច្ចប្រជុំពិសេសតាមរយៈអ៊ីម៉ែល | លោក ឆាយ សឿន<br>បណ្ឌិត អ៊ិន ចាន់នី<br>លោក Pieter Kooi<br>លោក វ៉ាន់ ស៊ូអៀង<br>លោកស្រី ភូរិ រតនា<br>លោក Stéphane Mangiavacca<br>លោក Kyosuke Hattori<br>បណ្ឌិត Albertus Bruggink<br>លោក កាយ ឡូត |
| ១២ | ០៩-សីហា-២០២៣ | កិច្ចប្រជុំពិសេសតាមរយៈអ៊ីម៉ែល | លោក ឆាយ សឿន<br>បណ្ឌិត អ៊ិន ចាន់នី<br>លោក Pieter Kooi<br>លោក វ៉ាន់ ស៊ូអៀង<br>លោកស្រី ភូរិ រតនា<br>លោក Stéphane Mangiavacca<br>លោក Kyosuke Hattori<br>បណ្ឌិត Albertus Bruggink<br>លោក កាយ ឡូត |
| ១៣ | ១៥-សីហា-២០២៣ | កិច្ចប្រជុំពិសេសតាមរយៈអ៊ីម៉ែល | លោក ឆាយ សឿន<br>បណ្ឌិត អ៊ិន ចាន់នី<br>លោក Pieter Kooi<br>លោក វ៉ាន់ ស៊ូអៀង<br>លោកស្រី ភូរិ រតនា<br>លោក Stéphane Mangiavacca<br>លោក Kyosuke Hattori<br>បណ្ឌិត Albertus Bruggink<br>លោក កាយ ឡូត |
| ១៤ | ២១-កញ្ញា-២០២៣ | កិច្ចប្រជុំផ្ទាល់ | លោក ឆាយ សឿន<br>បណ្ឌិត អ៊ិន ចាន់នី<br>លោក Pieter Kooi<br>លោក វ៉ាន់ ស៊ូអៀង<br>លោកស្រី ភូរិ រតនា<br>លោក Stéphane Mangiavacca<br>លោក Kyosuke Hattori<br>បណ្ឌិត Albertus Bruggink (ចូលរួមតាមរយៈ con-call)<br>លោក កាយ ឡូត |
| ១៥ | ០៦-វិច្ឆិកា-២០២៣ | កិច្ចប្រជុំពិសេសតាមរយៈអ៊ីម៉ែល | លោក ឆាយ សឿន<br>បណ្ឌិត អ៊ិន ចាន់នី<br>លោក Pieter Kooi<br>លោកស្រី ភូរិ រតនា<br>លោក Stéphane Mangiavacca<br>លោក Kyosuke Hattori<br>បណ្ឌិត Albertus Bruggink<br>លោក កាយ ឡូត |
| ១៦ | ១៩-ធ្នូ-២០២៣ | កិច្ចប្រជុំផ្ទាល់ | លោក ឆាយ សឿន<br>បណ្ឌិត អ៊ិន ចាន់នី<br>លោក Pieter Kooi<br>លោកស្រី ភូរិ រតនា<br>បណ្ឌិត ហេង ឌីណា<br>លោក Stéphane Mangiavacca<br>លោក Kyosuke Hattori<br>បណ្ឌិត Albertus Bruggink (ចូលរួមតាមរយៈ con-call)<br>លោក កាយ ឡូត |

# ខ. គណៈកម្មាធិការក្រុមប្រឹក្សាភិបាល

## ១. រចនាសម្ព័ន្ធគណៈកម្មាធិការក្រុមប្រឹក្សាភិបាល

នៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៩ ក្រុមប្រឹក្សាភិបាលបានធ្វើការកែប្រែរចនាសម្ព័ន្ធ និងសមាសភាពគណៈកម្មាធិការក្រុមប្រឹក្សាភិបាល ដោយយោងលើច្បាប់របស់ប្រទេសកម្ពុជា តម្រូវការរបស់ធនាគារជាតិ នៃ កម្ពុជា ការអនុវត្តដ៏ល្អប្រសើរ និងកត្តាផ្សេងទៀតទៅតាមស្ថានភាពជាក់ស្តែងរបស់ធនាគារ។ សមាសភាពគណៈកម្មាធិការក្រុមប្រឹក្សាភិបាលចុងក្រោយបំផុតត្រូវបានធ្វើការកែប្រែនៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៣។

### ១.១ គណៈកម្មាធិកាសវនកម្ម

### វិសាលភាព និងគោលបំណង

គណៈកម្មាធិការសវនកម្មត្រូវបានបង្កើតឡើងដោយក្រុមប្រឹក្សាភិបាលនៃ ធនាគារ អេស៊ីលីដា ក្នុងគោលបំណងត្រួតពិនិត្យភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ ប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងដោយរួមបញ្ចូលទាំងការគ្រប់គ្រងលើការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម សវនកម្មផ្ទៃក្នុង និងសេវាកម្មដែលផ្តល់ដោយសវនករខាងក្រៅ។

### សមាជិក

- លោកស្រី ភូរិ រតនា — អភិបាលឯករាជ្យ ប្រធាន (ប្រសិទ្ធភាពនៅថ្ងៃទី០១ មករា ឆ្នាំ២០២២)
- លោក Pieter Kooi — អភិបាលឯករាជ្យ សមាជិក
- លោក ឆាយ សឿន — អភិបាលមិនប្រតិបត្តិ សមាជិក

### លទ្ធផលការងាររបស់គណៈកម្មាធិការសវនកម្ម ក្នុងឆ្នាំ២០២៣

គណៈកម្មាធិការសវនកម្មបានរៀបចំការប្រជុំចំនួន៤ដងនៅក្នុងឆ្នាំ២០២៣ ដែលមាន ១ដងនៅខែកុម្ភៈ ១ដងនៅខែឧសភា ១ដងនៅខែសីហា ១ដងនៅខែវិច្ឆិកា ដែលមានដំណើរការសំខាន់ៗដូចជា៖

- បានត្រួតពិនិត្យ អនុម័ត និងស្នើក្រុមប្រឹក្សាភិបាលសម្រាប់ការអនុម័តចុងក្រោយលើរបាយការណ៍សវនកម្មហិរញ្ញវត្ថុឆ្នាំ២០២២។
- បានត្រួតពិនិត្យ និងអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុឆ្នាំ២០២៣ សម្រាប់ខែមីនា មិថុនា និងកញ្ញា និងលើកសំណើជូនក្រុមប្រឹក្សាភិបាលដើម្បីអនុម័តចុងក្រោយ ។
- បានត្រួតពិនិត្យ និងអនុម័តរបាយការណ៍ត្រួតពិនិត្យផ្ទៃក្នុងប្រចាំឆ្នាំ២០២២ ដើម្បីដាក់ជូនធនាគារជាតិ នៃកម្ពុជា។
- បានត្រួតពិនិត្យ និងអនុម័តរបាយការណ៍សវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ២០២២ ដែលត្រូវបង្ហាញជាសាធារណៈ ។
- បានត្រួតពិនិត្យរបាយការណ៍សវនកម្មផ្ទៃក្នុង និងការវិភាគនិន្នាការ ឬហេតុការណ៍នានា ។
- បានស្នើសុំនូវប្រាក់លើកទឹកចិត្តប្រចាំឆ្នាំ២០២២ សម្រាប់គណៈប្រធាននាយិកាប្រតិបត្តិជាន់ខ្ពស់សវនករផ្ទៃក្នុង ព្រមទាំងផ្តល់អនុសាសន៍ជូនក្រុមប្រឹក្សាភិបាលអនុម័ត។
- បានវាយតម្លៃ និងផ្តល់ចំណាត់ថ្នាក់លទ្ធផលការងារប្រចាំឆ្នាំ២០២២ សម្រាប់គណៈប្រធាននាយិកាប្រតិបត្តិជាន់ខ្ពស់សវនកម្មផ្ទៃក្នុង និងផ្តល់អនុសាសន៍ជូនក្រុមប្រឹក្សាភិបាលសម្រាប់អនុម័ត។
- បានត្រួតពិនិត្យ និងអនុម័តរបាយការណ៍សវនកម្មផ្ទៃក្នុង ស្តីពីប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដើម្បីដាក់ជូន អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ។
- បានត្រួតពិនិត្យ និងអនុម័តលើផែនការសវនកម្មផ្ទៃក្នុងសម្រាប់ឆ្នាំសារពើពន្ធ២០២៤។
- បានត្រួតពិនិត្យ និងអនុម័តលើផែនការប្រាក់រង្វាន់លើកទឹកចិត្តឆ្នាំ២០២៤ ជូនគណៈប្រធាននាយិកាប្រតិបត្តិជាន់ខ្ពស់សវនកម្មផ្ទៃក្នុង និងលើកសំណើជូន គណៈកម្មាធិការតែងតាំងនិង លាភការអនុម័ត ។
- បានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តការងារសវនករខាងក្រៅ សម្រាប់ឆ្នាំ ២០២២។
- បានត្រួតពិនិត្យ និងអនុម័តវិសាលភាព និងថ្លៃសេវាកម្ម សម្រាប់ការងារសវនកម្មប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ប្រចាំឆ្នាំ ២០២៣ ។
- បានត្រួតពិនិត្យ និងអនុម័តលើតួនាទីភារកិច្ចរបស់គណៈកម្មាធិការសវនកម្ម និងផ្តល់អនុសាសន៍ជូនក្រុមប្រឹក្សាភិបាលសម្រាប់ការអនុម័តចុងក្រោយ។
- បានត្រួតពិនិត្យប្រចាំឆ្នាំនូវគោលការណ៍ផ្សេងៗ៖ គោលការណ៍សវនកម្ម គោលការណ៍ត្រួតពិនិត្យផ្ទៃក្នុង គោលការណ៍បង្ហាញព័ត៌មាន សាជីវកម្ម គោលការណ៍ភាគលាភ និងគោលការណ៍ណែនាំទូទៅ។

## ១.២ គណៈកម្មាធិការតែងតាំង និងលាភការ

### វិសាលភាព និងគោលបំណង

គណៈកម្មាធិការនេះត្រូវបានបង្កើតឡើងដោយក្រុមប្រឹក្សាភិបាលនៃធនាគារ អេស៊ីលីដា ដើម្បីផ្តល់មតិយោបល់ដោយឯករាជ្យ ស្តីពីការផ្តល់អនុសាសន៍ជូនក្រុមប្រឹក្សាភិបាលក្នុងបញ្ហា៖

ក) ការផ្តល់លាភការជូនអភិបាល ប្រធាននាយកប្រតិបត្តិ គណៈប្រធាននាយិកាប្រតិបត្តិជាន់ខ្ពស់សវនកម្មផ្ទៃក្នុង នាយកប្រតិបត្តិអនុលោមបញ្ញត្តិរបស់ធនាគារ និងអភិបាលរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ និង

ខ) ការជ្រើសរើសបេក្ខភាពដែលសមស្រប សម្រាប់ជាសមាជិកក្រុមប្រឹក្សាភិបាល ប្រធាននាយកប្រតិបត្តិ គណៈប្រធាននាយិកាប្រតិបត្តិជាន់ខ្ពស់សវនកម្មផ្ទៃក្នុង នាយកប្រតិបត្តិអនុលោមបញ្ញត្តិរបស់ធនាគារ។

### សមាជិក

| | | |
|---|---|---|
| • លោក Pieter Kooi | អភិបាលឯករាជ្យ | ប្រធាន |
| • បណ្ឌិត Albertus Bruggink | អភិបាលមិនប្រតិបត្តិ | សមាជិក |
| • លោក Stéphane Mangiavaca | អភិបាលមិនប្រតិបត្តិ | សមាជិក |

នៅពេលប្រជុំម្តងៗ គណៈកម្មាធិការនេះអាចអញ្ជើញសមាជិកថ្នាក់គ្រប់គ្រង និងទីប្រឹក្សាវិជ្ជាជីវៈខាងក្រៅ ដើម្បីចូលរួមក្នុងកិច្ចប្រជុំទាំងមូល ឬដោយផ្នែកណាមួយ ដើម្បីផ្តល់ពត៌មាន និងការពន្យល់បន្ថែម ដូចដែលពួកគាត់សម្រេចចិត្តតាមករណីចាំបាច់។

### លទ្ធផលការងាររបស់គណៈកម្មាធិការតែងតាំង និងលាភការ ក្នុងឆ្នាំ២០២៣

គណៈកម្មាធិការតែងតែង និងលាភការ បានប្រជុំចំនួន៦ដង ក្នុងឆ្នាំ២០២៣ ដែល ១ដងនៅខែកុម្ភៈ ១ដង នៅខែមីនា ២ដងនៅខែមិថុនា ១ដងនៅខែកញ្ញា ១ដងនៅខែធ្នូ។ ដំណើរការសំខាន់ៗ មានដូចជា៖

- បានត្រួតពិនិត្យ និងស្នើក្រុមប្រឹក្សាភិបាល ដើម្បីអនុម័តចុងក្រោយលើរបាយការណ៍ប្រចាំឆ្នាំ២០២២ របស់គណៈកម្មាធិការតែងតែង និងលាភការ។
- បានត្រួតពិនិត្យ និងស្នើក្រុមប្រឹក្សាភិបាល ដើម្បីអនុម័តចុងក្រោយលើអត្រាអតិផរណាឆ្នាំ២០២២ សម្រាប់ចំណាយជូនកម្មករនិយោជិតរបស់ធនាគារ ចាប់ពីថ្ងៃទី១ ខែមេសា ឆ្នាំ២០២៣ តទៅ។
- បានត្រួតពិនិត្យ និងស្នើក្រុមប្រឹក្សាភិបាល ដើម្បីអនុម័តចុងក្រោយក្នុងការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត និងបង្កើនប្រាក់បៀវត្សប្រចាំជូនបណ្ឌិត អ៊ិន ចាន់នី ប្រធាននាយកប្រតិបត្តិ សម្រាប់លទ្ធផលការងារឆ្នាំ២០២២។
- បានត្រួតពិនិត្យ និងស្នើក្រុមប្រឹក្សាភិបាល ដើម្បីអនុម័តក្នុងការបង្កើនប្រាក់បៀវត្សប្រចាំឆ្នាំជូនប្រធានក្រុមប្រឹក្សាភិបាល ដែលមានប្រសិទ្ធភាពប្រតិសកម្មចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៣។
- បានត្រួតពិនិត្យ និងស្នើក្រុមប្រឹក្សាភិបាល ដើម្បីអនុម័តក្នុងការបង្កើនកម្រៃសេវាជូនក្រុមប្រឹក្សាភិបាលរបស់ធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធ។
- បានត្រួតពិនិត្យ និងស្នើក្រុមប្រឹក្សាភិបាល ដើម្បីអនុម័តក្នុងការតែងតាំងអាណត្តិថ្មីរបស់អភិបាលរបស់ធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធ។
- បានធ្វើបច្ចុប្បន្នភាព និងស្នើក្រុមប្រឹក្សាភិបាល ដើម្បីអនុម័តលើឧបសម្ព័ន្ធ ង នៃគោលការណ៍អភិបាលកិច្ចសាជីវកម្ម ទាក់ទងនឹងប្រាក់កម្រៃសេវា និងការចំណាយសម្រាប់ក្រុមប្រឹក្សាភិបាល។
- បានត្រួតពិនិត្យរបាយការណ៍សវនកម្មទាក់ទងនឹងផែនការសោធននិវត្តន៍ និងអត្ថប្រយោជន៍ចូលនិវត្តន៍។
- បានត្រួតពិនិត្យផែនការសោធននិវត្តន៍ និងអត្ថប្រយោជន៍ចូលនិវត្តន៍របស់កម្មករនិយោជិត។
- បានត្រួតពិនិត្យច្បាប់ និងបទប្បញ្ញត្តិដែលពាក់ព័ន្ធ។
- បានត្រួតពិនិត្យផែនការស្នងតំណែង សម្រាប់តួនាទីថ្នាក់គ្រប់គ្រងជាន់ខ្ពស់ក្នុងធនាគារ និងបុត្រសម្ព័ន្ធ។
- បានត្រួតពិនិត្យ និងស្នើក្រុមប្រឹក្សាភិបាល ដើម្បីអនុម័ត បណ្ឌិត ហេង ឌីណា ជាបេក្ខភាពអភិបាលឯករាជ្យ របស់ធនាគារ។
- បានត្រួតពិនិត្យកម្រិតចំណាយជាក់ស្តែងលើកម្មករនិយោជិត មកដល់ថ្ងៃនៃរបាយការណ៍។
- បានត្រួតពិនិត្យគម្រោងរបស់ថ្នាក់គ្រប់គ្រង ស្តីពីការចំណាយកម្មករនិយោជិតនៅក្នុងផែនការថវិកាឆ្នាំបន្ទាប់។
- បានត្រួតពិនិត្យ និងស្នើក្រុមប្រឹក្សាភិបាល ដើម្បីអនុម័ត និងតែងតាំងលោក កាយ ឡូត ជាអភិបាលឯករាជ្យរបស់ធនាគារ។
- បានត្រួតពិនិត្យប្រចាំឆ្នាំលើគោលការណ៍របស់ធនាគារ។
- បានត្រួតពិនិត្យប្រចាំឆ្នាំលើតួនាទីរបស់គណៈកម្មាធិការតែងតាំង និងលាភការ។
- បានត្រួតពិនិត្យ និងស្នើក្រុមប្រឹក្សាភិបាល ដើម្បីអនុម័ត និងតែងតាំងសមាសភាពគណៈកម្មាធិការ នៃក្រុមប្រឹក្សាភិបាល។
- បានត្រួតពិនិត្យ និងស្នើក្រុមប្រឹក្សាភិបាល ដើម្បីអនុម័តលក្ខខណ្ឌប្រាក់រង្វាន់លើកទឹកចិត្តប្រចាំឆ្នាំ២០២៤ ជូនប្រធាននាយកប្រតិបត្តិ និងគណៈប្រធាននាយិកាប្រតិបត្តិជាន់ខ្ពស់សវនកម្មផ្ទៃក្នុង និងនាយកប្រតិបត្តិអនុលោមបញ្ញត្តិ។
- បានរៀបចំស្វ័យវាយតម្លៃប្រចាំឆ្នាំ សម្រាប់គណៈកម្មាធិការតែងតាំង និងលាភការ។
- បានរៀបចំទម្រង់ស្វ័យវាយតម្លៃប្រចាំឆ្នាំសម្រាប់ក្រុមប្រឹក្សាភិបាល។

## ១.៣ គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងព័ត៌មានវិទ្យា

### វិសាលភាព និងគោលបំណង

គណៈកម្មាធិការនេះត្រូវបានបង្កើតឡើងដោយក្រុមប្រឹក្សាភិបាលនៃធនាគារ អេស៊ីលីដា ដើម្បីជំនួយក្រុមប្រឹក្សាភិបាល និងធានាបាននូវការទទួលខុសត្រូវប្រកបដោយប្រសិទ្ធភាព សម្រាប់ការគ្រប់គ្រងហានិភ័យ អនុលោមបញ្ញត្តិ បច្ចេកវិទ្យាព័ត៌មាន និងត្រួតពិនិត្យជាប្រចាំលើសមត្ថភាពរបស់ថ្នាក់គ្រប់គ្រង ក្នុងការវាយតម្លៃ និងការគ្រប់គ្រងហានិភ័យរបស់ធនាគារ។

### សមាជិក

- លោក Pieter Kooi អភិបាលឯករាជ្យ ប្រធាន
- លោក កាយ ឡូត អភិបាលមិនប្រតិបត្តិ សមាជិក
- លោក Kyosuke Hattori អភិបាលមិនប្រតិបត្តិ សមាជិក
- បណ្ឌិត Albertus Bruggink អភិបាលមិនប្រតិបត្តិ សមាជិក
- បណ្ឌិត ហេង ឌីណា អភិបាលឯករាជ្យ សមាជិក

នៅពេលប្រជុំម្តងៗ គណៈកម្មាធិការនេះអាចអញ្ជើញសមាជិកថ្នាក់គ្រប់គ្រង និងទីប្រឹក្សាវិជ្ជាជីវៈខាងក្រៅ ដើម្បីចូលរួមក្នុងកិច្ចប្រជុំទាំងមូល ឬដោយផ្នែកណាមួយដើម្បីផ្តល់ព័ត៌មាន និងការពន្យល់បន្ថែម ដូចដែលពួកគាត់បានសម្រេចចិត្តតាមករណីចាំបាច់។

### លទ្ធផលសម្រេចបានរបស់គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងព័ត៌មានវិទ្យា ក្នុងឆ្នាំ២០២៣

គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងព័ត៌មានវិទ្យា នៃក្រុមប្រឹក្សាភិបាល បានជួបប្រជុំគ្នាចំនួន ១២ដង ក្នុងឆ្នាំ២០២៣ ដែលបានប្រជុំ ១ដងនៅខែមករា ១ដងនៅខែកុម្ភៈ ១ដងនៅខែមីនា ៣ដងនៅខែមេសា ២ដងនៅខែមិថុនា ១ដងនៅខែកក្កដា ១ដងនៅខែសីហា ១ដងនៅខែកញ្ញា និង១ដងទៀតនៅខែធ្នូ។ ដំណើរការសំខាន់ៗ មានដូចជាៈ

- បានត្រួតពិនិត្យ និងពិភាក្សាអំពីកម្រងហានិភ័យរបស់សម្ព័ន្ធធនាគារ និងធនាគារ ដែលត្រូវបានបង្ហាញដោយអនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិគ្រប់គ្រងហានិភ័យ ដើម្បីធានាថា សូចនាករហានិភ័យសំខាន់ៗ ត្រូវបានអនុវត្តស្របទៅតាមកម្រិតកំណត់ ដែលតម្រូវដោយនិយ័តករ កម្រិតកំណត់ផ្ទៃក្នុង និងកម្រិតកំណត់នៃសូចនាករហានិភ័យសំខាន់ៗ នៃវិសអាប់ភៃថាយ (RAS-KRIs)។
- បានវាយតម្លៃ និងបានពិភាក្សា អំពីហានិភ័យជាសារវន្ត នាពេលអនាគតរបស់ធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធ។
- សម្រិតសម្រាំងដំណើរការវិភាគហានិភ័យឱ្យបានប្រសើរឡើងបន្ថែមទៀត និងការអនុវត្តសេណារីយ៉ូ ស្រ្តេសតេស្ត និងរីវើសស្រ្តេសតេស្ត ដែលបណ្តាលឱ្យមានការកើតឡើងនូវហានិភ័យ ដំណាលគ្នា រួមទាំងផលប៉ះពាល់នៃការឆ្លងរីករាលដាលនៃកូវីដ-១៩ ការងើបឡើងយឺតនៃវិស័យសំណង់ និងអចលទ្រព្យ និងហ្វាស៊ីលីធីរៀបចំឡើងវិញ។
- បានត្រួតពិនិត្យរបាយការណ៍នៃដំណើរការវាយតម្លៃភាពគ្រប់គ្រាន់នៃដើមទុនផ្ទៃក្នុង (ICAAP) ក្នុងគោលបំណងវាយតម្លៃភាពគ្រប់គ្រាន់នៃដើមទុនផ្ទៃក្នុងទាំងមូល ស្របទៅនឹងកម្រងហានិភ័យ និងការកំណត់យុទ្ធសាស្រ្តដើម្បីរក្សាកម្រិតសមស្របនៃដើមទុន។
- បានវាយតម្លៃការអភិវឌ្ឍសមតុល្យឥណទានទៅតាមលក្ខណៈវិនិច្ឆ័យផ្សេងៗ និងជាពិសេសទៅលើគុណភាព និងអនុលោមភាពរបស់ឥណទាន ធៀបនឹងគោលការណ៍ផ្ទៃក្នុង។
- បានតាមដាន និងពិភាក្សាអំពីការរៀបចំហ្វាស៊ីលីធីឡើងវិញ បុនហិរញ្ញប្បទាន ការធ្វើចំណាត់ថ្នាក់ហ្វាស៊ីលីធីឡើងវិញ និងការលុបចោលហ្វាស៊ីលីធី។
- វិភាគពីផលប៉ះពាល់នៃសេណារីយ៉ូហានិភ័យ ដែលអាចកើតមាននៅលើតារាងតុល្យការ របាយការណ៍ចំណេញ-ខាត និងអនុបាតប្រុងប្រយ័ត្ន។
- បានត្រួតពិនិត្យ ហានិភ័យជាសារវន្ត ជាមួយនឹងការគិតគូរអំពីបទដ្ឋានប្រកបដោយកម្រិតខ្ពស់ ដែលកំណត់ដោយក្រុមប្រឹក្សាភិបាល ទាក់ទងនឹងបញ្ហា បរិស្ថាន សង្គម និងអភិបាលកិច្ច (ESG) និងការការពារអតិថិជន ។
- បានត្រួតពិនិត្យ និងវិភាគលើបញ្ហាសន្តិសុខសាយប័រ (cybersecurity) និងបញ្ហាបច្ចេកវិទ្យាព័ត៌មានសំខាន់ៗផ្សេងទៀតសម្រាប់ធនាគារឌីជីថល។
- បានត្រួតពិនិត្យ និងវិភាគលើការអភិវឌ្ឍនៃវិស័យធនាគារនៅក្នុងប្រទេសកម្ពុជា ដើម្បីវាយតម្លៃទៅលើហានិភ័យនៃការប្រកួតប្រជែង និងអាជីវកម្ម។
- បានត្រួតពិនិត្យ និងពិភាក្សាលើការអភិវឌ្ឍទីផ្សារសេវាកម្មហិរញ្ញវត្ថុឌីជីថល ឥណទានអាជីវកម្មខ្នាតតូច មធ្យម និងឥណទានអចលនទ្រព្យ និងសំណង់។
- បានពិភាក្សា អំពីយុទ្ធសាស្រ្តក្នុងការគ្រប់គ្រងព្រឹត្តិការណ៍ហានិភ័យដែលអាចកើតមាន ដើម្បីជាអត្ថប្រយោជន៍រយៈពេលវែងរបស់ធនាគារ អេស៊ីលីដា និងអតិថិជនរបស់ខ្លួន។
- បានត្រួតពិនិត្យលទ្ធផលស្រ្តេសតេស្តសន្ទនីយភាព និងផែនការទុនយថាភាព សម្រាប់ឆ្នាំ២០២៤ របស់ថ្នាក់គ្រប់គ្រង។
- បានត្រួតពិនិត្យ និងអនុម័តលើសំណើកម្ចីមូលនិធិរបស់ថ្នាក់គ្រប់គ្រង សម្រាប់គាំទ្រដល់ប្រតិបត្តិការតាមតម្រូវការ។
- បានត្រួតពិនិត្យរបាយការណ៍របស់នាយកដ្ឋានអនុលោមបញ្ញត្តិ និងបានទទួលរបាយការណ៍វិភាគ អំពីប្រតិបត្តិការសង្ស័យនានា។
- បានត្រួតពិនិត្យ និងអនុម័តលើការកំណត់លក្ខខណ្ឌលើកទឹកចិត្ត សម្រាប់នាយកដ្ឋានអនុលោមបញ្ញត្តិ ព្រមទាំងបានស្នើដល់គណៈកម្មាធិការតែងតាំង និងលាភការ ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលអនុម័ត។
- បានត្រួតពិនិត្យ និងអនុម័តលើផែនការថវិការបស់នាយកដ្ឋានអនុលោមបញ្ញត្តិ សម្រាប់ឆ្នាំសារពើពន្ធ២០២៤។
- បានត្រួតពិនិត្យ លក្ខខណ្ឌយោងរបស់គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងព័ត៌មានវិទ្យា។

- បានត្រួតពិនិត្យ និងស្នើនូវគោលការណ៍ជាច្រើនដូចជា៖ គោលការណ៍គ្រប់គ្រងហានិភ័យ ក្របខ័ណ្ឌគ្រប់គ្រងហានិភ័យសន្ទនីយភាព គោលការណ៍ Trade of ACLEDA Bank Shares គោលការណ៍ឥណទាន គោលការណ៍បរិស្ថាន សង្គម និងអភិបាលកិច្ច គោលការណ៍ IFRS9 Impairment គោលការណ៍ Credit Scoring គោលការណ៍អនុលោមភាព គោលការណ៍ប្រឆាំងនឹងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម គោលការណ៍ត្រួតពិនិត្យ-ស្គាល់អតិថិជន គោលការណ៍កំណារពារនិវេទនជន គោលការណ៍ប្រតិបត្តិការសម្ព័ន្ធញាតិ គោលការណ៍ទំនាស់ផលប្រយោជន៍ គោលការណ៍ការជួញដូរផ្ទៃក្នុង គោលការណ៍ក្រមប្រតិបត្តិការងារក្នុងតួនាទី គោលការណ៍បណ្ដឹងតវ៉ាញត្អូញត្អែរអតិថិជន គោលការណ៍អភិបាលព័ត៌មានវិទ្យា និងគោលការណ៍សន្តិសុខព័ត៌មានវិទ្យា។
- បានត្រួតពិនិត្យ និងអនុម័តលើកម្រិតកំណត់នៃសូចនាករហានិភ័យសំខាន់ៗ នៃរីសអាប់ភែថាយ។
- បានធ្វើស្វ័យវាយតម្លៃប្រចាំឆ្នាំ ទៅលើលទ្ធផលសម្រេចបានទាក់ទងទៅនឹងគោលបំណង ភារកិច្ច និងការទទួលខុសត្រូវរបស់គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងព័ត៌មានវិទ្យា ដើម្បីធានាបាននូវការទទួលខុសត្រូវប្រកបដោយប្រសិទ្ធភាព។

## ២. ការប្រែប្រួលសមាជិកនៅក្នុងគណៈកម្មាធិការ

| ល.រ | គណៈកម្មាធិការ | ឈ្មោះ | មូលហេតុ |
|---|---|---|---|
| ១ | សវនកម្ម | មិនមាន | មិនមាន |
| ២ | តែងតាំង និងលាភការ | លោក Pieter Kooi | លោក Pieter Kooi ត្រូវបានតែងតាំងជាប្រធានគណៈកម្មាធិការតែងតាំង និងលាភការ ប្រសិទ្ធភាពថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៣។ |
| ៣ | គ្រប់គ្រងហានិភ័យ និងព័ត៌មានវិទ្យា | បណ្ឌិត ហេង ឌីណា | បណ្ឌិត ហេង ឌីណា ជាសមាជិកអភិបាលថ្មី ត្រូវបានតែងតាំងជាសមាជិកគណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងព័ត៌មានវិទ្យា ប្រសិទ្ធភាពថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៣។ |

# គ. លាភការ ឬប្រាក់បំណាច់

## ១. គោលការណ៍សង្ខេបស្ដីពីលាភការ ឬប្រាក់បំណាច់សម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់

### អភិបាល

- ភាគហ៊ុនិករបស់ធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធកំណត់ អំពីលាភការ និងអត្ថប្រយោជន៍ សម្រាប់អភិបាលតាមស្ថានភាពជាក់ស្ដែង តាមរយៈកិច្ចព្រមព្រៀងភាគហ៊ុនិក ដោយផ្អែកលើ សំណើរបស់ក្រុមប្រឹក្សាភិបាល។
- ភាគហ៊ុនិករបស់ធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធតែងតាំងអភិបាលដូចមានចែងនៅក្នុងលក្ខន្តិកៈរបស់ធនាគារ។

### បុគ្គលិកជាន់ខ្ពស់

- ក្រុមប្រឹក្សាភិបាលរបស់ធនាគារ ទទួលខុសត្រូវជ្រើសរើស និងតែងតាំងបុគ្គលដែលមានគុណវុឌ្ឍិគ្រប់គ្រាន់ជា ប្រធាននាយកប្រតិបត្តិ គណៈប្រធាននាយក-នាយិកាប្រតិបត្តិជាន់ខ្ពស់សវនកម្មផ្ទៃក្នុង/គណៈប្រធាននាយក-នាយិកាប្រតិបត្តិសវនកម្មផ្ទៃក្នុង និងនាយក-នាយិកាប្រតិបត្តិអនុលោមបញ្ញត្តិ។
- ក្រុមប្រឹក្សាភិបាលរបស់ធនាគារ ទទួលខុសត្រូវអនុម័តលាភការសម្រាប់ប្រធាននាយកប្រតិបត្តិ គណៈប្រធាននាយក-នាយិកាប្រតិបត្តិជាន់ខ្ពស់សវនកម្មផ្ទៃក្នុង/គណៈប្រធាននាយក-នាយិកាប្រតិបត្តិសវនកម្មផ្ទៃក្នុង និងនាយក-នាយិកាប្រតិបត្តិអនុលោមបញ្ញត្តិ។
- ក្រុមប្រឹក្សាភិបាលរបស់ធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធ ទទួលខុសត្រូវអនុម័តលើផែនការថវិកាប្រចាំឆ្នាំទាំងអស់ សម្រាប់ការផ្ដល់លាភការជូនអភិបាល និងនិយោជិត។
- ក្រុមប្រឹក្សាភិបាលរបស់ធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធ ត្រូវវាយតម្លៃលទ្ធផលការងាររបស់ខ្លួនប្រចាំឆ្នាំ។

## ២. បុគ្គលទទួលលាភការ ឬប្រាក់បំណាច់

| ល រ | បុគ្គលទទួលបានលាភការ ឬប្រាក់បំណាច់ | ចំនួនលាភការ ឬប្រាក់បំណាច់ | ផ្សេងៗ |
|---|---|---|---|
| ១ | អភិបាល | $៥៤៤.៤៨៨,២៥ | |
| ២ | អភិបាលប្រតិបត្តិ និង បុគ្គលិកជាន់ខ្ពស់ | $៥.៨៣៣.១៨៧,៤២ | |
| ៣ | បុគ្គលិកដែលទទួលបានលាភការ ឬប្រាក់បំណាច់ខ្ពស់បំផុត ៥រូប | $៤.២២៩.០២៥,០១ | |

## ឃ. ការវាយតម្លៃលទ្ធផលប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាភិបាល អភិបាលនីមួយៗ គណៈកម្មាធិការ និងនាយកប្រតិបត្តិ

| ល រ | បរិយាយ | ដំណើរការនៃការវាយតម្លៃ | លក្ខណៈវិនិច្ឆ័យ |
|---|---|---|---|
| ១ | ក្រុមប្រឹក្សាភិបាល | ក្រុមប្រឹក្សាភិបាលធ្វើស្វ័យវាយតម្លៃលើលទ្ធផលការងាររបស់ខ្លួន | • សិទ្ធិអំណាច តួនាទី និងការទទួលខុសត្រូវ ដែលបានកំណត់ក្នុងធម្មនុញ្ញក្រុមប្រឹក្សាភិបាល លក្ខន្តិកៈរបស់ធនាគារ និងច្បាប់ជាធរមាន<br>• ការចូលរួមក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល |
| ២ | អភិបាល | ក្រុមប្រឹក្សាភិបាលធ្វើស្វ័យវាយតម្លៃលើលទ្ធផលការងាររបស់ខ្លួន | • សិទ្ធិអំណាច តួនាទី និងការទទួលខុសត្រូវ ដែលបានកំណត់ក្នុងធម្មនុញ្ញក្រុមប្រឹក្សាភិបាល លក្ខន្តិកៈរបស់ធនាគារ និងច្បាប់ជាធរមាន<br>• ការចូលរួមក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល |
| ៣ | គណៈកម្មាធិការ | គណៈកម្មាធិការក្រុមប្រឹក្សាភិបាលធ្វើស្វ័យវាយតម្លៃលើលទ្ធផលការងាររបស់ខ្លួន | • សិទ្ធិអំណាច តួនាទី និងការទទួលខុសត្រូវ ដែលកំណត់នៅក្នុងតួនាទីភារកិច្ចរបស់ខ្លួន<br>• ការចូលរួមក្នុងកិច្ចប្រជុំគណៈកម្មាធិការ |
| ៤ | ប្រធាននាយកប្រតិបត្តិ | លទ្ធផលការងាររបស់ប្រធាននាយកប្រតិបត្តិ គឺ ត្រូវបានវាយតម្លៃដោយគណៈកម្មាធិការតែងតាំង និងលាភការ និងត្រូវផ្តល់អនុសាសន៍ជូនក្រុមប្រឹក្សាភិបាល ដើម្បីអនុម័តចុងក្រោយ | លក្ខខណ្ឌវាយតម្លៃលទ្ធផលការងារ (ទាំងបរិមាណ និងគុណភាព) ដែលកំណត់ដោយគណៈកម្មាធិការតែងតាំង និងលាភការ និងត្រូវផ្តល់អនុសាសន៍ជូនក្រុមប្រឹក្សាភិបាល ដើម្បីអនុម័តចុងក្រោយ |

# ង. ការបណ្តុះបណ្តាលសម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់

ការបណ្តុះបណ្តាលសម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់ ក្នុងឆ្នាំ២០២៣ មានដូចខាងក្រោមនេះ៖

## ការហ្វឹកហ្វឺនក្នុងស្រុក

| ល.រ | ឈ្មោះ | មុខតំណែង | ប្រធានបទ | ទីកន្លែងហ្វឹកហ្វឺន | ប្រភេទវគ្គហ្វឹកហ្វឺន | រៀបចំហ្វឹកហ្វឺនដោយ | កាលបរិច្ឆេទហ្វឹកហ្វឺន |
|---|---|---|---|---|---|---|---|
| ១ | បណ្ឌិត អ៊ិន ចាន់នី | ប្រធាននាយកប្រតិបត្តិ | The Roles of Governance in Ensuring Commitment and Effective Implementation of Client Protection | រាជធានីភ្នំពេញ | សិក្ខាសាលា | សមាគមធនាគារនៅកម្ពុជា (ABC) | ២៣ សីហា ២០២៣ |
| ២ | លោក Pieter Kooi | អភិបាលឯករាជ្យ | The Roles of Governance in Ensuring Commitment and Effective Implementation of Client Protection | រាជធានីភ្នំពេញ | សិក្ខាសាលា | សមាគមធនាគារនៅកម្ពុជា (ABC) | ២៤ សីហា ២០២៣ |
| ៣ | លោកស្រី គីម សុធារី | គណៈប្រធាននាយិកាប្រតិបត្តិជាន់ខ្ពស់សវនកម្មផ្ទៃក្នុង | 25th training and examination and vocational education program | រាជធានីភ្នំពេញ | ហ្វឹកហ្វឺន | និយ័តករមូលបត្រកម្ពុជា (SERC) | ០៧-១៤សីហា ២០២៣ |
| ៤ | លោកស្រី ម៉ារ អមរា | អនុប្រធាននាយកប្រតិបត្តិជាន់ខ្ពស់ និងជាគណៈប្រធាននាយិកាប្រតិបត្តិហិរញ្ញវត្ថុ និងគណៈប្រធាននាយិកាប្រតិបត្តិប្រតិបត្តិការ | The Roles of Governance in Ensuring Commitment and Effective Implementation of Client Protection | រាជធានីភ្នំពេញ | សិក្ខាសាលា | សមាគមធនាគារនៅកម្ពុជា (ABC) | ១៤ មិថុនា ២០២៣ |
| ៤ | លោកស្រី ម៉ារ អមរា | អនុប្រធាននាយកប្រតិបត្តិជាន់ខ្ពស់ និងជាគណៈប្រធាននាយិកាប្រតិបត្តិហិរញ្ញវត្ថុ និងគណៈប្រធាននាយិកាប្រតិបត្តិប្រតិបត្តិការ | Establishing the Foundation Blocks in Accelerating the Expansion of Women's Financial Inclusion | រាជធានីភ្នំពេញ | សិក្ខាសាលា | Women's World Banking | ១០ សីហា ២០២៣ |
| ៤ | លោកស្រី ម៉ារ អមរា | អនុប្រធាននាយកប្រតិបត្តិជាន់ខ្ពស់ និងជាគណៈប្រធាននាយិកាប្រតិបត្តិហិរញ្ញវត្ថុ និងគណៈប្រធាននាយិកាប្រតិបត្តិប្រតិបត្តិការ | Cambodian Financial Technology Development 2023-2028 | រាជធានីភ្នំពេញ | សិក្ខាសាលា | គណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល (DEBC) និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ MEF) | ០៤ តុលា ២០២៣ |
| ៤ | លោកស្រី ម៉ារ អមរា | អនុប្រធាននាយកប្រតិបត្តិជាន់ខ្ពស់ និងជាគណៈប្រធាននាយិកាប្រតិបត្តិហិរញ្ញវត្ថុ និងគណៈប្រធាននាយិកាប្រតិបត្តិប្រតិបត្តិការ | Understanding and Managing Unhappy Clients Conference | រាជធានីភ្នំពេញ | សន្និសីទ | Singapore (Cambodia) International Academy Co., Ltd. | ០៩ ធ្នូ ២០២៣ |
| ៥ | លោក លី ថៃ | អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិអភិបាលកិច្ច | ទស្សនកិច្ចនៅអគារ IDT | រាជធានីភ្នំពេញ | ទស្សនកិច្ច | អគារ IDT | ១៣ មីនា ២០២៣ |
| ៦ | លោក យិន វីរៈ | អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិរតនាភិបាល | National Bank of Cambodia's Monetary Policy Framework and Tools | រាជធានីភ្នំពេញ | សិក្ខាសាលា | ធនាគារជាតិនៃកម្ពុជា (NBC) | ២៧ ធ្នូ ២០២៣ |

## ការហ្វឹកហ្វឺនក្រៅប្រទេស

| ល.រ | ឈ្មោះ | មុខតំណែង | ប្រធានបទ | ទីកន្លែងហ្វឹកហ្វឺន | ប្រភេទវគ្គហ្វឹកហ្វឺន | រៀបចំហ្វឹកហ្វឺនដោយ | កាលបរិច្ឆេទហ្វឹកហ្វឺន |
|---|---|---|---|---|---|---|---|
| ១ | បណ្ឌិត អ៊ិន ចាន់នី | ប្រធាននាយកប្រតិបត្តិ | Annual Partnership Development Conference | ប្រទេសជប៉ុន | សន្និសីទ | Prudential | ២០-២៥ មេសា ២០២៣ |
| ២ | លោក ឆាយ សឿន | ប្រធានក្រុមប្រឹក្សាភិបាល | Renewal Overseas Standard Graduate | - | ចូលជាសមាជិក | Australian Institute of Company Directors | ៣០ កក្កដា ២០២២-២៩ កក្កដា ២០២៣ |
| ៣ | លោកស្រី គឹម សុធារី | គណៈប្រធាននាយិកាប្រតិបត្តិជាន់ខ្ពស់សវនកម្មផ្ទៃក្នុង | Renewal Overseas Standard Graduate | - | ចូលជាសមាជិក | Australian Institute of Company Directors | ២៩ មេសា ២០២២-២៨ មេសា ២០២៣ |
| | | | IIA renewal membership 2022 | - | ចូលជាសមាជិក | The Institute of Internal Auditors | ៣១ ឧសភា ២០២២-៣០ ឧសភា ២០២៣ |
| ៤ | លោកស្រី ម៉ារ អមរា | អនុប្រធាននាយកប្រតិបត្តិជាន់ខ្ពស់ និងជាគណៈប្រធាននាយិកាប្រតិបត្តិហិរញ្ញវត្ថុ និងគណៈប្រធាននាយិកាប្រតិបត្តិប្រតិបត្តិការ | ASEAN Central Bank Governors & Financial Institute Dialogue as part of 19th ASEAN Central Bank | ប្រទេសឥណ្ឌូនេស៊ី | សន្និសីទ | ASEAN Banker Association | ២៨-៣១ មីនា ២០២៣ |
| | | | World Economic Forum "Looking Ahead Foresight" | - | សិក្ខាសាលាអនឡាញ | World Economic | ០៦ កញ្ញា ២០២៣ |
| | | | 23rd ASEAN BANKING CONFERENCE AND 51st ASEAN BANKING COUNCIL MEETING & 8th AGM | ប្រទេសឡាវ | សន្និសីទ | សមាគមធនាគារនៅឡាវ (Lao Bankers Association) | ០៦-០៨ ធ្នូ ២០២៣ |
| ៥ | បណ្ឌិត ឡឹង សុភាព | អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិហានិភ័យ | The COP28 UAE on Climate Change | សហព័ន្ធអារ៉ាប់រួម | សន្និសីទ | ក្រសួងបរិស្ថាន | ០១-០២ ធ្នូ ២០២៣ |
| ៦ | លោក ម៉ាច់ ធារី | អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិព័ត៌មានវិទ្យា | Core Banking System | ប្រទេសវៀតណាម | ទស្សនកិច្ចនៅកន្លែង | MB Bank | ១២-១៣ កក្កដា ២០២៣ |
| ៧ | លោកស្រី ប៊ុត ប៊ុនសីហា | អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយិកាប្រតិបត្តិនីតិកម្ម និងលេខាធិការក្រុមហ៊ុន | Strategy Execution | - | ហ្វឹកហ្វឺន (អនឡាញ) | Harvard Business School Online | ១៣ កញ្ញា ២០២៣ |
| | | | Leadership Principles | - | ហ្វឹកហ្វឺន (អនឡាញ) | Harvard Business School Online | ០១ កុម្ភៈ ២០២៣ |
| | | | New Overseas Affiliate | - | ចូលជាសមាជិក | Australian Institute of Company Directors | ០១ ធ្នូ ២០២៣-៣០ វិច្ឆិកា ២០២៤ |
| ៨ | លោក យិន វីរៈ | អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិរតនាភិបាល | SOCIAL BANKING at the COFIDES Headquarters in Madrid | ប្រទេសអេស្ប៉ាញ | សិក្ខាសាលា | Social Banking | ១៩-២០ មិថុនា ២០២៣ |
| | | | DEG SE Asia Client Forum 2023 at Bangkok | ប្រទេសថៃ | វេទិកា | DEG (Germany) | ០៧-០៨ កញ្ញា ២០២៣ |

# ផ្នែកទី ៣

## ការអនុវត្តក្រមសីលធម៌
## សម្រាប់អនុវត្តធុរកិច្ច

## ក. ក្រមប្រតិបត្តិរបស់អភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិត៖

- ### ការអនុវត្តច្បាប់

ធនាគារ អេស៊ីលីដា ដំណើរការធុរកិច្ចរបស់ខ្លួនដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិដែលមានជាធរមាន និងស្របតាមគោលការណ៍សីលធម៌ក្នុងកម្រិតខ្ពស់បំផុត។ សម្ព័ន្ធធនាគារ អេស៊ីលីដា តម្រូវឱ្យគ្រប់អភិបាល និងនិយោជិតទាំងអស់អនុវត្តតាមស្របច្បាប់ និងបទប្បញ្ញត្តិជាធរមាន នៅគ្រប់ទីកន្លែងដែលខ្លួនប្រកបអាជីវកម្មឱ្យបានត្រឹមត្រូវ។ លើសពីនេះទៅទៀតគ្រប់កម្មករនិយោជិតទាំងអស់ ត្រូវតែយល់ដឹងអំពីគោលការណ៍របស់ធនាគារ ច្បាប់ វិធាន និងបទប្បញ្ញត្តិនានាដែលអនុវត្តចំពោះតួនាទីរបស់ខ្លួន។ ហេតុដូច្នេះហើយ ធនាគារបានដាក់ចេញនូវគោលការណ៍ ស្តីពីអនុលោមបញ្ញត្តិ ដើម្បីធានាថាធនាគារអនុវត្តត្រឹមត្រូវតាមច្បាប់ និងគោលការណ៍នានាបានគ្រប់ពេលវេលា។

- ### ការកសាងទំនុកចិត្ត និងភាពជឿជាក់

ទំនុកចិត្ត និងភាពជឿជាក់ ដែលយើងទទួលបានពីភាគីពាក់ព័ន្ធ រួមមាន៖ និយោជិត អតិថិជន និងភាគហ៊ុនិក គឺជាផ្នែកនៃភាពជោគជ័យនៃអាជីវកម្មរបស់យើង។ យើងទទួលបានភាពជឿជាក់ដោយការប្រកាន់ខ្ជាប់ និងការប្តេជ្ញា ឈានដល់គោលដៅតាមរយៈការអនុវត្តការងារប្រកបដោយសេចក្តីថ្លៃថ្នូរ។

- ### គោលការណ៍ ស្តីពីក្រមប្រតិបត្តិ

ធនាគារបានអនុម័តនូវគោលការណ៍ស្តីពីក្រមប្រតិបត្តិ ដោយកំណត់នូវស្តង់ដារក្រមសីលធម៌ សម្រាប់គ្រប់បុគ្គលិកទាំងអស់ ដោយមានគោលការណ៍សំខាន់ៗដូចខាងក្រោម៖

១. ស្មោះត្រង់ យុត្តិធម៌ និងសុចរិតភាព៖ គ្រប់បុគ្គលិកទាំងអស់ត្រូវមានសេចក្តីស្មោះត្រង់ និងសុច្ចរិតភាពចំពោះរាល់សកម្មភាពរបស់ខ្លួន ហើយបុគ្គលិកទាំងអស់នឹងមិនត្រូវបានរើសអើងលើពូជសាសន៍ សាសនា ភេទ ស្ថានភាពគ្រួសារ ឬពិការភាពឡើយ។

២. ប្រតិបត្តិការផ្ទាល់ខ្លួន៖ មិនត្រូវប្រើប្រាស់ឈ្មោះធនាគារ អេស៊ីលីដា ដើម្បីធ្វើកិច្ចការផ្ទាល់ខ្លួន ឬអាជីវកម្មផ្សេងៗឡើយ។

៣. ភាពសម្ងាត់នៃព័ត៌មាន៖ ធានារក្សាព័ត៌មានសម្ងាត់ពាក់ព័ន្ធនឹងអតិថិជន បុគ្គលិក និងប្រតិបត្តិការរបស់ធនាគារ និងគោរពឯកជនភាពរបស់បុគ្គលដទៃ។

៤. ការធានានូវសុក្រឹតភាពនៃរបាយការណ៍ និងការត្រួតពិនិត្យផ្ទៃក្នុង។

៥. អនុលោមភាពច្បាប់៖ បុគ្គលិកធនាគារត្រូវគោរព និងប្រតិបត្តិតាមច្បាប់ វិធាន និងបទប្បញ្ញត្តិ នៃព្រះរាជាណាចក្រកម្ពុជា និងគោលការណ៍ផ្ទៃក្នុងរបស់ធនាគារគ្រប់ពេលវេលា។

- ### ការជៀសវាងនូវទំនាស់ផលប្រយោជន៍ (គោលការណ៍ ស្តីពីទំនាស់ផលប្រយោជន៍)

ធនាគារបានបង្កើតនូវគោលការណ៍ ស្តីពីទំនាស់ផលប្រយោជន៍ ដើម្បីឱ្យគ្រប់បុគ្គលិកទាំងអស់របស់ធនាគារមានភាពងាយស្រួលក្នុងការកំណត់ ការទប់ស្កាត់ និងការគ្រប់គ្រងទំនាស់ផលប្រយោជន៍ដែលអាចកើតឡើងក្នុងដំណើរការអាជីវកម្មរបស់ធនាគារ។

- ### គោលការណ៍ ស្តីពីការបង្ហាញព័ត៌មានសាជីវកម្ម

ធនាគារបានដាក់ចេញនូវគោលការណ៍ ស្តីពីការបង្ហាញព័ត៌មាន ដើម្បីធានាថាព័ត៌មានសាជីវកម្មរបស់ធនាគារ ត្រូវបានផ្សព្វផ្សាយទៅអាជ្ញាធរពាក់ព័ន្ធ វិនិយោគិន អតិថិជន ម្ចាស់កម្ចី និយោជិត និងសាធារណជនទូទៅ បានទាន់ពេលវេលា ត្រឹមត្រូវ គ្រប់គ្រាន់ ងាយយល់ និងមានលក្ខណៈសមស្រប។

- ### គោលការណ៍ ស្តីពីការជួញដូរផ្ទៃក្នុង

គោលការណ៍ ស្តីពីការជួញដូរផ្ទៃក្នុង គឺបង្កើតឡើងដើម្បី

- ការពារផលប្រយោជន៍របស់វិនិយោគិន និងការពារកេរ្តិ៍ឈ្មោះរបស់ធនាគារ
- ជៀសវាងការប្រើប្រាស់មិនត្រឹមត្រូវនូវព័ត៌មានសំខាន់មិនផ្សព្វផ្សាយជាសាធារណៈ
- អនុលោមតាមលក្ខខណ្ឌតម្រូវនៃបទប្បញ្ញត្តិ។

យោងតាមគោលការណ៍នេះ អ្នកផ្ទៃក្នុង (ក្រុមប្រឹក្សាភិបាល និងនិយោជិតរបស់ធនាគារ ឬបុគ្រសម្ព័ន្ធរបស់ខ្លួន ព្រមទាំងទីប្រឹក្សា អ្នកម៉ៅការ និងភ្នាក់ងារជាប់កិច្ចសន្យា) ដែលទទួលបាន ឬមានសិទ្ធិចូលយក/ប្រើប្រាស់ព័ត៌មានសំខាន់មិនផ្សព្វផ្សាយជាសាធារណៈរបស់ធនាគារ ត្រូវបានហាមមិនឱ្យទិញ-លក់ ឬធ្វើប្រតិបត្តិការណាមួយដោយផ្ទាល់ ឬដោយប្រយោល ដែលទាក់ទងនឹងមូលបត្រដែលកំពុងចរាចរនៅលើ ផមក ឬទីផ្សារមូលបត្រប្រតិស្រុតផ្សេងទៀត។ (មូលបត្រនៅទីនេះ គឺសំដៅទៅលើមូលបត្រដែលបោះផ្សាយដោយធនាគារ អេស៊ីលីដា ឬក្រុមហ៊ុនបោះផ្សាយផ្សេងទៀត ប្រសិនបើអ្នកផ្ទៃក្នុងមានព័ត៌មានសំខាន់មិនផ្សព្វផ្សាយជាសាធារណៈទាំងនេះតាមរយៈការងាររបស់ពួកគេជាមួយធនាគារ)។

- ## ក្របខ័ណ្ឌគ្រប់គ្រងហានិភ័យសន្ទនីយភាព

  ធនាគារបានបង្កើតក្របខ័ណ្ឌនេះឡើងក្នុងគោលដៅ ដើម្បី៖

  - ធានាថា ធនាគាររក្សាបានគ្រប់ពេលនូវមូលដ្ឋានមូលនិធិដែលមានលក្ខណៈពិពិធកម្ម និងមានស្ថេរភាព ដែលអាចឱ្យធនាគារបំពេញតម្រូវការប្រើប្រាស់សន្ទនីយភាពប្រចាំថ្ងៃ និងអាចបំពេញបាននូវតម្រូវការមូលនិធិទាំងបានរំពឹងទុក និងមិនបានរំពឹងទុក ក្នុងចំណាយដ៏សមរម្យ។
  - គ្រប់គ្រងមូលនិធិ និងសន្ទនីយភាព ក្នុងគោលដៅបង្កើតគុណតម្លៃ (អត្ថប្រយោជន៍) រយៈពេលវែងមួយដល់ភាគហ៊ុនិក។
  - ការពារបាននូវបញ្ហាសន្ទនីយភាពធ្ងន់ធ្ងរដែលអាចកើតមាននាពេលអនាគត និងកាត់បន្ថយផលវិបាកនានាមកលើធនាគារ ថែមទាំងការពាររាល់ភាគីដែលពាក់ព័ន្ធផងដែរ។

- ## គោលការណ៍ ស្តីពីកំណារពារនិវេទនជន

  ធនាគារបានបង្កើតគោលការណ៍នេះ ដើម្បី៖

  - ការពារនិវេទនជនម្នាក់ៗ ដែលបានរាយការណ៍ អំពីបញ្ហាផ្សេងៗដោយសច្ចភាព គ្មានបំណងអាក្រក់ ហើយមិនមានការរំពឹងទុកពីផលចំណេញផ្ទាល់ខ្លួន។
  - លើកទឹកចិត្តនិយោជិតគ្រប់លំដាប់ថ្នាក់ ឱ្យរាយការណ៍ទៅដល់ថ្នាក់គ្រប់គ្រងតាមកម្រិតដែលពាក់ព័ន្ធ នូវសកម្មភាព ឬបញ្ហាណាមួយ ដែលធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍ របស់ធនាគារ និងសាធារណជនទូទៅ។

- ## គោលការណ៍ស្តីពីបរិស្ថាន សង្គម និងអភិបាលកិច្ច

  ធនាគារបង្កើតគោលការណ៍នេះ ដើម្បី៖

  - ធានាថា ធនាគារអាចផ្តល់សេវាកម្មហិរញ្ញវត្ថុ ជាពិសេសដល់គម្រោង និងការផ្តួចផ្តើមប្រកបអាជីវកម្មដែលមាននិរន្តរភាព ដោយគោរពតាមគោលការណ៍ការពារធម្មជាតិ និងបរិស្ថាន។
  - ផ្តល់នូវក្របខ័ណ្ឌនៃគោលការណ៍ណែនាំ ដើម្បីឱ្យធនាគារអាចអនុវត្តអាជីវកម្មប្រកបដោយចីរភាព និងអាចគ្រប់គ្រងបាននូវផលប៉ះពាល់ដល់បរិស្ថាន សង្គម និងអភិបាលកិច្ច។
  - អនុវត្តតាមច្បាប់បរិស្ថាន និងគោលការណ៍ណែនាំរបស់ប្រទេសកម្ពុជា។

- ## ការប្រឆាំងនឹងអំពើពុករលួយ

  ធនាគារហាមឃាត់មិនឱ្យផ្តល់ ឬទទួលសំណូក ឬប្រព្រឹត្តអំពើពុករលួយគ្រប់រូបភាព។ ទង្វើ និងសកម្មភាពហាមឃាត់ទាំងនេះ មានបញ្ជាក់នៅក្នុងអនុសញ្ញារួមនៃការងារ បទប្បញ្ញត្តិផ្ទៃក្នុង ក្រមប្រតិបត្តិអនុវត្តការងារ របាយកំហុស និងគោលការណ៍ប្រតិបត្តិ ស្តីពីអំណោយ កម្រៃជើងសា និងការបញ្ចុះបញ្ចូល។ គ្រប់និយោជិតត្រូវអនុវត្តអនុលោម តាមច្បាប់ និងបទប្បញ្ញត្តិដែលមានជាធរមាន។ សម្ព័ន្ធធនាគារប្តេជ្ញាអនុវត្តធុរកិច្ចដោយស្មោះត្រង់ សុចរិត និងអនុលោមតាមច្បាប់ជាធរមាន រួមទាំងច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយផងដែរ។ និយោជិតដែលអនុវត្តបំពាន ឬផ្ទុយនឹងច្បាប់ និងគោលការណ៍ពាក់ព័ន្ធ នឹងត្រូវទទួលរងនូវពិន័យតាមវិធានវិន័យ។

- ## គោលការណ៍ ស្តីពីការប្រឆាំងនឹងការសម្អាតប្រាក់ និងការប្រយុទ្ធប្រឆាំងនឹងហិរញ្ញប្បទានភេរវកម្ម

  នៅក្នុងការអនុវត្តសកម្មភាពអាជីវកម្មប្រចាំថ្ងៃរបស់ធនាគារ យើងអនុវត្តតាមគោលការណ៍ និងនីតិវិធីដែលបានកំណត់នៅក្នុងគោលការណ៍ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។ ថ្នាក់គ្រប់គ្រង និងកម្មករនិយោជិតធនាគារគ្រប់លំដាប់ថ្នាក់ មានកាតព្វកិច្ចរាយការណ៍នូវរាល់ប្រតិបត្តិការសង្ស័យទាំងអស់ និងតម្រូវឱ្យរក្សាការសម្ងាត់រាល់ប្រតិបត្តិការសង្ស័យរបស់អតិថិជនទាំងនោះ ហើយត្រូវកត់ត្រាទុក។ នាយកប្រតិបត្តិអនុលោមបញ្ញត្តិ មានកាតព្វកិច្ចបញ្ជូនព័ត៌មាននៃប្រតិបត្តិការសង្ស័យទាំងនោះដោយឯករាជ្យ ទៅអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ក្នុងរយៈពេល ២៤ ម៉ោង បន្ទាប់ពីបានទទួលការរាយការណ៍ ប្រសិនបើពិនិត្យឃើញថាប្រតិបត្តិការនោះពិតជាប្រតិបត្តិការដែលសង្ស័យ។ នាយកប្រតិបត្តិអនុលោមបញ្ញត្តិ ត្រូវកត់ត្រានូវមតិយោបល់របស់ខ្លួនទុកប្រសិនបើពិនិត្យឃើញថាប្រតិបត្តិការនោះមិនមានហេតុផលសមរម្យ។

- ## គោលការណ៍ពាក់ព័ន្ធនឹងការងារ/វិធានផ្ទៃក្នុង

  យើងគោរពច្បាប់ដែលមានជាធរមាន រួមមានច្បាប់ និងបទប្បញ្ញត្តិក្នុងប្រទេសដែលពាក់ព័ន្ធនឹងការអនុវត្តធុរកិច្ចរបស់យើង។ ធនាគារមាននូវអនុសញ្ញារួមនៃការងារច្បាស់លាស់ ដែលរៀបចំឡើងស្របតាមជំពូកទី៥ នៃច្បាប់ស្តីពីការងារនៃព្រះរាជាណាចក្រកម្ពុជា។

  អនុសញ្ញារួមនៃការងារ របស់ធនាគារ អេស៊ីលីដា កំណត់នូវលក្ខខណ្ឌការងារ ផលិតភាពនៃការងាររបស់កម្មករនិយោជិត និងគ្រប់គ្រងទំនាក់ទំនងរវាងនិយោជកនិងនិយោជិត ក៏ដូចជានិយោជកជាមួយនឹងប្រតិភូបុគ្គលិកផងដែរ។

- ## ការដោះស្រាយជម្លោះ

  វិធីសាស្ត្រល្អបំផុត ដើម្បីដោះស្រាយជម្លោះនៅកន្លែងធ្វើការ គឺដើម្បីការពារកុំឱ្យមានជម្លោះកើតឡើងពីកន្លែងដំបូង។ អនុសញ្ញារួមនៃការងាររបស់ធនាគារក៏បានចែងអំពីនីតិវិធី បណ្តឹងតវ៉ា សម្រាប់បង្ហាញ និងដោះស្រាយវិវាទនៅកន្លែងធ្វើការ។ ការលើកឡើង និងការទទួលស្គាល់បញ្ហាដើម្បីជជែកដេញដោល ដើម្បីជម្រះមន្ទិលសង្ស័យ និងការយល់ច្រឡំ ដែលមិនសមហេតុផល ជាការងារអាទិភាពត្រូវចាត់វិធានការដោយ ធនាគារ អេស៊ីលីដា និងប្រតិភូបុគ្គលិក។

- ## ការធ្វើអាជីវកម្មដោយស្មោះត្រង់

  ធនាគារបានប្តេជ្ញាប្រកបអាជីវកម្មដោយតម្លាភាព លក្ខណៈត្រឹមត្រូវ និងស្មោះត្រង់ ហើយថែមទាំងប្តេជ្ញាផ្តល់នូវលទ្ធភាពដោះស្រាយដោយយុត្តិធម៌ សម្រាប់អតិថិជនដោយធានាថារាល់ផលិតផល និងសេវាកម្ម ដែលធនាគារបម្រើជូនស្របតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ ហើយសមស្របតាមតម្រូវការរបស់អតិថិជនរបស់ធនាគារ។

## ខ. ការផ្សព្វផ្សាយក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ចដល់អភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិត

ក្រុមប្រឹក្សាភិបាលបានអនុម័តគោលការណ៍ក្រមប្រតិបត្តិ (Code of Conduct Policy) និងបានអនុវត្តចាប់តាំងពីឆ្នាំ២០១៤។

## គ. យន្តការ និងនីតិវិធីតាមដានការអនុវត្តក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ច

ដើម្បីឱ្យកម្មករនិយោជិតយល់ច្បាស់ពីក្រមក្នុងការដំណើរការអជីវកម្ម វិសាលភាពក្នុងការអនុវត្ត ធនាគារបានកំណត់នូវនីតិវិធីដូចខាងក្រោម៖

### សម្រាប់កម្មករនិយោជិតថ្មី

គ្រប់កម្មករនិយោជិតថ្មី ដែលត្រូវបានជ្រើសរើស និងតែងតាំងឲ្យចូលបម្រើការងារក្នុងធនាគារ អេស៊ីលីដា ឬក្រុមហ៊ុនបុត្រសម្ព័ន្ធត្រូវរៀបចំលិខិតក្រមប្រតិបត្តិការងារក្នុងតួនាទី នៅពេលចុះកិច្ចសន្យាការងារ ដោយត្រូវអានគ្រប់ចំណុចនូវខ្លឹមសារនៃក្រមប្រតិបត្តិ និងផ្តិតមេដៃស្តាំទុកជាសក្ខីភាព ដើម្បីបញ្ជាក់ថាយល់ច្បាស់ និងអះអាងរាល់ការបដិបត្តិ។

### សម្រាប់កម្មករនិយោជិតដែលកំពុងបម្រើការងារ

- គ្រប់កម្មករនិយោជិតដែលត្រូវបានតែងតាំង ឬដំឡើងលំដាប់ថ្នាក់ក្នុងមុខងារតួនាទីថ្មី ថ្នាក់គ្រប់គ្រងផ្ទាល់ចុងក្រោយ ត្រូវរៀបចំលិខិតក្រមប្រតិបត្តិការងារក្នុងតួនាទីថ្មី ជូនសាមីអានសាឡើងវិញ គ្រប់ចំណុចនៃខ្លឹមសារ និងផ្តិតស្នាមមេដៃស្តាំទុកជាសក្ខីភាព។
- គ្រប់កម្មករនិយោជិតដែលត្រូវចូលរួមធ្វើវិសោធនកម្ម នៅនាយកដ្ឋានធនធានមនុស្ស តម្រូវឲ្យសរសេរខ្លឹមសារនៃក្រមប្រតិបត្តិការងារក្នុងតួនាទីថ្មី។
- កម្មករនិយោជិតដែលត្រូវដល់កាលបរិច្ឆេទវាយតម្លៃលទ្ធផលការងារតាមកាលកំណត់ ឬមុនកាលកំណត់ត្រូវអនុវត្តដូចខាងក្រោម៖
- សាមីថ្នាក់គ្រប់គ្រងផ្ទាល់ត្រូវផ្តល់លិខិតនៃក្រមប្រតិបត្តិការងារក្នុងតួនាទី ជូនសាមីកម្មករនិយោជិត ដើម្បីអានដោយយកចិត្តទុកដាក់បំផុតតាមអត្ថន័យ និងមាតិកា ដែលមានបញ្ជាក់ក្នុងលិខិតភ្ជាប់ជាមួយទម្រង់វាយតម្លៃលទ្ធផលការងារ។
- បន្ទាប់ពីបានអាននូវអត្ថន័យ នៃក្រមប្រតិបត្តិការងារក្នុងតួនាទី សាមីកម្មករនិយោជិតត្រូវផ្តិតមេដៃស្តាំ ដើម្បីទុកជាសក្ខីភាព។

## ឃ. ប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ

### ១. គោលការណ៍របស់បុគ្គលិកចុះបញ្ជីលក់មូលបត្រ សម្រាប់គ្រប់គ្រងលើប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ

| ល រ | ភាគីជាប់ពាក់ព័ន្ធ | គោលនយោបាយ |
|---|---|---|
| ១ | ក្រុមហ៊ុនហូលឌីង | មិនមាន |
| ២ | កិច្ចព្រមព្រៀងវិនិយោគចម្រុះ | មិនមាន |
| ៣ | ក្រុមហ៊ុនបុត្រសម្ព័ន្ធ | គោលការណ៍ប្រតិបត្តិស្តីពីសម្ព័ន្ធញាតិ |
| ៤ | ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើន និងច្រើនលើសលុប | គោលការណ៍ប្រតិបត្តិស្តីពីសម្ព័ន្ធញាតិ |
| ៥ | អភិបាល និងសមាជិកគ្រួសារផ្ទាល់របស់អភិបាល | គោលការណ៍ប្រតិបត្តិស្តីពីសម្ព័ន្ធញាតិ |
| ៦ | បុគ្គលិក និងសមាជិកគ្រួសារផ្ទាល់របស់បុគ្គលិក | គោលការណ៍ប្រតិបត្តិស្តីពីសម្ព័ន្ធញាតិ |
| ៧ | ផ្សេងៗ | មិនមាន |

## ២. ប្រតិបត្តិការសំខាន់ៗជាមួយភាគីជាប់ពាក់ព័ន្ធ

| ល.រ | ឈ្មោះភាគីជាប់ពាក់ព័ន្ធ | ប្រភេទប្រតិបត្តិការ | ទំហំប្រតិបត្តិការ | | សង្ខេបអំពីប្រតិបត្តិការ |
|---|---|---|---|---|---|
| | | | គិតជាដុល្លារអាមេរិក | ពាន់រៀល | |
| ១ | ភាគហ៊ុនិកដែលមានភាគហ៊ុនចាប់ពី៥ (ប្រាំ) ភាគរយឡើងទៅ នៃមូលបត្រកម្មសិទ្ធិកំពុងធ្វើចរាចរលើទីផ្សារ | សមតុល្យជាមួយសម្ព័ន្ធញាតិ | ៦៥៥.៩៩១ | ២.៦៧៩.៧២៣ | ប្រាក់បញ្ញើនៅភាគហ៊ុនិក |
| | | ប្រាក់បញ្ញើពីសម្ព័ន្ធញាតិ | ៤.២៥៨.១៨២ | ១៧.៣៩៤.៦៧៤ | ប្រាក់បញ្ញើពីភាគហ៊ុនិក |
| | | ប្រាក់កម្ចីពីសម្ព័ន្ធញាតិ | ៦៤.៥៨៥.៨៦៧ | ២៦៣.៨៣៣.២៦៧ | ប្រាក់កម្ចីពីភាគហ៊ុនិក |
| | | គណនីត្រូវទូទាត់ | (៧៥៥.៩០៣) | (៣.០៨៧.៨៦៤) | គណនីត្រូវទូទាត់ទៅភាគហ៊ុនិក |
| | | ចំណូលកម្រៃនិងជើងសាពីសម្ព័ន្ធញាតិ | ១១៥ | ៤៧២ | ចំណូល និងកម្រៃជើងសាពីភាគហ៊ុនិក |
| | | ចំណាយការប្រាក់ | ៦.០៩២.៧០០ | ២៥.០៤០.៩៩៧ | ការប្រាក់ចំណាយទៅភាគហ៊ុនិក |
| ២ | អភិបាល និងបុគ្គលិកជាន់ខ្ពស់ | ឥណទាននិងបុរេប្រទាន | ១០.៤៩៦.៧៧១ | ៤២.៨៧៩.៣០៩ | ឥណទាននិងបុរេប្រទានផ្តល់ទៅអភិបាល និងបុគ្គលិកជាន់ខ្ពស់ |
| | | ប្រាក់បញ្ញើពីសម្ព័ន្ធញាតិ | ៥.៤១៧.២៨៧ | ២២.១២៩.៦១៨ | ប្រាក់បញ្ញើពីអភិបាល និងបុគ្គលិកជាន់ខ្ពស់ |
| | | ចំណូលការប្រាក់ | ៨៩៦.០១៩ | ៣.៦៨២.៦៣៨ | ចំណូលការប្រាក់ពីអភិបាល និងបុគ្គលិកជាន់ខ្ពស់ |
| | | ចំណាយការប្រាក់ | ១១៨.៣០១ | ៤៨៦.២១៧ | ចំណាយការប្រាក់ទៅអភិបាល និងបុគ្គលិកជាន់ខ្ពស់ |
| | | ចំណាយកម្រៃនិងជើងសា | ១១.៣៤៣.៣៥៨ | ៤៦.៦២១.២០២ | ចំណាយកម្រៃនិងជើងសាទៅអភិបាល និងបុគ្គលិកជាន់ខ្ពស់ |
| | | ការប្រាក់ត្រូវបង់ | (៦២.៤៧៣) | (២៥៥.២០២) | ការប្រាក់ត្រូវបង់ទៅអភិបាល និងបុគ្គលិកជាន់ខ្ពស់ |
| ៣ | ប្រតិបត្តិការសំខាន់ៗជាមួយសមាជិកគ្រួសារផ្ទាល់របស់អភិបាល បុគ្គលិកជាន់ខ្ពស់ និងភាគហ៊ុនិកដែលមានភាគហ៊ុនចាប់ពី៥ (ប្រាំ) ភាគរយឡើងទៅ | ឥណទាននិងបុរេប្រទាន | ២.៥៧៧.៥៦២ | ១០.៥២៩.៣៤១ | ឥណទាននិងបុរេប្រទានផ្តល់ទៅសមាជិកគ្រួសារផ្ទាល់របស់អភិបាល បុគ្គលិកជាន់ខ្ពស់ និងភាគហ៊ុនិក |
| | | ប្រាក់បញ្ញើ | ២.៥៥២.២១៣ | ១០.៤២៥.៧៩០ | ប្រាក់បញ្ញើពីសមាជិកគ្រួសារផ្ទាល់របស់អភិបាល បុគ្គលិកជាន់ខ្ពស់ និងភាគហ៊ុនិក |
| | | ការប្រាក់ត្រូវបង់ | (៣១.៤១០) | (១២៨.៣១០) | ការប្រាក់ត្រូវបង់ទៅសមាជិកគ្រួសារផ្ទាល់របស់អភិបាល បុគ្គលិកជាន់ខ្ពស់ និងភាគហ៊ុនិក |
| ៤ | ប្រតិបត្តិការសំខាន់ៗជាមួយក្រុមហ៊ុនបុត្រសម្ព័ន្ធ | សមតុល្យជាមួយសម្ព័ន្ធញាតិ | ១៥.៨៧១ | ៦៤.៨៣៣ | ប្រាក់បញ្ញើនៅក្រុមហ៊ុនបុត្រសម្ព័ន្ធ |
| | | ប្រាក់បញ្ញើ | ៦.២១០.៥២៥ | ២៥.៣៦៩.៩៩៦ | ប្រាក់បញ្ញើពីក្រុមហ៊ុនបុត្រសម្ព័ន្ធ |
| | | គណនីត្រូវទទួល | ៤៤៩.៣៧៧ | ១.៨៣៥.៧០៥ | គណនីត្រូវទទួលពីក្រុមហ៊ុនបុត្រសម្ព័ន្ធ |
| | | ចំណូលការប្រាក់ | ១៨.២៤៧ | ៧៤.៩៩៥ | ចំណូលការប្រាក់ពីក្រុមហ៊ុនបុត្រសម្ព័ន្ធ |
| | | ចំណូលកម្រៃនិងជើងសា | ២៦.៩៧៤ | ១១០.៨៦២ | ចំណូលកម្រៃនិងជើងសាពីក្រុមហ៊ុនបុត្រសម្ព័ន្ធ |
| | | ចំណាយការប្រាក់ | ២០៨.១០១ | ៨៥៥.២៩៥ | ចំណាយការប្រាក់ទៅក្រុមហ៊ុនបុត្រសម្ព័ន្ធ |
| | | ចំណាយកម្រៃនិងជើងសា | ១.៩៦៣.១២៦ | ៨.០៦៨.៤៤៨ | ចំណាយកម្រៃនិងជើងសាទៅក្រុមហ៊ុនបុត្រសម្ព័ន្ធ |
| | | គណនីត្រូវទូទាត់ | (១៨.៩៦០) | (៧៧.៤៥១) | គណនីត្រូវទូទាត់ទៅក្រុមហ៊ុនបុត្រសម្ព័ន្ធ |
| | | កិច្ចសន្យាផ្សេងៗ | (១៧.៦៧៥) | (៧២.៦៤៤) | ការខាតបង់ឥណទានរំពឹងទុកលើការធានាហិរញ្ញវត្ថុលើកម្ចីរបស់វិទ្យាស្ថានពាណិជ្ជសាស្ត្រ អេស៊ីលីដា |

# ផ្នែកទី ៤

## ការគ្រប់គ្រងហានិភ័យ ការត្រួតពិនិត្យផ្ទៃក្នុង និងការធ្វើសវនកម្ម

# ក. សង្ខេបអំពីប្រព័ន្ធគ្រប់គ្រងហានិភ័យ ឬគោលនយោបាយគ្រប់គ្រងហានិភ័យ

ធនាគារ អេស៊ីលីដា បានយកចិត្តទុកដាក់លើកកម្ពស់ប្រព័ន្ធគ្រប់គ្រងហានិភ័យ និងប្រព័ន្ធត្រួតពិនិត្យតាមដានប្រកបដោយប្រសិទ្ធភាពខ្ពស់បំផុត ដើម្បីធានាបាននូវសុវត្ថិភាព និងប្រសិទ្ធភាព ចំពោះធនាគារ ។ វិធីសាស្ត្រក្នុងការគ្រប់គ្រងហានិភ័យរបស់ធនាគារ អេស៊ីលីដា រួមមាន ការកំណត់អត្តសញ្ញាណ ការវាយតម្លៃ ការកាត់បន្ថយ និងការត្រួតពិនិត្យតាមដាន ហានិភ័យ ដែលត្រូវអនុវត្តនៅគ្រប់ផ្នែកអាជីវកម្មរបស់ធនាគារ អេស៊ីលីដា។ លើសពីនេះទៀត ធនាគារ អេស៊ីលីដា មានការគាំទ្ររឹងមាំដោយរចនាសម្ព័ន្ធអភិបាលកិច្ចហានិភ័យ ដែលបានដាក់ឱ្យអនុវត្តស្របទៅតាម "ម៉ូដែលខ្សែបន្ទាត់ទាំងបី" ។ រចនាសម្ព័ន្ធអភិបាលកិច្ចហានិភ័យ បានចែងយ៉ាងច្បាស់លាស់អំពីការទទួលខុសត្រូវ ឯករាជ្យភាព ការរាយការណ៍ ទំនាក់ទំនង និងតម្លាភាព សម្រាប់ភាគីពាក់ព័ន្ធទាំងខាងក្នុង និងខាងក្រៅ ។ ការទទួលខុសត្រូវក្នុងការគ្រប់គ្រងហានិភ័យ គឺមាននៅគ្រប់កម្រិតនៃកម្មករនិយោជិត របស់ធនាគារ អេស៊ីលីដា ដែលនេះជាវិធីសាស្ត្រនៅក្នុងការគ្រប់គ្រងហានិភ័យទៅតាមមុខងារ និងតួនាទី ព្រមទាំងបង្កើតឱ្យមានដំណើរការត្រួតពិនិត្យជាផ្លូវការ តាមរយៈការត្រួតពិនិត្យតាមមុខងារ និងតួនាទីដែលខ្លួនទទួលខុសត្រូវ និងការត្រួតពិនិត្យដោយអ្នកឯករាជ្យ ។ ថ្នាក់គ្រប់គ្រងនីមួយៗ ទទួលខុសត្រូវលើការគ្រប់គ្រងហានិភ័យនៅក្នុងផ្នែករបស់ខ្លួន ព្រមទាំងតម្រូវឲ្យថ្នាក់គ្រប់គ្រងទាំងអស់ត្រូវតែយល់ដឹង និងគ្រប់គ្រងហានិភ័យជាសារវន្តដែលកើតមានឡើងនៅក្នុងអាជីវកម្ម ប្រកបដោយប្រសិទ្ធភាពខ្ពស់បំផុត ។

# ខ. សង្ខេបអំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង

ធនាគារ អេស៊ីលីដា បានបង្កើតប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងយ៉ាងរឹងមាំតាមរយៈដាក់ចេញនូវគោលការណ៍ នីតិវិធី និងសេចក្តីណែនាំផ្សេងៗ ដែលជាមូលដ្ឋានគ្រឹះការពារហានិភ័យ និងសម្រាប់អនុវត្តការប្រតិបត្តិប្រចាំថ្ងៃឱ្យមានប្រសិទ្ធភាព។ ធនាគារមានរចនាសម្ព័ន្ធនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងច្បាស់លាស់ ដូចជាក្រុមប្រឹក្សាភិបាលមានភារកិច្ចដាក់ចេញនូវគោលនយោបាយប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង អនុលោមតាមច្បាប់ ប្រកាស និងបទប្បញ្ញត្តិ។

ថ្នាក់ដឹកនាំជាន់ខ្ពស់មានតួនាទីប្រតិបត្តិតាមគោលនយោបាយ ដែលអនុម័តដោយក្រុមប្រឹក្សាភិបាលតាមរយៈការដាក់ចេញនូវគោលការណ៍ប្រតិបត្តិ នីតិវិធី និងសេចក្តីណែនាំ និងតាមដានត្រួតពិនិត្យការប្រតិបត្តិប្រចាំថ្ងៃ។ មន្ត្រីប្រតិបត្តិតាមមានភារកិច្ចដោយឯករាជ្យក្នុងការគាំទ្រការគ្រប់គ្រងនិងការការពារហានិភ័យអនុលោមបញ្ញត្តិ និងត្រួតពិនិត្យប្រសិទ្ធភាពនៃការប្រតិបត្តិតាមរួមទាំងតាមដានយន្តការកែតម្រូវ។ ភាពរឹងមាំនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងនិងការប្រតិបត្តិតាមគោលការណ៍នីតិវិធី និងសេចក្តីណែនាំត្រូវបានធានាតាមរយៈការធ្វើសវនកម្មផ្ទៃក្នុងនិងភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុត្រូវបានធានាតាមរយៈការធ្វើសវនកម្មដោយក្រុមហ៊ុនសវនកម្មឯករាជ្យ ។

# គ. ការធ្វើសវនកម្ម

## ១. សវនកម្មផ្ទៃក្នុង

### ១.១ កាតព្វកិច្ច និងការទទួលខុសត្រូវរបស់សវនករផ្ទៃក្នុង

សវនកម្មផ្ទៃក្នុងមានតួនាទីតាមដាន និងត្រួតពិនិត្យប្រសិទ្ធភាពនៃមុខងារត្រួតពិនិត្យផ្ទៃក្នុងនិងការប្រតិបត្តិតាមគោលការណ៍ នីតិវិធី និងសេចក្តីណែនាំការការពារហានិភ័យក្នុងប្រតិបត្តិការធនាគារប្រចាំថ្ងៃ។ សវនកម្មផ្ទៃក្នុងមានភារៈរៀបចំផែនការសវនកម្ម ប្រតិបត្តិសវនកម្ម និងរាយការណ៍ផ្ទាល់ជូនគណៈកម្មាធិការសវនកម្ម ។

គ្រប់បញ្ហារកឃើញតាមរយៈការធ្វើសវនកម្មត្រូវមានរបាយការណ៍ និងអនុសាសន៍ច្បាស់លាស់ផ្តល់ជូនគណៈកម្មាធិការសវនកម្ម និងថ្នាក់គ្រប់គ្រង។ រាល់ការកែលម្អតាមអនុសាសន៍មិនទាន់បានអនុវត្តពេញលេញ ត្រូវបន្តធ្វើសវនកម្មតាមដានយ៉ាងតិចពីរដងក្នុងមួយឆ្នាំ ព្រមទាំងរាយការណ៍ជូនគណៈកម្មាធិការសវនកម្ម ។

សវនកម្មផ្ទៃក្នុងដឹកនាំគ្រប់គ្រងការប្រតិបត្តិប្រចាំថ្ងៃដោយគណៈប្រធាននាយិកាប្រតិបត្តិជាន់ខ្ពស់សវនកម្មផ្ទៃក្នុង ដែលមានភារៈជាលេខាធិការ និងទំនាក់ទំនងផ្ទាល់ជាមួយគណៈកម្មាធិការសវនកម្ម ។

គណៈកម្មាធិការសវនកម្មមានតួនាទីតាមដាន វាយតម្លៃ ជ្រើសរើស ចាត់តាំង និងបញ្ឈប់គណៈប្រធាននាយិកាប្រតិបត្តិជាន់ខ្ពស់សវនកម្មផ្ទៃក្នុង ។

### ១.២ ការតែងតាំង និងការដកហូត/ការលាលែងតំណែងរបស់ប្រធាន និង/ឬអនុប្រធានសវនករផ្ទៃក្នុង

ក្នុងឆ្នាំ ២០២៣ តំណែងគណៈប្រធាននាយក/នាយិកាប្រតិបត្តិជាន់ខ្ពស់សវនកម្មផ្ទៃក្នុង មិនមានការតែងតាំងថ្មី ឬការលាលែងឡើយ។

## ២. សវនកម្មខាងក្រៅ

គណៈកម្មាធិការសវនកម្មមានតួនាទីតាមដាន វាយតម្លៃ ជ្រើសរើស និងបញ្ចប់កិច្ចសន្យាសវនកម្មខាងក្រៅតាមរយៈការផ្តល់អនុសាសន៍ជូនក្រុមប្រឹក្សាភិបាលសម្រេច ។ សវនកម្មខាងក្រៅរបស់ធនាគារ អេស៊ីលីដា ប្រចាំឆ្នាំ២០២៣ ដោយក្រុមហ៊ុន ហ្គ្រេន សនថុន (ខេមបូឌា) លីមីធីត ។

| ល រ | ឈ្មោះក្រុមហ៊ុន | កាលបរិច្ឆេទជ្រើសតាំង | តម្លៃសេវាសវនកម្ម | តម្លៃសេវាមិនមែនសវនកម្ម |
|---|---|---|---|---|
| ១ | ហ្គ្រេន សនថុន (ខេមបូឌា) លីមីធីត | ០៨ កញ្ញា ២០២៣ | ៤៥.០០០ ដុល្លារអាមេរិក | - |
| ២ | ប្រាយវ៉តធ័រហោវខូភើស៍ (ខេមបូឌា) | ២០ កញ្ញា ២០២៣ | ៣២០.០០០ ដុល្លារអាមេរិក | - |

- ហ្គ្រេន សនថុន (ខេមបូឌា) លីមីធីត៖ ត្រួតពិនិត្យ វាយតម្លៃភាពសមល្មម និងភាពគ្រប់គ្រាន់នៃមុខងារអនុលោមច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម (AML/CFT) និងច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ (PF) របស់បុគ្គលរាយការណ៍ សម្រាប់ការិយបរិច្ឆេទចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ។
- ប្រាយវ៉តធ័រហោវខូភើស៍ (ខេមបូឌា)៖ កិច្ចព្រមព្រៀងផ្តល់សេវាសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ និង កម្រៃសេវាសវនកម្មសម្រាប់ ឆ្នាំ២០២៤ រួមមាន ៖ សវនកម្មរបាយការណ៍ហិរញ្ញវត្ថុដោយឡែករបស់ធនាគារសម្រាប់សវនកម្មប្រចាំត្រីមាស, សវនកម្មប្រចាំឆ្នាំ និងសវនកម្មរបាយការណ៍ហិរញ្ញវត្ថុក្រុមហ៊ុនរួមប្រចាំឆ្នាំសម្រាប់បំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ។

# ផ្នែកទី ៥

## ភាគីពាក់ព័ន្ធ

## ក. ការបង្ហាញគោលការណ៍ និងសកម្មភាពទាក់ទងនឹងចំណុចដូចខាងក្រោម៖

| ល រ | ខ្លឹមសារ | គោលការណ៍ | សកម្មភាព |
|---|---|---|---|
| ១ | សុខុមាលភាពរបស់អតិថិជន | ១. លិខិតលេខៈ នទផ ០១៩/១៧ ការដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវនីតិវិធី ស្តីពីការថែរក្សាអតិថិជន និង ជំរុញលក់ Cross-Selling & Up-Selling របស់ធនាគារ អេស៊ីលីដា។ | **១. ការថែរក្សាអតិថិជន៖**<br>• មានប្រព័ន្ធក្នុងការគ្រប់គ្រងទិន្នន័យអតិថិជនប្រកបដោយសុវត្ថិភាព និងសុក្រឹតភាព ។<br>• មានការកំណត់ប្រភេទអតិថិជនច្បាស់លាស់ ដើម្បីយកចិត្តទុកដាក់ក្នុងការថែរក្សាអតិថិជន រួមមាន៖<br>▪ អតិថិជនសក្តានុពល (Top 20) ជាប្រភេទ Platinum ទទួលបម្រើជា អាទិភាពទីមួយ<br>▪ អតិថិជនសក្តានុពល (Top 21 to 100) ជាប្រភេទ Gold ទទួលបម្រើជា អាទិភាពទីពីរ<br>▪ អតិថិជនធម្មតា ជាប្រភេទ Classic ទទួលបម្រើជា លក្ខណៈធម្មតា ។<br>• ដើម្បីទទួលបានប្រសិទ្ធភាព លើការជំរុញថែរក្សាអតិថិជនខាងលើ យើងបានកំណត់នូវវិធីសាស្រ្តថែរក្សាអតិថិជន តាមមធ្យោបាយមួយចំនួនរួមមាន៖ ការផ្តល់អត្រាពិសេស, ការជូនប័ណ្ណជូនពរដល់អតិថិជន, ការជូនវត្ថុអនុស្សាវរីយ៍ជូនអតិថិជន,ការអញ្ជើញអតិថិជនពិសារភោជនាហារជាដើម។<br>• មានផែនការច្បាស់លាស់ ក្នុងការចុះថែរក្សាអតិថិជនប្រកបដោយប្រសិទ្ធភាព រួមមានដូចជា៖<br>▪ ការចុះថែរក្សាផ្ទាល់ និងថែរក្សាដោយប្រយោល (តាមទូរស័ព្ទ ឬមធ្យោបាយអេឡិចត្រូនិចជាដើម) ។<br>▪ ការវិភាគប្រតិបត្តិការ និងតម្រូវការអតិថិជន<br>• មានការកំណត់ភ្នាក់ងារទទួលខុសត្រូវតាមដាន និងដឹកនាំលើការអនុវត្តផែនការក្នុងការចុះថែរក្សាអតិថិជននៅតាមបណ្តាលសាខា ច្បាស់លាស់ និងប្រកបដោយចំណេះជំនាញ ។<br>• មានរបាយការណ៍ស្តីពីការថែរក្សាអតិថិជនជូនថ្នាក់គ្រប់គ្រង។<br><br>**២.ការជំរុញលក់** Cross-Selling & Up-Selling<br>• មានការកំណត់ផែនការ Cross-Selling & Up-Selling ច្បាស់លាស់ដើម្បីជាមូលដ្ឋាន សម្រាប់ការជំរុញលក់ជាមួយអតិថិជនសក្តានុពល និងអតិថិជនធម្មតាប្រកដដោយប្រសិទ្ធភាពខ្ពស់ ។<br>• មានភ្នាក់ងារទទួលខុសត្រូវច្បាស់លាស់ លើការជំរុញលក់លើគ្រប់ផលិតផល-សេវាកម្ម ជាមួយគ្រប់ប្រភេទអតិថិជនទាំងក្នុង និងក្រៅការិយាល័យ ដើម្បីសម្រេចឱ្យបានទៅតាមផែនការអាជីវកម្ម ។<br>• មានប្រព័ន្ធដើម្បីរក្សាទុកនូវលទ្ធផលស្តីពីការជំរុញលក់ Cross-Selling ដើម្បីឱ្យភ្នាក់ងារទទួលខុសត្រូវងាយស្រួលក្នុងការតាមដានជាប្រចាំថ្ងៃ ប្រកបដោយប្រសិទ្ធភាពខ្ពស់ ។ ការិយាល័យដើម្បីសម្រេចឱ្យបានទៅតាមផែនការអាជីវកម្ម។<br>• មានមន្ត្រីជំនាញនៃនាយកដ្ឋានទីផ្សារ ធ្វើការតាមដាន និងដឹកនាំលើការជំរុញលក់ ដល់ភ្នាក់ងារទទួលខុសត្រូវនៅតាមបណ្តាសាខា ដើម្បីឱ្យសម្រេចទៅតាមផែនការយុទ្ធសាស្រ្តដែលបានកំណត់ ។ |
| | | ២.សេចក្តីសម្រេចលេខ ធអក ១៣១/១៩ ចុះថ្ងៃព្រហស្បតិ៍ ៤រោច ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ ស្តីពីគោលការណ៍ប្រតិបត្តិស្តីពីការបម្រើអតិថិជនរបស់ធនាគារ អេស៊ីលីដា។ | • យកចិត្តទុកដាក់បម្រើអតិថិជន<br>• គុណភាពបម្រើអតិថិជន<br>• មធ្យោបាយ និងដំណោះស្រាយបញ្ហា ត្អូញត្អែររបស់អតិថិន<br>• ខ្នាតគំរូនៃការបម្រើអតិថិជន<br>• កំណារពារសុវត្ថិភាព (រក្សាការសម្ងាត់លើព័ត៌មានគណនី និងប្រតិបត្តិការរបស់អតិថិជនខាងក្នុង/ក្រៅ ដោយមិនត្រូវបញ្ចេញឱ្យភាគីតតិយជនណាមួយបានដឹងឡើយ) ។ |

| ល.រ | ខ្លឹមសារ | គោលការណ៍ | សកម្មភាព |
|---|---|---|---|
| ២ | ការជ្រើសរើសអ្នកផ្គត់ផ្គង់ | • គោលការណ៍ប្រតិបត្តិស្តីពីលទ្ធកម្ម<br>• គោលការណ៍ណែនាំស្តីពីលទ្ធកម្ម<br>• នីតិវិធីស្តីពីការបោះពុម្ព និងផលិតសម្ភារ | • ការរៀបចំផែនការអាជីវកម្ម (ផែនការអចលនទ្រព្យ)<br>• របាយការណ៍វិភាគ តម្រូវការដោយការិយាល័យគ្រប់គ្រងគម្រោង<br>• ការប្រជុំពិភាក្សា និងអនុម័តដោយគណៈកម្មាធិការគ្រប់គ្រងវិនិយោគ<br>• ការអនុម័តលើសំណើសុំទិញ<br>• ដំណើរការលទ្ធកម្ម<br>សមត្ថកិច្ចអនុម័តក្រៅគណៈកម្មាធិការលទ្ធកម្ម (ទំហំទឹកប្រាក់ស្មើ ឬទាបជាង៣០០,០០០ដុល្លារ)<br>▪ ការយកសម្រង់តម្លៃ<br>▪ ការត្រួតពិនិត្យឯកសារផ្លូវច្បាប់របស់អ្នកផ្គត់ផ្គង់<br>▪ សិទ្ធិលក់ផលិតផល (អាជ្ញាប័ណ្ណ)<br>▪ ការចុះត្រួតពិនិត្យដល់ទីតាំងលក់របស់អ្នកផ្គង់ផ្គង់ (ប្រសិនបើមាន)<br>សមត្ថកិច្ចអនុម័តដោយគណៈកម្មាធិការលទ្ធកម្ម (ទំហំទឹកប្រាក់លើសពី៣០០,០០០ដុល្លារ)<br>▪ ការយកសម្រង់តម្លៃ/ដេញថ្លៃ<br>▪ ការត្រួតពិនិត្យឯកសារផ្លូវច្បាប់របស់អ្នកផ្គត់ផ្គង់<br>▪ សិទ្ធិលក់ផលិតផល (អាជ្ញាប័ណ្ណ)<br>▪ ការចុះត្រួតពិនិត្យដល់ទីតាំងលក់របស់អ្នកផ្គង់ផ្គង់ (ប្រសិនបើមាន)<br>▪ ត្រួតពិនិត្យចំណុចសំខាន់ៗក្នុងការវាយតម្លៃជ្រើសរើសអ្នកផ្គត់ផ្គង់ (ឯកសារផ្លូវច្បាប់, ឯកសារបញ្ជាក់ការបង់ពន្ធ, របាយការណ៍ហិរញ្ញវត្ថុ, ធនធានមនុស្ស, លក្ខណសម្បត្តិទីប្រឹក្សា, វិធីសាស្ត្រអនុវត្ត, កេរ្តិ៍ឈ្មោះក្រុមហ៊ុន,ការផ្តល់សេវាកម្មក្រោយពេលផ្គត់ផ្គង់, គណនីទូទាត់ និងការប្រើប្រាស់សេវាកម្មធនាគារអេស៊ីលីដារបស់ក្រុមហ៊ុនផ្គត់ផ្គង់)<br>▪ ការប្រជុំពិភាក្សា និងអនុម័តដោយគណៈកម្មាធិការលទ្ធកម្ម (ពិចារណាលើតម្លៃ, គុណភាពផលិតផល, បទពិសោធន៍ការងារក្នុងករណីចាំបាច់ និងចំណុចសំខាន់ៗក្នុងការវាយតម្លៃខាងលើ)<br>• ការអនុម័តទម្រង់លទ្ធកម្មជ្រើសរើសអ្នកផ្គត់ផ្គង់ (PCF-15)<br>• ការរៀបចំកិច្ចព្រមព្រៀង/កិច្ចសន្យា<br>• ការប្រគល់-ទទួលផលិតផល/សេវាកម្ម និងការទូទាត់ |

| ល.រ | ខ្លឹមសារ | គោលការណ៍ | សកម្មភាព |
|---|---|---|---|
| ៣ | ការគ្រប់គ្រង និងការការពារនិយោជិត | ១- បទបញ្ជាផ្ទៃក្នុង និងអនុសញ្ញារួមនៃការងារ<br>២- គោលការណ៍ប្រតិបត្តិស្តីពីសុខុមាលភាពកម្មករនិយោជិត<br>៣- កំណារពារនិវេទនជន. | ១- ថ្ងៃបម្រើការងារ, ថិរវេលាធ្វើការ, ប្រាក់ម៉ោងបន្ថែម, ថ្ងៃឈប់សម្រាក, សុវត្ថិភាពការងារ, សិទ្ធិរបស់កម្មករនិយោជិតក្នុងការការពារខ្លួន, ការបៀតបៀន, តំណាងប្រតិភូបុគ្គលិក<br>២- កំណារពារសុខុមាលភាពកម្មករនិយោជិត, ផាសុកភាព, បរិយាកាសការងារ, កន្លែងធ្វើការប្រកបដោយសុវត្ថិភាព បរិយាកាសភ្លឺថ្លា, ការសង្គ្រោះបឋម, ការឧបត្ថម្ភព្យាបាលជំងឺ និងការឧបត្ថម្ភបេសកកម្មការងារ<br>៣- កម្មករនិយោជិតអាចធ្វើការរាយការណ៍អំពីបញ្ហា ដែលអាចបណ្តាលឱ្យប៉ះពាល់អត្ថប្រយោជន៍របស់ធនាគារ ជូននាយកដ្ឋាន/ ការិយាល័យ តាមការយល់ដឹងរបស់ពួកគេ។ បញ្ហាទាំងនោះរួមមាន៖<br>▪ ការមិនអនុវត្តស្របតាមបទប្បញ្ញត្តិ និងក្របខ័ណ្ឌច្បាប់<br>▪ ការមិនប្រកាន់ខ្ជាប់នូវគោលការណ៍ និងនីតិវិធីផ្ទៃក្នុងរបស់ធនាគារ អេស៊ីលីដា<br>▪ ការកេងប្រវ័ញ្ច, ការលួច, ការកែបំបាត់ ឬកម្រែជើងសារផ្សេងៗ<br>▪ សំណូក, ការក្លែងបន្លំ ឬការគ្រប់គ្រងមិនតម្លាភាព, បក្សពួកនិយម<br>▪ ឥរិយាបថដែលអាចបណ្តាលឱ្យប៉ះពាល់ផ្លូវចិត្ត និងសុវត្ថិភាពរបស់កម្មករនិយោជិត<br>▪ ឥរិយាបថមិនត្រឹមត្រូវ ឬគ្មានក្រមសីលធម៌<br>▪ បំពានសិទ្ធិអំណាច, បង្ខំ ឬរូបភាពណាមួយនៃការបំពាន និងការបៀតបៀនដទៃទៀត<br>▪ បទឧក្រិដ្ឋ ឬសកម្មភាពខុសច្បាប់ដទៃទៀត ។ល។ |

| ល រ | ខ្លឹមសារ | គោលការណ៍ | សកម្មភាព |
| --- | --- | --- | --- |
| ៤ | ការគាំពារបរិស្ថាន | លិខិតលេខ ធអក ១៦១៤/២២ ស្ដីពីការដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវគោលការណ៍បរិស្ថានសង្គម និងអភិបាលកិច្ច | • ធនាគា រអនុវត្តតាមច្បាប់ពាក់ព័ន្ធទៅនឹងកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ព្រមទាំងលក្ខណ្ឌតម្រូវផ្សេងៗ ដែលត្រូវបានដាក់កម្រិតអនុវត្ត នៅក្នុងប្រទេសនីមួយៗ។<br>• ធនាគារ ធ្វើប្រតិបត្តិការប្រកបដោយនិរន្តរភាព ដោយកាត់បន្ថយផលប៉ះពាល់ទៅលើបរិស្ថាន និងសង្គម តាមរយៈការលើកកម្ពស់ការអនុវត្តដែលពាក់ព័ន្ធនឹងក្របខ័ណ្ឌ និងសេចក្ដីណែនាំ ។<br>• ធនាគារ មិនផ្ដល់ប្រាក់កម្ចី ឬ ផ្ដល់សេវាហិរញ្ញវត្ថុដល់អតិថិជនដែលពាក់ព័ន្ធនឹងសកម្មភាពដែលបង្កគ្រោះថ្នាក់ដល់បរិស្ថាន ឬដែលមានចែងក្នុងបញ្ជីអាជីវកម្មដែលត្រូវហាមឃាត់ របស់ធនាគារ អេស៊ីលីដានិង/ឬគោលការណ៍ពាក់ព័ន្ធផ្សេងទៀតឡើយ។<br>• ធនាគារ ធ្វើការជាមួយភ្នាក់ងារមានសមត្ថកិច្ច និងទីប្រឹក្សាតាមការចាំបាច់ក្នុងការអនុវត្តគោលការណ៍បរិស្ថានប្រកបដោយប្រសិទ្ធភាពក្នុងករណីដែលមិនមានចែងក្នុងបទប្បញ្ញត្តិ យើងនឹងកំណត់គោលការណ៍ណែនាំមួយដោយអនុលោមទៅតាមឧត្តមនុវត្តន៍ ដែលទទួលស្គាល់ជាអន្តរជាតិ ។<br>• ធនាគារ ផ្ដល់អាទិភាពទៅលើការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព និងការគ្រប់គ្រងរាល់កាកសំណល់ និងសារធាតុពុល ពីសកម្មភាពប្រតិបត្តិការរបស់ខ្លួន ។<br>• ធនាគារផ្ដល់អាទិភាព ចំពោះប្រភពថាមពលកកើតឡើងវិញ និងកាប្រើប្រាស់ថាមពលប្រកបដោយប្រសិទ្ធភាពតាមរយៈសេវាហិរញ្ញវត្ថុ ។<br>• ធនាគារ ប្ដេជ្ញាកាត់បន្ថយការប្រើប្រាស់ថាមពល និងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលពាក់ព័ន្ធនឹងគ្រឿងបរិក្ខារ និងសម្ភារៈ តាមរយៈការប្រើប្រាស់ថាមពលប្រកបដោយប្រសិទ្ធភាព ។<br>• ធនាគារបន្តណែនាំឲ្យមានការប្រើប្រាស់ថាមពលប្រកបដោយប្រសិទ្ធភាព ក្នុងអគារការិយាល័យរបស់ខ្លួន និងចាត់ចែងតម្រូវការប្រើប្រាស់ថាមពលឲ្យសមស្រប នៅគ្រប់កន្លែងប្រតិបត្តិការ ។ |

| លរ | ខ្លឹមសារ | គោលការណ៍ | សកម្មភាព |
|---|---|---|---|
| ៥ | ការទំនាក់ទំនងសហគមន៍ | លិខិតលេខ ធអក ១៦១៤/២២ ស្តីពីការដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវគោលការណ៍បរិស្ថាន សង្គម និងអភិបាលកិច្ច | • ធនាគារ អេស៊ីលីដា គោរពដល់សហគមន៍ និងសង្គមដែលខ្លួនធ្វើប្រតិបត្តិការ និងចូលរួមយ៉ាងសកម្មដើម្បីលើកកម្ពស់វប្បធម៌ឲ្យតម្លៃ និងកោតសរសើរមិន ត្រឹមតែម្ចាស់ភាគហ៊ុន និងបុគ្គលិក អតិថិជន និងដៃគូអាជីវកម្មប៉ុណ្ណោះទេ ប៉ុន្តែថែមទាំង គោរពចំពោះបុគ្គលម្នាក់ៗនៅក្នុងសហគមន៍ ។<br>• អេស៊ីលីដាជឿជាក់ថា ធនាគារអាចសម្រេចគោលដៅធុរកិច្ចទៅបាន ដោយត្រូវធានាថាសកម្មភាពរបស់ខ្លួនស្រប ទៅនឹងសេចក្តីត្រូវការរបស់សហគមន៍ និងសង្គម ប្រកបដោយចីរភាព ដូចជា៖<br>▪ ការផ្តល់ផលិតផល និងសេវាដែលត្រឹមត្រូវ តាមរយៈការជ្រើសរើស និងការអភិវឌ្ឍដោយប្រុងប្រយ័ត្នដើម្បីសេចក្តីត្រូវការជាពិសេសរបស់សហគមន៍កម្ពុជា ។<br>▪ បង្កើនការផ្តល់សេវា៖ ផ្តល់សេវាធនាគារដល់សហគមន៍ថ្មី នៅទីកន្លែងថ្មីៗ តាមរយៈការពង្រីកបណ្តាញប្រតិបត្តិការនៅតាមខេត្ត និងសេវាធនាគារឌីជីថល និងសេវាបញ្ញើ-សន្សំ ។<br>▪ ចូលរួមកម្មវិធីផ្តល់ការអប់រំដល់សាធារណជនទាក់ទងនឹងហិរញ្ញវត្ថុ ដូច្នេះពួកគេអាចគ្រប់គ្រងធនធានរបស់ពួកគេប្រកបដោយប្រសិទ្ធភាព បង្កើនជំនាញធ្វើធុរកិច្ច និងបង្កើនគុណភាពចំពោះវិស័យធនាគារនិងហិរញ្ញវត្ថុ ។<br>▪ ផ្តល់កម្មសិក្សា និងការហ្វឹកហ្វឺនដល់និស្សិត ដើម្បីលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុ ដល់សាធារណជនយ៉ាងទូលំទូលាយ ។<br>▪ រក្សាជំហរក្នុងការផ្តល់សេវាហិរញ្ញវត្ថុដល់សហគមន៍ដែលមានចំណូលទាប ដើម្បីបង្កើនជីវភាពរស់នៅរបស់ពួកគេ ។<br>▪ លើកកម្ពស់ឱកាសការងារសម្រាប់ស្ត្រី ជាមួយ តម្រូវការការងារដ៏សមស្រប ដើម្បីធានាឲ្យមានតុល្យភាពយេនឌ័រ ។<br>▪ ធ្វើការជាមួយក្រុមសហគមន៍ អាជ្ញាធរ និងភាគីពាក់ព័ន្ធដើម្បីអភិវឌ្ឍផលិតផល និងសេវាថ្មី ដើម្បីបំពេញសេចក្តីត្រូវការរបស់ពួកគេ ។<br>▪ ចូលរួមកម្មវិធីសប្បុរសធម៌ ដែលមានគោលដៅ ធ្វើឲ្យមនុស្សចេះជួយខ្លួនឯង ឬ ជួយតាមរយៈការសិក្សា ។ |
| ៦ | ការការពារសិទ្ធិរបស់ម្ចាស់បំណុល | • គោលការណ៍ ស្តីពីក្រមប្រតិបត្តិ<br>• គោលការណ៍ ស្តីពីការបង្ហាញព័ត៌មានសាជីវកម្ម | • បុគ្គលិកទាំងអស់របស់ធនាគារត្រូវអនុវត្តនូវក្រមសីលធម៌ក្នុងកម្រិតខ្ពស់បំផុតដើម្បីការពារសិទ្ធិ និងផលប្រយោជន៍របស់ភាគីពាក់ព័ន្ធ។<br>• ធនាគារធានាការបង្ហាញព័ត៌មានសាជីវកម្មជូនដល់ភាគីពាក់ព័ន្ធ រួមទាំងម្ចាស់បំណុលបានត្រឹមត្រូវ។ |
| ៧ | កម្មវិធីប្រឆាំងអំពីពុករលួយ | • អនុសញ្ញារួមនៃការងារ<br>• បទប្បញ្ញត្តិផ្ទៃក្នុង<br>• របាយលម្អិត ស្តីពីកំហុសរបស់កម្មករនិយោជិត | ជូនដំណឹង និងបណ្តុះបណ្តាលដល់និយោជិតទាំងអស់ ពាក់ព័ន្ធនឹងការប្រឆាំងអំពើពុករលួយ។ |

## ខ. ពិពណ៌នាអំពីទំនួលខុសត្រូវសង្គម ឆ្នាំ២០២៣ របស់ធនាគារ អេស៊ីលីដា

| លរ | អ្នកទទួលផលប្រយោជន៍ | ទំហំនៃការបរិច្ចាគ | គោលបំណងនៃការបរិច្ចាគ |
|---|---|---|---|
| ១ | កាកបាទក្រហមកម្ពុជា | **១.២០០.០០០.០០០ រៀល** | ចូលបច្ច័យដើម្បីកសាងអគារសិក្សា និងសាលប្រជុំថ្មី **ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ** ទីតាំងគោលរាជធានីភ្នំពេញ។ |
| ២ | កាកបាទក្រហមកម្ពុជា | **៨០០.០០០.០០០ រៀល** | ឧបត្ថម្ភដល់ **កាកបាទក្រហមកម្ពុជា** ក្នុងកម្មវិធី អបអរខួបទី១៦០ ទិវាពិភពលោកកាកបាទក្រហម និងអឌ្ឍចន្ទក្រហម ៨ ឧសភា ២០២៣ ។ |
| ៣ | សមាគមគ្រូពេទ្យស្ម័គ្រចិត្តយុវជនសម្តេចតេជោ | **៤០០.០០០.០០០ រៀល** | ឧបត្ថម្ភថវិកាសម្រាប់ចូលរួមចំណែកជាមួយ **សមាគមគ្រូពេទ្យស្ម័គ្រចិត្តយុវជនសម្តេចតេជោ** ដើម្បីផ្តល់សេវាថែរក្សាសុខភាព ក្នុងការពិនិត្យ និងព្យាបាលជំងឺនៅតាមមូលដ្ឋានដោយឥតគិតថ្លៃ ក្នុងបុព្វហេតុលើកកម្ពស់សុខមាលភាពជូនដល់ប្រជាពលរដ្ឋនៅទូទាំងប្រទេស។ |
| ៤ | គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ | **៤០.០០០.០០០ រៀល** | ឧបត្ថម្ភដល់ **គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ** សម្រាប់គាំទ្រនូវឧបករណ៍ និងសម្ភារៈសង្គ្រោះលើផ្ទៃទឹក។ |

# ផ្នែកទី ៦

## ការបង្ហាញព័ត៌មាន និងតម្លាភាព

## ក. ការបង្ហាញព័ត៌មានក្នុងរបាយការណ៍ប្រចាំឆ្នាំដូចខាងក្រោម៖

| លរ | ព័ត៌មាន | មាន /គ្មានបង្ហាញ |
|---|---|---|
| ១ | ចក្ខុវិស័យ/ បេសកម្ម/ គោលដៅអាជីវកម្ម | មាន |
| ២ | សូចនាករហិរញ្ញវត្ថុ | មាន |
| ៣ | សូចនាការមិនមែនហិរញ្ញវត្ថុ | មាន |
| ៤ | កត្តាហានិភ័យសំខាន់ៗ | មាន |
| ៥ | គោលការណ៍ភាគលាភ | មាន |
| ៦ | ជីវប្រវត្តិរបស់អភិបាល | មាន |
| ៧ | ការបណ្តុះបណ្តាលសម្រាប់អភិបាល | មាន |
| ៨ | ចំនួនកិច្ចប្រជុំក្រុមប្រឹក្សាភិបាល | មាន |
| ៩ | វត្តមានរបស់អភិបាលក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល | មាន |
| ១០ | លាភការ ឬប្រាក់បំណាច់សម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់ | មាន |

## ខ. ពិពណ៌នាអំពីយន្តការនៃការបង្ហាញព័ត៌មាន ដោយរៀបរាប់ពីមធ្យោបាយ នីតិវិធី និងបុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មាន

ធនាគារបានអនុម័តនូវគោលការណ៍ ស្តីពីការបង្ហាញព័ត៌មានសាជីវកម្ម ដែលបង្ហាញពីវិធីសាស្ត្រក្នុងការកំណត់នូវព័ត៌មានសំខាន់ និងដើម្បីធានាថាព័ត៌មានសាជីវកម្ម (ព័ត៌មានទាន់ពេល របាយការណ៍សាមាយិក ព័ត៌មានពិសេស ព័ត៌មានតាមការស្នើសុំ និងឯកសារព័ត៌មានពាក់ព័ន្ធផ្សេងទៀត ដែលតម្រូវដោយច្បាប់ និងបទប្បញ្ញត្តិរបស់និយ័តករ/ អាជ្ញាធរពាក់ព័ន្ធ) ត្រូវបានបង្ហាញទៅអាជ្ញាធរពាក់ព័ន្ធ វិនិយោគិន អតិថិជន ម្ចាស់កម្ចី កម្មករនិយោជិត និងសាធារណជន បានទាន់ពេលវេលា ត្រឹមត្រូវ គ្រប់គ្រាន់ ងាយយល់ និងមានលក្ខណៈសមស្រប។ ធនាគារបានរៀបចំព័ត៌មានសាជីវកម្មជាលាយលក្ខណ៍អក្សរ ហើយផ្តល់ជូន ផមក និង/ឬ ន.ម.ក. ដោយផ្ទាល់ ឬតាមរយៈប្រព័ន្ធ e-Disclosure ឬសារអេឡិចត្រូនិក ឬប្រព័ន្ធអេឡិចត្រូនិកផ្សេងទៀត។ ព័ត៌មានដែលត្រូវបង្ហាញនេះ ត្រូវផ្តល់ជាភាសាខ្មែរ និងភាសាអង់គ្លេសក្នុងពេលដំណាលគ្នា។ ក្នុងករណីចាំបាច់និងបន្ទាន់ ការផ្តល់ព័ត៌មានសាជីវកម្មអាចធ្វើឡើងដោយផ្ទាល់មាត់ ឬតាមរយៈទូរស័ព្ទ ឬតាមប្រព័ន្ធអេឡិចត្រូនិក និងធ្វើជាលាយលក្ខណ៍អក្សរភ្លាម។ ក្រៅពីព័ត៌មានសាជីវកម្មដែលត្រូវផ្សព្វផ្សាយជាសាធារណៈទៅវិនិយោគិន ដូចមានចែងក្នុងគោលការណ៍នេះ ធនាគារអាចផ្តល់ឯកសារសម្រាប់ប្រើប្រាស់ផ្ទៃក្នុង ជូន ផមក និង/ឬ ន.ម.ក. ដោយបញ្ជាក់ថា "មិនសម្រាប់ផ្សព្វផ្សាយជាសាធារណៈ"។ ផមក ឬ ន.ម.ក. អាចពិនិត្យ និងតម្រូវឱ្យផ្សព្វផ្សាយជាសាធារណៈ បានក្នុងករណីយល់ឃើញថាដើម្បីការពារផលប្រយោជន៍វិនិយោគិន។

បន្ទាប់ពីព័ត៌មានសាជីវកម្ម ត្រូវបានផ្សព្វផ្សាយនៅលើគេហទំព័រ ផមក (www.csx.com.kh) ធនាគារបានផ្សព្វផ្សាយភ្លាមរាល់ព័ត៌មានទាំងនេះ តាមរយៈគេហទំព័ររបស់ធនាគារ (www.acledabank.com.kh/kh/khm/investor-relation)។

ដើម្បីអនុវត្តស្របតាមប្រកាសរបស់ ន.ម.ក. លេខ៖ ០០៧/១៨ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨ ស្តីពីការបង្ហាញព័ត៌មានសាជីវកម្ម ធនាគារបានតែងតាំង

និងបានទទួលស្គាល់ដោយ ន.ម.ក. នូវមន្ត្រីទំនាក់ទំនងសាធារណៈ មន្ត្រីទទួលបន្ទុកផ្តល់ព័ត៌មាន និងជំនួយការមន្ត្រីទទួលបន្ទុកផ្តល់ព័ត៌មាន នូវសមាសភាពដូចខាងក្រោម៖

### មន្ត្រីទំនាក់ទំនងសាធារណៈ

| លរ | ឈ្មោះ | តំណែង |
|---|---|---|
| ១ | លោកស្រី ម៉ារ អមរា | អនុប្រធាននាយកប្រតិបត្តិជាន់ខ្ពស់ និងជាគណៈប្រធាននាយិកាប្រតិបត្តិហិរញ្ញវត្ថុ និងគណៈប្រធាននាយិកាប្រតិបត្តិប្រតិបត្តិការ |

### មន្ត្រីទទួលបន្ទុកផ្តល់ព័ត៌មាន

| លរ | ឈ្មោះ | តំណែង |
|---|---|---|
| ១ | លោកស្រី ប៊ុត ប៊ុនសីហា | អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយិកាប្រតិបត្តិនីតិកម្ម និងលេខាធិការក្រុមហ៊ុន |

### ជំនួយការមន្ត្រីទទួលបន្ទុកផ្តល់ព័ត៌មាន

| លរ | ឈ្មោះ | តំណែង |
|---|---|---|
| ១ | លោក សុង ផាន់នូ | នាយកប្រតិបត្តិរងនីតិកម្ម |
| ២ | លោកស្រី លាង ច័ន្ទដារ៉ា | ជំនួយការនាយកប្រតិបត្តិលេខាធិការក្រុមហ៊ុន និងបង្ហាញព័ត៌មាន |
| ៣ | លោក សោ សុភា | អ្នកឯកទេសជាន់ខ្ពស់លេខាធិការក្រុមហ៊ុន និងបង្ហាញព័ត៌មាន |
| ៤ | លោក ធិន ពៅ | អ្នកឯកទេសបង្ហាញព័ត៌មាន |
| ៥ | កញ្ញា រឿន ស្រីរដ្ឋ | បុគ្គលិកជាន់ខ្ពស់ផ្នែកបង្ហាញព័ត៌មាន |

## គ. ទំនាក់ទំនងជាមួយវិនិយោគិន

### ១. ការបង្ហាញយន្តការ និងនីតិវិធីទំនាក់ទំនងជាមួយវិនិយោគិន

យើងទទួលស្គាល់ពីសារៈសំខាន់នៃការរក្សាទំនាក់ទំនងជាមួយភាគហ៊ុនិក និងវិនិយោគិនរបស់យើងតាមរយៈបណ្តាញនានាដូចជា របាយការណ៍សមាយិករួមមានរបាយការណ៍ប្រចាំឆ្នាំ និងរបាយការណ៍ប្រចាំត្រីមាស។ ការបង្ហាញព័ត៌មានទាន់ពេលរួមមានសេចក្តីប្រកាសព័ត៌មាន និងសេចក្តីប្រកាសនានា ។ល។ របាយការណ៍ប្រចាំឆ្នាំ និងប្រចាំត្រីមាសរបស់យើងមានព័ត៌មានលម្អិតអំពីហិរញ្ញវត្ថុ និងព័ត៌មានផ្សេងទៀតអំពីសកម្មភាពរបស់សម្ព័ន្ធធនាគារ។ យើងស្វាគមន៍សំណួរផ្សេងៗអំពីសកម្មភាពរបស់សម្ព័ន្ធធនាគារ ហើយនឹងដោះស្រាយឱ្យទាន់ពេលវេលា។

ធនាគារ អេស៊ីលីដា មានបណ្តាញទំនាក់ទំនងយ៉ាងទូលំទូលាយជាមួយអតិថិជនរបស់ខ្លួន ក៏ដូចជាវិនិយោគិន រួមមាន គេហទំព័រ អ៊ីម៉ែល ទូរស័ព្ទ ការជួបដោយផ្ទាល់ និងការអញ្ជើញភាគហ៊ុនិកចូលរួមក្នុងមហាសន្និបាតភាគហ៊ុនិក។

### ២. ពិពណ៌នាដោយសង្ខេបអំពីទំនាក់ទំនងវិនិយោគិនក្នុងរយៈពេល១ (មួយ) ឆ្នាំចុងក្រោយ

ធនាគារ អេស៊ីលីដា គឺជាធនាគារពាណិជ្ជទីមួយដែលបានចុះបញ្ជីលក់ភាគហ៊ុនរបស់ខ្លួនលើផ្សារមូលបត្រកម្ពុជាកាលពីថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០ ដោយទទួលបានចំណាប់អារម្មណ៍យ៉ាងខ្លាំងពីសាធារណជន និងវិនិយោគិនទាំងក្នុងស្រុក និងបរទេស។ ក្នុងឆ្នាំ២០២៣ ធនាគារ អេស៊ីលីដា បានទទួលសំណួរ និងឆ្លើយតបរាល់សំណួររបស់សាធារណជន និងវិនិយោគិន និងបានអញ្ជើញភាគហ៊ុនិកដើម្បីចូលរួមកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកសាមញ្ញលើកទី២៣ ដែលបានប្រារព្ធឡើងកាលពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៣ និងកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកវិសាមញ្ញ ដែលបានប្រារព្ធឡើងកាលពីថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៣៕

## ឃ. របាយការណ៍ចីរភាព

សូមពិនិត្យមើលឧបសម្ព័ន្ធដែលបានភ្ជាប់មកជាមួយរបាយការណ៍ចីរភាពឆ្នាំ២០២៣

# ឧបសម្ព័ន្ធនៃរបាយការណ៍ប្រចាំឆ្នាំ២០២៣របស់ធនាគារ អេស៊ីលីដា

## របាយការណ៍ចីរភាព ឆ្នាំ២០២៣

# ESG

## ឆ្ពោះទៅកាន់ធនាគារឈានមុខប្រកបដោយចីរភាព



## របាយការណ៍ចីរភាព ប្រចាំឆ្នាំ២០២៣

# គុណតម្លៃ

ធនាគារ អេស៊ីលីដា ភីអិលស៊ី គឺជាធនាគារខ្មែរ ធ្វើប្រតិបត្តិការនៅក្នុងប្រទេសដូចជា កម្ពុជា ឡាវ និងមីយ៉ាន់ម៉ា ដែលប្តេជ្ញា និងរក្សាគុណតម្លៃរបស់ខ្លួន ជាមួយនឹងស្ថិរភាពហិរញ្ញវត្ថុ សុវត្ថិភាព សមត្ថភាព សុចរិតភាព គណនេយ្យភាព តម្លាភាព ភាពស្មោះត្រង់ បរិសុទ្ធ និងការយល់ចិត្ត។ តម្លៃទាំងនេះត្រូវបានកំណត់យ៉ាងច្បាស់ក្នុងអត្ថន័យនៃអក្សរជាភាសាខ្មែរ-អង់គ្លេស “អ-A, ស-C, ល-L, ដ-D (**អេស៊ីលីដា**-ACLEDA)”។

**អ**
អភិសមាចារ

ធនាគារផ្តោតលើការប្រព្រឹត្តរៀបរយគួរឱ្យពេញចិត្ត គួរឱ្យជ្រះថ្លាដល់គ្រប់ភាគី រួមមានបុគ្គលិក អតិថិជន ដៃគូរអាជីវកម្ម និងសាធារណជនទូទៅ។

**ស**
សុចរិតភាព
ស្មោះត្រង់

ធនាគារផ្តោតលើការបម្រើសេវាកម្មជូនអតិថិជន សាធារណជន ប្រកបដោយសេចក្តីសុចរិត និងក្រមសីលធម៌វិជ្ជាជីវៈ។

**ល**
លឿនទាន់ចិត្ត
លទ្ធផលល្អ

ធនាគារផ្តោតលើការបម្រើរហ័សទាន់ចិត្ត ផ្គាប់ចិត្ត ផ្តល់នូវទំនុកចិត្តខ្ពស់ជូនអតិថិជន-សាធារណជនប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលល្អ។

**ដ**
ដុះដាលថ្កើងថ្កាន

ធនាគារផ្តោតលើការអភិវឌ្ឍគំនិតច្នៃប្រឌិតទាន់សម័យនៃគ្រប់ផលិតផល-សេវាកម្ម ប្រកបដោយឧត្តមភាព និងវិបុលភាព។

# ទស្សនៈ

ជាធនាគារពាណិជ្ជនាំមុខដែលលោកអ្នកជឿទុកចិត្តបំផុតនៅប្រទេសកម្ពុជា ក្នុងការផ្ដល់ និងបម្រើសេវាកម្មហិរញ្ញវត្ថុជូនដល់សាធារណជនគ្រប់មជ្ឈដ្ឋានក្នុងសហគមន៍។

# បេសកកម្ម

ធនាគារ អេស៊ីលីដា ភីអិលស៊ី ផ្ដល់ជូនអតិថិជននូវផលិតផល និងសេវាកម្មប្រកបដោយនវានុវត្តន៍ និងសុវត្ថិភាព ដើម្បីជាមធ្យោបាយក្នុងការគ្រប់គ្រង ចាត់ចែងធនធានហិរញ្ញវត្ថុឱ្យមានប្រសិទ្ធភាពខ្ពស់។ យើងប្រកាន់ខ្ជាប់ជានិច្ចនូវ គោលការណ៍សីលធម៌ វិជ្ជាជីវៈ សង្គម ច្បាប់ និងបរិស្ថានប្រកបដោយកម្រិតខ្ពស់បំផុត ក្នុងគោលបំណងលើកស្ទួយជីវភាពរស់នៅឱ្យប្រសើរឡើង និងបង្កើនអត្ថប្រយោជន៍ជូនដល់គ្រប់ភាគីពាក់ព័ន្ធ ព្រមទាំងគាំទ្រដល់ការអភិវឌ្ឍ សេដ្ឋកិច្ចជាតិទាំងមូលប្រកបដោយនិរន្តរភាព។

# គតិពេចន៍

**គតិពេចន៍របស់ធនាគារ**

ប្រជាធនាគារដែលលោកអ្នកជឿទុកចិត្ត!

**គតិពេចន៍អេស៊ីលីដាម៉ូបាល**

ធនាគារពិតស្ថិតនៅក្នុងដៃលោកអ្នក!



# មាតិកា


**០៥ សេចក្តីថ្លែងរបស់ប្រធាននាយកប្រតិបត្តិ**

**០៦ អំពីធនាគារ អេស៊ីលីដា ភីអិលស៊ី**

០៨ ទិន្នន័យហិរញ្ញវត្ថុសង្ខេប
០៩ អង្គការលេខ
១០ បណ្តាញប្រតិបត្តិការ
១១ ផលិតផល និងសេវាកម្ម

**១២ ធនាគារ អេស៊ីលីដា ឆ្ពោះទៅកាន់ការអភិវឌ្ឍប្រកបដោយចីរភាព**

១៣ យុទ្ធសាស្ត្រចីរភាពរបស់ធនាគារ អេស៊ីលីដា
១៦ បរិស្ថាន សង្គម និងអភិបាលកិច្ចសង្ខេប
១៧ អភិបាលកិច្ចប្រកបដោយចីរភាព
១៨ ភាគីពាក់ព័ន្ធ
១៩ ការវាយតម្លៃជាសារវន្ត

**២៤ ទិដ្ឋភាពបរិស្ថាន**

២៦ ហានិភ័យនៃការប្រែប្រួលអាកាសធាតុ
៣៤ សូចនាករលើការអនុវត្តផ្នែកបរិស្ថាន

**៣៨ ទិដ្ឋភាពសង្គម**

៤០ សុវត្ថិភាព និងបរិយាកាសការងារ
៤១ ការអនុវត្តសមភាពការងារ
៤៣ ការចូលរួមជាមួយសហគមន៍ និងកិច្ចការសង្គម
៤៩ ការអភិវឌ្ឍធនធានមនុស្ស
៥១ បរិយាបន្នហិរញ្ញវត្ថុ និងចំណេះដឹងហិរញ្ញវត្ថុ
៥៦ ហិរញ្ញប្បទានប្រកបដោយការទទួលខុសត្រូវ និងការរួមបញ្ចូលបរិស្ថាន សង្គម និងអភិបាលកិច្ច
៥៨ សូចនាករលើការអនុវត្តផ្នែកសង្គម

**៦១ ទិដ្ឋភាពអភិបាលកិច្ច**

៦២ អភិបាលកិច្ចសាជីវកម្ម និងការប្រឆាំងអំពើពុករលួយ
៦៤ ក្រមសីលធម៌អាជីវកម្ម
៦៦ សុវត្ថិភាពទិន្នន័យ និងឯកជនភាពរបស់អតិថិជន
៦៨ ការគ្រប់គ្រងហានិភ័យ
៧២ ការអភិវឌ្ឍផលិតផល និងនវានុវត្តន៍ឌីជីថល

**៧៤ អំពីរបាយការណ៍ចីរភាព**

# សេចក្តីថ្លែងរបស់ប្រធាននាយកប្រតិបត្តិ

> "ទន្ទឹមនឹងការខិតខំប្រឹងប្រែង ព្យាយាមឱ្យទទួលបាននូវនិរន្តរភាពខ្ពស់នៃប្រាក់ចំណេញ ធនាគារ អេស៊ីលីដា ក៏គោរពផងដែរចំពោះបរិស្ថាន និងសហគមន៍ដែលយើងរស់នៅ"

**បណ្ឌិត អ៊ិន ចាន់នី**

ប្រធាននាយកប្រតិបត្តិ



បន្ទាប់ពីវិបត្តិកូវីដ១៩ អាជីវកម្ម និងសង្គមត្រូវបានជួបប្រទះនឹងបញ្ហាប្រឈមសំខាន់ៗរួមមាន ការរំខានផ្នែកបច្ចេកវិទ្យាថ្មីៗ សុវត្ថិភាពធនធានសកល ការផ្លាស់ប្តូរបទប្បញ្ញត្តិ និងជាពិសេសផលប៉ះពាល់គួរឱ្យព្រួយបារម្ភនៃការប្រែប្រួលអាកាសធាតុ។

រយៈពេលជាង ៣០ ឆ្នាំកន្លងមកនេះ ក្នុងនាមជាគ្រឹះស្ថានហិរញ្ញវត្ថុឈានមុខគេមួយក្នុងប្រទេសកម្ពុជា ធនាគារយល់ច្បាស់អំពីតួនាទីដ៏សំខាន់របស់ធនាគារក្នុងការគាំទ្រអតិថិជន និងសហគមន៍ ដោយមិនត្រឹមតែផ្តោតលើការផ្តល់សេវាហិរញ្ញវត្ថុ និងប្រាក់ចំណេញប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងយកចិត្តទុកដាក់អំពីសកម្មភាពអាជីវកម្ម ចំពោះអតិថិជន សង្គម និងបរិស្ថាន ដែលវាក៏ជាផ្នែកមួយដ៏សំខាន់នៃការអភិវឌ្ឍប្រកបដោយចីរភាពផងដែរ ។

ខណៈពេលដែលភាគីពាក់ព័ន្ធកំពុងយកចិត្តទុកដាក់ និងផ្តល់តម្លៃដំណើរការអាជីវកម្មទាំងមូលដោយផ្សារភ្ជាប់ទៅនឹងប្រធានបទស្តីពី បរិស្ថាន សង្គម និងអភិបាលកិច្ច (ESG) សំខាន់ៗ ធនាគារក៏បានបង្ហាញពីឆន្ទៈក្នុងការចូលរួមនិងសកម្មភាពទាក់ទងនឹងប្រធានបទនេះ។ ដូច្នេះហើយធនាគារបានធ្វើការវិវឌ្ឍដើម្បីពង្រីកវិសាលភាពនៃរបាយការណ៍បរិស្ថាន និងសង្គម ឱ្យកាន់តែទូលំទូលាយដើម្បីបំពេញតាមតម្រូវការរបស់ភាគីពាក់ព័ន្ធ។ ធនាគារមានមោទនភាពក្នុងការបង្ហាញរបាយការណ៍ចីរភាពនៅឆ្នាំនេះ ដោយសាររបាយការណ៍នេះបានបង្ហាញអំពី ដំណើរការនៃការយកចិត្តទុកដាក់លើបរិស្ថាន សង្គម និងអភិបាលកិច្ចរបស់ធនាគារ ដើម្បីធានាបាននូវតម្លាភាព ការរាស់វែង និងគណនេយ្យភាពចំពោះភាគីពាក់ព័ន្ធ។

ឆ្នាំ ២០២៣ គឺជាឆ្នាំគួរឱ្យកត់សម្គាល់សម្រាប់វិធីសាស្ត្របរិស្ថាន សង្គម និងអភិបាលកិច្ច ក៏ដូចជាសកម្មភាពចីរភាពរបស់ធនាគារ អេស៊ីលីដា។ ខណៈពេលដែលធនាគារ បានគិតគូរអំពីសកម្មភាពរបស់យើងឆ្ពោះទៅរកនិរន្តរភាព ដោយខិតខំកសាងសមត្ថភាព បង្កើតក្របខណ្ឌ និងពង្រឹងភាពត្រឹមត្រូវនៃទិន្នន័យជុំវិញបញ្ហានេះ ដើម្បីឱ្យធនាគារឈានមុខលើរបៀបវារៈចីរភាព ពីព្រោះធនាគារមិនត្រឹមតែចង់ចូលរួមរក្សាភពផែនដី ប្រកបដោយសុខមាលភាពល្អប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធានាដល់ការសម្រេចបាន នៃការផ្លាស់ប្តូររបស់ធនាគារផងដែរ។ ជាងនេះទៅទៀត ធនាគារក៏បានពង្រឹងក្របខណ្ឌគ្រប់គ្រងហានិភ័យ និងផែនការយុទ្ធសាស្ត្ររបស់ធនាគារ ជាមួយនឹងការរួមបញ្ចូលបរិស្ថាន សង្គម និងអភិបាលកិច្ច ដើម្បីវាយតម្លៃហានិភ័យ និងផលប៉ះពាល់ទាក់ទងនឹងបញ្ហាអាកាសធាតុនៅក្នុងសកម្មភាពអាជីវកម្មរបស់យើង។

ជាចុងក្រោយ ខ្ញុំសូមថ្លែងអំណរគុណចំពោះម្ចាស់ភាគហ៊ុន អតិថិជន និងអ្នកពាក់ព័ន្ធទាំងអស់ចំពោះទំនុកចិត្ត និងរក្សាការគាំទ្រមកលើធនាគារក្នុងការបង្កើតតម្លៃ ជាការលើកទឹកចិត្តដល់ការរីកចម្រើនប្រកបដោយចីរភាព ដែលអនុញ្ញាតឱ្យធនាគារសម្រេចបាននូវគោលដៅរបស់ខ្លួនជា "ធនាគារពាណិជ្ជនាំមុខដែលលោកអ្នកជឿទុកចិត្តបំផុត នៅប្រទេសកម្ពុជា" ។

**បណ្ឌិត អ៊ិន ចាន់នី**

*ប្រធាននាយកប្រតិបត្តិ*

*ធនាគារ អេស៊ីលីដា ភីអិលស៊ី*

# អំពីធនាគារ អេស៊ីលីដា ភីអិលស៊ី



## ក- អត្តសញ្ញាណរបស់ធនាគារ អេស៊ីលីដា

| | |
|---|---|
| ឈ្មោះក្រុមហ៊ុនជាអក្សរខ្មែរ | **ធនាគារ អេស៊ីលីដា ភីអិលស៊ី** |
| ឈ្មោះក្រុមហ៊ុនជាអក្សរឡាតាំង | **ACLEDA BANK PLC.** |
| លេខកូដស្តង់ដារ | KH១០០០១០០០០៣ |
| ទីស្នាក់ការ | អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ |
| លេខទូរសព្ទ | +៨៥៥ (០)២៣ ៩៩៨ ៧៧៧ / ៤៣០ ៩៩៩ |
| ទូរសារ | +៨៥៥ (០)២៣ ៤៣០ ៥៥៥ |
| គេហទំព័រ | www.acledabank.com.kh |
| អ៊ីម៉ែល | acledabank@acledabank.com.kh |
| លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម | លេខ ០០០០៣០៧៧ ចុះថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ ២០០០ ចេញដោយក្រសួងពាណិជ្ជកម្ម |
| លេខអាជ្ញាប័ណ្ណអាជីវកម្ម | ធ.ព.០៦ ចុះថ្ងៃទី ០៧ ខែធ្នូ ឆ្នាំ ២០២៣ ចេញដោយ ធនាគារជាតិ នៃ កម្ពុជា |
| លេខចុះបញ្ជីឯកសារ | លេខ០៥៣/២០ គ.ម.ក./ស.ស.រ. ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ ២០២០ ចេញដោយគណៈកម្មការមូលបត្រកម្ពុជា (បច្ចុប្បន្នជា និយ័តករមូលបត្រកម្ពុជា "ន.ម.ក") |
| ឈ្មោះអ្នកតំណាងធនាគារដែលបានចុះបញ្ជី | **បណ្ឌិត អ៊ិន ចាន់នី** |

## ខ- លក្ខណៈធុរកិច្ច

ធនាគារ អេស៊ីលីដា គឺជាធនាគារពាណិជ្ជ និងជាធនាគារដំបូងគេក្នុងប្រទេសកម្ពុជា ដែលបានចុះបញ្ជីនៅផ្សារមូលបត្រកម្ពុជា ដែលមានបណ្តាញសាខា និងការិយាល័យធំជាងគេបង្អស់សម្រាប់ផ្តល់ផលិតផល និងសេវាកម្មហិរញ្ញវត្ថុយ៉ាងទូលំទូលាយដល់អតិថិជនដូចជា ឥណទាន ប្រាក់បញ្ញើ ផ្ទេរប្រាក់ ការគ្រប់គ្រងសាច់ប្រាក់ ហិរញ្ញប្បទានពាណិជ្ជកម្ម ប័ណ្ណអេស៊ីលីដា ប័ណ្ណឥណទាន ប័ណ្ណឥណពន្ធ និងសេវាកម្មឌីជីថល រួមទាំងសេវាអេស៊ីលីដាអ៊ីនធើណែត អេស៊ីលីដាម៉ូបាល (កម្មវិធីធនាគារចល័ត) សេវាអេស៊ីលីដាអ៊ីខុមមើស សេវាអេស៊ីលីដាអេធីអឹម និងម៉ាស៊ីនឆូតកាត និងម៉ាស៊ីនដាក់ប្រាក់តាមកាលកំណត់។ បច្ចុប្បន្នធនាគារមានក្រុមហ៊ុនបុត្រសម្ព័ន្ធចំនួន ៤៖ (១) ធនាគារ អេស៊ីលីដា ឡាវ លីមីតធីត (២) ស្ថាប័នមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា មីយ៉ាន់ម៉ា (៣) ក្រុមហ៊ុន អេស៊ីលីដា ស៊ីឃ្យួរិធី ភីអិលស៊ី និង (៤) សាកលវិទ្យាល័យ ពាណិជ្ជសាស្ត្រ អេស៊ីលីដា ព្រមទាំងមានការិយាល័យតំណាងចំនួន ១ នៅប្រទេសមីយ៉ាន់ម៉ា។

ធនាគារ អេស៊ីលីដា មានភាគទុនិកចំនួន ៦ ដែលកាន់កាប់ភាគហ៊ុនយ៉ាងហោចណាស់ ៥% ឡើងទៅនៃមូលបត្រកម្មសិទ្ធកំពុងធ្វើចរាចរលើទីផ្សារ ក្នុងនោះរួមមាន៖ (១) AFT (២) SMBC (៣) COFIBRED (៤) ORIX Corporation (៥) Public Shareholders និង (៦) Shareholders Legalized from ASA, Plc ។

# ទិន្នន័យហិរញ្ញវត្ថុសង្ខេប

| ឯកតាគិតជា ដុល្លារអាមេរិក '០០០ | ៣១/១២/១៩ បានធ្វើសវនកម្ម | ៣១/១២/២០ បានធ្វើសវនកម្ម | ៣១/១២/២១ បានធ្វើសវនកម្ម | ៣១/១២/២២ បានធ្វើសវនកម្ម | ៣១/១២/២៣ បានធ្វើសវនកម្ម | បម្រែបម្រួល (%) |
|---|---|---|---|---|---|---|

## ទិន្នន័យហិរញ្ញវត្ថុសង្ខេបរួម (ស.រ.ហ.អ.ក)

| | | | | | | |
|---|---|---|---|---|---|---|
| ទ្រព្យសកម្ម | ៦.១៧៥.១៦២ | ៦.៥៥១.៤៩៤ | ៧.៨៥៥.២៥២ | ៩.០៣១.១៦៣ | ៩.៧៤៤.០៤០ | ៧,៨៩% |
| ឥណទាន និងបុរេប្រទាន (សុទ្ធ) | ៣.៨៤៦.០២១ | ៤.៤៧១.៣០១ | ៥.៣៩៣.៩៥៤ | ៦.៣៧៩.៤០៦ | ៦.៦០១.៦៦៥ | ៣,៤៨% |
| បំណុល | ៥.២១០.៧០០ | ៥.៤៦១.៨៦៨ | ៦.៦៥០.២១៧ | ៧.៧១៤.៥១៥ | ៨.៣៦២.០២០ | ៨,៣៩% |
| ប្រាក់បញ្ញើ | ៤.៣៦៧.៨៩៨ | ៤.៦១១.២៩៦ | ៥.៧១៦.០២០ | ៦.៣៨៨.៩៩១ | ៧.២២៧.៨១៣ | ១៣,១៣% |
| ដើមទុន | ៤២៨.៨១៨ | ៤៣៣.១៦៣ | ៤៣៣.១៦៣ | ៤៣៣.១៦៣ | ៤៣៣.១៦៣ | ០,០០% |
| ភាគហ៊ុនិក | ៩៦៤.៤៦២ | ១.០៨៩.៦២៦ | ១.១៩៩.០៤២ | ១.៣១០.៥៨៨ | ១.៣៧៥.៩៩៩ | ៤,៩៩% |
| ចំណូលដុល | ៥៥០.១២៨ | ៥៧៩.២២១ | ៦៣៦.៦៩៨ | ៧៤៣.៨៣១ | ៨២៨.០០៨ | ១១,៣២% |
| ប្រាក់ចំណេញមុនដកពន្ធ | ១៥៣.៥២៣ | ១៨០.០៣៥ | ២០៤.៧៥៣ | ២២៨.៣០៨ | ១៨៤.២៣៨ | -១៩,៣០% |
| ប្រាក់ចំណេញសុទ្ធបន្ទាប់ពីដកពន្ធ | ១២០.៨៦០ | ១៤១.៤៩៣ | ១៦៦.៦៧៤ | ១៨១.៨១៥ | ១៤៨.០១៨ | -១៨,៥៩% |
| ប្រាក់ចំណូលក្នុងមួយហ៊ុន | ០,២៩ | ០,៣៣ | ០,៣៩ | ០,៤២ | ០,៣៤ | -១៩,០៥% |
| ភាគលាភ | ០.០៧៦៣$ | ០.០៩៨១$ | ៥៤៨,៦៤០៥៛ | ៦៨៥,៨៩៨៥៛ | - | - |

## ទិន្នន័យហិរញ្ញវត្ថុសង្ខេប (ស.រ.ហ.អ.ក)

| | | | | | | |
|---|---|---|---|---|---|---|
| ទ្រព្យសកម្ម | ៦.០១៧.៣០៣ | ៦.៣៧៩.៤៨៤ | ៧.៦៩៥.១៦៣ | ៨.៩១៨.៤៤៦ | ៩.៦០៥.៦៤៧ | ៧,៧១% |
| ឥណទាន និងបុរេប្រទាន (សុទ្ធ) | ៣.៦៨៦.៥៧៩ | ៤.២៩២.៦៤៩ | ៥.២៣២.០៥៩ | ៦.២៤៦.២៦៩ | ៦.៤៥៧.០៤៣ | ៣,៣៧% |
| បំណុល | ៥.០៤៥.០២៥ | ៥.២៨៥.៤៥៨ | ៦.៤៨៦.០៧១ | ៧.៥៨៧.៣៥៩ | ៨.២១៣.០០១ | ៨,២៥% |
| ប្រាក់បញ្ញើ | ៤.២៥៦.៤២៤ | ៤.៤៧៧.០៣៣ | ៥.៥៨២.៥៣៤ | ៦.២៨០.០៤៥ | ៧.១០១.៦៩៥ | ១៣,០៨% |
| ដើមទុន | ៤២៨.៨១៨ | ៤៣៣.១៦៣ | ៤៣៣.១៦៣ | ៤៣៣.១៦៣ | ៤៣៣.១៦៣ | ០,០០% |
| ភាគហ៊ុនិក | ៩៧២.២៧៩ | ១.០៩៤.០២៦ | ១.២០៩.០៩២ | ១.៣៣១.០៨៦ | ១.៣៩២.៦៤៦ | ៤,៦២% |
| ចំណូលដុល | ៥១៤.៩៣៣ | ៥៣៧.៧៥៦ | ៥៩៤.៦២៥ | ៧០៥.២១៤ | ៧៩២.១២៥ | ១២,៣២% |
| ប្រាក់ចំណេញមុនដកពន្ធ | ១៤៨.២២៦ | ១៧២.១៥៤ | ២០១.៦៦២ | ២១៧.៤២៣ | ១៧២.២០២ | -២០,៨០% |
| ប្រាក់ចំណេញសុទ្ធបន្ទាប់ពីដកពន្ធ | ១១៧.៨៨៧ | ១៣៨.៣៨២ | ១៦២.០៨៥ | ១៧៣.៤០៦ | ១៣៨.១៣៩ | -២០,៣៤% |

# អង្គការលេខ


ភាគទុនិក
ក្រុមប្រឹក្សាភិបាល
គណៈកម្មាធិការសវនកម្ម
គណៈកម្មាធិការតែងតាំង និងលាភការ
គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងព័ត៌មានវិទ្យា
ប្រធាននាយកប្រតិបត្តិ
គណៈកម្មាធិការប្រតិបត្តិ
អេស៊ីលីដា ការិយាល័យតំណាង
អេស៊ីលីដា មីក្រូហិរញ្ញវត្ថុ មីយ៉ាន់ម៉ា លីមីតធីត
ធនាគារ អេស៊ីលីដា ឡាវ លីមីធីត
អេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី
វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា
គណៈកម្មាធិការធនធានមនុស្ស ទទួលខុសត្រូវបញ្ហាអេដស៍ និងការប្រយុទ្ធប្រឆាំងគ្រឿងញៀន
គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងអកម្ម
គណៈកម្មាធិការលទ្ធកម្ម
គណៈកម្មាធិការគ្រប់គ្រងវិនិយោគ
គណៈកម្មាធិការដឹកនាំ និងគ្រប់គ្រងបច្ចេកវិទ្យាព័ត៌មាន
គណៈកម្មាធិការឥណទានកម្រិតប្រតិបត្តិ
គណៈកម្មាធិការគ្រប់គ្រងយុទ្ធសាស្ត្របច្ចេកវិទ្យាព័ត៌មាន
អនុប្រធាននាយកប្រតិបត្តិជាន់ខ្ពស់ និងជាគណៈប្រធាននាយកប្រតិបត្តិហិរញ្ញវត្ថុ និងគណៈប្រធាននាយកប្រតិបត្តិប្រតិបត្តិការ
នាយកដ្ឋានប្រតិបត្តិការ
នាយកដ្ឋានគ្រប់គ្រងសេវាឥណទាន
នាយកដ្ឋានទីផ្សារ
នាយកដ្ឋានអភិវឌ្ឍន៍ផលិតផល
នាយកដ្ឋានសេវាហិរញ្ញវត្ថុ
នាយកដ្ឋានផែនការយុទ្ធសាស្ត្រ
ការិយាល័យហិរញ្ញប្បទានពាណិជ្ជកម្ម
នាយកដ្ឋានហិរញ្ញវត្ថុ
នាយកដ្ឋានរៀបចំ និងត្រួតពិនិត្យផែនការថវិកា
នាយកដ្ឋានវិនិយោគសាធារណៈ
ការិយាល័យគណនេយ្យគ្រប់គ្រង
អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិរតនាភិបាល
នាយកដ្ឋានប្រតិបត្តិការហិរញ្ញវត្ថុ
ការិយាល័យរតនាភិបាល
ការិយាល័យប្រាក់តម្កល់ និងអត្រាប្តូរប្រាក់បណ្ណ
ការិយាល័យរតនពាណិជ្ជកម្ម
អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិអភិបាលកិច្ច
នាយកដ្ឋានធនធានមនុស្ស
នាយកដ្ឋានរដ្ឋបាល
អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិនីតិកម្ម និងលេខាធិការក្រុមហ៊ុន
នាយកដ្ឋាននីតិកម្ម
នាយកដ្ឋាន លេខាធិការក្រុមហ៊ុន និងបង្ហាញព័ត៌មាន
ការិយាល័យប្រឹក្សាបុគ្គលសម្ព័ន្ធ
ការិយាល័យគ្រប់គ្រងវិវាទ
អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិព័ត៌មានវិទ្យា
នាយកដ្ឋានគ្រប់គ្រងសេវាកម្មផ្នែកទន់
នាយកដ្ឋានសន្តិសុខព័ត៌មានវិទ្យា
នាយកដ្ឋានប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ
នាយកដ្ឋានរៀបចំយុទ្ធសាស្ត្រ និងអភិបាលព័ត៌មានវិទ្យា
នាយកដ្ឋានគ្រប់គ្រងសេវាកម្មឌីជីថល
ការិយាល័យសេវាកម្មព័ត៌មានវិទ្យា
អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិហានិភ័យ
នាយកដ្ឋានគ្រប់គ្រងហានិភ័យ
នាយកដ្ឋានឥណទាន
នាយកដ្ឋានវិភាគទិន្នន័យឥណទាន
ការិយាល័យត្រួតពិនិត្យឥណទាន
គណៈប្រធាននាយិកាប្រតិបត្តិជាន់ខ្ពស់សវនកម្មផ្ទៃក្នុង
នាយកដ្ឋានអភិវឌ្ឍន៍សវនកម្មផ្ទៃក្នុង
នាយកដ្ឋានសវនកម្មប្រព័ន្ធព័ត៌មានវិទ្យា
ការិយាល័យសវនកម្មឥណទាន
ការិយាល័យសវនកម្មហិរញ្ញវត្ថុ
ការិយាល័យសវនកម្មប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម
ការិយាល័យរបាយការណ៍សវនកម្ម
នាយកដ្ឋានអនុលោមបញ្ញត្តិ
២៦៤ សាខា គ្របដណ្តប់ទូទាំងប្រទេស

# បណ្តាញប្រតិបត្តិការ

អេស៊ីលីដា
ACLEDA BANK

ធនាគារ អេស៊ីលីដា មានសាខា
ចំនួន ២៦៤ គ្របដណ្តប់គ្រប់ខេត្ត និងរាជធានី នៅ ព្រះរាជាណាចក្រកម្ពុជា និងចំនួន
៣៧ សាខា នៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ព្រមទាំង ១៧ សាខា នៅ
សាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា ។



# ផលិតផល និងសេវាកម្ម

## ឥណទាន

- ឥណទានអាជីវកម្មខ្នាតតូច
- ឥណទានអាជីវកម្មខ្នាតមធ្យម និងសាជីវកម្ម
- ឥណទានវិបារូបរ៍
- ឥណទានសម្រាប់ទុនបង្វិល
- ឥណទានសម្រាប់កិច្ចធានា
- ឥណទានពាណិជ្ជកម្ម
- ឥណទានសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួន
- ឥណទានរថយន្ត
- ឥណទានម៉ូតូ
- ឥណទាននិស្សិត
- ឥណទានគេហដ្ឋាន
- ឥណទានកែលម្អលំនៅឋាន
- សេវាភតិសន្យាហិរញ្ញវត្ថុ

## សេវាហិរញ្ញប្បទានពាណិជ្ជកម្ម

- សេវាការប្រមូលឯកសារ
- សេវាលិខិតឥណទាន (នាំចូល/នាំចេញ)
- សេវាលិខិតធានា

## សេវាបញ្ញើ-សន្សំ

- គណនីបញ្ញើសំចៃ
- គណនីបញ្ញើតាមតម្រូវការ
- គណនីចរន្ត
- ប្រាក់បញ្ញើមានកាលកំណត់
- គណនី Euro Flex
- គណនីមូលបត្រ
- គណនីព្រះសង្ឃ និងគណនីមូលនិធិវត្ត
- គណនីអនាគតកុមារ

## ប័ណ្ណឥណទាន

- ប័ណ្ណឥណទានប្រើប្រាស់ផ្ទាល់ខ្លួន
- ប័ណ្ណអេស៊ីលីដា
- ប័ណ្ណឥណពន្ធវីសាអេស៊ីលីដា / ប័ណ្ណឥណទានវីសាអេស៊ីលីដា
- ប័ណ្ណឥណពន្ធម៉ាស្ទ័រកាតអេស៊ីលីដា / ប័ណ្ណឥណទានម៉ាស្ទ័រកាតអេស៊ីលីដា
- ប័ណ្ណឥណពន្ធឡេឌីម៉ាស្ទ័រកាត / ប័ណ្ណឥណទានឡេឌីម៉ាស្ទ័រកាត
- ប័ណ្ណឥណពន្ធចេស៊ីប៊ីអេស៊ីលីដា
- ប័ណ្ណយូភីអាយអេស៊ីលីដា

## សេវាពិនិត្យសុខភាពហិរញ្ញវត្ថុ

## សេវាធានារ៉ាប់រងអាយុជីវិត ក្នុងនាមជាម៉ូឌែលភ្នាក់ងារ

## សេវាចាត់ចែងសាច់ប្រាក់

- សេវាលិខិតអះអាងលើគណនី និងព័ត៌មានអតិថិជន
- សេវាមូលប្បទានប័ត្រសាច់ប្រាក់
- សេវាបើកប្រាក់បៀវត្ស
- សេវាប្រមូលសាច់ប្រាក់
- សេវាទូទាត់ឱ្យអ្នកផ្គត់ផ្គង់
- សេវាសម្រួលគណនីអតិថិជន
- សេវាបញ្ជាអចិន្ត្រៃយ៍
- សេវាទិញមូលប្បទានប័ត្របរទេស និងមូលប្បទានប័ត្រទេសចរណ៍
- សេវាប្រមូលប្រាក់បង់ពន្ធ
- សេវាកិច្ចសន្យាប្តូររូបិយប័ណ្ណទុកមុន
- សេវាផ្ទេរប្រាក់ទូទាត់ជាកញ្ចប់
- សេវាប្តូរប្រាក់

## សេវាផ្ទេរប្រាក់

- ផ្ទេរប្រាក់ក្នុងស្រុក
- ផ្ទេរប្រាក់ទៅ-មក ក្រៅប្រទេសតាមរយៈ SWIFT
- ផ្ទេរប្រាក់ទៅ-មក ក្រៅប្រទេសតាមរយៈ វ៉េសស្ទឺន យូញៀន
- ផ្ទេរប្រាក់ទៅ-មក ក្រៅប្រទេសតាមរយៈ ម៉ាន់នីក្រាម
- ផ្ទេរប្រាក់ទៅ-មក ក្រៅប្រទេសតាមរយៈ Thune
- ផ្ទេរប្រាក់ទៅ-មក ក្រៅប្រទេសតាមរយៈ Ria Money Transfer

## សេវាឌីជីថល

- សេវាអេស៊ីលីដាអ៊ីនធើណែត
- អេស៊ីលីដាម៉ូបាល
- សេវាអេស៊ីលីដាអ៊ីខុមមើស
- ម៉ាស៊ីនអេធីអឹម អេស៊ីលីដា
- ម៉ាស៊ីនឆូតកាត អេស៊ីលីដា
- ម៉ាស៊ីនដាក់ប្រាក់បញ្ញើមានកាលកំណត់Virtual ម៉ាស៊ីនបើកគណនី និងបោះពុម្ពប័ណ្ណអេធីអឹម
- Pay Band
- ប័ណ្ណនិម្មិត
- សេវាបញ្ចូលទឹកប្រាក់
- សេវាទូទាត់វិក្កយបត្រ
- សេវាបញ្ជាតាមរយៈ E-mail/Fax
- សេវាផ្ញើសារជូនដំណឹងព័ត៌មានគណនី

## សេវាពាក់ព័ន្ធមូលបត្រ និងបរធន

- សេវារក្សាសុវត្ថិភាព ក្នុងវិស័យមូលបត្រ
- សេវាប្រតិបត្តិការ RTP
- សេវាមូលបត្ររដ្ឋ
- បរធនបាលកិច្ចពាណិជ្ជកម្ម
- បរធនបាលកិច្ចសង្គម
- បរធនបាលកិច្ចសាធារណៈ
- បរធនបាលកិច្ចបុគ្គល
- បរធនបាលកិច្ចហិរញ្ញវត្ថុ




# ធនាគារ អេស៊ីលីដា ឆ្ពោះទៅកាន់ការអភិវឌ្ឍដោយចីរភាព

ធនាគារ អេស៊ីលីដា ដំណើរការអាជីវកម្មស្របតាមគោលការណ៍ចីរភាព ដែលគ្របដណ្តប់លើវិស័យបីគឺ សេដ្ឋកិច្ច សង្គម និងបរិស្ថាន ។ ចាប់តាំងពីឆ្នាំ ២០០៥ មកគោលការណ៍បរិស្ថាន សង្គម និងអភិបាលកិច្ចត្រូវបានបង្កើតឡើង និងផ្សព្វផ្សាយជាផ្លូវការ ក្នុងគោលបំណងផ្តល់នូវក្របខណ្ឌនៃគោលការណ៍ណែនាំ ដែលអាចធ្វើឱ្យធនាគារដំណើរការប្រកបដោយនិរន្តរភាព ដោយកាត់បន្ថយផលប៉ះពាល់ដល់បរិស្ថាន សង្គម និងសហគមន៍ ខណៈពេលដែលគោលការណ៍នេះក៏ត្រូវបានត្រួតពិនិត្យឡើងវិញប្រចាំឆ្នាំផងដែរ។ គ្រប់ផ្នែកទាំងអស់នៃមុខងារអាជីវកម្មបានអនុវត្តគោលការណ៍នេះយ៉ាងខ្ជាប់ខ្ជួនក្នុងប្រតិបត្តិការប្រចាំថ្ងៃរបស់ពួកគេ។

# យុទ្ធសាស្ត្រចីរភាពរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី

ទន្ទឹមនឹងការខិតខំប្រឹងប្រែង ព្យាយាមឱ្យទទួលបាននូវនិរន្តរភាពខ្ពស់នៃប្រាក់ចំណេញ ធនាគារ អេស៊ីលីដា ក៏គោរពឱ្យបានផងដែរចំពោះការការពារបរិស្ថាន ទំនួលខុសត្រូវដល់សង្គម ក៏ដូចជាអភិបាលកិច្ចរឹងមាំ។ ដើម្បីឱ្យសម្រេចបាននូវគោលដៅនេះ ធនាគារបានប្តេជ្ញាខិតខំផ្តល់នូវផលិតផលហិរញ្ញវត្ថុប្រកបដោយចីរភាព ប្រកាន់ខ្ជាប់នូវគោលការណ៍ ក្រមសីលធម៌ល្អបំផុត គោរពដល់សង្គម ច្បាប់ និងកាត់បន្ថយដានបរិស្ថាន ដើម្បីឈានឆ្ពោះទៅរកគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។

## សសរស្តម្ភចីរភាព



### បរិស្ថាន

ធនាគារ ប្តេជ្ញាក្នុងការកាត់បន្ថយផលប៉ះពាល់អវិជ្ជមានដល់បរិស្ថាន និងការប្រែប្រួលអាកាសធាតុ ពីប្រតិបត្តិការរបស់ធនាគារ ដៃគូពាក់ព័ន្ធ សំដៅដើម្បីគាំទ្រ និងសម្រេចឱ្យបាននូវ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។



### សង្គម

ធនាគារ ប្តេជ្ញាលើកកម្ពស់វប្បធម៌ការងាររួម ដែលក្នុងនោះមិនមែនផ្តោតតែទៅលើ ភាគហ៊ុនិក បុគ្គលិក អតិថិជន និងដៃគូអាជីវកម្មប៉ុណ្ណោះទេ ប៉ុន្តែផ្តោតលើសហគមន៍ទាំងមូល។



### អភិបាលកិច្ច

ធនាគារ ប្តេជ្ញាប្រកាន់ខ្ជាប់នូវសុចរិតភាព និងការដោះស្រាយដោយយុត្តិធម៌ ក្នុងសកម្មភាពអាជីវកម្ម ទាំងអស់ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ហើយរក្សាបាននូវស្តង់ដារល្អបំផុត នៃអភិបាលកិច្ចសាជីវកម្ម។

## សកម្មភាពចីរភាព

- កាត់បន្ថយការបំភាយឧស្ម័នកាបូនិក ពីប្រតិបត្តិការអាជីវកម្មរបស់ធនាគារស្របតាមផែនការយុទ្ធសាស្ត្ររយៈពេលវែងរបស់កម្ពុជាក្នុងការសម្រេចឱ្យបាននូវអព្យាក្រឹតភាពកាបូន។
- លើកទឹកចិត្តបុគ្គលិកគ្រប់លំដាប់ថ្នាក់ឱ្យចូលរួមគ្រប់សកម្មភាពដើម្បីកាត់បន្ថយផលប៉ះពាល់ទៅលើបរិស្ថាន និងការប្រែប្រួលអាកាសធាតុ។
- ផ្តល់ការបណ្តុះបណ្តាល និងលើកទឹកចិត្តដល់កម្មករនិយោជិតគ្រប់លំដាប់ថ្នាក់ឱ្យចូលរួមក្នុងសកម្មភាពដែលជួយកាត់បន្ថយផលប៉ះពាល់លើបរិស្ថាន និងការប្រែប្រួលអាកាសធាតុ។

- គោរពសិទ្ធមនុស្ស លើកកម្ពស់ពិពិធកម្ម និង សមភាពយេនឌ័រ ។
- ផ្តល់នូវកន្លែងបំពេញការងារជាមួយនឹងបរិស្ថាន និងអនាម័យ ។
- បែងចែកកំលាំងពលកម្មការងារដោយស្មើភាព ។
- បន្តផ្តល់បរិយាបន្នហិរញ្ញវត្ថុ និងចំណេះដឹងហិរញ្ញវត្ថុដល់គ្រប់មជ្ឈដ្ឋាន ក្នុងសហគមន៍ ។
- ប្រកាន់ខ្ជាប់នូវក្រមសីលធម៌នៃគោលការណ៍ផ្តល់កម្ចី។
- ជៀសវាងសកម្មភាពទាំងឡាយណាដែលអាចនាំឱ្យកើតមានបញ្ហាដល់សង្គម និងបំពានលើច្បាប់កំណត់។

- ប្រកាន់ខ្ជាប់នូវអភិបាលកិច្ចល្អបំផុត ក្នុងប្រតិបត្តិការអាជីវកម្ម ។
- អនុវត្តក្រមប្រតិបត្តិខ្ពស់បំផុត ចំពោះគ្រប់ទម្រង់នៃអំពើពុករលួយ ។
- អាទិភាពការអភិវឌ្ឍកម្មវិធីឌីជីថលដើម្បីបង្កើនភាពងាយស្រួល និងបំពេញតម្រូវការដល់អតិថិជន ក្នុងការគ្រប់គ្រងប្រតិបត្តិការ និងកាត់បន្ថយចំណាយប្រតិបត្តិការ ។
- ការពារទ្រព្យសកម្ម និងឯកជនភាពរបស់អតិថិជន ជាមួយនឹងប្រព័ន្ធបច្ចេកវិទ្យាដ៏ល្អចុងក្រោយ។
- ដាក់បញ្ចូលបញ្ហាបរិស្ថាន សង្គម និងអភិបាលកិច្ចទៅក្នុងប្រតិបត្តិការអាជីវកម្ម។
- តម្លាភាពក្នុងការបង្ហាញព័ត៌មាន ទាំងប្រតិបត្តិការហិរញ្ញវត្ថុ និងចីរភាព។

ធនាគារ ប្តេជ្ញាប្រកាន់ខ្ជាប់នូវគោលការណ៍ហិរញ្ញវត្ថុប្រកបដោយចីរភាពកម្ពុជា ដោយអភិវឌ្ឍន៍ និងបញ្ចូលនូវវិធីសាស្ត្រហិរញ្ញវត្ថុប្រកបដោយចីរភាព ដើម្បីចូលរួមចំណែកក្នុងការអនុវត្តឱ្យបានល្អបំផុតស្របតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិ។ ជាងនេះទៅទៀត ធនាគារ អេស៊ីលីដា ក៏នឹងរៀបចំវគ្គបណ្តុះបណ្តាល និងលើកកម្ពស់ការយល់ដឹងអំពីបញ្ហាបរិស្ថាន សង្គម និងអភិបាលកិច្ចចំពោះភាគីពាក់ព័ន្ធ ដើម្បីគ្រប់គ្រងហានិភ័យ លើកកម្ពស់ការកសាងសមត្ថភាព លើកកម្ពស់ការអនុវត្តប្រព័ន្ធគ្រប់គ្រងបរិស្ថាន និងសង្គម និងធានាផ្តល់ជូននូវផលិតផលហិរញ្ញវត្ថុប្រកបដោយចីរភាព ដើម្បីចូលរួមចំណែកក្នុងការកាត់បន្ថយផលប៉ះពាល់អវិជ្ជមានស្របតាមបទដ្ឋានអន្តរជាតិ ឬស្តង់ដារពាក់ព័ន្ធនានា ។




## គោលការណ៍ហិរញ្ញវត្ថុប្រកបដោយចីរភាពកម្ពុជា

### ការការពារបរិស្ថាន ការពារមនុស្ស និងការអភិរក្សបេតិកភណ្ឌវប្បធម៌របស់យើង

គោលការណ៍ទី១. វាយតម្លៃ និងគ្រប់គ្រងហានិភ័យបរិស្ថាន

គោលការណ៍ទី២. វាយតម្លៃ និងគ្រប់គ្រងហានិភ័យដែលអាចជះឥទ្ធិពលអវិជ្ជមានដល់សង្គម

គោលការណ៍ទី៣. វាយតម្លៃ និងគ្រប់គ្រងហានិភ័យសង្គមដែលអាចជះឥទ្ធិពលអវិជ្ជមានចំពោះបេតិកភណ្ឌវប្បធម៌

### ការផ្តល់ហិរញ្ញប្បទានដើម្បីអនាគតប្រទេសកម្ពុជា

គោលការណ៍ទី៤. លើកកម្ពស់ការយល់ដឹង និងចំណេះដឹងហិរញ្ញវត្ថុ និងការការពារអតិថិជន

គោលការណ៍ទី៥. ពង្រីកវិសាលភាពនៃការទទួលបានសេវាហិរញ្ញវត្ថុ

គោលការណ៍ទី៦. នវានុវត្តន៍ហិរញ្ញប្បទានជាមួយ ហិរញ្ញប្បទានបៃតង

### ការដឹកនាំមាគ៌

គោលការណ៍ទី៧. កសាងសមត្ថភាព និងបង្កើនការយល់ដឹងដល់អតិថិជន និងសហគមន៍ អំពីហិរញ្ញវត្ថុប្រកបដោយចីរភាព

គោលការណ៍ទី៨. ការគ្រប់គ្រងដានបរិស្ថាន និងសង្គម

គោលការណ៍ទី៩. រាយការណ៍ជារៀងរាល់ឆ្នាំនូវវឌ្ឍនភាពនៃការប្តេជ្ញាចិត្ត

សម្គាល់៖

- គោលការណ៍ទាំង៩ចំណុចខាងលើ ដកស្រង់ពីគោលការណ៍ហិរញ្ញវត្ថុប្រកបដោយចីរភាពនៅកម្ពុជា ដែលបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅឆ្នាំ ២០១៩។

# សកម្មភាពស្តីពីការអនុវត្តគោលការណ៍ប្រកបដោយចីរភាព



**២០០០**

- បង្កើតគោលការណ៍ឥណទាន និងបញ្ជីអាជីវកម្មហាមឃាត់

**២០០២**

- បង្ហាញជាសាធារណៈនូវរបាយការណ៍ចីរភាពបរិស្ថាន និងសង្គម នៅក្នុងរបាយការណ៍ប្រចាំឆ្នាំ។

**២០០៥**

- បង្កើត និងដាក់ឱ្យប្រើប្រាស់ជាផ្លូវការគោលការណ៍បរិស្ថាន សង្គម និងសហគមន៍ ។

**២០០៧**

- បង្កើតការិយាល័យទំនាក់ទំនងអតិថជន ដើម្បីទទួល និងដោះស្រាយបញ្ហារបស់អតិថិជន។

**២០១៣**

- បង្កើតគោលការណ៍ប្រតិបត្តិស្តីពីបរិស្ថាន និងសង្គម ព្រមទាំងនីតិវិធី ក្នុងគោលបំណងផ្តល់ជាក្របខណ្ឌនៃគោលការណ៍ណែនាំដល់បុគ្គលិកដែលពាក់ព័ន្ធដើម្បីកំណត់ វាយតម្លៃ និងគ្រប់គ្រងហានិភ័យ បរិស្ថាន និងសង្គមដែលអាចកើតមាន ។

**២០១៧**

- ជាសមាជិកគណៈកម្មាធិការ ហិរញ្ញវត្ថុប្រកបដោយចីរភាព នៃសមាគមធនាគារ នៅកម្ពុជា
- ទទួលបានវិញ្ញាបនបត្រការពារអតិថិជនពី Smart Campaign

**២០១៩**

- ជាធនាគារស្ម័គ្រចិត្តអនុវត្តគោលការណ៍ហិរញ្ញវត្ថុប្រកបដោយចីរភាពកម្ពុជា។

**២០២១**

- ធ្វើបច្ចុប្បន្នភាពគោលការណ៍ បរិស្ថាន សង្គម និងសហគមន៍ទៅជាគោលការណ៍បរិស្ថាន សង្គម និងអភិបាលកិច្ច

**២០២៤**

- បច្ចុប្បន្នភាពរបាយការណ៍ចីរភាពស្របតាមការអនុវត្តស្តង់ដារអន្តរជាតិ ឬស្តង់ដារពាក់ព័ន្ធ
- ប្រកាន់ខ្ជាប់ និងគោរពតាមក្រមប្រតិបត្តិសម្រាប់វិស័យធនាគារ និងហិរញ្ញវត្ថុ

# បរិស្ថាន សង្គម និងអភិបាលកិច្ចសង្ខេប

## ពានរង្វាន់



ទទួលពានរង្វាន់ប្រភេទ **មាស** ជា "**ធនាគារដ៏ល្អបំផុត ក្នុងការផ្តល់ហិរញ្ញប្បទានដល់សហគ្រិនស្ត្រី**" ពី វេទិកាហិរញ្ញប្បទានសហគ្រាសធុនតូច និងមធ្យម (SME Finance Forum) នៅក្នុងកម្មវិធីផ្តល់ពានរង្វាន់ ហិរញ្ញប្បទានសហគ្រាសធុនតូច និងមធ្យមសកលលោក ២០២៣។



ទទួលពានរង្វាន់ជាធនាគារឈានមុខក្នុងតំបន់អាស៊ីក្នុងការផ្តួចផ្តើមបរិយាបន្នហិរញ្ញវត្ថុ។

## ការទទួលស្គាល់







ការរក្សាបាននូវចំណាត់ថ្នាក់នេះសបញ្ជាក់អំពីភាពរឹងមាំនៃប្រតិបត្តិការអាជីវកម្ម និងស្ថិរភាពប្រវត្តិហិរញ្ញវត្ថុរបស់ធនាគារ អេស៊ីលីដា ដោយរក្សាបាននូវការអភិវឌ្ឍប្រកបដោយចីរភាព។




ធនាគារ អេស៊ីលីដា ភីអិលស៊ី ត្រូវបានទទួលស្គាល់ធនាគារ ដែលបានអនុវត្តយ៉ាងពេញលេញតាមស្តង់ដារ និងគោលការណ៍ដ៏រឹងមាំនៃការការពារអតិថិជន។

# អភិបាលកិច្ចប្រកបដោយចីរភាព

ធនាគារ អេស៊ីលីដា ទទួលស្គាល់នូវសារៈសំខាន់ នៃអភិបាលកិច្ចសាជីវកម្ម ក្នុងការគាំទ្រដល់ការរីកចម្រើនប្រកបដោយចីរភាពរបស់ធនាគារ បង្កើនប្រសិទ្ធភាពការងារ បង្កើនតម្លៃភាគហ៊ុនិក និងជំនឿទុកចិត្តដល់ភាគីពាក់ព័ន្ធទាំងអស់ រួមទាំងម្ចាស់ភាគហ៊ុន អតិថិជន កម្មករនិយោជិត ព្រមទាំងសាធារណជន។ ក្រុមប្រឹក្សាភិបាលដឹកនាំការគ្រប់គ្រងហានិភ័យ វប្បធម៌ ការត្រួតពិនិត្យ ដោយការគាំទ្រ និងលើកទឹកចិត្តដល់ការប្រកាន់ភ្ជាប់ និងការអនុវត្តគោលការណ៍អភិបាលកិច្ចល្អ រួមជាមួយនឹងក្រមប្រតិបត្តិ និងក្រមសីលធម៌អាជីវកម្មល្អបំផុត ។ ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវក្នុងការកំណត់យុទ្ធសាស្ត្ររបស់ធនាគារ និងការត្រួតពិនិត្យការប្រតិបត្តិនៃអាជីវកម្ម និងកិច្ចការនានា។ គ្រប់សមាជិកទាំងអស់ ត្រូវធ្វើសកម្មភាពដើម្បីផលប្រយោជន៍ល្អបំផុតរបស់ធនាគារ ដូចដែលបានបង្ហាញឱ្យឃើញពីការទទួលខុសត្រូវរបស់ធនាគារចំពោះបរិស្ថាន សង្គម និងអភិបាលកិច្ច។ លើសពីនេះទៀត រចនាសម្ព័ន្ធ គោលការណ៍ និងការគ្រប់គ្រង ដែលទាក់ទងនឹងការអនុវត្តបរិស្ថាន សង្គម និងអភិបាលកិច្ច ព្រមទាំងហានិភ័យ និងកាលានុវត្តភាពដែលទាក់ទងនឹងអាកាសធាតុ ក៏ត្រូវបានដាក់បញ្ចូលជាផ្នែកមួយនៃដំណើរការនៃប្រតិបត្តិការប្រកបដោយចីរភាពដូចខាងក្រោម៖

## ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល អនុម័តគោលដៅអាជីវកម្មរយៈពេលវែង គោលនយោបាយ និងផ្តល់យុទ្ធសាស្ត្រសម្រាប់ការអនុវត្តប្រតិបត្តិការប្រកបដោយចីរភាពរបស់ធនាគារ។ ក្រុមប្រឹក្សាភិបាលក៏អនុម័តលើគោលនយោបាយ និងក្របខណ្ឌគ្រប់គ្រងហានិភ័យ វិសអាប់ភៃថាយ ក៏ដូចជាការកំណត់ និងពិនិត្យមើលការគ្រប់គ្រង និងតាមដានកត្តាហានិភ័យសារវន្ត វិសាលភាពដែលជាប់ពាក់ព័ន្ធនឹងកាលានុវត្តភាព និងហានិភ័យនានាដែលទាក់ទងនឹងបរិស្ថាន សង្គម និងអភិបាលកិច្ច (ESG) ព្រមទាំងផលប៉ះពាល់នានាដែលបណ្តាលមកពីហានិភ័យដែលទាក់ទងនឹងអាកាសធាតុ។ លើសពីនេះ ក្រុមប្រឹក្សាភិបាលក៏ពិនិត្យ និងអនុម័តលើការបង្ហាញព័ត៌មានដែលពាក់ព័ន្ធនានាផងដែរ។

## គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងព័ត៌មានវិទ្យា

គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងព័ត៌មានវិទ្យា (BRIC) ទទួលខុសត្រូវក្នុងការត្រួតពិនិត្យកម្រងហានិភ័យរបស់ធនាគារ ទៅនឹងវិសអាប់ភៃថាយ ជាពិសេសត្រួតពិនិត្យហានិភ័យជាសារវន្ត ជាមួយនឹងការគិតគូរអំពីបទដ្ឋានប្រកបដោយកម្រិតខ្ពស់ ដែលកំណត់ដោយក្រុមប្រឹក្សាភិបាល ទាក់ទងនឹងបញ្ហា បរិស្ថាន សង្គម និងអភិបាលកិច្ច និងហានិភ័យទាក់ទងនឹងអាកាសធាតុ។ គណៈកម្មាធិការរៀបចំកិច្ចប្រជុំប្រចាំត្រីមាស ដើម្បីពិភាក្សាអំពីហានិភ័យ និងកាលានុវត្តភាពពាក់ព័ន្ធដែលមាននៅក្នុងប្រតិបត្តិការប្រចាំថ្ងៃ។

## គណៈកម្មាធិការប្រតិបត្តិ

គណៈកម្មាធិការប្រតិបត្តិ (EXCO) ផ្តល់អនុសាសន៍ លើគោលដៅ និងយុទ្ធសាស្ត្រសម្រាប់ក្រុមប្រតិបត្តិ ក្នុងការអភិវឌ្ឍអាជីវកម្មរបស់ខ្លួន ដោយគិតគូរពីអត្ថប្រយោជន៍របស់ម្ចាស់ភាគហ៊ុនិក អតិថិជន កម្មករនិយោជិត និងអ្នកពាក់ព័ន្ធផ្សេងទៀត។ ធានានូវការគ្រប់គ្រងការសម្របសម្រួល និងការត្រួតពិនិត្យនៅក្នុងក្រុមប្រតិបត្តិ លើហានិភ័យនានា និងផ្តល់ការអភិវឌ្ឍ ការគ្រប់គ្រងឱ្យបានគ្រប់គ្រាន់នៅក្នុងផ្នែកអាជីវកម្ម។ គណៈកម្មាធិការប្រតិបត្តិ ក៏ពិនិត្យមើលលើការគ្រប់គ្រង និងតាមដានកត្តាហានិភ័យសារវន្តទាក់ទងនឹងបរិស្ថាន សង្គម និងអភិបាលកិច្ចទៅតាមមុខងារអាជីវកម្មនីមួយៗផងដែរ ។

## គណៈកម្មាធិការឥណទានកម្រិតប្រតិបត្តិ

គណៈកម្មាធិការឥណទានកម្រិតប្រតិបត្តិ (MCC) ទទួលខុសត្រូវរួមលើដំណើរការឥណទាន ត្រួតពិនិត្យថាគោលការណ៍ឥណទាន គោលការណ៍ប្រតិបត្តិការឥណទាន នីតិវិធី ឬសេចក្តីណែនាំទាក់ទងនឹងឥណទានត្រូវបានដាក់ឱ្យប្រើប្រាស់ ទាន់សម័យ សមស្របនឹងអាជីវកម្ម និងការអនុវត្តដែលល្អបំផុត។ ត្រួតពិនិត្យគុណភាពសំពៀតឥណទាន និងកំណត់និន្នាការអវិជ្ជមាន ដើម្បីធានាថាសំពៀតឥណទានរបស់ធនាគារត្រូវបានតម្រឹមសមស្របជាមួយនឹងផែនការចីរភាព ស្របតាមគោលដៅផ្តល់ប្រាក់កម្ចី និងការអនុលោមតាមក្របខណ្ឌបទប្បញ្ញត្តិ ព្រមទាំងតាមដានបញ្ហាប្រឈមនានា និងចាត់វិធានការសមស្របក្នុងការដោះស្រាយ។

## ភាគីពាក់ព័ន្ធ

# ភាគីពាក់ព័ន្ធ

### ភាគីពាក់ព័ន្ធរបស់ធនាគាររួមមានភាគហ៊ុនិក ក្រុមប្រឹក្សាភិបាល អតិថិជន សហគមន៍ កម្មករនិយោជិត ដៃគូអាជីវកម្ម/អ្នកផ្គត់ផ្គង់ និងនិយ័តករ។

ធនាគារបានកំណត់អត្តសញ្ញាណភាគីពាក់ព័ន្ធ ផ្អែកទៅតាមទំនាក់ទំនង និងផលប៉ះពាល់ដែលអាចមានចំពោះប្រតិបត្តិការរបស់ខ្លួន ។ ធនាគារជឿជាក់ថា កិច្ចសហប្រតិបត្តិការ និងការមានទំនាក់ទំនងល្អជាមួយដៃគូពាក់ព័ន្ធ ពិតជាមានសារៈសំខាន់បំផុត ក្នុងការបង្កើត រក្សាតម្លៃ និងផលប្រយោជន៍ចំពោះគ្នាទៅវិញទៅមក។ ការចូលរួមរបស់ភាគីពាក់ព័ន្ធក៏ជាកត្តាសំខាន់ក្នុងការវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្ររបស់ធនាគារ។

| ភាគីពាក់ព័ន្ធសំខាន់ៗ | យន្តការទំនាក់ទំនង |
|---|---|
| ភាគហ៊ុនិក | កិច្ចប្រជុំមហាសន្និបាតប្រចាំឆ្នាំ របាយការណ៍ប្រចាំឆ្នាំ របាយការណ៍ចីរភាព គេហទំព័រធនាគារ អេស៊ីលីដា និងប្រព័ន្ធផ្សព្វផ្សាយសង្គម។ |
| ក្រុមប្រឹក្សាភិបាល | កិច្ចប្រជុំពិភាក្សា របាយការណ៍ប្រចាំឆ្នាំ របាយការណ៍ចីរភាព គេហទំព័រធនាគារអេស៊ីលីដា និងប្រព័ន្ធផ្សព្វផ្សាយសង្គម។ |
| កម្មករនិយោជិត | បណ្តាញទំនាក់ទំនងខាងក្នុងធនាគារ រួមមានអ៊ីម៉ែល ការទំនាក់ទំនងតាមវីដេអូ ការសន្ទនាទល់មុខគ្នារវាងអ្នកគ្រប់គ្រង និងក្រុមការងារ ការប្រជុំក្រុមការងារ ការបណ្តុះបណ្តាល និងសិក្ខាសាលា។ |
| អតិថិជន | កិច្ចប្រជុំ (ទាំងផ្លូវការ និងក្រៅផ្លូវការ) ការស្ទង់មតិ គេហទំព័រធនាគារ អេស៊ីលីដា ប្រព័ន្ធផ្សព្វផ្សាយសង្គម ការិយាល័យទំនាក់ទំនងអតិថិជន របាយការណ៍ប្រចាំឆ្នាំ និងរបាយការណ៍ចីរភាព។ |
| ដៃគូអាជីវកម្ម/អ្នកផ្គត់ផ្គង់ | កិច្ចប្រជុំ (ទាំងផ្លូវការ និងក្រៅផ្លូវការ) ការស្ទង់មតិ និងកិច្ចព្រមព្រៀងរួម។ |
| សហគមន៍ | ការចូលរួមដោយផ្ទាល់នៅក្នុងសហគមន៍ដែលយើងប្រតិបត្តិការ តាមរយៈកិច្ចសហការ ភាពជាដៃគូ សកម្មភាពស្ម័គ្រចិត្ត និងសកម្មភាពបរិច្ចាគ។ |
| និយ័តករ | កិច្ចប្រជុំ ពិគ្រោះយោបល់ ការចូលរួម របាយការណ៍ប្រចាំឆ្នាំ។ |

# ការវាយតម្លៃជាសារវន្ត

ការវាយតម្លៃជាសារវន្ត គឺជាមធ្យោបាយមួយដើម្បីកំណត់ និងសម្រិតសម្រាំងបញ្ហាសំខាន់ៗ ទាក់ទងនឹងបរិស្ថាន សង្គម និងអភិបាលកិច្ច (ESG) ដែលអ្នកពាក់ព័ន្ធយកចិត្តទុកដាក់ ក៏ដូចជាអ្វីដែលសំខាន់សម្រាប់អាជីវកម្ម។ ដើម្បីកំណត់នូវកត្តាបរិស្ថាន សង្គម និងអភិបាលកិច្ច ដែលមានសារៈសំខាន់បំផុតសម្រាប់អាជីវកម្ម និងអ្នកពាក់ព័ន្ធរបស់យើង ធនាគារអនុវត្តនូវដំណើរការវាយតម្លៃជាសារវន្តចំពោះបញ្ហាចីរភាព និងបញ្ហាទាក់ទងនឹងអាកាសធាតុ ដោយធ្វើការសិក្សា ប្រមូល វាយតម្លៃ និងរួមបញ្ចូលការវាយតម្លៃក្នុងបរិបទជាតិ និងពិភពលោក ដូចជាបទប្បញ្ញត្តិ ក្របខណ្ឌអន្តរជាតិ សាធារណៈ/ យោបល់អតិថិជន និងគោលនយោបាយផ្ទៃក្នុង។ បន្ទាប់ពីកំណត់ប្រធានបទសំខាន់ៗ មតិភាគីពាក់ព័ន្ធ និងការផ្តល់យោបល់ក៏ត្រូវបានប្រមូលផ្តុំផងដែរ ដើម្បីពិនិត្យពីទំនាក់ទំនង បញ្ហាសំខាន់ៗដែលទាក់ទង និងលទ្ធផលពីក្រុមពាក់ព័ន្ធ និងប្រតិបត្តិការរបស់ធនាគារ។

ជាលទ្ធផល ប្រធានបទជាសារវន្តចំនួន ១២ ត្រូវបានកំណត់ បង្ហាញ និងផ្តល់អាទិភាពដោយផ្អែកលើសារៈសំខាន់ និងឥទ្ធិពលទៅលើប្រតិបត្តិការរបស់សម្ព័ន្ធធនាគារ និងធនាគារ។ អាស្រ័យហេតុនេះ របាយការណ៍នេះពិពណ៌នាអំពីប្រតិបត្តិការរបស់សម្ព័ន្ធធនាគារ និងធនាគារទាក់ទងនឹងបញ្ហាដែលត្រូវបានកំណត់គោលដៅ ដើម្បីឆ្លើយតបទៅនឹងការរំពឹងទុករបស់អ្នកពាក់ព័ន្ធទាក់ទងនឹងបញ្ហាចីរភាព និង អាកាសធាតុ។

ខាងក្រោមនេះគឺជាប្រធានបទជាសារវន្តបានមកពីការកំណត់ វាស់វែង ដែលបានឆ្លុះបញ្ចាំងពីយុទ្ធសាស្ត្រ ទិសដៅ និងអាទិភាពបច្ចុប្បន្នរបស់ធនាគារក្នុងការរួមបញ្ចូល និងការគិតគូរលើបញ្ហាបរិស្ថាន សង្គម និងអភិបាលកិច្ចទៅក្នុងប្រតិបត្តិការអាជីវកម្ម៖



## វិធីសាស្ត្រកំណត់ហានិភ័យសារវន្ត




**១- ការកំណត់អត្តសញ្ញាណ:** ពិនិត្យ និងកំណត់ប្រធានបទសារវន្តដែលអាចប៉ះពាល់ដល់ការអនុវត្តយុទ្ធសាស្ត្ររបស់ធនាគារ។ តាមរយៈការប្រមូលទិន្នន័យ និងរួមបញ្ចូលពីស្តង់ដារជាតិ និងអន្តរជាតិ ប្រធានបទសារវន្តពាក់ព័ន្ធត្រូវបានកំណត់អត្តសញ្ញាណ។ ម្យ៉ាងទៀត គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) របស់អង្គការសហប្រជាជាតិ ក៏ត្រូវបានវាយតម្លៃអំពីសារៈសំខាន់ និងភាពពាក់ព័ន្ធនៃគោលដៅនីមួយៗក្នុងចំណោមគោលដៅទាំង ១៧ ក្នុងកម្រិតគួបសរុប និងស្ថាប័ន។ តាមរយៈការពិនិត្យនេះ កត្តាសារវន្ត និងនិន្នាការដែលពាក់ព័ន្ធទាំងសម្ព័ន្ធធនាគារ និងធនាគារត្រូវបានកំណត់។

**២- ការវិភាគ និងវាយតម្លៃ:** ធ្វើការវិភាគ និងវាយតម្លៃប្រធានបទសារវន្តពាក់ព័ន្ធ ដោយពិចារណាលើព័ត៌មានដែលទទួលបានពីភាគីពាក់ព័ន្ធខាងក្នុង និងខាងក្រៅ ដូចជាភាគហ៊ុនិក អតិថិជន និងកម្មករនិយោជិតតាមរយៈការធ្វើការស្ទង់មតិ ផ្តល់យោបល់ និងកម្រងសំណួរ។

**៣- ការរួមបញ្ចូល:** ប្រធានបទសារវន្ត ដែលអាចប៉ះពាល់ដល់ការបង្កើតតម្លៃ និងយុទ្ធសាស្ត្ររបស់ធនាគារ ត្រូវបានពិនិត្យឡើងវិញដោយថ្នាក់គ្រប់គ្រងជាន់ខ្ពស់ និងផ្នែកដែលទទួលខុសត្រូវ។ លទ្ធផលចុងក្រោយត្រូវបានប្រើប្រាស់ជាព័ត៌មានមូលដ្ឋានសម្រាប់អភិវឌ្ឍន៍ផែនការសកម្មភាពប្រកបដោយនិរន្តរភាព និងរបាយការណ៍ចីរភាពឆ្នាំ២០២៣។

**៤- របាយការណ៍ចីរភាព:** លាតត្រដាងព័ត៌មានដោយស្ម័គ្រចិត្ត ទៅក្នុងរបាយការណ៍ចីរភាព។

## លម្អិតការវាយតម្លៃកត្តាហានិភ័យសារវន្ត

| កត្តាហានិភ័យសារវន្ត | ភាគីពាក់ព័ន្ធ | យុទ្ធសាស្ត្រធនាគារ | ផលប៉ះពាល់ | ការរួមចំណែកដល់ UN SDGs |
|---|---|---|---|---|
| សុវត្ថិភាពទិន្នន័យ និងឯកជនភាពរបស់អតិថិជន | - ភាគហ៊ុនិក<br>- ក្រុមប្រឹក្សាភិបាល<br>- អតិថិជន<br>- កម្មករនិយោជិត<br>- ដៃគូអាជីវកម្ម/អ្នកផ្គត់ផ្គង់<br>- និយ័តករ | - ពង្រឹងសមត្ថភាពផ្ទៃក្នុងលើការការពារទិន្ន័យ និងឯកជនភាពរបស់អតិថិជន។<br>- បង្កើតសេវាកម្មប្រព័ន្ធព័ត៌មានវិទ្យាខ្ពស់បំផុត ចុងក្រោយ ដើម្បីគាំទ្រដល់អាជីវកម្មរបស់ធនាគារ។ | ខ្លី មធ្យម វែង |   |

| | | | | |
|---|---|---|---|---|
| ហានិភ័យនៃការប្រែប្រួលអាកាសធាតុ | - ភាគហ៊ុនិក<br>- កម្មករនិយោជិត<br>- អតិថិជន<br>- ដៃគូអាជីវកម្ម/អ្នកផ្គត់ផ្គង់<br>- និយ័តករ | - កំណត់អត្តសញ្ញាណ និងគ្រប់គ្រងហានិភ័យ និងកាលានុវត្តភាព ដើម្បីឆ្លើយតបទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។<br>- សហការជាមួយភាគីពាក់ព័ន្ធដើម្បីគ្រប់គ្រងហានិភ័យអាកាសធាតុ។<br>- លើកកម្ពស់ការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ។ | ខ្លី មធ្យម វែង | |
| ក្រមសីលធម៌អាជីវកម្ម | - ភាគហ៊ុនិក<br>- កម្មករនិយោជិត<br>- អតិថិជន<br>- ដៃគូអាជីវកម្ម/អ្នកផ្គត់ផ្គង់ | - កសាង និងរក្សានូវវប្បធម៌ក្រមសីលធម៌ សុចរិតភាព តម្លាភាព និងគណនេយ្យភាព។<br>- ហ្វឹកហ្វឺនដើម្បីជៀសវាងការប្រព្រឹត្តខុស។ | ខ្លី មធ្យម វែង | |
| ការអភិវឌ្ឍផលិតផល និងនវានុវត្តន៍ឌីជីថល | - ភាគហ៊ុនិក<br>- កម្មករនិយោជិត<br>- អតិថិជន<br>- ដៃគូអាជីវកម្ម/អ្នកផ្គត់ផ្គង់ | - នវានុវត្តន៍ និងផ្លាស់ប្តូរផលិតផលធនាគារឌីជីថល ដើម្បីបំពេញតម្រូវការរបស់អតិថិជន។ | ខ្លី មធ្យម វែង | |
| ហិរញ្ញប្បទានប្រកបដោយការទទួលខុសត្រូវ និងការរួមបញ្ចូលបរិស្ថាន សង្គម និងអភិបាលកិច្ច | - ភាគហ៊ុនិក<br>- កម្មករនិយោជិត<br>- អតិថិជន<br>- និយ័តករ | - រួមបញ្ចូលបរិស្ថាន សង្គម និងអភិបាលកិច្ច ទៅក្នុងដំណើរការឥណទាន។<br>- ពង្រឹងលើការអនុវត្ត ESMS។<br>- បណ្តុះបណ្តាលបុគ្គលិកដើម្បីកំណត់អត្តសញ្ញាណ និងគាំទ្រលើការអនុវត្តហិរញ្ញវត្ថុប្រកបដោយចីរភាព។ | ខ្លី មធ្យម វែង | |

| | | | | |
|---|---|---|---|---|
| បរិយាបន្នហិរញ្ញវត្ថុ និងចំណេះដឹងហិរញ្ញវត្ថុ | - អតិថិជន<br>- សហគមន៍<br>- និយ័តករ | - បង្កើនភាពងាយស្រួលក្នុងការទទួលបាន និងប្រើប្រាស់ផលិតផល និងសេវាកម្មធនាគារ ដល់សាធារណជនគ្រប់មជ្ឈដ្ឋានក្នុងសហគមន៍។<br>- ផ្ដោតលើទីផ្សារឌីជីថលដោយផ្ដល់ជូននូវធនធានអប់រំដើម្បីបង្កើនការយល់ដឹងអំពីធនាគារឌីជីថល និងផ្ដល់ការលើកទឹកចិត្តដើម្បីបង្កើនបទពិសោធន៍ដល់អតិថិជនជាមួយសេវាកម្ម និងផលិតផលឌីជីថល រក្សាភាពស្មោះត្រង់ និងលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុរបស់ពួកគេ។ | ខ្លី មធ្យម វែង |  |
| ការគ្រប់គ្រងហានិភ័យ | - ភាគហ៊ុនិក<br>- ក្រុមប្រឹក្សាភិបាល<br>- អតិថិជន<br>- កម្មករនិយោជិត<br>- ដៃគូអាជីវកម្ម/អ្នកផ្គត់ផ្គង់<br>- និយ័តករ | - ពង្រឹងសមត្ថភាពផ្ទៃក្នុងដើម្បីកំណត់ និងគ្រប់គ្រងហានិភ័យ។<br>- អភិបាលកិច្ចគ្រប់គ្រងហានិភ័យរឹងមាំ និងតម្លាភាព។ | ខ្លី មធ្យម វែង |  |
| អភិបាលកិច្ចសាជីវកម្ម និងការប្រឆាំងអំពើពុករលួយ | - ភាគហ៊ុនិក<br>- អតិថិជន<br>- កម្មករនិយោជិត<br>- ដៃគូអាជីវកម្ម/អ្នកផ្គត់ផ្គង់ | - រក្សានូវស្តង់ដារល្អបំផុតនៃអភិបាលកិច្ច និងវប្បធម៌ហានិភ័យ។<br>- មិនមានការអត់អោនចំពោះការស៊ីសំណូក និងការប្រព្រឹត្តអំពើពុករលួយ។<br>- គោរពតាមបទប្បញ្ញត្តិធនាគារ ការត្រួតពិនិត្យ និងរាយការណ៍ទាន់ពេល។ | ខ្លី មធ្យម វែង |  |
| ការចូលរួមជាមួយសហគមន៍ និងកិច្ចការសង្គម | - កម្មករនិយោជិត<br>- សហគមន៍ | - លើកទឹកចិត្តឱ្យមានការចូលរួមជាមួយសង្គម និងសហគមន៍តាមរយៈសកម្មភាពស្ម័គ្រចិត្ត។ | ខ្លី មធ្យម វែង |  |

| | | | | |
|---|---|---|---|---|
| ការអនុវត្តសមភាពការងារ | - ភាគហ៊ុនិក<br>- ក្រុមប្រឹក្សាភិបាល<br>- កម្មករនិយោជិត<br>- និយ័តករ | - ធានាឱ្យបានការអនុវត្តដោយយុត្តិធម៌ និងស្មើភាព ដល់គ្រប់កម្មករនិយោជិតទាំងអស់។<br>- ធានាបាននូវឱកាសស្មើៗគ្នាដល់កម្មករនិយោជិតទាំងអស់តាមប្រវត្តិផ្សេងៗគ្នា អាយុ ភេទ។ |  |  |
| ការអភិវឌ្ឍធនធានមនុស្ស | - ភាគហ៊ុនិក<br>- ក្រុមប្រឹក្សាភិបាល<br>- កម្មករនិយោជិត | - ពង្រឹងសមត្ថភាពតាមរយៈការបណ្តុះបណ្តាល និងអភិវឌ្ឍន៍វិជ្ជាជីវៈ។<br>- អភិវឌ្ឍន៍ដោយផ្តល់នូវជំនាញថ្មី ឬបំពាក់បំប៉នលើជំនាញដែលមានស្រាប់។ |  |  |
| សុវត្ថិភាព និងបរិយាកាសការងារ | - ភាគហ៊ុនិក<br>- ក្រុមប្រឹក្សាភិបាល<br>- កម្មករនិយោជិត<br>- និយ័តករ | - ធានាបាននូវទីកន្លែងបំពេញការងារ និងបរិស្ថានជុំវិញប្រកបដោយសុវត្ថិភាព និងសុខុមាលភាពដល់គ្រប់កម្មករនិយោជិតទាំងអស់។ |  |  |

ធនាគារ អេស៊ីលីដា ដំណើរការអាជីវកម្មប្រកបដោយចីរភាព ដោយកាត់បន្ថយភាពផលប៉ះពាល់អវិជ្ជមានទៅលើបរិស្ថាន តាមរយៈការធ្វើឱ្យប្រសើរឡើងនូវការអនុវត្តក្របខណ្ឌ និងគោលការណ៍ណែនាំដែលពាក់ព័ន្ធ ។

# ទិដ្ឋភាពបរិស្ថាន











ការចូលរួមចំណែក UN SDGs

# ហានិភ័យនៃការប្រែប្រួលអាកាសធាតុ

បញ្ហាបម្រែបម្រួលអាកាសធាតុ បានបង្កើនការព្រួយបារម្ភដល់សហគមន៍ទូទាំងពិភពលោក រួមទាំងប្រទេសកម្ពុជា ដោយសារផលប៉ះពាល់ដោយផ្ទាល់ទៅលើការអភិវឌ្ឍសេដ្ឋកិច្ច អាជីវកម្ម ប្រព័ន្ធអេកូឡូស៊ី ប្រព័ន្ធជីវចម្រុះ និងសុខភាពមនុស្ស។ ប្រទេសជាច្រើនក្នុងពិភពលោកបានលើកឡើងពីបញ្ហានេះ ហើយស្វែងរកដោះស្រាយតាមរយៈការដាក់ចេញគោលនយោបាយ និងដំណើរការរបស់ស្ថាប័ននីមួយៗ ស្របពេលដែលការប្រែប្រួលអាកាសធាតុក៏ជាបញ្ហាដែលអង្គការសហប្រជាជាតិបាននិងកំពុងស្វែងរកការដោះស្រាយតាមរយៈគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។

ធនាគារ យល់ច្បាស់ពីតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន ក្នុងការការពារ និងធ្វើឱ្យប្រសើរឡើងនូវភពផែនដីមានភាពស្រស់បំព្រងហើយបានទទួលស្គាល់ថា ហានិភ័យនៃការប្រែប្រួលអាកាសធាតុអាចបង្កផលប៉ះពាល់ដោយផ្ទាល់ និងដោយប្រយោលដល់ប្រតិបត្តិការធុរកិច្ចរបស់ធនាគារ និងសេដ្ឋកិច្ចប្រទេសជាតិទាំងមូល ។ ក្នុងនាមជាធនាគារដែលមានទំនួលខុសត្រូវខ្ពស់ និងបានគិតគូរពីបញ្ហាបរិស្ថាន សង្គម និងអភិបាលកិច្ច ធនាគារ អេស៊ីលីដា បាន និងកំពុងអភិវឌ្ឍន៍ជានិច្ចនូវសូចនាករសម្រាប់វាស់វែង និងរាយការណ៍អំពីការអនុវត្ត និងផលប៉ះពាល់ចំពោះសង្គម និងបរិស្ថាន។

## វិធីសាស្ត្រគ្រប់គ្រង




- បញ្ជីអាជីវកម្មហាមឃាត់របស់ធនាគារ អេស៊ីលីដា មានសារៈសំខាន់ក្នុងការវាយតម្លៃនូវផលប៉ះពាល់ពីសកម្មភាពអាជីវកម្មរបស់អតិថិជន ទៅលើបរិស្ថាន ។
- ផ្ដល់ការលើកទឹកចិត្តដល់អាជីវកម្មបៃតង ដោយផ្ដល់ប្រាក់កម្ចី ឬហិរញ្ញប្បទាន គឺជាផ្នែកមួយនៃការលើកកម្ពស់ហិរញ្ញវត្ថុប្រកបដោយចីរភាព ក៏ដូចជាការរួមចំណែកក្នុងការគ្រប់គ្រងបម្រែបម្រួលអាកាសធាតុ។
- ធនាគារ អេស៊ីលីដា បានដាក់ចេញនូវគោលការណ៍ស្ដីពីបរិស្ថាន សង្គម និងអភិបាលកិច្ច គោលការណ៍ណែនាំ និងនីតិវិធីស្ដីពីបរិស្ថាន និងសង្គម ជាក្របខណ្ឌ និងគោលការណ៍ណែនាំសម្រាប់ប្រតិបត្តិការប្រកបដោយចីរភាព ដូច្នេះផលប៉ះពាល់របស់ធនាគារទៅលើបរិស្ថាន សង្គម និងអភិបាលកិច្ចដែលប្រតិបត្តិការត្រូវបានគ្រប់គ្រងប្រកបដោយការទទួលខុសត្រូវខ្ពស់។



- កាត់បន្ថយដានបរិស្ថាន ដោយការលើកកម្ពស់ដំណើរការអនុវត្តការងារ និងប្រតិបត្តិការដែលអាចកាត់បន្ថយនូវការបំភាយឧស្ម័នកាបូនិក ដូចជាការធ្វើឌីជីថលនីយកម្ម ដែលប្រើប្រាស់ធនធានតិច និងបន្សល់ទុកដានបរិស្ថានតិចជាងមុន មានដូចជាកិច្ចប្រជុំតាមរយៈវីដេអូ ការអនុម័តឌីជីថល និងការបំពាក់នូវឧបករណ៍ចាប់សញ្ញាជាដើម។
- ក្លាយជាសមាជិកនៃគណៈកម្មាធិការហិរញ្ញវត្ថុប្រកបដោយចីរភាព នៃសមាគមធនាគារ នៅកម្ពុជា និងជាធនាគារស្ម័គ្រចិត្តអនុវត្តតាមគោលការណ៍ហិរញ្ញវត្ថុប្រកបដោយចីរភាពនៅកម្ពុជា ។
- រួមបញ្ចូលគោលការណ៍ហិរញ្ញវត្ថុប្រកបដោយចីរភាពនៅកម្ពុជា និងគោលការណ៍ណែនាំសម្រាប់ការអនុវត្ត ទៅក្នុងវិធីសាស្ត្រ ការអនុវត្ត និងដំណើរការនៃការសម្រេចចិត្ត ។




- លើកទឹកចិត្តគ្រប់កម្មករនិយោជិតទាំងអស់ចូលរួមក្នុងការអនុវត្តតាមគោលការណ៍ (5R) តាមការណែនាំរបស់ក្រសួងបរិស្ថាន សំដៅបង្កើនប្រសិទ្ធភាពក្នុងការកាត់បន្ថយការបំពុលតាមរយៈការកាត់បន្ថយប្រើប្រាស់ប្លាស្ទិក។
- បង្កើនការយល់ដឹងអំពីការប្រើប្រាស់អគ្គិសនីដោយសន្សំសំចៃ ដូចជាការបើក និងបិទភ្លើង ម៉ាស៊ីនត្រជាក់ និងឧបករណ៍អគ្គិសនីផ្សេងទៀតស្របតាមពេលប្រតិបត្តិការជាក់ស្តែង ។
- ការលើកទឹកចិត្តឱ្យប្រើប្រាស់ប្រភពថាមពលកកើតឡើងវិញ និងមិនប៉ះពាល់ដល់បរិស្ថាន។
- ការកំណត់សូចនាករបរិស្ថាន សម្រាប់វាស់វែង និងដើម្បីតាមដានការអនុវត្ត និងផលប៉ះពាល់ដល់បរិស្ថាន។
- ដាក់ចេញនូវប្រព័ន្ធគ្រប់គ្រងបរិស្ថាន និងសង្គម (ESMS) និងរចនាសម្ព័ន្ធអភិបាលកិច្ច គោលការណ៍ណែនាំ គោលការណ៍ប្រតិបត្តិ នីតិវិធី និងធនធានដែលមានសមត្ថភាព ដើម្បីគ្រប់គ្រង តាមដាន និងដោះស្រាយហានិភ័យបរិស្ថាន ដែលបង្កឱ្យមានផលប៉ះពាល់ដល់គម្រោង/ផែនការអាជីវកម្មដែលបានផ្តល់ហិរញ្ញប្បទានដោយធនាគារ ។

## ការវាយតម្លៃហានិភ័យទាក់ទងនឹងអាកាសធាតុ

ធនាគារធ្វើការវាយតម្លៃហានិភ័យទាក់ទងនឹងអាកាសធាតុ ដើម្បីកំណត់ពីហានិភ័យខាងក្រៅ ខាងក្នុង និងកាលានុវត្តភាពដែលអាចមានឥទ្ធិពលលើការគ្រប់គ្រង ព្រមទាំងឆ្លុះបញ្ចាំងពីលទ្ធផលនៅក្នុងប្រតិបត្តិការអាជីវកម្មរបស់ធនាគារផងដែរ។ ការវាយតម្លៃនេះមិនត្រឹមតែអនុវត្តចំពោះផលប៉ះពាល់ទាក់ទងនឹងកត្តាចីរភាព និងកត្តាទាក់ទងនឹងអាកាសធាតុរបស់ធនាគារប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផលប៉ះពាល់ដែលប្រតិបត្តិការអាជីវកម្មរបស់ធនាគារអាចមានចំពោះសេដ្ឋកិច្ច សង្គម និងបរិស្ថានផងដែរ។

### ការកំណត់អត្តសញ្ញាណហានិភ័យ និងឱកាសទាក់ទងនឹងអាកាសធាតុ

ហានិភ័យនៃការផ្លាស់ប្តូរ (Transition Risk) គឺជាហានិភ័យដែលកើតចេញពីដំណើរការនៃការផ្លាស់ប្តូរឆ្ពោះទៅរកសេដ្ឋកិច្ចដែលមានកាបូនទាប រួមមានហានិភ័យគោលនយោបាយ និងច្បាប់ បច្ចេកវិទ្យា ទីផ្សារ និងហានិភ័យកេរ្តិ៍ឈ្មោះដែលអាចបណ្តាលឱ្យមានផលប៉ះពាល់ទាំងផ្នែកហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ។

ហានិភ័យរូបវន្ត (Physical Risk) គឺជាហានិភ័យដែលកើតចេញពីការប្រែប្រួលអាកាសធាតុ វាអាចមានលក្ខណៈស្រួចស្រាវ (បណ្តាលមកពីហេតុការណ៍ដូចជាទឹកជំនន់ ឬខ្យល់ព្យុះ) ឬរ៉ាំរ៉ៃ (ដែលកើតឡើងពីការផ្លាស់ប្តូរគន្លងអាកាសធាតុរយៈពេលវែង) ដែលអាចបណ្តាលឱ្យមានការកើនឡើង ហានិភ័យហិរញ្ញវត្ថុ រួមទាំងការខូចខាតទ្រព្យសម្បត្តិ ការរំខានប្រតិបត្តិការ និងខ្សែច្រវ៉ាក់នៃការផ្គត់ផ្គង់។



# ហានិភ័យទាក់ទងនឹងអាកាសធាតុ

| | ហានិភ័យទាក់ទងនឹងអាកាសធាតុ | ប្រភេទហានិភ័យ | ផលប៉ះពាល់អាជីវកម្ម |
|---|---|---|---|
| **ហានិភ័យនៃការផ្លាស់ប្តូរ** (Transition Risk) | ហានិភ័យទាក់ទងនឹងគោលការណ៍ និងច្បាប់ | - មិនអនុលោមតាមច្បាប់ ឬបទប្បញ្ញត្តិ<br>- ពង្រឹងកាតព្វកិច្ចរាយការណ៍ប្រកបដោយចីរភាព<br>- ការប្រឈមនឹងវិវាទ | - បង្កើនថ្លៃដើមប្រតិបត្តិការដោយប្រយោល។ |
| | ហានិភ័យទាក់ទងនឹងទីផ្សារ | - ការផ្លាស់ប្តូរឥរិយាបថអតិថិជនដែលបណ្តាលឱ្យមានការផ្លាស់ប្តូរតម្រូវការ និងការផ្គត់ផ្គង់<br>- អតិថិជនយកចិត្តទុកដាក់លើបញ្ហាបរិស្ថាន និងកំដៅផែនដី ដែលជាកត្តាមួយទៀតក្នុងការសម្រេចចិត្តទិញរបស់ពួកគេ | - កាត់បន្ថយតម្លៃនៃទ្រព្យសកម្ម ឬ អាយុកាលប្រើប្រាស់<br>- បង្កផលប៉ះពាល់ដល់ការលក់  ឬមិនអាចបង្កើនទំនោរនៃការលក់ និងអាចបង្កឱ្យមានបញ្ហាទៅលើការគ្រប់គ្រងហិរញ្ញវត្ថុ |
| | ហានិភ័យទាក់ទងនឹងបច្ចេកវិទ្យា | - ការវិវត្តបច្ចេកវិទ្យា ផ្លាស់ប្តូរឈានទៅរកការបំភាយឧស្ម័នផ្ទះកញ្ចក់នៅកម្រិតទាប<br>- មិនបានវិនិយោគទៅលើបច្ចេកវិទ្យាថ្មីៗ<br>- ចំណាយខ្ពស់ក្នុងការផ្លាស់ប្តូរទៅរកបច្ចេកវិទ្យាដើម្បីកាត់បន្ថយការបំភាយឧស្ម័នឱ្យនៅកម្រិតទាប | - ការបង្កើនការចំណាយក្នុងការរៀបចំដំណើរការអនុវត្តនូវគម្រោងថ្មីៗ<br>- តម្រូវការថវិកាបន្ថែមសម្រាប់ការស្រាវជ្រាវ និងអភិវឌ្ឍន៍ |
| | ហានិភ័យទាក់ទងនឹងកេរ្តិ៍ឈ្មោះ | - ការផ្លាស់ប្តូរទំនោររបស់អតិថិជន<br>- បង្កើនការយកចិត្តទុកដាក់ ឬយោបល់អវិជ្ជមាន ពីភាគីដែលពាក់ព័ន្ធ | - បាត់បង់ទំនុកចិត្តពីភាគីដែលពាក់ព័ន្ធ<br>- កាត់បន្ថយលទ្ធភាពនៃដើមទុន |
| **ហានិភ័យរូបវន្ត** (Physical Risk) | លក្ខណៈស្រួចស្រាល់ | - ការកើនឡើងខ្លាំងនូវព្រឹត្តិការណ៍ធាតុអាកាសធ្ងន់ធ្ងរ ដូចជាភាពរាំងស្ងួត និងទឹកជំនន់ដែលអាចមានទំនោរកើតឡើងញឹកញាប់ និងបង្កជាផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ | - បង្កើនហានិភ័យឥណទាន<br>- បង្កផលប៉ះពាល់ដោយផ្ទាល់ដល់  ទ្រព្យសកម្ម ហិរញ្ញវត្ថុ ប្រាក់ចំណូល និងកេរ្តិ៍ឈ្មោះ<br>- ការរំខានដល់ប្រតិបត្តិការអាជីវកម្ម<br>- បង្កើនការចំណាយទៅលើការការពារ និងស្តារឡើងវិញពីផលប៉ះពាល់នៃគ្រោះធម្មជាតិ |

| | | | |
|---|---|---|---|
| | លក្ខណៈរ៉ាំរ៉ៃ | - ការផ្លាស់ប្តូរលំនាំទឹកភ្លៀង និងធាតុអាកាស<br>- ការកើនឡើងសីតុណ្ហភាព<br>- ការកើនឡើងកម្រិតនីវ៉ូទឹកសមុទ្រ | - បង្កើនហានិភ័យឥណទាន<br>- បង្កផលប៉ះពាល់ដោយផ្ទាល់ដល់ទ្រព្យសកម្ម ហិរញ្ញវត្ថុ ប្រាក់ចំណូល និងកេរ្តិ៍ឈ្មោះ<br>- ធ្លាក់ចុះប្រាក់ចំណូលពីការលក់ / ផលិតផលទាប<br>- ការលុបចេញពីបញ្ជី និងការចូលនិវត្តន៍មុនកាលកំណត់នៃទ្រព្យសកម្មដែលមាន (ឧ. ខូចខាតទ្រព្យសម្បត្តិ) |

## កាលានុវត្តភាពទាក់ទងនឹងអាកាសធាតុ

| កាលានុវត្តភាពទាក់ទងនឹងអាកាសធាតុ | ប្រភេទនៃកាលានុវត្តភាព | កាលានុវត្តភាពចំពោះអាជីវកម្ម |
|---|---|---|
| ប្រសិទ្ធភាពថាមពល | - បង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ថាមពល ដូចជាការកែច្នៃទឹកដើម្បីប្រើប្រាស់ឡើងវិញ និងឧបករណ៍សន្សំសំចៃថាមពល<br>- ពង្រីកការសាងសង់អគារបៃតង | - កាត់បន្ថយថ្លៃប្រតិបត្តិការតាមរយៈការបង្កើនប្រសិទ្ធភាពថាមពល និងកាត់បន្ថយការបំភាយ ឧស្ម័នផ្ទះកញ្ចក់<br>- លើកកម្ពស់ជីវភាពរស់នៅរបស់កម្មករនិយោជិត |
| ធនធានថាមពល | - បង្កើនការប្រើប្រាស់ប្រភពថាមពលបៃតង (ថាមពលកកើតឡើងវិញ)<br>- ពង្រីកបច្ចេកវិទ្យា ដែលបំភាយកាបូនទាប | |
| ផលិតផល និងសេវាកម្ម | - ការកើនឡើងទំនោររបស់អតិថិជនចំពោះផលិតផលបៃតង<br>- ការអភិវឌ្ឍផលិតផល និងសេវាកម្មហិរញ្ញវត្ថុបៃតង<br>- ការអភិវឌ្ឍផលិតផលដែលអាចកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ | - បង្កើតប្រាក់ចំណូលពីផលិតផល និងសេវាកម្មហិរញ្ញវត្ថុ ដើម្បីគាំទ្រដល់អាជីវកម្មដែលមិនប៉ះពាល់ដល់បរិស្ថាន<br>- ការពង្រីកឱកាសអាជីវកម្ម |
| ទីផ្សារ | - ការធ្វើពិពិធកម្មអាជីវកម្ម<br>- ការបង្កើតទីផ្សារថ្មីជាមួយនឹងផលិតផល និងសេវាកម្មដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ | |

| | | |
|---|---|---|
| ភាពធន់ទ្រាំ | - ការលើកកម្ពស់ប្រសិទ្ធភាពនៃការប្រើប្រាស់និងការធ្វើពិពិធកម្មធនធាន<br>- ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ | - ត្រួតពិនិត្យយុទ្ធសាស្ត្រអាជីវកម្មដោយផ្តោតលើការគ្រប់គ្រងបរិស្ថាន និងលក្ខខណ្ឌអាកាសធាតុ<br>- ការវិភាគអំពីបញ្ហាទាក់ទងនឹងកត្តាចីរភាព អាកាសធាតុ និងកាលានុវត្តភាពអាជីវកម្ម |

## ការវិភាគហានិភ័យអាកាសធាតុ

ការប្រែប្រួលអាកាសធាតុអាចបង្កហានិភ័យដល់ស្ថិរភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប៉ុន្តែក៏អាចផ្តល់កាលានុវត្តភាពសម្រាប់កំណើនទៅមុខផងដែរ។ ការវិភាគអំពីហានិភ័យអាកាសធាតុជួយឱ្យធនាគារយល់កាន់តែច្បាស់អំពីហានិភ័យ និងឱកាសដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ ។ លទ្ធផលនៃការវិភាគទាំងនេះ នឹងជួយក្នុងការអភិវឌ្ឍវិធានការក្នុងការទប់ស្កាត់ ឬកែតម្រូវ ដែលនឹងអាចជួយធនាគារក្នុងការដោះស្រាយហានិភ័យដែលបង្កឡើងពីហានិភ័យដែលទាក់ទងនឹងអាកាសធាតុទាំងនេះ។




- **រយៈពេលខ្លី (ពី ០ ទៅ ៥ឆ្នាំ)៖** ហានិភ័យចម្បងទាក់ទងនឹងហានិភ័យនៃការផ្លាស់ប្តូរ មានដូចជាការផ្លាស់ប្តូរច្បាប់ និងបទប្បញ្ញត្តិ ការផ្លាស់ប្តូរបច្ចេកវិទ្យា ជាដើម។ ជាឧទាហរណ៍ សមត្ថភាពរបស់ធនាគារ និងអតិថិជនក្នុងការសម្រេចបាននូវការផ្លាស់ប្តូរទៅសេដ្ឋកិច្ចដែលមានកាបូនទាប។ ធនាគារ អេស៊ីលីដា មើលឃើញឱកាសដែលអាចជួយដល់អតិថិជន តាមរយៈការផ្តល់ហិរញ្ញប្បទានដល់ពួកគេ និងបង្កើនការផ្តល់ហិរញ្ញប្បទានរបស់យើងដើម្បីឈានឆ្ពោះទៅរកឧស្សាហកម្មបៃតង (ឧទាហរណ៍ ថាមពលកកើតឡើងវិញ)។
- **រយៈពេលមធ្យម (ពី ៥ ទៅ ១៥ ឆ្នាំ)៖** ហានិភ័យដែលនាំមកដោយការផ្លាស់ប្តូរជាមូលដ្ឋាននៃគំរូអាជីវកម្ម ការលេចឡើងនៃបច្ចេកវិទ្យាថ្មីៗ និងការបន្តធ្វើឱ្យទាន់សម័យបទប្បញ្ញត្តិទាក់ទងនឹងអាកាសធាតុ ។ បញ្ហាប្រឈមនឹងត្រូវបានបង្ហាញដោយហានិភ័យរូបវន្ត និងហានិភ័យនៃការផ្លាស់ប្តូរ។ ហានិភ័យផ្នែកបច្ចេកវិទ្យាអាចកើតឡើងឆាប់រហ័ស ប្រសិនបើនវានុវត្តន៍នៃប្រសិទ្ធភាពថាមពលរបស់ធនាគារមិនមានការអភិវឌ្ឍនោះទេ។
- **រយៈពេលវែង (លើសពី 15 ឆ្នាំ)៖** ហានិភ័យរូបវន្ត ជាបញ្ហាប្រឈមចម្បងមួយ ដោយសារតែផលប៉ះពាល់របស់វាទៅលើគំរូអាជីវកម្ម និងខ្សែច្រវ៉ាក់នៃការផ្គត់ផ្គង់របស់អតិថិជន និងធ្វើឱ្យប៉ះពាល់ទៅដល់សមត្ថភាពក្នុងការកាត់បន្ថយហានិភ័យ និងប៉ះពាល់ធ្ងន់ធ្ងរនៃសមត្ថភាពនៃការទូទាត់សង។ មានការវិភាគរយៈពេលវែងជាច្រើនបានបង្ហាញពីការខាតបង់ជាច្រើនដែលបណ្តាលមកពីការផ្លាស់ប្តូរអាកាសធាតុមិនស្មើគ្នាដូចជាទឹកជំនន់ ភាពរាំងស្ងួត រលកកម្ដៅជាដើម ខណៈពេលដែលវាក៏បាននាំមកនូវផលប៉ះពាល់យ៉ាងខ្លាំងដល់អតិថិជន និងអាជីវកម្មរបស់ធនាគារ។ ជាឧទាហរណ៍ ការប្រែប្រួលអាកាសធាតុនឹងជះឥទ្ធិពលដល់ការផលិតស្បៀង តាមរយៈផល

ប៉ះពាល់ដោយផ្ទាល់ និងដោយប្រយោលលើដំណើរការលូតលាស់របស់ផលដំណាំ ខណៈដែលត្រូវបានគេរំពឹងថានឹងធ្វើឱ្យខូចខាតដល់ទិន្នផលដំណាំសំខាន់ៗ។ ទន្ទឹមនឹងនេះ វានឹងជះឥទ្ធិពលដល់ធនាគារតាមរយៈការកើនឡើងនៃថ្លៃដើមប្រតិបត្តិការ ហានិភ័យឥណទាន និងការរំខានប្រតិបត្តិការអាជីវកម្មជាដើម។

## ការគ្រប់គ្រងហានិភ័យអាកាសធាតុ

ការគ្រប់គ្រងហានិភ័យអាកាសធាតុ គឺជាធាតុផ្សំសំខាន់នៃការឆ្លើយតបជារួមរបស់យើងចំពោះការប្រែប្រួលអាកាសធាតុ។ ធនាគារបានពិចារណាលើទិដ្ឋភាពហានិភ័យទាក់ទងនឹងអាកាសធាតុនៅក្នុងការវិភាគ ដូចជាការកើនឡើងនៃសីតុណ្ហភាពសកល គ្រោះរាំងស្ងួត ទឹកជំនន់ និងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុដែលនឹងអាចប៉ះពាល់ដល់សំពៀតឥណទាន។ ធនាគារ បានចូលរួមអនុវត្តយ៉ាងពេញលេញ ស្របតាមសន្ធិសញ្ញាអន្តរជាតិ ដែលហាមឃាត់លើការផ្តល់ឥណទាន ឬគាំទ្រចំពោះសកម្មភាពផ្សេងៗ ដែលធ្វើឱ្យប៉ះពាល់ដល់បរិស្ថាន ទាំងសកម្មភាពដែលប្រាសចាកពីសីលធម៌ ឬសកម្មភាពដែលធ្វើឱ្យមានការអន្តរាយចំពោះសិទ្ធិមនុស្ស ។ លើសពីនេះ ធនាគារក៏បានគិតគូរ និងចាត់វិធានការបង្ការ ឬការកែតម្រូវដើម្បីកាត់បន្ថយហានិភ័យទាំងនេះ ដោយរួមបញ្ចូលក្របខណ្ឌហានិភ័យបរិស្ថាន សង្គម និងអភិបាលកិច្ច និងគោលការណ៍ផ្សេងទៀត នៅក្នុងប្រតិបត្តិការអាជីវកម្ម ជាពិសេសក្នុងការវាយតម្លៃឥណទាន ដើម្បីធានាថាធនាគារបានរៀបចំនូវយុទ្ធសាស្ត្រចាំបាច់ និងផែនការកាត់បន្ថយ ដើម្បីគ្រប់គ្រងហានិភ័យដែលទាក់ទងនឹងបរិស្ថាន និងអាកាសធាតុ។

### ប្រព័ន្ធគ្រប់គ្រងបរិស្ថាន និងសង្គម

១- តួនាទី និងការទទួលខុសត្រូវ៖ ការបែងចែកតួនាទី និងការទទួលខុសត្រូវមានដូចជា ភ្នាក់ងារឥណទាន ផ្នែកបរិស្ថាន អ្នកសម្របសម្រួលបរិស្ថាន និងសង្គម អ្នកគ្រប់គ្រងបរិស្ថាន និងសង្គម ។

២- កម្ចីទាំងអស់ត្រូវបានត្រួតពិនិត្យ ដើម្បីធានាថារាល់សកម្មភាពអាជីវកម្ម អនុលោមតាមបញ្ជីអាជីវកម្មដែលត្រូវហាមឃាត់របស់ធនាគារ គោលការណ៍ប្រតិបត្តិស្តីពីបរិស្ថាន និងសង្គម រួមទាំងស្តង់ដានៃការអនុវត្តបរិស្ថាន និងសង្គមរបស់ធនាគារ អេស៊ីលីដា និងតម្រូវការផ្សេងៗទៀត។

៣- ក្រុមការងារបរិស្ថាន និងសង្គម៖ ក្នុងករណីកម្ចីដែលមានទំហំធំ ក្រុមការងារបរិស្ថាន និងសង្គម ដោយមានការគាំទ្រពីអ្នកសម្របសម្រួលបរិស្ថាន និងសង្គម នឹងធ្វើការត្រួតពិនិត្យ និងផ្តល់អនុសាសន៍ដល់អ្នកគ្រប់គ្រងបរិស្ថាន និងសង្គម បន្ទាប់មកអ្នកគ្រប់គ្រងបរិស្ថាន និងសង្គម នឹងផ្តល់អនុសាសន៍ដល់គណៈកម្មាធិការឥណទានកម្រិតប្រតិបត្តិ សម្រាប់ការសម្រេចចិត្តចុងក្រោយ។

### ការវាយតម្លៃឥណទាន

១- រាល់កម្ចីទាំងអស់ត្រូវបានវាយតម្លៃ និងរៀបចំដោយភ្នាក់ងារឥណទាន។

២- ភ្នាក់ងារវិភាគឥណទានបានធ្វើការផ្ទៀងផ្ទាត់/ត្រួតពិនិត្យដោយឯករាជ្យ និង/ឬធ្វើការវិភាគដាច់ដោយឡែក បន្ទាប់មកផ្តល់អនុសាសន៍ដល់សមត្ថកិច្ចអនុម័តឥណទានដើម្បីធ្វើការសម្រេចចិត្ត ។

៣- សមត្ថកិច្ចអនុម័ត៖ ពិនិត្យ និងធ្វើការសម្រេចចិត្តចុងក្រោយ។

### សិទ្ធអនុម័ត

ផ្ទេរិមជ្ឈការ/ការផ្ទេរសិទ្ធិអំណាចទៅកម្រិតថ្នាក់គ្រប់គ្រងដោយផ្អែកលើបទពិសោធន៍ ការអនុវត្ត និងទំហំប្រាក់កម្ចី។

### លក្ខណៈនៃគម្រោងបៃតងរបស់ធនាគារ អេស៊ីលីដា

| លក្ខណៈនៃគម្រោងបៃតង | |
|---|---|
| ថាមពលកកើតឡើងវិញ | ផ្តល់ហិរញ្ញប្បទានដល់ការអភិវឌ្ឍ ការសាងសង់ និងប្រតិបត្តិការដែលគាំទ្រដល់ការបង្កើតថាមពលកកើតឡើងវិញ រួមមាន (i) ថាមពលពន្លឺព្រះអាទិត្យ រួមទាំងគម្រោងថាមពលពន្លឺព្រះអាទិត្យប្រមូលផ្តុំ (CSP) និងគម្រោង Photovoltaic (PV) (ii) ថាមពលខ្យល់ (iii) ថាមពលជីវម៉ាស ដែលសំណល់បានមកពីកាកសំណល់សត្វពាហនៈ (iv) កាកសំណល់ទៅជាថាមពល ដែលភាគច្រើននៃវត្ថុដែលអាចកែច្នៃឡើងវិញបានត្រូវបានបែងចែកជាផ្នែកមុនពេលការបំប្លែងថាមពល ពោលគឺការការពារ និងការកែច្នៃកាកសំណល់ (v) វារីអគ្គិសនី និង (vi) ការផ្ទុកថាមពល។ |
| អគារបៃតង | ផ្តល់ហិរញ្ញប្បទានដល់ការទិញ ការអភិវឌ្ឍ និងការសាងសង់អចលនទ្រព្យលំនៅដ្ឋាន និងពាណិជ្ជកម្ម និងដឹកជញ្ជូន ឬការជួសជុល/ជួសជុលអគារដែលមានស្រាប់ដែលបញ្ជាក់ដោយភាគីទីបីថាជាអគារបៃតង គម្រោងវិញ្ញាបនបត្រដែលមានសិទ្ធិសម្រាប់ការបែងចែកប្រាក់ចំណូលរួមមាន LEED (មាស ឬខ្ពស់ជាងនេះ) BREEAM (ល្អឥតខ្ចោះ ឬខ្ពស់ជាងនេះ) និង EDGE (បញ្ជាក់ EDGE ឬខ្ពស់ជាងនេះ) ។ |
| ប្រសិទ្ធភាពថាមពល | ផ្តល់ហិរញ្ញប្បទានដល់ការដំឡើង ប្រតិបត្តិការ និងសេវាកម្មគាំទ្រដល់ឧបករណ៍អភិរក្សថាមពល រួមទាំង ប៉ុន្តែមិនកំណត់ចំពោះអំពូល LED ប្រសិទ្ធភាព HVAC (កំដៅ ខ្យល់ និងម៉ាស៊ីនត្រជាក់) អ៊ីសូឡង់អគារ និងប្រព័ន្ធគ្រប់គ្រងតម្រូវការថាមពល ដែលបង្កើនប្រសិទ្ធភាពថាមពល។ |
| ការដឹកជញ្ជូនស្អាត | ផ្តល់ហិរញ្ញប្បទានដល់យានជំនិះថាមពលស្អាត ក៏ដូចជាមធ្យោបាយដឹកជញ្ជូនសាធារណៈរួមមាន យានជំនិះអគ្គិសនី ឬរថយន្តកូនកាត់ (ម៉ូតូ កង់បី រថយន្ត) ស្ថានីយបញ្ចូលថាមពលអគ្គិសនីឡើងវិញ។ |
| ការគ្រប់គ្រងទឹក និងកាកសំណល់ប្រកបដោយនិរន្តរភាព | ផ្តល់ហិរញ្ញប្បទានដល់ការសាងសង់ ឬប្រតិបត្តិការនៃរោងចក្រប្រព្រឹត្តិកម្មទឹកស្អាត និងការតភ្ជាប់ទឹកស្អាតទៅកាន់លំនៅដ្ឋាន និងផ្តល់ហិរញ្ញប្បទានដល់ការទិញ និងដំឡើងផលិតផល ឬបច្ចេកវិទ្យាដែលកាត់បន្ថយការប្រើប្រាស់ទឹកនៅក្នុងអគារការិយាល័យ រួមទាំងការដំឡើង ប្រតិបត្តិការ និងសេវាកម្មគាំទ្រទាក់ទងនឹងទឹកស្អាត និង/ឬ ការសាងសង់ និងថែទាំហេដ្ឋារចនាសម្ព័ន្ធទឹកស្អាត ការកែច្នៃសំណល់ទឹក និងប្រព័ន្ធលូបង្ហូរទឹក។ ផ្តល់ហិរញ្ញប្បទានលើការចំណាយទាក់ទងនឹងទំនប់/ផ្លូវទឹក និងប្រព័ន្ធធារាសាស្ត្រខ្នាតតូច។ |
| ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ | ផ្តល់ហិរញ្ញប្បទានដល់ការដំឡើង ប្រតិបត្តិការ ការសាងសង់ដើម្បីការពារទឹកជំនន់ និងគ្រោះរាំងស្ងួត រួមទាំងការសាងសង់អាងស្តុកទឹក និងទំនប់ខ្នាតធំ/ផ្លូវទឹក/ប្រព័ន្ធធារាសាស្ត្រ។ ខ្នាតធំនេះតម្រូវឱ្យមានការវាយតម្លៃភាពងាយរងគ្រោះ និងផែនការសម្របខ្លួន។ |
| ការបង្ការ និងត្រួតពិនិត្យការបំពុល | ផ្តល់ហិរញ្ញប្បទានដល់ការប្រមូលសំរាម និងការកែច្នៃឡើងវិញ រួមទាំងការប្រមូលសំរាមដែលគាំទ្រដល់ការបំបែកប្រភពនៃកាកសំណល់ យានជំនិះប្រមូលសំរាមដែលស្របតាមប្រភេទដឹកជញ្ជូនស្អាត ការកែច្នៃមេកានិចនៃកាកសំណល់ ការបំបែក និងកែច្នៃកាកសំណល់ទៅជាវត្ថុអនុស្សាវរីយ៍/សិប្បកម្ម។ ការកែច្នៃសំណល់អេឡិកត្រូនិក និងការកែច្នៃសំណល់គីមី មិនត្រូវបានរាប់បញ្ចូលនោះទេ។ |

# សូចនាករលើការអនុវត្តផ្នែកបរិស្ថាន

ដើម្បីជាមូលដ្ឋានសម្រាប់វាស់វែងកិច្ចខិតខំប្រឹងប្រែងរបស់ធនាគារក្នុងការកាត់បន្ថយផលប៉ះពាល់លើបរិស្ថាន ធនាគារ អេស៊ីលីដា បានបង្កើតឱ្យមានសូចនាករការអនុវត្តផ្នែកបរិស្ថានសំខាន់ៗ (KPIs) ជាឧបករណ៍សំខាន់សម្រាប់តាមដានវឌ្ឍនភាពបរិស្ថាន គាំទ្រការវាយតម្លៃគោលនយោបាយ និងបង្ហាញព័ត៌មាន។ សូចនាករនេះនឹងជួយឱ្យធនាគារគ្រប់គ្រង និងធ្វើការទំនាក់ទំនងរវាងការអនុវត្តផ្នែកបរិស្ថាន និងប្រតិបត្តិការហិរញ្ញវត្ថុ។ ហើយលទ្ធផលប្រតិបត្តិការទាំងនេះត្រូវបានត្រួតពិនិត្យជានិច្ចដើម្បីឱ្យសម្រេចតាមគោលបំណងដែលបានបង្កើតឡើង។

**ការបំភាយឧស្ម័នផ្ទះកញ្ចក់**

**វិសាលភាព១**

ក្នុងឆ្នាំ ២០២៣

**២.៩៦៣** សមមូលឧស្ម័នកាបូនិកគិតជាតោន

ធនាគារ ប្តេជ្ញាកាត់បន្ថយដានកាបូននៅក្នុងប្រតិបត្តិការអាជីវកម្ម ដោយរក្សាថេរនូវដានកាបូនសម្រាប់ប្រតិបត្តិការធនាគារនៅឆ្នាំ ២០២៤ ។

**ការបំភាយឧស្ម័នផ្ទះកញ្ចក់**

**វិសាលភាព២**

ក្នុងឆ្នាំ ២០២៣

**២០.៧៥៥** សមមូលឧស្ម័នកាបូនិកគិតជាតោន

### គោលដៅរយៈពេលខ្លី

កាត់បន្ថយការបំភាយឧស្ម័នកាបូនិក **៤**% នៅឆ្នាំ២០២៥

ពីឆ្នាំមូលដ្ឋាន ២០២៣

## ប្រភពនៃឧស្ម័នផ្ទះកញ្ចក់ធនាគារ អេស៊ីលីដា ភីអិលស៊ី

| វិសាលភាព ប្រភេទ | ធនាគារ អេស៊ីលីដា ភីអិលស៊ី | ធនាគារ អេស៊ីលីដា ឡាវ លីមីតធីត | ស្ថាប័នមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា មីយ៉ាន់ម៉ា លីមីតធីត | សាកលវិទ្យាល័យពាណិជ្ជសាស្ត្រ អេស៊ីលីដា | មជ្ឈមណ្ឌលសុវត្ថិភាពគ្រប់គ្រងទិន្នន័យព័ត៌មានវិទ្យា |
|---|---|---|---|---|---|
| វិសាលភាព១ ការបំភាយឧស្ម័នផ្ទះកញ្ចក់ពាក់ព័ន្ធនឹងប្រតិបត្តិការ និងអាជីវកម្មរបស់ធនាគារដោយផ្ទាល់ | | | | | |
| • បរិមាណនៃការប្រើប្រាស់សាំង ឬម៉ាស៊ូតសម្រាប់ម៉ាស៊ីនភ្លើងរបស់ធនាគារ | ✓ | ✓ | ✓ | ✓ | ✓ |
| • បរិមាណនៃការប្រើប្រាស់សាំង ឬម៉ាស៊ូតសម្រាប់យានយន្តរបស់ធនាគារ | ✓ | ✓ | ✓ | ✓ | ✗ |
| វិសាលភាព២ ការបំភាយឧស្ម័នផ្ទះកញ្ចក់ពាក់ព័ន្ធនឹងប្រតិបត្តិការ និងអាជីវកម្មរបស់ធនាគារដោយប្រយោល | | | | | |
| • អគ្គិសនីដែលបានទិញ | ✓ | ✓ | ✓ | ✓ | ✓ |
| វិសាលភាព៣ ការបំភាយឧស្ម័នផ្ទះកញ្ចក់ពាក់ព័ន្ធនឹងប្រតិបត្តិការ និងអាជីវកម្មរបស់ធនាគារដោយប្រយោលផ្សេងទៀត | | | | | |
| • ការប្រើប្រាស់ទឹកម៉ាស៊ីន | ✓ | ✓ | ✓ | ✓ | ✓ |
| • ការប្រើប្រាស់ក្រដាស A៤ | ✓ | ✓ | ✓ | ✓ | ✗ |

ដើម្បីកាត់បន្ថយដល់ការប៉ះពាល់បរិស្ថាន នៅក្នុងឆ្នាំ២០០៩ ធនាគារបានបង្កើតប្រព័ន្ធឃ្លាំមើល ចំពោះការប្រើប្រាស់ធនធាន ។ លទ្ធផលត្រូវបានបង្ហាញជាចំណុចចម្បងតាមលំដាប់លំដោយដូចខាងក្រោមដើម្បីប្រើប្រាស់ជាគំរូសម្រាប់អនុវត្តនាពេលអនាគត ។

## ការប្រើប្រាស់ក្រដាស




ដើម្បីកាត់បន្ថយការប្រើប្រាស់ក្រដាសពីការបោះពុម្ព ធនាគារបានបង្កើតឱ្យមានទម្រង់ថ្មីគឺសំណើសុំឌីជីថល ការចុះហត្ថលេខា និងត្រាអេឡិចត្រូនិក ។ ជាលទ្ធផលក្នុងឆ្នាំ ២០២៣ ការប្រើប្រាស់ក្រដាស (A៤) បានថយចុះមកនៅត្រឹម ១២៤.៣៦០ គីឡូក្រាម (ពី ១២៧.៩២០ គីឡូក្រាមក្នុងឆ្នាំ ២០២២) ដែលស្មើនឹង ២,៥៥% ក្នុងបុគ្គលិកម្នាក់ បើធៀបនឹងឆ្នាំ ២០២២ ដោយសារធនាគារកំពុងបន្តពង្រឹងលើការប្រើប្រាស់ទិន្នន័យអេឡិចត្រូនិក ដោយប្រើប្រព័ន្ធអេឡិកត្រូនិកដែលបង្កើត ឡើងដោយ ផ្នែកព័ត៌មានវិទ្យា ក្នុងការផ្ញើ/ទទួលព័ត៌មានផ្ទៃក្នុង។ ជាងនេះទៅទៀត ធនាគារក៏បានប្តេជ្ញាចិត្តក្នុងការសម្រេចឱ្យបាននូវការ បោះពុម្ពកាន់តែតិច ជាងមុនផងដែរ។

ទន្ទឹមនឹងនេះដែរនៅឆ្នាំ ២០២៣ ការកែច្នៃក្រដាសសំណល់ក៏បានថយចុះ ២០% ក្នុងបុគ្គលិកម្នាក់ បើប្រៀបធៀបទៅនឹងឆ្នាំ ២០២២ ដោយសារតែការប្រជុំ / ការបណ្តុះបណ្តាលភាគច្រើនត្រូវបានធ្វើឡើងដោយមធ្យោបាយអេឡិចត្រូនិក / តាមអ៊ីនធើណែតជំនួសឱ្យការមកកន្លែងដោយផ្ទាល់ ។

| | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | គោលដៅ ២០២៤ |
|---|---|---|---|---|---|---|
| **ក្រដាស** | | | | | | |
| ក្រដាសប្រើប្រាស់ គិតជាគីឡូក្រាម /FTE | ១០,៦០ | ១០,៦១ | ១០,១៨ | ១០,៥៨ | ១០,៣១ | ១០,០០ |
| **សំណល់ក្រដាសកែច្នៃ** | | | | | | |
| សំណល់ក្រដាស គិតជាគីឡូក្រាម/FTE | ១,០៣ | ១,២៣ | ២,០៦ | ១,៨០ | ១,៤៤ | ១,៣០ |

## ការប្រើប្រាស់ថាមពល និងឥន្ធនៈ

នៅឆ្នាំ២០២៣ ការប្រើប្រាស់អគ្គិសនីក្នុងបុគ្គលិកម្នាក់ៗបានកើនឡើង ៥,៧២% បើធៀបនឹងឆ្នាំ ២០២២ ដោយសារតែការកើនឡើងនៃធនធានមនុស្ស និងឧបករណ៍/ឧបករណ៍អេឡិចត្រូនិកសម្រាប់ផ្គត់ផ្គង់ និងបម្រើដល់ការអនុវត្តការងារប្រចាំថ្ងៃ។ រីឯការប្រើប្រាស់ប្រេងសាំងក៏បានកើនឡើង ៧,៣១% ក្នុងឆ្នាំ ២០២៣ ហើយប្រេងម៉ាស៊ីនក៏កើនឡើង ៧,៥៥% ដោយសារតែការកើនឡើងនៃចំនួនបុគ្គលិកការិយាល័យជួរមុខ និងយានយន្តសម្រាប់ការធ្វើដំណើរ។ ទោះជាយ៉ាងណាក៏ដោយ ការប្រើប្រាស់ប្រេងម៉ាស៊ូតបានថយចុះ ២,២៣% បើធៀបនឹងឆ្នាំ២០២២។

ធនាគារព្យាយាមលើកកម្ពស់ការយល់ដឹងដល់បុគ្គលិកទាំងអស់តាមគ្រប់មធ្យោបាយ ទាក់ទងនឹងការអភិរក្សថាមពល ហើយជឿជាក់ថានឹងកាត់បន្ថយការបញ្ចេញឧស្ម័ននៅក្នុងប្រតិបត្តិការរបស់យើង ។







| | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | គោលដៅ ២០២៤ |
|---|---|---|---|---|---|---|
| **ថាមពល** | | | | | | |
| អគ្គិសនី ប្រើគិតជាគីឡូវ៉ាត់ម៉ោង/FTE | ១.៦៧៩,០៩ | ១.៩២២,៨៤ | ២.០១៣,៤៦ | ២.១៩៨,៩៥ | ២.៣២៤,៨១ | ២.១០០ |
| ប្រេងសាំង ប្រើគិតជាលីត្រ/FTE | ៣៦,៦៩ | ៣៦,២៧ | ៣៥,១៦ | ៣៨,៩៨ | ៤១,៨៣ | ៣៨,០៦ |
| ប្រេងម៉ាស៊ូត ប្រើគិតជាលីត្រ/FTE | ៤៣,៧០ | ៤៦,១១ | ៤០,១៩ | ៤២,១១ | ៤១,១៧ | ៤០,០០ |
| ប្រេងម៉ាស៊ីន ប្រើគិតជាលីត្រ/FTE | ១,១២ | ១,២៥ | ១,០២ | ១,០៦ | ១,១៤ | ១,០០ |

## ការប្រើប្រាស់ទឹក

ការប្រើប្រាស់ទឹកក្នុងបុគ្គលិកម្នាក់ៗ បានថយចុះចំនួន ៦,៩៥% ក្នុងឆ្នាំ ២០២៣ បើធៀបនឹងឆ្នាំ ២០២២ ដោយសារតែធនាគារនៅតែបន្តកិច្ចខិតខំប្រឹងប្រែងអភិរក្សធនធានទឹក ដោយធ្វើការបំពាក់នូវបច្ចេកវិទ្យាទំនើបៗ ដែលមានប្រសិទ្ធភាពក្នុងការគ្រប់គ្រងការប្រើប្រាស់ទឹក ដូចជាម៉ាស៊ីនចាប់សញ្ញាទឹក ក៏ដូចជាធ្វើការតាមដាន និងត្រួតពិនិត្យជាប្រចាំ ដើម្បីធានាថាមិនមែនការខូច បែក ឬលេចធ្លាយបំពង់បង្ហូរទឹកនោះទេ។ លើសពីនេះ ធនាគារក៏បានលើកកម្ពស់ការយល់ដឹង និងលើកទឹកចិត្តដល់គ្រប់កម្មករនិយោជិតទាំងអស់ ឱ្យចូលរួមសន្សំសំចៃការប្រើប្រាស់ទឹក តាមរយៈការពន្យល់ និងណែនាំអំពីផលប៉ះពាល់នៃការខ្វះខាតទឹកដល់បរិស្ថាន។



| | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | គោលដៅ ២០២៤ |
|---|---|---|---|---|---|---|
| **បរិមាណទឹកប្រើប្រាស់** | | | | | | |
| ទឹក ប្រើគិតជាម៉ែត្រគូប /FTE | ២៨,២១ | ២០,៤២ | ២២,១៩ | ១៨,៧០ | ១៧,៤០ | ១៧,០០ |

## ការធ្វើដំណើរ




នៅឆ្នាំ២០២៣ ចម្ងាយផ្លូវសរុបដែលធ្វើដំណើរដោយរថយន្តបានថយចុះ ០,០៧% ខណៈពេលដែលការធ្វើដំណើរតាមទោចក្រយានយន្តបានកើនឡើង ២៤,៣៣% បើធៀបនឹងឆ្នាំ២០២២ ដោយសារតែការងើបឡើងវិញនៃសេដ្ឋកិច្ច និងការកើនឡើងនៃការធ្វើដំណើរទៅជួបអតិថិជនដោយផ្ទាល់។

| | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|
| **ការធ្វើដំណើរ** | | | | | |
| ដោយរថយន្តគិតជាគីឡូម៉ែត្រ/FTE | ៥១៤,៥៤ | ៥៦៥,៥៩ | ៣៦៧,២៩ | ៥៧៤,២៨ | ៥៧៣,៩០ |
| ដោយទោចក្រយានយន្ត គិតជាគីឡូម៉ែត្រ /FTE | ១.៨៣៨,៧៣ | ១.៨៤៥,០៤ | ១.៧០៥,៥២ | ១.៩៧៩,៧០ | ២.៤៦១,៤៤ |

## ការបំភាយឧស្ម័នកាបូនិក

| | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|
| វិសាលភាព ១ (សមមូលនៃឧស្ម័នកាបូនិក គិតជាតោន) | ២.៤៨៤ | ២.៥៥០ | ២.៣៣៩ | ២.៥២១ | ២.៩៦៣ |
| វិសាលភាព ២ (សមមូលនៃឧស្ម័នកាបូនិក គិតជាតោន) | ១២.៥៩០ | ១៤.៤០៦ | ១៥.១៨៩ | ១៦.៦៤១ | ២០.៧៥៥ |
| ចំនួនបុគ្គលិកបម្រើការងារពេញម៉ោង (FTE) | ១១.៩៨៤ | ១១.៩៧៥ | ១២.០៥៧ | ១២.០៩៥ | ១២.០៦៧ |

សម្គាល់៖
- ធនាគារ អេស៊ីលីដា ភីអិលស៊ី (ABC) ធនាគារ អេស៊ីលីដា ឡាវ លីមីតធីត (ABL) អេស៊ីលីដា មីក្រូហិរញ្ញវត្ថុ មីយ៉ាន់ម៉ា លីមីតធីត (AMM) សាកលវិទ្យាល័យ ពាណិជ្ជសាស្ត្រ អេស៊ីលីដា (AUB)។
- សម្រាប់ការបំភាយឧស្ម័នកាបូនិកក្នុងវិសាលភាព១ និងវិសាលភាព២ ចាប់ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២២ គឺចំពោះតែធនាគារ អេស៊ីលីដា ភីអិលស៊ី ប៉ុណ្ណោះ ហើយឆ្នាំ២០២៣ គឺចំពោះសម្ព័ន្ធធនាគារ ។
- កត្តាបំភាយសម្រាប់គណនាការប្រើប្រាស់អគ្គិសនីត្រូវបានផ្លាស់ប្តូរស្របតាមកត្តាបំភាយបណ្តាញរបស់ក្រសួងបរិស្ថាន។
- សម្រាប់ការប្រើប្រាស់ក្រដាស ការប្រើប្រាស់ថាមពល ការប្រើប្រាស់ទឹក ការធ្វើដំណើរអាជីវកម្មគឺចំពោះតែធនាគារ អេស៊ីលីដា ភីអិលស៊ី ប៉ុណ្ណោះ។ មិនមានការបង្ហាញអំពីការប្រើប្រាស់ ផលិតថាមពលកកើតឡើងវិញ សំណល់រឹង ឬទឹកសំណល់ ពីព្រោះធនាគារចាត់ទុកថាព័ត៌មានទាំងនេះ មិនជាសារវន្ត និងមិនអាចរកទិន្នន័យ និងធនធានបាន។

វប្បធម៌ការងាររួមរបស់ធនាគារ អេស៊ីលីដា ត្រូវបានបង្កើតឡើង ដោយគោរពតាមសង្គម ដែលធនាគារធ្វើប្រតិបត្តិការ រួមទាំងអ្នកចូលរួមជាមួយយើងទាំងអស់ ដែលក្នុងនោះមិនមែនផ្តោតតែទៅលើភាគហ៊ុនិក បុគ្គលិក អតិថិជន និងដៃគូអាជីវកម្មប៉ុណ្ណោះទេ ប៉ុន្តែផ្តោតលើសហគមន៍ទាំងមូល ។

# ទិដ្ឋភាពសង្គម



វប្បធម៌ការងាររួមរបស់ធនាគារអេស៊ីលីដា ត្រូវបានបង្កើតឡើងដោយគោរពតាមសង្គម ដែលធនាគារធ្វើប្រតិបត្តិការ រួមទាំង អ្នកចូលរួមជាមួយយើងទាំងអស់ ដែលក្នុងនោះមិនមែនផ្តោតតែទៅលើភាគហ៊ុនិក បុគ្គលិក អតិថិជន និងដៃគូអាជីវកម្មប៉ុណ្ណោះទេ ប៉ុន្តែផ្តោតលើសហគមន៍ទាំងមូល ។ ធនាគារប្រកាន់ខ្ជាប់ជានិច្ចនូវគោលការណ៍នៃការផ្តល់ឱកាសស្មើគ្នាចំពោះបុគ្គលគ្រប់រូបក្នុងសង្គម ជាពិសេសធនាគារនឹង៖

- មិនផ្តល់ហិរញ្ញប្បទាន ឬការគាំទ្រចំពោះសកម្មភាពនានាដែលពាក់ព័ន្ធទៅនឹងការបង្ខិតបង្ខំ ឬការរំលោភបំពានលើកម្លាំងពលកម្មកុមារ ឬការរើសអើងផ្សេងៗ ។

- ផ្តល់ជូននូវផលិតផល និងសេវាកម្ម ឲ្យបានសមស្របប្រកបដោយការសម្រិតសម្រាំងយ៉ាងប្រុងប្រយ័ត្ន និងអភិវឌ្ឍឲ្យសមស្របទៅនឹងតម្រូវការពិសេសក្នុងសង្គមកម្ពុជាយើង ។

- ប្រុងប្រយ័ត្នក្នុងការផ្តល់ប្រាក់កម្ចីដល់អតិថិជន ដោយប្រកាន់ខ្ជាប់នូវការអនុវត្តល្អបំផុតនៃការការពារអតិថិជន។

- ការចូលរួមក្នុងកម្មវិធីអប់រំជាសាធារណៈលើបញ្ហាហិរញ្ញវត្ថុដើម្បីជួយដល់អតិថិជនក្នុងការគ្រប់គ្រងធនធានហិរញ្ញវត្ថុរបស់ពួកគាត់ប្រកបដោយប្រសិទ្ធភាព និងបង្កើនជំនាញក្នុងអាជីវកម្មឱ្យកាន់តែប្រសើរឡើងដើម្បីមានលក្ខណៈគ្រប់គ្រាន់សម្រាប់ហិរញ្ញវត្ថុធនាគារ។

- ថែរក្សា និងផ្តោតលើការផ្តល់សេវាហិរញ្ញវត្ថុដល់ចំណែកទីផ្សារតូចៗនៃសង្គម ដើម្បីផ្តល់ឱ្យពួកគាត់នូវមធ្យោបាយសមស្របមួយ ដើម្បីបង្កើនប្រសិទ្ធិភាពក្នុងការរស់នៅ ។

- ពង្រីកបណ្តាញប្រតិបត្តិការ ដោយផ្តល់សេវាកម្មហិរញ្ញវត្ថុដល់សហគមន៍ថ្មីៗ ដែលមានទីតាំងនៅកន្លែងផ្សេងៗ និងពង្រីកបណ្តាញប្រតិបត្តិការនៅតាមបណ្តោយខេត្ត-រាជធានី រួមទាំងពង្រីកសេវាកម្មធនាគារតាមរយៈប្រព័ន្ធអនឡាញ ដើម្បីទទួលបាននូវប្រាក់សន្សំឲ្យបានកាន់តែច្រើន ។

- លើកកម្ពស់ឱកាសការងារសម្រាប់ស្ត្រី ដោយសមស្របនូវតម្រូវការការងារ ដើម្បីធានាឱ្យមានសមភាពយេនឌ័រ ។

- លើកកម្ពស់បរិយាកាសការងារឲ្យបានល្អប្រសើរសម្រាប់កម្មករនិយោជិតទាំងអស់ ការពារផលប្រយោជន៍រួមរបស់កម្មករនិយោជិត និងសហគមន៍តាមរយៈការកែលម្អ និងការអនុវត្តគោលការណ៍ណែនាំស្តីពីការបម្រើការងារ ការគ្រប់គ្រងធនធានមនុស្ស សុខភាព សុវត្ថិភាព និងសន្តិសុខទាំងបុគ្គល និងសហគមន៍ ។

- គាំទ្រដល់គម្រោងសុខុមាលភាពសង្គម ឬប្រាក់សោធននិវត្តន៍ ។

- អនុលោមតាមរបបពន្ធដែលធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធដំណើរការ។

- លើកទឹកចិត្តយុវជនជំនាន់ក្រោយឱ្យចូលរៀន ដោយផ្តល់ឱកាសឱ្យពួកគេទទួលបានការរស់នៅកាន់តែប្រសើរ។

# សុវត្ថិភាព និងបរិយាកាសការងារ

ការចូលរួមចំណែក UN SDGs

ធនាគារ អេស៊ីលីដា បានរៀបចំផ្តល់ជូននូវបរិយាកាសការងារប្រកបដោយសុវត្ថិភាព និងសុខុមាលភាពល្អ ដើម្បីឱ្យកម្មករនិយោជិតទាំងអស់អាចបំពេញការងាររបស់ពួកគាត់បានល្អប្រសើរ។ ធនាគារក៏ជឿជាក់ដែរថាការថែរក្សាសុខុមាលភាពរបស់កម្មករនិយោជិត ក៏នឹងអាចជួយឱ្យយើងបង្កើនផលិតភាពការងាររបស់ធនាគារ ជម្រុញនូវកិច្ចខិតខំប្រឹងប្រែង និងរក្សាបានការរីកចម្រើនរយៈពេលវែង។ ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅនេះ ធនាគារបានយកចិត្តទុកដាក់យ៉ាងម៉ឺងម៉ាត់លើការបង្ការ និងគ្រប់គ្រងការរីករាលដាលនៃជំងឺកូវីដ-១៩ នៅក្នុងធនាគារស្របទៅតាមការជូនដំណឹងរបស់ក្រសួងសុខាភិបាល។

## វិធីសាស្ត្រគ្រប់គ្រង

- ដើម្បីគាំទ្រ និងថែរក្សាសុខភាព និងបរិយាកាសការងាររបស់កម្មករនិយោជិត ធនាគារបានដាក់ចេញគោលការណ៍ណែនាំ និងនីតិវិធីដូចជា គោលការណ៍ណែនាំ និងនីតិវិធីស្តីពីហានិភ័យការងារ គោលការណ៍ណែនាំអំពីសណ្តាប់ធ្នាប់ និងអនាម័យ គោលការណ៍ប្រតិបត្តិស្តីពីការគ្រប់គ្រងសុវត្ថិភាពការិយាល័យ និងគោលការណ៍ប្រតិបត្តិសុខុមាលភាព ។
- ធនាគារបង្កើតឱ្យមានគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយក្នុងគោលបំណងកាត់បន្ថយការកើតឡើងនៃគ្រោះមហន្តរាយ និងកាត់បន្ថយផលប៉ះពាល់ដែលមិនអាចទប់ស្កាត់បាន ។
- ដាក់ចេញនូវនីតិវិធីស្តីពីការជម្លៀសបុគ្គលិកចេញពីការិយាល័យក្នុងករណីមានអគ្គិភ័យកើតមានឡើង ។
- ធ្វើការវាយតម្លៃគុណភាពប្រព័ន្ធខ្យល់នៅក្នុងអគាររបស់ធនាគារជាប្រចាំ ដើម្បីធានាបាននូវបរិយាកាសល្អ សម្រាប់កម្មករនិយោជិតទាំងអស់ ។

**សីតុណ្ហភាពក្នុងការិយាល័យ**
**ចាប់ពី**
**២៤ - ២៦ អង្សាសេ**

**អាំងតង់ស៊ីតេពន្លឺនៅកន្លែងបំពេញការងារ**
**ចាប់ពី**
**៣០០ - ៥០០ (LUX)**



- ធានាឱ្យមានភ្លើងបំភ្លឺនៅកន្លែងបំពេញការងារគ្រប់គ្រាន់ សមស្របសម្រាប់ប្រតិបត្តិការ និងអនុលោមតាមតម្រូវការបទប្បញ្ញត្តិដែលពាក់ព័ន្ធ ។
- ផ្តល់ការធានារ៉ាប់រងសុខភាពដើម្បីឱ្យកម្មករនិយោជិតមានអារម្មណ៍ជឿជាក់លើសុវត្ថិភាព និងមានការចំណាយទាបលើការថែទាំសុខភាព ។
- ដើម្បីធានាបាននូវសុខុមាលភាពរបស់កម្មករនិយោជិត ធនាគារបានបំពាក់ម៉ាស៊ីនចម្រោះទឹកស្អាតសម្រាប់ប្រើប្រាស់នៅគ្រប់ការិយាល័យ។
- រៀបចំឱ្យមានអ្នកប្រឹក្សាផ្នែកថែទាំសុខភាព ដោយមានវេជ្ជបណ្ឌិត ០១នាក់ និងគិលានុបដ្ឋាយិកា ០២នាក់ សម្រាប់បុគ្គលិកងាយស្រួលក្នុងការពិគ្រោះ និងប្រាស្រ័យទាក់ទងជាមួយវេជ្ជបណ្ឌិតដោយផ្ទាល់ និងតាមរយៈទូរស័ព្ទ ឬតេឡេក្រាម។ ជាងនេះទៅទៀត ធនាគារក៏បានរៀបចំបន្ទប់សម្រាកសម្រាប់កម្មករនិយោជិតផងដែរនៅពេលពួកគាត់មិនស្រួលខ្លួន។ ការអនុវត្តការងារប្រកបដោយសុវត្ថិភាពលើបញ្ហាសុខភាព គឺជាផ្នែកមួយនៃការហ្វឹកហ្វឺនដែលផ្តល់ជូនគ្រប់កម្មករនិយោជិត ក្រោមការត្រួតពិនិត្យរបស់លោកវេជ្ជបណ្ឌិត ។

# ការអនុវត្តសមភាពការងារ

ការចូលរួមចំណែក UN SDGs

ធនាគារបានប្រកាន់ខ្ជាប់នូវគោលការណ៍សមភាពនៃឱកាស និងការប្រតិបត្តិ ចំពោះសមាជិកទាំងអស់នៅក្នុងសង្គម ដោយអនុវត្តគោលការណ៍សមភាពនៅទីកន្លែងធ្វើការចំពោះកម្មករនិយោជិតទាំងអស់។ ធនាគារយល់ច្បាស់ថាការគ្រប់គ្រង និងគោរពសិទ្ធិមនុស្សដោយត្រឹមត្រូវ និងការប្រព្រឹត្តចំពោះកម្មករនិយោជិតដោយស្មើភាព នឹងជាកំលាំងចលករក្នុងការជំរុញកំណើនអាជីវកម្ម ព្រមទាំងលើកកម្ពស់ការប្រកួតប្រជែង និងជំរុញការរីកចម្រើនប្រកបដោយចីរភាព។

## វិធីសាស្ត្រគ្រប់គ្រង

- ធនាគារបានដាក់ចេញគោលការណ៍ប្រតិបត្តិ និងនីតិវិធីដូចជា អនុសញ្ញារួមការងារ គោលនយោបាយស្តីពីមេរោគអេដស៍-ជំងឺអេដស៍ គោលការណ៍ប្រតិបត្តិរៀបចំធនធានមនុស្ស គោលការណ៍ប្រតិបត្តិស្តីពីប្រាក់បៀវត្ស និងការឧបត្ថម្ភប្រាក់នានា គោលការណ៍ប្រតិបត្តិវាយតម្លៃលទ្ធផលការងារកម្មករនិយោជិត ក៏ដូចជាគោលការណ៍ណែនាំនានាសម្រាប់ការអនុវត្តឱ្យមានប្រសិទ្ធភាព ។
- អនុវត្តវិធានការជាក់ស្តែងនានា ដូចជាការបណ្តុះបណ្តាលអ្នកសម្ភាសន៍ជ្រើសរើសបុគ្គលិក អំពីនីតិវិធី និងដំណើរការជ្រើសរើសដែលមិនមានការរើសអើង និងផ្សព្វផ្សាយដល់អ្នកគ្រប់គ្រង និងកម្មករនិយោជិតអំពីច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ។
- លើកកម្ពស់ឱកាសការងារសម្រាប់ស្ត្រី និងធានាឱ្យមានភាពស្មើគ្នាសម្រាប់ស្ត្រីនៅកន្លែងបម្រើការងារ។



### ធានាបាននូវសមភាពឱកាស និងការប្រតិបត្តិ




### ការលើកកម្ពស់សមភាពយេនឌ័រ

គិតត្រឹមខែធ្នូ ឆ្នាំ២០២៣

បុគ្គលិកជាស្ត្រី

មានចំនួន **៤.៧១១ នាក់**

ស្មើនឹង **៣៩,១១%** នៃចំនួនបុគ្គលិកសរុប

- ធនាគារបានដាក់ចេញគោលការណ៍ប្រតិបត្តិស្តីពីការគោរពសិទ្ធជនមានពិការភាព ដើម្បីធានាបាននូវឱកាស និងការអនុវត្តស្មើភាពគ្នាចំពោះកម្មករនិយោជិត ដែលមានពិការភាព និង ឱកាសការងារ ផ្អែកតាមតួនាទីការងាររបស់ពួកគាត់ ដោយពុំមានការរើសអើង។
- ធនាគារ អេស៊ីលីដា ជឿជាក់យ៉ាងមុតមាំថាការផ្តល់ឱកាសការងារសម្រាប់កម្មករនិយោជិតទាំងអស់ គឺជាមធ្យោបាយក្នុងការជម្រុញសមភាព និងបរិយាបន្នសង្គម ។ ជាមួយគ្នានោះដែរ ក្នុងឆ្នាំ ២០២៣ ធនាគារ ក៏បានផ្តល់ការងារដល់ជនដែលមានពិការភាពចំនួន ២.៨៩៧ នាក់នៅទូទាំងប្រទេសផងដែរ។

សម្គាល់៖ លក្ខណៈវិនិច្ឆ័យសម្រាប់បុគ្គលិកពិការភាព ផ្អែកតាមក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។



- ធានាបាននូវការអភិវឌ្ឍការងារ ការផ្តល់អត្ថប្រយោជន៍ និងបុព្វលាភ នានារបស់កម្មករនិយោជិតដោយស្មើភាព តម្លាភាព និងមិនមានទំនាស់ផលប្រយោជន៍ ក្នុងគោលបំណងជម្រុញ និងលើកទឹកចិត្តដល់កម្មករនិយោជិតទាំងអស់ ឱ្យបង្កើនសមត្ថភាពបន្ថែមតាមរយៈចំណេះដឹង ជំនាញ និងបទពិសោធន៍ក្នុងតួនាទីការងារ។

- បុគ្គលិកទាំងអស់មានប្រតិភូបុគ្គលិក ដែលពួកគេធ្វើការបោះឆ្នោតជ្រើសរើសដោយផ្ទាល់ដោយមិនរាប់បញ្ចូលថ្នាក់ដឹកនាំ ជាអ្នកនាំពាក្យប្រាប់និយោជកអំពីសេចក្តីតវ៉ារបស់កម្មករនិយោជិតម្នាក់ៗ ឬច្រើននាក់រួមគ្នាដែលមិនសុខចិត្តអំពីការអនុវត្តប្រាក់ឈ្នួល ការអនុវត្តការងារ បទបញ្ជាទូទៅនៃការងារ អនុសញ្ញារួមសម្រាប់អនុវត្ត និងលើកនូវរាល់សំណូមពរ ព្រមទាំងវិធានការដែលមានប្រយោជន៍សម្រាប់រួមចំណែកក្នុងការការពារសុខភាព កែលម្អសន្តិសុខ និងលក្ខខណ្ឌការងាររបស់កម្មករនិយោជិត។

## ការចាត់ថ្នាក់បុគ្គលិកតាមអាយុ




## ការចាត់ថ្នាក់បុគ្គលិកតាមភេទ

| | | |
|---|---|---|
| - អ្នកគ្រប់គ្រងជាន់ខ្ពស់ | ៦២,៥០% | ៣៧,៥០% |
| - អ្នកគ្រប់គ្រងថ្នាក់កណ្តាល | ៨៣,៧៧% | ១៦,២៣% |
| - អ្នកគ្រប់គ្រងជួរមុខ | ៦៥,៧៦% | ៣៤,២៤% |
| - បុគ្គលិក | ៥៩,២៩% | ៤០,៧១% |

ការចូលរួមចំណែក UN SDGs

# ការចូលរួមជាមួយសហគមន៍ និងសង្គម

ធនាគារ អេស៊ីលីដា ទទួលស្គាល់ថាការចូលរួមបំពេញនូវតួនាទីជាប្រជាពលរដ្ឋល្អក្នុងសហគមន៍របស់យើង ជាបច្ច័យមួយដ៏ល្អសម្រាប់ផលប្រយោជន៍ និងភាពរុងរឿងសម្រាប់ទាំងអស់គ្នា។ ការចូលរួមក្នុងសង្គម និងសហគមន៍ពិតជាមានសារៈសំខាន់ក្នុងការជំរុញឱ្យមានភាពរស់រវើកចម្រុះ និងមានភាពធន់ ដែលផ្តល់នូវមូលដ្ឋានគ្រឹះសម្រាប់បុគ្គលម្នាក់ៗក្នុងការអភិវឌ្ឍទំនាក់ទំនងសង្គមដ៏រឹងមាំ និងការយកចិត្តទុកដាក់ចំពោះគ្នាទៅវិញទៅមក។ ការចូលរួមយ៉ាងសកម្មនៅក្នុងសហគមន៍របស់ធនាគារ អេស៊ីលីដា មិនត្រឹមតែផ្តល់អត្ថប្រយោជន៍ដល់សង្គមប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្កើនការគាំទ្រផ្នែកសង្គម ធ្វើឱ្យប្រសើរឡើងនូវសុខុមាលភាពផ្លូវចិត្ត ព្រមទាំងជួយឱ្យទទួលបានការយល់ដឹងកាន់តែប្រសើរឡើងអំពីបញ្ហាប្រឈម និងឱកាសរបស់សហគមន៍។

## វិធីសាស្រ្តគ្រប់គ្រង

- ធនាគារលើកទឹកចិត្តដល់កម្មករនិយោជិតទាំងអស់ឱ្យមានទំនួលខុសត្រូវចំពោះសង្គម រួមទាំងការចូលរួមក្នុងកិច្ចការស្ម័គ្រចិត្ត និងការចូលរួមក្នុងសកម្មភាពនានាជាមួយសហគមន៍។
- សហការជាមួយស្ថាប័នរដ្ឋ ឯកជន និងសង្គមស៊ីវិល ដូចជា កាកបាទក្រហមកម្ពុជា មូលនិធិគន្ធបុប្ផា សមាគមគ្រូពេទ្យស្ម័គ្រចិត្តយុវជនសម្តេចតេជោ (TYDA) មជ្ឈមណ្ឌលជាតិផ្តល់ឈាម សហព័ន្ធកីឡាបាល់ទាត់កម្ពុជា និងសមាគមធនាគារកម្ពុជា ដើម្បីលើកកម្ពស់ជីវភាពការរស់នៅ និងសុខុមាលភាពទូទៅ។

ជាមួយគ្នានោះដែរ ក្នុងឆ្នាំ២០២៣ ធនាគារ អេស៊ីលីដា ភីអិលស៊ី បានចូលរួមសកម្មភាពសង្គម និងមនុស្សធម៌សំខាន់ៗដូចជា:

### សកម្មភាពមនុស្សធម៌

- ឧបត្ថម្ភថវិកាចំនួន **៨០០លានរៀល** ជូនដល់ កាកបាទក្រហមកម្ពុជា ក្នុងកម្មវិធីអបអរខួបទី១៦០ ទិវាពិភពលោកកាកបាទក្រហម និងអឌ្ឍចន្ទក្រហម ៨ ឧសភា ២០២៣ ។
- ឧបត្ថម្ភថវិកាក្នុងមូលនិធិរបស់ក្រសួងព័ត៌មាន ដើម្បីជួយដល់មន្ទីរពេទ្យគន្ធបុប្ផា និងអង្គការគ្រួសារថ្មី ដែលជាការងារមនុស្សធម៌ក្នុងការរួមចំណែកជាមួយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីកាត់បន្ថយភាពក្រីក្រ ។
- ឧបត្ថម្ភកម្មវិធី រាត្រីសមោសរសប្បុរសធម៌ រៃអង្គាសថវិកាលើកទី ៥ នៃសមាគមអភិរក្សដំរីអៃរាវត្តា ។





## ការអប់រំ




- ឧបត្ថម្ភសិក្ខាសាលាស្តីពី "ឈ្វេងយល់ពីបច្ចេកវិទ្យាហិរញ្ញវត្ថុ" ដែលរៀបចំដោយ មជ្ឈមណ្ឌលបណ្តុះបណ្តាល ឫទ្ធិពល ។
- ឧបត្ថម្ភកម្មវិធីការប្រកួតប្រជែងផែនការអាជីវកម្ម មានឈ្មោះថា "អាជីវកម្មខ្ញុំ" សម្រាប់ឆ្នាំ២០២៣ ដែលរៀបចំដោយ ក្រសួងអប់រំ យុវជន និងកីឡា ។
- ចូលបច្ច័យចំនួន **៣០០.០០០ ដុល្លារអាមេរិក** ដើម្បីកសាងអគារសិក្សា និងសាលប្រជុំថ្មី ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ ទីតាំងគោលរាជធានីភ្នំពេញ ។
- ឧបត្ថម្ភកម្មវិធី អបអរសាទរខួបគម្រប់ ២០ឆ្នាំ របស់សាលាវេស្ទើន អន្តរជាតិ ។
- ឧបត្ថម្ភកម្មវិធី ពិព័រណ៍អប់រំឆ្នាំ២០២៣ ដែលរៀបចំដោយ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។

## ការថែទាំសុខភាព

- ឧបត្ថម្ភថវិកាសម្រាប់ចូលរួមចំណែកជាមួយ សមាគមគ្រូពេទ្យស្ម័គ្រចិត្តយុវជនសម្តេចតេជោ ដើម្បីផ្តល់សេវាថែរក្សាសុខភាព ក្នុងការពិនិត្យ និងព្យាបាលជំងឺនៅតាមមូលដ្ឋានដោយឥតគិតថ្លៃ ក្នុងបុព្វហេតុលើកកម្ពស់សុខមាលភាពជូនដល់ប្រជាពលរដ្ឋនៅទូទាំងប្រទេស ។
- ឧបត្ថម្ភកម្មវិធីរត់ប្រណាំង Road To Give ២០២៣ ។
- ឧបត្ថម្ភ (Gold Sponsor) កម្មវិធីគម្រប់ខួប ៧ឆ្នាំ នៃការបើកដំណើរការ មន្ទីរពេទ្យជប៉ុនសាន់រ៉ាយស៍ភ្នំពេញ ។
- ឧបត្ថម្ភ "ទិវារត់ប្រណាំង ក្រុងអរិយក្សត្រលើកទី១" ដែលរៀបចំដោយ សហព័ន្ធខ្មែរ អត្តពលកម្ម ស្ម័គ្រចិត្ត ។
- ឧបត្ថម្ភព្រឹត្តិការណ៍ "ប្រណាំងកង់ និងរត់ពាក់កណ្តាលម៉ារ៉ាតុង លើកទី៨ សម្រាប់មន្ទីរពេទ្យកុមារ គន្ធបុប្ផា" ដែលរៀបចំដោយ សណ្ឋាគារ ឋានសួគ៌សុខា នាថ្ងៃទី២៨ ដល់ទី២៩ ខែតុលា ឆ្នាំ ២០២៣ ។
- ឧបត្ថម្ភដល់បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) ដើម្បីគាំទ្រកម្មវិធីរបស់ខ្លួន ប.ស.ស.ស ។



- នៅឆ្នាំ២០២៣ ធនាគារ អេស៊ីលីដា បានរៀបចំកម្មវិធីបរិច្ចាគឈាមចំនួនពីរដង ក្នុងគោលបំណងជួយដល់អ្នកជំងឺដែលស្ថិតក្នុងស្ថានភាពសង្គ្រោះបន្ទាន់។ គណៈគ្រប់គ្រង និងបុគ្គលិករបស់ធនាគារ អេស៊ីលីដាជាង ១.៤០០នាក់ នៅទូទាំងប្រទេសបានចូលរួមបរិច្ចាគឈាមដោយស្ម័គ្រចិត្ត ដល់មជ្ឈមណ្ឌលជាតិផ្តល់ឈាម ដើម្បីជួយសង្គ្រោះអ្នកជនរងគ្រោះ និងអ្នកជំងឺទាំងអស់ដែលត្រូវការឈាមក្នុងខែមីនា និងធ្នូ ឆ្នាំ២០២៣។





## សកម្មភាពកីឡា






- ឧបត្ថម្ភព្រឹត្តិការណ៍ "រត់ប្រណាំងកាត់វាល" ពាក់កណ្តាលម៉ារ៉ាតុង ។
- សហការឧបត្ថម្ភដល់ សហព័ន្ធកីឡាបាល់ទាត់កម្ពុជា (FFC) ក្នុងគោលបំណងឧបត្ថម្ភគាំទ្រថវិកា ដើម្បីចូលរួមចំណែកក្នុងការគាំទ្រ និងការអភិវឌ្ឍ វិស័យកីឡាបាល់ទាត់នៅកម្ពុជា ។
- ឧបត្ថម្ភព្រឹត្តិការណ៍ ជិះកង់របស់សមាគមធនាគារ នៅកម្ពុជា ក្រោមប្រធានបទ៖ "ជិះកង់ដើម្បីផ្សព្វផ្សាយអំពីនិរន្តរភាព នៃវិស័យធនាគារនៅកម្ពុជា និងការលើកកម្ពស់ប្រាក់រៀល" នៅថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២៣ នៅក្រុងព្រះសីហនុ ។
- ឧបត្ថម្ភកម្មវិធី CSX FUN RUN ២០២៣ ដែលរៀបចំដោយផ្សារមូលបត្រកម្ពុជា ក្នុងគោលបំណងបំផុសចលនាចូលរួមលេងកីឡា និងគៀងគរថវិកាបរិច្ចាគជូនមូលនិធិគន្ធបុប្ផាកម្ពុជា ។
- ឧបត្ថម្ភកម្មវិធី ការប្រកួតបាល់ទាត់ពានរង្វាន់ជើងឯកបុរស ប្រចាំសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ចាប់ពីថ្ងៃទី៩-៣០ ខែធ្នូ ឆ្នាំ២០២៣ ។

## វប្បធម៌ និងប្រពៃណី

- ឧបត្ថម្ភព្រឹត្តិការណ៍ "រំលឹកគុណអង្គរឆ្នាំទី៣" ដែលរៀបចំដោយ អាជ្ញាធរជាតិអប្សរា នាថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២៣ ។

## ការឧបត្ថម្ភកម្មវិធីក្នុងកម្មវិធីផ្សេងៗ

- ឧបត្ថម្ភថវិកាកម្មវិធី "សមាជិក ប.ស.ស. ឆ្នើម ២០២៣" ដែលរៀបចំដោយ បេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) ។
- ឧបត្ថម្ភកម្មវិធី "ទិវាជាតិ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍" ដែលរៀបចំដោយ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ថ្ងៃទី២៦-២៧-២៨ ខែមីនា ឆ្នាំ២០២៣ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ ។
- ឧបត្ថម្ភកម្មវិធី "ពិព័រណ៍ផលិតផលសហគ្រិនស្ត្រីកម្ពុជា" ដែលរៀបចំដោយ សមាគមសហគ្រិនស្ត្រីកម្ពុជា ថ្ងៃទី២៩-៣០-៣១ ខែមីនា ឆ្នាំ២០២៣ នៅផ្សារទំនើបអ៊ូឡាំព្យា ។






- ឧបត្ថម្ភកម្មវិធី "ទិវាប្រាក់រៀលខួបលើកទី៤៣" ដែលរៀបចំដោយ ធនាគារជាតិ នៃ កម្ពុជា ។
- ឧបត្ថម្ភកម្មវិធី "ពិព័រណ៍ផ្លាកលេខរថយន្ត ២០២៣" ដែលរៀបចំដោយ ក្រសួងសាធារណការ និងដឹកជញ្ជូន ។
- ឧបត្ថម្ភកម្មវិធី (កម្រិតមាស) "វេទិកាបរធនបាលកិច្ច លើកទី១ ឆ្នាំ២០២៣៖ ក្របខណ្ឌបទប្បញ្ញត្តិ ឧត្តមានុវត្តន៍ និងកាលានុវត្តភាព" ដែលរៀបចំដោយ និយ័តករបរធនបាលកិច្ច។

- ឧបត្ថម្ភកម្មវិធី "បុណ្យទន្លេលើកទី៧" ក្រោមប្រធានបទ "ទន្លេរបស់យើង ដើម្បីបច្ចុប្បន្ន និងអនាគត" ដែលរៀបចំដោយ ក្រសួងទេសចរណ៍ ។
- ឧបត្ថម្ភ "វេទិកាសេដ្ឋកិច្ច ឆ្នាំ២០២៣ លើកទី១" ដែលរៀបចំដោយ សមាគមយុវជនសេដ្ឋកិច្ចកម្ពុជា ។
- ចូលរួមពិធីសម្ពោធ ដាក់ឱ្យប្រើប្រាស់ជាផ្លូវការ អគារស្នាក់ការកណ្ដាលថ្មី របស់បេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) ។



- ឧបត្ថម្ភកម្មវិធី "ទិវាសន្សំអាស៊ាន" ដែលរៀបចំដោយ ធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៣ ។
- ឧបត្ថម្ភកម្មវិធី បុណ្យសមុទ្រលើទី១០ ក្រោមប្រធានបទ "ទាំងអស់គ្នាដើម្បីទេសចរណ៍" នាថ្ងៃទី១-២-៣ ខែធ្នូ ឆ្នាំ២០២៣ នៅខេត្តកែប ។

- ឧបត្ថម្ភកម្មវិធី "ពិព័រណ៍ផ្សារភាគហ៊ុនកម្ពុជា (My First Stock) ឆ្នាំ២០២២" ដែលរៀបចំដោយ ផ្សារមូលបត្រកម្ពុជា នៅថ្ងៃទី១៦ ដល់ទី១៩ ខែវិច្ឆិកា ឆ្នាំ២០២៣។
- ឧបត្ថម្ភកម្មវិធី "ពិព័រណ៍ជំនាញ និងការងារ ឆ្នាំ២០២៣" ដែលរៀបចំដោយ វិទ្យាស្ថានធនាគារនិងហិរញ្ញវត្ថុ នាថ្ងៃទី២៩ ដល់ ទី៣០ ខែកញ្ញា ឆ្នាំ២០២៣ ។
- ឧបត្ថម្ភកម្មវិធី "សន្និសីទ ធនាគារនៅកម្ពុជា ឆ្នាំ២០២៣" ដែលរៀបចំដោយ សមាគមធនាគារនៅកម្ពុជា ។
- ឧបត្ថម្ភព្រឹត្តិការណ៍ "ពិព័រណ៍ការងារ និងផលិតផលជាតិ ឆ្នាំ ២០២៣" នាថ្ងៃទី១០-១១ ខែវិច្ឆិកា ឆ្នាំ២០២៣ ។
- ឧបត្ថម្ភកម្មវិធី ទិវាសហគ្រិនស្ត្រីកម្ពុជា ក្រោមប្រធានបទ៖ "បញ្ហាប្រឈមរបស់សហគ្រិនស្ត្រីលើកាតព្វកិច្ចបង់ពន្ធ និងទស្សនៈវិស័យនាពេលអនាគត" ។
- ឧបត្ថម្ភកម្មវិធី "វេទិកាបច្ចេកវិទ្យាកម្ពុជា ឆ្នាំ២០២៣" នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ ។





ជាផ្នែកមួយនៃការរួមចំណែកដល់សេដ្ឋកិច្ច និងសង្គម ធនាគារ អេស៊ីលីដា អនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិពន្ធដារទូទាំងប្រទេស និងប្រទេសដែលធនាគារប្រតិបត្តិការ។ ធនាគារដាក់លិខិតប្រកាសពន្ធ និងបំពេញកាតព្វកិច្ចបង់ពន្ធបានត្រឹមត្រូវ និងទាន់ពេលវេលា។ ក្នុងឆ្នាំ ២០២២ ធនាគារបានទទួលវិញ្ញាបនបត្រអនុលោមសារពើពន្ធប្រភេទ “មាស” ដែលមានសុពលភាពសម្រាប់រយៈពេល ២ ឆ្នាំ (២០២២ និង២០២៣) ពីអគ្គនាយកដ្ឋានពន្ធដារ សម្រាប់ការអនុវត្តការបង់ពន្ធអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

## របាយការណ៍បង់ពន្ធ

នៅក្នុងនាមជាធនាគារដែលមានតម្លាភាពមួយ យើងខ្ញុំសូមផ្សព្វផ្សាយជូនលោកអ្នកនូវរបាយការណ៍ពន្ធដែលបានបង់ ដូចមានបង្ហាញជូននៅក្នុងតារាងខាងក្រោម ៖

| គិតជាដុល្លារអាមេរិក | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | សរុប |
|---|---|---|---|---|---|---|
| ពន្ធប៉ាតង់ | ១៩.១៣០ | ១៩.៥៧៦ | ១៨.៩៤២ | ១៨.៩០០ | ១៨.៧៦២ | ២៤៧.៧២៧ |
| ពន្ធលើស្លាកសញ្ញា | ៦៤.០៩៦ | ៨៣.៥៦២ | ៤៩.៩៦៥ | ៥៤.៧០៩ | ៨៩.១២០ | ៩៩៣.៤៤៥ |
| ពន្ធលើមធ្យោបាយដឹកជញ្ជូន | ៣៣.៦៤៣ | ២០.៧៥៣ | ៤៣.១៣៤ | ៥៤.៩៦៦ | ៥៧.១៦៧ | ៥០៧.២២០ |
| ពន្ធលើអចលនទ្រព្យ | ៧.៦៧៣ | ៧.៦៣៦ | ៧.៦៨៣ | ៩.៥៤៥ | ២២.៦១៦ | ១៥៩.៥៧១ |
| អាករលើតម្លៃបន្ថែម | ៥.៧៤៩ | ២២.១៨១ | ១៩៥.៥៧៤ | ៥៥៧.៥១៦ | ៧៧៥.៥៨៨ | ១.៥៦៦.១៦៣ |
| ប្រាក់រំលោះពន្ធលើប្រាក់ចំណេញ | ៥.១២២.៨៣៣ | ៥.២៩៨.១៩៩ | - | - | ៦.៨៣៥.០៩៧ | ៤៩.១០៣.៨៦០ |
| ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ | ១១.៩២៣.៤៦៤ | ២៨.៦៤៥.១៧១ | ២៦.៦៧៣.៦០០ | ៣៤.៧៤៣.៦៩០ | ៣៤.៩៣៤.២១៧ | ៣០៥.១១៦.៨៤៦ |
| ពន្ធលើប្រាក់បៀវត្សរ៍ | ៥.១៦៣.២១២ | ៦.៤៩៧.១៩៩ | ៧.២២៣.៣១៣ | ៩.៥០៧.១៨៩ | ១៣.៤៦៩.៤៧១ | ៨៣.១២៨.១២២ |
| ពន្ធកាត់ទុកលើប្រាក់បញ្ញើសន្សំ | ១៦៩.៦៦៧ | ១៦០.៤១៧ | ២០០.៣២៤ | ៤៤៧.០៣៥ | ១.០២៩.៣៣២ | ៤.០១២.១៨២ |
| ពន្ធកាត់ទុកលើប្រាក់បញ្ញើមានកាលកំណត់ | ៤.៧៥៨.៤៤២ | ៥.១២៩.០៩៦ | ៦.៣១០.៧៣៧ | ៧.៨៧៣.០៦៨ | ១១.៦៥១.២៧៥ | ៦១.៧៣៣.៧៤៥ |
| ពន្ធកាត់ទុកលើថ្លៃជួលអចលនទ្រព្យ | ១.០៤៩.៥០៤ | ១.០៣៦.៥៣០ | ១.១៤០.៩៣២ | ១.២១៥.៧៥៤ | ១.២៣២.៧១៦ | ១៣.៨៩២.៩៤៨ |
| ពន្ធកាត់ទុកលើថ្លៃសេវាក្នុងប្រទេស | ៣៣៥.១៩៣ | ២៩៨.០៣៣ | ២៥៦.៣៧៦ | ៣២៨.០២៨ | ៣២៩.៧៣៩ | ៤.៩៩២.៤៥៦ |
| ពន្ធកាត់ទុកលើថ្លៃសេវាក្រៅប្រទេស | ៥.៨៦៥.២០២ | ៦.៥១៩.០៧២ | ២.៩៣៧.៦៩៤ | ៤.២៥៩.៦៩៣ | ១០.៣៩៤.៧៨២ | ៦២.៩៣៦.៩៤១ |
| សរុប | ៣៤.៥១៧.៨០៩ | ៥៣.៧៣៧.៤២៣ | ៤៥.០៥៨.២៧៥ | ៥៩.០៧០.០៩៣ | ៨០.៨៣៩.៨៨១ | ៥៨៨.៣៩១.២២៦ |
| សរុបយោង* (មកដល់បច្ចុប្បន្ន) | ៣៨៩.៦៨៥.៥៥៤ | ៤០៣.៤២២.៩៧៧ | ៤៤៨.៤៨១.២៥១ | ៥០៧.៥៥១.៣៤៥ | ៥៨៨.៣៩១.២២៦ | |

*សរុប និងសរុបយោង គិតចាប់ពីឆ្នាំ២០០០ មក ។

ការចូលរួមចំណែក UN SDGs

# ការអភិវឌ្ឍធនធានមនុស្ស

ជាមួយនឹងការអភិវឌ្ឍយ៉ាងឆាប់រហ័សនៃឧស្សាហកម្ម និងសេវាកម្មហិរញ្ញវត្ថុ ដែលកំពុងផ្លាស់ប្តូរទៅរកសេដ្ឋកិច្ចឌីជីថល ធនាគារយល់ច្បាស់ថាប្រសិនបើចំណេះដឹងរបស់កម្មករនិយោជិតទាំងអស់មិនបានអភិវឌ្ឍន៍ស្របតាមការរំពឹងទុក នោះពួកគេនឹងមិនអាចគាំទ្រឱ្យការអនុវត្តការងារប្រកបដោយប្រសិទ្ធភាពនោះទេ។ ធនាគារប្តេជ្ញាធ្វើឱ្យប្រសើរឡើងនូវជំនាញរបស់កម្មករនិយោជិតគ្រប់រូប ដោយពង្រីកវិសាលភាពនៃការអភិវឌ្ឍបច្ចេកទេស និងចំណេះដឹង ដើម្បីឱ្យពួកគេអាចរក្សាបាននូវប្រសិទ្ធភាពការងារ និងឱកាសប្រកួតប្រជែង។

## វិធីសាស្ត្រគ្រប់គ្រង

- ធនាគារបានដាក់ចេញនូវគោលការណ៍ប្រតិបត្តិហ្វឹកហ្វឺន និងអភិវឌ្ឍន៍ធនធានមនុស្សក្នុងគោលបំណង ដើម្បីពង្រឹង អភិវឌ្ឍន៍នូវចំណេះដឹង ជំនាញទាន់សម័យ និងធ្វើឱ្យកាន់តែប្រសើរឡើងនូវអាកប្បកិរិយា របស់កម្មករនិយោជិត អេស៊ីលីដា ដើម្បីឱ្យពួកគេអនុវត្តការងារទទួលបានលទ្ធផលកាន់តែល្អប្រសើរឡើងថែម។
- ធនាគារបានដាក់ចេញនូវគោលការណ៍ប្រតិបត្តិ និងនីតិវិធីស្តីពីការឧបត្ថម្ភការសិក្សា ក្នុងការអនុវត្ត គាំទ្រ និងលើកកម្ពស់សមត្ថភាពវិជ្ជាជីវៈ ដើម្បីឱ្យស្របតាមការអភិវឌ្ឍ និងការរីកចម្រើនរបស់ធនាគារ ព្រមទាំងរក្សាបាននូវគុណភាពលើការប្រកួតប្រជែង ដែលជាយុទ្ធសាស្ត្រសំខាន់ក្នុងការគ្រប់គ្រង និងលើកទឹកចិត្ត។
- ធនាគារក៏បានផ្តល់ឱកាសជាច្រើនសម្រាប់កម្មករនិយោជិតក្នុងការហ្វឹកហ្វឺនតាមរយៈការចូលរួមវគ្គបណ្តុះបណ្តាលជាច្រើនទាំងក្នុង និងក្រៅ ក៏ដូចជាកម្មវិធីហ្វឹកហ្វឺនទាក់ទងនឹងអាជីវកម្មផងដែរ។
- នៅក្នុងឆ្នាំ២០២៣ ធនាគារបានធ្វើការវាយតម្លៃឡើងវិញនូវកម្មវិធីហ្វឹកហ្វឺនសម្រាប់កម្មករនិយោជិត និងថ្នាក់គ្រប់គ្រង។ ធនាគារក៏បានជម្រុញយ៉ាងសកម្មផងដែរ ដើម្បីលើកកម្ពស់ចំណេះជំនាញរបស់កម្មករនិយោជិតតាមរយៈការធ្វើសិក្ខាសាលា ការបណ្តុះបណ្តាល និងពង្រឹងកម្មវិធីសិក្សាឱ្យស្របតាមយុទ្ធសាស្ត្ររបស់ធនាគារ ។

នៅឆ្នាំ ២០២៣ ធនាគារបានវិនិយោគ និងចំណាយលើការបណ្តុះបណ្តាលបុគ្គលិកចំនួន

**៣.១៧១.៥៨៦**

ដុល្លារអាមេរិក

ម៉ោងបណ្តុះបណ្តាលជាមធ្យមសម្រាប់បុគ្គលិកម្នាក់

**២៥,៣ ម៉ោង**

ធនាគារលើកកម្ពស់ការយល់ដឹងស្តីពីហានិភ័យបរិស្ថាន សង្គម និងអភិបាលកិច្ច ដល់គ្រប់កម្មករនិយោជិតតាមរយៈប្រព័ន្ធអេឡិកត្រូនិក ដោយមានការចូលរួមពីថ្នាក់ដឹកនាំ និងបុគ្គលិកចំនួន

**១១.២៤៨ នាក់**

បុគ្គលិកសរុបដែលទទួលបានការគាំទ្រផ្នែកអប់រំបន្ថែមចំនួន

**២.៣៦៤ នាក់**

- បេក្ខជនដែលបានជ្រើសរើសចូលបម្រើការងារនៅធនាគារ អេស៊ីលីដា ពួកគេត្រូវបានបណ្តុះបណ្តាលជាផ្លូវការដោយធនាគារ អេស៊ីលីដា ដើម្បីបង្កើនជំនាញ ចំណេះដឹង និងអាកប្បកិរិយា ដើម្បីរួមបញ្ចូលទៅក្នុងវប្បធម៌ការងាររបស់ធនាគារ និងធ្វើឱ្យពួកគេមានអារម្មណ៍សប្បាយរីករាយក្នុងការអនុវត្តការងារ និងអាចបំពេញការងារបានកាន់តែមានប្រសិទ្ធភាព។
- ធនាគារ អេស៊ីលីដា បានដាក់ចេញនូវគោលការណ៍ប្រតិបត្តិ និងនីតិវិធីស្តីពីការធ្វើកម្មសិក្សា ដើម្បីផ្តល់ឱកាស និងសម្របសម្រួលដល់ការស្នើសុំធ្វើកម្មសិក្សារបស់និស្សិតទាំងក្នុង និងក្រៅប្រទេស នៅធនាគារ អេស៊ីលីដា ភីអិលស៊ី និងក្រុមហ៊ុនបុត្រសម្ព័ន្ធក្នុងប្រទេស។

នៅឆ្នាំ ២០២៣ ធនាគារបានដឹកនាំកម្មវិធីបណ្តុះបណ្តាលដល់កម្មករនិយោជិតថ្មីចំនួន

**៦០៧ នាក់**

និស្សិតដែលបានចុះកម្មសិក្សានៅធនាគារ អេស៊ីលីដា ឆ្នាំ២០២៣ មានចំនួន

**៥២០ នាក់**







ធនាគារ អេស៊ីលីដា បានយកចិត្តទុកដាក់ក្នុងការបង្កើនការចូលរួមរបស់កម្មករនិយោជិត ក្នុងកិច្ចការយុទ្ធសាស្ត្រ និងគំនិតផ្តួចផ្តើមនៃការគ្រប់គ្រងស្ថាប័ន ក្នុងគោលបំណងលើកកម្ពស់ និងបញ្ចូលវប្បធម៌ហានិភ័យទៅក្នុងប្រតិបត្តិការប្រចាំថ្ងៃ។ ក្នុងនោះធនាគារ ក៏បានកំណត់ផ្នែកចំនួន **៥** ដែលមានសារៈសំខាន់ចំពោះប្រតិបត្តិការរបស់ធនាគារ ជាវគ្គសិក្សាដ៏ចាំបាច់តាមរយៈប្រព័ន្ធអនឡាញ ដល់ថ្នាក់គ្រប់គ្រង និងកម្មករនិយោជិតទាំងអស់។

- ក្រមប្រតិបត្តិការងារ
- ទំនាស់ផលប្រយោជន៍
- ចំណេះដឹងទាក់ទងនឹងគោលការណ៍ប្រឆាំងនឹងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម
- កំណារពារនិវេទនជន
- ការគ្រប់គ្រងហានិភ័យធនាគារ

ការចូលរួមចំណែក UN SDGs

# បរិយាបន្នហិរញ្ញវត្ថុ និងចំណេះដឹងហិរញ្ញវត្ថុ

ជាមួយនឹងកិត្តិនាមក្នុងការផ្តល់ជូននូវសេវាកម្មធនាគារដ៏ល្អឥតខ្ចោះ ធនាគារ អេស៊ីលីដាបានផ្តល់ជូននូវសេវាហិរញ្ញវត្ថុដ៏សម្បូរបែបមានដូចជា សេវាឥណទាន សេវាប្រាក់បញ្ញើ សេវាផ្ទេរប្រាក់ សេវាចាត់ចែងសាច់ប្រាក់ សេវាហិរញ្ញប្បទានពាណិជ្ជកម្ម ប័ណ្ណអេស៊ីលីដា ប័ណ្ណឥណទាន-ឥណពន្ធ និងសេវាកម្មឌីជីថល រួមទាំងសេវាអេស៊ីលីដាអ៊ីនធើណែត សេវាអេស៊ីលីដាម៉ូបាល (កម្មវិធីធនាគារចល័ត) សេវាអេស៊ីលីដាអ៊ីខុមមើស ម៉ាស៊ីនអេធីអ៊ឹម ម៉ាស៊ីនឆូតកាត និងម៉ាស៊ីនដាក់ប្រាក់បញ្ញើមានកាលកំណត់ ។ ស្ថិតក្នុងចំណោមស្ថាប័នដែលគាំទ្រដោយហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងការិយាល័យរូបវន្តរបស់ខ្លួន ធនាគារ អេស៊ីលីដាបានឈានទៅដល់ការជួយកសិករក្នុងការគ្រប់គ្រងដីកសិកម្ម និងផ្តល់ជាទុនសម្រាប់សហគ្រាសខ្នាតតូច និងមធ្យមផងដែរ ។ តាមរយៈការបង្រួមគម្លាតហិរញ្ញប្បទាន សព្វថ្ងៃនេះប្រជាជនកម្ពុជាជាងបួនលាននាក់ មានលទ្ធភាពប្រើប្រាស់សេវារបស់ធនាគារ អេស៊ីលីដា ដែលជាបរិយាបន្នហិរញ្ញវត្ថុឈានមុខគេនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

## វិធីសាស្ត្រគ្រប់គ្រង

នៅពេលដ៏ខ្លីខាងមុខ គេនឹងមើលឃើញធនាគារ អេស៊ីលីដា ជាធនាគារឌីជីថលដែលមានវិស្វកម្មគ្រប់គ្រងទិន្នន័យដ៏ទំនើបទាន់សម័យ ដែលផ្តល់នូវគុណភាព សុវត្ថិភាព និងទំនុកចិត្ត ។ ខណៈពេលដែលអាចធ្វើឱ្យអតិថិជនទទួលបានសេវាហិរញ្ញវត្ថុ ធនាគារបានចូលរួមយ៉ាងសកម្មក្នុងការលើកកម្ពស់នវានុវត្តន៍ផលិតផល និងសេវាកម្មហិរញ្ញវត្ថុ ដែលសាកសមសម្រាប់អតិថិជននៅគ្រប់មជ្ឈដ្ឋានទាំងអស់។ គំនិតផ្តួចផ្តើមទាំងនេះមិនត្រឹមតែជួយផ្តល់នូវប្រភពមូលនិធិសម្រាប់ប្រតិបត្តិការអាជីវកម្មរបស់ពួកគេប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយលើកកម្ពស់គុណភាពនៃការរស់នៅ បង្កើតការងារ និងសេដ្ឋកិច្ចទាំងមូលផងដែរ។ ខាងក្រោមនេះគឺជាលទ្ធផលដែលធនាគារ អេស៊ីលីដា សម្រេចបានក្នុងឆ្នាំ ២០២៣ មានដូចជា៖




“ធនាគារបាន និងកំពុងធ្វើការយ៉ាងជិតស្និទ្ធជាមួយនឹងសហគ្រាសធុនតូច និងមធ្យម និងបម្រើនូវផលិតផល-សេវាកម្មហិរញ្ញវត្ថុចម្រុះយ៉ាងសម្បូរ បែប ជាពិសេសសេវាកម្មធនាគារអេឡិចត្រូនិក និងឌីជីថល ប្រកបដោយភាពងាយស្រួល និងសុវត្ថិភាព ដើម្បីឆ្លើយតបនឹងតម្រូវការរបស់អតិថិជន។ លើសពីនេះ ធនាគារ អេស៊ីលីដា បានផ្តល់ហិរញ្ញប្បទានយ៉ាងច្រើនដល់សហគ្រាសធុនតូច និងមធ្យម ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម ប្រកបដោយនិរន្តរភាព”




ក្នុងឆ្នាំ២០២៣ ធនាគារ អេស៊ីលីដា បានផ្តល់កម្ចីទៅដល់សហគ្រាសខ្នាតតូច និងមធ្យមចំនួន

**២៩៨.៦០៦ អតិថិជន**

ទឹកប្រាក់ចំនួន ៥.២០៤,២៣ លានដុល្លារអាមេរិក

(៨០,៤៣%) នៃឥណទានសរុប

ធនាគារប្តេជ្ញាក្នុងការពង្រីកបណ្តាញប្រតិបត្តិការសេវាហិរញ្ញវត្ថុឱ្យកាន់តែប្រសើរឡើង និងសមស្របជាងមុន សម្រាប់អតិថិជនគ្រប់មជ្ឈដ្ឋានទាំងអស់នៅក្នុងសហគមន៍ ប្រកបដោយនវានុវត្តន៍ និងបច្ចេកវិទ្យាទំនើប ដើម្បីលើកកម្ពស់ប្រសិទ្ធភាព និងភាពល្អប្រសើរក្នុងការទទួលបានសេវាហិរញ្ញវត្ថុនៅគ្រប់ពេលវេលា និងគ្រប់ទីកន្លែង។



នៅឆ្នាំ២០២៣ ធនាគារផ្តល់ឥណទានដល់វិស័យកសិកម្ម

**១៧៤.១៩០ អតិថិជន**

ទឹកប្រាក់ចំនួន

**១.៣៧០,០៥**

លានដុល្លារអាមេរិក

ជាមួយគ្នានេះដែរ ធនាគារ អេស៊ីលីដា ក៏បានលើកកម្ពស់កំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព និងបង្កើតឱកាសការងារ ដោយការផ្តល់លទ្ធភាពក្នុងការទទួលបានសេវាហិរញ្ញវត្ថុដល់គ្រប់មជ្ឈដ្ឋានទាំងអស់នៅក្នុងសហគមន៍ រួមទាំងកម្ចីសម្រាប់វិស័យកសិកម្ម លំនៅដ្ឋាន និស្សិត និងប្រាក់កម្ចីប្រើប្រាស់ផ្ទាល់ខ្លួនផងដែរ ។

| ឥណទានសម្រាប់អតិថិជនទិញផ្ទះដំបូង/ផ្ទះតម្លៃសមរម្យ | |
|---|---|
| ចំនួន<br>៤.៧៩៩<br>អតិថិជន | ទំហំឥណទាន<br>១៥១,៧១<br>លានដុល្លារអាមេរិក |

| ឥណទានបុគ្គលិក/ឥណទានគេហដ្ឋានបុគ្គលិក | |
|---|---|
| ចំនួន<br>១០.១៧១<br>អតិថិជន | ទំហំឥណទាន<br>៣២៤,៨៤<br>លានដុល្លារអាមេរិក |

| ឥណទានដល់ស្ត្រី | |
|---|---|
| ចំនួន<br>២២០.៧១៦<br>អតិថិជន | ទំហំឥណទាន<br>៣.១៥១,១៤<br>លានដុល្លារអាមេរិក |

| ឥណទានប្រើប្រាស់ផ្ទាល់ខ្លួន | |
|---|---|
| ចំនួន<br>៨១.៧៥២<br>អតិថិជន | ទំហំឥណទាន<br>៤៤០,៩៦<br>លានដុល្លារអាមេរិក |

ដើម្បីលើកកម្ពស់កំណើនសេដ្ឋកិច្ច បរិយាបន្ន និងកំណើនការងារ ក្នុងឆ្នាំ២០២៣ ធនាគារ អេស៊ីលីដា បានផ្តល់ឥណទានដល់អតិថិជនសហគ្រាសខ្នាតតូចចំនួន ២៨០.១៨៧ ដែលមានទំហំឥណទានសរុបចំនួន ២.៨៦៨,៦៥ លានដុល្លារអាមេរិក ឬស្មើនឹង ៤៤,៣៤% នៃឥណទានសរុប។

ធនាគាររក្សា និងបន្តពិពិធកម្មហេដ្ឋារចនាសម្ព័ន្ធឱ្យកាន់តែទូលំទូលាយ និងសម្បូរបែបជាមួយនឹងសាខាទាំង ២៦៤ ទីតាំង ឬការិយាល័យ និងសេវាកម្មធនាគារស្វ័យប្រវត្តិ ចំនួន ១៧៧ទីតាំង ព្រមទាំងមានម៉ាស៊ីនអេធីអ៊ឹម ចំនួន ១.៣៩៣ និងម៉ាស៊ីនឆូតកាតចំនួន ៤.៧២៨ ។

**ចំនួនគណនីប្រាក់បញ្ញើ-សន្សំ**

## ៤.៥៥០.៥៨២ គណនី

**សមតុល្យប្រាក់បញ្ញើ-សន្សំ**

## ៧.១០១,៦៩

លានដុល្លារអាមេរិក





- ធនាគារបានអភិវឌ្ឍន៍ផលិតផលហិរញ្ញវត្ថុជាច្រើន និងបណ្តាញប្រតិបត្តិការកាន់តែមានភាពងាយស្រួល ដើម្បីផ្តល់ជូនអតិថិជន សម្រាប់ការប្រើប្រាស់សេវាកម្មហិរញ្ញវត្ថុផ្សេងៗគ្នា ជាពិសេសមុខងារស្វ័យប្រតិបត្តិការលើអេស៊ីលីដាម៉ូបាល ស្របតាមតម្រូវការអតិថិជន និងវិវឌ្ឍនាការបច្ចេកវិទ្យា ឌីជីថល។

- នៅឆ្នាំ២០២៣ ធនាគារអេស៊ីលីដា និងសមាគមកម្ពុជា-ជប៉ុន (JCA) បានរៀបចំជំនួបធុរកិច្ចរវាងវិនិយោគិនកម្ពុជា និងជប៉ុន ដើម្បីផ្លាស់ប្តូរចំណេះដឹងអំពីការគ្រប់គ្រងហិរញ្ញវត្ថុ ចំណេះដឹងបច្ចេកទេស និងការច្នៃប្រឌិតសំខាន់ៗសម្រាប់ធុរកិច្ចកម្ពុជា និងវិនិយោគិនជប៉ុន។ កម្មវិធីនេះក៏បានជំរុញឱកាសអាជីវកម្មក្នុង និងក្រៅប្រទេសដល់វិនិយោគិនគ្រប់រូបផងដែរ។
- នៅចុងឆ្នាំ២០២៣ ធនាគារបានសិក្សាស្រាវជ្រាវពីកម្រិតជីវភាពរស់នៅរបស់អតិថិជន ដែលប្រើប្រាស់ឥណទានអាជីវកម្មខ្នាតតូច និងឥណទានអាជីវកម្មខ្នាតមធ្យម ដើម្បីវាស់ស្ទង់ពីផលប៉ះពាល់នៃសេវាកម្មឥណទាន របស់ធនាគារ ។ ជាលទ្ធផលនៃការសិក្សាស្រាវជ្រាវបង្ហាញថា លើគ្រប់វិស័យអតិថិជនមានកម្រិតជីវភាពល្អប្រសើរក្រោយពីទទួលបានកម្ចីឥណទានពីធនាគារ អេស៊ីលីដា ភីអិលស៊ី។

## បណ្តាញសេវាហិរញ្ញវត្ថុរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី

ធនាគារ អេស៊ីលីដា បានបន្តអភិវឌ្ឍន៍ទៅលើសេវាឌីជីថលរបស់ធនាគារ ដើម្បីឱ្យអតិថិជនកាន់តែមានភាពងាយស្រួលក្នុងការប្រើប្រាស់ ដោយបន្តបង្កើតផលិតផល និងសេវាកម្មថ្មីៗបន្ថែមទៀត ព្រមទាំងពង្រីកបណ្តាញសេវាកម្មនានា ដើម្បីផ្តល់ឱ្យអតិថិជនមានភាពងាយស្រួល រហ័ស និងអាចធ្វើប្រតិបត្តិការបាននៅគ្រប់ទីកន្លែង និងគ្រប់ពេលវេលា ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ពួកគេ ។




ផ្តល់ជូនសេវាកម្មដ៏ល្អបំផុត ជាមួយនឹងស្នាមញញឹមប្រកប ដោយវិជ្ជាជីវៈរបស់កម្មករនិយោជិត តាមរយៈបណ្តាញប្រតិបត្តិការទាំង ២៦៤ ការិយាល័យសាខាទាំងអស់នៅទូទាំងប្រទេស ។

- សម្រាប់ ០៤សាខា ធនាគារ អេស៊ីលីដា បើកប្រតិបត្តិការបម្រើសេវាជូនអតិថិជនចាប់ពីម៉ោង ៧:៣០ព្រឹក រហូតដល់ម៉ោង ៧:០០ល្ងាច និងចាប់ពីថ្ងៃចន្ទ រហូតដល់ ថ្ងៃសុក្រ (លើកលែងថ្ងៃឈប់សម្រាកសាធារណៈ) ។
- សម្រាប់ ០៣ សាខាក្នុងផ្សារទំនើបអ៊ីអន ១, ២,៣ បើកប្រតិបត្តិការបម្រើសេវាជូនអតិថិជនជារៀងរាល់ថ្ងៃចាប់ពីវេលាម៉ោង ៩:០០ព្រឹក រហូតដល់ម៉ោង ៧:០០ល្ងាច និងចាប់ពីថ្ងៃចន្ទ រហូតដល់ ថ្ងៃអាទិត្យ (រួមទាំងថ្ងៃឈប់សម្រាកសាធារណៈ) ។




សេវាធនាគារស្វ័យប្រវត្តិរបស់ធនាគារ អេស៊ីលីដា បំពាក់ដោយម៉ាស៊ីនដែលអាចឱ្យអតិថិជនធ្វើប្រតិបត្តិការបាន ២៤/៧ នៅជុំវិញទីក្រុងភ្នំពេញ និងតាមបណ្តាខេត្តនានា ។




ម៉ាស៊ីនអេឡិចត្រូនិកសម្រាប់ប្រើជាមួយ KHQR, GLN QR, កាតអេស៊ីលីដា និងកាតធនាគារផ្សេងទៀត ដើម្បីទូទាត់ទំនិញ ឬសេវាកម្មជំនួសឱ្យសាច់ប្រាក់ប្រកបដោយសុវត្ថិភាព និងងាយស្រួល ។

## ចំណេះដឹងផ្នែកហិរញ្ញវត្ថុ

ដើម្បីធ្វើឱ្យសាធារណជនទទួលបានការអប់រំ និងចំណេះដឹងផ្នែកហិរញ្ញវត្ថុ ធនាគារ អេស៊ីលីដា បាននិងកំពុងខិតខំប្រឹងប្រែងក្នុងការបញ្ជូនសារសំខាន់ៗ ក្នុងគោលបំណងលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុដល់សិស្ស និស្សិត អតិថិជន កម្មករនិយោជិត និងសាធារណជនទូទៅ ដែលផ្តោតលើការអប់រំផ្នែកហិរញ្ញវត្ថុសម្រាប់ជំនាន់ក្រោយតាមរយៈប្រព័ន្ធផ្សព្វផ្សាយដូចជា ហ្វេសប៊ុក តេឡេក្រាម យូធូប វីដេអូខ្លីៗ និង វិទ្យុជាដើម ។

















# ហិរញ្ញប្បទានប្រកបដោយការទទួលខុសត្រូវ និងការរួមបញ្ចូលបរិស្ថាន សង្គម និងអភិបាលកិច្ច

ការចូលរួមចំណែក UN SDGs

ធនាគារ អេស៊ីលីដា បានយល់ច្បាស់ពីតួនាទីដ៏សំខាន់របស់ធនាគារក្នុងការជំរុញឱ្យអតិថិជនទាំងអស់ ឈានទៅកាត់បន្ថយកាបូននាពេលអនាគត តាមរយៈការអនុវត្តហិរញ្ញប្បទានរបស់ធនាគារ។ ជាមួយនឹងទំនួលខុសត្រូវនេះផងដែរ ធនាគារបានអភិវឌ្ឍន៍នូវប្រព័ន្ធហិរញ្ញវត្ថុប្រកបដោយនិរន្តរភាព ដោយគិតគូរ និងយកចិត្តទុកដាក់ទៅលើផលប៉ះពាល់បរិស្ថាន សង្គម និងអភិបាលកិច្ច ក៏ដូចជាហានិភ័យអាកាសធាតុ នៅមុនពេលធ្វើការសម្រេចចិត្ត ។

## វិធីសាស្ត្រគ្រប់គ្រង

ធនាគារ អេស៊ីលីដា រក្សាបាននូវការរីកចម្រើនប្រកបដោយចីរភាព ដោយការប្រកាន់ខ្ជាប់នូវគោលការណ៍ច្បាប់ បរិស្ថាន សង្គម និងអភិបាលកិច្ចដ៏រឹងមាំ និងការផ្តោតទៅលើចំណុចសំខាន់បីគឺ មនុស្ស ប្រាក់ចំណេញ និងភពផែនដី ដូចដែលមានចែងក្នុងចក្ខុវិស័យ និងបេសកកម្មរបស់ធនាគារ ។ មិនត្រឹមតែការប្រកាន់ខ្ជាប់នូវការផ្តល់ហិរញ្ញប្បទានប្រកបដោយការទទួលខុសត្រូវ ធនាគារក៏បានយកចិត្តទុកដាក់ និងគិតគូរខ្ពស់ទៅលើកត្តាបរិស្ថាន សង្គម និងអភិបាលកិច្ច ក្នុងគោលបំណងជួយគាំទ្រដល់អាជីវកម្ម និងសង្គមក្នុងការផ្លាស់ប្តូរឆ្ពោះទៅរកការអភិវឌ្ឍ និងកំណើនប្រកបដោយចីរភាព ព្រមទាំងជួយដល់ការការពារហានិភ័យផ្នែកហិរញ្ញវត្ថុ ប្រតិបត្តិការ កេរ្តិ៍ឈ្មោះ និងបទប្បញ្ញត្តិផងដែរ។

- ធនាគារបានដាក់ចេញនូវគោលការណ៍បរិស្ថាន សង្គម និងអភិបាលកិច្ច គោលការណ៍ឥណទាន និងបញ្ជីអាជីវកម្មហាមឃាត់ ស្របតាមគោលការណ៍ហិរញ្ញវត្ថុប្រកបដោយចីរភាពនៅកម្ពុជា ។
- ចាប់តាំងពីឆ្នាំ២០១៣ ធនាគារ អេស៊ីលីដា បានបង្កើតនូវគោលការណ៍ប្រតិបត្តិ និងនីតិវិធីស្តីពី បរិស្ថាន និងសង្គម ក្នុងគោលបំណងដើម្បីផ្តល់ជាគោលការណ៍ការណែនាំ និងអនុវត្តដល់កម្មករនិយោជិតពាក់ព័ន្ធ ដើម្បីកំណត់ វាយតម្លៃ និងគ្រប់គ្រងហានិភ័យដែលអាចកើតមានលើបរិស្ថាន និងសង្គម ។
- ធនាគារតម្រូវឱ្យផ្នែកពាក់ព័ន្ធត្រូវតែត្រួតពិនិត្យលើឥណទានគ្រប់ប្រភេទដែលបានស្នើកម្ចី ដើម្បីអនុលោមទៅតាមបញ្ជីអាជីវកម្មហាមឃាត់របស់ធនាគារ អេស៊ីលីដា នៅពេលដែលមិនអាចជៀសផុតពីផលប៉ះពាល់បរិស្ថាន ធនាគារត្រូវស្វែងរកការចូលរួមពីអតិថិជនរបស់ខ្លួន ដើម្បីកាត់បន្ថយហានិភ័យ និងផលប៉ះពាល់ទាំងនោះ។

គោលនយោបាយហិរញ្ញប្បទានប្រកបដោយការទទួលខុសត្រូវ របស់ធនាគារ អេស៊ីលីដា បានហាមឃាត់ក្នុងការផ្តល់ហិរញ្ញប្បទានដល់អាជីវកម្មដូចជា ៖

- សកម្មភាពអាជីវកម្មដែលបង្កហានិភ័យ និងផលប៉ះពាល់ដល់បរិស្ថាន និងសង្គមដោយផ្ទាល់ ឬដោយប្រយោល ដូចជា ការកាប់បំផ្លាញព្រៃឈើ បង្កឱ្យមានទឹកជំនន់ធ្ងន់ធ្ងរ គ្រោះរាំងស្ងួត និងការបាត់បង់ជីវៈចម្រុះ ការផលិតសារធាតុគីមីគ្រោះថ្នាក់ កាកសំណល់ក្នុងទឹក ។ល។
- សកម្មភាពអាជីវកម្មដែលប៉ះពាល់ដល់លក្ខខណ្ឌការងារ និងសុខភាពសហគមន៍ សុវត្ថិភាព និងសន្តិសុខ ដូចជាការជួញដូរមនុស្ស ឬពលកម្មខុសច្បាប់ ពលកម្មកុមារ ការកេងប្រវ័ញ្ច ធ្វើការក្នុងបរិយាកាសគ្រោះថ្នាក់ ។ល។
- សកម្មភាពអាជីវកម្មដែលប្រើប្រាស់ប្រសិទ្ធភាពធនធាន និងការបំពុលដូចជាបរិមាណទឹកច្រើន និងឬថាមពលអគ្គិសនី ក្រដាស ការបំភាយឧស្ម័នផ្ទះកញ្ចក់ ឧស្ម័នកាបូនិក ការបំពុលទឹក និងការបំពុលទឹកក្រោមដី ។ល។
- សកម្មភាពអាជីវកម្មដែលបណ្តាលឱ្យមានការទិញយកដី និងការតាំងទីលំនៅថ្មី ដូចជាវិវាទដីធ្លី ការបាត់បង់ដីធ្លី និងការបាត់បង់សិទ្ធិលើដី ឬបាត់បង់ឱកាសដើម្បីទទួលបានផលប្រយោជន៍ពីដីនោះ ។ល។

- សកម្មភាពអាជីវកម្មដែលអាចបង្កផលប៉ះពាល់ដល់ការអភិរក្សជីវៈចម្រុះ និងការគ្រប់គ្រងប្រកបដោយនិរន្តរភាពនៃធនធានធម្មជាតិ ។ល។
- សកម្មភាពអាជីវកម្មដែលអាចបណ្តាលឱ្យបាត់បង់បេតិកភណ្ឌវប្បធម៌ និងជនជាតិដើមភាគតិច។

## ដំណើរការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គម

ការវាយតម្លៃផលប៉ះពាល់ បរិស្ថាន និងសង្គម ត្រូវបានបែងចែកជា **០៤កម្រិត** ដូចខាងក្រោម៖

- **កម្រិតទី១ ត្រួតពិនិត្យបញ្ជីអាជីវកម្មដែលត្រូវហាមឃាត់របស់ធនាគារ អេស៊ីលីដា**

  នៅដំណាក់កាលដំបូង ភ្នាក់ងារឥណទានត្រូវត្រួតពិនិត្យសកម្មភាពអាជីវកម្មរបស់អតិថិជនទៅនឹងបញ្ជីអាជីវកម្មដែលត្រូវហាមឃាត់របស់ធនាគារ អេស៊ីលីដា (ACLEDA's Exclusion List) ដែលត្រូវផ្តល់ហិរញ្ញប្បទាន។ ប្រសិនបើអាជីវកម្មរបស់អតិថិជនមានជាប់ពាក់ព័ន្ធទៅនឹងសកម្មភាពណាមួយនៅក្នុងបញ្ជីអាជីវកម្មដែលត្រូវហាមឃាត់របស់ធនាគារ ត្រូវតែជូនដំណឹងដល់អតិថិជន និងរាល់ការពិចារណាបន្ថែមលើការផ្តល់ហិរញ្ញប្បទានត្រូវតែបញ្ចប់។

- **កម្រិតទី២ ស្តង់ដារការអនុវត្តបរិស្ថាន និងសង្គមរបស់អេស៊ីលីដា ការពិនិត្យអេ ភី អេស (**APS)

  មន្ត្រីឥណទានតម្រូវឱ្យធ្វើការត្រួតពិនិត្យអំពីសកម្មភាពអាជីវកម្មរបស់អតិថិជនដល់ទីកន្លែង ដើម្បីអនុវត្តតាមស្តង់ដារប្រតិបត្តិការរបស់ធនាគារ អេស៊ីលីដា និងជៀសវាងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់បរិស្ថាន ដូចដែលមានចែងខាងលើ ។

- **កម្រិតទី៣- ការផ្ទៀងផ្ទាត់ និងការអនុលោមតាមច្បាប់ បទប្បញ្ញត្តិបរិស្ថាន និងសង្គមជាតិ**

  បន្ទាប់ពីអតិថិជន បានឆ្លងផុតដំណាក់កាលការត្រួតពិនិត្យបញ្ជីអាជីវកម្មដែលត្រូវហាមឃាត់របស់ធនាគារ និងការពិនិត្យ APS រួចមកធនាគារនឹងធ្វើការផ្ទៀងផ្ទាត់ក្នុងការអនុលោមតាមច្បាប់ នឹងត្រូវអនុវត្តសម្រាប់អាជីវកម្មសក្តានុពលដែលត្រូវបានផ្តល់ហិរញ្ញប្បទានដោយធនាគារ ។

- **កម្រិតទី៤- ការត្រួតពិនិត្យលើហានិភ័យបរិស្ថាន និងសង្គមកម្រិតខ្ពស់**

  ធនាគារត្រូវធ្វើការត្រួតពិនិត្យ និងវាយតម្លៃបន្ថែម លើសកម្មភាពអាជីវកម្ម ឬគម្រោងដែលមានហានិភ័យកម្រិតខ្ពស់ចំពោះបរិស្ថាន និងសង្គមដោយប្រើទម្រង់ ២ Filtering។ ជាលទ្ធផលនៃការពិនិត្យក្នុងទម្រង់ ២ Filtering គឺជាស្ថានភាពមួយក្នុងចំណោមស្ថានភាពទាំងបីខាងក្រោម៖

  - មិនមានហានិភ័យសារវន្តលើបរិស្ថាន និងសង្គមទេ
  - តម្រូវការវាយតម្លៃលើហានិភ័យបរិស្ថាន និងសង្គមបន្ថែម
  - ហានិភ័យបរិស្ថាន និងសង្គមមានកម្រិតខ្ពស់

ករណីអាជីវកម្មរបស់អតិថិជនត្រូវបានរកឃើញថាមានហានិភ័យបរិស្ថាន និងសង្គមខ្ពស់នោះ គឺត្រូវតែជូនដំណឹងដល់អតិថិជន ហើយរាល់ការពិចារណាបន្ថែមលើការផ្តល់ហិរញ្ញប្បទានត្រូវតែបញ្ចប់។

# សូចនាករលើការអនុវត្តផ្នែកសង្គម

## ទិន្នន័យបុគ្គលិក

| | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|
| ចំនួនបុគ្គលិកសរុប | ១១.៩៩៧ | ១២.០១៣ | ១២.០៨១ | ១២.០៨៣ | ១២.០៤៥ |
| ចំនួនបុគ្គលិកស្ត្រី | ៤.៨១៦ | ៤.៧៦១ | ៤.៧៥០ | ៤.៦៨៧ | ៤.៧១១ |
| ចំនួនបុគ្គលិកបុរស | ៧.១៨១ | ៧.២៥២ | ៧.៣៣១ | ៧.៣៩៦ | ៧.៣៣៤ |

## ទិន្នន័យក្រុមប្រឹក្សាភិបាល

| | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|
| ចំនួនក្រុមប្រឹក្សាភិបាលសរុប | ១០ | ៩ | ១០ | ១០ | ៩ |
| ចំនួនក្រុមប្រឹក្សាភិបាលជាស្ត្រី | ២ | ១ | ១ | ១ | ១ |
| ភាគរយស្ត្រី | ២០% | ១១% | ១០% | ១០% | ១១% |
| ចំនួនក្រុមប្រឹក្សាភិបាលជាបុរស | ៨ | ៨ | ៩ | ៩ | ៨ |
| ភាគរយបុរស | ៨០% | ៨៩% | ៩០% | ៩០% | ៨៩% |

## ទិន្នន័យថ្នាក់គ្រប់គ្រងជាន់ខ្ពស់

| | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|
| ចំនួនថ្នាក់គ្រប់គ្រងជាន់ខ្ពស់សរុប | ៩ | ៩ | ៩ | ៨ | ៨ |
| ចំនួនថ្នាក់គ្រប់គ្រងជាន់ខ្ពស់ជាស្ត្រី | ៤ | ៤ | ៤ | ៤ | ៣ |
| ភាគរយស្ត្រី | ៤៤% | ៤៤% | ៤៤% | ៥០% | ៣៨% |
| ចំនួនថ្នាក់គ្រប់គ្រងជាន់ខ្ពស់ជាបុរស | ៥ | ៥ | ៥ | ៤ | ៥ |
| ភាគរយបុរស | ៥៦% | ៥៦% | ៥៦% | ៥០% | ៦២% |

| | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|
| សមាមាត្រនៃបុគ្គលិកដែលមានប្រាក់ឈ្នួលទាបបំផុតធៀបនឹងប្រាក់ឈ្នួលអប្បបរមា | ០,៩៥ | ០,៩៥ | ០,៩៥ | ១,០០ | ១,០០ |
| ប្រាក់ឈ្នួលទាបបំផុត (គិតជាដុល្លារ) | ១៨៥ | ១៨៥ | ១៨៥ | ២៤០ | ២៤០ |
| ប្រាក់ឈ្នួលអប្បបរមា (គិតជាដុល្លារ) | ១៩៥ | ១៩៥ | ១៩៥ | ២៤០ | ២៤០ |

## ទិន្នន័យបុគ្គលិកមានពិការភាព

| | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|
| ចំនួនបុគ្គលិកបុរសមានពិការភាព | ១.០៥៨ | ៩៨១ | ១.២២៥ | ១.២៧៧ | ១.៤៥៧ |
| ចំនួនបុគ្គលិកស្ត្រីមានពិការភាព | ១.១៣៧ | ១.០៤៩ | ១.២៥៤ | ១.៣០៥ | ១.៤៤០ |
| បុគ្គលិកមានពិការភាពសរុប | ២.១៩៥ | ២.០៣០ | ២.៤៧៩ | ២.៥៨២ | ២.៨៩៧ |

## ការគាំពារជីវភាព

| | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|
| ចំនួនបុគ្គលិកជាស្ត្រីដែលទទួលបានការគាំពារជីវភាព | ៤.៨៣៤ | ៤.៧៧៩ | ៤.៧៣៨ | ៤.៦៩៧ | ៤.៣៦៧ |
| ចំនួនបុគ្គលិកជាបុរសដែលទទួលបានការគាំពារជីវភាព | ៧.១៥៧ | ៧.១៩១ | ៧.២៨៦ | ៧.៣៥៨ | ៦.៨៥៣ |

## គ្រោះថ្នាក់ការងារ

| | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|
| ចំនួនបុគ្គលិករងរបួស | ២៥៨ | ២៤៥ | ២០៣ | ២១៧ | ២១៩ |
| ចំនួនមរណៈភាព | - | - | ២ | - | - |
| ភាគរយមរណៈភាព | - | - | ០,៩៩% | - | - |

## មូលនិធិសុខុមាលភាពសង្គម (ប.ស.ស.)

| | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|
| ចំនួនបុគ្គលិកជាស្ត្រីដែលទទួលបានមូលនិធិសុខុមាលភាពសង្គម | ៨២៥ | ៨០៦ | ៥៥៤ | ៤៨០ | ៥១១ |
| ចំនួនបុគ្គលិកជាបុរសដែលទទួលបានមូលនិធិសុខុមាលភាពសង្គម | ១៦៥ | ១៧៧ | ១២២ | ១៣៥ | ១៤៥ |
| ចំនួនបុគ្គលិកសរុបដែលទទួលបានមូលនិធិសុខុមាលភាពសង្គម | ៩៩០ | ៩៨៣ | ៦៧៦ | ៦១៥ | ៦៥៦ |

## ថ្ងៃសេវាទូរស័ព្ទប្រចាំខែ

| | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|
| ចំនួនបុគ្គលិកជាស្ត្រីដែលទទួលបានថ្លៃសេវាទូរស័ព្ទប្រចាំខែ | ១.៣៩៣ | ១.៤១៩ | ១.៤៩៥ | ១.៥៨៦ | ១.៨០៨ |
| ចំនួនបុគ្គលិកជាបុរសដែលទទួលបានថ្លៃសេវាទូរស័ព្ទប្រចាំខែ | ៥.១៨៦ | ៥.២៣៦ | ៥.៤៣៦ | ៥.៥៣៨ | ៥.២៧២ |

| | | | | | |
|---|---|---|---|---|---|
| ចំនួនបុគ្គលិកសរុបដែលទទួលបានថ្លៃសេវាទូរស័ព្ទប្រចាំខែ | ៦.៥៧៩ | ៦.៦៥៥ | ៦.៩៣១ | ៧.១២៤ | ៧.០៨០ |

## ម៉ោងបណ្តុះបណ្តាលបុគ្គលិក

| | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|
| ចំនួនម៉ោងបណ្តុះបណ្តាលសរុប | ២៨៣.៧០៥ | ២២៧.៤៦៨ | ២៧៥.៩៧២ | ៣៣៩.៦៩៥ | ៣០៤.៥៨៣ |
| ម៉ោងបណ្តុះបណ្តាលជាមធ្យមសម្រាប់បុគ្គលិកម្នាក់ | ២៣,៦ | ១៨,៩ | ២២,៨ | ២៨,១ | ២៥,៣ |

## ការបណ្តុះបណ្តាល និងអភិវឌ្ឍន៍បុគ្គលិក

| | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|
| ការបណ្តុះបណ្តាល (កម្មវិធីបំពាក់បំប៉ន និងអភិវឌ្ឍវិជ្ជាជីវៈ) | ៥.០២៣ | ៧.២៩៣ | ៦.៥៥៤ | ៧.៩៧៩ | ៥.៣១៣ |
| ការបណ្តុះបណ្តាលបុគ្គលិកចូលថ្មី (កម្មវិធីដំបូង) | ៩៤០ | ៧៨៨ | ៨៤៣ | ៧៧៦ | ៦០៧ |
| ការបណ្តុះបណ្តាលនិស្សិតនៅក្នុងស្រុក | ៦៨៥ | ២៣៧ | ៤១៥ | ៥៥៧ | ៥២០ |
| ការបណ្តុះបណ្តាលនិស្សិតបរទេស | ៤ | ៥ | - | - | ១ |
| ការវិនិយោគ/ចំណាយលើការបណ្តុះបណ្តាលបុគ្គលិក (ដុល្លារអាមេរិក) | ២.៥០០.៥៦៤ | ២.៨៩២.៩៨៣ | ២.៨៨៣.៦៩០ | ៤.០៥៨.០២៦ | ៣.១៧១.៥៨៦ |

## ការអប់រំបន្ថែម/ជំនួយក្នុងការបណ្តុះបណ្តាល

| | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|
| ចំនួនបុគ្គលិកជាស្ត្រីដែលទទួលបានការគាំទ្រផ្នែកអប់រំបន្ថែម | ៣៨ | ២៦ | ៩៣ | ៥៣ | ២០៨ |
| ចំនួនបុគ្គលិកជាបុរសដែលទទួលបានការគាំទ្រផ្នែកអប់រំបន្ថែម | ៣៨ | ៩២ | ២០៣ | ២១៣ | ២.១៥៦ |
| ចំនួនបុគ្គលិកសរុបដែលទទួលបានការគាំទ្រផ្នែកអប់រំបន្ថែម | ១៤៤ | ១១៨ | ២៩៦ | ២៦៦ | ២.៣៦៤ |

ធនាគារ អេស៊ីលីដា ភីអិលស៊ី ទទួលស្គាល់នូវសារៈសំខាន់នៃអភិបាលកិច្ចសាជីវកម្ម ដើម្បីគាំទ្រការរីកចម្រើនប្រកបដោយចីរភាពរបស់ធនាគារ បង្កើនប្រសិទ្ធភាពការងារ បង្កើនតម្លៃរបស់ភាគហ៊ុនិក និងជំនឿទុកចិត្តដល់ភាគហ៊ុនិក អតិថិជន បុគ្គលិក ព្រមទាំងសាធារណជន។

# ទិដ្ឋភាពអភិបាលកិច្ច



ការចូលរួមចំណែក UN SDGs

# អភិបាលកិច្ចសាជីវកម្ម និងការប្រឆាំងអំពើពុករលួយ

ធនាគារ អេស៊ីលីដា បានទទួលស្គាល់នូវសារៈសំខាន់នៃអភិបាលកិច្ចសាជីវកម្ម ក្នុងការជួយដល់ការរីកចម្រើនប្រកបដោយចីរភាពរបស់ធនាគារ បង្កើនប្រសិទ្ធភាពការងារ បង្កើតតម្លៃដល់ភាគហ៊ុនិក និងធានាបាននូវការជឿទុកចិត្តដល់ ភាគហ៊ុនិក អតិថិជន បុគ្គលិក  ព្រមទាំងសាធារណជន។ ក្រុមប្រឹក្សាភិបាលក៏គាំទ្រ និងលើកទឹកចិត្តក្នុងការអនុវត្តគោលការណ៍អភិបាលកិច្ចសាជីវកម្មល្អ រួមទាំងក្រមសីលធម៌ ។

## វិធីសាស្ត្រគ្រប់គ្រង

ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវក្នុងការកំណត់យុទ្ធសាស្ត្ររបស់ធនាគារ តាមរយៈការគ្រប់គ្រងហានិភ័យ រួមបញ្ចូលវប្បធម៌សម្រាប់ដំណើរការ ឬត្រួតពិនិត្យការប្រតិបត្តិនៃអាជីវកម្ម។ សមាជិករបស់ក្រុមប្រឹក្សាភិបាលត្រូវធ្វើសកម្មភាពក្នុងផលប្រយោជន៍ល្អបំផុតរបស់ធនាគារ ។ ក្រុមប្រឹក្សាភិបាលគាំទ្រ និងលើក ទឹកចិត្តឱ្យអនុវត្តគោលការណ៏អភិបាលកិច្ចសាជីវកម្មល្អ រួមទាំងក្រមសីលធម៌។

ក្រុមប្រឹក្សាភិបាល ទទួលខុសត្រូវលើអភិបាលកិច្ចសាជីវកម្ម និងជំរុញអភិវឌ្ឍន៏ជោគជ័យរបស់ធនាគារ តាមរយៈការដឹកនាំរាល់ប្រតិបត្តិការការងារ និងអាជីវកម្ម។ ក្រុមប្រឹក្សាភិបាលជាអ្នកតែងតាំង និងអាចដកតំណែងរបស់ប្រធាននាយកប្រតិបត្តិ ក្រុមប្រឹក្សាភិបាលក៏ធានាផងដែរថាធនធានមនុស្ស ដែលចាំបាច់មានគ្រប់គ្រាន់ក្នុងការបង្កើត យុទ្ធសាស្ត្រ និងគោលដៅហិរញ្ញវត្ថុជាមួយថ្នាក់គ្រប់គ្រង ដើម្បីដាក់ឱ្យថ្នាក់គ្រប់គ្រងអនុវត្ត ព្រមទាំងត្រួតពិនិត្យលើការអនុវត្តរបស់ថ្នាក់គ្រប់គ្រងដោយផ្ទាល់ និងតាមរយៈគណៈកម្មាធិការក្រុមប្រឹក្សាភិបាល។ ធនាគារ អេស៊ីលីដា យកចិត្តទុកដាក់យ៉ាងខ្លាំងលើការធ្វើប្រតិបត្តិការអាជីវកម្មស្របតាមអភិបាលកិច្ចសាជីវកម្មល្អ និងទប់ស្កាត់អំពើពុករលួយគ្រប់ទម្រង់ ជាមួយនឹងយុទ្ធសាស្ត្រគ្រប់គ្រងដូចខាងក្រោម៖

- ដាក់ចេញនូវគោលការណ៍អភិបាលកិច្ចសាជីវកម្ម ដែលគ្របដណ្តប់លើតួនាទី និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល សិទ្ធិ តម្លាភាព សមាសភាព និងគុណវុឌ្ឍិ។
- ដាក់ចេញនូវគោលការណ៍ និងគោលការណ៍ប្រតិបត្តិស្តីពី ក្រមប្រតិបត្តិការងារក្នុងតួនាទី របស់កម្មករនយោជិតគ្រប់លំដាប់ថ្នាក់ ដើម្បីអនុវត្តបាននូវក្រមសីលធម៌ខ្ពស់បំផុត ដើម្បីជាផលប្រយោជន៍ដល់ភាគីពាក់ព័ន្ធ មាននាយកប្រតិបត្តិ ថ្នាក់គ្រប់គ្រង និងកម្មករនិយោជិតទាំងអស់ក្នុងការ អនុវត្តការងារប្រកបដោយសុចរិតភាព។ ធនាគារលើកទឹកចិត្តដល់គ្រប់កម្មករនិយោជិតទាំងអស់ ប្រកាន់ខ្ជាប់ជានិច្ចនូវការប្រព្រឹត្តដោយស្មោះត្រង់ ក្របដោយក្រមសីលធម៌ អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ ។
- ដាក់ចេញនូវគោលការណ៍ទំនាស់ផលប្រយោជន៍ ដើម្បីឱ្យកម្មករនិយោជិតទាំងអស់ របស់ធនាគារ អេស៊ីលីដា ងាយស្រួលកំណត់ ទប់ស្កាត់ និងគ្រប់គ្រងរាល់ទំនាស់ផលប្រយោជន៍ដែលអាចកើតឡើងក្នុងដំណើរការអាជីវកម្មរបស់ធនាគារ។

**ក្រមប្រតិបត្តិការងារក្នុងតួនាទី**
របស់កម្មករនិយោជិត ធនាគារ អេស៊ីលីដា ភីអិលស៊ី

- ធនាគារប្រកាន់ខ្ជាប់ជានិច្ចនូវក្រមប្រតិបត្តិ សម្រាប់វិស័យធនាគារ និងហិរញ្ញវត្ថុ ដើម្បីរក្សាស្ថិរភាព និងនិរន្តរភាពក្នុងការអភិវឌ្ឍវិស័យធនាគារ កសាងសុចរិតភាព និងទំនុកចិត្តជាមួយអតិថិជន និងសាធារណជន ដោយគ្របដណ្តប់លើ ១) ការពង្រឹងអភិបាលកិច្ចល្អ ២) តួនាទីរបស់ក្រុមប្រឹក្សាភិបាល និងថ្នាក់គ្រប់គ្រងប្រតិបត្តិ ៣) ការលើកកម្ពស់ការយល់ដឹង និងការបណ្តុះបណ្តាល ៤) ហិរញ្ញប្បទានប្រកបដោយទំនួលខុសត្រូវ ៥) ទំនាស់ផលប្រយោជន៍ ៦) ការតាំងបង្ហាញ ៧) គណនេយ្យភាព និងទំនុកចិត្ត ៨) ទំនួលខុសត្រូវ និងតម្លាភាព ៩) ឯកជនភាពនៃទិន្នន័យអ្នកប្រើប្រាស់ ១០) បទដ្ឋានសេវា ១១) ព័ត៌មាន ១២) ការធានា ១៣) ការផ្សាយពាណិជ្ជកម្ម ទីផ្សារ និងការលក់ ១៤) ក្រមសីលធម៌ ១៥) ការប្រមូលបំណុល ១៦) ការលក់ដោយមិនមានការបង្ខិតបង្ខំ ១៧) ការបង្កើតផលិតផល និងសេវា ១៨) ការរើសអើង ១៩) មធ្យោបាយទំនាក់ទំនង ២០) ការដោះស្រាយទំនាស់សម្រាប់អ្នកប្រើប្រាស់ ២១) ការដោះស្រាយទំនាស់ សម្រាប់គ្រឹះស្ថានហិរញ្ញវត្ថុ។




- ធនាគារហាមដាច់ខាតក្នុងការផ្តល់ ឬការទទួលយកសំណូក ឬការប្រព្រឹត្តអំពើពុករលួយក្នុងទម្រង់ណាមួយ។ កម្មករនិយោជិតទាំងអស់ត្រូវអនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។ ធនាគារប្តេជ្ញាយ៉ាងមុតមាំក្នុងការប្រកបអាជីវកម្មដោយភាពស្មោះត្រង់ សុចរិតភាព និងស្របតាមច្បាប់ និងបទប្បញ្ញត្តិ ព្រមទាំងច្បាប់ប្រឆាំងអំពើពុករលួយផងដែរ។
- ដាក់ចេញនូវអនុសញ្ញារួមនៃការងារ ដែលបានលើកឡើងពីទំនួលខុសត្រូវរបស់កម្មករនិយោជិតទាំងអស់ ក្នុងការប្រកាន់ខ្ជាប់នូវក្រមសីលធម៌វិជ្ជាជីវៈ និងជៀសវាងនូវគ្រប់ទម្រង់នៃការកិបកេង ក្លែងបន្លំ និងអំពើពុករលួយ ជាដើម។
- ដាក់ចេញនូវគោលការណ៍អនុលោមភាព និងមុខងារអនុលោមភាពក្នុងការកំណត់ ការវាយតម្លៃ និងដោះស្រាយហានិភ័យ អនុលោមភាព ដែលនឹងជួយឱ្យធនាគារត្រួតពិនិត្យមើលលើមុខងារអាជីវកម្ម និងសកម្មភាពរបស់ស្ថាប័នទាំងមូល ក៏ដូចជាគិតគូរអំពីសកម្មភាពដែលអាចប៉ះពាល់ដល់ ហានិភ័យផ្នែកច្បាប់ និងកេរ្តិ៍ឈ្មោះ និងក្រុម ឬគ្រឹះស្ថានទាំងមូល ។
- ដាក់ចេញនូវគោលការណ៍ប្រតិបត្តិស្តីពីអំណោយ កម្រៃជើងសារ និងការបញ្ចុះបញ្ចូល ដើម្បីការពារនូវការអនុវត្តមិនសមរម្យរបស់កម្មករនិយោជិត ដូចជាការស៊ីសំណូក អំពើពុករលួយ និងសកម្មភាពផ្សេងទៀតដែលបំពានលើគោលការណ៍ នីតិវិធី និងគោលការណ៍ណែនាំរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី។

ការចូលរួមចំណែក UN SDGs

# ក្រមសីលធម៌អាជីវកម្ម



ធនាគារ អេស៊ីលីដា ប្តេជ្ញារក្សាបាននូវបទដ្ឋានក្រមសីលធម៌ខ្ពស់បំផុត រក្សានូវតម្លាភាព និងគណនេយ្យភាព នៅគ្រប់កម្រិតនៃប្រតិបត្តិការ។ អាស្រ័យហេតុនេះ ធនាគារអេស៊ីលីដា បានអនុម័តក្រមសីលធម៌ ដើម្បីធានាថា ថ្នាក់គ្រប់គ្រង និងកម្មករនិយោជិតរបស់ធនាគារ អេស៊ីលីដាទាំងអស់ អាចអនុវត្តនូវក្រមសីលធម៌ល្អបំផុត ដើម្បីផលប្រយោជន៍របស់ម្ចាស់ភាគហ៊ុនិក អតិថិជន បុគ្គលិក និងសាធារណជនទូទៅ ។

## វិធីសាស្រ្តគ្រប់គ្រង

បុគ្គលិកទាំងអស់នឹងចូលរួមក្នុងការលើកកម្ពស់ភាពស្មោះត្រង់ ក្រមសីលធម៌ ការអនុលោមតាមវិធាន បទប្បញ្ញត្តិ និងគណនេយ្យភាព ដោយប្រកាន់ខ្ជាប់ជានិច្ចនូវការអនុវត្តតាមក្រមប្រតិបត្តិការងារក្នុងតួនាទី របស់កម្មករនិយោជិត។ ក្រមប្រតិបត្តិការងារក្នុងតួនាទី របស់ធនាគារ អេស៊ីលីដា គ្របដណ្តប់លើគោលការណ៍សំខាន់ៗ ចរិតលក្ខណៈបុគ្គល ទំនាក់ទំនងជាមួយអ្នករួមការងារ អតិថិជន និងអ្នកគ្រប់គ្រង អាថ៌កំបាំងវិជ្ជាជីវៈ វិវាទលើផលប្រយោជន៍ ការទទួលយកអំណោយ ការសម្អាតប្រាក់ និងការបកអាក្រាតកំហុសឆ្គង ។

### កំណារពារនិវេទនជន

ធនាគារមានស្មារតីប្រុងប្រយ័ត្នជាប់ជានិច្ចចំពោះអាកប្បកិរិយា ឬការប្រព្រឹត្តទង្វើណាមួយដែលផ្ទុយនឹងបទប្បញ្ញត្តិ ច្បាប់ គោលការណ៍ នីតិវិធី ក្រមសីលធម៌ ដែលអាចកើតមានឡើងគ្រប់ពេលវេលា។ ដូចនេះហើយទើបធនាគារដាក់ចេញនូវគោលការណ៍ស្តីពីកំណារពារនិវេទនជន សម្រាប់ជាវិធានមួយក្នុងការកំណត់អត្តសញ្ញាណដែលមិនសមស្រប ព្រមទាំងចាត់វិធានការបង្ការ និងកែតម្រូវដើម្បីលុបបំបាត់នូវរាល់សកម្មភាពដែលមិនសមស្របទាំងនោះ។ កម្មករនិយោជិតត្រូវបានលើកទឹកចិត្តឱ្យរាយការណ៍ (ក្នុងន័យស្ថាបនា) អំពីវិបត្តិបញ្ហាផ្សេងៗ ដែលអាចធ្វើឱ្យប៉ះពាល់ និងខូចខាតផលប្រយោជន៍ដល់ធនាគារ អេស៊ីលីដា ភីអិលស៊ី និងសាធារណជនទូទៅ។ ធនាគារអនុម័តគោលការណ៍កំណារពារនិវេទនជនក្នុងគោលបំណង ដើម្បីទទួលបានព័ត៌មាន និងផ្តល់ការការពារអ្នកបានផ្តល់ព័ត៌មាន ឬរាយការណ៍ ដែលបង្ហាញពីការព្រួយបារម្ភដោយសុចរិត ដោយមិនមានការព្យាបាទ និងគ្មានការរំពឹងទុកពីផលប្រយោជន៍ណាមួយ ។

ស្ថិតក្រោមគោលការណ៍ប្រតិបត្តិស្តីពីកំណារពារនិវេទនជន ធនាគារផ្តល់ជូននូវយន្តការសម្រាប់ការរាយការណ៍ព័ត៌មាន ឬការផ្តល់យោបល់នានាទាក់ទងនឹងការបំពានច្បាប់ វិធាន និងក្រមសីលធម៌របស់ធនាគារ ដូចជាករណីនៃការប្រព្រឹត្តអំពើពុករលួយ លំអៀង កិបកេង ឬទង្វើអសីលធម៌ជាដើម។

### ដំណើរការដោះស្រាយយោបល់របស់កម្មករនិយោជិត



ផ្ញើព័ត៌មានតាមរយៈលិខិតស្នើសុំបុគ្គលិក អ៊ីម៉ែល ឬការហៅទូរស័ព្ទផ្ទាល់។



នាយកដ្ឋានអនុលោមបញ្ញត្តិ ចងក្រង និងពិនិត្យ ខណៈពេលដែលព័ត៌មានរបស់អ្នកផ្តល់ព័ត៌មានត្រូវបានរក្សាទុកជាសម្ងាត់។



ចំណាត់ការវិន័យនឹងត្រូវធ្វើឡើង ប្រសិនបើរកឃើញថាមានការប្រព្រឹត្តខុស ឬអាកប្បកិរិយាមិនសមរម្យ។

# យន្តការបណ្តឹងត្អូញត្អែររបស់អតិថិជន



## ពាក្យបណ្តឹងត្អូញត្អែរ

(បម្រើជូនចាប់ពីម៉ោង ៧:៣០ ដល់ម៉ោង ១៦:៣០ រៀងរាល់ថ្ងៃធ្វើការ)

- ទូរស័ព្ទ ៖ ០១៥ ៨៨៨ ៦៥៨
- អ៊ីម៉ែល ៖ cmc@acledabank.com.kh

## ការិយាល័យទំនាក់ទំនងអតិថិជន

(បម្រើជូន២៤ម៉ោង)

- ទូរស័ព្ទ ៖ ០២៣ ៩៩៤ ៤៤៤, ០១៥ ៩៩៩ ២៣៣
- អ៊ីម៉ែល ៖ inquiry@acledabank.com.kh
- ឬអញ្ជើញមកកាន់សាខារបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ដែលនៅជិតលោកអ្នកបំផុត ដើម្បីឱ្យយើងខ្ញុំដោះស្រាយបញ្ហាជូនលោកអ្នក ។
- បំពេញព័ត៌មាននៅក្នុងទម្រង់បណ្តឹងត្អូញត្អែររបស់អតិថិជន ។



ការចូលរួមចំណែក UN SDGs

# សុវត្ថិភាពទិន្នន័យ និងឯកជនភាពរបស់អតិថិជន



បច្ចុប្បន្ននេះអាជីវកម្មត្រូវការភ្ជាប់ទំនាក់ទំនងជាមួយភាគីខាងក្រៅបន្ថែមទៀត ដូចជាដៃគូអាជីវកម្ម និងអ្នកផ្តល់សេវាកម្ម ដូចនេះហើយ ការគំរាមកំហែងតាមរយៈអ៊ីនធើណែតនៅតែជាហានិភ័យដ៏សំខាន់សម្រាប់ធនាគារ អេស៊ីលីដា។ សម្ព័ន្ធធនាគារ និងធនាគារ បានប្តេជ្ញាក្នុងការការពារភាពឯកជន និងការរក្សាអាថ៌កំបាំងព័ត៌មានរបស់បុគ្គលិក អតិថិជន ដៃគូអាជីវកម្ម និងបុគ្គលផ្សេងទៀត ។

## វិធីសាស្ត្រគ្រប់គ្រង

ដើម្បីសម្រេចកិច្ចការនេះ សម្ព័ន្ធធនាគារ និងធនាគារ បានកំណត់នូវរចនាសម្ព័ន្ធអភិបាលកិច្ចច្បាស់លាស់ ក្រោមកិច្ចសហការពីក្រុមប្រឹក្សាភិបាល ថ្នាក់គ្រប់គ្រងជាន់ខ្ពស់ និងកម្មករនិយោជិតគ្រប់លំដាប់ថ្នាក់។ នៅក្រោមរចនាសម្ព័ន្ធនេះ ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវក្នុងការពិនិត្យឡើងវិញនូវគោលការណ៍ដែលពាក់ព័ន្ធ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដើម្បីធានាបាននូវការគោរពតាមបទប្បញ្ញត្តិ មិនមានជម្លោះផលប្រយោជន៍ និងទទួលបានការយកចិត្តទុកដាក់ជាពិសេស ។

- ធនាគារបង្កើតឱ្យមានគណៈកម្មាធិការដឹកនាំ និងគ្រប់គ្រងបច្ចេកវិទ្យាព័ត៌មាន (IT Steering Committee) ដើម្បីដឹកនាំ ត្រួតពិនិត្យ និងគ្រប់គ្រងហានិភ័យបច្ចេកវិទ្យា និងធ្វើការកែលម្អជាបន្តបន្ទាប់នៃការអនុវត្តអភិបាលកិច្ចព័ត៌មានវិទ្យា ។
- ការបង្កើតនាយកដ្ឋានសន្តិសុខព័ត៌មាន ដើម្បីត្រួតពិនិត្យ តាមដាន និងពង្រឹងការអនុលោមតាមគោលការណ៍សុវត្ថិភាពបច្ចេកវិទ្យាព័ត៌មានរបស់អ្នកប្រើប្រាស់ និងត្រួតពិនិត្យសុវត្ថិភាពដោយផ្ទាល់ លើការរៀបចំឧបករណ៍បច្ចេកវិទ្យាព័ត៌មានដែលបំពាក់នៅក្នុងមជ្ឈមណ្ឌលទិន្នន័យ ដើម្បីកំណត់ហានិភ័យ និងឈានទៅកំណត់គោលការណ៍ និងនីតិវិធីក្នុងការទប់ស្កាត់ហានិភ័យ និងការពារសុវត្ថិភាពបានទាន់ពេល។
- ដាក់ចេញនូវគោលការណ៍ចាត់ថ្នាក់ទិន្នន័យ ដើម្បីការពារទិន្នន័យរបស់ធនាគារឱ្យបានត្រឹមត្រូវ និងអនុវត្តស្របតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធទាក់ទងនឹងប្រភេទទិន្នន័យផ្សេងៗ។ គោលការណ៍នេះគ្របដណ្តប់លើការគ្រប់គ្រងលើការរក្សាព័ត៌មានសម្ងាត់ សុចរិតភាព ការតាំងបង្ហាញ ឯកជនភាព និងសុវត្ថិភាពនៃទិន្នន័យសំខាន់ៗរបស់ធនាគារ និងទំនួលខុសត្រូវរបស់បុគ្គលគ្រប់រូប។
- ដាក់ចេញនូវគោលការណ៍គ្រប់គ្រងឧប្បត្តិហេតុសន្តិសុខព័ត៌មានវិទ្យា ដើម្បីទប់ស្កាត់ផលប៉ះពាល់រយៈពេលខ្លី និងរយៈពេលវែងដែលរំខានដោយឧប្បត្តិហេតុសន្តិសុខព័ត៌មាន និងការពារមិនឱ្យកើតមានហេតុការណ៍នេះកើតឡើងម្តងទៀតនៅក្នុងធនាគារ។
- ដាក់ចេញគោលការណ៍ បើក អាប់ ជាវិធានសម្រាប់ការបម្រុងទុក និងការផ្ទុកព័ត៌មាន ព្រមទាំងធ្វើឱ្យ ប្រតិបត្តិការអាជីវកម្មកាន់តែប្រសើរឡើង និងជាផែនការយថាភាពអាជីវកម្ម ការស្តារទិន្នន័យ និងកម្មវិធី ក្នុងករណីមានគ្រោះមហន្តរាយ ប្រព័ន្ធមិនដំណើរការ និងចារកម្មប្រព័ន្ធជាដើម។
- ដាក់ចេញនូវគោលការណ៍ឯកជនភាពទិន្នន័យ ដើម្បីការពារឯកជនភាព និងរក្សាការសម្ងាត់ព័ត៌មានផ្ទាល់ខ្លួនរបស់បុគ្គលិក អតិថិជន ដៃគូអាជីវកម្ម និងបុគ្គលផ្សេងទៀតរបស់ធនាគារ អេស៊ីលីដា។

ធនាគារ អេស៊ីលីដា បានប្រកាសជូនដំណឹងពី ច្បាប់ និងឯកជនភាព ដើម្បីជូនដំណឹងដល់អតិថិជន និងសាធារណជនទាំងអស់អំពីការប្រើប្រាស់ និងការកំណត់ឯកជនភាពនៃព័ត៌មាន ឬទិន្នន័យ ស្របពេលដែលធនាគារប្រកាន់ខ្ជាប់នូវការអនុវត្តយ៉ាងម៉ឺងម៉ាត់ចំពោះគោលការណ៍ឯកជនភាពទិន្នន័យ និងគោលការណ៍សន្តិសុខព័ត៌មានវិទ្យារបស់ធនាគារទាំងមូល ។ កម្មករនិយោជិតទាំងអស់របស់ធនាគារ និងអ្នកផ្តល់សេវាកម្ម ដែលបានចុះកិច្ចសន្យារបស់ខ្លួន គឺតម្រូវឱ្យប្រកាន់ខ្ជាប់នូវគោលការណ៍ និងនីតិវិធីដែលពាក់ព័ន្ធទាំងអស់ រួមមានការគ្រប់គ្រង ការការពារ ការប្រមូលព័ត៌មាន ឬទិន្នន័យរបស់អតិថិជន បុគ្គលិក និងព័ត៌មានផ្ទាល់ខ្លួនដទៃទៀត ដូចដែលបានកំណត់ដោយច្បាប់។

ដើម្បីទប់ស្កាត់ការបំពាន និងការចូលប្រើប្រាស់ព័ត៌មានផ្ទាល់ខ្លួនដោយគ្មានការអនុញ្ញាត វិធានការពារសមស្របត្រូវបានដាក់នៅពេលប្រើប្រាស់ ផ្ទើ ឬផ្ទេរទិន្នន័យនោះ។ ធនាគារតម្រូវឱ្យមានការយល់ព្រមពីអតិថិជនមុនពេលផ្តល់ ឬចែករំលែកព័ត៌មានផ្ទាល់ខ្លួនជាមួយអ្នកខាងក្រៅ រួមទាំង ក្រេឌីត ប្យូរ៉ូផងដែរ ។

## ការបង្កើតវប្បធម៌យល់ដឹងអំពីហានិភ័យតាមអ៊ីនធើណែត

ដើម្បីជួយឱ្យកម្មករនិយោជិតអាចដោះស្រាយ និងឆ្លើយតបចំពោះករណីនៃការរំលោភបំពានទៅលើឯកជនភាពប្រកបដោយប្រសិទ្ធភាព និង សមស្រប ធនាគារបានដាក់ចេញនូវគោលការណ៍សន្តិសុខព័ត៌មានវិទ្យា និងគោលការណ៍ផ្សេងទៀត។ លើសពីនេះ ធនាគារក៏បានយកចិត្តទុកដាក់ទៅលើការលើកកម្ពស់ការយល់ដឹងរបស់កម្មករនិយោជិតតាមរយៈការបណ្តុះបណ្តាល ការទំនាក់ទំនង និងសកម្មភាពដែលជាប់លាប់ ។

### ១- ក្រុមប្រឹក្សាភិបាល និងថ្នាក់គ្រប់គ្រងជាន់ខ្ពស់

- ការគ្រប់គ្រងសន្តិសុខព័ត៌មានវិទ្យា ការគ្រប់គ្រងហានិភ័យបច្ចេកវិទ្យាព័ត៌មាន និងបញ្ហាបច្ចេកវិទ្យាព័ត៌មានសំខាន់ៗផ្សេងទៀតត្រូវបានរាយការណ៍ទៅក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងព័ត៌មានវិទ្យា ប្រចាំត្រីមាស។
- គណៈគ្រប់គ្រងជាន់ខ្ពស់ របស់ធនាគារ អេស៊ីលីដា គ្រប់រូបបានចូលរួមក្នុងការធ្វើតេស្តសាកល្បងអំពីសន្តិសុខព័ត៌មានវិទ្យា ដើម្បីដឹងពីឧប្បត្តិហេតុបែបនេះ និងបង្កើតជានីតិវិធី ដែលពួកគេអាចធ្វើការដោះស្រាយ ជាមួយនឹងការគំរាមកំហែងណាមួយនាពេលអនាគត។

### ២- កម្មករនិយោជិត

- ការសិក្សា និងការធ្វើតេស្ត តាមប្រព័ន្ធអេឡិកត្រូនិក លើការគ្រប់គ្រងសុវត្ថិភាពទិន្នន័យ ត្រូវបានរៀបចំសម្រាប់បុគ្គលិកគ្រប់រូប។
- ដើម្បីធានាថាបុគ្គលិករបស់ធនាគារទាំងអស់មានការយល់ដឹង និងការយល់កាន់តែច្បាស់អំពីការគំរាមកំហែងតាម ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ព្រឹត្តិបត្រព័ត៌មានស្តីពីគន្លឹះសុវត្ថិភាព និងការជូនដំណឹងអំពីសុវត្ថិភាពត្រូវបានចេញផ្សាយជាទៀងទាត់នៅលើអេក្រង់កុំព្យូទ័ររបស់បុគ្គលិកទាំងអស់។
- ការធ្វើតេស្តសាកល្បងត្រូវបានអនុវត្តទៀងទាត់ គ្រប់កម្មករនិយោជិតរបស់ធនាគារ អេស៊ីលីដា និងក្រុមហ៊ុនបុត្រសម្ព័ន្ធបានទទួលនូវអ៊ីម៉ែលក្លែងក្លាយដែលជាមធ្យោបាយមួយដើម្បីអាចឱ្យពួកគេធ្វើតេស្ត ពង្រឹងនូវការយល់ដឹង និងផ្តល់ការបណ្តុះបណ្តាលដល់ពួកគេអំពីរបៀបដោះស្រាយ និងគ្រប់គ្រងស្ថានការណ៍។ យោងតាមលទ្ធផលលំហាត់នៃការធ្វើតេស្តនេះ កម្មករនិយោជិតគ្រប់រូបកាន់តែមានការប្រុងប្រយ័ត្ន និងយល់ច្បាស់អំពីអ៊ីម៉ែលក្លែងបន្លំ។

## របាយការណ៍អំពីការអនុវត្តសន្តិសុខព័ត៌មានវិទ្យា

ក្នុងឆ្នាំ២០២៣ មិនមានឧប្បត្តិហេតុនៃការលេចធ្លាយ ការលួច ឬការបាត់បង់ទិន្នន័យរបស់អតិថិជនណាមួយ ដែលជាលទ្ធផលនៃការគំរាមកំហែងសន្តិសុខព័ត៌មានវិទ្យាត្រូវបានរាយការណ៍នោះទេ ។

## ការយល់ដឹងអំពីសុវត្ថិភាពបច្ចេកវិទ្យាព័ត៌មាន

នៅក្នុងឆ្នាំ២០២៣ នាយកដ្ឋានសន្តិសុខព័ត៌មានវិទ្យា បានបើកវគ្គបណ្តុះបណ្តាលផ្នែកសន្តិសុខព័ត៌មានវិទ្យាចំនួន ២.៥៦៨ វគ្គ ដល់នាយកប្រតិបត្តិ និងកម្មករនិយោជិតរបស់ធនាគារ អេស៊ីលីដាគ្រប់លំដាប់ ដើម្បីធានាបាននូវការយល់ដឹង និងស្គាល់ពីការគំរាមកំហែងសន្តិសុខព័ត៌មានវិទ្យា ស្របតាមបទប្បញ្ញត្តិ និងគោលការណ៍សន្តិសុខព័ត៌មានរបស់ធនាគារ។

# ការគ្រប់គ្រងហានិភ័យ

ការចូលរួមចំណែក UN SDGs

ស្ថិតក្នុងមជ្ឈដ្ឋានអាជីវកម្មដែលមានការវិវត្តន៍ និងរីកលូតលាស់យ៉ាងឆាប់រហ័សបច្ចេកវិទ្យា និងការផ្លាស់ប្តូរនៃច្បាប់ សម្ព័ន្ធធនាគារ និងធនាគារយល់ច្បាស់ថា ប្រតិបត្តិការអាជីវកម្មនាពេលបច្ចុប្បន្ននេះ អាចជាប់ពាក់ព័ន្ធនឹងការប្រែប្រួល និងភាពមិនច្បាស់លាស់ពីកត្តាខាងក្នុង និងខាងក្រៅដែលកត្តាមួយចំនួនមិនអាចគ្រប់គ្រងបាន ដូចជា ការរាតត្បាតនៃជំងឺកូវីដ ១៩ សេដ្ឋកិច្ចជាតិ និងអន្តរជាតិ បញ្ហាអាកាសធាតុដែលមិនអាចទាយទុកជាមុនបាន ការផ្លាស់ប្តូរច្បាប់ និងតម្រូវការបទប្បញ្ញត្តិ ។ល។ កត្តាទាំងនេះភាគច្រើនមានផលប៉ះពាល់ជាវិជ្ជមាន ឬអវិជ្ជមានលើសម្ព័ន្ធធនាគារ និងប្រតិបត្តិការរបស់ធនាគារ ។

## វិធីសាស្រ្តគ្រប់គ្រង

ធនាគារ អេស៊ីលីដា ផ្តល់សារៈសំខាន់ទៅលើការគ្រប់គ្រងហានិភ័យ ខណៈដែលជឿជាក់ថា ការកំណត់បាននូវអត្តសញ្ញាណហានិភ័យមុនពេលកើតឡើង និងការសម្របខ្លួនទៅនឹងការផ្លាស់ប្តូរនាពេលអនាគត អាចជួយឱ្យធនាគារអាចគ្រប់គ្រង និងកាត់បន្ថយហានិភ័យដែលអាចកើតមានបានទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាព ។

- ធនាគារដាក់បញ្ចូលការគ្រប់គ្រងហានិភ័យទៅក្នុងដំណើរការអាជីវកម្មទាំងអស់ ដោយប្រកាន់ខ្ជាប់នូវរចនាសម្ព័ន្ធអភិបាលកិច្ចហានិភ័យដែលបានបង្កើតឡើង ស្របតាមតួនាទី និងការទទួលខុសត្រូវរបស់កម្មករនិយោជិតគ្រប់លំដាប់ថ្នាក់ ដើម្បីឱ្យការគ្រប់គ្រងហានិភ័យប្រកបដោយប្រសិទ្ធភាព ។
- ក្រុមប្រឹក្សាភិបាលមានទំនួលខុសត្រូវទៅលើការអនុម័ត និងពិនិត្យឡើងវិញលើគោលការណ៍គ្រប់គ្រងហានិភ័យ និងវិសអាប់តៃថាយ ដោយគិតគូរពីហានិភ័យសំខាន់ៗ ផ្អែកតាមចរិកលក្ខណៈ ប្រភេទ និងកម្រិតហានិភ័យដែលធនាគារអាចទទួលយក ព្រមទាំងផ្តល់នូវវិធីសាស្រ្តក្នុងការគ្រប់គ្រងហានិភ័យទាំងនោះផងដែរ។
- គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងព័ត៌មានវិទ្យា (BRIC) ត្រូវបានចាត់តាំងដោយក្រុមប្រឹក្សាភិបាល ទទួលខុសត្រូវទៅលើការត្រួតពិនិត្យ និងលើកកម្ពស់ការគ្រប់គ្រងហានិភ័យរបស់ធនាគារ ដោយធ្វើការត្រួតពិនិត្យប្រចាំឆ្នាំអំពីភាពគ្រប់គ្រាន់នៃក្របខណ្ឌគ្រប់គ្រងហានិភ័យ ដែលជាគោលនយោបាយកម្រិតខ្ពស់របស់ធនាគារ ក្នុងការកំណត់អត្តសញ្ញាណហានិភ័យ ការវាយតម្លៃហានិភ័យ ការកាត់បន្ថយហានិភ័យ ការត្រួតពិនិត្យ និងការរាយការណ៍អំពីហានិភ័យ ។
- ធនាគារបានដាក់ចេញនូវគោលការណ៍គ្រប់គ្រងហានិភ័យ ដែលជាស្តង់ដារសម្រាប់ការគ្រប់គ្រងហានិភ័យរបស់ធនាគារទាំងមូល ក្នុងគោលបំណងធ្វើឱ្យការគ្រប់គ្រងហានិភ័យមានប្រសិទ្ធភាព និងដើម្បីបន្ថែមតម្លៃចំពោះធនាគារ ។ គោលការណ៍នេះបានបែងចែកប្រភេទហានិភ័យផ្សេងៗគ្នា ស្របទៅតាមប្រភេទដែលបានកំណត់ដោយស្តង់ដារ Basel ។
- បង្កើតឱ្យមាននាយកដ្ឋានគ្រប់គ្រងហានិភ័យ ដើម្បីធានាថាហានិភ័យជាសារវន្ត ដែលមានចែងក្នុងគោលការណ៍គ្រប់គ្រងហានិភ័យត្រូវបានកំណត់ វាស់វែង ត្រួតពិនិត្យ និងរាយការណ៍ប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលា ។
- បង្កើត "ម៉ូដែលខ្សែបន្ទាត់ទាំងបី" ដែលជារចនាសម្ព័ន្ធទាក់ទងនឹងការគ្រប់គ្រង និងត្រួតពិនិត្យហានិភ័យនៅក្នុងធនាគារ ដោយកំណត់ច្បាស់លាស់ពីតួនាទី និងការទទួលខុសត្រូវផ្សេងៗគ្នា និងទំនាក់ទំនងរវាងតួនាទីទាំងនោះ។

### ដំណើរការគ្រប់គ្រងហានិភ័យ

ដំណើរការនៃការគ្រប់គ្រងហានិភ័យរបស់ធនាគារ រួមមានការកំណត់អត្តសញ្ញាណហានិភ័យ ការវាយតម្លៃ ការត្រួតពិនិត្យ និងការរាយការណ៍ ។

## ការកំណត់អត្តសញ្ញាណហានិភ័យ

ដំណើរការនៃកំណត់អត្តសញ្ញាណហានិភ័យរបស់ធនាគារ ចាប់ផ្តើមពីការកំណត់នូវហេតុការណ៍ដែលអាចនឹងកើតឡើង និងអាចបណ្តាលឱ្យមានការបាត់បង់ ដែលប្រមើលមើលទាក់ទងនឹង តើវាអាចកើតឡើងយ៉ាងដូចម្តេច នៅទីកន្លែងណា និងមូលហេតុអ្វី ដែលបណ្តាលឱ្យមានហេតុការណ៍ទាំងនោះកើតឡើង ។ លើសពីនោះទៀត ការកំណត់អត្តសញ្ញាណហានិភ័យដែលប្រឈមដោយធនាគារ ត្រូវបានកំណត់ដោយការវាយតម្លៃទៅលើកត្តាមនុស្ស ដំណើរការ ប្រព័ន្ធ ផលិតផល និងព្រឹត្តិការណ៍ខាងក្រៅ ដែលអាចជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរ ដល់យុទ្ធសាស្ត្រអាជីវកម្ម និង កម្រងហានិភ័យរបស់ធនាគារ។

## ការវាយតម្លៃ

ហានិភ័យដែលត្រូវបានកំណត់អត្តសញ្ញាណ ចាំបាច់ត្រូវវាយតម្លៃ និងវាស់វែង។ ការវាយតម្លៃហានិភ័យ ឬការវាស់វែងអាចឱ្យធនាគារពិចារណាពីវិសាលភាពនៃហេតុការណ៍សក្តានុពលដែលអាចប៉ះពាល់ដល់ដំណើរការសម្រេចបាន ដោយផ្អែកលើពីរលក្ខខណ្ឌ (១) លទ្ធភាពដែលអាចកើតឡើង និង (២) ផលប៉ះពាល់នៃហានិភ័យជាសារវន្តមកលើធនាគារ ដែលជាធម្មតាត្រូវបានប្រើប្រាស់ដោយការរួមបញ្ចូលគ្នានៃហានិភ័យដែលអាចវាស់វែងបាន និងហានិភ័យដែលមិនអាចវាស់វែងបាន។ លើសពីនេះ ហានិភ័យដែលបានកំណត់ ត្រូវបានដាក់ទៅក្នុងរបាយការណ៍ហានិភ័យដែលមានបីកម្រិត ខ្ពស់ មធ្យម និងទាប ដោយផ្អែកលើលទ្ធភាពដែលអាចកើតមានឡើង ផលប៉ះពាល់ និងប្រសិទ្ធភាពនៃការគ្រប់គ្រង។

## ការកាត់បន្ថយហានិភ័យ

លទ្ធផលបានមកពីការវាយតម្លៃហានិភ័យ ត្រូវបានប្រើជាមូលដ្ឋានដើម្បីស្វែងរកវិធានការសមស្រប ក្នុងការកាត់បន្ថយហានិភ័យដែលបានកំណត់ទាំងនោះ ជម្រើសក្នុងការចាត់វិធានការត្រូវស្របទៅនឹងវិសអាប់ភៃថាយ និងការវិភាគអំពីផលចំណេញ-ខាតនៃការអនុវត្តវិធានការកាត់បន្ថយ ។ វិធានការកាត់បន្ថយហានិភ័យជាសារវន្ត រួមមាន៖

១

### ការទទួលយកហានិភ័យ

ហានិភ័យដែលមានផលប៉ះពាល់តិចតួចបំផុត ឬដោយសារតែអត្ថប្រយោជន៍ដែលទទួលបានធំជាងហានិភ័យ ដូច្នេះធនាគារអាចទទួលយកហានិភ័យនោះ ។

២

### ការកាត់បន្ថយហានិភ័យ

ហានិភ័យដែលមានផលប៉ះពាល់ខ្លាំងដល់ធនាគារហើយ ធនាគារមានវិធានការក្នុងការដោះស្រាយគ្រប់គ្រាន់ និង ចំណាយថ្លៃដើមទាប ដូច្នេះធនាគារអាចជ្រើសរើសវិធីសាស្រ្តនៃការកាត់បន្ថយហានិភ័យ ។

៣

### ការផ្ទេរហានិភ័យ

ហានិភ័យដែលមានផលប៉ះពាល់ខ្លាំងដល់ធនាគារ ដោយសារខ្វះជំនាញក្នុងការគ្រប់គ្រង ថ្លៃដើមក្នុងការគ្រប់គ្រងខ្ពស់ ការខាតបង់ខ្ពស់ ដូច្នេះធនាគារអាចផ្ទេរហានិភ័យទៅភាគីដទៃទៀតដូចជាការទិញធានារ៉ាប់រង ។

៤

### ការចៀសវាងពីហានិភ័យ

ហានិភ័យដែលមានការគំរាមកំហែងខ្លាំងបំផុតដល់អាជីវកម្ម ឬហានិភ័យដែលមានកម្រិតលើសពី វិសអាប់ភៃថាយ ដែលអាចបណ្តាលឲ្យមានការបញ្ឈប់ប្រតិបត្តិការ-ប្រព័ន្ធ ថ្លៃដើមក្នុងការគ្រប់គ្រងខ្ពស់ និងមិនមានដំណោះស្រាយគ្រប់គ្រាន់ក្នុងការផ្ទេរហានិភ័យ ដូច្នេះធនាគារអាចជ្រើសរើសវិធីសាស្រ្តនៃការជៀសវាងពីហានិភ័យ ។

## ប្រភេទហានិភ័យរបស់ធនាគារ




## វិធីសាស្ត្រគ្រប់គ្រងហានិភ័យ

ដើម្បីកំណត់ និងគ្រប់គ្រងហានិភ័យប្រកបដោយប្រសិទ្ធភាព ធនាគារបានបង្កើតវិធីសាស្ត្រ "ម៉ូដែលខ្សែបន្ទាត់ទាំងបី" ដែលជារចនាសម្ព័ន្ធទាក់ទងនឹងការគ្រប់គ្រងហានិភ័យ និងការត្រួតពិនិត្យនៅក្នុងធនាគារ ដោយកំណត់តួនាទី និងការទទួលខុសត្រូវក្នុងតួនាទីផ្សេងៗគ្នា និងទំនាក់ទំនងរវាងតួនាទីផ្សេងៗគ្នាទាំងនោះ។

## ម៉ូដែលខ្សែបន្ទាត់ទាំងបី

### ១- តួនាទីខ្សែបន្ទាត់ទីមួយ

តួនាទីខ្សែបន្ទាត់ទីមួយ គឺសំដៅលើផ្នែកប្រតិបត្តិការអាជីវកម្ម និងគាំទ្រអាជីវកម្មដែលជាម្ចាស់ហានិភ័យដែលទទួលខុសត្រូវក្នុងការស្វែងយល់ និងគ្រប់គ្រងហានិភ័យ ប្រតិបត្តិការអាជីវកម្មប្រចាំថ្ងៃរបស់ធនាគារ។

### ២- តួនាទីខ្សែបន្ទាត់ទីពីរ

តួនាទីខ្សែបន្ទាត់ទីពីរ គឺសំដៅទៅនាយកដ្ឋានគ្រប់គ្រងហានិភ័យ ទទួលខុសត្រូវក្នុងការបង្កើតវិធីសាស្ត្រ ទម្រង់គំរូ និងនីតិវិធី ព្រមទាំងផ្តល់ការបណ្តុះបណ្តាល និងផ្តល់ការណែនាំដល់ខ្សែបន្ទាត់ទីមួយដើម្បីអនុវត្តដំណើរការគ្រប់គ្រងហានិភ័យ។

### ៣- តួនាទីខ្សែបន្ទាត់ទីបី

សវនកម្មផ្ទៃក្នុង ដែលជាតួនាទីខ្សែបន្ទាត់ទីបី ទទួលខុសត្រូវក្នុងការត្រួតពិនិត្យឡើងវិញដោយឯករាជ្យ និងធ្វើការត្រួតពិនិត្យមើលជាទៀងទាត់ទៅលើការអនុវត្តសកម្មភាពអាជីវកម្ម និងប្រតិបត្តិការរបស់ធនាគារ។

រចនាសម្ព័ន្ធអភិបាលកិច្ចហានិភ័យ ធនាគារ អេស៊ីលីដា ភីអិលស៊ី




- ធនាគារបានដាក់ចេញនូវរចនាសម្ព័ន្ធអភិបាលកិច្ចហានិភ័យ និងការបែងចែកម្ចាស់ហានិភ័យ ស្របទៅតាមមុខងារអាជីវកម្ម ដើម្បីគ្រប់គ្រងហានិភ័យបានទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាព ។
- ដាក់ចេញនូវវិសអាប់ភែថាយ និងសូចនាករហានិភ័យសំខាន់ៗ ដើម្បីជាក្របខណ្ឌក្នុងការកំណត់អត្តសញ្ញាណ វាស់វែង កាត់បន្ថយ តាមដាន និងរាយការណ៍ហានិភ័យសំខាន់ៗនៅទូទាំងធនាគារ ។
- អនុវត្តការវាយតម្លៃហានិភ័យជាសារវន្តជារៀងរាល់ឆ្នាំ ដើម្បីគ្រប់គ្រងហានិភ័យរបស់ធនាគារប្រកបដោយប្រសិទ្ធភាព និងដើម្បីកំណត់បាននូវហានិភ័យមុនពេលកើតមានឡើង ព្រមទាំងកាត់បន្ថយហានិភ័យដែលអាចកើតមានបានត្រឹមត្រូវ និងទាន់ពេលវេលា ។
- ដាក់ចេញនូវ ការវាយតម្លៃហានិភ័យ និងប្រព័ន្ធត្រួតពិនិត្យដោយខ្លួនឯង (RCSA) និង សូចនាករហានិភ័យសំខាន់ៗ (KRI) ជាឧបករណ៍ និងវិធីសាស្ត្រក្នុងការត្រួតពិនិត្យ និងវាយតម្លៃលើទិដ្ឋភាពផ្សេងៗ នៃមុខងារអាជីវកម្មទាំងអស់របស់ធនាគារ ។

ការចូលរួមចំណែក UN SDGs

# ការអភិវឌ្ឍផលិតផល និងនវានុវត្តន៍ឌីជីថល

ធនាគារ អេស៊ីលីដា យល់ច្បាស់អំពីសារៈសំខាន់នៃការកសាងសមត្ថភាពប្រកួតប្រជែង តាមរយៈការជម្រុញនវានុវត្តន៍ និងបច្ចេកវិទ្យានាពេលបច្ចុប្បន្ននេះ ។ ធនាគារបានការកែលម្អ និងធ្វើឱ្យសេវាកម្មឌីជីថល កាន់តែមានភាពងាយស្រួលចំពោះអតិថិជនក្នុងការប្រើប្រាស់ ដោយបន្តអភិវឌ្ឍន៍ផលិតផល និងសេវាកម្មថ្មីៗ និងធ្វើបច្ចុប្បន្នភាពលើផលិតផល និងសេវាកម្មឌីជីថលដែលមានស្រាប់។ បន្ថែមពីនេះ ធនាគារ អេស៊ីលីដា មានផែនការកាត់បន្ថយចំនួនសាខាបច្ចុប្បន្ន និងជំនួសមកវិញដោយការបង្កើនចំនួនការិយាល័យធនាគារស្វ័យប្រវត្តិ (Self Service Banking) ដែលបំពាក់ទៅដោយម៉ាស៊ីន និងអាចគាំទ្រប្រតិបត្តិការរបស់អតិថិជនបាន ២៤/៧ ទាំងនៅរាជធានីភ្នំពេញ និងនៅតាមបណ្តាខេត្តនានា។

## វិធីសាស្ត្រគ្រប់គ្រង

ធនាគារកំពុងអភិវឌ្ឍន៍ប្រព័ន្ធទូទាត់ដែលអាចឱ្យដៃគូទាំងក្នុង និងក្រៅប្រទេសអាចភ្ជាប់ប្រព័ន្ធនេះ ដើម្បីបម្រើអតិថិជនទៅវិញទៅមក និងឆ្លងព្រំដែន។ ប្រព័ន្ធនេះមិនត្រឹមតែផ្តល់អត្ថប្រយោជន៍ដោយផ្ទាល់ដល់អតិថិជនដ៏ឆ្លាតវៃរបស់យើងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដល់ដៃគូរអាជីវកម្ម របស់ពួកគាត់ផងដែរ។ ទន្ទឹមនឹងនោះដែរ ការវិវឌ្ឍរបស់អេស៊ីលីដា ម៉ូបាល បានទទួលប្រជាប្រិយភាពកាន់តែខ្លាំង ដែលគិតត្រឹមដំណាច់ខែធ្នូ ឆ្នាំ២០២៣ ចំនួននៃអ្នកដែលបានចុះឈ្មោះប្រើប្រាស់បានកើនដល់ ៣,៣ លាននាក់ នេះជាកត្តាដែលអាចជួយឱ្យចរាចរសាច់ប្រាក់បានឆាប់រហ័សនៅក្នុងសេដ្ឋកិច្ច។

ធនាគារគាំទ្រដល់ការអភិវឌ្ឍនវានុវត្តន៍ និង ឌីជីថលដោយផ្អែកលើវិធីសាស្ត្រគ្រប់គ្រងដូចខាងក្រោម៖

- ការបង្កើតឱ្យមានគណៈកម្មាធិការគ្រប់គ្រងវិនិយោគ ដើម្បីគ្រប់គ្រងគម្រោង និងការវិនិយោគទាំងអស់ បានទាន់ពេលវេលា ស្របតាមតម្រូវការទីផ្សារ និងស្របតាមផែនការយុទ្ធសាស្ត្ររបស់ធនាគារ ព្រមទាំងបម្រុងទុកនូវធនធាន ឧបករណ៍ និងសម្ភារៈឱ្យបានគ្រប់គ្រាន់ ដើម្បីគាំទ្រដល់ដំណើរការអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធភាព។
- ដាក់ចេញនូវគោលការណ៍ប្រតិបត្តិ ស្តីពីការអភិវឌ្ឍផលិតផល-សេវាកម្ម ដើម្បីអភិវឌ្ឍន៍ និងកែលម្អផលិតផល និងហេដ្ឋារចនាសម្ព័ន្ធព័ត៌មានវិទ្យាយ៉ាងទូលំទូលាយ រួមទាំងការវិនិយោគលើការអភិវឌ្ឍផលិតផលថ្មី ការកែលម្អផលិតផលដែលមានស្រាប់ ការអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាថ្មី ឬទំនើបកម្មនៃបច្ចេកវិទ្យា ភាពងាយស្រួល និងសុវត្ថិភាពខ្ពស់ ដើម្បីឆ្លើយតបទៅតាមតម្រូវការទីផ្សារ ។

### ដំណើរការអភិវឌ្ឍផលិតផល

| ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ |
|---|---|---|---|---|---|---|
| ការផ្តួចផ្តើម | ការធ្វើផែនការ | ការរចនា | ការអនុវត្ត | ការកំណត់ថ្លៃសេវា | ដំណើរការត្រួតពិនិត្យការអនុវត្តគម្រោង | ការបិទគម្រោង |

- ធនាគារបានដាក់ចេញនូវគោលការណ៍ប្រតិបត្តិស្តីពី Software Development Project Management ដើម្បីជាគោលការណ៍ណែនាំសម្រាប់អ្នកពាក់ព័ន្ធដើម្បីអនុវត្តដោយយោងលើដំណាក់កាលផ្សេងៗនៃគម្រោង។ គោលការណ៍នេះបានគូសបញ្ជាក់អំពីសកម្មភាព ព្រឹត្តិការណ៍សំខាន់ៗ និងការប្រគល់ជូនដែលពាក់ព័ន្ធក្នុងដំណើរការគ្រប់គ្រងគម្រោង។ ដំណើរការ Software Development Project Management ត្រូវបានរៀបចំជាប្រាំដំណាក់កាលគឺ ការផ្តួចផ្តើម ការធ្វើផែនការ ការរចនា ការអនុវត្ត និងការបិទគម្រោង ។
- ធ្វើការចង្អុលបង្ហាញ និងអប់រំដល់កម្មករនិយោជិតទាំងអស់អំពីការអភិវឌ្ឍផលិតផល និងបច្ចេកវិទ្យាថ្មីៗ ដើម្បីបង្កើននូវសក្តានុពល និងរៀបចំរបៀបធ្វើការងារថ្មីៗ ដូចជាសិក្សា និងប្រើប្រាស់នូវបច្ចេកវិទ្យាថ្មីៗ និងការវិភាគទិន្នន័យ វិធីសាស្រ្តគ្រប់គ្រងដែលរហ័ស វិធីសាស្រ្ត Scrum និងភាពច្នៃប្រឌិត សម្រាប់ភាពជោគជ័យរយៈពេលវែង ។
- ផ្តួចផ្តើមក្នុងការអភិវឌ្ឍ និងទទួលយកនូវនវានុវត្តន៍ និងបច្ចេកវិទ្យាឌីជីថលនៅក្នុងដំណើរការប្រតិបត្តិការ និងសេវាកម្មអតិថិជនរបស់ធនាគារ ដើម្បីធានាបាននូវបទពិសោធន៍វិជ្ជមានសម្រាប់បុគ្គលិក អតិថិជន និងអ្នកពាក់ព័ន្ធ។

- កម្មវិធីធនាគារចល័ត (Mobile App) បង្ហាញពីភាពពេញនិយម និងភាពប្រកួតប្រជែងរបស់ខ្លួន នៅក្នុងយុគសម័យឌីជីថល ដោយក្នុងនោះមានធនាគារប្រហែល ពីរភាគបី (២/៣) បើកដំណើរការកម្មវិធីរបស់ពួកគេ។
- អេស៊ីលីដា ម៉ូបាល ត្រូវបានរចនាឡើង ដើម្បីបំពេញនូវតម្រូវការហិរញ្ញវត្ថុរបស់អតិថិជនគ្រប់វ័យ។ អតិថិជនអាចប្រើប្រាស់ អេស៊ីលីដា ម៉ូបាលនៅគ្រប់ទីកន្លែង ដែលមានវ៉ាយហ្វាយ (WiFi)/ អ៊ិនធើណែត ស្កេន KHQR/QR ក្នុងប្រទេសកម្ពុជាទូទាំងប្រទេស និងការទូទាត់ឆ្លងប្រទេសជាមួយ QR ក្នុងប្រទេសថៃ វៀតណាម ឡាវ។ល។
- ធនាគារបានរចនា អេស៊ីលីដា ម៉ូបាល ដោយគិតគូរពីអត្ថប្រយោជន៍ដែលធនាគារអាចផ្តល់ជូនអ្នកប្រើប្រាស់ រួមមានភាពងាយស្រួល រហ័ស និងសុវត្ថិភាពខ្ពស់ កាត់បន្ថយការចំណាយ និងចំណេញពេលវេលាដោយមិនចាំបាច់ទៅធនាគារព្រមទាំង កាត់បន្ថយហានិភ័យនៃការយកសាច់ប្រាក់តាមខ្លួនសម្រាប់ការទូទាត់ ក៏ដូចជាកាត់បន្ថយការប្រើប្រាស់ក្រដាសឯកសារតាមរយៈសេវាកម្មឌីជីថល។







- ក្នុងឆ្នាំ២០២២ ធនាគារបានទទួល “ពានរង្វាន់ឈានមុខផ្នែកនវានុវត្តន៍ទិន្នន័យ” ពីក្រុមហ៊ុនក្រេឌីត ប្យូរ៉ូ (ខេមបូឌា) ខូអិលធីឌី នៅក្នុងឱកាសខួប១០ឆ្នាំ របស់ក្រុមហ៊ុនក្រេឌីត ប្យូរ៉ូ (ខេមបូឌា)។ ធនាគារមានមោទនភាពយ៉ាងក្រៃលែងដែលបានទទួលពានរង្វាន់នេះ ដោយសារធនាគារឈានមុខគេផ្នែកនវានុវត្តន៍ទិន្នន័យនៅក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ ជាពិសេសប្រសិទ្ធភាពក្នុងការចែករំលែកព័ត៌មានឥណទាននៅកម្ពុជា។

# អំពីរបាយការណ៍ចីរភាព

នេះគឺជា របាយការណ៍ចីរភាពរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ដែលអនុវត្តលើឆ្នាំហិរញ្ញវត្ថុ ២០២៣។ របាយការណ៍នេះគ្របដណ្តប់លើព័ត៌មានរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី (“ធនាគារ”) និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួន (ហៅជារួមថាជា “សម្ព័ន្ធ”) ដែលប្រតិបត្តិការក្នុងអំឡុងថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ។

## ព័ត៌មានអំពីហិរញ្ញវត្ថុ និងអភិបាលកិច្ច

ការអនុវត្តរបស់របស់សម្ព័ន្ធធនាគារ និងធនាគារ ដែលស្របតាមរបាយការណ៍ប្រចាំឆ្នាំ២០២៣ ។

## ព័ត៌មានអំពីបរិស្ថាន

### ដែនកំណត់នៃការរាយការណ៍

ការបំភាយឧស្ម័នផ្ទះកញ្ចក់ដោយផ្ទាល់ និងការបំភាយឧស្ម័នផ្ទះកញ្ចក់ដោយប្រយោល ពីការប្រើប្រាស់អគ្គិសនី ត្រូវបានរាយការណ៍ដោយធនាគារអេស៊ីលីដាការិយាល័យកណ្តាល គ្រប់សាខា និងបុត្រសម្ព័ន្ធ ដែលធនាគារ អេស៊ីលីដា គ្រប់គ្រងប្រតិបត្តិការ និងតាមរយៈការធ្វើអាជីវកម្ម ធនាគារ និងហិរញ្ញវត្ថុ ឬផ្តល់សេវាគាំទ្រដល់អាជីវកម្មបែបនេះ។

### ការបំភាយឧស្ម័នផ្ទះកញ្ចក់ (GHG)

ការបំភាយឧស្ម័នផ្ទះកញ្ចក់ដែលបានបង្ហាញនៅក្នុងរបាយការណ៍គឺបានមកពីប្រតិបត្តិការ និងសកម្មភាពរបស់ធនាគារអេស៊ីលីដា ហើយគណនាដោយផ្អែកទៅតាម Intergovernmental Panel on Climate Change 2006 (IPCC) and greenhouse gas protocol។

តួលេខនៃការបំភាយឧស្ម័នផ្ទះកញ្ចក់ទាំងអស់គឺគិតជាតោន នៃសមមូលឧស្ម័នកាបូនិក ។

### វិធីសាស្ត្រគណនា

១- ការគណនា វិសាលភាព ១ ការបំភាយឧស្ម័នផ្ទះកញ្ចក់ដោយផ្ទាល់ គឺផ្អែកលើការប្រើប្រាស់ប្រេងឥន្ធនៈ (ទម្ងន់ ឬបរិមាណ) ឧ. បរិមាណប្រេងសាំង/សាំង និងម៉ាស៊ូត គុណនឹងកត្តាបំភាយរបស់វា។

២- ការគណនា វិសាលភាព ២ ការបំភាយឧស្ម័នផ្ទះកញ្ចក់ដោយប្រយោល គឺផ្អែកលើបរិមាណអគ្គិសនីដែលបានទិញ ឬប្រើប្រាស់ គុណនឹងកត្តាបំភាយ ។

៣- ការគណនា វិសាលភាព ៣ ការបំភាយឧស្ម័នផ្ទះកញ្ចក់ដោយប្រយោល មិនត្រូវបានអនុវត្តនៅក្នុងរបាយការណ៍នេះទេ។

## ព័ត៌មានអំពីសង្គម

### ចំនួនកម្មករនិយោជិតធនាគារ អេស៊ីលីដា ភីអិលស៊ី

កម្មករនិយោជិតទាំងអស់ ជាបុគ្គលិកស្ថិតក្រោមកិច្ចសន្យាការងារជាមួយធនាគារ អេស៊ីលីដា ភីអិលស៊ី។ ពួកគេត្រូវបានបែងចែកជាប្រាំក្រុមដូចខាងក្រោមៈ

១- អ្នកគ្រប់គ្រងជាន់ខ្ពស់៖ រួមមានប្រធាននាយកប្រតិបត្តិ និងអនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិ។

២- អ្នកគ្រប់គ្រងថ្នាក់កណ្តាល៖ រួមមាន នាយក-នាយិកាប្រតិបត្តិនាយកដ្ឋាន នាយក-នាយិកាការិយាល័យ និងនាយក-នាយិកាសាខា "ក"។

៣- អ្នកគ្រប់គ្រងជួរមុខ៖ រួមមាន នាយក-នាយិកាប្រតិបត្តិរង ជំនួយការនាយក-នាយិកាប្រតិបត្តិ ជំនួយការនាយក-នាយិកាការិយាល័យ នាយក-នាយិកាសាខា "ខ" នាយក-នាយិកាសាខា "គ" ប្រធានផ្នែកជំនាញ អនុប្រធានផ្នែកជំនាញ និងប្រធានសាខា "ខ"។

៤- បុគ្គលិកជំនាញ/បុគ្គលិកបច្ចេកទេស៖ រួមមាន ក្រុមអ្នកឯកទេស ក្រុមវិស្វករ ក្រុមឃ្លាំងប្រាក់ បុគ្គលិក និងជំនួយការ។

៥- បុគ្គលិកមិនជំនាញ៖ រួមមាន អ្នកបើកបរ ជំនួយការបម្រើអតិថិជន អ្នកសម្អាត ។

កម្មករនិយោជិតខាងលើ ត្រូវបានចាត់ថ្នាក់ដោយអនុលោមតាមកិច្ចសន្យាបុគ្គលិក ដូចជាកម្មករនិយោជិតអចិន្ត្រៃយ៍ និងបណ្តោះអាសន្ន។ ការប្រមូលទិន្នន័យអំពីចំនួនបុគ្គលិកត្រូវបានប្រមូលនៅចុងបញ្ចប់នៃការិយបរិច្ឆេទនៃរបាយការណ៍។

របាយការណ៍ចីរភាពនេះរៀបចំ និងចេញផ្សាយដោយ ធនាគារ អេស៊ីលីដា ភីអិលស៊ី ។ សម្រាប់ព័ត៌មានបន្ថែម និងចម្ងល់ផ្សេងៗសូមទាក់ទងមក៖



## ទំនាក់ទំនងមកកាន់ធនាគារ

**ការិយាល័យកណ្តាល** ៖ អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ ៖ ០២៣ ៩៩៨ ៧៧៧ / ៤៣០ ៩៩៩ | ទូរសារ ៖ ០២៣ ៤៣០ ៥៥៥

អ៊ីម៉ែល ៖ acledabank@acledabank.com.kh | គេហទំព័រ ៖ www.acledabank.com.kh

ប្រអប់សំបុត្រលេខ ៖ ១១៤៩ | SWIFT Code ៖ ACLBKHPP

**ការិយាល័យទំនាក់ទំនងអតិថិជន (បម្រើ ២៤ម៉ោង)**

ទូរស័ព្ទ ៖ ០២៣ ៩៩៤ ៤៤៤, ០១៥ ៩៩៩ ២៣៣

អ៊ីម៉ែល ៖ inquiry@acledabank.com.kh

# ផែនទីទៅកាន់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព

| គោលដៅ | ចំណុចដៅ | យោង |
|---|---|---|
| ១. ពុំមានភាពក្រីក្រ | ១.៤ មានសិទ្ធិស្មើគ្នាលើការគ្រប់គ្រងដី សេវាមូលដ្ឋាន បច្ចេកវិទ្យា និងការប្រើប្រាស់ធនធានសេដ្ឋកិច្ច | • បរិយាបន្នហិរញ្ញវត្ថុ និងចំណេះដឹងហិរញ្ញវត្ថុ ទំព័រ ៥១-៥៥<br>• ការចូលរួមជាមួយសហគមន៍ និងសង្គម ទំព័រ ៤៣ |
| ២. គ្រោះអត់ឃ្លានស្មើសូន្យ | ២.៣ កំណើនទ្វេដងនៃផលិតភាព និងចំណូលរបស់ផលិតផលករធុនតូច | • បរិយាបន្នហិរញ្ញវត្ថុ និងចំណេះដឹងហិរញ្ញវត្ថុ ទំព័រ ៥៥ |
| ៣. សុខភាព និងសុខុមាលភាពមាំមួន | ៣.៨ សម្រេចឱ្យបាននូវសុខភាពល្អជាសកល | • សុវត្ថិភាព និងបរិយាកាសការងារ ទំព័រ ៤០ |
| | ៣.C បង្កើនថវិកាលើវិស័យសុខាភិបាល និងផ្តល់ជំនួយដល់បុគ្គលិកផ្នែកសុខាភិបាលនៅតាមបណ្តាប្រទេសកំពុងអភិវឌ្ឍន៍នានា | • ការចូលរួមជាមួយសហគមន៍ និងសង្គម ទំព័រ ៤៣-៤៤ |
| ៤. ការអប់រំប្រកបដោយគុណភាព | ៤.៣ ទទួលបានភាពស្មើគ្នានូវការបណ្តុះបណ្តាលបច្ចេកទេស និងនៅកម្រិតឧត្តមសិក្សា | • ការអនុវត្តសមភាពការងារ ទំព័រ ៤១<br>• ការអភិវឌ្ឍធនធានមនុស្ស ទំព័រ ៤៩ |
| | ៤.៤ បង្កើនចំនួនមនុស្សដែលមានជំនាញពាក់ព័ន្ធដើម្បីភាពជោគជ័យផ្នែកហិរញ្ញវត្ថុ | • ការអភិវឌ្ឍធនធានមនុស្ស ទំព័រ ៤៩-៥០ |
| | ៤.៦ យុវវ័យគ្រប់រូប សម្រេចបាននូវលក្ខខណ្ឌអក្ខរភាព | • ការចូលរួមជាមួយសហគមន៍ និងសង្គម ទំព័រ ៤៤ |
| | ៤.៧ ការអប់រំសម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងសញ្ជាតិសកល | • ការអភិវឌ្ឍធនធានមនុស្ស ទំព័រ ៤៩-៥០<br>• បរិយាបន្នហិរញ្ញវត្ថុ និងចំណេះដឹងហិរញ្ញវត្ថុ ទំព័រ ៥១-៥៥ |
| ៥. សមភាពយេនឌ័រ | ៥.៥ ធានាការចូលរួមពេញលេញ ក្នុងភាពជាអ្នកដឹកនាំ និងការធ្វើសេចក្តីសម្រេច | • ការអនុវត្តសមភាពការងារ ទំព័រ ៤១-៤២<br>• ហិរញ្ញប្បទានប្រកបដោយការទទួលខុសត្រូវ និងការរួមបញ្ចូលបរិស្ថាន សង្គម និងអភិបាលកិច្ច ទំព័រ ៥៦-៥៧ |
| ៦. ទឹកស្អាត និងអនាម័យ | ៦.១ ទឹកបរិភោគដែលមានសុវត្ថិភាព និងតម្លៃសមរម្យ | • សុវត្ថិភាព និងបរិយាកាសការងារ ទំព័រ ៤០ |
| | ៦.៣ ធ្វើឱ្យប្រសើរឡើងគុណភាពទឹកកាត់បន្ថយការបំពុលក្នុងទឹក និងការប្រើប្រាស់ឡើងវិញប្រកបដោយសុវត្ថិភាព | • ហិរញ្ញប្បទានប្រកបដោយការទទួលខុសត្រូវ និងការរួមបញ្ចូលបរិស្ថាន សង្គម និងអភិបាលកិច្ច ទំព័រ ៥៦-៥៧ |
| ៧. ថាមពលស្អាតដែលមានតម្លៃសមរម្យ | ៧.២ បង្កើនចំណែកនៃថាមពលកកើតឡើងវិញជាសកល | • ហិរញ្ញប្បទានប្រកបដោយការទទួលខុសត្រូវ និងការរួមបញ្ចូលបរិស្ថាន សង្គម និងអភិបាលកិច្ច ទំព័រ ៥៦-៥៧ |
| ៨. ការងារសមរម្យ និងកំណើនសេដ្ឋកិច្ច | ៨.២ ធ្វើពិពិធកម្មការបង្កើនកម្រិតបច្ចេកវិទ្យា និង នវានុវត្តន៍សម្រាប់ផលិតភាពសេដ្ឋកិច្ច | • ការអភិវឌ្ឍផលិតផល និងនវានុវត្តន៍ឌីជីថល ទំព័រ ៧២-៧៣ |
| | ៨.៥ លើកកម្ពស់ការងារ ការអប់រំ និងការបណ្តុះបណ្តាលយុវជន | • ការអនុវត្តសមភាពការងារ ទំព័រ ៤១-៤២<br>• ការអភិវឌ្ឍធនធានមនុស្ស ទំព័រ ៤៩-៥០ |
| ៩. ឧស្សាហកម្ម នវានុវត្តន៍ និងហេដ្ឋារចនាសម្ព័ន្ធ | ៩.១អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធដែលមានចីរភាព ភាពបន្សាំនិងបរិយាបន្ន | • សុវត្ថិភាព និងបរិយាកាសការងារ ទំព័រ ៤០ |

| | | |
|---|---|---|
| | ៩.២ លើកកម្ពស់ឧស្សាហូបនីយកម្មប្រកបដោយបរិយាបន្ន និងចីរភាព | • បរិយាបន្នហិរញ្ញវត្ថុ និងចំណេះដឹងហិរញ្ញវត្ថុ ទំព័រ ៥១-៥៥ |
| **១០. កាត់បន្ថយវិសមភាព** | ១០.២ លើកកម្ពស់បរិយាបន្នសង្គមសេដ្ឋកិច្ច និងនយោបាយ | • ការអនុវត្តសមភាពការងារ ទំព័រ ៤២<br>• ហិរញ្ញប្បទានប្រកបដោយការទទួលខុសត្រូវ និងការរួមបញ្ចូលបរិស្ថាន សង្គម និងអភិបាលកិច្ច ទំព័រ ៥៦-៥៧ |
| **១១. ទីក្រុង និងសហគមន៍ប្រកបដោយចីរភាព** | ១១.៤ ការពារបេតិកភ័ណ្ឌវប្បធម៌ និងធម្មជាតិរបស់ពិភពលោក | • ហិរញ្ញប្បទានប្រកបដោយការទទួលខុសត្រូវ និងការរួមបញ្ចូលបរិស្ថាន សង្គម និងអភិបាលកិច្ច ទំព័រ ៥៦-៥៧ |
| | ១១.៦ កាត់បន្ថយផលប៉ះពាល់បរិស្ថាននៅទីក្រុង រួមទាំងតាមរយៈការផ្តោតការយកចិត្តទុកដាក់លើ គុណភាពខ្យល់ និងការគ្រប់គ្រងសំណល់នៅទីក្រុង និងតំបន់ផ្សេងទៀត | |
| **១២. ការប្រើប្រាស់ និងការផលិតប្រកបដោយការទទួលខុសត្រូវ** | ១២.៥ កាត់បន្ថយឱ្យបានច្រើនការបង្កើតសំណល់ តាមរយៈការការពារ ការកាត់បន្ថយ ការកែច្នៃឡើងវិញ និងការប្រើប្រាស់ឡើងវិញ | • ហានិភ័យនៃការប្រែប្រួលអាកាសធាតុ ទំព័រ ២៦-២៧, ៣៤-៣៧ |
| **១៣. សកម្មភាពបរិស្ថាន** | ១៣.២ ធ្វើសមាហរណកម្មការវាស់វែងការប្រែប្រួលអាកាសធាតុទៅក្នុងគោលនយោបាយ និងផែនការជាតិ | • ហានិភ័យនៃការប្រែប្រួលអាកាសធាតុ ទំព័រ ៣៤-៣៧ |
| | ១៣.៣ លើកកម្ពស់ការយល់ដឹង និងសមត្ថភាពដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ | • ហិរញ្ញប្បទានប្រកបដោយការទទួលខុសត្រូវ និងការរួមបញ្ចូលបរិស្ថាន សង្គម និងអភិបាលកិច្ច ទំព័រ ៥៦-៥៧ |
| **១៤. ជីវិតក្រោមទឹក** | ១៤.១ កាត់បន្ថយការបំពុលនៅក្នុងសមុទ្រ | • ហិរញ្ញប្បទានប្រកបដោយការទទួលខុសត្រូវ និងការរួមបញ្ចូលបរិស្ថាន សង្គម និងអភិបាលកិច្ច ទំព័រ ៥៦-៥៧ |
| **១៥. ជីវិតលើដី** | ១៥.A កៀរគរធនធានហិរញ្ញវត្ថុសម្រាប់អភិរក្ស និងការប្រើប្រាស់ជីវចម្រុះ និងប្រព័ន្ធអេកូឡូស៊ីប្រកបដោយចីរភាព | • ហិរញ្ញប្បទានប្រកបដោយការទទួលខុសត្រូវ និងការរួមបញ្ចូលបរិស្ថាន សង្គម និងអភិបាលកិច្ច ទំព័រ ៥៦-៥៧ |
| **១៦. សន្តិភាព យុត្តិធម៌ និងស្ថាប័នរឹងមាំ** | ១៦.៤ ប្រឆាំងឧក្រិដ្ឋកម្មគ្រោងទុកលំហូរហិរញ្ញវត្ថុ និងគឿងញៀនសព្វាវុធខុសច្បាប់ | • សុវត្ថិភាព ទិន្នន័យ និងឯកជនភាពរបស់អតិថិជន ទំព័រ ៦៦ |
| | ១៦.៥ កាត់បន្ថយឱ្យបានច្រើននូវអំពើពុករលួយ និងការស៊ីសំណូក | • ក្រមសីលធម៌អាជីវកម្ម ទំព័រ ៦៤<br>• អភិបាលកិច្ចសាជីវកម្ម និងការប្រឆាំងអំពើពុករលួយ ទំព័រ ៦២ |
| **១៧. ភាពជាដៃគូ ដើម្បីសម្រេចគោលដៅ** | ១៧.១ កៀរគរធនធានបន្ថែមទៀតដើម្បីកែលម្អការប្រមូលចំណូលក្នុងស្រុក | • បរិយាបន្នហិរញ្ញវត្ថុ និងចំណេះដឹងហិរញ្ញវត្ថុ ទំព័រ ៥១-៥៥<br>• ការចូលរួមជាមួយសហគមន៍ និងសង្គម ទំព័រ ៤៣-៤៨ |
| | ១៧.១៦ លើកកម្ពស់ភាពជាដៃគូជាសកលសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព | • ហិរញ្ញប្បទានប្រកបដោយការទទួលខុសត្រូវ និងការរួមបញ្ចូលបរិស្ថាន សង្គម និងអភិបាលកិច្ច ទំព័រ ៥៦-៥៧<br>• ការអភិវឌ្ឍផលិតផល និងនវានុវត្តន៍ឌីជីថល ទំព័រ ៧២ |


អេស៊ីលីដា
ACLEDA BANK

# ធនាគារ អេស៊ីលីដា ភីអិលស៊ី
# និងក្រុមហ៊ុនបុត្រសម្ព័ន្ធ

របាយការណ៍ហិរញ្ញវត្ថុរួម
និងរបាយការណ៍ហិរញ្ញវត្ថុដោយឡែក

នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និង
សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់
និង
របាយការណ៍របស់សវនករឯករាជ្យ
ស្តីពីរបាយការណ៍ហិរញ្ញវត្ថុ

## ធនាគារ អេស៊ីលីដា ភីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

**របាយការណ៍ហិរញ្ញវត្ថុរួម និង របាយការណ៍ហិរញ្ញវត្ថុដោយឡែក**
**នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និងសម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់**

# មាតិកា


| | ទំព័រ |
|---|---|
| របាយការណ៍របស់ក្រុមប្រឹក្សាភិបាល | ១ - ៨ |
| របាយការណ៍របស់សវនករឯករាជ្យ | ៩ - ១៥ |
| របាយការណ៍ហិរញ្ញវត្ថុ៖ | |
| របាយការណ៍ហិរញ្ញវត្ថុរួម៖ | |
| របាយការណ៍ស្ថានភាពហិរញ្ញវត្ថុរួម | ១៦ |
| របាយការណ៍ចំណេញឬខាត និងលទ្ធផលលម្អិតផ្សេងៗរួម | ១៧ - ១៨ |
| របាយការណ៍បម្រែបម្រួលមូលធនរួម | ១៩ - ២០ |
| របាយការណ៍លំហូរសាច់ប្រាក់រួម | ២១ - ២២ |
| របាយការណ៍ហិរញ្ញវត្ថុដោយឡែក៖ | |
| របាយការណ៍ស្ថានភាពហិរញ្ញវត្ថុដោយឡែក | ២៣ |
| របាយការណ៍ចំណេញឬខាត និងលទ្ធផល លម្អិតផ្សេងៗដោយឡែក | ២៤ - ២៥ |
| របាយការណ៍បម្រែបម្រួលមូលធនដោយឡែក | ២៦ - ២៧ |
| របាយការណ៍លំហូរសាច់ប្រាក់ដោយឡែក | ២៨ - ២៩ |
| កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ | ៣០ - ២៥៦ |

## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល សូមដាក់បង្ហាញរបាយការណ៍របស់ខ្លួន និងរបាយការណ៍ហិរញ្ញវត្ថុរួមរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ហៅកាត់ថា ("ធនាគារ") និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ធនាគារ (ដែលតទៅនេះ ទាំងធនាគារ និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ ត្រូវហៅកាត់ថា "សម្ព័ន្ធធនាគារ") និង របាយការណ៍ហិរញ្ញវត្ថុដោយឡែករបស់ធនាគារ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និង សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ (ដែលតទៅនេះ ហៅកាត់ថា "របាយការណ៍ហិរញ្ញវត្ថុ")។

### អំពីសម្ព័ន្ធធនាគារ និងធនាគារ

មុនថ្ងៃទី១ ខែធ្នូ ឆ្នាំ២០០៣ ធនាគារ អេស៊ីលីដា ភីអិលស៊ី គឺជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ដែលត្រូវបានបង្កើតឡើងក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ហើយធ្វើប្រតិបត្តិការជាធនាគារឯកទេស ដែលមាន ទីស្នាក់ការកណ្តាលនៅរាជធានីភ្នំពេញ និងមានសាខាចំនួន ១៤ ក្នុងព្រះរាជាណាចក្រកម្ពុជា។ នៅថ្ងៃទី១ ខែធ្នូ ឆ្នាំ២០០៣ ធនាគារជាតិ នៃ កម្ពុជា ("NBC") បានផ្តល់អាជ្ញាបណ្ណដល់ធនាគារ ជាធនាគារពាណិជ្ជឯកជន សម្រាប់ រយៈពេលបីឆ្នាំគិតចាប់ពីថ្ងៃទី១ ខែធ្នូ ឆ្នាំ២០០៣។ នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៦ អាជ្ញាបណ្ណរបស់ធនាគារ ត្រូវបានប្តូរ សារជាថ្មីម្តងទៀតទៅជាអាជ្ញាបណ្ណអចិន្ត្រៃយ៍។ ការិយាល័យចុះបញ្ជីរបស់ធនាគារមានទីតាំងស្ថិតនៅអគារលេខ ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។ ធនាគារ អាចបង្កើត ការិយាល័យបន្ថែមទាំងក្នុង និងក្រៅប្រទេស ព្រមទាំងអាចផ្លាស់ប្តូរទីតាំងការិយាល័យ ដែលបានចុះបញ្ជីរួចហើយ ដោយចុះបញ្ជិកាផ្លាស់ប្តូរទាំងនោះ នៅក្រសួងពាណិជ្ជកម្ម ("MOC") និងត្រូវមានការអនុម័តយល់ព្រមពីធនាគារជាតិ នៃ កម្ពុជា។

ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០ ធនាគារជោគជ័យនៅក្នុងការចុះបញ្ជីនៅក្នុងទីផ្សារមូលបត្រកម្ពុជា ("ផមក")។ ភាគហ៊ុនថ្មីត្រូវបានបោះផ្សាយចំនួន ៤.៣៩៤.៨៦៥ ភាគហ៊ុន ក្នុងតម្លៃចារឹក ៤.០០០ រៀល (០,៩៨ ដុល្លារអាមេរិក) ក្នុង មួយហ៊ុន នៅក្នុងតម្លៃបោះផ្សាយ ១៦.២០០ រៀល (៣,៩៧ ដុល្លារអាមេរិក)។ ធនាគារទទួលបានទឹកប្រាក់ពីការបោះផ្សាយ លក់មូលបត្រជាសាធារណៈលើកដំបូង ("IPO") ចំនួន ១៧.០៨២.១០៥ ដុល្លារអាមេរិក និងចំណាយថ្លៃដើមអស់ ១.០៣១.០២៥ ដុល្លារអាមេរិក ដែលទទួលបានបុព្វលាភភាគហ៊ុនចំនួន ១១.៧០៦.២១៥ ដុល្លារអាមេរិក (៤៨.២៣៥.៤៥៩ ពាន់រៀល)។

នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២០ ម្ចាស់ភាគហ៊ុនបានអនុម័តឱ្យកែប្រែលក្ខន្តិកៈក្រុមហ៊ុនទាក់ទងនឹងការបង្កើន ដើមទុនសម្រាប់ការបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង។ នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១ ធនាគារបានដាក់ លិខិតស្នើសុំទៅធនាគារជាតិ នៃ កម្ពុជា ក្នុងការបង្កើនដើមទុន ហើយត្រូវបានអនុម័តនៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២១។ ការកែប្រែលក្ខន្តិកៈធនាគារ ក៏ត្រូវបានអនុម័តដោយក្រសួងពាណិជ្ជកម្មនៅថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២១។



ចុះបញ្ជីក្រោមលេខ
Registration No. 00003077

អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Building Nº 61, Preah Monivong Blvd., Sangkat Srah Chak, Khan Doun Penh, Phnom Penh, Kingdom of Cambodia.
ទូរស័ព្ទ Tel: +855 (0) 23 998 777 / 430 999, ទូរសារ Fax: +855 (0) 23 430 555, ប្រអប់សំបុត្រ P.O.Box: 1149
E-mail: acledabank@acledabank.com.kh, Website: www.acledabank.com.kh, SWIFT Code: ACLBKHPP

### អំពីសម្ព័ន្ធធនាគារ និងធនាគារ (ត)

ធនាគារ និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ រួមមាន អេស៊ីលីដា ឡាវ លីមីធីត (ហៅកាត់ថា "ABL") និង ស្ថាប័នមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា មីយ៉ាន់ម៉ា (ហៅកាត់ថា "AMM") គឺនៅក្នុងវិស័យហិរញ្ញវត្ថុ និងមានប្រតិបត្តិការ ២៦៤ ការិយាល័យ ទូទាំងខេត្តក្រុងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ៣៧ ការិយាល័យ នៅក្នុងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និង ១៧ ការិយាល័យ នៅសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា។ ក្រុមហ៊ុនបុត្រសម្ព័ន្ធផ្សេងៗទៀតរបស់ធនាគារ មានក្រុមហ៊ុនអេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី (ហៅកាត់ថា "ACS") គឺនៅក្នុងវិស័យមូលបត្រ និងវិទ្យាស្ថានពាណិជ្ជសាស្ត្រអេស៊ីលីដា ឯ.ក (ហៅកាត់ថា "AIB") គឺនៅក្នុងវិស័យអប់រំ។

នៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២២ ធនាគារជាតិ នៃ កម្ពុជា បានអនុម័តសំណើរបស់ធនាគារក្នុងការបោះផ្សាយមូលបត្របំណុលបៃតងដល់វិនិយោគិនមានទឹកប្រាក់ចំនួន ៤០០ ពាន់លានរៀល (ស្មើនឹង ១០០ លានដុល្លារអាមេរិក) នៅលើទីផ្សារមូលបត្រកម្ពុជា។

នៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២២ និយ័តករមូលបត្រកម្ពុជា ("ន.ម.ក") បានអនុម័តសំណើរបស់ធនាគារសម្រាប់ជាភ្នាក់ងារទូទាត់សាច់ប្រាក់ ភ្នាក់ងារចុះបញ្ជី និងភ្នាក់ងារផ្ទេរប្រាក់របស់ខ្លួន ហើយ ACS ជាភ្នាក់ងារមូលបត្របំណុលនៅពេលធនាគារបោះផ្សាយនូវមូលបត្របំណុលបៃតងនៅលើទីផ្សារមូលបត្រកម្ពុជា។

នៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២៣ ធនាគារជាតិ នៃ កម្ពុជា បានអនុម័តសំណើរបស់ធនាគារ ក្នុងការបោះផ្សាយលក់សញ្ញាបណ្ណ Thai Baht Denominated Subordinated Unsecured Debentures ក្នុងសមាគមទីផ្សារមូលបត្ររបស់ប្រទេសថៃ ក្នុងចំនួនទឹកប្រាក់ ៣,៥ ពាន់លានបាត (សមមូលនឹង១០០ លានដុល្លារអាមេរិក)។

### សកម្មភាពអាជីវកម្មចម្បង

ធនាគារធ្វើប្រតិបត្តិការក្រោមបទប្បញ្ញត្តិរបស់ធនាគារជាតិ នៃ កម្ពុជា ដោយផ្តោតជាពិសេសលើការផ្តល់ឥណទាន និងសេវាហិរញ្ញវត្ថុផ្សេងៗទៀត សម្រាប់ប្រជាពលរដ្ឋទូទៅ ក៏ដូចជាសហគ្រាសធុនតូច និងមធ្យម ព្រមទាំងសកម្មភាពអាជីវកម្មដទៃទៀត ដែលក្រុមប្រឹក្សាភិបាលជឿជាក់ថាគាំទ្រដល់គោលបំណងទាំងនេះ។

ធនាគារ អេស៊ីលីដា ភីអិលស៊ី កាន់កាប់ភាគហ៊ុនរបស់ ABL ចំនួន ៩៩,៩០% ហើយសកម្មភាពអាជីវកម្មចម្បងគឺការផ្តល់សេវាធនាគារ និងសេវាហិរញ្ញវត្ថុផ្សេងៗទៀតនៅ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។

ធនាគារ អេស៊ីលីដា ភីអិលស៊ី កាន់កាប់ភាគហ៊ុនរបស់ ACS ទាំងស្រុង ហើយសកម្មភាពអាជីវកម្មចម្បង គឺការផ្តល់សេវាជាឈ្មួញជើងសាមូលបត្រ និងសេវាផ្សេងៗទៀត ដែលបានអនុម័តដោយគណៈកម្មការមូលបត្រកម្ពុជា ("គ.ម.ក") (បច្ចុប្បន្នជា ន.ម.ក)។

ធនាគារ អេស៊ីលីដា ភីអិលស៊ី កាន់កាប់ភាគហ៊ុនរបស់ AIB ចំនួន ៧៦,៦០៩% ហើយសកម្មភាពអាជីវកម្មចម្បងគឺបណ្តុះបណ្តាលកម្រិតបរិញ្ញាបត្ររង កម្រិតបរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ លើដេប៉ាតឺម៉ង់គ្រប់គ្រងពាណិជ្ជកម្ម មុខជំនាញហិរញ្ញវត្ថុ និងធនាគារ។

ធនាគារ អេស៊ីលីដា ភីអិលស៊ី កាន់កាប់ភាគហ៊ុនរបស់ AMM ទាំងស្រុង និង AMM ត្រូវបានអនុញ្ញាតឱ្យធ្វើប្រតិបត្តិការជាស្ថាប័នមីក្រូហិរញ្ញវត្ថុ ទទួលប្រាក់បញ្ញើ ដោយផ្តល់នូវសេវាផ្នែកមីក្រូហិរញ្ញវត្ថុមួយចំនួនជូនទីផ្សារសម្រាប់ប្រជាជនដែលមានប្រាក់ចំណូលទាប និងសកម្មភាពផ្សេងៗទៀតដែលអនុញ្ញាតដោយអាជ្ញាធរត្រួតពិនិត្យផ្នែកមីក្រូហិរញ្ញវត្ថុក្នុងប្រទេសមីយ៉ាន់ម៉ា។



ចុះបញ្ជីក្រោមលេខ
Registration No. 00003077

អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Building Nº 61, Preah Monivong Blvd., Sangkat Srah Chak, Khan Doun Penh, Phnom Penh, Kingdom of Cambodia.
ទូរស័ព្ទ Tel: +855 (0) 23 998 777 / 430 999, ទូរសារ Fax: +855 (0) 23 430 555, ប្រអប់សំបុត្រ P.O.Box: 1149
E-mail: acledabank@acledabank.com.kh, Website: www.acledabank.com.kh, SWIFT Code: ACLBKHPP

## លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរបស់សម្ព័ន្ធធនាគារ និងធនាគារសម្រាប់ដំណាច់ឆ្នាំ ដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗរួម និងរបាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗដោយឡែកនៅលើទំព័រទី១៧ - ១៨ និងទំព័រទី ២៤ - ២៥។

## ដើមទុន និង បុព្វលាភភាគហ៊ុន

ដើមទុន និងបុព្វលាភភាគហ៊ុនត្រូវបានចាត់ថ្នាក់ជាមូលធន។ ថ្លៃដើមបន្ថែមទាក់ទងដោយផ្ទាល់លើការបោះផ្សាយដើមទុនថ្មី ត្រូវបានបង្ហាញក្នុងមូលធនបន្ទាប់ពីបានកាត់ពន្ធពីសាច់ប្រាក់ទទួលបានពីការលក់ភាគហ៊ុន។

## ទុនបម្រុង និងសំវិធានធន

ពុំមានការប្រែប្រួលជាសារវន្តរវាងទុនបម្រុង និងសំវិធានធននៅក្នុងឆ្នាំនេះទេ ក្រៅពីការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ។

## ឥណទានអាក្រក់ និងឥណទានសង្ស័យ

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ ត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាល បានចាត់វិធានការដែលមានមូលដ្ឋានសមស្រប ដើម្បីបញ្ជាក់ថាវិធានការទាក់ទងទៅនឹងការជម្រះបុរេប្រទាន និងឥណទានអាក្រក់លុបចេញពីបញ្ជី ឬការធ្វើសំវិធានធនបុរេប្រទាន និងឥណទានសង្ស័យ ហើយ ក្រុមប្រឹក្សាភិបាលជឿជាក់ថា រាល់បុរេប្រទាន និងឥណទានអាក្រក់ទាំងអស់ដែលបានដឹងត្រូវបានជម្រះចេញពីបញ្ជី និងបានកត់ត្រាសំវិធានធនពេញលេញសម្រាប់បុរេប្រទាន និងឥណទានអាក្រក់ និងឥណទានសង្ស័យ។

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ និងផ្អែកតាមការយល់ដឹងដ៏សុក្រឹត ក្រុមប្រឹក្សាភិបាលពុំបានដឹងពីស្ថានភាពណាមួយដែលនាំឱ្យចំនួនឥណទាន និងបុរេប្រទានអាក្រក់ដែលបានជម្រះចេញពីបញ្ជី ឬសំវិធានធនលើឥណទាន និងបុរេប្រទានអាក្រក់ និងសង្ស័យនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះមានចំនួនមិនគ្រប់គ្រាន់ជាសារវន្តនោះឡើយ។

## ទ្រព្យសកម្ម

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ ត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាល បានចាត់វិធានការដែលមានមូលដ្ឋានសមស្របដើម្បីបញ្ជាក់ថា បណ្តាទ្រព្យសកម្មទាំងឡាយ ដែលទំនងជាមិនអាចបម្រើនៅក្នុងប្រតិបត្តិការអាជីវកម្មទៅតាមតម្លៃដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យ ត្រូវបានកាត់បន្ថយឱ្យនៅស្មើនឹងតម្លៃដែលគិតថានឹងអាចប្រើប្រាស់ និងទទួលបានជាក់ស្តែង។

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ និងផ្អែកតាមការយល់ដឹងដ៏សុក្រឹត ក្រុមប្រឹក្សាភិបាល ពុំបានដឹងពីហេតុការណ៍ណាមួយដែលនឹងធ្វើឱ្យប៉ះពាល់ដល់ការវាយតម្លៃទ្រព្យសកម្ម នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ ថាមានភាពមិនត្រឹមត្រូវជាសារវន្តនោះទេ។



ចុះបញ្ជីក្រោមលេខ
Registration No. 00003077

អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Building Nº 61, Preah Monivong Blvd., Sangkat Srah Chak, Khan Doun Penh, Phnom Penh, Kingdom of Cambodia.
ទូរស័ព្ទ Tel: +855 (0) 23 998 777 / 430 999, ទូរសារ Fax: +855 (0) 23 430 555, ប្រអប់សំបុត្រ P.O.Box: 1149
E-mail: acledabank@acledabank.com.kh, Website: www.acledabank.com.kh, SWIFT Code: ACLBKHPP

## វិធីសាស្ត្រវាយតម្លៃ

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ និងផ្អែកតាមការយល់ដឹងដ៏សុក្រឹត ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលបានកើតឡើង ហើយអាចបណ្តាលឱ្យប៉ះពាល់ដល់វិធីសាស្រ្តកន្លងមកក្នុងការវាយតម្លៃទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ ដែលមានភាពមិនត្រឹមត្រូវ ឬមិនសមស្របជាសារវន្តនោះទេ។

## បំណុលយថាហេតុ និងបំណុលផ្សេងៗទៀត

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ៖

(ក) ពុំមានបន្ទុកណាមួយលើទ្រព្យសកម្មរបស់សម្ព័ន្ធធនាគារ និងធនាគារ ដែលបានកើតឡើងចាប់តាំងពីចុង-ឆ្នាំមក ដោយសារការដាក់បញ្ចាំសម្រាប់ការធានាចំពោះបំណុលរបស់បុគ្គលណាម្នាក់ឡើយ និង

(ខ) ពុំមានបំណុលយថាហេតុណាមួយដែលកើតមាន ឬអាចនឹងកើតមានឡើងចំពោះសម្ព័ន្ធធនាគារ និងធនាគារ ចាប់តាំងពីចុងឆ្នាំមក ក្រៅអំពីប្រតិបត្តិការអាជីវកម្មធម្មតារបស់ធនាគារឡើយ។

តាមមតិយោបល់របស់ក្រុមប្រឹក្សាភិបាល ពុំមានបំណុលយថាហេតុ ឬបំណុលផ្សេងៗទៀតរបស់សម្ព័ន្ធធនាគារ និងធនាគារ ដែលត្រូវបំពេញ ឬអាចនឹងត្រូវបំពេញក្នុងអំឡុងពេល ១២ខែ បន្ទាប់ពីចុងបញ្ចប់ឆ្នាំដែលនឹងមាន ឬអាចនឹងមានផលប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់សម្ព័ន្ធធនាគារ ឬធនាគារក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនដូចដែលបានកំណត់ និងនៅពេលដែលដល់ថ្ងៃកំណត់សងនោះទេ។

## ការប្រែប្រួលកាលៈទេសៈ

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាល ពុំបានដឹងពីកាលៈទេសៈណាមួយដែលមិនបានវែកញែកនៅក្នុងរបាយការណ៍នេះ ឬក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ ដែលនឹងបណ្តាលឱ្យចំនួនណាមួយដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុមានភាពមិនត្រឹមត្រូវជាសារវន្តនោះទេ។

## ប្រតិបត្តិការមិនប្រក្រតី

តាមមតិយោបល់របស់ក្រុមប្រឹក្សាភិបាល លទ្ធផលនៃប្រតិបត្តិការរបស់សម្ព័ន្ធធនាគារ និងធនាគារក្នុងឆ្នាំហិរញ្ញវត្ថុនេះ មិនបានទទួលរងនូវផលប៉ះពាល់ជាសារវន្តពីសកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍មិនប្រក្រតីណាមួយឡើយលើកលែងតែផលប៉ះពាល់បន្តនៃស្ថានភាពណ្ហូវែលវីរុសកូរ៉ូណា (“កូវីដ-១៩”)។

តាមមតិយោបល់របស់ក្រុមប្រឹក្សាភិបាល នៅរវាងដំណាច់ឆ្នាំនេះរហូតដល់កាលបរិច្ឆេទនៃរបាយការណ៍នេះ ពុំមានសកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍មិនប្រក្រតីណាមួយដែលអាចជះឥទ្ធិពលជាសារវន្តដល់លទ្ធផលនៃប្រតិបត្តិការរបស់សម្ព័ន្ធធនាគារ និងធនាគារ ក្នុងឆ្នាំហិរញ្ញវត្ថុដែលរបាយការណ៍នេះបានរៀបចំឡើងនោះទេ។



ចុះបញ្ជីក្រោមលេខ
Registration No. 00003077

អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Building Nº 61, Preah Monivong Blvd., Sangkat Srah Chak, Khan Doun Penh, Phnom Penh, Kingdom of Cambodia.
ទូរស័ព្ទ Tel: +855 (0) 23 998 777 / 430 999, ទូរសារ Fax: +855 (0) 23 430 555, ប្រអប់សំបុត្រ P.O.Box: 1149
E-mail: acledabank@acledabank.com.kh, Website: www.acledabank.com.kh, SWIFT Code: ACLBKHPP

## ប្រតិបត្តិការមិនប្រក្រតី (ត)

*វីរុសកូវីដ-១៩ និងផលប៉ះពាល់បន្តលើការខាតបង់ឥណទានរំពឹងទុក*

ការខាតបង់ឥណទានរំពឹងទុក ("ECL") ត្រូវបានប៉ាន់ប្រមាណដោយផ្អែកទៅលើលក្ខខណ្ឌសេដ្ឋកិច្ច ដែលបានព្យាករណ៍ មួយចំនួននៅក្នុងការិយបរិច្ឆេទរាយការណ៍។ ក្នុងឆ្នាំ២០២០ ការផ្ទុះឡើងនៃវីរុសកូវីដ-១៩ បានរាលដាលលើប្រទេសចិនដីគោក កម្ពុជា និងបណ្តាប្រទេសផ្សេងៗទៀត បានធ្វើឱ្យមានការរាំងស្ទះដល់សកម្មភាពអាជីវកម្ម និងសេដ្ឋកិច្ច។ ក្នុងការឆ្លើយតបទៅនឹងស្ថានភាពកូវីដ-១៩ អ្នកគ្រប់គ្រងបានធ្វើការព្យាករណ៍ផលប៉ះពាល់បន្តនៃជំងឺកូវីដ-១៩ ទៅលើការខាតបង់ឥណទានរំពឹងទុករបស់សម្ព័ន្ធធនាគារ និងធនាគារ ដែលពិចារណាទៅលើសេណារីយ៉ូសេដ្ឋកិច្ចដែលអាចកើតមានឡើងនាពេលបច្ចុប្បន្ន និងអនាគត។

## ក្រុមប្រឹក្សាភិបាល និង គណៈកម្មាធិការប្រតិបត្តិ

សមាជិកក្រុមប្រឹក្សាភិបាលដែលបានបម្រើការក្នុងឆ្នាំ និងនាថ្ងៃចេញរបាយការណ៍នេះ រួមមាន៖

| | |
|---|---|
| ▪ លោក ឆាយ សឿន | ប្រធានក្រុមប្រឹក្សាភិបាល (អភិបាលមិនប្រតិបត្តិ) |
| ▪ បណ្ឌិត អ៊ិន ចាន់នី | សមាជិក (អភិបាលប្រតិបត្តិ) |
| ▪ លោក Kyosuke Hattori | សមាជិក (អភិបាលមិនប្រតិបត្តិ) |
| ▪ លោក Albertus Bruggink | សមាជិក (អភិបាលមិនប្រតិបត្តិ) |
| ▪ លោក Kay Lot | សមាជិក (អភិបាលមិនប្រតិបត្តិ) |
| ▪ លោក Stéphane Mangiavacca | សមាជិក (អភិបាលមិនប្រតិបត្តិ) |
| ▪ បណ្ឌិត Pieter Kooi | សមាជិក (អភិបាលឯករាជ្យ) |
| ▪ លោក Van Sou Ieng | សមាជិក (អភិបាលឯករាជ្យ) (បានចូលនិវត្តន៍នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៣) |
| ▪ បណ្ឌិត ហេង ឌីណា | សមាជិក (អភិបាលឯករាជ្យ) (ប្រសិទ្ធភាពនៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៣) |
| ▪ លោកស្រី Phurik Ratana | សមាជិក (អភិបាលឯករាជ្យ) |



ចុះបញ្ជីក្រោមលេខ
Registration No. 00003077

អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Building Nº 61, Preah Monivong Blvd., Sangkat Srah Chak, Khan Doun Penh, Phnom Penh, Kingdom of Cambodia.
ទូរស័ព្ទ Tel: +855 (0) 23 998 777 / 430 999, ទូរសារ Fax: +855 (0) 23 430 555, ប្រអប់សំបុត្រ P.O.Box: 1149
E-mail: acledabank@acledabank.com.kh, Website: www.acledabank.com.kh, SWIFT Code: ACLBKHPP

### ក្រុមប្រឹក្សាភិបាល និង គណៈកម្មាធិការប្រតិបត្តិ (ត)

សមាជិកគណៈកម្មាធិការប្រតិបត្តិដែលបានបម្រើការក្នុងឆ្នាំ និងនាថ្ងៃចេញរបាយការណ៍នេះរួមមាន៖

- បណ្ឌិត អ៊ិន ចាន់នី ប្រធាននាយកប្រតិបត្តិ
- បណ្ឌិត សូ ផនណារី អនុប្រធាននាយកប្រតិបត្តិជាន់ខ្ពស់ និងជាគណៈប្រធាននាយិកាប្រតិបត្តិប្រតិបត្តិការ (បានចូលនិវត្តន៍នៅថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០២៣)
- លោកស្រី ម៉ារ អមរា អនុប្រធាននាយកប្រតិបត្តិជាន់ខ្ពស់ និងជាគណៈប្រធាននាយិកាប្រតិបត្តិហិរញ្ញវត្ថុ និងគណៈប្រធាននាយិកាប្រតិបត្តិប្រតិបត្តិការ (បានតែងតាំងនៅថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០២៣)
- លោក លី ថៃ អនុប្រធាននាយកប្រតិបត្តិ និង ជាគណៈប្រធាននាយកប្រតិបត្តិអភិបាលកិច្ច
- លោកស្រី ប៊ុត ប៊ុនសីហា អនុប្រធាននាយកប្រតិបត្តិ និង ជាគណៈប្រធាននាយិកាប្រតិបត្តិនីតិកម្ម និង លេខាធិការក្រុមហ៊ុន
- លោក ម៉ាច់ ធារី អនុប្រធាននាយកប្រតិបត្តិ និង ជាគណៈប្រធាននាយកប្រតិបត្តិព័ត៌មានវិទ្យា
- បណ្ឌិត ឡឹង សុភាព អនុប្រធាននាយកប្រតិបត្តិ និង ជាគណៈប្រធាននាយកប្រតិបត្តិហានិភ័យ
- លោក យិន វីរៈ អនុប្រធាននាយកប្រតិបត្តិ និង ជាគណៈប្រធាននាយកប្រតិបត្តិរតនាភិបាល (ត្រូវបានតែងតាំងនៅថ្ងៃទី១ ខែមករា ឆ្នាំ២០២៣)

### ការទទួលខុសត្រូវរបស់អ្នកគ្រប់គ្រង និងអ្នកទទួលបន្ទុកលើអភិបាលកិច្ចរបាយការណ៍ហិរញ្ញវត្ថុ

អ្នកគ្រប់គ្រង និងអ្នកទទួលបន្ទុកលើអភិបាលកិច្ច ទទួលខុសត្រូវក្នុងការបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើង និងបានបង្ហាញត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់នៃស្ថានភាពហិរញ្ញវត្ថុនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ លទ្ធផលហិរញ្ញវត្ថុសម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ និងលំហូរសាច់ប្រាក់សម្រាប់ដំណាច់ការិយបរិច្ឆេទ ដែលបានបញ្ចប់របស់សម្ព័ន្ធធនាគារ និងធនាគារ ដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("ស.រ.ទ.ហ.អ.ក") និងសេចក្តីណែនាំរបស់ធនាគារជាតិ នៃ កម្ពុជា។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ អ្នកគ្រប់គ្រង និងអ្នកទទួលបន្ទុកលើអភិបាលកិច្ច ចាំបាច់ត្រូវតែ៖

(i) អនុលោមតាមគោលនយោបាយគណនេយ្យដ៏សមស្រប ដែលគាំទ្រដោយការវិនិច្ឆ័យ និងការប៉ាន់ស្មានសមហេតុផល និងប្រកបដោយការប្រុងប្រយ័ត្ន ព្រមទាំងអនុវត្តឱ្យមានសង្គតិភាព

(ii) អនុវត្តតាមតម្រូវការលាតត្រដាងព័ត៌មាន ដែលអនុលោមទៅតាម ស.រ.ទ.ហ.អ.ក ឬប្រសិនបើមានការប្រាសចាកណាមួយក្នុងការបង្ហាញឱ្យមានភាពពិត និងត្រឹមត្រូវ ការប្រាសចាកទាំងនោះត្រូវបង្ហាញ ពន្យល់ និងកំណត់បរិមាណឱ្យបានសមស្រប នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ

(iii) រក្សាទុកកំណត់ត្រាគណនេយ្យឱ្យបានគ្រប់គ្រាន់ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងប្រកបដោយប្រសិទ្ធភាព



ចុះបញ្ជីក្រោមលេខ
Registration No. 00003077
អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Building Nº 61, Preah Monivong Blvd., Sangkat Srah Chak, Khan Doun Penh, Phnom Penh, Kingdom of Cambodia.
ទូរស័ព្ទ Tel: +855 (0) 23 998 777 / 430 999, ទូរសារ Fax: +855 (0) 23 430 555, ប្រអប់សំបុត្រ P.O.Box: 1149
E-mail: acledabank@acledabank.com.kh, Website: www.acledabank.com.kh, SWIFT Code: ACLBKHPP

## ការទទួលខុសត្រូវរបស់អ្នកគ្រប់គ្រង និងអ្នកទទួលបន្ទុកលើអភិបាលកិច្ចរបាយការណ៍ហិរញ្ញវត្ថុ (ត)

(iv) រៀបចំរបាយការណ៍ហិរញ្ញវត្ថុក្នុងមូលដ្ឋាននៃការបន្តនិរន្តរភាពនៃដំណើរការអាជីវកម្ម លើកលែងតែមិនមានភាពសមស្របដែលសន្មតថាសម្ព័ន្ធធនាគារ និងធនាគារនឹងបន្តនិរន្តរភាពនៃដំណើរការអាជីវកម្មនាពេលអនាគត

(v) ត្រួតពិនិត្យ និងដឹកនាំសម្ព័ន្ធធនាគារ និងធនាគារឱ្យមានប្រសិទ្ធភាព តាមការសម្រេចចិត្តជាសារវន្តទាំងអស់ដែលជះឥទ្ធិពលដល់ប្រតិបត្តិការ និងដំណើរការរបស់សម្ព័ន្ធធនាគារ និងធនាគារ ហើយត្រូវប្រាកដថា កិច្ចការទាំងនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ និង

(vi) ការថែរក្សាទ្រព្យសម្បត្តិរបស់សម្ព័ន្ធធនាគារ និងធនាគារ ហើយក៏ត្រូវចាត់វិធានការឱ្យបានសមស្រប ដើម្បីទប់ស្កាត់ និងរកឱ្យឃើញនូវការក្លែងបន្លំ និងភាពមិនប្រក្រតីផ្សេងៗ។

អ្នកគ្រប់គ្រង និងអ្នកទទួលបន្ទុកលើអភិបាលកិច្ច ធានាអះអាងថា សម្ព័ន្ធធនាគារ និងធនាគារ បានអនុវត្តតាមរាល់តម្រូវការដូចបានរាយការណ៍ខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

**លោកស្រី ម៉ារ អមរា**
*អនុប្រធាននាយកប្រតិបត្តិជាន់ខ្ពស់ និងជាគណៈប្រធាននាយិកាប្រតិបត្តិហិរញ្ញវត្ថុ និងគណៈប្រធាននាយិកាប្រតិបត្តិប្រតិបត្តិការ*

**បណ្ឌិត អ៊ិន ចាន់នី**
*ប្រធាននាយកប្រតិបត្តិ*

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២៤



ចុះបញ្ជីក្រោមលេខ
Registration No. 00003077

អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Building Nº 61, Preah Monivong Blvd., Sangkat Srah Chak, Khan Doun Penh, Phnom Penh, Kingdom of Cambodia.
ទូរស័ព្ទ Tel: +855 (0) 23 998 777 / 430 999, ទូរសារ Fax: +855 (0) 23 430 555, ប្រអប់សំបុត្រ P.O.Box: 1149
E-mail: acledabank@acledabank.com.kh, Website: www.acledabank.com.kh, SWIFT Code: ACLBKHPP

**ការិយាល័យកណ្តាល**

អេស៊ីលីដា
ACLEDA BANK

# ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុ ព្រមទាំងកំណត់សម្គាល់ទាំងឡាយដែលភ្ជាប់មកជាមួយដូចដែលបានបង្ហាញនៅទំព័រទី១៦ ដល់ទី២៥៦ បានបង្ហាញយ៉ាងត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់នៃស្ថានភាពហិរញ្ញវត្ថុនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ លទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់ សម្រាប់ដំណាច់ការិយបរិច្ឆេទ ដែលបានបញ្ចប់របស់សម្ព័ន្ធធនាគារ និងធនាគារ បានអនុលោមទៅតាម ស.រ.ទ.ហ.អ.ក និងគោលការណ៍ណែនាំរបស់ធនាគារជាតិ នៃកម្ពុជា ត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាល។

*ចុះហត្ថលេខាដោយយោងទៅតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ។*

ធនាគារ អេស៊ីលីដា ភីអិលស៊ី
ACLEDA BANK PLC.

**លោក ឆាយ សឿន**
*ប្រធានក្រុមប្រឹក្សាភិបាល*

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២៤



ចុះបញ្ជីក្រោមលេខ
Registration No. 00003077
អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Building Nº 61, Preah Monivong Blvd., Sangkat Srah Chak, Khan Doun Penh, Phnom Penh, Kingdom of Cambodia.
ទូរស័ព្ទ Tel: +855 (0) 23 998 777 / 430 999, ទូរសារ Fax: +855 (0) 23 430 555, ប្រអប់សំបុត្រ P.O.Box: 1149
E-mail: acledabank@acledabank.com.kh, Website: www.acledabank.com.kh, SWIFT Code: ACLBKHPP

Grant Thornton

# របាយការណ៍របស់សវនករឯករាជ្យ

**ហ្គ្រេន សនថុន (ខេមបូឌា) លីមីធីត**
ជាន់ទី២០ អគារកាណាឌីយ៉ា
៣១៥ ផ្លូវព្រះអង្គឌួង
(កែងមហាវិថីព្រះមុនីវង្ស)
សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ
រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
លេខទូរសព្ទ +៨៥៥ ២៣ ៩៦៦ ៥២០
www.grantthornton.com.kh

**ជូនចំពោះក្រុមប្រឹក្សាភិបាល និង ភាគហ៊ុនិកនៃ
ធនាគារ អេស៊ីលីដា ភីអិលស៊ី និងក្រុមហ៊ុនបុត្រសម្ព័ន្ធ**

## មតិយោបល់

យើងខ្ញុំបានធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរួមរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ហៅកាត់ថា ("ធនាគារ") និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ធនាគារ ដែលតទៅនេះទាំងធនាគារ អេស៊ីលីដា ភីអិលស៊ី និងក្រុមហ៊ុនបុត្រសម្ព័ន្ធ ត្រូវហៅកាត់ថា ("សម្ព័ន្ធធនាគារ") និងរបាយការណ៍ហិរញ្ញវត្ថុដោយឡែករបស់ធនាគារ ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុរួម និងដោយឡែកនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ របស់សម្ព័ន្ធធនាគារ និងធនាគារ របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗរួម និងដោយឡែក របាយការណ៍ស្តីពីបម្រែបម្រួលមូលធន និងលំហូរសាច់ប្រាក់រួម និងដោយឡែកសម្រាប់ដំណាច់ការិយបរិច្ឆេទ ដែលបានបញ្ចប់ និងកំណត់សម្គាល់លើរបាយការណ៍រួម និងដោយឡែកដែលរួមមានគោលនយោបាយគណនេយ្យជាសារវន្ត ព្រមទាំងព័ត៌មានពន្យល់ផ្សេងៗ ដែលបានបង្ហាញនៅទំព័រទី១៦ ដល់ទី២៥៦ (តទៅនេះហៅកាត់ថា "របាយការណ៍ហិរញ្ញវត្ថុ")។

ជាមតិយោបល់របស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុរួម និងដោយឡែកដែលភ្ជាប់មកជាមួយបានបង្ហាញនូវភាពត្រឹមត្រូវជាសារវន្តអំពីស្ថានភាពហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ និងលំហូរសាច់ប្រាក់ សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("ស.រ.ទ.ហ.អ.ក") និងសេចក្តីណែនាំពីធនាគារជាតិ នៃ កម្ពុជា។

## មូលដ្ឋាននៃមតិយោបល់សវនកម្ម

យើងខ្ញុំ បានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជា ("ស.ស.អ.ក")។ ការទទួលខុសត្រូវរបស់យើងខ្ញុំ ស្របតាមស្តង់ដាទាំងនោះ ត្រូវបានរៀបរាប់បន្ថែមទៀតនៅក្នុងកថាខណ្ឌស្តីពី ការទទួលខុសត្រូវរបស់សវនករសម្រាប់ការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ ដែលមាននៅក្នុងរបាយការណ៍របស់យើងខ្ញុំ។ យើងខ្ញុំ មានភាពឯករាជ្យពីសម្ព័ន្ធធនាគារ និងធនាគារ ដោយអនុលោមតាមក្រុមប្រឹក្សាស្តង់ដាវិជ្ជាជីវៈគណនេយ្យអន្តរជាតិ ក្រមសីលធម៌របស់គណនេយ្យករជំនាញ (រួមទាំងស្តង់ដាឯករាជ្យអន្តរជាតិ) ("IESBA Code") រួមជាមួយនឹងតម្រូវការក្រមសីលធម៌ ដែលពាក់ព័ន្ធទៅនឹងការធ្វើសវនកម្មរបស់យើងខ្ញុំទៅលើរបាយការណ៍ហិរញ្ញវត្ថុ ដែលមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយយើងខ្ញុំបានបំពេញការទទួលខុសត្រូវទៅតាមតម្រូវការក្រមសីលធម៌ទាំងនោះ និង IESBA Code។ យើងខ្ញុំជឿជាក់ថា ភស្តុតាងសវនកម្មដែលយើងខ្ញុំប្រមូលបានមានលក្ខណៈគ្រប់គ្រាន់ និងសមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ។



**គណនេយ្យករជំនាញ និងសវនករប្រតិស្រុត**
សមាជិកភាពហ្គ្រេន សនថុន អន្តរជាតិ។ ហ្គ្រេន សនថុន អន្តរជាតិ និងសមាជិក គឺមិនមែនជាដៃគូពាណិជ្ជកម្មទូទាំងសកលលោកទេ។
រាល់សេវាកម្មនានាត្រូវបានផ្តល់យ៉ាងឯករាជ្យដោយសមាជិកនីមួយៗ។

## បញ្ហាសំខាន់ៗក្នុងការធ្វើសវនកម្ម

បញ្ហាសំខាន់ៗ ក្នុងការធ្វើសវនកម្ម គឺជាបញ្ហាទាំងឡាយណាដែលតាមការវិនិច្ឆ័យប្រកបដោយវិជ្ជាជីវៈរបស់យើងខ្ញុំ កំណត់ថា ជាបញ្ហាសំខាន់បំផុតក្នុងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ឆ្នាំបច្ចុប្បន្ន។ បញ្ហាទាំងនេះ ត្រូវបានដោះស្រាយក្នុងបរិបទនៃការធ្វើសវនកម្ម និងជាមូលដ្ឋានក្នុងការបញ្ចេញមតិយោបល់សវនកម្មរបស់យើងខ្ញុំ លើរបាយការណ៍ហិរញ្ញវត្ថុទាំងមូល ដោយមិនមានការបញ្ចេញមតិសវនកម្មដាច់ដោយឡែកសម្រាប់បញ្ហានេះទេ។

ខាងក្រោមនេះ គឺជាបញ្ហាសំខាន់ៗក្នុងការធ្វើសវនកម្ម ដែលត្រូវបានកំណត់នៅក្នុងការធ្វើសវនកម្មរបស់យើងខ្ញុំ ទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារៈ

| បញ្ហាសំខាន់ៗក្នុងការធ្វើសវនកម្ម | វិធីដែលបញ្ហានេះត្រូវបានដោះស្រាយក្នុងការធ្វើសវនកម្មរបស់យើងខ្ញុំ |
|---|---|
| **សំវិធានធនសម្រាប់ឱនភាពនៃការខាតបង់តម្លៃទៅលើឥណទាន និងបុរេប្រទាន**<br><br>ឥណទាន និងបុរេប្រទាន មានចំនួនប្រមាណ ៦៧,៧៥% និង ៦៧,២២% នៃទ្រព្យសកម្មសរុបរបស់សម្ព័ន្ធធនាគារ និង ធនាគារ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣។ ផលបត្រឥណទានរបស់សម្ព័ន្ធធនាគារ និងធនាគាររួមមានប្រាក់កម្ចី និងបុរេប្រទានផ្តល់ដល់អតិថិជន (ទាំងក្រុមហ៊ុនសាជីវកម្ម និង ឯកត្តជន) ការបោះដុំ និងលក់រាយ សេវាកម្ម និងកសិកម្ម។ យោងទៅលើកំណត់សម្គាល់លេខ ៣៨.១ (ឃ) (២) សម្រាប់ព័ត៌មានលម្អិត។<br><br>សម្ព័ន្ធធនាគារ និងធនាគារ បានបង្ហាញពីការខាតបង់ឥណទានដែលបានរំពឹងទុក ("ECL") គំរូមានភាពជាសារវន្តទៅលើការធ្វើសវនកម្មរបស់យើងខ្ញុំ ដែលតម្រូវឱ្យប្រើប្រាស់នូវគំរូស្មុគស្មាញ និងការសន្មតសំខាន់ៗអំពីស្ថានភាពសេដ្ឋកិច្ចនាពេលអនាគត និងស្ថានភាពឥណទាន។ គំរូ ECL នេះតម្រូវឱ្យមានការពិចារណាពីការវិនិច្ឆ័យ និងបកស្រាយ នៅក្នុងការអនុវត្តលើតម្រូវការរបស់ស្តង់ដាគណនេយ្យ ស.រ.ទ.ហ.អ.ក ៩ *ស្តីពីឧបករណ៍ហិរញ្ញវត្ថុ* ដែលនាំមកនូវភាពមិនច្បាស់លាស់ខ្ពស់នៃការប៉ាន់ស្មាន។ | នីតិវិធីសវនកម្មរបស់យើងខ្ញុំមានដូចខាងក្រោមៈ<br><br>• យើងខ្ញុំបានធ្វើបច្ចុប្បន្នភាពពីការយល់ដឹងនៃការវាយតម្លៃលើការកែតម្រូវ និងការអនុវត្ត ព្រមទាំងពិនិត្យលើប្រសិទ្ធភាពនៃការគ្រប់គ្រងសំខាន់ៗទៅលើសំវិធានធនសម្រាប់ឱនភាពនៃការខាតបង់។ ការត្រួតពិនិត្យក្នុងចំណោមផ្សេងៗទៀតរួមមានៈ<br>- ធ្វើការត្រួតពិនិត្យការស្នើសុំកម្ចី និងត្រួតពិនិត្យលើឥណទាន<br>- ការកំណត់អត្តសញ្ញាណនៃការកើនឡើងនូវហានិភ័យឥណទានសំខាន់ៗ<br>- ការត្រួតពិនិត្យ នៃលទ្ធភាពសងរបស់អ្នកខ្ចីនិង<br>- ភាពត្រឹមត្រូវនៃការបញ្ចូលទិន្នន័យ។<br><br>• យើងខ្ញុំបានធ្វើការវាយតម្លៃថាតើវិធីសាស្ត្រ និងការសន្មតដែលបានប្រើប្រាស់នៅក្នុងម៉ូដែល ECL គឺសមស្របជាមួយនឹងតម្រូវការរបស់ស.រ.ទ.ហ.អ.ក ៩ រួមបញ្ចូលទាំងផលប៉ះពាល់បន្តនៃជំងឺកូវីដ-១៩។ |



**គណនេយ្យករជំនាញ និងសវនករប្រតិស្រុត**
សមាជិកភាពហ្គ្រេន សនថុន អន្តរជាតិ។ ហ្គ្រេន សនថុន អន្តរជាតិ និងសមាជិក គឺមិនមែនជាដៃគូពាណិជ្ជកម្មទូទាំងសកលលោកទេ។
រាល់សេវាកម្មនានាត្រូវបានផ្តល់យ៉ាងឯករាជ្យដោយសមាជិកនីមួយៗ។

<table>
<tr><th>បញ្ហាសំខាន់ៗក្នុងការធ្វើសវនកម្ម</th><th>វិធីដែលបញ្ហានេះត្រូវបានដោះស្រាយក្នុងការធ្វើសវនកម្មរបស់យើងខ្ញុំ</th></tr>
<tr><td>ការវិនិច្ឆ័យសំខាន់ៗនៅក្នុងការអនុវត្តគណនេយ្យដែលតម្រូវនៅក្នុងការវាស់វែង ECL រួមមានដូចខាងក្រោម៖<br><br>• បង្កើតម៉ូដែលដែលសមស្របនៃការវាយតម្លៃដែលបានប្រើប្រាស់ក្នុងការគណនា ECL។ ម៉ូដែលទាំងនេះ គឺមានភាពស្មុគស្មាញ ហើយការវិនិច្ឆ័យគឺត្រូវបានអនុវត្តក្នុងការកំណត់លើការបង្កើតឡើងនូវម៉ូដែលដែលសមស្រប<br>• ការកំណត់អត្តសញ្ញាណនៃឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន ឱ្យទាន់ពេលវេលា និងហិរញ្ញប្បទានដែលមានការកើនឡើងគួរឱ្យកត់សម្គាល់នៅក្នុងហានិភ័យឥណទាន<br>• ការសន្មតដែលបានប្រើប្រាស់នៅក្នុងម៉ូដែល ECL មានដូចជាលំហូរសាច់ប្រាក់នាថ្ងៃអនាគតដែលបានរំពឹងទុកកត្តាម៉ាក្រូសេដ្ឋកិច្ចថ្ងៃអនាគត និង ទិន្នន័យកំណត់ និង<br>• ការបន្តផលប៉ះពាល់នៃជំងឺរាតត្បាតកូវីដ-១៩ ដែលពាក់ព័ន្ធទៅនឹងការវិនិច្ឆ័យសំខាន់ដូចដែលបានរៀបរាប់ខាងលើ។<br><br>គោលនយោបាយគណនេយ្យលម្អិតដែលសម្ព័ន្ធធនាគារ និងធនាគារ បានប្រើប្រាស់ក្នុងការវិនិច្ឆ័យ គណនេយ្យសំខាន់ៗ និងការប៉ាន់ស្មានមិនច្បាស់លាស់ និងការគ្រប់គ្រងហានិភ័យដែលបានប្រើប្រាស់បានបង្ហាញនៅក្នុងកំណត់សម្គាល់លេខ ២ (ង) (vii) ៤ និង៣៨.១ លើរបាយការណ៍ហិរញ្ញវត្ថុ។</td><td>• យើងខ្ញុំបានធ្វើការពិនិត្យទៅលើម៉ូដែលក្នុងការត្រួតពិនិត្យទៅលើភាពសមស្របនៃការផ្តល់ចំណាត់ថ្នាក់ និងដំណាក់កាលឥណទានត្រូវបានធ្វើការវាយតម្លៃ និងការសន្និដ្ឋានរបស់អ្នកគ្រប់គ្រងទៅលើលទ្ធភាពនៃការទទួលបានឥណទាន និងការធ្វើចំណាត់ថ្នាក់ទៅលើឥណទានដែលបានជ្រើសរើស។<br>• យើងខ្ញុំបានវាយតម្លៃទៅលើដំណើរការដែលបានប្រើប្រាស់ដោយអ្នកគ្រប់គ្រងដើម្បីអភិវឌ្ឍព័ត៌មាននាពេលអនាគត (ការត្រួតគ្នា) ដែលបានប្រើក្នុងគំរូ ECL និងបានផ្ទៀងផ្ទាត់ភាពសមហេតុផលរបស់វាដែលទាក់ទងនឹងព័ត៌មានជាសាធារណៈ និងការយល់ដឹងរបស់យើងខ្ញុំ នៃសំពៀតឥណទានរបស់ធនាគារ និងសម្ព័ន្ធធនាគារ និងវិស័យ ដែលសម្ព័ន្ធធនាគារធ្វើប្រតិបត្តិការ។ លើសពីនេះទៀត យើងខ្ញុំបានវាយតម្លៃកម្រិតនៃការពាក់ព័ន្ធចម្បងរបស់កត្តាម៉ាក្រូសេដ្ឋកិច្ចដែលបានជ្រើសរើសទៅនឹងអត្រាខកខានសង ក៏ដូចជាផលប៉ះពាល់នៃបម្រែបម្រួល ECL ទាំងនេះ។<br>• យើងខ្ញុំបានធ្វើការពិនិត្យទៅលើភាពត្រឹមត្រូវនៃធាតុចូលសំខាន់ៗដែលមាននៅក្នុងម៉ូដែល ECL តាមរយៈការប្រៀបធៀបជាមួយប្រព័ន្ធនៃប្រភពឯកសារ និងឯកសារ។<br>• យើងខ្ញុំបានគណនាឡើងវិញនូវ ECL ដើម្បីសាកល្បងលើភាពត្រឹមត្រូវនៃការគណនានៃគំរូ ECL។<br>• យើងខ្ញុំបានធ្វើការវាយតម្លៃលើភាពគ្រប់គ្រាន់នៃការលាតត្រដាងដើម្បីធានាបាននូវការអនុលោមលើ ស.រ.ទ.ហ.អ.ក ៩។<br><br>យើងខ្ញុំក៏បានចូលរួមជាមួយអ្នកឯកទេសរបស់យើងខ្ញុំក្នុងការអនុវត្តទៅលើនីតិវិធីខាងលើនៅពេលដែលជំនាញជាក់លាក់ត្រូវការចាំបាច់។</td></tr>
</table>



**គណនេយ្យករជំនាញ និងសវនករប្រតិស្រុត**
សមាជិកភាពហ្គ្រេន សនថុន អន្តរជាតិ។ ហ្គ្រេន សនថុន អន្តរជាតិ និងសមាជិក គឺមិនមែនជាដៃគូពាណិជ្ជកម្មទូទាំងសកលលោកទេ។
រាល់សេវាកម្មនានាត្រូវបានផ្តល់យ៉ាងឯករាជ្យដោយសមាជិកនីមួយៗ។

## ព័ត៌មានផ្សេងៗ

អ្នកគ្រប់គ្រងមានភារៈកិច្ចទទួលខុសត្រូវលើព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗ រួមទាំងព័ត៌មានដែលបានរាយការណ៍នៅក្នុងរបាយការណ៍របស់ក្រុមប្រឹក្សាភិបាលនៅ ទំព័រទី១ ដល់ទី៨ ប៉ុន្តែមិនរួមបញ្ចូលរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សវនកម្មរបស់យើងខ្ញុំឡើយ ដែលយើងខ្ញុំទទួលបានមុនកាលបរិច្ឆេទនៃរបាយការណ៍សវនករនេះ ព្រមជាមួយរបាយការណ៍ប្រចាំឆ្នាំដែលត្រូវបានរំពឹងទុកថាបានរៀបចំរួចរាល់សម្រាប់ប្រើប្រាស់បន្ទាប់ពីកាលបរិច្ឆេទ។

មតិយោបល់របស់យើងខ្ញុំ ទៅលើរបាយការណ៍ហិរញ្ញវត្ថុ មិនបានគ្របដណ្តប់លើព័ត៌មានផ្សេងៗឡើយ ហើយយើងខ្ញុំមិនធ្វើការផ្តល់នូវអំណះអំណាងណាមួយទៅលើព័ត៌មាននេះទេ។

ការទទួលខុសត្រូវរបស់យើងខ្ញុំ ពាក់ព័ន្ធនឹងការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុ គឺត្រូវអានព័ត៌មានផ្សេងៗ ហើយពិចារណាថា តើព័ត៌មានផ្សេងៗទាំងនោះមានភាពមិនស្របគ្នាជាសារវន្តជាមួយរបាយការណ៍ហិរញ្ញវត្ថុ ឬការយល់ដឹងរបស់យើងខ្ញុំ ដែលទទួលបាននៅក្នុងការធ្វើសវនកម្ម ឬមានបង្ហាញនូវកំហុសឆ្គងជាសារវន្តឬទេ។

ប្រសិនបើការអានព័ត៌មានផ្សេងៗ ដែលបានទទួលមុនកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះ អាចឱ្យយើងខ្ញុំសន្និដ្ឋានថា មានកំហុសឆ្គងជាសារវន្តកើតឡើងលើព័ត៌មានផ្សេងៗនេះ យើងខ្ញុំត្រូវរាយការណ៍ទៅតាមស្ថានភាពជាក់ស្តែង។ យើងខ្ញុំពុំមានអ្វីដែលត្រូវរាយការណ៍ពាក់ព័ន្ធនឹងព័ត៌មានផ្សេងៗនេះទេ។

នៅពេលដែលយើងខ្ញុំអានរបាយការណ៍ប្រចាំឆ្នាំ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាមានកំហុសឆ្គងជាសារវន្តណាមួយកើតមានឡើង យើងខ្ញុំត្រូវធ្វើការទាក់ទងជាមួយក្រុមប្រឹក្សាភិបាល និងទទួលខុសត្រូវលើបញ្ហាទាំងនេះដោយអនុលោមតាមការតម្រូវរបស់ CISA ៧២០ (បានធ្វើការកែតម្រូវ)។

## ការទទួលខុសត្រូវលើរបាយការណ៍ហិរញ្ញវត្ថុរបស់អ្នកគ្រប់គ្រង និងអ្នកទទួលខុសត្រូវលើអភិបាលកិច្ច

អ្នកគ្រប់គ្រង មានភារៈទទួលខុសត្រូវលើការរៀបចំ និងការបង្ហាញនូវភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា និងសេចក្តីណែនាំរបស់ធនាគារជាតិ នៃ កម្ពុជា និងទទួលខុសត្រូវលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលអ្នកគ្រប់គ្រងកំណត់ថាមានភាពចាំបាច់ សម្រាប់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុឱ្យចៀសផុតពីការបង្ហាញខុសជាសារវន្ត ដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ អ្នកគ្រប់គ្រង មានភារៈទទួលខុសត្រូវលើការវាយតម្លៃនូវលទ្ធភាពរបស់សម្ព័ន្ធធនាគារ និងធនាគារ ក្នុងការបន្តនិរន្តរភាពអាជីវកម្ម ការលាតត្រដាងព័ត៌មាន ប្រសិនបើពាក់ព័ន្ធនូវបញ្ហាទាំងឡាយដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យ លើកលែងតែអ្នកគ្រប់គ្រងមានបំណងចង់ជម្រះបញ្ជី ផ្អាកដំណើរការសម្ព័ន្ធធនាគារ និងធនាគារ ឬគ្មានជម្រើសសមរម្យដទៃទៀតក្រៅពីធ្វើបែបនេះ។

អ្នកទទួលខុសត្រូវលើអភិបាលកិច្ច មានភារៈទទួលខុសត្រូវក្នុងការត្រួតពិនិត្យដំណើរការនៃការរាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ។



គណនេយ្យករជំនាញ និងសវនករប្រតិស្រុត
សមាជិកភាពហ្គ្រេន សនថុន អន្តរជាតិ។ ហ្គ្រេន សនថុន អន្តរជាតិ និងសមាជិក គឺមិនមែនជាដៃគូពាណិជ្ជកម្មទូទាំងសកលលោកទេ។
រាល់សេវាកម្មនានាត្រូវបានផ្តល់យ៉ាងឯករាជ្យដោយសមាជិកនីមួយៗ។

## ការទទួលខុសត្រូវរបស់សវនករ សម្រាប់ការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ

គោលដៅរបស់យើងខ្ញុំ គឺទទួលបាននូវអំណះអំណាងសមហេតុផលថារបាយការណ៍ហិរញ្ញវត្ថុទាំងមូលមិនមានការបង្ហាញខុសជាសារវន្តដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងផ្តល់នូវរបាយការណ៍របស់សវនករដែលរួមបញ្ចូលមតិយោបល់របស់យើងខ្ញុំ។ អំណះអំណាងសមហេតុផល គឺជាអំណះអំណាងមានកម្រិតខ្ពស់មួយ ប៉ុន្តែវាមិនអាចធានាថា គ្រប់ពេលនៃការធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជា អាចរកឃើញនូវការបង្ហាញខុសជាសារវន្តដែលបានកើតឡើងនោះទេ។ ការបង្ហាញខុសជាសារវន្តអាចកើតឡើងដោយសារការក្លែងបន្លំ ឬកំហុសឆ្គង ហើយត្រូវបានចាត់ទុកថាជាសារវន្ត នៅពេលដែលការក្លែងបន្លំ ឬកំហុសឆ្គងតែមួយ ឬក៏រួមបញ្ចូលគ្នា មានផលប៉ះពាល់ដល់ការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ ដោយយោងលើមូលដ្ឋាននៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

ជាផ្នែកមួយនៃការធ្វើសវនកម្ម ដោយអនុលោមតាមស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជា យើងខ្ញុំអនុវត្តនូវការវិនិច្ឆ័យដែលប្រកបទៅដោយវិជ្ជាជីវៈ និងរក្សានូវមជ្ឈធាតុនិយម ក្នុងអំឡុងពេលសវនកម្ម។ យើងខ្ញុំក៏បាន៖

- ធ្វើការកំណត់ និងវាយតម្លៃនូវហានិភ័យនៃការបង្ហាញខុសជាសារវន្តលើរបាយការណ៍ហិរញ្ញវត្ថុ ថាតើវាកើតឡើងដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងទទួលខុសត្រូវលើការរៀបចំ និងការអនុវត្តនូវនីតិវិធីសវនកម្មដើម្បីឆ្លើយតបទៅនឹងហានិភ័យទាំងនោះ និងប្រមូលនូវភស្តុតាងដែលមានលក្ខណៈគ្រប់គ្រាន់ និងសមស្របជាមូលដ្ឋានសម្រាប់មតិយោបល់របស់យើងខ្ញុំ។ ហានិភ័យដែលមិនអាចរកឃើញ នូវការបង្ហាញខុសជាសារវន្តដែលកើតឡើង ដោយសារបណ្តាលមកពីការក្លែងបន្លំមានលក្ខណៈខ្ពស់ជាងការបង្ហាញខុសកើតឡើងពីកំហុសឆ្គង ដោយសារតែការក្លែងបន្លំ អាចរួមបញ្ចូលទាំងការឃុបឃិតគ្នា ការលួចបន្លំ ការលុបចោលដោយចេតនា ការបកស្រាយមិនពិត ឬមិនអនុវត្តតាមនីតិវិធីគ្រប់គ្រងផ្ទៃក្នុង។
- ធ្វើការស្វែងយល់អំពីការគ្រប់គ្រងផ្ទៃក្នុង ដែលពាក់ព័ន្ធនឹងការធ្វើសវនកម្ម ក្នុងគោលបំណងដើម្បីរៀបចំនូវនីតិវិធីសវនកម្មដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនមែនក្នុងគោលបំណងដើម្បីបញ្ចេញមតិយោបល់លើប្រសិទ្ធភាពនៃការគ្រប់គ្រងផ្ទៃក្នុងរបស់សម្ព័ន្ធធនាគារ និងធនាគារឡើយ។
- ធ្វើការវាយតម្លៃលើភាពសមស្របនៃគោលនយោបាយគណនេយ្យដែលបានប្រើប្រាស់ និងភាពសមហេតុផលនៃគណនេយ្យប៉ាន់ស្មានសំខាន់ៗ ព្រមទាំងការលាតត្រដាងព័ត៌មានពាក់ព័ន្ធដែលបានធ្វើឡើងដោយអ្នកគ្រប់គ្រង។
- ធ្វើការសន្និដ្ឋានលើភាពសមស្រប ចំពោះការប្រើប្រាស់មូលដ្ឋានគណនេយ្យរបស់អ្នកគ្រប់គ្រង ក្នុងការរក្សានិរន្តរភាព និងដោយផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបានដើម្បីធ្វើការសន្និដ្ឋានថាតើភាពមិនច្បាស់លាស់ជាសារវន្តកើតឡើងពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលអាចធ្វើឱ្យមានមន្ទិលជាសារវន្តលើលទ្ធភាពរបស់សម្ព័ន្ធធនាគារ និងធនាគារដើម្បីបន្តរក្សានិរន្តរភាពអាជីវកម្មដែរឬទេ។ ប្រសិនបើយើងខ្ញុំធ្វើការសន្និដ្ឋានថា មានភាពមិនប្រាកដប្រជាជាសារវន្តបានកើតឡើង យើងខ្ញុំចាំបាច់ត្រូវបញ្ចូលនៅក្នុងរបាយការណ៍សវនកម្មរបស់យើងខ្ញុំ ដើម្បីទាញចំណាប់អារម្មណ៍លើការលាតត្រដាងព័ត៌មានពាក់ព័ន្ធនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើការលាតត្រដាងព័ត៌មាន មានលក្ខណៈមិនគ្រប់គ្រាន់ យើងខ្ញុំចាំបាច់ត្រូវធ្វើការកែប្រែមតិយោបល់របស់យើងខ្ញុំ។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺផ្អែកតាមភស្តុតាងសវនកម្ម ដែលប្រមូលបានត្រឹមកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មរបស់យើងខ្ញុំ។ ទោះជាយ៉ាងណាក៏ដោយ ព្រឹត្តិការណ៍ ឬលក្ខខណ្ឌនាពេលអនាគតអាចធ្វើឱ្យសម្ព័ន្ធធនាគារ និងធនាគារបញ្ឈប់និរន្តរភាពនៃអាជីវកម្មបាន។



**គណនេយ្យករជំនាញ និងសវនករប្រតិស្រុត**
សមាជិកភាពហ្គ្រេន សនថុន អន្តរជាតិ។ ហ្គ្រេន សនថុន អន្តរជាតិ និងសមាជិក គឺមិនមែនជាដៃគូពាណិជ្ជកម្មទូទាំងសកលលោកទេ។
រាល់សេវាកម្មនានាត្រូវបានផ្តល់យ៉ាងឯករាជ្យដោយសមាជិកនីមួយៗ។

- វាយតម្លៃលើការបង្ហាញ ទម្រង់ និងខ្លឹមសារនៃរបាយការណ៍ហិរញ្ញវត្ថុទាំងមូល ដែលរួមបញ្ចូលទាំងការលាតត្រដាងព័ត៌មានថាតើរបាយការណ៍ហិរញ្ញវត្ថុបានបង្ហាញពីប្រតិបត្តិការ និងព្រឹត្តិការណ៍ពាក់ព័ន្ធក្នុងអត្ថន័យដែលអាចសម្រេចបាននូវការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដ៏ត្រឹមត្រូវ។
- ប្រមូលនូវភស្តុតាងសវនកម្មដែលសមស្រប និងគ្រប់គ្រាន់ ពាក់ព័ន្ធនឹងព័ត៌មានហិរញ្ញវត្ថុនៃអង្គភាព ឬសកម្មភាពអាជីវកម្ម នៅក្នុងសម្ព័ន្ធធនាគារ ដើម្បីបញ្ចេញមតិយោបល់លើរបាយការណ៍ហិរញ្ញវត្ថុរួម។ យើងខ្ញុំទទួលខុសត្រូវក្នុងការដឹកនាំ ការត្រួតត្រាមើល និងការប្រតិបត្តិសវនកម្មរបស់សម្ព័ន្ធធនាគារ។ យើងខ្ញុំរក្សាការទទួលខុសត្រូវលើមតិយោបល់សវនកម្មរបស់យើងខ្ញុំ។

នៅពេលដែលសម្ព័ន្ធលែងមានអភិបាលភាព អត្ថប្រយោជន៍ដែលមាននៅក្នុងក្រុមហ៊ុនត្រូវបានវាស់វែងឡើងវិញទៅតាមតម្លៃសមស្រប នៅកាលបរិច្ឆេទដែលអភិបាលភាពបានបាត់បង់ជាមួយនឹងការផ្លាស់ប្តូរសមតុល្យយោងដែលត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាត។ តម្លៃសមស្របគឺជាតម្លៃយោងដំបូងសម្រាប់គោលបំណងគណនេយ្យជាបន្តបន្ទាប់ សម្រាប់អត្ថប្រយោជន៍ដែលត្រូវទទួលបានទុកជាសមាគត ការដាក់ទុនរួមគ្នា ឬទ្រព្យសកម្មហិរញ្ញវត្ថុ។ លើសពីនេះទៀត ចំនួនទឹកប្រាក់ ដែលត្រូវបានទទួលស្គាល់នៅគ្រាមុននៅក្នុងលទ្ធផលលម្អិតផ្សេងៗទាក់ទងនឹងអង្គភាពនោះ ត្រូវកត់ត្រាដូចករណីដែលសម្ព័ន្ធបានលក់ដោយផ្ទាល់នៃទ្រព្យសកម្ម ឬសងបំណុលដែលពាក់ព័ន្ធ។ វាអាចមានន័យថា ចំនួនដែលបានទទួលស្គាល់លើនៅគ្រាមុននៅក្នុងលទ្ធផលលម្អិតផ្សេងៗ ត្រូវបានចាត់ថ្នាក់ឡើងវិញទៅក្នុងរបាយការណ៍ប្រាក់ចំណេញ ឬខាត។

*(iv) ការផ្លាស់ប្តូរអត្ថប្រយោជន៍ភាគហ៊ុនិកក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ ដោយមិនផ្លាស់ប្តូរអភិបាលភាព*

ប្រតិបត្តិការជាមួយភាគកម្មមិនមានអភិបាលភាព ("NCI") ដែលមិនធ្វើឱ្យមានការបាត់បង់អភិបាលភាពត្រូវបានកត់ត្រាជាប្រតិបត្តិការមូលធនដូចប្រតិបត្តិការជាមួយម្ចាស់ក្រុមហ៊ុនក្នុងនាមជាម្ចាស់ដែរ។ ករណីមានការទិញពីភាគកម្មមិនមានអភិបាលភាពលម្អៀងរវាងតម្លៃតបស្នងដែលបានបង់ និងចំណែកពាក់ព័ន្ធនៃតម្លៃយោងទ្រព្យសកម្មសុទ្ធរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធដែលបានទិញ ត្រូវបានកត់ត្រាដកចេញពីមូលធន។ ករណីមានការលក់ភាគកម្មមិនមានអភិបាលភាព លម្អៀងរវាងតម្លៃតបស្នងដែលបានទទួល និងចំណែកភាគហ៊ុនពាក់ព័ន្ធនៃភាគកម្មមិនមានអភិបាលដែលបានលក់ក៏ត្រូវកត់ត្រាក្នុងមូលធនដែរ។

## ២. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត (ត)

### (គ) របាយការណ៍ហិរញ្ញវត្ថុរួម (ត)

*(v) ភាគកម្មមិនមានអភិបាលភាព*

ភាគកម្មមិនមានអភិបាលភាពត្រូវបានវាស់វែងដំបូងតាមចំណែកសមាមាត្រនៃទ្រព្យសកម្មសុទ្ធដែលអាចកំណត់អត្តសញ្ញាណនៅកាលបរិច្ឆេទនៃការទិញ។

ការផ្លាស់ប្តូរភាគកម្មនៅក្រុមហ៊ុនបុត្រសម្ព័ន្ធ ដែលមិនធ្វើឱ្យមានការបាត់បង់អភិបាលភាពត្រូវបានកត់ត្រាជាប្រតិបត្តិការមូលធន។

អង្គភាពមានជម្រើសតាមមូលដ្ឋានរួមបញ្ចូលគ្នា ដើម្បីវាស់វែងភាគកម្មមិនមានអភិបាលភាពណាមួយ ក្នុងការទិញតាមចំណែកសមាមាត្រនៃទ្រព្យសកម្មសុទ្ធដែលអាចកំណត់អត្តសញ្ញាណនៃការទិញ ឬតាមតម្លៃសមស្រប។ សម្ព័ន្ធធនាគារ បានជ្រើសរើសដើម្បីរក្សាវិធីសាស្ត្រពីមុន។

ភាគកម្មមិនមានអភិបាលភាព នៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធត្រូវបានកំណត់ដាច់ដោយឡែកពីមូលធនរបស់សម្ព័ន្ធធនាគារ។ បន្ទាប់ពីការទិញ តម្លៃចុះបញ្ជីរបស់ភាគកម្មមិនមានអភិបាលភាព គឺជាចំនួននៃភាគកម្មទាំងនោះ ដែលបានទទួលស្គាល់ដំបូងបូកនឹងចំណែករបស់ភាគកម្មមិនមានអភិបាលភាពនៃបម្រែបម្រួលមូលធនបន្តបន្ទាប់។

### (ឃ) ការប្រែសម្រួលរូបិយប័ណ្ណបរទេស

*(i) រូបិយប័ណ្ណមុខងារ និងរូបិយប័ណ្ណសម្រាប់ការបង្ហាញ*

ធាតុនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារត្រូវបានវាស់វែងដោយប្រើប្រាស់រូបិយប័ណ្ណនៃបរិស្ថានសេដ្ឋកិច្ចសំខាន់ ដែលក្រុមហ៊ុនប្រើនៅក្នុងកិច្ចប្រតិបត្តិការ ("រូបិយប័ណ្ណមុខងារ")។ របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិក ("US$" ឬ "USD") ដែលជារូបិយប័ណ្ណមុខងារ និងជារូបិយប័ណ្ណសម្រាប់ការបង្ហាញរបស់សម្ព័ន្ធធនាគារ និងធនាគារ។

*(ii) ប្រតិបត្តិការ និងសមតុល្យ*

ប្រតិបត្តិការជារូបិយប័ណ្ណផ្សេងៗក្រៅពីប្រាក់ដុល្លារអាមេរិក ត្រូវបានប្រែសម្រួលទៅជារូបិយប័ណ្ណមុខងារតាមអត្រាប្តូរប្រាក់នាកាលបរិច្ឆេទនៃប្រតិបត្តិការនោះ។ ចំណេញ និងខាតពីការប្តូររូបិយប័ណ្ណបរទេសដែលកើតមកពីការទូទាត់ប្រតិបត្តិការទាំងនេះ និងពីការប្រែសម្រួលអត្រាប្តូរប្រាក់ នៅចុងឆ្នាំរបស់ទ្រព្យសកម្ម និងបំណុលរូបិយវត្ថុនានា ដែលកំណត់ជារូបិយប័ណ្ណផ្សេងៗ ក្រៅពីប្រាក់ដុល្លារអាមេរិក ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ។

## ២. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត (ត)

### (ឃ) ការប្រែសម្រួលរូបិយប័ណ្ណបរទេស (ត)

*(iii) សម្ព័ន្ធធនាគារ*

របាយការណ៍លទ្ធផល និងស្ថានភាពហិរញ្ញវត្ថុ នៃកិច្ចប្រតិបត្តិការក្រៅប្រទេស (ដែលមិនមានរូបិយប័ណ្ណនៃសេដ្ឋកិច្ចដែលមានអតិផរណាខ្ពស់ហួសហេតុ) ដែលមានរូបិយប័ណ្ណមុខងារខុសគ្នាពីរូបិយប័ណ្ណសម្រាប់ការបង្ហាញរបស់ធនាគារ ត្រូវបានប្រែសម្រួលទៅជារូបិយប័ណ្ណសម្រាប់ការបង្ហាញ ដូចខាងក្រោម៖

ក) ទ្រព្យសកម្ម និងបំណុលសម្រាប់របាយការណ៍ស្ថានភាពហិរញ្ញវត្ថុនីមួយៗដែលបានបង្ហាញ ត្រូវបានប្រែសម្រួលតាមអត្រាបិទបញ្ជីនៅចុងការិយបរិច្ឆេទនៃរបាយការណ៍

ខ) ប្រាក់ចំណូល និងចំណាយ សម្រាប់របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗនីមួយៗ ដែលបានបង្ហាញ ត្រូវបានប្រែសម្រួលតាមអត្រាប្តូរប្រាក់ជាមធ្យម (លើកលែងតែអត្រាមធ្យមនេះមិនមែនជាភាពប្រហាក់ប្រហែលសមហេតុផលនៃផលប៉ះពាល់បង្គររបស់អត្រាប្តូររូបិយប័ណ្ណ នៅកាលបរិច្ឆេទប្រតិបត្តិការ ក្នុងករណីដែលចំណូល និងចំណាយ ត្រូវបានប្រែសម្រួលតាមអត្រានៅកាលបរិច្ឆេទនៃប្រតិបត្តិការនេះ) និង

គ) រាល់ភាពខុសគ្នានៃលម្អៀងពីការប្តូររូបិយប័ណ្ណ ត្រូវបានទទួលស្គាល់ជាសមាសធាតុដាច់ដោយឡែកនៃមូលធន។

ជារួមមកលម្អៀងពីការប្តូររូបិយប័ណ្ណដែលកើតឡើងពីការប្រែសម្រួលនៃការវិនិយោគសុទ្ធនៅក្នុងកិច្ចប្រតិបត្តិការបរទេសណាមួយ ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផលលម្អិតផ្សេងៗ នៅក្នុងមូលដ្ឋាននៃការរួមបញ្ចូលគ្នា។ នៅពេលកិច្ចប្រតិបត្តិការបរទេស ត្រូវបានលក់ដោយផ្នែកលម្អៀងពីការប្តូររូបិយប័ណ្ណ ត្រូវបានចាត់ថ្នាក់ឡើងវិញទៅក្នុងរបាយការណ៍ចំណេញ ឬខាត និងលទ្ធផល លម្អិតផ្សេងៗ ដែលជាចំណេញ ឬខាតពីការលក់។

### (ង) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ

*(i) ការទទួលស្គាល់ និងការវាស់វែងលើកដំបូង*

សម្ព័ន្ធធនាគារ និងធនាគារទទួលស្គាល់លើកដំបូងនូវឥណទាន និងបុរេប្រទាន ប្រាក់បញ្ញើនៅធនាគារផ្សេងៗ ប្រាក់កម្ចី និង បំណុលបន្ទាប់បន្សំ នៅកាលបរិច្ឆេទដែលកើតមាន។ ឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត (រួមមានការទិញ និងលក់ទ្រព្យសកម្មហិរញ្ញវត្ថុជាប្រចាំ) ត្រូវបានទទួលស្គាល់នៅកាលបរិច្ឆេទជួញដូរ ដែលសម្ព័ន្ធធនាគារ និងធនាគារក្លាយជាភាគីនៃកិច្ចសន្យារបស់ឧបករណ៍។

ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ ត្រូវបានវាស់វែងលើកដំបូងតាមតម្លៃសមស្រប បូកនឹងឧបករណ៍ដែលមិនមែនវាស់វែងតាមតម្លៃសមស្របតាមរយៈចំណេញ ឬខាត ("FVTPL") ចំណាយប្រតិបត្តិការដែលកើតមកពីការទិញ ឬចេញផ្សាយទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ។

## ២. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត (ត)

### (ង) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

*(ii) ការធ្វើចំណាត់ថ្នាក់*

នៅក្នុងការទទួលស្គាល់លើកដំបូង ទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានចាត់ថ្នាក់ជា ថ្លៃដើមបានរំលស់ តម្លៃសមស្របតាមរយៈចំណេញ ឬខាត ("FVTPL") ឬតម្លៃសមស្របតាមរយៈលទ្ធផលលម្អិតផ្សេងៗ ("FVOCI") ។

ទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានវាស់វែងតាមថ្លៃដើមបានរំលស់ ប្រសិនបើវាបំពេញតាមលក្ខខណ្ឌទាំងពីរដូចខាងក្រោម ហើយមិនត្រូវបានកំណត់ជា FVTPL នោះទេ៖

- ទ្រព្យសកម្មដែលមាននៅក្នុងម៉ូដែលអាជីវកម្ម ក្នុងគោលបំណងរក្សាទុកដើម្បីការប្រមូលសាច់ប្រាក់តាមកិច្ចសន្យានិង
- លក្ខខណ្ឌនៃកិច្ចសន្យារបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ផ្តល់នូវកាលបរិច្ឆេទជាក់លាក់ចំពោះលំហូរសាច់ប្រាក់ដែលត្រូវទូទាត់តែប្រាក់ដើម និងការប្រាក់ តាមបរិមាណប្រាក់ដើមនៅជំពាក់ ("SPPI")។

ឧបករណ៍បំណុល ត្រូវបានវាស់វែងតាម FVOCI លុះត្រាតែវាបានបំពេញតាមលក្ខខណ្ឌទាំងពីរដូចខាងក្រោម ហើយមិនត្រូវបានកំណត់ជា FVTPL នោះទេ៖

- ទ្រព្យសកម្មដែលមាននៅក្នុងម៉ូដែលអាជីវកម្ម ក្នុងគោលបំណងរក្សាទុកដើម្បីការប្រមូលសាច់ប្រាក់តាមកិច្ចសន្យា និងការលក់ទ្រព្យសកម្មហិរញ្ញវត្ថុ និង
- លក្ខខណ្ឌនៃកិច្ចសន្យារបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ផ្តល់នូវកាលបរិច្ឆេទជាក់លាក់ចំពោះលំហូរសាច់ប្រាក់ដែលជា SPPI។

សម្រាប់ការទទួលស្គាល់ការវិនិយោគលើមូលធនលើកដំបូង ដែលមិនត្រូវបានកាន់កាប់សម្រាប់ជួញដូរ សម្ព័ន្ធធនាគារ និងធនាគារ ត្រូវអាចជ្រើសរើសជាស្ថាពរដើម្បីបង្ហាញការប្រែប្រួលតម្លៃសមស្របនៅគ្រាបន្ទាប់ក្នុងលទ្ធផលលម្អិតផ្សេងៗ។ ការជ្រើសរើសនេះធ្វើឡើងដោយផ្អែកលើមូលដ្ឋានតាមការវិនិយោគនីមួយៗ។ ទោះជាយ៉ាងណាក៏ដោយ សម្ព័ន្ធធនាគារ និងធនាគារ មិនបានជ្រើសរើសដូច្នេះឡើយ។

ទ្រព្យសកម្មហិរញ្ញវត្ថុទាំងអស់ផ្សេងទៀតដែលត្រូវបានចាត់ថ្នាក់តាមការវាស់វែងតាម FVTPL។ នាកាលបរិច្ឆេទរបាយការណ៍សម្ព័ន្ធធនាគារ និងធនាគារមិនមានទ្រព្យសកម្មហិរញ្ញវត្ថុដែលត្រូវបានចាត់ថ្នាក់តាមការវាស់វែងតាម FVTPL ទេ។

បន្ថែមពីនេះទៀត ការទទួលស្គាល់ដំបូង សម្ព័ន្ធធនាគារ និងធនាគារអាចកំណត់ជាស្ថាពរនូវទ្រព្យសកម្មហិរញ្ញវត្ថុដែលបំពេញតាមតម្រូវការ ហើយត្រូវបានវាស់វែងតាមថ្លៃដើមបានរំលស់ FVOCI ឬ FVTPL ប្រសិនបើអនុវត្តដូច្នេះការលុបបំបាត់ ឬកាត់បន្ថយជាសារវន្តនូវភាពមិនស៊ីគ្នានៃគណនេយ្យដែលនឹងកើតមានឡើង។

## ២. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត (ត)

### (ង) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

*(ii) ការធ្វើចំណាត់ថ្នាក់ (ត)*

*ការវាយតម្លៃម៉ូដែលអាជីវកម្ម*

សម្ព័ន្ធធនាគារ និងធនាគារ ធ្វើការវាយតម្លៃអំពីគោលបំណងនៃម៉ូដែលអាជីវកម្ម ដែលទ្រព្យសកម្មមួយត្រូវបានកាន់កាប់ក្នុងកម្រិតសម្ពាធហ្វាស៊ីលីធីមួយ ព្រោះវាឆ្លុះបញ្ចាំងបានល្អបំផុតអំពីមធ្យោបាយដែលអាជីវកម្មត្រូវបានគ្រប់គ្រង និងព័ត៌មាន ដែលបានផ្តល់ជូនអ្នកគ្រប់គ្រង។ ព័ត៌មានទាំងនោះរួមមានៈ

- គោលនយោបាយ និងគោលបំណងដែលបានចែងសម្រាប់សម្ពាធហ្វាស៊ីលីធី និងការអនុវត្តជាក់ស្តែងនូវគោលនយោបាយទាំងនោះ។ ជាពិសេសថាតើយុទ្ធសាស្ត្ររបស់អ្នកគ្រប់គ្រង ផ្តោតលើការស្វែងរកចំណូលការប្រាក់តាមកិច្ចសន្យារក្សានូវទម្រង់អត្រាការប្រាក់ជាក់លាក់មួយ ធ្វើឱ្យស៊ីសង្វាក់គ្នារវាងរយៈពេលនៃទ្រព្យសកម្មហិរញ្ញវត្ថុទៅនឹងរយៈពេលនៃបំណុល ដែលជាហិរញ្ញប្បទានរបស់ទ្រព្យសកម្មទាំងនោះ ឬការធ្វើឱ្យមានលំហូរសាច់ប្រាក់តាមរយៈការលក់ទ្រព្យសកម្ម
- វិធីក្នុងការវាយតម្លៃលទ្ធផលនៃសម្ពាធហ្វាស៊ីលីធី និងវិធីរាយការណ៍ទៅអ្នកគ្រប់គ្រងរបស់សម្ព័ន្ធធនាគារ និងធនាគារ
- ហានិភ័យដែលជះឥទ្ធិពលដល់លទ្ធផលនៃម៉ូដែលអាជីវកម្ម (និងទ្រព្យសកម្មហិរញ្ញវត្ថុដែលមាននៅក្នុងម៉ូដែលអាជីវកម្មនោះ) និងយុទ្ធសាស្ត្រសម្រាប់គ្រប់គ្រងហានិភ័យទាំងនោះ
- របៀបដែលអ្នកគ្រប់គ្រងអាជីវកម្មទទួលបានការទូទាត់ (ឧទាហរណ៍៖ តើការទូទាត់ផ្អែកលើតម្លៃសមស្របនៃទ្រព្យសកម្មដែលបានគ្រប់គ្រង ឬលំហូរសាច់ប្រាក់តាមកិច្ចសន្យាដែលបានប្រមូល) និង
- ភាពញឹកញាប់ បរិមាណនិងរយៈពេលនៃការលក់ក្នុងគ្រាមុន មូលហេតុនៃការលក់ទាំងនោះ និងការរំពឹងទុកអំពីសកម្មភាពនៃការលក់នាពេលអនាគត។ ទោះជាយ៉ាងណាក៏ដោយ ព័ត៌មានអំពីសកម្មភាពនៃការលក់មិនត្រូវបានយកមកពិចារណាដាច់ដោយឡែកឡើយ ប៉ុន្តែជាផ្នែកមួយនៃការវាយតម្លៃទាំងមូលនៃវិធីសាស្ត្រដែលសម្ព័ន្ធធនាគារ និងធនាគារ បានចែងអំពីគោលបំណងសម្រាប់សម្រេចបានការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ និងវិធីសាស្ត្រក្នុងការទទួលបានលំហូរសាច់ប្រាក់។

ទ្រព្យសកម្មហិរញ្ញវត្ថុដែលទុកសម្រាប់ការជួញដូរ ឬចាត់ចែង ហើយដែលលទ្ធផលរបស់ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានវាយតម្លៃតាមមូលដ្ឋានតម្លៃសមស្រប ត្រូវបានវាស់វែងតាម FVTPL ព្រោះទ្រព្យសកម្មទាំងនោះមិនមែនទុកសម្រាប់ប្រមូលសាច់ប្រាក់តាមកិច្ចសន្យា ឬមិនមែនទុកសម្រាប់ទាំងការប្រមូលសាច់ប្រាក់តាមកិច្ចសន្យា និងសម្រាប់លក់ឡើយ។

## ២. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត (ត)

### (ឯ) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

*(ii) ការធ្វើចំណាត់ថ្នាក់ (ត)*

*ការវាយតម្លៃថាតើលំហូរសាច់ប្រាក់តាមកិច្ចសន្យាជាការទូទាត់តែប្រាក់ដើម និងការប្រាក់*

ចំពោះគោលបំណងនៃការវាយតម្លៃនេះ "ប្រាក់ដើម" គឺជាតម្លៃសមស្របនៃទ្រព្យសកម្មហិរញ្ញវត្ថុនៅពេលទទួលស្គាល់លើកដំបូង។ "ការប្រាក់" គឺជាតម្លៃតបស្នងមួយសម្រាប់ពេលវេលានៃការប្រើប្រាស់ទឹកប្រាក់ សម្រាប់រយៈពេលណាមួយ និងសម្រាប់ហានិភ័យឥណទានដែលពាក់ព័ន្ធនឹងបរិមាណប្រាក់ដើម នៅជាប់ជំពាក់ ក្នុងអំឡុងពេលជាក់លាក់មួយ និងសម្រាប់ចំណាយរួមទាំងហានិភ័យក្នុងការផ្តល់កម្ចីជាមូលដ្ឋានផ្សេងៗទៀត (ដូចជាហានិភ័យសន្ទនីយភាព និងចំណាយរដ្ឋបាល)រួមទាំងកម្រិតប្រាក់ចំណេញ។

សម្ព័ន្ធធនាគារ និងធនាគារពិចារណាទៅលើលក្ខខណ្ឌកិច្ចសន្យារបស់ឧបករណ៍ហិរញ្ញវត្ថុ ដើម្បីវាយតម្លៃថាតើលំហូរសាច់ប្រាក់តាមកិច្ចសន្យា គឺសម្រាប់ទូទាត់តែប្រាក់ដើម និងការប្រាក់ដែរឬទេ។ វារួមបញ្ចូលការវាយតម្លៃថាតើទ្រព្យសកម្មហិរញ្ញវត្ថុ មានលក្ខខណ្ឌកិច្ចសន្យាដែលអាចផ្លាស់ប្តូរពេលវេលា ឬចំនួនលំហូរសាច់ប្រាក់តាមកិច្ចសន្យាដែល មិនអាចបំពេញតាមលក្ខខណ្ឌនេះបាន។

ក្នុងការវាយតម្លៃ សម្ព័ន្ធធនាគារ និងធនាគារ ពិចារណាទៅលើៈ

- ព្រឹត្តិការណ៍ជាយថាហេតុដែលអាចផ្លាស់ប្តូរចំនួន និងពេលវេលានៃលំហូរសាច់ប្រាក់
- លក្ខណៈពិសេសជាអានុភាព
- លក្ខខណ្ឌសងប្រាក់មុនកាលកំណត់ និងការពន្យារពេលសង
- លក្ខខណ្ឌដែលកម្រិតសម្ព័ន្ធធនាគារ និងធនាគារ ក្នុងការទាមទារមកវិញនូវលំហូរសាច់ប្រាក់ពីទ្រព្យសកម្មជាក់លាក់ (ដូចជា ឥណទានមានទ្រព្យដាក់បញ្ចាំជាក់លាក់) និង
- លក្ខណៈពិសេសដែលកែប្រែតម្លៃតបស្នងអំពីពេលវេលានៃការប្រើប្រាស់ទឹកប្រាក់ (ឧទាហរណ៍ ការកំណត់អត្រាការប្រាក់ឡើងវិញតាមរយៈពេលកំណត់)។

សម្ព័ន្ធធនាគារ និងធនាគារមានសំពៀតឥណទានមានអត្រាថេររយៈពេលវែងដែលសម្ព័ន្ធធនាគារ និងធនាគារមានជម្រើសស្នើឱ្យកែប្រែអត្រាការប្រាក់នៅកាលបរិច្ឆេទនៃការកំណត់ជាថ្មីឡើងវិញតាមរយៈពេលកំណត់។ សិទ្ធិកំណត់ឡើងវិញទាំងនេះ ត្រូវបានកម្រិតតាមអត្រាទីផ្សារនៅពេលមានការកែប្រែដែលសម្ព័ន្ធធនាគារ និងធនាគារមានជម្រើសក្នុងការទទួលយកអត្រាការប្រាក់ ដែលបានកែតម្រូវ ឬសងប្រាក់ដើមឥណទានដោយមិនមានការពិន័យ។ សម្ព័ន្ធធនាគារ និងធនាគារបានកំណត់ថា លំហូរសាច់ប្រាក់តាមកិច្ចសន្យានៃឥណទានទាំងនេះ គឺជា SPPI ពីព្រោះជម្រើសមានការផ្លាស់ប្តូរអត្រាការប្រាក់តាមរបៀបមួយដែលជាតម្លៃតបស្នង សម្រាប់ពេលវេលា នៃការប្រើប្រាស់សាច់ប្រាក់ ហានិភ័យឥណទាន និងហានិភ័យក្នុងការផ្តល់កម្ចីជាមូលដ្ឋានផ្សេងៗទៀតព្រមទាំងចំណាយទាក់ទងនឹងចំនួនប្រាក់ដើមដែលនៅជាប់ជំពាក់។

## ២. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត (ត)

### (ង) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

*(ii) ការធ្វើចំណាត់ថ្នាក់ (ត)*

*ឥណទានដែលមានទ្រព្យដាក់បញ្ចាំដាក់លាក់*

ក្នុងករណីខ្លះ ឥណទានដែលផ្តល់ដោយសម្ព័ន្ធធនាគារ និងធនាគារ ដែលត្រូវបានធានាដោយទ្រព្យដាក់បញ្ចាំពីអតិថិជន បានកម្រិតសម្ព័ន្ធធនាគារ និងធនាគារក្នុងការទាមទារលំហូរសាច់ប្រាក់របស់ទ្រព្យដាក់បញ្ចាំ (ឥណទានដែលមានទ្រព្យដាក់បញ្ចាំដាក់លាក់)។ ក្នុងករណីនេះ សម្ព័ន្ធធនាគារ និងធនាគារធ្វើការវិនិច្ឆ័យក្នុងការវាយតម្លៃថាតើឥណទាននោះ បំពេញតាមលក្ខខណ្ឌទូទាត់តែប្រាក់ដើម និងការប្រាក់ដែរឬទេ។ ជាទូទៅសម្ព័ន្ធធនាគារ និងធនាគារពិចារណាលើព័ត៌មានខាងក្រោមក្នុងការវិនិច្ឆ័យ៖

- ថាតើកិច្ចសន្យាមានបញ្ជាក់ច្បាស់ពីចំនួន និងកាលបរិច្ឆេទនៃសំណងឥណទានដែរឬទេ
- តម្លៃសមស្របនៃទ្រព្យបញ្ចាំពាក់ព័ន្ធនឹងចំនួននៃទ្រព្យសកម្មហិរញ្ញវត្ថុដែលមានការធានា
- សមត្ថភាព និងឆន្ទៈរបស់អតិថិជន ក្នុងការទូទាត់សងតាមកិច្ចសន្យា ទោះបីមានឱនភាពនៃតម្លៃទ្រព្យបញ្ចាំក៏ដោយ
- ថាតើអតិថិជន គឺជារូបវន្តបុគ្គល ឬជាអង្គភាពប្រតិបត្តិការសំខាន់ ឬជាអង្គភាពដែលមានគោល-បំណងពិសេស
- ហានិភ័យរបស់សម្ព័ន្ធធនាគារ និងធនាគារនៃការបាត់បង់ទ្រព្យសកម្ម ទាក់ទងនឹងឥណទានដែលទ្រព្យដាក់បញ្ចាំពេញលេញ
- វិសាលភាពដែលទ្រព្យដាក់បញ្ចាំបង្ហាញពីទ្រព្យសកម្មរបស់អតិថិជនទាំងអស់ ឬជាផ្នែកណាមួយ និង
- ថាតើសម្ព័ន្ធធនាគារ និងធនាគារនឹងទទួលបានអត្ថប្រយោជន៍ពីការកើនតម្លៃនៃទ្រព្យសកម្មនេះ ឬទេ។

***ការធ្វើចំណាត់ថ្នាក់ឡើងវិញ***

ទ្រព្យសកម្មហិរញ្ញវត្ថុមិនត្រូវបានចាត់ថ្នាក់ឡើងវិញបន្ទាប់ពីការទទួលស្គាល់លើកដំបូងឡើយ លើកលែងតែក្នុងអំឡុងពេលបន្ទាប់ពីសម្ព័ន្ធធនាគារ និងធនាគារផ្លាស់ប្តូរម៉ូដែលអាជីវកម្មរបស់ខ្លួន ក្នុងការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ។

## ២. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត (ត)

### (ង) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

*(ii) ការធ្វើចំណាត់ថ្នាក់ (ត)*

*បំណុលហិរញ្ញវត្ថុ*

សម្ព័ន្ធធនាគារ និងធនាគារ បានចាត់ថ្នាក់បំណុលហិរញ្ញវត្ថុរបស់ខ្លួន ក្រៅពីការធានាហិរញ្ញវត្ថុ និងការសន្យាផ្តល់ឥណទាន តាមថ្លៃដើមបានរំលស់ ឬ FVTPL។ នាកាលបរិច្ឆេទនៃរបាយការណ៍ សម្ព័ន្ធធនាគារ និងធនាគារមិនមានបំណុលហិរញ្ញវត្ថុដែលត្រូវបានចាត់ថ្នាក់តាមការវាស់វែងតាម FVTPL ទេ។

*(iii) ការឈប់ទទួលស្គាល់*

*ទ្រព្យសកម្មហិរញ្ញវត្ថុ*

សម្ព័ន្ធធនាគារ និងធនាគារ ឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ នៅពេលដែលសិទ្ធិតាមកិច្ចសន្យាក្នុងការទទួលលំហូរសាច់ប្រាក់ពីទ្រព្យសកម្មហិរញ្ញវត្ថុផុតកំណត់ [សូមមើល(iv)] ឬការផ្ទេរសិទ្ធិទទួលលំហូរសាច់ប្រាក់តាមកិច្ចសន្យាក្នុងប្រតិបត្តិការ ដែលរាល់ហានិភ័យ និងផលចំណេញស្ទើរតែទាំងអស់នៃភាពជាកម្មសិទ្ធិនៃទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានផ្ទេរ ឬក្នុងករណីដែលសម្ព័ន្ធធនាគារ និងធនាគារមិនផ្ទេរ ឬមិនរក្សាទុកនូវហានិភ័យ និងផលចំណេញស្ទើរតែទាំងអស់នៃភាពជាកម្មសិទ្ធិ ហើយវាមិនរក្សាអភិបាលភាពនៃទ្រព្យសកម្មហិរញ្ញវត្ថុឡើយ។

នៅពេលដែលមានការឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ ភាពលម្អៀងរវាងតម្លៃយោងរបស់ទ្រព្យសកម្ម (ឬតម្លៃយោងដែលជាចំណែកនៃទ្រព្យសកម្មដែលឈប់ទទួលស្គាល់) និងផលបូកនៃ (i). តម្លៃតបស្នងដែលទទួលបាន (រាប់បញ្ចូលទាំងទ្រព្យសកម្មថ្មីដែលទទួលបាន ដកបំណុលថ្មីដែលបានទទួលយក) និង (ii). ចំណេញ ឬខាតសរុបបង្គរដែលបានទទួលស្គាល់ក្នុងលទ្ធផលលម្អិតផ្សេងៗ ត្រូវបានទទួលស្គាល់នៅក្នុងចំណេញ ឬខាត។

ការចំណេញ ឬខាតសរុបបង្គរ ដែលត្រូវបានទទួលស្គាល់នៅក្នុងលទ្ធផលលម្អិតផ្សេងៗ ទាក់ទងនឹងមូលបត្រវិនិយោគមូលធន ដែលបានកំណត់ជា FVOCI មិនត្រូវបានទទួលស្គាល់នៅក្នុងប្រាក់ចំណេញ ឬខាត នៅពេលដែលមានការឈប់ទទួលស្គាល់នូវមូលបត្របែបនេះឡើយ។ ភាគកម្មលើទ្រព្យសកម្មហិរញ្ញវត្ថុ ដែលបានផ្ទេរហើយមានលក្ខណៈគ្រប់គ្រាន់សម្រាប់ការឈប់ទទួលស្គាល់ដែលត្រូវបានបង្កើត ឬរក្សាទុកដោយសម្ព័ន្ធធនាគារ និងធនាគារត្រូវបានទទួលស្គាល់ជាទ្រព្យសកម្ម ឬបំណុលដាច់ដោយឡែក។

*បំណុលហិរញ្ញវត្ថុ*

សម្ព័ន្ធធនាគារ និងធនាគារឈប់ទទួលស្គាល់បំណុលហិរញ្ញវត្ថុមួយ នៅពេលកាតព្វកិច្ចតាមកិច្ចសន្យាត្រូវបានបោះបង់ចោល ឬត្រូវបានលុបចោល ឬផុតកាលកំណត់។

## ២. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត (ត)

### (ង) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

*(iv) ការកែប្រែនៃទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)*

**ទ្រព្យសកម្មហិរញ្ញវត្ថុ**

ប្រសិនបើលក្ខខណ្ឌនៃទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានកែប្រែ នោះសម្ព័ន្ធធនាគារ និងធនាគារវាយតម្លៃថាតើលំហូរសាច់ប្រាក់នៃទ្រព្យសកម្មដែលបានកែប្រែនោះ មានភាពខុសគ្នាខ្លាំងឬទេ។ សម្ព័ន្ធធនាគារ និងធនាគារពិចារណាទៅលើភាពខុសគ្នាផ្សេងទៀត ក្នុងចំណោមភាពខុសគ្នាទាំងនោះដូចខាងក្រោម៖

- ថាតើប្រសិនបើអ្នកខ្ចីមានការលំបាកផ្នែកហិរញ្ញវត្ថុ ការកែប្រែនេះគ្រាន់តែជាការកាត់បន្ថយលំហូរសាច់-ប្រាក់តាមកិច្ចសន្យាទៅនឹងចំនួនទឹកប្រាក់ដែលអ្នកខ្ចីត្រូវបានគេរំពឹងថានឹងអាចទូទាត់បានដែរឬទេ
- ថាតើលក្ខខណ្ឌថ្មីសំខាន់ៗទាំងឡាយដែលត្រូវបានណែនាំ ថានឹងមានផលប៉ះពាល់ដល់ទម្រង់ហានិភ័យនៃប្រាក់កម្ចីដែរឬទេ
- ការពន្យារពេលលក្ខខណ្ឌកម្ចីជាសារវន្តនៅពេលដែលអ្នកខ្ចីមិនមានការលំបាកផ្នែកហិរញ្ញវត្ថុ
- ការផ្លាស់ប្តូរជាសារវន្តនៃអត្រាការប្រាក់
- ការផ្លាស់ប្តូររូបិយប័ណ្ណ ដែលត្រូវបានកំណត់នៅក្នុងឥណទាន និង/ឬ
- ការរួមបញ្ចូលទ្រព្យបញ្ចាំ ទ្រព្យតម្កល់នានា ឬការពង្រឹងឥណទាន ដែលនឹងមានឥទ្ធិពលលើហានិភ័យឥណទានជាសារវន្តដែលពាក់ព័ន្ធនឹងឥណទាន ។

ប្រសិនបើលំហូរសាច់ប្រាក់មានភាពខុសគ្នាខ្លាំង នោះសិទ្ធិតាមកិច្ចសន្យាចំពោះលំហូរសាច់ប្រាក់ពីទ្រព្យសកម្មហិរញ្ញវត្ថុដើម ត្រូវបានចាត់ទុកថាផុតកាលកំណត់។ ក្នុងករណីនេះទ្រព្យសកម្មហិរញ្ញវត្ថុដើម ត្រូវឈប់ទទួលស្គាល់ (សូមមើល (iii) ហើយទ្រព្យសកម្មហិរញ្ញវត្ថុថ្មីមួយត្រូវបានទទួលស្គាល់តាមតម្លៃសមស្រប បូកនឹងចំណាយប្រតិបត្តិការដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។ ថ្លៃសេវានានាដែលទទួលបានជាផ្នែកនៃការកែប្រែនេះ ត្រូវបានកត់ត្រាដូចខាងក្រោម៖

- ថ្លៃសេវាដែលត្រូវបានពិចារណាក្នុងការកំណត់តម្លៃសមស្របនៃទ្រព្យសកម្មថ្មី និងថ្លៃសេវាដែលជាសំណងនៃចំណាយប្រតិបត្តិការដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ត្រូវបានរាប់បញ្ចូលក្នុងការវាស់វែងលើកដំបូងនៃទ្រព្យសកម្ម និង
- ថ្លៃសេវាផ្សេងទៀតត្រូវបានរាប់បញ្ចូលក្នុងចំណេញ ឬខាត ដែលជាផ្នែកមួយនៃការចំណេញ ឬខាតលើការឈប់ទទួលស្គាល់។

## ២. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត (ត)

### (ង) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

*(iv) ការកែប្រែនៃទ្រព្យសកម្មហិរញ្ញវត្ថុនិងបំណុលហិរញ្ញវត្ថុ (ត)*

**ទ្រព្យសកម្មហិរញ្ញវត្ថុ (ត)**

ប្រសិនបើលំហូរសាច់ប្រាក់ត្រូវបានកែប្រែនៅពេលដែលអតិថិជនជួបការលំបាកផ្នែកហិរញ្ញវត្ថុ នោះគោលបំណងនៃការកែប្រែជាទូទៅ គឺដើម្បីទទួលបានមកវិញជាអតិបរមានៃលក្ខខណ្ឌតាមកិច្ចសន្យាដើមជាជាងបង្កើតទ្រព្យសកម្មថ្មីដែលមានលក្ខខណ្ឌខុសគ្នាខ្លាំង។ ប្រសិនបើសម្ព័ន្ធធនាគារ ឬធនាគារមានគម្រោងកែប្រែទ្រព្យសកម្មហិរញ្ញវត្ថុតាមរបៀបមួយ ដែលអាចនាំឱ្យមានការលើកលែងចំពោះលំហូរសាច់ប្រាក់ នោះត្រូវពិចារណាជាដំបូងថាតើផ្នែកមួយនៃទ្រព្យសកម្ម គួរតែត្រូវបានលុបចេញពីបញ្ជី មុនពេលធ្វើការកែប្រែកើតឡើងដែរឬទេ [សូមមើល(vii)គោលនយោបាយការលុបចេញពីបញ្ជី]។ វិធីសាស្ត្រនេះមានផលប៉ះពាល់ដល់លទ្ធផលនៃការវាយតម្លៃបរិមាណ និងមានន័យថាលក្ខណៈវិនិច្ឆ័យនៃការឈប់ទទួលស្គាល់ជាធម្មតាមិនបានបំពេញករណីទាំងនេះទេ។

ប្រសិនបើការកែប្រែទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានវាស់វែងតាមថ្លៃដើមបានរំលស់ ឬ FVOCI មិនបណ្តាលឱ្យមានការឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុទេ នោះសម្ព័ន្ធធនាគារ និងធនាគារនឹងគណនាឡើងវិញនូវតម្លៃយោងដុលនៃទ្រព្យសកម្មហិរញ្ញវត្ថុជាមុន ដោយប្រើអត្រាការប្រាក់ប្រសិទ្ធភាពដំបូងនៃទ្រព្យសកម្ម និងទទួលស្គាល់លទ្ធផលនៃការកែតម្រូវជាចំណេញ ឬខាត នៅក្នុងរបាយការណ៍ចំណេញ ឬខាត។ សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានអត្រាអថេរ អត្រាការប្រាក់ប្រសិទ្ធភាពដំបូងដែលធ្លាប់បានប្រើដើម្បីគណនាចំណេញ ឬខាតពីការកែប្រែ ត្រូវបានកែតម្រូវដើម្បីឆ្លុះបញ្ចាំងពីលក្ខខណ្ឌទីផ្សារបច្ចុប្បន្ននៅពេលដែលធ្វើការកែប្រែ។ រាល់ចំណាយ ឬថ្លៃសេវាដែលកើតឡើង និងថ្លៃសេវាទទួលបានដែលជាផ្នែកមួយនៃការធ្វើការកែប្រែពីការកែតម្រូវតម្លៃយោងដុលរបស់ទ្រព្យសកម្មហិរញ្ញវត្ថុដែលបានធ្វើការកែប្រែ និងត្រូវបានរំលស់ផ្អែកលើរយៈពេលដែលនៅសល់នៃទ្រព្យសកម្មហិរញ្ញវត្ថុ ដែលបានកែប្រែនោះ។

ប្រសិនបើការកែប្រែនេះ ត្រូវបានធ្វើឡើងដោយសារតែអតិថិជនជួបការលំបាកផ្នែកហិរញ្ញវត្ថុ [សូមមើល (vii)] នោះចំណេញ ឬខាតត្រូវបានបង្ហាញជាមួយគ្នានឹងការខាតបង់លើឱនភាពនៃតម្លៃរបស់ទ្រព្យសកម្ម។ ក្នុងករណីផ្សេងទៀត ត្រូវបានបង្ហាញជាចំណូលការប្រាក់ ដែលគណនាដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព [សូមមើលកំណត់សម្គាល់លេខ ២ (ន)]។

**បំណុលហិរញ្ញវត្ថុ**

សម្ព័ន្ធធនាគារ និងធនាគារ ឈប់ទទួលស្គាល់បំណុលហិរញ្ញវត្ថុ នៅពេលដែលលក្ខខណ្ឌរបស់វាត្រូវបានកែប្រែ ហើយលំហូរសាច់ប្រាក់នៃបំណុលដែលបានកែប្រែនោះមានភាពខុសគ្នាខ្លាំង។ ក្នុងករណីនេះ បំណុលហិរញ្ញវត្ថុថ្មីមួយ ត្រូវបានទទួលស្គាល់តាមតម្លៃសមស្រប។ ភាពលម្អៀងរវាងតម្លៃយោងនៃបំណុលហិរញ្ញវត្ថុដែលត្រូវបានឈប់ទទួលស្គាល់ និងតម្លៃតបស្នងដែលបានទូទាត់ ត្រូវបានទទួលស្គាល់នៅក្នុងចំណេញ ឬខាត។ តម្លៃតបស្នងដែលបានទូទាត់រួមមានទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុដែលបានផ្ទេរ (ប្រសិនបើមាន) និងការទទួលយកបំណុលថ្មី រួមទាំងបំណុលហិរញ្ញវត្ថុដែលបានកែប្រែថ្មី។

## ២. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត (ត)

### (ង) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

*(iv) ការកែប្រែនៃទ្រព្យសកម្មហិរញ្ញវត្ថុនិងបំណុលហិរញ្ញវត្ថុ (ត)*

**បំណុលហិរញ្ញវត្ថុ (ត)**

ប្រសិនបើការកែប្រែបំណុលហិរញ្ញវត្ថុនេះមិនធ្វើឱ្យមានការឈប់ទទួលស្គាល់ទេ នោះថ្លៃដើមបានរំលស់នៃបំណុល ត្រូវបានគណនាឡើងវិញដោយធ្វើអប្បហារលំហូរសាច់ប្រាក់ដែលបានកែប្រែ តាមអត្រាការប្រាក់ប្រសិទ្ធភាពដំបូង ហើយលទ្ធផលនៃចំណេញ ឬខាត ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាត។

សម្រាប់បំណុលហិរញ្ញវត្ថុដែលមានអត្រាអថេរ អត្រាការប្រាក់ប្រសិទ្ធភាពដំបូងដែលធ្លាប់បានប្រើដើម្បីគណនាចំណេញ ឬខាតពីការកែប្រែ ត្រូវបានកែតម្រូវដើម្បីឆ្លុះបញ្ចាំងពីលក្ខខណ្ឌទីផ្សារបច្ចុប្បន្ននៅពេលដែលធ្វើការកែប្រែ។ រាល់ចំណាយ និងថ្លៃសេវាដែលកើតឡើង ត្រូវបានទទួលស្គាល់ជាការកែតម្រូវទៅលើតម្លៃយោងនៃបំណុល និងត្រូវបានរំលស់ផ្អែកលើរយៈពេលដែលនៅសល់នៃបំណុលហិរញ្ញវត្ថុដែលបានកែប្រែនោះ។

*(v) ការកាត់កង*

ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ អាចកាត់កងគ្នាបាន និងត្រូវបង្ហាញជាចំនួនសុទ្ធនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ លុះត្រាតែសម្ព័ន្ធធនាគារ ឬធនាគារ មានសិទ្ធិតាមច្បាប់ដើម្បីធ្វើការ កាត់កងគ្នាបាន និងមានបំណងធ្វើការទូទាត់ដោយផ្អែកលើមូលដ្ឋានចំនួននៅសល់សុទ្ធ ឬក៏លក់ទ្រព្យសកម្ម និងទូទាត់បំណុលក្នុងពេលដំណាលគ្នា។

ចំណូល និងចំណាយ ត្រូវបានបង្ហាញជាមូលដ្ឋានសុទ្ធនៅពេលដែលត្រូវបានអនុញ្ញាតដោយ ស.រ.ទ.ហ.អ.ក ឬសម្រាប់ចំណេញ និងខាត ដែលកើតឡើងពីក្រុមនៃប្រតិបត្តិការស្រដៀងគ្នា ដូចជានៅក្នុងសកម្មភាពជួញដូររបស់សម្ព័ន្ធធនាគារ និងធនាគារ។

*(vi) ការវាស់វែងតម្លៃសមស្រប*

តម្លៃសមស្រប គឺជាតម្លៃដែលនឹងទទួលបានដោយការលក់ទ្រព្យសកម្ម ឬថ្លៃដែលបានសងចំពោះការផ្ទេរបំណុលនៅក្នុងប្រតិបត្តិការធម្មតា រវាងអ្នកចូលរួមក្នុងទីផ្សារនានានៅកាលបរិច្ឆេទនៃការវាស់វែងនៅក្នុងទីផ្សារគោល ឬក្នុងករណីមិនមានទីផ្សារគោល គឺយកទីផ្សារជាអាទិភាពបំផុត ដែលសម្ព័ន្ធធនាគារ និងធនាគារ អាចកំណត់រកបាននៅកាលបរិច្ឆេទនៃការវាស់វែងនោះ។ តម្លៃសមស្របរបស់បំណុល ឆ្លុះបញ្ចាំងពីហានិភ័យមិនមែនប្រតិបត្តិការ។

តម្លៃសមស្របនៃបំណុលហិរញ្ញវត្ថុមានលក្ខណៈពិសេសនៃតម្រូវការ (ឧទាហរណ៍ ប្រាក់បញ្ញើតាមតម្រូវការ) គឺមិនត្រូវតិចជាងចំនួនទឹកប្រាក់ដែលត្រូវសងតាមតម្រូវការទេ ដោយត្រូវធ្វើអប្បហារចាប់ពីថ្ងៃដំបូងដែលចំនួនទឹកប្រាក់អាចតម្រូវឱ្យសង។

សម្ព័ន្ធធនាគារ និងធនាគារ ទទួលស្គាល់ការផ្ទេររវាងកម្រិតនៃឋានានុក្រមនៃតម្លៃសមស្របនៅចុងការិយបរិច្ឆេទនៃរបាយការណ៍ក្នុងអំឡុងពេលដែលការផ្លាស់ប្តូរបានកើតឡើង។

## ២. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត (ត)

### (ង) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

*(vii) ឱនភាពនៃតម្លៃ*

សម្ព័ន្ធធនាគារ និងធនាគារទទួលស្គាល់សំវិធានធនលើការខាតបង់ សម្រាប់ការខាតបង់ឥណទានដែលរំពឹង-ទុក (“ECL”) ចំពោះឧបករណ៍ហិរញ្ញវត្ថុ ដែលមិនបានវាស់វែងតាម FVTPL ដូចខាងក្រោម៖

- ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលជាឧបករណ៍បំណុល
- ឥណទាន និងបុរេប្រទាន
- កិច្ចសន្យាធានាហិរញ្ញវត្ថុដែលបានបោះផ្សាយ និង
- កិច្ចសន្យាផ្តល់ឥណទានដែលបានបោះផ្សាយ។

ពុំមានការខាតបង់លើឱនភាពនៃតម្លៃត្រូវបានទទួលស្គាល់លើការវិនិយោគមូលធនឡើយ។

សម្ព័ន្ធធនាគារ និងធនាគារវាស់វែង សំវិធានធនលើការខាតបង់ តាមចំនួនដែលស្មើនឹង ECL ពេញមួយអាយុកាល លើកលែងឧបករណ៍ហិរញ្ញវត្ថុដែលត្រូវបានវាស់វែងតាម ECL ១២ ខែ ដូចខាងក្រោមនេះ៖

- មូលបត្រវិនិយោគបំណុល ដែលត្រូវបានកំណត់ថាមានហានិភ័យឥណទានទាប នាកាលបរិច្ឆេទនៃការរាយការណ៍ និង
- ឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត (ក្រៅពីគណនីឥណទាន និងបុរេប្រទាន) ដែលហានិភ័យឥណទានមិនបានកើនឡើងជាសារវន្ត ចាប់តាំងពីការទទួលស្គាល់លើកដំបូង។

សំវិធានធនលើការខាតបង់សម្រាប់គណនីឥណទាន និងបុរេប្រទាន តែងតែត្រូវបានវាស់វែងតាមចំនួនស្មើនឹង ECL ពេញមួយអាយុកាល។

សម្ព័ន្ធធនាគារ និង ធនាគារពិចារណាលើមូលបត្រវិនិយោគបំណុលមួយថាមានហានិភ័យឥណទានទាប នៅពេលដែលចំណាត់ថ្នាក់ហានិភ័យឥណទានរបស់វាស្មើទៅនឹងនិយមន័យ ដែលត្រូវបានគេស្គាល់ជាសកលនៃ “ថ្នាក់វិនិយោគ”។ សម្ព័ន្ធធនាគារ និងធនាគារមិនអនុវត្តការលើកលែងហានិភ័យឥណទានទាបចំពោះឧបករណ៍ហិរញ្ញវត្ថុដទៃទៀតឡើយ។

ECL ១២ ខែ គឺជាផ្នែកនៃ ECL ដែលបណ្តាលមកពីព្រឹត្តិការណ៍ខកខានសងប្រាក់ក្នុងរយៈពេល ១២ ខែរបស់ឧបករណ៍ហិរញ្ញវត្ថុមួយដែលអាចកើតឡើងក្នុងរយៈពេល ១២ខែ បន្ទាប់ពីកាលបរិច្ឆេទនៃការរាយការណ៍។ ឧបករណ៍ហិរញ្ញវត្ថុ ដែលបានទទួលស្គាល់តាម ECL ១២ខែ ត្រូវបានចាត់ទុកជា “ឧបករណ៍ហិរញ្ញវត្ថុស្ថិតក្នុងដំណាក់កាលទី១”។

ECL ពេញមួយអាយុកាល (Life-time ECL) គឺជា ECL ដែលអាចបណ្តាលមកពីព្រឹត្តិការណ៍ខកខានសងប្រាក់ក្នុងអាយុកាលដែលរំពឹងទុក (expected life) ទាំងអស់របស់ឧបករណ៍ហិរញ្ញវត្ថុ។ ឧបករណ៍ហិរញ្ញវត្ថុដែលបានទទួលស្គាល់តាម ECL ពេញមួយអាយុកាល ប៉ុន្តែមិនមែនមានឱនភាពនៃតម្លៃឥណទាន (credit-impaired) ត្រូវបានចាត់ទុកជា “ឧបករណ៍ហិរញ្ញវត្ថុស្ថិតក្នុងដំណាក់កាលទី ២”។

## ២. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត (ត)

### (ង) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

*(vii) ឱនភាពនៃតម្លៃ(ត)*

*ការវាស់វែង ECL*

ECL គឺជាការប៉ាន់ស្មានដែលបានថ្លឹងតាមប្រូបាប៊ីលីតេនៃការខាតបង់ឥណទាន។ ECL ត្រូវបានវាស់វែងដូចខាងក្រោម៖

- ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលមិនមានឱនភាពនៃតម្លៃឥណទាននាកាលបរិច្ឆេទនៃការរាយការណ៍៖ ជាតម្លៃបច្ចុប្បន្ននៃកង្វះខាតសាច់ប្រាក់ទាំងអស់ (ពោលគឺភាពខុសគ្នារវាងលំហូរសាច់ប្រាក់ដែលជំពាក់ ដោយយោងតាមកិច្ចសន្យា និងលំហូរសាច់ប្រាក់ដែលសម្ព័ន្ធធនាគារ និងធនាគាររំពឹងទុកថានឹងទទួលបាន)។
- ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពនៃតម្លៃឥណទាននាកាលបរិច្ឆេទនៃការរាយការណ៍៖ ជាភាពខុសគ្នារវាងតម្លៃយោងដុល និងតម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់នាពេលអនាគតដែលរំពឹងទុក។
- កិច្ចសន្យាផ្តល់ឥណទានដែលមិនទាន់បានប្រើប្រាស់៖ ជាតម្លៃបច្ចុប្បន្ននៃភាពខុសគ្នារវាងលំហូរសាច់ប្រាក់តាមកិច្ចសន្យាដែលជំពាក់សម្ព័ន្ធធនាគារ និងធនាគារ ប្រសិនបើកិច្ចសន្យាឥណទានត្រូវបានប្រើប្រាស់ និងលំហូរ-សាច់ប្រាក់ដែលសម្ព័ន្ធធនាគារ និងធនាគារ រំពឹងទុកថានឹងទទួលបាន និង
- កិច្ចសន្យាធានាហិរញ្ញវត្ថុ៖ ការទូទាត់ដែលរំពឹងទុក ចំពោះចំនួនទឹកប្រាក់ដែលនឹងផ្តល់ទៅអ្នកទទួលផល ដោយដកចេញនូវចំនួនទឹកប្រាក់ដែលសម្ព័ន្ធធនាគារ និងធនាគាររំពឹងថានឹងទទួលបានមកវិញ។

ធាតុចូលសំខាន់ៗ ក្នុងការវាស់វែង ECL គឺបានមកពីអថេរដូចខាងក្រោម៖

- ប្រូបាប៊ីលីតេនៃការខកខានសង (“PD”)
- ការខាតបង់ដែលបណ្តាលមកពីការខកខានសង (“LGD”) និង
- ទំហំនៃការខកខានសង (“EAD”)។

ECL សម្រាប់ទំហំក្នុងដំណាក់កាលទី ១ ត្រូវបានគណនាដោយផលគុណនៃប្រូបាប៊ីលីតេនៃការខកខានសងក្នុង ១២ ខែ និងការខាតបង់ដែលបណ្តាលមកពីការខកខានសង និងទំហំនៃការខកខានសង។ ECL ពេញមួយអាយុកាលត្រូវបានគណនាដោយផលគុណនៃប្រូបាប៊ីលីតេនៃការខកខានសងពេញមួយអាយុកាល និងការខាតបង់ដែលបណ្តាលមកពីការខកខានសង និងទំហំនៃការខកខានសង។

ការសន្មតដែលផ្អែកលើការគណនា ECL ត្រូវបានត្រួតពិនិត្យប្រចាំខែ និងត្រួតពិនិត្យឡើងវិញប្រចាំត្រីមាស។ មិនមានការផ្លាស់ប្តូរសំខាន់ៗទៅលើបច្ចេកទេសប៉ាន់ស្មាន ឬមានការសន្មតសំខាន់ៗណាមួយបានកើតឡើង ក្នុងអំឡុងការិយបរិច្ឆេទនៃរបាយការណ៍នេះឡើយ។

## ២. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត (ត)

### (ង) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

*(vii) ឱនភាពនៃតម្លៃ(ត)*

*ការវាស់វែង ECL (ត)*

ប្រូបាប៊ីលីតេនៃការខកខានសង (PD) ផ្ដល់នូវការប៉ាន់ប្រមាណនៃលទ្ធភាពដែលអតិថិជនម្នាក់នឹងមិនអាចបំពេញកាតព្វកិច្ចបំណុល ឬភាពខកខានក្នុងរយៈពេលជាក់លាក់មួយ។ ទ្រព្យសកម្មហិរញ្ញវត្ថុក្រោមវិធីសាស្ត្រទូទៅ ដែលតម្រូវមានដំណាក់កាល និងតម្រូវទាំងការប៉ាន់ស្មានប្រូបាប៊ីលីតេនៃការខកខានសងក្នុង១២ខែ និង ប្រូបាប៊ីលីតេនៃការខកខានសងក្នុងពេញមួយអាយុកាល ដោយយោងទៅតាមទិន្នន័យប្រវត្តិសាស្ត្រដោយប្រើវិធីសាស្ត្រ Migration (migration approach) ឬវិធីសាស្ត្រការផ្ដល់ចំណាត់ថ្នាក់លទ្ធភាពសងពីភាគីឯករាជ្យ។

ការខាតបង់ដែលបណ្ដាលមកពីការខកខានសង គឺជាកម្រិតដែលអាចបាត់បង់ប្រសិនបើមានការខកខានសង។ ការខាតបង់ដែលបណ្ដាលមកពីការខកខានសង ត្រូវបានកំណត់ជាភាគរយនៃទំហំប្រឈមដែលសម្ព័ន្ធធនាគារ និងធនាគារអាចនឹងបាត់បង់ក្នុងករណីដែលអតិថិជនខកខានសង។ ការខាតបង់ទាំងនេះជាធម្មតាត្រូវបានបង្ហាញជាភាគរយនៃទំហំនៃការខកខានសង (EAD) ហើយពឹងផ្អែកលើប្រភេទ និងចំនួនទ្រព្យដាក់បញ្ចាំព្រមទាំងប្រភេទនៃអតិថិជន និងការប្រមូលបំណុលដែលរំពឹងទុកពីអតិថិជន។

ជាមួយនឹងតម្លៃទ្រព្យដាក់បញ្ចាំដែលត្រឹមត្រូវ ដែលត្រូវបានធ្វើបច្ចុប្បន្នកម្មពីមួយពេលទៅមួយពេលសម្ព័ន្ធធនាគារ និងធនាគារអាចពិចារណាយកទ្រព្យដាក់បញ្ចាំចូលទៅក្នុងការគណនា ការខាតបង់ដែលបណ្ដាលមកពីការខកខានសងសម្រាប់ការគណនា ECL។ ក្នុងករណីមានទ្រព្យដាក់បញ្ចាំលើសលប់ កម្រិតទាបបំផុតរបស់ការខាតបង់ដែលបណ្ដាលមកពីការខកខានសងមួយ នឹងត្រូវយកទៅអនុវត្តសម្រាប់ការគណនា ECL។

ទំហំនៃការខកខានសង គឺជាចំនួនទឹកប្រាក់នៅជំពាក់ នៅពេលមានការខកខានសង។ ទោះយ៉ាងណា ទំហំនៃការខកខានសងខុសគ្នាទៅតាមលក្ខណៈនៃផលិតផលៈ

- ហ្វាស៊ីលីធីវិលស់ៈ ចំនួនទឹកប្រាក់បច្ចុប្បន្នដែលត្រូវបានអនុញ្ញាតក្រោមកិច្ចសន្យា និងកើតឡើងពីការធ្វើវិលស់
- ហ្វាស៊ីលីធីអាចប្រើប្រាស់ឡើងវិញៈ អត្រាប្រើប្រាស់
- ក្រៅតារាងតុល្យការៈ កត្តាបំប្លែងឥណទាន

ដូចការរៀបរាប់ខាងលើ និងដោយផ្អែកលើការប្រើប្រាស់ជាអតិបរមានៃប្រូបាប៊ីលីតេនៃការខកខានសងក្នុង ១២ខែ សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុនៅដំណាក់កាលទី១ សម្ព័ន្ធធនាគារ និងធនាគារវាស់វែង ECL ដោយពិចារណាលើហានិភ័យនៃការខកខានសង ក្នុងរយៈពេលតាមកិច្ចសន្យាជាអតិបរមា (រួមបញ្ចូលទាំងជម្រើសការពន្យារពេលសងរបស់អតិថិជនប្រសិនបើមាន) ដែលប្រឈមនឹងហានិភ័យឥណទាន ទោះបីជាក្នុងគោលបំណងគ្រប់គ្រងហានិភ័យឥណទានក៏ដោយ សម្ព័ន្ធធនាគារ និងធនាគារពិចារណាលើរយៈពេលមួយវែងជាង។ រយៈពេលដែលវែងបំផុត គឺនាថ្ងៃដែលសម្ព័ន្ធធនាគារ និងធនាគារមានសិទ្ធិទាមទារការសងត្រឡប់ ឬបញ្ចប់កិច្ចសន្យា ឬការធានា។

## ២. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត (ត)

### (ង) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

*(vii) ឱនភាពនៃតម្លៃ (ត)*

*ការវាស់វែង ECL (ត)*

ទោះបីជាយ៉ាងណាក៏ដោយ សម្រាប់ហ្វាស៊ីលីធីប័ណ្ណឥណទានដែលរួមមានទាំងឥណទាន និងការសន្យាផ្តល់ឥណទានដែលមិនទាន់បានប្រើប្រាស់ ដែលសម្ព័ន្ធធនាគារ និងធនាគារវាស់វែង ECL ក្នុងរយៈពេលមួយវែងជាងរយៈពេលតាមកិច្ចសន្យាអតិបរមា ប្រសិនបើសមត្ថភាពតាមកិច្ចសន្យារបស់សម្ព័ន្ធធនាគារ និងធនាគារក្នុងការទាមទារសំណង និងលុបចោលការសន្យាផ្តល់ឥណទានដែលមិនទាន់បានប្រើប្រាស់ មិនកំណត់ការប្រឈមរបស់សម្ព័ន្ធធនាគារ និងធនាគារចំពោះការខាតបង់ឥណទានចំពោះរយៈពេលជូនដំណឹងតាមកិច្ចសន្យា។ ហ្វាស៊ីលីធីទាំងនេះមិនមានរយៈពេលថេរ ឬរចនាសម្ព័ន្ធសងត្រឡប់ទេ ហើយត្រូវបានគ្រប់គ្រងលើមូលដ្ឋានហ្វាស៊ីលីធីក្រុម។ សម្ព័ន្ធធនាគារ និងធនាគារអាចលុបចោលពួកគេដោយប្រសិទ្ធភាពភ្លាមៗ ប៉ុន្តែសិទ្ធិតាមកិច្ចសន្យានេះមិនត្រូវបានអនុវត្តនៅក្នុងការគ្រប់គ្រងប្រចាំថ្ងៃជាធម្មតាទេ ប៉ុន្តែនៅពេលដែលសម្ព័ន្ធធនាគារ ឬធនាគារ ដឹងអំពីការកើនឡើងហានិភ័យឥណទាននៅកម្រិតហ្វាស៊ីលីធី។ រយៈពេលវែងជាងនេះ ត្រូវបានប៉ាន់ប្រមាណដោយគិតគូរពីសកម្មភាពគ្រប់គ្រងហានិភ័យឥណទាន ដែលសម្ព័ន្ធធនាគារ និងធនាគារ រំពឹងថានឹងអនុវត្ត ហើយដែលអាចជួយកាត់បន្ថយ ECL បាន។ ទាំងនេះរួមបញ្ចូលទាំងការកាត់បន្ថយកម្រិតកំណត់ការលុបចោលនៃហ្វាស៊ីលីធី និង/ឬ បង្វែរសមតុល្យដែលនៅជំពាក់ទៅជាឥណទានដែលមានលក្ខខណ្ឌសងត្រឡប់វិញថេរ។

*ទ្រព្យសកម្មហិរញ្ញវត្ថុដែលបានរៀបចំឡើងវិញ*

ប្រសិនបើលក្ខខណ្ឌនៃទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានចរចា ឬកែប្រែ ឬទ្រព្យសកម្មហិរញ្ញវត្ថុដែលមានស្រាប់ត្រូវបានជំនួសដោយទ្រព្យសកម្មហិរញ្ញវត្ថុថ្មី ដោយសារស្ថានភាពលំបាកផ្នែកហិរញ្ញវត្ថុរបស់អតិថិជន នោះការវាយតម្លៃត្រូវបានធ្វើឡើង ដើម្បីវាយតម្លៃថាតើទ្រព្យសកម្មហិរញ្ញវត្ថុគួរតែត្រូវឈប់ទទួលស្គាល់ឬទេ [សូមមើលសម្គាល់ (iv)] ហើយ ECL ត្រូវបានវាស់វែងដូចខាងក្រោម៖

- ប្រសិនបើការរៀបចំឡើងវិញ មិននាំឱ្យការឈប់ទទួលស្គាល់ទ្រព្យសកម្មដែលមានស្រាប់ទេ នោះលំហូរសាច់ប្រាក់ដែលរំពឹងទុកថាកើតមានពីទ្រព្យសកម្មហិរញ្ញវត្ថុដែលបានកែប្រែ ត្រូវបានបញ្ចូលនៅក្នុងការគណនាកង្វះខាតនៃសាច់ប្រាក់ពីទ្រព្យសកម្មដែលមានស្រាប់។
- ប្រសិនបើការរៀបចំឡើងវិញ នាំឱ្យមានការឈប់ទទួលស្គាល់ទ្រព្យសកម្មដែលមានស្រាប់ នោះតម្លៃសមស្របរំពឹងទុកនៃទ្រព្យសកម្មថ្មីនោះ ត្រូវបានចាត់ទុកជាលំហូរសាច់ប្រាក់ចុងក្រោយទទួលបានពីទ្រព្យសកម្មហិរញ្ញវត្ថុបច្ចុប្បន្ន នៅពេលដែលឈប់ទទួលស្គាល់។ ចំនួនទឹកប្រាក់នេះត្រូវបានបញ្ចូលទៅក្នុងការគណនាកង្វះខាតសាច់ប្រាក់ពីទ្រព្យសកម្មហិរញ្ញវត្ថុបច្ចុប្បន្ន ដែលត្រូវបានធ្វើអប្បហារពីកាលបរិច្ឆេទរំពឹងទុកនៃការឈប់ទទួលស្គាល់ទៅកាលបរិច្ឆេទនៃការរាយការណ៍ ដោយប្រើអត្រាការប្រាក់ប្រសិទ្ធភាពដើមនៃទ្រព្យសកម្មហិរញ្ញវត្ថុបច្ចុប្បន្ន។

## ២. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត (ត)

### (ង) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

*(vii) ឱនភាពនៃតម្លៃ (ត)*

*ទ្រព្យសកម្មហិរញ្ញវត្ថុដែលបានរៀបចំឡើងវិញ (ត)*

ដោយអនុលោមតាមសារាចរលេខ ធ៧-០២១-២៣១៤ របស់ធនាគារជាតិ នៃ កម្ពុជា ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការធ្វើចំណាត់ថ្នាក់ និងសំវិធានធន ចំពោះឥណទានរៀបចំឡើងវិញ ធនាគារត្រូវបានតម្រូវឱ្យធ្វើការវាយតម្លៃលើការធ្វើចំណាត់ថ្នាក់ទៅលើឥណទានដែលបានរៀបចំឡើងវិញ ដែលនៅមានសមតុល្យជំពាក់នៅឡើយ និងការធ្វើសំវិធានធនដូចខាងក្រោម៖

- ឥណទានដែលបានរៀបចំឡើងវិញដែល "មិនមានការប្រែប្រួល" ត្រូវបានកំណត់ជា "ឥណទានដំណើរការ" និងត្រូវបានចាត់ថ្នាក់ជា "ឥណទានឃ្លាំមើល" ជាមួយសំវិធានធន ៣% ដោយមិនគិតពីចំនួននៃការរៀបចំឡើងវិញ។
- ឥណទានដែលបានរៀបចំឡើងវិញដែលត្រូវការ "ការរៀបចំឡើងវិញបន្ថែម" ត្រូវបានកំណត់ជា "ឥណទានមិនដំណើរការ" និងត្រូវបានចាត់ថ្នាក់ជា "ឥណទានក្រោមស្តង់ដា" ជាមួយសំវិធានធន ២០% សម្រាប់ឥណទានដែលរៀបចំឡើងវិញលើកទីមួយ និងត្រូវបានចាត់ថ្នាក់ជា "ឥណទានសង្ស័យ" ជាមួយសំវិធានធន ៥០% សម្រាប់ឥណទានដែលរៀបចំឡើងវិញលើកទីពីរ។
- ឥណទានដែលបានរៀបចំឡើងវិញដែល "មានការប្រែប្រួល" ត្រូវបានកំណត់ជា "ឥណទានមិនដំណើរការ" និងត្រូវបានចាត់ថ្នាក់ជា "ឥណទានដែលបាត់បង់" ដែលត្រូវធ្វើសំវិធានធន ១០០%។

*ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពនៃតម្លៃឥណទាន*

នៅកាលបរិច្ឆេទនៃការរាយការណ៍នីមួយៗ សម្ព័ន្ធធនាគារ និងធនាគារវាយតម្លៃថាតើទ្រព្យសកម្មហិរញ្ញវត្ថុដែលបានកត់ត្រាតាមថ្លៃដើមបានរំលស់ (និងទ្រព្យសកម្មហិរញ្ញវត្ថុបំណុលដែលបានកត់ត្រាតាម FVOCI ប្រសិនបើមាន) មានឱនភាពនៃតម្លៃឥណទានដែរឬទេ (សំដៅលើ "ទ្រព្យសកម្មហិរញ្ញវត្ថុនៅដំណាក់កាលទី៣")។ ទ្រព្យសកម្មហិរញ្ញវត្ថុមួយមានឱនភាពនៃតម្លៃឥណទាន នៅពេលដែលព្រឹត្តិការណ៍មួយ ឬច្រើន ដែលនាំឱ្យមានផលប៉ះពាល់ជាអវិជ្ជមានទៅលើលំហូរសាច់ប្រាក់នាពេលអនាគត ដែលរំពឹងទុកនៃទ្រព្យសកម្មហិរញ្ញវត្ថុ បានកើតឡើង។

ភស្តុតាងដែលបញ្ជាក់ថាទ្រព្យសកម្មហិរញ្ញវត្ថុមានឱនភាពនៃតម្លៃឥណទាន រួមមានទិន្នន័យដែលអាចអង្កេតបានដូចខាងក្រោម៖

- ការលំបាកផ្នែកហិរញ្ញវត្ថុជាសារវន្តរបស់អតិថិជន ឬអ្នកបោះផ្សាយ
- ការបំពានកិច្ចសន្យា ដូចជាការខកខានសង ឬហួសកាលកំណត់
- ការរៀបចំឡើងវិញលើលក្ខខណ្ឌនៃឥណទាន ឬបុរេប្រទាន ដោយសម្ព័ន្ធធនាគារ និងធនាគារលើលក្ខខណ្ឌដែលសម្ព័ន្ធធនាគារ និងធនាគារមិនគួរយល់ព្រម

## ២. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត (ត)

### (ង) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

*(vii) ឱនភាពនៃតម្លៃ (ត)*

*ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពនៃតម្លៃឥណទាន (ត)*

- អតិថិជនទំនងជានឹងក្ស័យធន ឬត្រូវរៀបចំហិរញ្ញវត្ថុផ្សេងទៀតឡើងវិញ ឬ
- ការបាត់បង់ទីផ្សារសកម្មចំពោះទ្រព្យដាក់បញ្ចាំមួយដោយសារតែការលំបាកផ្នែកហិរញ្ញវត្ថុ។

ឥណទានដែលត្រូវបានចរចាឡើងវិញ ដោយសារតែការធ្លាក់ចុះនៃស្ថានភាពរបស់អតិថិជន ត្រូវបានចាត់ទុកថាមានឱនភាពនៃតម្លៃឥណទាន លុះត្រាតែមានភស្តុតាងបញ្ជាក់ថាហានិភ័យនៃការមិនទទួលបានលំហូរសាច់ប្រាក់តាមកិច្ចសន្យាបានថយចុះជាសារវន្ត និងមិនមានសូចនាករផ្សេងទៀតដែលនាំឱ្យមានឱនភាពនៃតម្លៃ។ បន្ថែមពីនេះ ឥណទានសម្រាប់ការជួញដូររាយដែលហួសកាលកំណត់សង ៩០ថ្ងៃ ឬលើសពីនេះ ត្រូវបានចាត់ទុកថាមានឱនភាពនៃតម្លៃឥណទាន ទោះបីជានិយមន័យនៃការខកខានសងតាមបទប្បញ្ញត្តិបានកំណត់ផ្សេងគ្នាក៏ដោយ។

**ការបង្ហាញសំវិធានធនសម្រាប់ ECL នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ**

សម្ព័នធនាគារ និងធនាគារបង្ហាញសំវិធានធនខាតបង់សម្រាប់ ECL នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុដូចខាងក្រោម៖

- ទ្រព្យសកម្មហិរញ្ញវត្ថុដែលវាស់វែងតាមថ្លៃដើមបានរំលស់៖ ជាការកាត់បន្ថយពីតម្លៃយោងដុលរបស់ទ្រព្យសកម្ម
- ការសន្យាផ្តល់ឥណទាន និងកិច្ចសន្យាធានាហិរញ្ញវត្ថុ៖ ជាទូទៅជាការធ្វើសំវិធានធន
- នៅពេលដែលឧបករណ៍ហិរញ្ញវត្ថុមួយរួមបញ្ចូលទាំងសមាសធាតុមិនទាន់បានប្រើប្រាស់ និងបានប្រើប្រាស់ ហើយសម្ព័ន្ធធនាគារ និងធនាគារមិនអាចកំណត់ ECL លើសមាសធាតុការសន្យាផ្តល់ឥណទានដោយឡែកពីសមាសធាតុនៃការសន្យាផ្តល់ឥណទានដែលបានប្រើប្រាស់សម្ព័ន្ធធនាគារ និងធនាគារធ្វើការបង្ហាញសំវិធានធនខាតបង់រួមបញ្ចូលគ្នាសម្រាប់សមាសធាតុទាំងពីរ។ ចំនួនរួមបញ្ចូលគ្នាត្រូវបានបង្ហាញជាការកាត់ចេញពីតម្លៃយោងដុលនៃសមាសធាតុដែលបានប្រើប្រាស់។ ចំនួនលើសរបស់សំវិធានធនខាតបង់លើតម្លៃយោងដុលនៃសមាសធាតុ ដែលបានប្រើប្រាស់ត្រូវបានបង្ហាញជាការធ្វើសំវិធានធន និង
- ឧបករណ៍បំណុលដែលបានវាស់វែងតាម FVOCI៖ មិនមានសំវិធានធនខាតបង់ដែលត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុទេ ពីព្រោះតម្លៃយោងនៃទ្រព្យសកម្មទាំងនេះគឺជាតម្លៃសមស្រប។ ទោះយ៉ាងណាក៏ដោយសំវិធានធនខាតបង់ត្រូវបានលាតត្រដាង និងទទួលស្គាល់នៅក្នុងទុនបម្រុងតម្លៃសមស្រប។

## ២. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត(ត)

### (ង) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

*(vii) ឱនភាពនៃតម្លៃ (ត)*

**ការជម្រះចេញពីបញ្ជី**

ឥណទាន និងមូលបត្របំណុល ត្រូវបានជម្រះចេញពីបញ្ជី (ជាផ្នែក ឬទាំងស្រុង) នៅពេលមិនមានការរំពឹងទុកសមហេតុផលថា អាចប្រមូលបានមកវិញនូវទ្រព្យសកម្មហិរញ្ញវត្ថុនោះទាំងស្រុង ឬចំណែកណាមួយ។ ករណីនេះមានជាទូទៅ នៅពេលសម្ព័ន្ធធនាគារ និងធនាគារកំណត់ថាអ្នកខ្ចីពុំមានទ្រព្យសកម្ម ឬប្រភពចំណូលណាដែលអាចបង្កើតបាននូវលំហូរសាច់ប្រាក់គ្រប់គ្រាន់ ដើម្បីទូទាត់សងនូវចំនួនដែលត្រូវលុបចេញពីបញ្ជី។ ការវាយតម្លៃនេះត្រូវបានធ្វើឡើងតាមកម្រិតទ្រព្យសកម្មទោល។

ទឹកប្រាក់ដែលប្រមូលបានមកវិញពីចំនួនដែលបានលុបចេញពីបញ្ជី ត្រូវបញ្ចូលនៅក្នុងរបាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ។

ទ្រព្យសកម្មហិរញ្ញវត្ថុដែលបានជម្រះចេញពីបញ្ជី នៅតែអាចជាកម្មវត្ថុចំពោះសកម្មភាពទាមទារសងមកវិញតាមផ្លូវច្បាប់ ដើម្បីអនុលោមតាមនីតិវិធីរបស់សម្ព័ន្ធធនាគារ និងធនាគារក្នុងការប្រមូលមកវិញនូវទឹកប្រាក់ដែលនៅជំពាក់។

**ការធានាហិរញ្ញវត្ថុមិនមែនជាផ្នែកសំខាន់នៃកិច្ចសន្យា**

សម្ព័ន្ធធនាគារ និងធនាគារ វាយតម្លៃថាតើកិច្ចសន្យាធានាហិរញ្ញវត្ថុ គឺជាធាតុផ្សំមួយដ៏សំខាន់នៃទ្រព្យសកម្មហិរញ្ញវត្ថុ ដែលត្រូវបានរាប់បញ្ចូលជាសមាសធាតុនៃឧបករណ៍នោះ ឬជាកិច្ចសន្យាដែលត្រូវបានកត់ត្រាដោយឡែកពីគ្នា។ កត្តាដែលសម្ព័ន្ធធនាគារ និងធនាគារពិចារណានៅពេលធ្វើការវាយតម្លៃនេះ រួមមាន៖

- ការធានា គឺជាផ្នែកមួយនៃលក្ខខណ្ឌតាមកិច្ចសន្យារបស់ឧបករណ៍បំណុល
- ការធានាត្រូវបានទាមទារដោយច្បាប់ និងបទប្បញ្ញត្តិដែលគ្រប់គ្រងកិច្ចសន្យារបស់ឧបករណ៍បំណុល
- ការធានាត្រូវបានបញ្ចូលក្នុងពេលដំណាលគ្នា និងឧបករណ៍បំណុល ឬ
- ការធានាត្រូវបានផ្តល់ដោយក្រុមហ៊ុនមេរបស់អ្នកខ្ចី ឬក្រុមហ៊ុនផ្សេងទៀតនៅក្នុងសម្ព័ន្ធរបស់អ្នកខ្ចី។

## ២. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត (ត)

### (ង) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

*(vii) ឱនភាពនៃតម្លៃ (ត)*

**ការធានាហិរញ្ញវត្ថុមិនមែនជាផ្នែកសំខាន់នៃកិច្ចសន្យា (ត)**

ប្រសិនបើសម្ព័ន្ធធនាគារ និងធនាគារកំណត់ថាការធានាគឺជាធាតុផ្សំសំខាន់មួយនៃទ្រព្យសកម្មហិរញ្ញវត្ថុ នោះបុព្វលាភត្រូវសងណាមួយទាក់ទងនឹងការទទួលស្គាល់លើកដំបូងនៃទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានចាត់ទុកថាជាចំណាយ ប្រតិបត្តិការក្នុងការធ្វើលទ្ធកម្មទ្រព្យសកម្មហិរញ្ញវត្ថុ។ សម្ព័ន្ធធនាគារ និងធនាគារពិចារណាលើផលប៉ះពាល់នៃការការពារនៅពេលវាស់វែងតម្លៃសមស្របនៃឧបករណ៍បំណុល និងនៅពេលវាស់វែង ECL។

ប្រសិនបើសម្ព័ន្ធធនាគារ ឬធនាគារកំណត់ថាការធានាមិនមែនជាធាតុផ្សំសំខាន់នៃឧបករណ៍បំណុលទេ នោះវាទទួលស្គាល់ជាទ្រព្យសកម្មមួយ ដែលបង្ហាញពីការបង់ប្រាក់ជាមុននៃបុព្វលាភនៃការធានា និងសិទ្ធិទូទាត់សងសម្រាប់ការខាតបង់ឥណទាន។ ទ្រព្យសកម្មបុព្វលាភបង់មុន ត្រូវបានទទួលស្គាល់លុះត្រាតែការធានាមិនមានឱនភាពនៃតម្លៃឥណទាន ឬមិនមានការកើនឡើងជាសារវន្តនូវហានិភ័យឥណទាន (“SICR”) នៅពេលការធានាត្រូវបានទទួលស្គាល់។ ទ្រព្យសកម្មទាំងនេះត្រូវបានទទួលស្គាល់នៅក្នុង "ទ្រព្យសកម្មផ្សេងៗ"។ សម្ព័ន្ធធនាគារ និងធនាគារបង្ហាញពីចំណេញ ឬខាត លើការទទួលបាននូវសំណងទាំងស្រុងនៅក្នុងចំណេញ ឬខាត ជា "ការខាតបង់លើឱនភាពនៃតម្លៃលើឧបករណ៍ហិរញ្ញវត្ថុ"។

*(viii) ឧបករណ៍ហិរញ្ញវត្ថុនិស្សន្ទ*

សម្ព័ន្ធធនាគារ និងធនាគារមានឧបករណ៍ហិរញ្ញវត្ថុនិស្សន្ទច្រើនប្រភេទ ដើម្បីគ្រប់គ្រងការប្រឈមទៅនឹងហានិភ័យអត្រាការប្រាក់តាមរយៈការផ្លាស់ប្តូរអត្រាការប្រាក់។ ការប្រើប្រាស់ឧបករណ៍ហិរញ្ញវត្ថុនិស្សន្ទ ត្រូវបានគ្រប់គ្រងដោយគោលនយោបាយរបស់សម្ព័ន្ធធនាគារ និងធនាគារ ដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាល ដែលផ្តល់នូវគោលការណ៍ជាលាយលក្ខណ៍អក្សរលើការប្រើប្រាស់និស្សន្ទហិរញ្ញវត្ថុ។

ឧបករណ៍និស្សន្ទ ត្រូវបានទទួលស្គាល់ដំបូងតាមតម្លៃសមស្របនាកាលបរិច្ឆេទនៃកិច្ចសន្យារបស់ឧបករណ៍និស្សន្ទដែលបានធ្វើឡើង និងត្រូវបានវាស់វែងជាបន្តបន្ទាប់តាមតម្លៃសមស្របរបស់វានាកាលបរិច្ឆេទនៃរបាយការណ៍នីមួយៗ។ លទ្ធផលចំណេញ/ខាត ត្រូវបានទទួលស្គាល់ក្នុងគណនីចំណេញ ឬខាតភ្លាមៗ លើកលែងតែឧបករណ៍និស្សន្ទត្រូវបានកំណត់ និងមានប្រសិទ្ធភាពជាឧបករណ៍ការពារហានិភ័យ ក្នុងរយៈពេលនៃព្រឹត្តិការណ៍ពីការទទួលស្គាល់ក្នុងគណនីចំណេញ ឬខាត គឺអាស្រ័យលើលក្ខណៈនៃទំនាក់ទំនងនៃការការពារហានិភ័យ។

ឧបករណ៍និស្សន្ទដែលមានតម្លៃសមស្របវិជ្ជមានត្រូវបានទទួលស្គាល់ជាទ្រព្យសកម្មហិរញ្ញវត្ថុ ខណៈពេលដែលឧបករណ៍និស្សន្ទដែលមានតម្លៃសមស្របអវិជ្ជមានត្រូវបានទទួលស្គាល់ជាបំណុលហិរញ្ញវត្ថុ។ ឧបករណ៍និស្សន្ទ មិនត្រូវបានកាត់កងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុលើកលែងតែសម្ព័ន្ធធនាគារ និងធនាគារមានទាំងសិទ្ធិស្របច្បាប់ និងគោលបំណងក្នុងការកាត់កង។

## ២. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត (ត)

### (ង) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

*(ix) គណនេយ្យការពារលើហានិភ័យ*

សម្ព័ន្ធធនាគារ និងធនាគារ កំណត់នូវឧបករណ៍និស្សន្ទជាក់លាក់ជាឧបករណ៍ការពារហានិភ័យដែលទាក់ទងនឹងហានិភ័យរូបិយប័ណ្ណបរទេស និងហានិភ័យអត្រាការប្រាក់ក្នុងការការពារហានិភ័យតម្លៃសមស្របការការពារហានិភ័យលើលំហូរសាច់ប្រាក់ ឬការការពារហានិភ័យដែលសមស្រប ក្នុងការវិនិយោគក្នុងក្រុមហ៊ុនបរទេស។ ការការពារហានិភ័យនៃអត្រាការប្រាក់តាមកិច្ចព្រមព្រៀងរបស់ក្រុមហ៊ុន ត្រូវបានកំណត់ជាការការពារហានិភ័យលំហូរសាច់ប្រាក់។ សម្ព័ន្ធធនាគារ និងធនាគារមិនត្រូវបានអនុវត្តទៅលើគណនេយ្យការពារហានិភ័យតម្លៃសមស្របនៃផលបត្រនៃការការពារហានិភ័យអត្រាការប្រាក់ឡើយ។

នាកាលបរិច្ឆេទនៃការចាប់ផ្តើមអនុវត្តលើទំនាក់ទំនងនៃការការពារហានិភ័យ សម្ព័ន្ធធនាគារ និងធនាគារធ្វើការកត់ត្រាពីទំនាក់ទំនងរវាងឧបករណ៍ការពារហានិភ័យ និងសមាសធាតុការពារហានិភ័យ រួមជាមួយគោលបំណងចម្បងក្នុងការគ្រប់គ្រងហានិភ័យ និងយុទ្ធសាស្រ្តក្នុងការធ្វើប្រតិបត្តិការក្នុងការការពារហានិភ័យ។ បន្ថែមពីនេះទៀតនាកាលបរិច្ឆេទនៃការចាប់ផ្តើមការការពារហានិភ័យ និងបន្តនិរន្តរភាព សម្ព័ន្ធធនាគារ និងធនាគារកត់ត្រាថាតើឧបករណ៍ការពារហានិភ័យមានប្រសិទ្ធភាពក្នុងការកាត់កងក្នុងការផ្លាស់ប្តូរតម្លៃសមស្រប ឬលំហូរសាច់ប្រាក់នៃឧបករណ៍ការពារហានិភ័យដែលចូលរួមក្នុងការការពារហានិភ័យ នៅពេលដែលការការពារហានិភ័យទាក់ទងនឹងការបំពេញតាមតម្រូវការក្នុងការការពារហានិភ័យប្រកបដោយប្រសិទ្ធភាពដូចខាងក្រោម៖

- មានទំនាក់ទំនងផ្នែកសេដ្ឋកិច្ចរវាងសមាសធាតុគណនីការពារហានិភ័យ និងឧបករណ៍ការពារហានិភ័យ
- ផលប៉ះពាល់ពីហានិភ័យឥណទាន មិនទទួលឥទ្ធិពលពីការផ្លាស់ប្តូរតម្លៃដែលជាលទ្ធផលបានពីផ្នែកសេដ្ឋកិច្ច និង
- អនុបាតនៃការការពារហានិភ័យដែលទាក់ទង គឺដូចគ្នាទៅនឹងលទ្ធផលពីបរិមាណការពារហានិភ័យដែលសម្ព័ន្ធធនាគារ និងធនាគារធ្វើការការពារហានិភ័យជាក់ស្តែង និងបរិមាណនៃឧបករណ៍ការពារហានិភ័យដែលសម្ព័ន្ធធនាគារ និងធនាគារបានប្រើប្រាស់ជាក់ស្តែងក្នុងការពារហានិភ័យ។

សម្ព័ន្ធធនាគារ និងធនាគារ ធ្វើតុល្យភាពឡើងវិញទាក់ទងនឹងការពារហានិភ័យ ដើម្បីបំពេញនូវតម្រូវការនៃអនុបាតការពារហានិភ័យនៅពេលដែលចាំបាច់។

ប្រសិនបើទំនាក់ទំនងនៃការពារហានិភ័យ មិនបានបំពេញតាមតម្រូវការនៃការការពារហានិភ័យប្រកបដោយប្រសិទ្ធភាពទាក់ទងអនុបាតការពារហានិភ័យ ប៉ុន្តែគោលបំណងនៃការគ្រប់គ្រងហានិភ័យសម្រាប់ទំនាក់ទំនងនៃការការពារហានិភ័យនៅរក្សាដដែល សម្ព័ន្ធធនាគារ និងធនាគារ ធ្វើការកែតម្រូវលើអនុបាតការពារហានិភ័យនៃទំនាក់ទំនងនៃការការពារហានិភ័យ (ឧទាហរណ៍ ធ្វើតុល្យភាពការពារហានិភ័យឡើងវិញ) ដូច្នេះវាបំពេញតាមតម្រូវការលក្ខណៈនៃវិនិច្ឆ័យម្តងទៀត។

## ២. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត (ត)

### (ង) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

*(ix) គណនេយ្យការពារលើហានិភ័យ (ត)*

នាកាលបរិច្ឆេទរាយការណ៍ សម្ព័ន្ធធនាគារ និងធនាគារ មានតែការការពារហានិភ័យលំហូរសាច់ប្រាក់តែប៉ុណ្ណោះនៅក្នុងកិច្ចសន្យាផ្លាស់ប្តូរអត្រាការប្រាក់។

ផ្នែកដែលមានប្រសិទ្ធភាពក្នុងការផ្លាស់ប្តូរលើតម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុនិស្សន្ទ និងឧបករណ៍ការពារហានិភ័យដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលត្រូវបានកំណត់ និងការការពារហានិភ័យលំហូរសាច់ប្រាក់ត្រូវបានទទួលស្គាល់ក្នុងគណនីប្រាក់ចំណេញរក្សាទុករបស់សម្ព័ន្ធធនាគារ និងធនាគារ ប៉ុន្តែបានកំណត់ទៅលើការផ្លាស់ប្តូរតម្លៃសមស្របលើសមាសធាតុការពារហានិភ័យ ចាប់ពីកាលបរិច្ឆេទចាប់ផ្តើមការការពារហានិភ័យដកចេញនូវសមតុល្យដែលបានកែតម្រូវឡើងវិញទៅលើគណនីចំណេញ ឬខាត។

សមតុល្យសាច់ប្រាក់ដែលបានទទួលស្គាល់កន្លងមកក្នុងលទ្ធផលលម្អិតផ្សេងៗ និងត្រូវបានបង្គរក្នុងគណនីមូលធនត្រូវបានធ្វើចំណាត់ថ្នាក់ឡើងវិញទៅជាគណនីចំណេញ ឬខាត ក្នុងការិយបរិច្ឆេទនៅពេលដែលសមាសធាតុការពារហានិភ័យប៉ះពាល់ដល់គណនីចំណេញ ឬខាត និងក្នុងករណីដូចគ្នាក្នុងការទទួលស្គាល់សមាសធាតុការពារហានិភ័យ។ ប្រសិនបើសម្ព័ន្ធធនាគារ និងធនាគារមិនរំពឹងទុកថាប្រតិបត្តិការនេះនឹងកើតឡើង នោះសមតុល្យនេះត្រូវបានចាត់ថ្នាក់ឡើងវិញភ្លាមៗទៅក្នុងគណនីចំណេញ ឬខាត។

សម្ព័ន្ធធនាគារ និងធនាគារបញ្ចប់គណនីការពារហានិភ័យលុះត្រាតែទំនាក់ទំនងការពារហានិភ័យ (ឬផ្នែកមួយរបស់វា) មិនបានបំពេញតាមលក្ខណៈវិនិច្ឆ័យគ្រប់គ្រាន់ (បន្ទាប់ពីការធ្វើសមតុល្យឡើងវិញ ប្រសិនបើអាចអនុវត្តបាន)។ ទាំងនេះរួមបញ្ចូលទាំងករណីដែលឧបករណ៍ការពារហានិភ័យបានហួសកាលកំណត់ ឬបានលក់ចេញ បានលុបចោល ឬបានប្រើប្រាស់ ឬនៅពេលដែលប្រតិបត្តិការក្នុងការព្យាករណ៍លើការការពារហានិភ័យដែលបានកំណត់មិនត្រូវបានកំណត់ថាអាចកើតមានឡើង។ ការបញ្ឈប់ ត្រូវបានកំណត់សម្រាប់ពេលអនាគត។ រាល់ការចំណេញ/ខាត ត្រូវបានទទួលស្គាល់ក្នុងលទ្ធផលលម្អិតផ្សេងៗ និង បង្គរទុកក្នុងគណនីមូលធននាកាលបរិច្ឆេទដែលគណនីមូលធនដែលនៅសល់ ហើយត្រូវបានទទួលស្គាល់នៅពេលដែលការព្យាករណ៍ប្រតិបត្តិការត្រូវបានទទួលស្គាល់ចុងក្រោយក្នុងគណនីចំណេញ ឬខាត។ នៅពេលដែលការព្យាករណ៍ប្រតិបត្តិការមិនត្រូវបានរំពឹងទុកថានឹងកើតមានឡើងទៀត ចំណេញ/ខាត ត្រូវបានបង្គរក្នុងគណនីមូលធន គឺត្រូវបានចាត់ថ្នាក់ឡើងវិញ និងបានទទួលស្គាល់ភ្លាមៗក្នុងគណនីចំណេញ ឬខាត។

### (ច) សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សាច់ប្រាក់ និងសាច់ប្រាក់សមមូលរួមមានសាច់ប្រាក់ក្នុងដៃ និងប្រាក់បញ្ញើនៅធនាគារផ្សេងៗ ដែលរយៈពេលដំបូងមានរយៈពេល៣ខែ ឬតិចជាង និងដែលអាចប្តូរជាសាច់ប្រាក់ពេលណាក៏បានដោយមានហានិភ័យមិនជាសារវន្តចំពោះការផ្លាស់ប្តូរតម្លៃ។

សាច់ប្រាក់ និងសមមូលសាច់ប្រាក់ ត្រូវបានគិតតាមថ្លៃដើមបានរំលស់ក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

## ២. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត (ត)

### (ឍ) ឥណទាន និងបុរេប្រទាន

"ឥណទាន និងបុរេប្រទាន" ដែលបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ រួមមានឥណទាន និងបុរេប្រទាន ដែលបានវាស់វែងតាមថ្លៃដើមបានរំលស់។ ឥណទាន និងបុរេប្រទានត្រូវបានវាស់វែងលើកដំបូងតាមតម្លៃសមស្រប បូកនឹងចំណាយប្រតិបត្តិការដែលកើតឡើងដោយផ្ទាល់បន្ថែម ហើយនាពេលបន្ទាប់ត្រូវកត់ត្រាតាមថ្លៃដើមបានរំលស់ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។

### (ណ) ការវិនិយោគហិរញ្ញវត្ថុ

"ការវិនិយោគហិរញ្ញវត្ថុ" ដែលបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ អាចរួមមាន៖

- មូលបត្រវិនិយោគបំណុល ដែលបានវាស់វែងតាមថ្លៃដើមបានរំលស់។ មូលបត្រវិនិយោគបំណុលទាំងនេះត្រូវបានវាស់លើកដំបូង តាមតម្លៃសមស្របបូកនឹងចំណាយប្រតិបត្តិការដែលកើតឡើងដោយផ្ទាល់បន្ថែម ហើយនាពេលបន្ទាប់ត្រូវកត់ត្រាតាមថ្លៃដើមបានរំលស់ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។
- មូលបត្របំណុលដែលវាស់វែងតាម FVOCI និង
- មូលបត្រវិនិយោគលើមូលធនដែលបានកំណត់តាម FVOCI។

ចំពោះមូលបត្របំណុលដែលបានវាស់វែងតាម FVOCI ចំណេញ និងខាត ត្រូវបានទទួលស្គាល់នៅក្នុងលទ្ធផលលម្អិតផ្សេងៗ លើកលែងតែចំណុចដូចខាងក្រោម ដែលត្រូវបានទទួលស្គាល់នៅក្នុងចំណេញ ឬខាតតាមរបៀបដូចគ្នានឹងទ្រព្យសកម្មហិរញ្ញវត្ថុដែលត្រូវបានវាស់តាមថ្លៃដើមបានរំលស់៖

- ចំណូលការប្រាក់ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព
- ECL និងការកត់ត្រាបញ្ច្រាស និង
- ចំណេញ និងខាតលើការប្តូររូបិយប័ណ្ណបរទេស។

នៅពេលដែលមូលបត្របំណុលវាស់វែងតាម FVOCI ត្រូវបានឈប់ទទួលស្គាល់ចំណេញ ឬខាតបង្គរដែលបានទទួលស្គាល់ពីមុននៅក្នុងលទ្ធផលលម្អិតផ្សេងៗ ត្រូវបានចាត់ថ្នាក់ឡើងវិញពីមូលធនទៅរបាយការណ៍ចំណេញ ឬខាត។

សម្ព័ន្ធធនាគារ និងធនាគារជ្រើសរើសបង្ហាញនៅក្នុងលទ្ធផលលម្អិតផ្សេងៗ អំពីការផ្លាស់ប្តូរនៅក្នុងតម្លៃសមស្របនៃការវិនិយោគជាក់លាក់នៅក្នុងឧបករណ៍មូលធន ដែលមិនត្រូវបានទុកសម្រាប់ជួញដូរ។ ការជ្រើសរើសនេះធ្វើឡើងដោយផ្អែកលើមូលដ្ឋាននៃឧបករណ៍នីមួយៗនៅពេលទទួលស្គាល់លើកដំបូង និងជាស្ថាពរ។

## ២. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត (ត)

### (ជ) ការវិនិយោគហិរញ្ញវត្ថុ (ត)

ចំណេញ និងខាតលើឧបករណ៍មូលធនទាំងនេះនឹងមិនត្រូវបានចាត់ថ្នាក់ឡើងវិញទៅលើរបាយការណ៍ចំណេញ ឬខាតទេ ហើយក៏ពុំមានឱនភាពនៃតម្លៃត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ចំណេញ ឬខាតដែរ។ ភាគលាភ ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាត លើកលែងតែវាបង្ហាញយ៉ាងច្បាស់ពីការប្រមូលបានមកវិញលើផ្នែកខ្លះរបស់ថ្លៃដើមនៃការវិនិយោគ ក្នុងករណីដែលពួកគេត្រូវបានទទួលស្គាល់នៅក្នុងលទ្ធផលលម្អិតផ្សេងៗ។ ចំណេញ និងខាតបង្គរដែលត្រូវបានទទួលស្គាល់នៅក្នុងលទ្ធផលលម្អិតផ្សេងៗ ត្រូវបានផ្ទេរទៅក្នុងប្រាក់ចំណេញរក្សាទុកលើការលក់ចេញរបស់ការវិនិយោគ។

### (ឈ) ទ្រព្យសកម្មផ្សេងៗ

ទ្រព្យសកម្មផ្សេងៗរួមមានការទូទាត់ជាមុន និងបុរេប្រទាន ការផ្គត់ផ្គង់សម្ភារការិយាល័យ ប្រាក់ទទួលបានពី Western Union និង Visa ពន្ធប្រាក់ចំណេញត្រូវទទួល និងផ្សេងៗ។

ការទូទាត់ជាមុន និងបុរេប្រទានរួមបញ្ចូលការចំណាយគ្រប់ប្រភេទដែលបានទូទាត់ជាមុន ប៉ុន្តែសម្រាប់ទ្រព្យ-សកម្មនឹងមិនត្រូវបានប្រើប្រាស់រហូតដល់ការិយបរិច្ឆេទនាពេលអនាគតមួយ ហើយនឹងត្រូវបានជម្រះជាបន្តបន្ទាប់ទៅចំណេញ ឬខាតនៅក្នុងការិយបរិច្ឆេទរាយការណ៍ ខណៈដែលបុរេប្រទានរួមបញ្ចូលទាំងប្រាក់កក់ដែលអាចបង្វិលមកវិញបាន និងការទូទាត់បុរេប្រទានគ្រប់ប្រភេទ សម្រាប់ការទិញទំនិញ ឬសេវាកម្មដែលនឹងត្រូវបានជម្រះដោយផ្អែកលើវិក្កយបត្ររបស់ទំនិញ ឬសេវាកម្មទាំងនោះ។

ការផ្គត់ផ្គង់សម្ភារការិយាល័យរួមបញ្ចូលទាំងសម្ភាររដ្ឋបាលធម្មតា និងចាំបាច់ទាំងអស់សម្រាប់ប្រើប្រាស់ក្នុងប្រតិបត្តិការប្រចាំថ្ងៃ។

ប្រាក់ទទួលបានពី Western Union និង Visa តំណាងឱ្យសមតុល្យពីការផ្ទេរប្រាក់ទាំងអស់ ដែលកំពុងរង់ចាំការទូទាត់ពីដៃគូក្រៅប្រទេសក៏ដូចជាដៃគូគ្រប់ប្រភេទកាត។

ពន្ធប្រាក់ចំណេញត្រូវទទួលពាក់ព័ន្ធនឹងឥណទានពន្ធដែលអាចកាត់កងនឹងបំណុលពន្ធបាន។

ទ្រព្យសកម្មផ្សេងៗរួមមានទ្រព្យសកម្មរយៈពេលខ្លីផ្សេងៗទាំងអស់ដែលមិនត្រូវបានបញ្ជាក់នៅខាងលើ ដូចជាគណនីត្រូវទទួលផ្សេងៗដែលរង់ចាំក្នុងការជម្រះ ការដោះស្រាយ និង/ឬការទូទាត់ជាមួយអតិថិជន អ្នកផ្គត់ផ្គង់ ឬដៃគូនានា ក៏ដូចជាធនាគារផ្សេងៗ។

### (ញ) ដើមទុន និងបុព្វលាភដើមទុន

ដើមទុន និងបុព្វលាភដើមទុន ត្រូវបានចាត់ថ្នាក់ជាមូលធន។

## ២. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត (ត)

### (ញ) ដើមទុន និងបុព្វលាភដើមទុន (ត)

ដើមទុនតំណាងឱ្យតម្លៃដើម (ចារឹក) នៃភាគហ៊ុនដែលត្រូវបានបោះផ្សាយ។ ភាគហ៊ុនដទៃទៀតប្រសិនបើមានត្រូវបានចាត់ថ្នាក់ជាមូលធន និង/ឬបំណុល ផ្អែកលើសមាសធាតុសេដ្ឋកិច្ចនៃឧបករណ៍ទាំងនោះ។ ការបែងចែកទៅអ្នកកាន់កាប់ឧបករណ៍ហិរញ្ញវត្ថុមួយដែលបានចាត់ថ្នាក់ជាឧបករណ៍មូលធនត្រូវបានទូទាត់ដោយផ្ទាល់ទៅមូលធន។

បុព្វលាភភាគហ៊ុន រួមបញ្ចូលបុព្វលាភដែលបានទទួលក្នុងការបោះផ្សាយដើមទុន។ ថ្លៃដើមបន្ថែមដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹងការបោះផ្សាយដើមទុនថ្មី ត្រូវបានបង្ហាញក្នុងផ្នែកមូលធនដោយកាត់ចេញប្រាក់ពន្ធពីសាច់ប្រាក់ដែលបានទទួល។

### (ដ) ចំណេញក្នុងមួយភាគហ៊ុន

មូលដ្ឋានចំណេញក្នុងមួយភាគហ៊ុន ("EPS") គឺកំណត់ដោយយកប្រាក់ចំណេញសុទ្ធដែលបានធ្វើនិយ័តកម្មរួចបែងចែកទៅម្ចាស់ភាគហ៊ុនដោយចែកនឹងចំនួនជាមធ្យមនៃចំនួនភាគហ៊ុន ដែលមាននៅក្នុងឆ្នាំបន្ទាប់ពីការបែងចែកភាគលាភនៅក្នុងការិយបរិច្ឆេទបច្ចុប្បន្ន។

ចំណេញក្នុងមួយភាគហ៊ុនថយចុះ ក៏គណនាដូចគ្នាដោយយកប្រាក់ចំណេញសុទ្ធចែកនឹងចំនួនជាមធ្យមនៃចំនួនភាគហ៊ុនដែលមាន និងចេញផ្សាយនៅក្នុងឆ្នាំ។ ទោះជាយ៉ាងណាក៏ដោយប្រាក់ចំណេញសុទ្ធសម្រាប់បែងចែកភាគហ៊ុន និងចំនួនជាមធ្យមនៃចំនួនភាគហ៊ុន ត្រូវបានកែតម្រូវដើម្បីបង្ហាញពីផលប៉ះពាល់នៃភាគហ៊ុនសក្តានុពលថយចុះទៅក្នុងភាគហ៊ុនធម្មតា។ បច្ចុប្បន្នមិនមានភាគហ៊ុនសក្តានុពលថយចុះទេ។

### (ឋ) ទ្រព្យសម្បត្តិ និងបរិក្ខារ

ទ្រព្យសម្បត្តិ និងបរិក្ខារត្រូវបានកត់ត្រាតាមថ្លៃដើមដករំលស់បង្គរ និងការខាតបង់ឱនភាពនៃតម្លៃបង្គរ។ ថ្លៃដើមរួមមានការចំណាយផ្ទាល់នានា ក្នុងការធ្វើលទ្ធកម្មទ្រព្យសកម្មនៃទ្រព្យសម្បត្តិ និងបរិក្ខារ។ ថ្លៃដើមរបស់ទ្រព្យ-សម្បត្តិ និងបរិក្ខាររួមមាន៖

- តម្លៃទិញចូលនៃទ្រព្យសម្បត្តិ និងបរិក្ខារ រួមទាំងចំណាយនាំចូល និងពន្ធលើការទិញដែលមិនអាចដកមកវិញបាន បន្ទាប់ពីការដកតម្លៃអប្បហារពាណិជ្ជកម្ម និងការបង្វិលប្រាក់មកវិញ និង
- ថ្លៃដើមណាមួយដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹងការនាំយកទ្រព្យសម្បត្តិទៅកាន់ទីតាំង និងលក្ខខណ្ឌដែលសមស្របក្នុងការធ្វើប្រតិបត្តិការអាជីវកម្មតាមការកំណត់របស់អ្នកគ្រប់គ្រង។

# ធនាគារ អេស៊ីលីដា ភីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)

## នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និង សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់

## ២. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត (ត)

### (ឋ) ទ្រព្យសម្បត្តិ និងបរិក្ខារ (ត)

ចំណាយបន្តបន្ទាប់ផ្សេងៗត្រូវបានកត់ត្រាបញ្ចូលទៅក្នុងតម្លៃយោងនៃទ្រព្យនោះ ឬត្រូវបានកត់ត្រាជាទ្រព្យដាច់ដោយឡែក តាមការសមស្រប តែនៅពេលដែលមានភាពប្រាកដប្រជាថា ផលប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគត នៃទ្រព្យនោះនឹងហូរចូលមកក្នុងសម្ព័ន្ធធនាគារ និងធនាគារ ហើយថ្លៃដើមនៃទ្រព្យនោះអាចត្រូវបានវាស់វែងគួរឱ្យជឿជាក់បានតែប៉ុណ្ណោះ។ តម្លៃយោងផ្នែកនៃទ្រព្យដែលបានជំនួសត្រូវបានឈប់ទទួលស្គាល់។ រាល់ចំណាយលើការជួសជុល និងការថែទាំផ្សេងៗទៀតទាំងអស់ ត្រូវបានកត់ត្រាជាបន្ទុកនៅក្នុងរបាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ ក្នុងការិយបរិច្ឆេទដែលប្រតិបត្តិការនោះកើតឡើង។

ថ្លៃដើមក្នុងការសាងសង់ទ្រព្យសម្បត្តិដោយខ្លួនឯងណាមួយ រួមបញ្ចូលទាំងចំណាយលើវត្ថុធាតុដើម និងកម្លាំងពលកម្មផ្ទាល់ រួមទាំងចំណាយណាមួយដែលចូលរួមដោយផ្ទាល់ក្នុងការនាំយកទ្រព្យសម្បត្តិទៅកាន់លក្ខខណ្ឌការងារសម្រាប់គោលបំណងនៃការប្រើប្រាស់ដែលបានគ្រោងទុក រួមទាំងថ្លៃដើមនៃការរុះរើ និងការដកហូតធាតុនៃទ្រព្យសម្បត្តិ និងការរៀបចំទីតាំងដែលទ្រព្យសម្បត្តិនោះស្ថិតនៅ ហើយនិងចំណាយការប្រាក់ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។

ដីធ្លីមិនត្រូវបានធ្វើរំលស់ទេ។ ទ្រព្យសម្បត្តិ និងបរិក្ខារផ្សេងទៀតត្រូវបានធ្វើរំលស់តាមមូលដ្ឋានរំលស់ថេរដើម្បីលុបចេញពីបញ្ជីនូវថ្លៃដើមនៃទ្រព្យសកម្មទាំងនេះ ត្រឹមតម្លៃសំណល់លើអាយុកាលប្រើប្រាស់ប៉ាន់ស្មាននៃទ្រព្យសកម្មនីមួយៗ ដូចខាងក្រោម៖

| | ឆ្នាំ |
|---|---|
| ការកែលម្អដី | ៣ ដល់ ២០ |
| អគារ និង ការកែលម្អ | ៣ ដល់ ២០ |
| ការកែលម្អលើទ្រព្យជួល* | ៣ ដល់ ៥ |
| បរិក្ខារការិយាល័យ | ៣ ដល់ ១៥ |
| បរិក្ខារកុំព្យូទ័រ | ៣ ដល់ ៧ |
| យានយន្ត | ៣ ដល់ ៨ |

**ការកែលម្អលើទ្រព្យជួល គឺត្រូវបានរំលស់ដោយផ្អែកលើអាយុកាលប្រើប្រាស់នៃការកែលម្អចាប់ពី៣ឆ្នាំ ដល់៥ឆ្នាំ ឬរយៈពេលខ្លីជាងនេះនៃភតិសន្យាដែលពាក់ព័ន្ធ។*

តម្លៃសំណល់របស់ទ្រព្យសកម្ម និងអាយុកាលប្រើប្រាស់ត្រូវបានត្រួតពិនិត្យ និងកែតម្រូវប្រសិនជាមានភាពសមស្រប នៅរៀងរាល់ចុងការិយបរិច្ឆេទនៃរបាយការណ៍នីមួយៗ។

រំលស់លើទ្រព្យសកម្មដែលកំពុងសាងសង់ចាប់ផ្តើមនៅពេលដែលទ្រព្យសកម្ម ត្រូវបានត្រៀមរួចរាល់ សម្រាប់ការប្រើប្រាស់ដែលបានគ្រោងទុក។

ទ្រព្យសម្បត្តិ និងបរិក្ខារ ត្រូវបានពិនិត្យឡើងវិញ សម្រាប់ការបង្ហាញពីឱនភាពនៃតម្លៃនៅរៀងរាល់នៅក្នុងកាលបរិច្ឆេទរាយការណ៍នីមួយៗ និងរាល់ពេលដែលព្រឹត្តិការណ៍ ឬការផ្លាស់ប្តូរកាលៈទេសៈបង្ហាញថាតម្លៃយោងអាចនឹងមិនអាចប្រមូលបានមកវិញ។ នៅពេលដែលតម្លៃយោងនៃទ្រព្យសកម្មណាមួយលើសពីតម្លៃដែលអាចប្រមូលបានមកវិញដែលប៉ាន់ស្មាន ត្រូវបានកត់ត្រាបន្ថយឱ្យនៅត្រឹមតម្លៃដែលអាចប្រមូលបានមកវិញ។

## ២. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត (ត)

### (ឋ) ទ្រព្យសម្បត្តិ និងបរិក្ខារ (ត)

ចំណេញ និងខាតពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ ត្រូវបានកំណត់ដោយធ្វើការប្រៀបធៀបចំណូលបានមកពីការលក់ និងតម្លៃយោង ហើយត្រូវបានកត់ត្រានៅក្នុងចំណេញ ឬខាតក្នុងធាតុ "ចំណូលផ្សេងៗសុទ្ធ"។

### (ឌ) ទ្រព្យសកម្មអរូបី

ទ្រព្យអរូបីរួមមានអាជ្ញាបណ្ណកម្មវិធីកុំព្យូទ័រដែលបានធ្វើលទ្ធកម្ម និងចំណាយដែលទាក់ទង។ ទ្រព្យសកម្មអរូបីត្រូវបានទទួលស្គាល់តែនៅពេលដែលការចំណាយរបស់វាអាចវាស់វែងដោយជឿទុកចិត្តបាន ហើយទំនងជាផលប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតដែលរំពឹងទុក នឹងហូរចូលក្នុងសម្ព័ន្ធធនាគារ និងធនាគារ។

ទ្រព្យសកម្មអរូបីត្រូវបានរាយការណ៍តាមថ្លៃដើមប្រវត្តិសាស្ត្រដករំលស់បង្គរ និងការខាតបង់ឱនភាពនៃតម្លៃបង្គរប្រសិនជាមាន។ ទ្រព្យសកម្មអរូបីត្រូវបានធ្វើរំលស់ដោយប្រើប្រាស់វិធីសាស្ត្រថេរលើអាយុកាលប្រើប្រាស់ប៉ាន់ស្មានរបស់ទ្រព្យសកម្ម។ អាយុកាលប្រើប្រាស់របស់កម្មវិធីកុំព្យូទ័រមានរយៈពេលប្រាំឆ្នាំ លើកលែងតែអាជ្ញាបណ្ណកម្មវិធីរបស់ប្រព័ន្ធធនាគារស្នូល ដែលមានអាយុកាលប្រើប្រាស់រយៈពេលដប់ឆ្នាំ។

ទ្រព្យសកម្មអរូបីមិនត្រូវបានទទួលស្គាល់នៅពេលលុបចោល ឬនៅពេលគ្មានការរំពឹងទុកពីផលប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតពីការប្រើប្រាស់របស់វា។ ចំណេញ ឬខាតដែលកើតចេញពីការមិនទទួលស្គាល់ទ្រព្យសកម្មអរូបីដែលវាស់វែងដោយភាពខុសគ្នារវាងផលចំណេញនៃការលុបចោលសុទ្ធ និងទឹកប្រាក់យោងរបស់ទ្រព្យសកម្មត្រូវបានទទួលស្គាល់ជាប្រាក់ចំណេញ ឬខាត នៅពេលដែលទ្រព្យសកម្មនោះត្រូវបានលុបចោល។ ចំណាយផ្សេងៗពាក់ព័ន្ធនឹងការថែរក្សាកម្មវិធីកុំព្យូទ័រ ត្រូវបានកត់ត្រាជាចំណាយនៅពេលដែលប្រតិបត្តិការនោះបានកើតឡើង។

### (ឍ) ឱនភាពនៃតម្លៃរបស់ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

ទ្រព្យសកម្មដែលមានអាយុកាលមិនអាចកំណត់បានមិនមែនជាកម្មវត្ថុក្នុងការធ្វើរំលស់ទេ និងត្រូវបានធ្វើតេស្តឡើងវិញជាប្រចាំឆ្នាំដើម្បីកំណត់ឱនភាពនៃតម្លៃ។ ទ្រព្យសកម្មជាកម្មវត្ថុក្នុងការធ្វើរំលស់ត្រូវបានត្រួតពិនិត្យឡើងវិញនៅពេលមានព្រឹត្តិការណ៍ ឬការផ្លាស់ប្តូរក្នុងកាលៈទេសៈ ដែលបង្ហាញថាតម្លៃយោងអាចនឹងមិនប្រមូលបានមកវិញ។ ការខាតបង់ឱនភាពនៃតម្លៃ ត្រូវបានទទួលស្គាល់ស្មើនឹងចំនួនដែលតម្លៃយោងរបស់ទ្រព្យសកម្មលើសពីតម្លៃដែលអាចប្រមូលបានមកវិញ។ តម្លៃដែលអាចប្រមូលបានមកវិញ គឺជាតម្លៃដែលខ្ពស់ជាងរវាងតម្លៃសមស្របដកការចំណាយដើម្បីលក់ និងតម្លៃកំពុងប្រើប្រាស់។

សម្រាប់គោលបំណងនៃការធ្វើតេស្តឱនភាពនៃតម្លៃទ្រព្យសកម្ម ត្រូវបានដាក់បញ្ចូលគ្នាជាក្រុមតូចៗបំផុតដែលមានលំហូរសាច់ប្រាក់អាចកំណត់បានដោយផ្នែក (អង្គភាពរកសាច់ប្រាក់)។ ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុក្រៅពីមូលនិធិពាណិជ្ជកម្មដែលទទួលរងនូវឱនភាពនៃតម្លៃ ត្រូវបានពិនិត្យឡើងវិញចំពោះការកត់ត្រាបញ្ច្រាសមកវិញរបស់ឱនភាពនៃតម្លៃដែលអាចកើតមាននៅក្នុងកាលបរិច្ឆេទរាយការណ៍នីមួយៗ។ ការខាតបង់ឱនភាពនៃតម្លៃត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាត និងលទ្ធផល លម្អិតផ្សេងៗ។

## ២. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត (ត)

### (ឍ) ឱនភាពនៃតម្លៃរបស់ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ(ត)

ការខាតបង់ឱនភាពត្រូវបានទទួលស្គាល់នៅក្នុងកាលបរិច្ឆេទឆ្នាំចាស់ គឺត្រូវបានវាយតម្លៃនារាល់ចុងការិយបរិច្ឆេទនៃរបាយការណ៍នីមួយៗ សម្រាប់ការចង្អុលបង្ហាញណាមួយដែលបង្ហាញថាការខាតបង់បានថយចុះ ឬមិនបានកើតមានទៀត។ ការខាតបង់ឱនភាពគឺត្រូវបានកត់ត្រាបញ្ច្រាស ប្រសិនបើមានការកែប្រែក្នុងការប៉ាន់ស្មានដែលបានប្រើប្រាស់ក្នុងការកំណត់ចំនួនទឹកប្រាក់ដែលអាចប្រមូលមកវិញបាន។ ឱនភាពនៃការខាតបង់ គឺត្រូវបានកត់ត្រាបញ្ច្រាស ចំពោះតែទំហំទឹកប្រាក់យោងរបស់ទ្រព្យសកម្មដែលមិនលើសពីចំនួនទឹកប្រាក់ ដែលត្រូវបានកំណត់រួចរាល់ចំនួនរំលស់លើទ្រព្យរូបី និងរំលស់លើទ្រព្យអរូបីសុទ្ធ ប្រសិនបើមិនមានឱនភាពនៃការខាតបង់ត្រូវបានទទួលស្គាល់។ ការកត់ត្រាបញ្ច្រាសនៃឱនភាពនៃការខាតបង់ត្រូវបានទទួលស្គាល់ជាចំណូល។

### (ណ) ទុនបម្រុង

ទុនបម្រុងរួមមាន ទុនបម្រុងទូទៅ ទុនបម្រុងតាមបទប្បញ្ញត្តិ ទុនបម្រុងការពារហានិភ័យ និងទុនបម្រុងផ្សេងៗ។

ទុនបម្រុងទូទៅ ត្រូវបានបង្កើតឡើងសម្រាប់ហានិភ័យហិរញ្ញវត្ថុទូទៅ។ ក្រុមប្រឹក្សាភិបាលអនុវត្តការសម្រេចចិត្តរបស់ខ្លួន សម្រាប់ការប្រើប្រាស់ និងថែរក្សាទុនបម្រុងទូទៅ។ ការផ្ទេរពីប្រាក់ចំណេញរក្សាទុក ទៅទុនបម្រុងទូទៅ ត្រូវមានការយល់ព្រមពីក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុននីមួយៗនៅក្នុងសម្ព័ន្ធ។

ទុនបម្រុងតាមបទប្បញ្ញត្តិ ត្រូវបានបង្កើតឡើងសម្រាប់ភាពខុសគ្នា នៃសំវិធានធនរវាងឱនភាពនៃតម្លៃដោយអនុ លោមតាម ស.រ.ហ.អ.ក (លើឥណទាន និងបុរេប្រទាន ប្រាក់បញ្ញើរបស់ធនាគារ គណនីត្រូវទទួលផ្សេងៗ ការវិនិយោគលើមូលបត្របំណុល និងកិច្ចសន្យាក្រៅតារាងតុល្យការ) និងសំវិធានធនតាមបទប្បញ្ញត្តិ (លើឥណទាន និងបុរេប្រទាន ប្រាក់បញ្ញើរបស់ធនាគារ គណនីត្រូវទទួលផ្សេងៗ និងកិច្ចសន្យាក្រៅតារាងតុល្យការ ដោយអនុលោមតាមអត្រាចំណាត់ថ្នាក់ឥណទានពី ធនាគារជាតិនៃកម្ពុជា)។ វាត្រូវបានផ្ទេររវាងប្រាក់ចំណេញរក្សាទុក និងទុនបម្រុងតាមបទប្បញ្ញត្តិ។

ទុនបម្រុងការពារហានិភ័យរួមមានចំណែកប្រសិទ្ធភាពនៃបម្រែបម្រួលបង្គរសុទ្ធ ក្នុងតម្លៃសមស្របនៃឧបករណ៍ការពារហានិភ័យ ដែលប្រើក្នុងការការពារហានិភ័យលំហូរសាច់ប្រាក់ដែលនៅមិនទាន់មានការទទួលស្គាល់ជាបន្តបន្ទាប់នៅក្នុងប្រាក់ចំណេញ ឬខាត។

ទុនបម្រុងផ្សេងៗ គឺសម្រាប់លម្អៀងពីការប្តូររូបិយប័ណ្ណនៃការវិនិយោគសុទ្ធក្នុងកិច្ចប្រតិបត្តិការបរទេស។

### (ត) ប្រាក់ចំណេញរក្សាទុក

ប្រាក់ចំណេញរក្សាទុករួមបញ្ចូលទាំងប្រាក់ចំណេញរក្សាទុកពេលបច្ចុប្បន្ន និងពីមុនទាំងអស់។

### (ថ) ពន្ធលើប្រាក់ចំណូលបច្ចុប្បន្ន និងពន្ធពន្យារ

ការចំណាយពន្ធក្នុងឆ្នាំរួមមាន ពន្ធលើប្រាក់ចំណូលបច្ចុប្បន្ន និងពន្ធពន្យារ។ ពន្ធត្រូវបានទទួលស្គាល់នៅក្នុងចំណេញ ឬខាត លើកលែងតែវិសាលភាពដែលវាទាក់ទងទៅនឹងខ្ទង់ដែលត្រូវបានទទួលស្គាល់នៅក្នុងលទ្ធផលលម្អិតផ្សេងៗ ឬដោយផ្ទាល់ក្នុងមូលធន។ ក្នុងករណីនេះ ពន្ធត្រូវបានទទួលស្គាល់នៅក្នុងលទ្ធផលលម្អិតផ្សេងៗ ឬដោយផ្ទាល់ក្នុងមូលធនរៀងគ្នា។

## ២. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត (ត)

### (ថ) ពន្ធលើប្រាក់ចំណូលបច្ចុប្បន្ន និងពន្ធពន្យារ (ត)

ចំណាយពន្ធបច្ចុប្បន្ន ត្រូវបានកំណត់យោងទៅតាមច្បាប់ពន្ធនៃយុត្តាធិការនីមួយៗ ដែលក្រុមហ៊ុននីមួយៗរបស់សម្ព័ន្ធធនាគារធ្វើប្រតិបត្តិការ និងបង្កើតប្រាក់ចំណេញដែលជាប់ពន្ធ និងរាប់បញ្ចូលពន្ធទាំងអស់ដែលផ្អែកលើប្រាក់ចំណេញជាប់ពន្ធ។

ពន្ធលើប្រាក់ចំណូលពន្យារ ត្រូវបានទទួលស្គាល់ទាំងអស់ដោយប្រើវិធីសាស្ត្របំណុលលើភាពខុសគ្នាបណ្ដោះ-អាសន្ន ដែលកើតឡើងរវាងមូលដ្ឋានពន្ធនៃទ្រព្យសកម្មនិងបំណុល និងតម្លៃយោងរបស់ពួកគេនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ទ្រព្យសកម្មពន្ធពន្យារ ត្រូវបានទទួលស្គាល់ក្នុងវិសាលភាពដែលវាទំនងថាប្រាក់ចំណេញជាប់ពន្ធនាពេលអនាគតនឹងកើតមានសម្រាប់ភាពខុសគ្នាបណ្ដោះអាសន្ន និងការខាតបង់ពន្ធដែលមិនបានប្រើ ឬឥណទានពន្ធមិនបានប្រើប្រាស់។

ទ្រព្យសកម្មពន្ធពន្យារ និងបំណុលពន្ធពន្យារ ត្រូវបានកាត់កងនៅពេលមានសិទ្ធិអនុវត្តតាមច្បាប់ ដើម្បីកាត់កងទ្រព្យសកម្មពន្ធប្រចាំឆ្នាំ និងបំណុលពន្ធប្រចាំឆ្នាំ និងនៅពេលដែលពន្ធពន្យារពាក់ព័ន្ធទៅនឹងអាជ្ញាធរសារពើពន្ធដដែល។

### (ទ) អត្ថប្រយោជន៍និយោជិត

*(i). អត្ថប្រយោជន៍និយោជិតរយៈពេលខ្លី*

សម្ព័ន្ធធនាគារ និងធនាគារទទួលស្គាល់បំណុល និងចំណាយសម្រាប់អត្ថប្រយោជន៍និយោជិតរយៈពេលខ្លី។ សម្ព័ន្ធធនាគារ និងធនាគារ ទទួលស្គាល់សំវិធានធនមួយ នៅពេលមានកាតព្វកិច្ចមានកិច្ចសន្យា ឬមានការអនុវត្តកន្លងមកដែលបានបង្កើតកាតព្វកិច្ចស្ថាបនា។

ប្រាក់ឈ្នួល ប្រាក់បៀវត្ស ប្រាក់រង្វាន់ និងអត្ថប្រយោជន៍រយៈពេលខ្លីផ្សេងៗ ត្រូវបានទទួលស្គាល់ជាចំណាយក្នុងឆ្នាំដែលសេវាកម្មពាក់ព័ន្ធ ត្រូវបានផ្តល់ជូនដោយនិយោជិតរបស់សម្ព័ន្ធធនាគារ និងធនាគារ។

*(ii). អត្ថប្រយោជន៍ក្រោយពីបំពេញការងារ*

**អត្ថប្រយោជន៍ពេលចូលនិវត្តន៍**

ធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធ លើកលែងតែស្ថាប័នមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា មីយ៉ាន់ម៉ា ផ្តល់ជូនផែនការអត្ថប្រយោជន៍ពេលចូលនិវត្តន៍ដែលមិនត្រូវបានផ្តល់ជាមូលនិធិ ដែលជាផែនការអត្ថប្រយោជន៍ដែលបានកំណត់សម្រាប់បុគ្គលិកដែលមានសិទ្ធិទទួលនៅពេលដែលពួកគាត់ដល់អាយុចូលនិវត្តន៍ដូចខាងក្រោម៖

- បុគ្គលិកដែលមានអតីតភាពការងារចំនួន ១៥ឆ្នាំ ឬលើស ហើយត្រូវចូលនិវត្តន៍នៅអាយុ ៥៨ឆ្នាំ ចំពោះអ្នកគ្មានជំនាញ និង ៦០ឆ្នាំ ចំពោះអ្នកមានជំនាញ នឹងទទួលបានអត្ថប្រយោជន៍ពេលចូលនិវត្តន៍ស្មើនឹងប្រាក់បៀវត្សចំនួន ១២ខែ នៃប្រាក់បៀវត្សរបស់ពួកគាត់ចុងក្រោយ ឬ
- បុគ្គលិកដែលមានអតីតភាពការងារចំនួន ១៥ឆ្នាំ ឬលើស ហើយត្រូវចូលនិវត្តន៍មុននៅអាយុ ៥៥ឆ្នាំ ចំពោះអ្នកគ្មានជំនាញ និង ៥៧ឆ្នាំ ចំពោះអ្នកមានជំនាញ នឹងទទួលបានអត្ថប្រយោជន៍ពេលចូលនិវត្តន៍ស្មើនឹង ប្រាក់បៀវត្សចំនួន ៦ខែ នៃប្រាក់បៀវត្សរបស់ពួកគាត់ចុងក្រោយ។

## ២. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត (ត)

### (ទ) អត្ថប្រយោជន៍និយោជិត (ត)

*(ii). អត្ថប្រយោជន៍ក្រោយពីបំពេញការងារ (ត)*

**អត្ថប្រយោជន៍ពេលចូលនិវត្តន៍ (ត)**

ចំពោះអត្ថប្រយោជន៍ពេលចូលនិវត្តន៍នេះ មិនមានរក្សាទុកក្នុងមូលនិធិដាច់ដោយឡែកទេ។

នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ បំណុលត្រូវបានកត់ត្រានៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ តាមតម្លៃបច្ចុប្បន្ននៃកាតព្វកិច្ចអត្ថប្រយោជន៍ដែលបានកំណត់ នាការិយបរិច្ឆេទនៃការរាយការណ៍ ដោយប្រើវិធីសាស្ត្រឥណទានតាមឯកតាព្យាករណ៍ ដើម្បីប៉ាន់ស្មានតម្លៃចុងក្រោយបំផុតដែលសម្ព័ន្ធធនាគារ និងធនាគារត្រូវចំណាយចំពោះអត្ថប្រយោជន៍ដែលនិយោជិតត្រូវទទួលបានជាថ្នូរនឹងការបម្រើការងាររបស់ពួកគេក្នុងពេលបច្ចុប្បន្ន និងពេលកន្លងមក។ សម្ព័ន្ធធនាគារ និងធនាគារបែងចែកអត្ថប្រយោជន៍តាមគ្រានីមួយៗ ដែលកាតព្វកិច្ចផ្តល់អត្ថប្រយោជន៍ពេលចូលនិវត្តន៍បានកើតឡើង។ កាតព្វកិច្ចនោះកើតឡើងនៅពេលដែលបុគ្គលិកបម្រើការងារ ដើម្បីទទួលបានអត្ថប្រយោជន៍ពេលចូលនិវត្តន៍ ដែលសម្ព័ន្ធធនាគារ និងធនាគារ រំពឹងថានឹងទូទាត់ក្នុងការិយបរិច្ឆេទរាយការណ៍នាពេលអនាគត។ តម្លៃបច្ចុប្បន្ននៃកាតព្វកិច្ចអត្ថប្រយោជន៍ពេលចូលនិវត្តន៍ ត្រូវបានកំណត់ដោយធ្វើការអប្បហារការទូទាត់ដែលរំពឹងទុកនាពេលអនាគត ដោយប្រើប្រាស់អត្រាការប្រាក់នៃប្រាក់បញ្ញើមានកាលកំណត់ សម្រាប់រយៈពេលវែងរបស់ធនាគារ ជាអត្រាយោងរបស់វា ដោយសារនៅពេលបច្ចុប្បន្នមិនមានមូលបត្រក្រុមហ៊ុនដែលមានគុណភាពខ្ពស់ ឬក៏មិនមានមូលបត្របំណុលរាជរដ្ឋាភិបាលនៅក្នុងទីផ្សារដែរ។

ចំណេញ និងខាតដែលគណនាដោយផ្អែកលើមូលដ្ឋានច្បាស់លាស់ កើតឡើងពីការកែតម្រូវគណនីសម្រង់ និងពីបម្រែបម្រួលនៃការសន្មត ដែលគណនាដោយផ្អែកលើមូលដ្ឋានច្បាស់លាស់ ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផលលម្អិតផ្សេងៗ និងទទួលស្គាល់ដោយផ្ទាល់នៅក្នុងប្រាក់ចំណេញរក្សាទុក ក្នុងការិយបរិច្ឆេទដែលប្រតិបត្តិការនោះកើតឡើង។ ចំណាយទាក់ទិននឹងការផ្តល់អត្ថប្រយោជន៍ទាំងនេះ ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផលលម្អិតផ្សេងៗ ដើម្បីធ្វើការបែងចែកចំណាយទាំងនោះទៅតាមរយៈពេលបម្រើការងារ ដែលមានសិទ្ធិទទួលបានអត្ថប្រយោជន៍នេះ។ តម្លៃសេវាកម្មពីអតីតកាលណាមួយ ត្រូវបានទទួលស្គាល់ភ្លាមៗនៅក្នុងរបាយការណ៍ចំណេញ ឬខាត និងលទ្ធផល លម្អិតផ្សេងៗ។

ក្នុងឆ្នាំ២០២៣ សម្ព័ន្ធធនាគារ និងធនាគារ បានធ្វើវិសោធនកម្មទៅលើគោលការណ៍ប្រតិបត្តិ ស្តីពីប្រាក់សោធននិវត្តន៍របស់និយោជិត ហើយបានសម្រេចបញ្ចប់គម្រោងអត្ថប្រយោជន៍ចូលនិវត្តន៍ ដោយសារសម្ព័ន្ធធនាគារ និងធនាគារមានកាតព្វកិច្ចផ្លូវច្បាប់ដែលរាជរដ្ឋាភិបាលកម្ពុជាតម្រូវឱ្យបង់ថ្លៃទៅលើអត្ថប្រយោជន៍ប្រាក់បំណាច់អតីតភាពការងារ និងមូលនិធិសោធននិវត្តន៍ (សូមមើលកំណត់សម្គាល់លេខ ២៥)។

## ២. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត (ត)

### (ទ) អត្ថប្រយោជន៍និយោជិត (ត)

*(iii). អត្ថប្រយោជន៍ការងាររយៈពេលវែង*

សម្ព័ន្ធធនាគារ និងធនាគារមានផែនការអត្ថប្រយោជន៍ក្រោយការងាររយៈពេលវែងផ្សេងៗ ត្រូវបានសង្ខេបដូចខាងក្រោម៖

**អត្ថប្រយោជន៍អតីតភាពការងារ**

យោងទៅតាមប្រកាសលេខ ៤៤៣ កប/ប្រ.ក.ខ.ល ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ និងសេចក្តីណែនាំលេខ ០៤២/១៩ កប/ស.ណ.ន.ខ.ល ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៩ ចេញដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (“MoLVT”) ធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធ លើកលែងតែ ធនាគារ អេស៊ីលីដា ឡាវ លីមីធីត (“ABL”) និង ស្ថាប័នមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា មីយ៉ាន់ម៉ា (“AMM”) នឹងផ្តល់ជូននិយោជិតនូវប្រាក់បំណាច់អតីតភាពការងារ ដូចខាងក្រោម៖

- ប្រាក់បំណាច់អតីតភាពការងារបច្ចុប្បន្ន៖ និយោជិតដែលបម្រើការចាប់ពី ១ខែ ដល់ ៦ខែ (មិនរាប់បញ្ចូលរយៈពេលសាកល្បងការងារ) នឹងទទួលបានប្រាក់បំណាច់អតីតភាពការងារចំនួន ៧.៥ថ្ងៃក្នុងខែមិថុនា ឬខែធ្នូនៃឆ្នាំនីមួយៗ

- ប្រាក់បំណាច់រំលឹកអតីតភាពការងារ៖ និយោជិតដែលបម្រើការក្រោមកិច្ចសន្យាការងារមានថិរវេលាមិនកំណត់ ហើយបម្រើការចាប់ពី ១ខែ ដល់ ៦ខែ ក្នុងឆ្នាំហិរញ្ញវត្ថុដែលអាចអនុវត្តបាន នឹងទទួលបានប្រាក់រំលឹកអតីតភាពការងារស្មើនឹង ៣ថ្ងៃ ហើយក្នុងករណីបម្រើការងារលើសពី ៣ខែ និយោជិតនឹងទទួលបាន ១៥ថ្ងៃ។ ប្រាក់បំណាច់អតិបរមាដែលត្រូវទូទាត់ មិនត្រូវលើសពី ៦ថ្ងៃ នៃប្រាក់ឈ្នួលមូលដ្ឋានគិតជាមធ្យមតាមឆ្នាំនីមួយៗ ដែលបានទូទាត់ ចាប់ពីឆ្នាំ២០០៨ ដល់ឆ្នាំ២០១៨ ប៉ុន្តែមិនត្រូវលើសពី ១៥៦ថ្ងៃឡើយ។ ប្រាក់បំណាច់នឹងត្រូវទូទាត់នៅក្នុងខែមិថុនា និងខែធ្នូនៃឆ្នាំនីមួយៗ។

បំណុលនេះត្រូវបានទទួលស្គាល់តាមតម្លៃបច្ចុប្បន្ន នៃកាតព្វកិច្ចអត្ថប្រយោជន៍ដែលបានកំណត់នាការិយបរិច្ឆេទរាយការណ៍ ដោយប្រើវិធីសាស្រ្តឥណទានតាមឯកតាព្យាករណ៍ ដើម្បីប៉ាន់ស្មានតម្លៃអត្ថប្រយោជន៍ចុងក្រោយរបស់សម្ព័ន្ធ-ធនាគារ និងធនាគារ ដែលនិយោជិតត្រូវទទួលបានចំពោះសេវាកម្មរបស់ពួកគេនៅក្នុងពេលបម្រើការងារចាប់ពីឆ្នាំ២០០៨ ដល់ឆ្នាំ២០១៨។ សម្ព័ន្ធធនាគារ និងធនាគារបែងចែកអត្ថប្រយោជន៍ទៅតាមថិរវេលា ដែលត្រូវទូទាត់ប្រាក់បំណាច់រំលឹក-អតីតភាពនេះ។ កាតព្វកិច្ចនេះកើតឡើង នៅពេលនិយោជិតបម្រើការងារដើម្បីទទួលបានប្រាក់បំណាច់រំលឹកអតីតភាពការងារ ដែលសម្ព័ន្ធធនាគារ និងធនាគាររំពឹងថានឹងត្រូវទូទាត់នៅការិយបរិច្ឆេទនៃការរាយការណ៍នាពេលអនាគត។

តម្លៃបច្ចុប្បន្នប្រាក់បំណាច់រំលឹកអតីតភាពការងារត្រូវបានកំណត់ដោយធ្វើអប្បហារប្រាក់ដែល ត្រូវទូទាត់នាពេលអនាគត ដោយប្រើអត្រាការប្រាក់បញ្ញើមានកាលកំណត់សម្រាប់រយៈពេល៥ឆ្នាំ។

***មូលនិធិសោធននិវត្តន៍***

មូលនិធិសោធននិវត្តន៍ គឺជាកាតព្វកិច្ចរបស់ធនាគារ និងនិយោជិត។ ការចូលរួមទាំងនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃទី១ ខែតុលា ឆ្នាំ២០២២ ហើយការចូលរួមទាំងនេះត្រូវបង់ជារៀងរាល់ខែទៅបេឡាជាតិរបបសន្តិសុខសង្គម។ សម្រាប់រយៈពេលប្រាំឆ្នាំដំបូង ការចូលរួមនៃមូលនិធិត្រូវបានកំណត់ចំនួន ៤% (ចាប់ពី ៤០០.០០០ រៀល ទៅ ១.២០០.០០០ រៀល សមមូលនឹង ៩៧ ដុល្លារអាមេរិក ទៅ ២៩១ ដុល្លារអាមេរិករៀងគ្នា) ដែលត្រូវបានបង់ចំនួន ២% ដោយធនាគារ និងចំនួន ២% ដោយនិយោជិត។ (សូមមើលកំណត់សម្គាល់លេខ ២៥)។

# ធនាគារ អេស៊ីលីដា ភីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)**

**នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និង សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់**

## ២. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត (ត)

### (ទ) អត្ថប្រយោជន៍និយោជិត (ត)

*(iii). អត្ថប្រយោជន៍ការងាររយៈពេលវែង*

*អត្ថប្រយោជន៍អភិវឌ្ឍន៍វិជ្ជាជីវៈ*

ធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួនផ្តល់អត្ថប្រយោជន៍អភិវឌ្ឍន៍វិជ្ជាជីវៈដល់និយោជិតចន្លោះពី ១.២៥០ ដុល្លារអាមេរិក រហូតដល់ ៦.២៥០ ដុល្លារអាមេរិក អាស្រ័យលើលំដាប់តួនាទីរបស់អ្នកគ្រប់គ្រង លើកលែងតែ ABL ដែលផ្តល់អត្ថប្រយោជន៍អភិវឌ្ឍន៍វិជ្ជាជីវៈដល់និយោជិតចន្លោះពី ៧.៩៤៧.០០០ គីបឡាវ (សមមូលនឹង ៤១៧ ដុល្លារអាមេរិកគត់) រហូតដល់ ២៣.៣៧២.៥០០ គីបឡាវ (សមមូលនឹង ១.២២៦ ដុល្លារអាមេរិកគត់) អាស្រ័យលើលំដាប់តួនាទីរបស់អ្នកគ្រប់គ្រង។

បុគ្គលិកមានតំណែងជាអ្នកគ្រប់គ្រង មានសិទ្ធិទទួលបានអត្ថប្រយោជន៍ដែលបានផ្តល់ឱ្យនៅពេលដែលពួកគេបានធ្វើការចាប់តាំងពីកាលបរិច្ឆេទនៃការតែងតាំង នៅក្នុងមុខតំណែងគ្រប់គ្រងបានរយៈពេលពីរឆ្នាំជាប់ៗគ្នា ហើយការវាយតម្លៃលទ្ធផលការងាររបស់ពួកគេមានកម្រិតខ្ពស់ (ឧទាហរណ៍៖ ពិន្ទុនៃការវាយតម្លៃស្មើនឹង ឬខ្ពស់ជាង ៧០០ និងគ្មានលិខិតព្រមាន)។ ពួកគេនឹងមានសិទ្ធិទទួលបានអត្ថប្រយោជន៍ដោយស្វ័យប្រវត្តិនៅថ្ងៃដំបូងនៃឆ្នាំទីបីរបស់ពួកគេ។

បំណុលត្រូវបានទទួលស្គាល់ នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នៅតម្លៃបច្ចុប្បន្ននៃកាតព្វកិច្ចអត្ថប្រយោជន៍និយោជិតនៅចុងការិយបរិច្ឆេទនៃរបាយការណ៍នីមួយៗ ដោយប្រើវិធីសាស្ត្រឥណទានតាមឯកតាព្យាករណ៍។ តម្លៃបច្ចុប្បន្ន ត្រូវបានកំណត់ដោយធ្វើការអប្បហារការទូទាត់នាពេលអនាគតដែលបានប៉ាន់ស្មាន ដោយយោងទៅលើអត្រាការប្រាក់នៃប្រាក់បញ្ញើមានកាលកំណត់សម្រាប់រយៈពេលបីឆ្នាំ ដោយសារសិទ្ធិក្នុងការទទួលបានអត្ថប្រយោជន៍មានរយៈពេលបីឆ្នាំ។

### (ធ) សំវិធានធន

សំវិធានធន ត្រូវបានទទួលស្គាល់នៅពេលដែលសម្ព័ន្ធធនាគារ និងធនាគារមានកាតព្វកិច្ចផ្លូវច្បាប់ ឬកាតព្វកិច្ចស្ថាបនានាពេលបច្ចុប្បន្ន ដែលជាលទ្ធផលនៃព្រឹត្តិការណ៍ពីអតីតកាល ហើយវាទំនងជាអាចមានការហូរចេញនៃធនធានដើម្បីទូទាត់កាតព្វកិច្ចនោះ ហើយទឹកប្រាក់នៃកាតព្វកិច្ចអាចត្រូវបានប៉ាន់ស្មានដោយភាពជឿជាក់។

នៅពេលដែលមានកាតព្វកិច្ចស្រដៀងគ្នាច្រើន ភាពដែលកើតមានឡើងនៃលំហូរចេញដើម្បីទូទាត់កាតព្វកិច្ចនោះ ត្រូវបានកំណត់ដោយធ្វើការពិចារណាទៅលើថ្នាក់នៃកាតព្វកិច្ចទាំងមូល។ សំវិធានធនត្រូវបានទទួលស្គាល់ទោះបីជាលទ្ធភាពនៃលំហូរចេញទាក់ទងនឹងធាតុណាមួយដែលបានរួមបញ្ចូលនៅក្នុងថ្នាក់ដូចគ្នានៃកាតព្វកិច្ច អាចមានតិចតួចក៏ដោយ។

សំវិធានធន ត្រូវបានវាស់វែងតាមតម្លៃបច្ចុប្បន្ននៃចំណាយដែលរំពឹងថានឹងត្រូវធ្វើការទូទាត់កាតព្វកិច្ចនោះ ដោយប្រើប្រាស់អត្រាមុនគិតពន្ធ ដើម្បីឆ្លុះបញ្ចាំងពីការវាយតម្លៃតាមទីផ្សារបច្ចុប្បន្ននៃពេលវេលានៃការប្រើប្រាស់សាច់ប្រាក់ និងហានិភ័យជាក់លាក់ចំពោះកាតព្វកិច្ចនោះ។ ការកើនឡើងនៃសំវិធានធនដោយសារការកន្លងផុតទៅនៃពេលវេលា ត្រូវបានទទួលស្គាល់ជាចំណាយការប្រាក់។

## ២. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត (ត)

### (ន) ការប្រាក់

*អត្រាការប្រាក់ប្រសិទ្ធភាព*

ចំណូល និងចំណាយការប្រាក់ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាត ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។ "អត្រាការប្រាក់ប្រសិទ្ធភាព" គឺជាអត្រាដែលអប្បហារការទទួល ឬទូទាត់សាច់ប្រាក់ នាពេលអនាគតដែលរំពឹងទុក ក្នុងអាយុកាលដែលរំពឹងទុករបស់ឧបករណ៍ហិរញ្ញវត្ថុមកស្មើនឹងៈ

- តម្លៃយោងដុលរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬ
- ថ្លៃដើមបានរំលស់របស់បំណុលហិរញ្ញវត្ថុ។

នៅពេលគណនាអត្រាការប្រាក់ប្រសិទ្ធភាពសម្រាប់ឧបករណ៍ហិរញ្ញវត្ថុ ក្រៅពីទ្រព្យសកម្មដែលមានឱនភាពនៃតម្លៃឥណទាននៅពេលធ្វើលទ្ធកម្ម ឬបង្កើត សម្ព័ន្ធធនាគារ និងធនាគារ ធ្វើការប៉ាន់ស្មានលំហូរសាច់ប្រាក់នាពេលអនាគតដោយពិចារណារាល់លក្ខខណ្ឌតាមកិច្ចសន្យាទាំងអស់របស់ឧបករណ៍ហិរញ្ញវត្ថុ ប៉ុន្តែមិនរាប់បញ្ចូលនូវការខាតបង់ដែលរំពឹងទុក ECL នោះទេ។ សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពនៃតម្លៃឥណទាននៅពេលធ្វើលទ្ធកម្ម ឬបង្កើត អត្រាការប្រាក់ប្រសិទ្ធភាពដែលបានកែតម្រូវហានិភ័យឥណទាន ត្រូវបានគណនាដោយប្រើលំហូរសាច់ប្រាក់នាពេលអនាគតដែលប៉ាន់ស្មាន រួមបញ្ចូលទាំងការខាតបង់ឥណទានដែលរំពឹងទុក។

ការគណនាអត្រាការប្រាក់ប្រសិទ្ធភាព រួមបញ្ចូលនូវចំណាយប្រតិបត្តិការ និងកម្រៃដែលបានបង់ ឬទទួល ដែលជាផ្នែកនៃអត្រាការប្រាក់ប្រសិទ្ធភាព។ ចំណាយប្រតិបត្តិការរួមមាន ថ្លៃដើមបន្ថែមដែលចូលរួមដោយផ្ទាល់ទៅនឹងការធ្វើលទ្ធកម្ម ឬការបោះផ្សាយទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ។

***ថ្លៃដើមបានរំលស់ និងតម្លៃយោងដុល***

'ថ្លៃដើមបានរំលស់' របស់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ គឺជាចំនួនដែលទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ ត្រូវបានវាស់វែងនៅពេលទទួលស្គាល់លើកដំបូង ដកការសងមកវិញនូវប្រាក់ដើម បូក ឬដករំលស់បង្គរ ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាពនៃភាពខុសគ្នារវាងចំនួនដែលទទួលស្គាល់លើកដំបូង និងចំនួននៅឥណប្រតិទាន និងត្រូវធ្វើនិយ័តកម្មចំពោះការខាតបង់ឥណទានដែលរំពឹងទុក (ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុ)។

'តម្លៃយោងដុល' របស់ទ្រព្យសកម្មហិរញ្ញវត្ថុ គឺជាថ្លៃដើមបានរំលស់របស់ទ្រព្យសកម្មហិរញ្ញវត្ថុ មុនពេលធ្វើនិយ័តកម្មសំវិធានធនលើការខាតបង់ឥណទានដែលរំពឹងទុក។

## ២. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត (ត)

### (ន) ការប្រាក់ (ត)

*ការគណនាចំណូលការប្រាក់ និងចំណាយការប្រាក់*

អត្រាការប្រាក់ប្រសិទ្ធភាពរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ ត្រូវបានគណនាលើការទទួលស្គាល់ដំបូងនៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ។ ក្នុងការគណនាចំណូលការប្រាក់ និងចំណាយការប្រាក់ អត្រាការប្រាក់ប្រសិទ្ធភាពត្រូវបានអនុវត្តលើតម្លៃយោងដុលរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ (នៅពេលដែលទ្រព្យសកម្មមិនត្រូវបានចាត់ទុកថាមានឱនភាពនៃតម្លៃឥណទាន) ឬថ្លៃដើមបានរំលស់របស់បំណុលហិរញ្ញវត្ថុ។ អត្រាការប្រាក់ប្រសិទ្ធភាពត្រូវបានធ្វើការកែប្រែឡើងវិញ ដែលជាលទ្ធផលនៃការប៉ាន់ស្មានឡើងវិញតាមពេលកំណត់របស់លំហូរសាច់ប្រាក់នៃឧបករណ៍ ដែលមានអត្រាការប្រាក់អថេរ ដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរអត្រាការប្រាក់ទីផ្សារ។ អត្រាការប្រាក់ប្រសិទ្ធភាព ក៏ត្រូវធ្វើការកែប្រែឡើងវិញ សម្រាប់ការធ្វើនិយ័តកម្មតម្លៃសមស្របនៃការទប់ស្កាត់ហានិភ័យ នៅកាលបរិច្ឆេទធ្វើរំលស់នៃការធ្វើនិយ័តកម្មការទប់ស្កាត់ហានិភ័យ ត្រូវចាប់ផ្តើម។

ទោះបីជាយ៉ាងណាក៏ដោយ ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពនៃតម្លៃឥណទានបន្ទាប់ពីបានទទួលស្គាល់លើកដំបូង ចំណូលការប្រាក់ ត្រូវបានគណនាដោយប្រើអត្រាការប្រាក់ប្រសិទ្ធភាពលើថ្លៃដើមបានរំលស់របស់ទ្រព្យសកម្មហិរញ្ញវត្ថុ។ ប្រសិនបើទ្រព្យសកម្មហិរញ្ញវត្ថុលែងមានឱនភាពនៃតម្លៃឥណទាន នោះការគណនាចំណូលការប្រាក់ត្រូវប្តូរមកលើមូលដ្ឋានតម្លៃដុលវិញ។

ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពនៃតម្លៃឥណទាន នៅពេលទទួលស្គាល់លើកដំបូងចំណូលការប្រាក់ ត្រូវបានគណនាដោយប្រើអត្រាការប្រាក់ប្រសិទ្ធភាពដែលបានកែតម្រូវឥណទានលើថ្លៃដើមបានរំលស់របស់ទ្រព្យសកម្មហិរញ្ញវត្ថុ។ ការគណនាចំណូលការប្រាក់នេះ មិនត្រូវប្តូរទៅមូលដ្ឋានតម្លៃដុលវិញទេ ទោះបីជាហានិភ័យឥណទានរបស់ទ្រព្យសកម្មនោះ មានភាពប្រសើរក៏ដោយ។

*ការបង្ហាញ*

ចំណូលការប្រាក់ ត្រូវបានគណនាដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព ដែលបានបង្ហាញនៅក្នុងរបាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ អាចរួមមាន៖

- ការប្រាក់លើទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុវាស់វែងតាមថ្លៃដើមបានរំលស់
- ការប្រាក់លើឧបករណ៍បំណុលវាស់វែងតាម FVOCI
- ចំណែកដែលមានប្រសិទ្ធភាពនៃការផ្លាស់ប្តូរតម្លៃសមស្របក្នុងនិស្សន្ទការទប់ស្កាត់ហានិភ័យ ដែលមានគុណវុឌ្ឍិ ដែលបានកំណត់ជាការទប់ស្កាត់ហានិភ័យលំហូរសាច់ប្រាក់នៃភាពប្រែប្រួលរបស់លំហូរសាច់ប្រាក់ការប្រាក់ ក្នុងអំឡុងពេលដូចគ្នា ខណៈដែលលំហូរសាច់ប្រាក់បានទប់ស្កាត់ហានិភ័យមានឥទ្ធិពលដល់ចំណូល ឬចំណាយការប្រាក់ និង
- ចំណែកដែលមានប្រសិទ្ធភាពនៃការផ្លាស់ប្តូរតម្លៃសមស្របក្នុងនិស្សន្ទការទប់ស្កាត់ហានិភ័យដែលមានគុណវុឌ្ឍិ ដែលបានកំណត់ជាតម្លៃសមស្របនៃការទប់ស្កាត់ហានិភ័យនៃតម្លៃហានិភ័យអត្រាការប្រាក់។

# ធនាគារ អេស៊ីលីដា ភីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)**

**នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និង សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់**

## ២. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត (ត)

### (ន) ការប្រាក់ (ត)

*ការបង្ហាញ (ត)*

ចំណាយការប្រាក់ដែលបានបង្ហាញនៅក្នុងរបាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗអាចរួមមាន៖ (ត)

- បំណុលហិរញ្ញវត្ថុដែលវាស់វែងតាមថ្លៃដើមបានរំលស់ និង
- ចំណែកដែលមានប្រសិទ្ធភាពនៃការផ្លាស់ប្តូរតម្លៃសមស្របក្នុងនិស្សន្ទការទប់ស្កាត់ហានិភ័យ ដែលមានគុណវុឌ្ឍិ ដែលបានកំណត់ជាការទប់ស្កាត់ហានិភ័យលំហូរសាច់ប្រាក់នៃភាពប្រែប្រួលរបស់លំហូរសាច់-ប្រាក់ការប្រាក់ក្នុងអំឡុងពេលដូចគ្នា ខណៈដែលលំហូរសាច់ប្រាក់បានទប់ស្កាត់ហានិភ័យមានឥទ្ធិពលដល់ចំណូល ឬចំណាយការប្រាក់។

ចំណូល និងចំណាយការប្រាក់លើទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុណាមួយ តាម FVTPL ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ។

### (ប) កម្រៃ និងជើងសា

ចំណូល និងចំណាយកម្រៃ និងជើងសា ដែលជាផ្នែកនៃការគណនាអត្រាការប្រាក់ប្រសិទ្ធភាពរបស់ទ្រព្យ-សកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ។

ចំណូលកម្រៃ និងជើងសាផ្សេងៗ រួមមានកម្រៃសេវាកម្មគណនី កម្រៃគ្រប់គ្រងការវិនិយោគ ជើងសាលើការលក់ កម្រៃបញ្ញើ និងកម្រៃការប្រមូលផ្តុំ ត្រូវបានទទួលស្គាល់ជាសេវាកម្មពាក់ព័ន្ធត្រូវបានបម្រើ។

ប្រសិនបើ កិច្ចសន្យាផ្តល់ឥណទានមិនត្រូវបានរំពឹងថានឹងមានការដកប្រើប្រាស់ជាឥណទាន នោះកម្រៃកិច្ចសន្យាផ្តល់ឥណទានដែលទាក់ទង ត្រូវបានទទួលស្គាល់ដោយឈរលើមូលដ្ឋានថេរ ក្នុងរយៈពេលនៃកិច្ចសន្យា។

កិច្ចសន្យាជាមួយអតិថិជនដែលបង្កើតឱ្យមានការទទួលស្គាល់ជាឧបករណ៍ហិរញ្ញវត្ថុ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ អាចជាផ្នែកនៅក្នុងវិសាលភាពនៃ ស.រ.ហ.អ.ក ៩ ឧបករណ៍ហិរញ្ញវត្ថុ និងជាផ្នែកនៅក្នុងវិសាលភាពនៃ ស.រ.ហ.អ.ក ១៥ *ចំណូលដែលបានពីកិច្ចសន្យាជាមួយអតិថិជន*។ ក្នុងករណីនេះ សម្ព័ន្ធធនាគារ និងធនាគារត្រូវអនុវត្តជាដំបូងនូវ ស.រ.ហ.អ.ក ៩ ដើម្បីបែងចែក និងវាស់វែងផ្នែកនៃកិច្ចសន្យា ដែលស្ថិតក្នុងវិសាលភាពនៃ ស.រ.ហ.អ.ក ៩ ហើយបន្ទាប់មកអនុវត្ត ស.រ.ហ.អ.ក ១៥ ចំពោះផ្នែកដែលនៅសេសសល់។

### (ផ) ការទទួលស្គាល់កម្រៃសេវា និងចំណូលផ្សេងៗ

*(i) ភាគលាភ*

ចំណូលពីភាគលាភណាមួយ ត្រូវបានទទួលស្គាល់នៅពេលសិទ្ធិទទួលបានការទូទាត់ត្រូវបានបង្កើតឡើង។ ជាធម្មតានេះ គឺជាកាលបរិច្ឆេទនៃការបែងចែកភាគលាភ (អិចឌីវីដឹន) សម្រាប់មូលបត្រមូលធនសម្រង់។

ភាគលាភលើឧបករណ៍មូលធនកំណត់តាម FVOCI ដែលបង្ហាញយ៉ាងច្បាស់ពីការប្រមូលបានមកវិញរបស់ផ្នែកនៃថ្លៃដើមរបស់ការវិនិយោគត្រូវបង្ហាញនៅក្នុងលទ្ធផលលម្អិតផ្សេងៗ។

## ២. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត (ត)

### (ផ) ការទទួលស្គាល់កម្រៃសេវា និងចំណូលផ្សេងៗ (ត)

*(ii) សេវាកម្មបណ្តុះបណ្តាល និងប្រឹក្សាយោបល់*

សម្ព័ន្ធធនាគារ និងធនាគារទទួលស្គាល់ចំណូលពីសេវាកម្ម នៅពេលដែលវាទំនងថាអត្ថប្រយោជន៍សេដ្ឋកិច្ចនឹងហូរចូលសម្ព័ន្ធធនាគារ និងធនាគារ ហើយចំនួនទឹកប្រាក់នៃចំណូលអាចវាស់វែងដោយជឿជាក់។ ចំណូលពីសេវាកម្មបណ្តុះបណ្តាល និងសេវាកម្មប្រឹក្សាយោបល់ ត្រូវបានទទួលស្គាល់នៅពេលដែលសេវាកម្មត្រូវបានផ្តល់។

### (ព) ភតិសន្យា

នៅដំណាក់កាលដំបូងនៃកិច្ចសន្យា សម្ព័ន្ធធនាគារ និងធនាគារធ្វើការវាយតម្លៃថាតើកិច្ចសន្យាមួយមាន ឬជាភតិសន្យាដែរឬទេ។ កិច្ចសន្យាជា ឬមានភតិសន្យា ប្រសិនបើកិច្ចសន្យាផ្តល់សិទ្ធិអភិបាលធ្វើការប្រើប្រាស់ទ្រព្យសកម្មជាក់លាក់មួយក្នុងរយៈពេលកំណត់មួយ ជាថ្នូរនឹងតម្លៃតបស្នង។

*ក្នុងនាមជាភតិកៈ*

នាពេលចាប់ផ្តើម ឬការកែប្រែនៃកិច្ចសន្យាដែលមានសមាសធាតុភតិសន្យា សម្ព័ន្ធធនាគារ និងធនាគារបែងចែកតម្លៃតបស្នងនៅក្នុងកិច្ចសន្យាទៅតាមសមាសធាតុភតិសន្យានីមួយៗ ដោយផ្អែកលើមូលដ្ឋានតម្លៃតែម្នាក់ឯង។

សម្ព័ន្ធធនាគារ និងធនាគារទទួលស្គាល់សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម និងបំណុលភតិសន្យានៅកាលបរិច្ឆេទចាប់ផ្តើមភតិសន្យា។ សិទ្ធិប្រើប្រាស់ទ្រព្យសកម្មត្រូវបានវាស់វែងតាមថ្លៃដើមដំបូង ដែលរួមមានតម្លៃដំបូងនៃបំណុលភតិសន្យាដែលត្រូវបានកែតម្រូវសម្រាប់ការទូទាត់ភតិសន្យាដែលបានធ្វើឡើងនៅ ឬមុនកាលបរិច្ឆេទចាប់ផ្តើម បូកនឹងចំណាយដោយផ្ទាល់ដំបូងដែលបានកើតឡើង និងការប៉ាន់ស្មាននៃចំណាយដើម្បីរុះរើ និងផ្លាស់ចេញទ្រព្យសកម្មជាមូលដ្ឋាន ឬដើម្បីស្តារឡើងវិញនូវទ្រព្យសកម្មជាមូលដ្ឋាន ឬទីតាំងដែលវាស្ថិតនៅ ឬស្តារឡើងវិញនូវទ្រព្យសកម្មជាមូលដ្ឋានទៅតាមលក្ខខណ្ឌតម្រូវក្នុងលក្ខខណ្ឌនៃភតិសន្យា លើកលែងតែចំណាយដែលកើតឡើងក្នុងការផលិតសន្និធិដកចេញការលើកទឹកចិត្តភតិសន្យាដែលបានទទួល។

សិទ្ធិប្រើប្រាស់ទ្រព្យសកម្មត្រូវបានរំលស់ជាបន្តបន្ទាប់តាមវិធីសាស្ត្រថេរ ចាប់ពីកាលបរិច្ឆេទចាប់ផ្តើមរហូតដល់ចុងបញ្ចប់នៃអាយុកាលភតិសន្យា លើកលែងតែភតិសន្យាផ្ទេរការកាន់កាប់ទ្រព្យសកម្មជាមូលដ្ឋានទៅឱ្យសម្ព័ន្ធធនាគារ និងធនាគារនៅចុងការិយបរិច្ឆេទនៃរយៈពេលភតិសន្យា ឬថ្លៃដើមនៃសិទ្ធិប្រើប្រាស់ទ្រព្យសកម្ម ឆ្លុះបញ្ចាំងថាសម្ព័ន្ធធនាគារ និងធនាគារនឹងអនុវត្តជម្រើសធ្វើលទ្ធកម្ម។ ក្នុងករណីដែលសិទ្ធិប្រើប្រាស់ទ្រព្យសកម្មនឹងត្រូវបានធ្វើរំលស់ក្នុងអាយុប្រើប្រាស់នៃទ្រព្យសកម្មជាមូលដ្ឋាន ដែលត្រូវបានកំណត់ដោយផ្អែកលើមូលដ្ឋានដូចគ្នាទៅនឹងទ្រព្យនិង បរិក្ខារ។ បន្ថែមលើនេះ សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម ត្រូវបានកាត់បន្ថយជាប្រចាំទៅតាមការខាតបង់ឱនភាពនៃតម្លៃ និងកែតម្រូវសម្រាប់ការវាស់វែងឡើងវិញនៃបំណុលភតិសន្យា។

## ២. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត (ត)

### (៣) ភតិសន្យា (ត)

*ក្នុងនាមជាភតិកៈ (ត)*

បំណុលភតិសន្យា ត្រូវបានវាស់វែងលើកដំបូងតាមតម្លៃបច្ចុប្បន្ននៃការទូទាត់ភតិសន្យាដែលមិនទាន់បានបង់នៅកាលបរិច្ឆេទចាប់ផ្តើម ធ្វើអប្បហារដោយប្រើអត្រាការប្រាក់ដែលបង្កប់នៅក្នុងភតិសន្យា ឬករណីដែលអត្រានោះមិនអាចកំណត់នោះសម្ព័ន្ធធនាគារ និងធនាគារប្រើប្រាស់អត្រាការប្រាក់កម្ចីបន្ថែមរបស់ខ្លួន។ ជាការអនុវត្ត សម្ព័ន្ធធនាគារ និងធនាគារប្រើប្រាស់អត្រាការប្រាក់កម្ចីបន្ថែម ជាអត្រាអប្បហារ ដើម្បីវាស់វែងសិទ្ធិប្រើប្រាស់ទ្រព្យសកម្ម និង បំណុលភតិសន្យា។

ការទូទាត់ភតិសន្យាដែលបានរួមបញ្ចូលក្នុងការវាស់វែងនៃបំណុលភតិសន្យា មានដូចខាងក្រោម៖

- ការទូទាត់ថេរ រួមទាំងសមាសធាតុនៃការទូទាត់ថេរ ដកចេញនូវរាល់អត្ថប្រយោជន៍នៃភតិសន្យា
- ការទូទាត់ភតិសន្យាអថេរដែលអាស្រ័យលើសន្ទស្សន៍ ឬអត្រាមួយ ដែលវាស់វែងលើកដំបូងដោយប្រើសន្ទស្សន៍ ឬអត្រានៅកាលបរិច្ឆេទចាប់ផ្តើម
- តម្លៃដែលរំពឹងថានឹងត្រូវបង់នៅក្រោមតម្លៃសំណល់មានការធានា និង
- ថ្លៃអនុវត្តដែលស្ថិតក្រោមជម្រើសនៃការធ្វើលទ្ធកម្មដែលសម្ព័ន្ធធនាគារ និងធនាគារមានភាពប្រាកដប្រជាក្នុងការអនុវត្ត ការទូទាត់ភតិសន្យានៅក្នុងរយៈពេលមានជម្រើសនៃការបន្តជាថ្មីប្រសិនបើសម្ព័ន្ធធនាគារ និងធនាគារ មានភាពប្រាកដប្រជាក្នុងការអនុវត្តជម្រើសពន្យារ និងការពិន័យ សម្រាប់ការបញ្ចប់ភតិសន្យាមុនពេលកំណត់ លើកលែងតែសម្ព័ន្ធធនាគារ និងធនាគារមានភាពប្រាកដប្រជា មិនបញ្ចប់មុនពេលកំណត់។

បំណុលភតិសន្យា ត្រូវបានវាស់វែងតាមថ្លៃដើមបានរំលស់ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។ បំណុលភតិសន្យា ត្រូវបានវាស់វែងឡើងវិញ នៅពេលមានការកែប្រែការទូទាត់ភតិសន្យានាពេលអនាគត ដែលកើតឡើងពីការផ្លាស់ប្តូរនៃសន្ទស្សន៍ ឬអត្រាណាមួយ ប្រសិនបើមានការកែប្រែតម្លៃប៉ាន់ស្មានដែលសម្ព័ន្ធធនាគារ និងធនាគាររំពឹងថានឹងត្រូវទូទាត់ក្រោមតម្លៃសំណល់មានការធានា ប្រសិនបើសម្ព័ន្ធធនាគារ និងធនាគារ ផ្លាស់ប្តូរការវាយតម្លៃថា តើត្រូវអនុវត្តជម្រើសការធ្វើលទ្ធកម្ម ពន្យារ ឬបញ្ចប់ដែរឬទេ ឬប្រសិនបើមានការទូទាត់ថេរជាស្ថានភាពពិតដែលកែប្រែ ឬភតិសន្យាត្រូវបានកែប្រែ ហើយការកែប្រែលើភតិសន្យា មិនត្រូវបានកត់ត្រាជាភតិសន្យាដាច់ដោយឡែកឡើយ។ នៅពេលដែលបំណុលភតិសន្យា ត្រូវបានវាស់វែងឡើងវិញតាមវិធីសាស្ត្រនេះ ការកែតម្រូវត្រូវបានធ្វើឡើងលើតម្លៃយោងនៃសិទ្ធិប្រើប្រាស់ទ្រព្យសកម្ម ឬក៏ទទួលស្គាល់ក្នុងចំណេញ ឬខាត បើសិនជាសិទ្ធិប្រើប្រាស់ទ្រព្យសកម្ម ត្រូវបានបញ្ចុះរហូតដល់មានតម្លៃសូន្យ។

# ធនាគារ អេស៊ីលីដា ភីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)**

**នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និង សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់**

## ២. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត (ត)

### (ឍ) ភតិសន្យា (ត)

*ភតិសន្យារយៈពេលខ្លី និងភតិសន្យានៃទ្រព្យសកម្មដែលមានតម្លៃទាប*

ភតិសន្យារយៈពេលខ្លីគឺជាភតិសន្យានាកាលបរិច្ឆេទចាប់ផ្តើម ដែលមានរយៈពេល ១២ខែ ឬតិចជាងនេះ។ ភតិសន្យាដែលរួមមានជម្រើសក្នុងការទិញគឺមិនមែនជាភតិសន្យារយៈពេលខ្លីនោះទេ។

មូលដ្ឋាននៃការជួលទ្រព្យសម្បត្តិ ដែលមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាភតិសន្យានៃទ្រព្យសកម្មដែលមានតម្លៃទាប ប្រសិនបើលក្ខណៈនៃទ្រព្យសម្បត្តិដែលមានសភាពថ្មី ហើយជាទូទៅមិនមានតម្លៃទាប។ ឧទាហរណ៍ ការជួលឡានដែលមិនសមស្របជាភតិសន្យានៃទ្រព្យសកម្មដែលមានតម្លៃទាបឡើយ ព្រោះឡានថ្មីមិនមានតម្លៃទាបឡើយ។

សម្ព័ន្ធធនាគារ និងធនាគារបានជ្រើសរើសមិនទទួលស្គាល់សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម និងបំណុលភតិសន្យាត្រឹមត្រូវ សម្រាប់ភតិសន្យានៃទ្រព្យសកម្មដែលមានតម្លៃទាប និងភតិសន្យារយៈពេលខ្លី។ សម្ព័ន្ធធនាគារ និងធនាគារទទួលស្គាល់ការទូទាត់ភតិសន្យាដែលទាក់ទងនឹងភតិសន្យាទាំងនេះ ជាការចំណាយតាមមូលដ្ឋានថេរក្នុងរយៈពេលនៃភតិសន្យា។

### (ណ) ទ្រព្យសកម្មយថាហេតុ និងបំណុលយថាហេតុ

ទ្រព្យសកម្មយថាហេតុ គឺជាការកើតឡើងដោយមិនបានគ្រោងទុក ឬការរំពឹងទុកផ្សេងៗដែលបណ្តាលមកពីភាពដែលអាចទៅរួចនៃលំហូរចូលនូវអត្ថប្រយោជន៍សេដ្ឋកិច្ចទៅលើសម្ព័ន្ធធនាគារ និងធនាគារ។ ជាលទ្ធផល វាត្រូវបានគេចាត់ទុកថាជាចំណូលដែលមិនអាចទទួលស្គាល់ ទ្រព្យសកម្មយថាហេតុ មិនត្រូវបានកត់ត្រាក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ។ ទ្រព្យសកម្មយថាហេតុ គួរតែត្រូវបានបង្ហាញនៅពេលដែលទំនងជាមានលំហូរចូលនៃអត្ថប្រយោជន៍សេដ្ឋកិច្ច។

បំណុលយថាហេតុ ត្រូវបានរាប់បញ្ចូលទាំងការធានា និងលិខិតឥណទានដែលត្រូវបានដាក់តម្កល់ជាទ្រព្យបញ្ចាំ គឺកាតព្វកិច្ចដែលអាចកើតមានបណ្តាលពីព្រឹត្តិការណ៍អតីតកាលទាំងឡាយ ដែលអត្ថិភាពរបស់វានឹងត្រូវបានបញ្ជាក់ដោយការកើតឡើង ឬមិនកើតឡើងនៃព្រឹត្តិការណ៍នាពេលអនាគតមិនប្រាកដប្រជាមួយ ឬច្រើន ដែលមិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់សម្ព័ន្ធធនាគារ និងធនាគារ ឬជាកាតព្វកិច្ចបច្ចុប្បន្ន ដែលកើតឡើងពីព្រឹត្តិការណ៍អតីតកាលដែលមិនបានទទួលស្គាល់ ពីព្រោះវាអាចជាលំហូរចេញនៃអត្ថប្រយោជន៍សេដ្ឋកិច្ច ឬព្រោះតែមិនអាចវាស់វែងទៅលើចំនួននៃកាតព្វកិច្ចឱ្យបានច្បាស់លាស់។

បំណុលយថាហេតុ មិនត្រូវបានកត់ត្រាក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ ប៉ុន្តែត្រូវបានដាក់បង្ហាញ លើកលែងតែប្រូបាប៊ីលីតេនៃការកាត់កង គឺស្ទើរតែគ្មាន។

## ២. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត (ត)

### (ម) ព្រឹត្តិការណ៍បន្ទាប់ពីការិយបរិច្ឆេទនៃរបាយការណ៍

សម្ព័ន្ធធនាគារ និងធនាគារកំណត់យកព្រឹត្តិការណ៍ ថាព្រឹត្តិការណ៍ទាំងនោះជាព្រឹត្តិការណ៍អំណោយផល និងមិនអំណោយផល ដែលកើតឡើងក្នុងរវាងចុងការិយបរិច្ឆេទនៃរបាយការណ៍ និងនាកាលបរិច្ឆេទដែលរបាយការណ៍ហិរញ្ញវត្ថុបានអនុម័តឱ្យចេញផ្សាយ។ របាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ គឺត្រូវធ្វើនិយ័តកម្មដើម្បីឆ្លុះបញ្ចាំងពីព្រឹត្តិការណ៍ទាំងនោះ ដែលផ្តល់នូវភស្តុតាងនៃស្ថានភាពដែលបានកើតឡើង នាចុងការិយបរិច្ឆេទនៃរបាយការណ៍។ ព្រឹត្តិការណ៍ដែលមិនបានធ្វើនិយ័តកម្ម បន្ទាប់ពីចុងការិយបរិច្ឆេទនៃរបាយការណ៍ ត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់នៃរបាយការណ៍ហិរញ្ញវត្ថុជាសារវន្ត។

### (យ) របាយការណ៍តាមផ្នែក

ប្រតិបត្តិការតាមផ្នែក គឺជាធាតុផ្សំរបស់សម្ព័ន្ធធនាគារដែលទាក់ទងនឹងសកម្មភាពអាជីវកម្ម ដែលវាអាចនឹងកើតមានចំណូល និងចំណាយ ដែលរួមបញ្ចូលចំណូល និងចំណាយ ដែលទាក់ទងនឹងប្រតិបត្តិការដែលមាននៅក្នុងធាតុផ្សំរបស់សម្ព័ន្ធធនាគារ។

ព័ត៌មានអំពីប្រតិបត្តិការតាមផ្នែក ដែលត្រូវនឹងកម្រិតកំណត់ខាងក្រោម សម្ព័ន្ធធនាគារនឹងរាយការណ៍ដាច់ដោយឡែករួមមានៈ

- ចំនួនទឹកប្រាក់នៃរបាយការណ៍ចំណេញ ឬខាតដែលស្មើនឹង ១០% ឬច្រើនជាងនៃចំនួនទឹកប្រាក់ចំណេញរួមនៃប្រតិបត្តិការតាមផ្នែកទាំងអស់ ដែលមិនរាយការណ៍ខាត និងទឹកប្រាក់ខាតរួមនៃប្រតិបត្តិការតាមផ្នែកទាំងអស់ដែលរាយការណ៍ខាត ឬ
- ទ្រព្យសកម្មដែលមានចំនួន ១០% ឬច្រើនជាងនៃទ្រព្យសកម្មរួមនៃប្រតិបត្តិការតាមផ្នែក។

ប្រតិបត្តិការតាមផ្នែក ដែលមិនត្រូវនឹងកម្រិតកំណត់ទាំងនេះ អាចត្រូវបានរាយការណ៍ និងលាតត្រដាងដាច់ដោយឡែក ប្រសិនបើអ្នកគ្រប់គ្រងជឿថាព័ត៌មានអំពីផ្នែកនោះ គឺផ្តល់ផលប្រយោជន៍សម្រាប់អ្នកប្រើប្រាស់នៃរបាយការណ៍ហិរញ្ញវត្ថុរួម។

សម្រាប់គោលបំណងរបស់អ្នកគ្រប់គ្រង សម្ព័ន្ធធនាគារ គឺកំពុងតែរៀបចំឱ្យទៅជាអាជីវកម្មធំៗចំនួន២ គឺឱ្យកម្ចី និងសេវាហិរញ្ញវត្ថុផ្សេងៗ។ ផ្នែកទាំងនេះជាមូលដ្ឋាន ដែលសម្ព័ន្ធធនាគាររាយការណ៍ ក្នុងរបាយការណ៍តាមផ្នែកដំបូង។

ព័ត៌មានហិរញ្ញវត្ថុតាមផ្នែកត្រូវបានលាតត្រដាងនៅក្នុងកំណត់សម្គាល់លេខ ៦។

## ៣. សមាសភាពនៃសម្ព័ន្ធធនាគារ

លម្អិតនៃបុត្រសម្ព័ន្ធរបស់ធនាគារនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និងឆ្នាំ២០២២ គឺត្រូវបានលាតត្រដាងនៅក្នុងកំណត់សម្គាល់លេខ ១៣។

ព័ត៌មានហិរញ្ញវត្ថុសំខាន់ៗនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ នៃបុត្រសម្ព័ន្ធមិនមែនកាន់កាប់ដោយធនាគារ ដែលមានភាគកម្មមិនមានអភិបាលភាពជាសារវន្ត ត្រូវបានបង្ហាញនៅខាងក្រោម និងនៅក្នុងទំព័រនេះ។ ព័ត៌មានហិរញ្ញវត្ថុដែលបានសង្ខេប គឺតំណាងឱ្យចំនួនទឹកប្រាក់មុនពេលលុបបំបាត់ចោល។

# ធនាគារ អេស៊ីលីដា ភីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)

## នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និង សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់

## ៣. សមាសភាពនៃសម្ព័ន្ធ (ត)

| <u>វិទ្យាស្ថានពាណិជ្ជសាស្ត្រ អេស៊ីលីដា ឯ.ក</u> | ២០២៣<br>ដុល្លារអាមេរិក | ២០២២<br>ដុល្លារអាមេរិក | ២០២៣<br>ពាន់រៀល<br>(កំណត់សម្គាល់ ៥) | ២០២២<br>ពាន់រៀល<br>(កំណត់សម្គាល់ ៥) |
|---|---|---|---|---|
| <u>ស្ថានភាពហិរញ្ញវត្ថុ៖</u> | | | | |
| ទ្រព្យសកម្មរយៈពេលខ្លី | ២៩៦.៦៩១ | ១.៥៣៨.៧២៣ | ១.២១១.៩៨៣ | ៦.៣៣៤.៩២៣ |
| ទ្រព្យសកម្មរយៈពេលវែង | ៣១.៤៣៣.០១៩ | ៣២.១១៧.៤៦៤ | ១២៨.៤០៣.៨៨៣ | ១៣២.២២៧.៥៩៩ |
| ទ្រព្យសកម្មសរុប | ៣១.៧២៩.៧១០ | ៣៣.៦៥៦.១៨៧ | ១២៩.៦១៥.៨៦៦ | ១៣៨.៥៦២.៥២២ |
| បំណុលរយៈពេលខ្លី | ២.៧៩៣.២៦២ | ២.១៣៤.៥៨០ | ១១.៤១០.៤៧៥ | ៨.៧៨៨.០៦៦ |
| បំណុលរយៈពេលវែង | ៣.១៧៩.០៩៣ | ៥.៦០០.០៥៤ | ១២.៩៨៦.៥៩៦ | ២៣.០៥៥.៤២២ |
| បំណុលសរុប | ៥.៩៧២.៣៥៥ | ៧.៧៣៤.៦៣៤ | ២៤.៣៩៧.០៧១ | ៣១.៨៤៣.៤៨៨ |
| មូលធន | ២៥.៧៥៧.៣៥៥ | ២៥.៩២១.៥៥៣ | ១០៥.២១៨.៧៩៥ | ១០៦.៧១៩.០៣៤ |
| ម្ចាស់កម្មសិទ្ធិ និងសិទ្ធិបោះឆ្នោតកាន់កាប់ដោយភាគកម្មមិន មានអភិបាលភាព | ២៣,៣៩១% | ២៣,៣៩១% | ២៣,៣៩១% | ២៣,៣៩១% |
| មូលធនបែងចែកទៅ៖ | | | | |
| មូលធនកាន់កាប់ដោយធនាគារមេ | ១៩.៧៣២.៤៥២ | ១៩.៨៥៨.២៤៣ | ៨០.៦០៧.០៦៧ | ៨១.៧៥៦.៣៨៥ |
| ភាគកម្មមិនមានអភិបាលភាព | ៦.០២៤.៩០៣ | ៦.០៦៣.៣១០ | ២៤.៦១១.៧២៨ | ២៤.៩៦២.៦៤៩ |
| <u>លទ្ធផលនៃប្រតិបត្តិការ៖</u> | | | | |
| ចំណូល | ៤.៦៥១.១៩៥ | ៥.៣១២.៨២៨ | ១៩.១១៦.២០៦ | ២១.៧១៣.៥២៨ |
| ថ្លៃដើម និងចំណាយ | (៤.៨១៥.៣៩៣) | (៤.៩៩៣.២០៨) | (១៩.៧៩១.០៦០) | (២០.៤០៧.២៤១) |
| (ខាត)/ចំណេញក្នុងឆ្នាំ | (១៦៤.១៩៨) | ៣១៩.៦២០ | (៦៧៤.៨៥៤) | ១.៣០៦.២៨៧ |
| សរុបលទ្ធផល(ខាត)/ចំណេញលម្អិតក្នុងឆ្នាំ | (១៦៤.១៩៨) | ២៩៩.៣១៤ | (៦៧៤.៨៥៤) | ១.២២៣.២៩៦ |
| (ខាត)/ប្រាក់ចំណេញបែងចែកទៅ៖ | | | | |
| មូលធនកាន់កាប់ដោយធនាគារមេ | (១២៥.៧៩០) | ២៤៤.៨៥៨ | (៥១៦.៩៩៧) | ១.០០០.៧៣៥ |
| ភាគកម្មមិនមានអភិបាលភាព | (៣៨.៤០៨) | ៧៤.៧៦២ | (១៥៧.៨៥៧) | ៣០៥.៥៥២ |
| សរុបលទ្ធផល(ខាត)/ចំណេញលម្អិតក្នុងឆ្នាំបែងចែកទៅ៖ | | | | |
| មូលធនកាន់កាប់ដោយ ធនាគារមេ | (១២៥.៧៩០) | ២២៩.៣០១ | (៥១៦.៩៩៧) | ៩៣៧.១៥៣ |
| ភាគកម្មមិនមានអភិបាលភាព | (៣៨.៤០៨) | ៧០.០១៣ | (១៥៧.៨៥៧) | ២៨៦.១៤៣ |
| ភាគលាភបានបង់ទៅភាគកម្មមិនមានអភិបាលភាព | - | - | - | - |
| <u>លំហូរសាច់ប្រាក់៖</u> | | | | |
| សាច់ប្រាក់ចូលសុទ្ធប្រើក្នុងសកម្មភាពប្រតិបត្តិការ | ១.៥១៤.៧៤៧ | ២.២២២.៨១៥ | ៦.២២៥.៦១០ | ៩.០៨៤.៦៤៥ |
| សាច់ប្រាក់ចេញសុទ្ធប្រើក្នុងសកម្មភាពវិនិយោគ | (៧២.៣១៩) | (៥៤.៤៧៩) | (២៩៧.២៣១) | (២២២.៦៥៦) |
| សាច់ប្រាក់ចេញសុទ្ធប្រើក្នុងសកម្មភាពហិរញ្ញប្បទាន | (១.៨៦៧.៤៨០) | (១.៨៦៨.៥២៣) | (៧.៦៧៥.៣៤៣) | (៧.៦៣៦.៦៥៤) |
| លំហូរសាច់ប្រាក់(ចេញ)/ចូលសុទ្ធ | (៤២៥.០៥២) | ២៩៩.៨១៣ | (១.៧៤៦.៩៦៤) | ១.២២៥.៣៣៥ |

## ៤. ការប៉ាន់ស្មាន និង វិនិច្ឆ័យគណនេយ្យសំខាន់ៗក្នុងការអនុវត្តគោលនយោបាយគណនេយ្យ

សម្ព័ន្ធធនាគារ និងធនាគារធ្វើការប៉ាន់ស្មាន និងការសន្មតដែលពាក់ព័ន្ធនឹងអនាគត។ តាមនិយមន័យការប៉ាន់ស្មានគណនេយ្យ កម្រស្មើនឹងលទ្ធផលជាក់ស្តែងដែលពាក់ព័ន្ធ។ ដើម្បីលើកកម្ពស់ខ្លឹមសារព័ត៌មាននៃការប៉ាន់ស្មានអថេរសំខាន់ៗមួយចំនួនដែលត្រូវបានគេរំពឹងថានឹងមានផលប៉ះពាល់ជាសារវន្តដល់លទ្ធផល និងក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ ត្រូវបានសាកល្បងសម្រាប់ភាពប្រែប្រួលទៅនឹងការផ្លាស់ប្តូរនៅក្នុងប៉ារ៉ាម៉ែត្រជាមូលដ្ឋាន។ ការប៉ាន់ស្មាន និងការសន្មតដែលមានហានិភ័យជាសារវន្តក្នុងការបង្កឱ្យមានការកែតម្រូវជាសារវន្តទៅនឹងតម្លៃយោងនៃទ្រព្យសកម្ម និងបំណុលក្នុងឆ្នាំហិរញ្ញវត្ថុបន្ទាប់មានដូចខាងក្រោម៖

### (ក) ការវិនិច្ឆ័យ

ព័ត៌មានអំពីការវិនិច្ឆ័យ ដែលបានធ្វើឡើងក្នុងការអនុវត្តគោលនយោបាយគណនេយ្យដែលមានឥទ្ធិពលជាសារវន្តលើចំនួនទឹកប្រាក់ដែលត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានបញ្ចូលក្នុងកំណត់សម្គាល់ដូចខាងក្រោម៖

- កំណត់សម្គាល់លេខ ២(ច) (ii)៖ ការធ្វើចំណាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុ៖ ការវាយតម្លៃម៉ូដែលអាជីវកម្មដែលទ្រព្យទាំងនោះត្រូវបានកាន់កាប់ និងការវាយតម្លៃថាតើលក្ខខណ្ឌកិច្ចសន្យានៃទ្រព្យសកម្មហិរញ្ញវត្ថុគឺជាការទូទាត់តែប្រាក់ដើម និងការប្រាក់ ("SPPI") តាមបរិមាណប្រាក់ដើមដែលនៅជាប់ជំពាក់។
- កំណត់សម្គាល់លេខ ៣៨.១(ច)៖ ការបង្កើតលក្ខណៈវិនិច្ឆ័យសម្រាប់កំណត់ ថាតើហានិភ័យឥណទានលើទ្រព្យសកម្មហិរញ្ញវត្ថុបានកើនឡើងជាសារវន្ត ចាប់តាំងពីការទទួលស្គាល់ដំបូង ដោយកំណត់វិធីសាស្រ្តសម្រាប់បញ្ចូលព័ត៌មាននាពេលអនាគតទៅក្នុងការវាស់វែងនៃឥណទានដែលរំពឹងថា នឹងបាត់បង់ ECL និងការជ្រើសរើស និងការអនុម័តលើម៉ូដែល ដែលប្រើដើម្បីវាស់វែង ECL។
- អត្រាប្រាក់បញ្ញើមានកាលកំណត់រយៈពេលវែងរបស់អតិថិជនត្រូវបានប្រើជាអត្រាអប្បហារ សម្រាប់គណនាបំណុលភតិសន្យា (តាមអត្រាប្រាក់កម្ចីបន្ថែម) និងកាតព្វកិច្ចអត្ថប្រយោជន៍ដែលបានកំណត់។

#### រូបិយប័ណ្ណមុខងារ

ផ្អែកលើខ្លឹមសារសេដ្ឋកិច្ចនៃមូលដ្ឋានកាលៈទេសៈដែលពាក់ព័ន្ធនឹងសម្ព័ន្ធធនាគារ និងធនាគារ អ្នកគ្រប់គ្រងកំណត់យករូបិយប័ណ្ណមុខងាររបស់សម្ព័ន្ធធនាគារ និងធនាគារ ជាប្រាក់ដុល្លារអាមេរិក។ ដុល្លារអាមេរិក គឺជារូបិយប័ណ្ណនៃបរិយាកាសសេដ្ឋកិច្ចចម្បងដែលសម្ព័ន្ធធនាគារ និងធនាគារ ធ្វើប្រតិបត្តិការ។

## ៤. ការប៉ាន់ស្មាន និង វិនិច្ឆ័យគណនេយ្យសំខាន់ៗក្នុងការអនុវត្តគោលនយោបាយគណនេយ្យ (ត)

### ភតិសន្យា

ការវាយតម្លៃថាតើការរៀបចំមានរួមបញ្ចូលនូវភតិសន្យា គឺផ្អែកលើខ្លឹមសាររបស់ភតិសន្យានោះ។ ការរៀបចំគឺជា ឬរួមមានភតិសន្យានៅពេលដែលការបំពេញនូវការរៀបចំដោយផ្អែកលើទ្រព្យសកម្មជាក់លាក់ ឬ ទ្រព្យ-សកម្ម និងការរៀបចំដែលទាក់ទងនឹងសិទ្ធិក្នុងការប្រើប្រាស់លើទ្រព្យសកម្ម។

ក្នុងការសិក្សាដើម្បីកំណត់ថាភតិសន្យាមានតម្លៃទាប អ្នកគ្រប់គ្រងពិចារណាលើតម្លៃសេដ្ឋកិច្ចនៃទ្រព្យសកម្មទាំងមូល។

### អត្ថប្រយោជន៍ក្រោយពីបំពេញការងារ

អវត្តមាននៃទីផ្សារសញ្ញាបណ្ណ និងមូលបត្របំណុលរដ្ឋាភិបាល អ្នកគ្រប់គ្រងបានប្រើអត្រាការប្រាក់បញ្ញើមានកាលកំណត់រយៈពេល ៥ ឆ្នាំ ៦ ឆ្នាំ និង៧ឆ្នាំ របស់ពួកគេ ជាអត្រាអប្បហារដើម្បីកំណត់តម្លៃបច្ចុប្បន្ននៃលំហូរសាច់-ប្រាក់ដែលត្រូវបានប៉ាន់ស្មាននាពេលអនាគតដែលគេរំពឹងថា នឹងត្រូវបានតម្រូវដើម្បីទូទាត់កាតព្វកិច្ចអត្ថប្រយោជន៍ប្រាក់បំណាច់អតីតភាពការងារ កាតព្វកិច្ចអត្ថប្រយោជន៍ពេលចូលនិវត្តន៍ និងកាតព្វកិច្ចអត្ថប្រយោជន៍មូលនិធិអភិវឌ្ឍន៍វិជ្ជាជីវៈរៀងគ្នា។

### (ខ) ភាពមិនច្បាស់លាស់នៃការសន្មត និងការប៉ាន់ស្មាន

ខាងក្រោមនេះ គឺជាការសន្មតសំខាន់ៗទាក់ទងនឹងអនាគត និងប្រភពសំខាន់ៗផ្សេងទៀតនៃភាពមិនប្រាកដប្រជានៃការប៉ាន់ប្រមាណនៅចុងបញ្ចប់នៃការិយបរិច្ឆេទរបាយការណ៍នីមួយៗ។

### *ឱនភាពនៃទ្រព្យសកម្មហិរញ្ញវត្ថុ និងទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ*

ឱនភាពកើតឡើងនៅពេលតម្លៃយោងរបស់ទ្រព្យសកម្ម ឬអង្គភាពរកសាច់ប្រាក់លើសតម្លៃអាចប្រមូលមកវិញបាន គឺជាតម្លៃដែលខ្ពស់ជាងរវាងតម្លៃសមស្របដកថ្លៃដើមដើម្បីលក់ និងតម្លៃប្រើប្រាស់។ តម្លៃសមស្របដកថ្លៃដើមដើម្បីលក់ ត្រូវបានគណនាដោយប្រើប្រាស់ទិន្នន័យដែលមានស្រាប់ពីប្រតិបត្តិការលក់នៅក្នុងប្រតិបត្តិការជំហោង-ដៃរបស់ទ្រព្យសកម្មដែលមានភាពស្រដៀងគ្នា ឬតម្លៃទីផ្សារដែលអាចសង្កេតបានដកថ្លៃដើមបន្ថែមសម្រាប់ការលក់ទ្រព្យសកម្ម។ តម្លៃប្រើប្រាស់ ត្រូវបានគណនាដោយប្រើមូលដ្ឋានអប្បហារលំហូរសាច់ប្រាក់។ លំហូរសាច់ប្រាក់បានពីគម្រោងថវិកា និងមិនរួមបញ្ចូលការកែប្រែរចនាសម្ព័ន្ធរបស់ធនាគារ និង/ឬសម្ព័ន្ធធនាគារ ដែលមិនទាន់បានប្តេជ្ញា ឬធ្វើការវិនិយោគនាពេលអនាគត ដែលនឹងធ្វើឱ្យប្រសើរឡើងវិញនូវសមត្ថភាពទ្រព្យសកម្មរបស់អង្គភាពរកសាច់ប្រាក់ដែលកំពុងធ្វើតេស្ត។

តម្លៃអាចប្រមូលមកវិញបាន គឺល្អបំផុតសម្រាប់អត្រាអប្បហារ ដែលប្រើប្រាស់សម្រាប់ម៉ូដែលអប្បហារលំហូរ-សាច់ប្រាក់ ក៏ដូចជាលំហូរសាច់ប្រាក់ដែលរំពឹងទុកថានឹងហូរចូលនៅពេលអនាគត និងអត្រាកំណើនដែលត្រូវបានប្រើប្រាស់សម្រាប់គោលបំណងបន្ថែម។

## ៤. ការប៉ាន់ស្មាន និងវិនិច្ឆ័យគណនេយ្យសំខាន់ៗក្នុងការអនុវត្តគោលនយោបាយគណនេយ្យ (ត)

### (ខ) ភាពមិនច្បាស់លាស់នៃការសន្មត និងការប៉ាន់ស្មាន (ត)

*ឱនភាពនៃទ្រព្យសកម្មហិរញ្ញវត្ថុ និងទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ (ត)*

- កំណត់សម្គាល់លេខ ៣៨.១(ច)៖ ឱនភាពនៃតម្លៃរបស់ឧបករណ៍ហិរញ្ញវត្ថុ៖ កំណត់ការបញ្ចូលសមាសធាតុទៅក្នុងម៉ូដែលនៃការវាស់វែង ការខាតបង់ឥណទានដែលរំពឹងទុក (ECL) រួមទាំងការបញ្ចូលព័ត៌មាននាពេលអនាគត ។
- កំណត់សម្គាល់លេខ ៣៩៖ ការកំណត់លើតម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុជាមួយទិន្នន័យដែលមិនអាចអង្កេតបានជាសារវន្ត។
- កំណត់សម្គាល់លេខ ៣៥៖ ការទទួលស្គាល់ និងការវាស់វែងយថាភាព៖ ការសន្មតសំខាន់ៗអំពីលទ្ធភាព និងទំហំលំហូរចេញនៃធនធាន។
- កំណត់សម្គាល់លេខ ២(ង)(vii)៖ ឱនភាពនៃតម្លៃរបស់ឧបករណ៍ហិរញ្ញវត្ថុ៖ ការសន្មតសំខាន់ៗ ដែលប្រើក្នុងការប៉ាន់ស្មានលំហូរសាច់ប្រាក់ដែលអាចប្រមូលមកវិញបាន។

អនុវត្តតាម ស.គ.អ.ក ៣៦៖ *ឱនភាពនៃទ្រព្យសកម្ម៖* នៅចុងបញ្ចប់នៃការិយបរិច្ឆេទរបាយការណ៍នីមួយៗ សម្ព័ន្ធធនាគារ និងធនាគារធ្វើការសិក្សាថាតើមានសូចនាករណាមួយ ដែលបង្ហាញថា ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុអាចនឹងមានឱនភាពដែរឬទេ។ ប្រសិនបើមានការចង្អុលបង្ហាញបែបនេះ សម្ព័ន្ធធនាគារ និងធនាគារត្រូវប៉ាន់ប្រមាណនូវចំនួនទឹកប្រាក់ដែលអាចទទួលបានមកវិញនៃទ្រព្យសកម្ម និងធ្វើការប្រៀបធៀប សមតុល្យយោង ជាមួយនឹងការសិក្សាលើទឹកប្រាក់ដែលអាចប្រមូលមកវិញបាន។

ក្នុងការសិក្សាថាតើមានសូចនាករណាមួយដែលបង្ហាញថាទ្រព្យសកម្មអាចនឹងមានឱនភាព សម្ព័ន្ធធនាគារ និងធនាគារត្រូវពិចារណាជាអប្បបរមាលើសូចនាករដូចខាងក្រោម៖

- ប្រភពព័ត៌មានខាងក្រៅ
  - ក) តម្លៃទីផ្សារនៃទ្រព្យសកម្មបានថយចុះគួរឱ្យកត់សម្គាល់ក្នុងអំឡុងពេលណាមួយ លើសពីការរំពឹងទុកដោយសារការកន្លងហួសពេលវេលា ឬការប្រើប្រាស់ធម្មតា។
  - ខ) ការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់ដែលមានផលប៉ះពាល់អវិជ្ជមានដល់សម្ព័ន្ធធនាគារ និងធនាគារដែលបានកើតឡើងក្នុងអំឡុងពេល ឬនឹងកើតឡើងនាពេលអនាគតដ៏ខ្លី នៅក្នុងបរិស្ថាននៃបច្ចេកវិទ្យា ទីផ្សារ សេដ្ឋកិច្ច ឬច្បាប់ដែលសម្ព័ន្ធធនាគារ និងធនាគារធ្វើអាជីវកម្ម ឬនៅក្នុងទីផ្សារដែលទ្រព្យសកម្មមានគោលបំណងពិសេស។
  - គ) អត្រាការប្រាក់ទីផ្សារឬអត្រាទីផ្សារផ្សេងទៀតនៃផលចំណេញពីការវិនិយោគ ដែលបានកើនឡើងក្នុងអំឡុងពេលនោះ ហើយការកើនឡើងទាំងនោះទំនងជាប៉ះពាល់ដល់អត្រាអប្បហារដែលបានប្រើប្រាស់ក្នុងការគណនាតម្លៃកំពុងប្រើប្រាស់របស់ទ្រព្យសកម្ម ហើយធ្លាក់ចុះជាសារវន្តនូវតម្លៃទទួលបានមកវិញរបស់ទ្រព្យសកម្មទាំងនេះ

## ៤. ការប៉ាន់ស្មាន និង វិនិច្ឆ័យគណនេយ្យសំខាន់ៗក្នុងការអនុវត្តគោលនយោបាយគណនេយ្យ (ត)

### (ខ) ភាពមិនច្បាស់លាស់នៃការសន្មត និងការប៉ាន់ស្មាន (ត)

*ឱនភាពនៃទ្រព្យសកម្មហិរញ្ញវត្ថុ និងទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ (ត)*

ឃ) សមតុល្យយោងដុលរបស់ទ្រព្យសកម្មសុទ្ធរបស់អង្គភាពលើសពីមូលធននីយកម្ម។

- ប្រភពព័ត៌មានខាងក្នុង

ក) ភស្តុតាងដែលអាចរកបានពីភាពហួសសម័យ ឬការខូចខាតនៃទ្រព្យសកម្ម។

ខ) ការផ្លាស់ប្តូរដែលមានផលប៉ះពាល់អវិជ្ជមានលើសម្ព័ន្ធធនាគារ និងធនាគារ ដែលបានកើតឡើងក្នុងអំឡុងពេលនោះ ឬត្រូវបានរំពឹងថានឹងកើតឡើងនាពេលអនាគតដ៏ខ្លី ក្នុងទំហំ ឬឥរិយាបថដែលទ្រព្យសកម្មត្រូវបានកំពុងប្រើប្រាស់ ឬរំពឹងថានឹងប្រើប្រាស់។ ការផ្លាស់ប្តូរទាំងនេះរួមមានទ្រព្យសកម្មដែលនៅទំនេរ ផែនការមិនបន្ត ឬរះរើប្រតិបត្តិការដែលទ្រព្យសកម្មកំពុងស្ថិតនៅ និងផែនការលុបចោលទ្រព្យសកម្មមុនកាលបរិច្ឆេទដែលរំពឹងទុកពីមុន។

គ) ភស្តុតាងដែលអាចរកបានពីរបាយការណ៍ផ្ទៃក្នុង ដែលបង្ហាញថាដំណើរការសេដ្ឋកិច្ចរបស់ទ្រព្យសកម្ម មានភាពអាក្រក់ ឬនឹងអាក្រក់ជាងការរំពឹងទុក។

ក្នុងការកំណត់តម្លៃដែលអាចប្រមូលមកវិញបាន សម្ព័ន្ធធនាគារ និងធនាគារបានធ្វើការព្យាករណ៍លើលំហូរសាច់ប្រាក់សុទ្ធក្នុងការិយបរិច្ឆេទប្រាំឆ្នាំខាងមុខរបស់ខ្លួន ដោយប្រើប្រាស់គំរូ Gordon Growth។ ក្រោមគំរូនេះ អ្នកគ្រប់គ្រងកំណត់ថ្លៃដើមជាមធ្យមនៃដើមទុនជាអត្រាអប្បហារ ដោយផ្អែកលើរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មចុងក្រោយបង្អស់របស់ធនាគារ ហើយអាចផ្លាស់ប្តូរបានប្រសិនបើមានការធានា។ បន្ថែមពីនេះទៀតអ្នកគ្រប់គ្រងសន្មតថាអត្រាកំណើនផលិតផលក្នុងស្រុកសរុប (“GDP”) ជាមធ្យមក្នុងរយៈពេល ១០ឆ្នាំ របស់ប្រទេសនីមួយៗដែលក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ធនាគារកំពុងធ្វើប្រតិបត្តិការអាជីវកម្ម គឺស្មើនឹងអត្រាកំណើន និងត្រូវធ្វើបច្ចុប្បន្នភាពតាមការិយបរិច្ឆេទនីមួយៗ។

នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ អ្នកគ្រប់គ្រងជឿជាក់ថាតម្លៃដែលអាចប្រមូលមកវិញបាននៃមូលធនវិនិយោគ និងទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុរបស់ធនាគារលើសពីតម្លៃយោងរបស់ខ្លួន។ ដូច្នេះហើយមិនមានការខាតបង់លើឱនភាពនៃតម្លៃណាមួយត្រូវបានកត់ត្រាឡើយ។

*វីរុសកូរ៉ូណា និងផលប៉ះពាល់បន្តលើការខាតបង់ឥណទានរំពឹងទុក*

ការខាតបង់ឥណទានរំពឹងទុក ត្រូវបានប៉ាន់ប្រមាណដោយផ្អែកទៅលើលក្ខខណ្ឌសេដ្ឋកិច្ចដែលបានព្យាករណ៍មួយចំនួននៅក្នុងការិយបរិច្ឆេទរាយការណ៍។ ក្នុងឆ្នាំ២០២០ ការផ្ទុះឡើងនៃល្វៃវីរុសកូរ៉ូណា (“កូវីដ-១៩”) បានរីករាលដាលលើប្រទេសចិនដីគោក កម្ពុជា និងបណ្តាប្រទេសផ្សេងៗទៀត ធ្វើឱ្យមានការរាំងស្ទះសកម្មភាពអាជីវកម្ម និងសេដ្ឋកិច្ច។ ឆ្លើយតបនឹងស្ថានភាពជំងឺកូវីដ-១៩ អ្នកគ្រប់គ្រងផ្តល់នូវការប៉ាន់ប្រមាណដ៏ល្អបំផុតរបស់ខ្លួនពីផលប៉ះពាល់បន្តនៃជំងឺកូវីដ-១៩ ទៅលើ ECL របស់សម្ព័ន្ធធនាគារ និងធនាគារ ដោយពិចារណាលើសេណារីយ៉ូសេដ្ឋកិច្ចដែលអាចកើតមាននាពេលបច្ចុប្បន្ន និងនាពេលអនាគត។

## ៤. ការប៉ាន់ស្មាន និង វិនិច្ឆ័យគណនេយ្យសំខាន់ៗក្នុងការអនុវត្តគោលនយោបាយគណនេយ្យ (ត)

### (ខ) ភាពមិនច្បាស់លាស់នៃការសន្មត និងការប៉ាន់ស្មាន (ត)

**អត្ថប្រយោជន៍ក្រោយពីបំពេញការងារ**

តម្លៃបច្ចុប្បន្ននៃកាតព្វកិច្ចអត្ថប្រយោជន៍ប្រាក់បំណាច់អតីតភាពការងារ កាតព្វកិច្ចអត្ថប្រយោជន៍ពេលចូលនិវត្តន៍ និងកាតព្វកិច្ចអត្ថប្រយោជន៍មូលនិធិអភិវឌ្ឍវិជ្ជាជីវៈ អាស្រ័យលើកត្តាមួយចំនួន ដែលត្រូវបានកំណត់ដោយអ្នកគ្រប់គ្រង ដោយប្រើការសន្មតមួយចំនួនដូចជាអត្រាកំណើនប្រាក់ខែ អត្រាឈប់ពីការងារ និងអត្រាមរណភាព។ ការសន្មតដែលត្រូវបានប្រើក្នុងការកំណត់ចំណាយសុទ្ធសម្រាប់អត្ថប្រយោជន៍ក្រោយបំពេញការងាររួមមានអត្រាអប្បហារ។ ការផ្លាស់ប្តូរណាមួយនៅក្នុងការសន្មតទាំងនេះ នឹងប៉ះពាល់ដល់តម្លៃនៃកាតព្វកិច្ចអត្ថប្រយោជន៍ដែលបានកំណត់។

**ការទទួលស្គាល់ទ្រព្យសកម្មពន្ធពន្យារ**

ទ្រព្យសកម្មពន្ធពន្យារត្រូវបានទទួលស្គាល់ទៅលើការខាតបង់ពន្ធដែលមិនបានប្រើប្រាស់ទាំងអស់ និងភាពខុសគ្នាបណ្តោះអាសន្នចំពោះវិសាលភាពដែលវាអាចទៅរួចដែលថាប្រាក់ចំណេញជាប់ពន្ធនាពេលអនាគត នឹងអាចរកបានធៀបនឹងការខាតបង់ដែលអាចប្រើប្រាស់បាន។ ការប៉ាន់ស្មានចម្បង ត្រូវបានតម្រូវដើម្បីកំណត់ចំនួននៃទ្រព្យសកម្មពន្ធពន្យារដែលអាចទទួលស្គាល់បាន ដោយផ្អែកលើពេលវេលា និងកម្រិតនៃប្រាក់ចំណូលជាប់ពន្ធនាពេលអនាគតរួមជាមួយនឹងយុទ្ធសាស្ត្ររៀបចំផែនការពន្ធនាពេលអនាគត។

**ពន្ធ**

ពន្ធត្រូវបានគណនាលើមូលដ្ឋាននៃការបកស្រាយលើបទប្បញ្ញត្តិពន្ធបច្ចុប្បន្ន ដែលបានអនុម័តនាកាលបរិច្ឆេទនៃរបាយការណ៍។ អ្នកគ្រប់គ្រងវាយតម្លៃជាប្រចាំលើស្ថានភាពនៃប្រកាសពន្ធដែលស្របជាមួយបទប្បញ្ញត្តិ ស្តីពីពន្ធដារ ដែលត្រូវបានបកស្រាយ។ ច្បាប់នេះបង្កើតនូវបទប្បញ្ញត្តិដែលសមស្របលើមូលដ្ឋាននៃចំនួនទឹកប្រាក់ដែលបានរំពឹងទុកថានឹងត្រូវបង់ជូនអាជ្ញាធរពន្ធដារ។

ទោះជាយ៉ាងណាក៏ដោយ បទប្បញ្ញត្តិទាំងនេះអាចមានការប្រែប្រួលតាមកាលកំណត់ ហើយការកំណត់នៃបំណុលពន្ធនឹងត្រូវបានធ្វើឡើងបន្ទាប់ពីការត្រួតពិនិត្យពីអាជ្ញាធរពន្ធដារ។ នៅពេលដែលលទ្ធផលពន្ធចុងក្រោយ នៃបញ្ហាទាំងនេះខុសគ្នាពីចំនួនទឹកប្រាក់ដែលបានកត់ត្រាដំបូង ភាពខុសគ្នាទាំងនេះនឹងប៉ះពាល់ដល់បំណុលពន្ធ និងសមតុល្យក្នុងការិយបរិច្ឆេទដែលការកំណត់ត្រូវបានធ្វើឡើង។

## ៤. ការប៉ាន់ស្មាន និង វិនិច្ឆ័យគណនេយ្យសំខាន់ៗក្នុងការអនុវត្តគោលនយោបាយគណនេយ្យ (ត)

### (ខ) ភាពមិនច្បាស់លាស់នៃការសន្មត និងការប៉ាន់ស្មាន (ត)

#### ការប៉ាន់ស្មានថ្លៃដើមនៃសិទ្ធិប្រើប្រាស់ទ្រព្យសកម្ម និងបំណុលភតិសន្យា

ការកំណត់ថ្លៃដើមនៃសិទ្ធិប្រើប្រាស់ទ្រព្យសកម្មរួមបញ្ចូលចំនួននៃបំណុលភតិសន្យា ដែលបានទទួលស្គាល់ និងការប៉ាន់ស្មានថ្លៃដើម ដែលនឹងកើតឡើងនៅពេលរុះរើ និងដកចេញនូវទ្រព្យសកម្មនោះ ឬធ្វើឱ្យដូចដើមតាមលក្ខខណ្ឌដែលមានចែងក្នុងកិច្ចសន្យាភតិសន្យា។

បំណុលភតិសន្យា គឺវាស់វែងតាមតម្លៃបច្ចុប្បន្ន នៃភតិសន្យាដែលត្រូវទូទាត់ទៅតាមរយៈពេលនៃភតិសន្យា។ នៅក្នុងការគណនា បំណុលភតិសន្យា សម្ព័ន្ធធនាគារ និងធនាគារប្រើប្រាស់អត្រាមធ្យមនៃប្រាក់កម្ចីបន្ថែមដោយផ្អែកលើអត្រាការប្រាក់បញ្ញើមានកាលកំណត់រយៈពេលវែងនៅពេលចាប់ផ្តើមអនុវត្តទៅតាមរយៈពេលនៃភតិសន្យា។

#### ការប៉ាន់ស្មានអាយុកាលប្រើប្រាស់ទ្រព្យសកម្ម

អាយុកាលនៃការប្រើប្រាស់ទ្រព្យសកម្មរបស់សម្ព័ន្ធធនាគារ និងធនាគារត្រូវបានកំណត់ការប៉ាន់ស្មានផ្អែកលើការរំពឹងទុកទ្រព្យសកម្មអាចប្រើប្រាស់បាន។ ការប៉ាន់ស្មានអាយុកាលទ្រព្យសម្បត្តិ និងបរិក្ខារ និងទ្រព្យសកម្មអរូបីរបស់សម្ព័ន្ធធនាគារ និងធនាគារត្រូវបានត្រួតពិនិត្យជាប្រចាំតាមកាលកំណត់ និងធ្វើបច្ចុប្បន្នភាពប្រសិនបើការរំពឹងទុកខុសពីការប៉ាន់ស្មានដោយសាររូបរាង បច្ចេកទេស ឬសម័យកាល និងតាមច្បាប់ ឬការកំណត់ការប្រើប្រាស់ទ្រព្យសកម្មនៃសម្ព័ន្ធធនាគារ និងធនាគារ។ បន្ថែមលើសពីនេះការប៉ាន់ស្មានអាយុកាលប្រើប្រាស់ គឺផ្អែកទៅលើការវាយតម្លៃតាមការអនុវត្តនៅក្នុងវិស័យ ការវាយតម្លៃតាមអ្នកបច្ចេកទេសខាងក្នុង និងបទពិសោធន៍លើទ្រព្យសកម្មដែលស្រដៀងគ្នា។ ទោះបីជាយ៉ាងណាក៏ដោយលទ្ធផលប្រតិបត្តិការនៅពេលអនាគតអាចប៉ះពាល់ជាសារវន្ត ដោយការកែប្រែការប៉ាន់ស្មានតាមកត្តាដែលរៀបរាប់ខាងលើ។ ចំនួនទឹកប្រាក់ និងពេលវេលានៃការកត់ត្រាចំណាយនៃរយៈពេលណាមួយ អាចមានផលប៉ះពាល់ដោយសារការកែប្រែនៃកត្តាទាំងនោះ។ ការថយចុះនៃការប៉ាន់ស្មានអាយុកាលប្រើប្រាស់ទ្រព្យសកម្ម នឹងបង្កើនការទទួលស្គាល់ចំណាយប្រតិបត្តិការ និងថយចុះទ្រព្យសកម្មរយៈពេលវែង។

#### ការវាស់វែងតម្លៃសមស្រប

អ្នកគ្រប់គ្រងប្រើប្រាស់បច្ចេកទេសវាយតម្លៃផ្សេងៗដើម្បីកំណត់តម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុ (ដែលមិនមានសម្រង់តម្លៃនៃទីផ្សារសកម្ម) និងទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ។ ការពាក់ព័ន្ធទាំងនេះនឹងបង្កើតការប៉ាន់ស្មាន និងការសន្មតដែលស្របជាមួយនឹងរបៀបដែលអ្នកចូលរួមទីផ្សារនឹងដាក់តម្លៃនៃឧបករណ៍នេះ។ អ្នកគ្រប់គ្រងផ្អែកលើការសន្មតរបស់ខ្លួនទៅលើទិន្នន័យដែលអាចសង្កេតបានតាមដែលអាចធ្វើទៅបាន ប៉ុន្តែវាមិនកើតមានឡើងទាំងអស់នោះទេ។ ក្នុងករណីនេះ អ្នកគ្រប់គ្រងប្រើប្រាស់ព័ត៌មានល្អបំផុតដែលកើតមាន។ តម្លៃសមស្របដែលបានប៉ាន់ស្មានអាចប្រែប្រួលពីតម្លៃជាក់ស្តែងដែលនឹងត្រូវសម្រេចបាននៅក្នុងប្រតិបត្តិការជំហោងដៃ នៅកាលបរិច្ឆេទនៃការរាយការណ៍ (សូមមើលកំណត់សម្គាល់លេខ ៣៩)។

## ៥. ការប្តូរពីដុល្លារអាមេរិកទៅជាប្រាក់រៀល

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិក។ ការប្តូររូបិយប័ណ្ណពីប្រាក់ដុល្លារអាមេរិកទៅជាប្រាក់រៀល ("KHR") ត្រូវបានធ្វើឡើងដើម្បីសម្រាប់តែអនុវត្តទៅតាមច្បាប់ស្តីពីគណនេយ្យ និង សវនកម្ម។ ទ្រព្យ-សកម្ម និងបំណុលត្រូវបានប្តូរតាមអត្រាចុងគ្រានាកាលបរិច្ឆេទនៃការរាយការណ៍។ របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ និងរបាយការណ៍លំហូរសាច់ប្រាក់ ត្រូវបានប្តូរទៅជាប្រាក់រៀល ដោយប្រើប្រាស់អត្រាមធ្យមដែលអាចអនុវត្តបានសម្រាប់ដំណាច់ការិយបរិច្ឆេទ។ ភាពខុសគ្នា ដែលកើតឡើងពីការប្តូររូបិយប័ណ្ណ ត្រូវបានទទួលស្គាល់ជា "លម្អៀងពីការប្តូររូបិយប័ណ្ណ" នៅក្នុងរបាយការណ៍ លទ្ធផល លម្អិតផ្សេងៗ។

សម្ព័ន្ធធនាគារ និង ធនាគារ ប្រើប្រាស់អត្រាប្តូរប្រាក់ដូចខាងក្រោម៖

| | | អត្រានាកាលបរិច្ឆេទរាយការណ៍ | អត្រាមធ្យម |
|---|---|---|---|
| ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ | ១ ដុល្លារអាមេរិក = | ៤.០៨៥រៀល | ៤.១១០រៀល |
| ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | ១ ដុល្លារអាមេរិក = | ៤.១១៧រៀល | ៤.០៨៧រៀល |

តួលេខដែលត្រូវបានប្តូរនេះ មិនគួរបកស្រាយថាតួលេខនេះជាតួលេខសម្រាប់បង្ហាញ ដូចតួលេខជាប្រាក់ដុល្លារអាមេរិក ឬយល់ថាជាតួលេខត្រូវបានប្តូរ ឬអាចប្តូរទៅជាប្រាក់រៀលតាមអត្រាប្តូរប្រាក់ខាងលើ ឬអត្រាប្តូរប្រាក់ផ្សេងទៀតទេ។

## ៦. ព័ត៌មានតាមផ្នែក

ប្រតិបត្តិការចម្បងរបស់សម្ព័ន្ធធនាគារ គឺក្នុងវិស័យហិរញ្ញវត្ថុ ដែលបានកំណត់ដោយរបាយការណ៍តាមផ្នែករបស់សម្ព័ន្ធធនាគារ។

### (ក) អាជីវកម្មតាមផ្នែក

ប្រតិបត្តិការអាជីវកម្មរបស់សម្ព័ន្ធធនាគារ គឺគ្រប់គ្រងដាច់ដោយឡែក តាមលក្ខណៈនៃសេវាដែលបានផ្តល់ (ផ្នែកដំបូង) និងតាមទីផ្សារតំបន់ផ្សេងគ្នា (ផ្នែកទី២) ដែលផ្នែកនីមួយៗ គឺតំណាងឱ្យយុទ្ធសាស្ត្រអាជីវកម្ម។ ផ្នែកអាជីវកម្មរបស់សម្ព័ន្ធធនាគារមានដូចខាងក្រោម៖

- *កម្ចី*៖ ផ្តល់ប្រាក់កម្ចីទៅឯកត្តជន ក្រុម និងនីតិបុគ្គល ក៏ដូចជាស្ថាប័នហិរញ្ញវត្ថុ។ ផលិតផលត្រូវផ្តល់ជូនទៅតាមគោលបំណង លក្ខណៈ និងទំហំដូចជា កម្ចីជាក្រុម កម្ចីធុនតូច កម្ចីមធ្យម កម្ចីទិញផ្ទះ កម្ចីទិញឡានកម្ចីទិញម៉ូតូ ឥណទានវិបារូបន៍ កម្ចីសម្រាប់ទុនបង្វិល ភតិសន្យាហិរញ្ញវត្ថុ កម្ចីហិរញ្ញប្បទានពាណិជ្ជកម្ម។ ល។

## ៦. ព័ត៌មានតាមផ្នែក (ត)

### (ក) អាជីវកម្មតាមផ្នែក (ត)

- *សេវាហិរញ្ញវត្ថុផ្សេងៗ៖* ផ្តល់សេវាផ្សេងៗដូចជាប្រតិបត្តិការប្តូរប្រាក់ ការផ្តល់កាតឥណទាន និងឥណពន្ធ និងការទទួល សេវាកម្មការផ្ទេរប្រាក់ (នៅក្នុងប្រទេស និងក្រៅប្រទេស) និង សេវាចាត់ចែងសាច់ប្រាក់ ដូចជា ប្រាក់បៀវត្ស និងប្រមូលសាច់ប្រាក់ ទូទាត់វិក្កយបត្រ បញ្ចូលទឹកប្រាក់ទូរសព្ទ និងបញ្ជាអចិន្ត្រៃយ៍។ សេវាទាំងនេះ គឺកំពុងធ្វើទំនើបកម្មប្រើប្រាស់តាមប្រព័ន្ធធនាគារឌីជីថលតាមរយៈកម្មវិធីទូរសព្ទក្នុងទូរសព្ទដៃ ការប្រើប្រាស់សេវាធនាគារអេស៊ីលីដា អ៊ីនធើណែត និង អ៊ីខុមមើស ក៏ដូចជាកម្មវិធីឌីជីថលផ្សេងៗទៀត។

ផ្នែកទាំងនេះ គឺជាមូលដ្ឋានដែលសម្ព័ន្ធធនាគាររាយការណ៍ជាព័ត៌មាននៃផ្នែកដំបូងរបស់ខ្លួន។ ប្រតិបត្តិការរវាងផ្នែកនីមួយៗកើតឡើងតាមការប៉ាន់ស្មានអត្រាទីផ្សារលើមូលដ្ឋានជំហោងដៃ។

ចំណូល និងចំណាយតាមផ្នែក គឺបែងចែកដោយផ្ទាល់ទៅផ្នែកដំបូងនៃអាជីវកម្ម និងទាក់ទងនឹងផ្នែកខ្លះនៃចំណូល និងចំណាយរបស់សម្ព័ន្ធធនាគារ ដែលអាចចែកទៅតាមផ្នែកនៃអាជីវកម្ម ដែលឆ្លុះបញ្ចាំងពីចំណូល និងចំណាយនៃផ្នែកអាជីវកម្មនោះ។

សម្រាប់ផ្នែកទី២ ចំណូល និងចំណាយ នឹងបែងចែកទៅតាមតំបន់ភូមិសាស្ត្រ ដោយផ្អែកលើទីតាំងនៃធនធានដែលបង្កើតប្រាក់ចំណូល និងតំបន់ភូមិសាស្ត្រដែលចំណាយកើតឡើង។

# ធនាគារ អេស៊ីលីដា ភីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)

## នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និង សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់

## ៦. ព័ត៌មានតាមផ្នែក (ត)

### (ខ) ការវិភាគព័ត៌មានផ្នែកដំបូង

ព័ត៌មានផ្នែកដំបូង តាមផ្នែកអាជីវកម្មលើមូលដ្ឋានរួម មានដូចខាងក្រោម៖

| | ២០២៣ | | | | | | ២០២២ | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | កម្ចី | | សេវាហិរញ្ញវត្ថុផ្សេងៗ | | សរុប | | កម្ចី | | សេវាហិរញ្ញវត្ថុផ្សេងៗ | | សរុប | |
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៥) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៥) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៥) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៥) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៥) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៥) |
| ចំណូល | | | | | | | | | | | | |
| ចំណូលការប្រាក់ | ៧៥៥.៦៣១.០៨៥ | ៣.១០៥.៦៤៣.៧៥៩ | - | - | ៧៥៥.៦៣១.០៨៥ | ៣.១០៥.៦៤៣.៧៥៩ | ៦៧០.៧៥៣.៤៥៦ | ២.៧៤១.៣៦៩.៣៧៥ | - | - | ៦៧០.៧៥៣.៤៥៦ | ២.៧៤១.៣៦៩.៣៧៥ |
| ចំណាយការប្រាក់ | (៣២៩.០០១.៤៣៤) | (១.៣៥២.១៩៥.៨៩៤) | - | - | (៣២៩.០០១.៤៣៤) | (១.៣៥២.១៩៥.៨៩៤) | (២២០.៨២២.៤៦៦) | (៩០២.៥០១.៤១៩) | - | - | (២២០.៨២២.៤៦៦) | (៩០២.៥០១.៤១៩) |
| ចំណូលការប្រាក់សុទ្ធ | ៤២៦.៦២៩.៦៥១ | ១.៧៥៣.៤៤៧.៨៦៥ | - | - | ៤២៦.៦២៩.៦៥១ | ១.៧៥៣.៤៤៧.៨៦៥ | ៤៤៩.៩៣០.៩៩០ | ១.៨៣៨.៨៦៧.៩៥៦ | - | - | ៤៤៩.៩៣០.៩៩០ | ១.៨៣៨.៨៦៧.៩៥៦ |
| ចំណូលមិនមែនការប្រាក់ | - | - | ៧២.៣៧៧.១៥៣ | ២៩៧.៤៧០.០៩៩ | ៧២.៣៧៧.១៥៣ | ២៩៧.៤៧០.០៩៩ | - | - | ៧៣.០៧៧.៩២៨ | ២៩៨.៦៦៩.៤៩២ | ៧៣.០៧៧.៩២៨ | ២៩៨.៦៦៩.៤៩២ |
| **សរុបចំណូលសុទ្ធ** | ៤២៦.៦២៩.៦៥១ | ១.៧៥៣.៤៤៧.៨៦៥ | ៧២.៣៧៧.១៥៣ | ២៩៧.៤៧០.០៩៩ | ៤៩៩.០០៦.៨០៤ | ២.០៥០.៩១៧.៩៦៤ | ៤៤៩.៩៣០.៩៩០ | ១.៨៣៨.៨៦៧.៩៥៦ | ៧៣.០៧៧.៩២៨ | ២៩៨.៦៦៩.៤៩២ | ៥២៣.០០៨.៩១៨ | ២.១៣៧.៥៣៧.៤៤៨ |

# ធនាគារ អេស៊ីលីដា ភីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)

## នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និង សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់

## ៦. ព័ត៌មានតាមផ្នែក (ត)

### (គ) ការវិភាគព័ត៌មានផ្នែកទី២

ព័ត៌មានផ្នែកទី២ (តាមភូមិសាស្ត្រ) មានដូចខាងក្រោម៖

| | ២០២៣ | | | | | | | | ២០២២ | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ព្រះរាជាណាចក្រកម្ពុជា | | សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ | | សាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា | | សរុប | | ព្រះរាជាណាចក្រកម្ពុជា | | សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ | | សាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា | | សរុប | |
| **សមតុល្យនាថ្ងៃទី១ ខែមករា ឆ្នាំ២០២២ បានធ្វើចំណាត់ថ្នាក់ឡើងវិញ** | ៥១០.៧៤១.៥៥៦ | ២.០៨០.៧៦១.០៩៩ | (៥០៦.១៥៨) | (២.០៦២.០៨៨) | ៩៧.១៤០.០០៤ | ៣៩៥.៧៤៨.៣៧៩ | ១៧.៥២៩.៨០៤ | ៦០៧.៣៧៥.៤០២ | ២.៤៩១.៩៧៧.១៩៤ |
| **លទ្ធផលលម្អិតផ្សេងៗ៖** | | | | | | | | | |
| ការវាស់វែងឡើងវិញលើផ្នែកដែលមានប្រសិទ្ធភាពរបស់ឧបករណ៍និស្សន្ទ ដែលកើតឡើងពីការការពារហានិភ័យលំហូរសាច់ប្រាក់ | - | - | ១០.១៣៦.៧៥១ | ៤១.៤២៨.៩០១ | - | - | - | ១០.១៣៦.៧៥១ | ៤១.៤២៨.៩០១ |
| លម្អៀងពីអត្រាប្តូរប្រាក់ | - | - | - | - | - | - | ១១.៨៥២.៧៥៣ | - | ១១.៨៥២.៧៥៣ |
| **លទ្ធផលចំណេញលម្អិតក្នុងការិយបរិច្ឆេទសរុប** | - | - | ១០.១៣៦.៧៥១ | ៤១.៤២៨.៩០១ | - | - | ១១.៨៥២.៧៥៣ | ១០.១៣៦.៧៥១ | ៥៣.២៨១.៦៥៤ |
| **ប្រតិបត្តិការជាមួយភាគហ៊ុនិក៖** | | | | | | | | | |
| ការផ្ទេរពីចំណេញរក្សាទុកទៅជាទុនបម្រុងតាមបទប្បញ្ញត្តិ | - | - | - | - | ៥៨.៥៦៦.៨៣១ | ២៣៩.៣៦២.៦៣៨ | - | ៥៨.៥៦៦.៨៣១ | ២៣៩.៣៦២.៦៣៨ |
| លម្អៀងពីអត្រាប្តូរប្រាក់ | - | ២១.៩៦១.៨៨៧ | - | ២៨២.៣៤៣ | - | ៥.៩៣៤.០២៣ | (៤.៦១៩.៥៦៣) | - | ២៣.៥៥៨.៦៩០ |
| **ប្រតិបត្តិការជាមួយភាគហ៊ុនិកសរុប** | - | ២១.៩៦១.៨៨៧ | - | ២៨២.៣៤៣ | ៥៨.៥៦៦.៨៣១ | ២៤៥.២៩៦.៦៦១ | (៤.៦១៩.៥៦៣) | ៥៨.៥៦៦.៨៣១ | ២៦២.៩២១.៣២៨ |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | ៥១០.៧៤១.៥៥៦ | ២.១០២.៧២២.៩៨៦ | ៩.៦៣០.៥៩៣ | ៣៩.៦៤៩.១៥៦ | ១៥៥.៧០៦.៨៣៥ | ៦៩១.០៤៥.០៤០ | ២៤.៧៦២.៩៩៤ | ៦៧៦.០៧៨.៩៨៤ | ២.៨០៨.១៨០.១៧៦ |

# ធនាគារ អេស៊ីលីដា ភីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និង សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់

## ៣៧. សមតុល្យ និងប្រតិបត្តិការជាមួយសម្ព័ន្ធញាតិ

(ក) សម្ព័ន្ធញាតិ និងទំនាក់ទំនង

សម្ព័ន្ធញាតិរបស់ធនាគារ និងទំនាក់ទំនងជាមួយធនាគារមានដូចខាងក្រោម៖

| សម្ព័ន្ធញាតិ | ទំនាក់ទំនង |
|---|---|
| ក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ធនាគារដូចដែលបានបង្ហាញនៅក្នុង កំណត់សម្គាល់លេខ ១៣ | ក្រុមហ៊ុនបុត្រសម្ព័ន្ធ |
| ភាគហ៊ុនិកដូចដែលបានបង្ហាញនៅក្នុងកំណត់សម្គាល់លេខ ២៦ | ភាគហ៊ុនិក |
| បុគ្គលិកជាអ្នកគ្រប់គ្រងសំខាន់ៗ | បុគ្គលិកអ្នកគ្រប់គ្រងសំខាន់ៗគឺជាបុគ្គលទាំងឡាយណាដែលមានសិទ្ធិអំណាច និង ការទទួលខុសត្រូវដោយផ្ទាល់ ឬដោយប្រយោលក្នុងការធ្វើផែនការ ការដឹកនាំ និង ការត្រួតពិនិត្យសកម្មភាពនានារបស់សម្ព័ន្ធធនាគារ និង ធនាគារ។ បុគ្គលិកអ្នកគ្រប់គ្រងសំខាន់ៗរបស់សម្ព័ន្ធធនាគារ និង ធនាគាររួមមានក្រុមប្រឹក្សាភិបាលទាំងអស់របស់ធនាគារ និង សមាជិកអ្នកគ្រប់គ្រងជាន់ខ្ពស់របស់សម្ព័ន្ធធនាគារ និង ធនាគារ។ |

# ធនាគារ អេស៊ីលីដា ភីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និង សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់

## ៣៧. សមតុល្យ និងប្រតិបត្តិការជាមួយសម្ព័ន្ធញាតិ (ត)

(ខ) សមតុល្យជាមួយសម្ព័ន្ធញាតិ

| | សម្ព័ន្ធធនាគារ | | | | ធនាគារ | | | |
|---|---|---|---|---|---|---|---|---|
| | ២០២៣<br>ដុល្លារអាមេរិក | ២០២២<br>ដុល្លារអាមេរិក | ២០២៣<br>ពាន់រៀល<br>(កំណត់សម្គាល់ ៥) | ២០២២<br>ពាន់រៀល<br>(កំណត់សម្គាល់ ៥) | ២០២៣<br>ដុល្លារអាមេរិក | ២០២២<br>ដុល្លារអាមេរិក | ២០២៣<br>ពាន់រៀល<br>(កំណត់សម្គាល់ ៥) | ២០២២<br>ពាន់រៀល<br>(កំណត់សម្គាល់ ៥) |
| **i). ឥណទាន និង បុរេប្រទាន** | | | | | | | | |
| បុគ្គលិកជាអ្នកគ្រប់គ្រងសំខាន់ៗ | ១៣.៥៣៩.៩២៨ | ១៤.៦៥១.៧៩៦ | ៥៥.៣១០.៦០៦ | ៦០.៣២១.៤៤៤ | ១៣.០៧៤.៣៣៣ | ១៤.១៧១.៨៥៣ | ៥៣.៤០៨.៦៥០ | ៥៨.៣៤៥.៥១៩ |
| **ii). សមតុល្យជាមួយសម្ព័ន្ធញាតិ** | | | | | | | | |
| ភាគហ៊ុនិក | ៦៥៥.៩៩១ | ៧២៥.៣៨៨ | ២.៦៧៩.៧២៣ | ២.៩៨៦.៤២២ | ៦៥៥.៩៩១ | ៧២៥.៣៨៨ | ២.៦៧៩.៧២៣ | ២.៩៨៦.៤២២ |
| ក្រុមហ៊ុនបុត្រសម្ព័ន្ធ | - | - | - | - | ១៥.៨៧១ | - | ៦៤.៨៣៣ | - |
| | ៦៥៥.៩៩១ | ៧២៥.៣៨៨ | ២.៦៧៩.៧២៣ | ២.៩៨៦.៤២២ | ៦៧១.៨៦២ | ៧២៥.៣៨៨ | ២.៧៤៤.៥៥៦ | ២.៩៨៦.៤២២ |
| **iii). គណនីត្រូវទទួលពី/(គណនីត្រូវទូទាត់ឱ្យ) សម្ព័ន្ធញាតិ** | | | | | | | | |
| បុគ្គលិកជាអ្នកគ្រប់គ្រងសំខាន់ៗ | | | | | | | | |
| គណនីត្រូវទូទាត់ផ្សេងៗ | (១០៦.៧១២) | (៦៨.៩៧៨) | (៤៣៥.៩១៩) | (២៨៣.៩៨២) | (៩៣.៨៨៣) | (៥៦.៨២០) | (៣៨៣.៥១២) | (២៣៣.៩២៨) |
| ភាគហ៊ុនិក | | | | | | | | |
| គណនីត្រូវទូទាត់ផ្សេងៗ | (៧៥៥.៩០៣) | (៤៨៨.៩៣០) | (៣.០៨៧.៨៦៤) | (២.០១២.៩២៤) | (៧៥៥.៩០៣) | (៤៨៨.៩៣០) | (៣.០៨៧.៨៦៤) | (២.០១២.៩២៤) |
| ក្រុមហ៊ុនបុត្រសម្ព័ន្ធ | | | | | | | | |
| គណនីត្រូវទទួលផ្សេងៗ | - | - | - | - | ៤៤៩.៣៧៧ | ២៥៩.៩១០ | ១.៨៣៥.៧០៥ | ១.០៧០.០៤៩ |
| គណនីត្រូវទូទាត់ផ្សេងៗ | - | - | - | - | (១៨.៩៦០) | (២៨.៧០៩) | (៧៧.៤៥១) | (១១៨.១៩៥) |
| | (៨៦២.៦១៥) | (៥៥៧.៩០៨) | (៣.៥២៣.៧៨៣) | (២.២៩៦.៩០៦) | (៤១៩.៣៦៩) | (៣១៤.៥៤៩) | (១.៧១៣.១២២) | (១.២៩៤.៩៩៨) |

# ធនាគារ អេស៊ីលីដា ភីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និង សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់

## ៣៧. សមតុល្យ និងប្រតិបត្តិការជាមួយសម្ព័ន្ធញាតិ (ត)

(ខ) សមតុល្យជាមួយសម្ព័ន្ធញាតិ (ត)

| | សម្ព័ន្ធធនាគារ | | | | ធនាគារ | | | |
|---|---|---|---|---|---|---|---|---|
| | ២០២៣<br>ដុល្លារអាមេរិក | ២០២២<br>ដុល្លារអាមេរិក | ២០២៣<br>ពាន់រៀល<br>(កំណត់សម្គាល់ ៥) | ២០២២<br>ពាន់រៀល<br>(កំណត់សម្គាល់ ៥) | ២០២៣<br>ដុល្លារអាមេរិក | ២០២២<br>ដុល្លារអាមេរិក | ២០២៣<br>ពាន់រៀល<br>(កំណត់សម្គាល់ ៥) | ២០២២<br>ពាន់រៀល<br>(កំណត់សម្គាល់ ៥) |
| **iv). ប្រាក់បញ្ញើរបស់សម្ព័ន្ធញាតិ** | | | | | | | | |
| បុគ្គលិកជាអ្នកគ្រប់គ្រងសំខាន់ៗ | ៨.៤៤៥.៥៩៩ | ៦.២០៩.៩៦០ | ៣៤.៥០០.២៧២ | ២៥.៥៦៦.៤០៥ | ៧.៩៦៩.៥០០ | ៥.៧៣០.៣០៨ | ៣២.៥៥៥.៤០៨ | ២៣.៥៩១.៦៧៨ |
| ភាគហ៊ុនិក | | | | | | | | |
| គណនីចរន្ត | ៣.៣២៨.០៣៥ | ៧.០១៦.៨៤៦ | ១៣.៥៩៥.០២៣ | ២៨.៨៨៨.៣៥៥ | ២.៦៨៨.៧២៨ | ៦.២៩៨.៥៧០ | ១០.៩៨៣.៤៥៤ | ២៥.៩៣១.២១៣ |
| គណនីសន្សំ | ៦៨.០៣១ | ៩០២.៦០៥ | ២៧៧.៩០៧ | ៣.៧១៦.០២៦ | ៦៨.០៣១ | ៩០២.៦០៥ | ២៧៧.៩០៧ | ៣.៧១៦.០២៦ |
| ប្រាក់បញ្ញើមានកាលកំណត់ | ១.៥០១.៤២៣ | ២.៩៦៦.៤៤៨ | ៦.១៣៣.៣១៣ | ១២.២១២.៨៦៦ | ១.៥០១.៤២៣ | ២.៩៦៦.៤៤៨ | ៦.១៣៣.៣១៣ | ១២.២១២.៨៦៦ |
| ក្រុមហ៊ុនបុត្រសម្ព័ន្ធ | | | | | | | | |
| គណនីចរន្ត | - | - | - | - | ៣.៨៤១.០៥៩ | ៤.២៧៤.៥៧០ | ១៥.៦៩០.៧២៦ | ១៧.៥៩៨.៤០៤ |
| គណនីសន្សំ | - | - | - | - | ២៥១.២៨៩ | ២៥៨.៣៨៨ | ១.០២៦.៥១៦ | ១.០៦៣.៧៨៣ |
| ប្រាក់បញ្ញើមានកាលកំណត់ | - | - | - | - | ២.១១៨.១៧៧ | ៣.៤៥៤.៥២៦ | ៨.៦៥២.៧៥៤ | ១៤.២២២.២៨៣ |
| | ១៣.៣៤៣.០៨៨ | ១៧.០៩៥.៨៥៩ | ៥៤.៥០៦.៥១៥ | ៧០.៣៨៣.៦៥២ | ១៨.៤៣៨.២០៧ | ២៣.៨៨៥.៤១៥ | ៧៥.៣២០.០៧៨ | ៩៨.៣៣៦.២៥៣ |
| **v). ប្រាក់កម្ចីពីសម្ព័ន្ធញាតិ** | | | | | | | | |
| ភាគហ៊ុនិក | ៤៩.៤៩១.៦៥៩ | ៤៨.៨៤៧.៥២៨ | ២០២.១៧៣.៤២៧ | ២០១.១០៥.២៧៣ | ៤៩.៤៩១.៦៥៩ | ៤៨.៨៤៧.៥២៨ | ២០២.១៧៣.៤២៧ | ២០១.១០៥.២៧៣ |
| **vi). ប្រាក់កម្ចីបន្ទាប់បន្សំពីសម្ព័ន្ធញាតិ** | | | | | | | | |
| ភាគហ៊ុនិក | ១៥.០៩៤.២០៨ | - | ៦១.៦៥៩.៨៤០ | - | ១៥.០៩៤.២០៨ | - | ៦១.៦៥៩.៨៤០ | - |

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និង សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់

### ៣៧. សមតុល្យ និងប្រតិបត្តិការជាមួយសម្ព័ន្ធញាតិ (ត)

(គ) ប្រតិបត្តិការសម្ព័ន្ធញាតិ

| | សម្ព័ន្ធធនាគារ | | | | ធនាគារ | | | |
|---|---|---|---|---|---|---|---|---|
| | ២០២៣ ដុល្លារអាមេរិក | ២០២២ ដុល្លារអាមេរិក | ២០២៣ ពាន់រៀល (កំណត់សម្គាល់ ៥) | ២០២២ ពាន់រៀល (កំណត់សម្គាល់ ៥) | ២០២៣ ដុល្លារអាមេរិក | ២០២២ ដុល្លារអាមេរិក | ២០២៣ ពាន់រៀល (កំណត់សម្គាល់ ៥) | ២០២២ ពាន់រៀល (កំណត់សម្គាល់ ៥) |
| **i). ចំណូលការប្រាក់ពីសម្ព័ន្ធញាតិ** | | | | | | | | |
| ឥណទាន និងបុរេប្រទានផ្តល់ដល់បុគ្គលិកជាអ្នកគ្រប់គ្រងសំខាន់ៗ | ៨៩៦.១១១ | ៩០៤.៩៧៥ | ៣.៦៨៣.០១៦ | ៣.៦៩៨.៦៣៣ | ៨៩៦.០១៩ | ៩០៤.១៥៤ | ៣.៦៨២.៦៣៨ | ៣.៦៩៥.២៧៧ |
| ប្រាក់បញ្ញើជាមួយក្រុមហ៊ុនបុត្រសម្ព័ន្ធ | - | - | - | - | ១៨.២៤៧ | ៦.២១៧ | ៧៤.៩៩៥ | ២៥.៤០៩ |
| | ៨៩៦.១១១ | ៩០៤.៩៧៥ | ៣.៦៨៣.០១៦ | ៣.៦៩៨.៦៣៣ | ៩១៤.២៦៦ | ៩១០.៣៧១ | ៣.៧៥៧.៦៣៣ | ៣.៧២០.៦៨៦ |
| **ii). ចំណាយកម្រៃ និងជើងសាពីសម្ព័ន្ធញាតិ** | | | | | | | | |
| ភាគហ៊ុនិក | ១១៥ | ៤៥.៥១០ | ៤៧២ | ១៨៦.០០០ | ១១៥ | ៤៥.៥១០ | ៤៧២ | ១៨៦.០០០ |
| ក្រុមហ៊ុនបុត្រសម្ព័ន្ធ | - | - | - | - | ២៦.៩៧៤ | ៩៨៨ | ១១០.៨៦២ | ៤.០៣៧ |
| | ១១៥ | ៤៥.៥១០ | ៤៧២ | ១៨៦.០០០ | ២៧.០៨៩ | ៤៦.៤៩៨ | ១១១.៣៣៤ | ១៩០.០៣៧ |

# ធនាគារ អេស៊ីលីដា ភីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និង សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់

## ៣៧. សមតុល្យ និងប្រតិបត្តិការជាមួយសម្ព័ន្ធញាតិ (ត)

(គ) ប្រតិបត្តិការសម្ព័ន្ធញាតិ (ត)

| | សម្ព័ន្ធធនាគារ | | | | ធនាគារ | | | |
|---|---|---|---|---|---|---|---|---|
| | ២០២៣<br>ដុល្លារអាមេរិក | ២០២២<br>ដុល្លារអាមេរិក | ២០២៣<br>ពាន់រៀល<br>(កំណត់សម្គាល់ ៥) | ២០២២<br>ពាន់រៀល<br>(កំណត់សម្គាល់ ៥) | ២០២៣<br>ដុល្លារអាមេរិក | ២០២២<br>ដុល្លារអាមេរិក | ២០២៣<br>ពាន់រៀល<br>(កំណត់សម្គាល់ ៥) | ២០២២<br>ពាន់រៀល<br>(កំណត់សម្គាល់ ៥) |
| **iii). ចំណាយការប្រាក់ទៅឱ្យសម្ព័ន្ធញាតិ** | | | | | | | | |
| ប្រាក់បញ្ញើរបស់បុគ្គលិកជាអ្នកគ្រប់គ្រងសំខាន់ៗ | ១៤៣.១០៧ | ៨៨.៤១៦ | ៥៨៨.១៧០ | ៣៦១.៣៥៦ | ១១៨.៣០១ | ៤៩.០៣៤ | ៤៨៦.២១៧ | ២០០.៤០២ |
| ប្រាក់កម្ចីពីភាគហ៊ុនិក | ៥.៩៣៨.៨០៤ | ១.៦០៧.៤៩៩ | ២៤.៤០៨.៤៨៤ | ៦.៥៦៩.៨៤៨ | ៥.៩៣៨.៨០៤ | ១.៦០៧.៤៩៩ | ២៤.៤០៨.៤៨៤ | ៦.៥៦៩.៨៤៨ |
| ប្រាក់បញ្ញើរបស់ភាគហ៊ុនិក | ១៥៣.៨៩៦ | ២៧៣.០៤៦ | ៦៣២.៥១៣ | ១.១១៥.៩៣៩ | ១៥៣.៨៩៦ | ២៧៣.០៤៦ | ៦៣២.៥១៣ | ១.១១៥.៩៣៩ |
| ប្រាក់បញ្ញើរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ | - | - | - | - | ២០៨.១០១ | ២២២.៧៦៦ | ៨៥៥.២៩៥ | ៩១០.៤៤៤ |
| | ៦.២៣៥.៨០៧ | ១.៩៦៨.៩៦១ | ២៥.៦២៩.១៦៧ | ៨.០៤៧.១៤៣ | ៦.៤១៩.១០២ | ២.១៥២.៣៤៥ | ២៦.៣៨២.៥០៩ | ៨.៧៩៦.៦៣៣ |
| **iv). ចំណាយកម្រៃ និងដើមសារទៅឱ្យសម្ព័ន្ធញាតិ** | | | | | | | | |
| ក្រុមប្រឹក្សាភិបាល | ៨២៤.៩៨៦ | ៧៤៨.២០៩ | ៣.៣៩០.៦៩២ | ៣.០៥៧.៩៣០ | ៥៨៩.៥៧៨ | ៥០៣.០៧៣ | ២.៤២៣.១៦៦ | ២.០៥៦.០៥៩ |
| បុគ្គលិកជាអ្នកគ្រប់គ្រងសំខាន់ៗ | ១២.២០៨.៦១៣ | ១១.៣២៧.៥៤១ | ៥០.១៧៧.៣៩៩ | ៤៦.២៩៥.៦៦០ | ១០.៧៥៣.៧៨០ | ៩.៥៦២.០៨៣ | ៤៤.១៩៨.០៣៦ | ៣៩.០៨០.២៣៣ |
| ក្រុមហ៊ុនបុត្រសម្ព័ន្ធ | - | - | - | - | ១.៩៦៣.១២៦ | ៣.១៤៧.៧៤៧ | ៨.០៦៨.៤៤៨ | ១២.៨៦៤.៨៤២ |
| | ១៣.០៣៣.៥៩៩ | ១២.០៧៥.៧៥០ | ៥៣.៥៦៨.០៩១ | ៤៩.៣៥៣.៥៩០ | ១៣.៣០៦.៤៨៤ | ១៣.២១២.៩០៣ | ៥៤.៦៨៩.៦៥០ | ៥៤.០០១.១៣៤ |
| **v). កិច្ចសន្យាផ្សេងៗ** | | | | | | | | |
| ECL លើការធានាហិរញ្ញវត្ថុ លើកម្ចីរបស់វិទ្យាស្ថានពាណិជ្ជសាស្ត្រ អេស៊ីលីដា ពី IFC | - | - | - | - | (១៧.៦៧៥) | (៦៤.១១៤) | (៧២.៦៤៤) | (២៦២.០៣៤) |

# ធនាគារ អេស៊ីលីដា ភីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)**
**នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និង សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់**

## ៣៨. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ

### (ក) សេចក្តីផ្តើម និង ទស្សនៈទូទៅ

ធនាគារ គឺជាធនាគារនាំមុខ ដែលបានចុះបញ្ជីក្នុងទីផ្សារមូលបត្រ និងមានបណ្តាញប្រតិបត្តិការសាខា និងសេវាស្វ័យប្រតិបត្តិការច្រើនជាងគេនៅក្នុងប្រទេសកម្ពុជា ក្នុងការផ្តល់នូវផលិតផល និងសេវាកម្មជាច្រើនប្រភេទជូនដល់សាធារណជនដូចជា សេវាឥណទាន សេវាប្រាក់បញ្ញើ សេវាផ្ទេរប្រាក់ សេវាចាត់ចែងសាច់ប្រាក់ សេវាហិរញ្ញប្បទានពាណិជ្ជកម្ម ប័ណ្ណអេស៊ីលីដា និងប័ណ្ណឥណពន្ធ-ឥណទាន និងសេវាឌីជីថល ដូចជា សេវាអេស៊ីលីដាអ៊ីនធើណែត សេវាអេស៊ីលីដាម៉ូបាល (mobile banking app) សេវាអេស៊ីលីដាអ៊ីខុមមើស ម៉ាស៊ីនអេធីអឹម ម៉ាស៊ីន ឆូតកាត និងម៉ាស៊ីនដាក់ប្រាក់បញ្ញើមានកាលកំណត់។ ដូចដែលបានបង្ហាញក្នុងកំណត់សម្គាល់លេខ ១៣ ក្រុមហ៊ុនបុត្រសម្ព័ន្ធទាំង៤ របស់ធនាគារមានដូចខាងក្រោម៖

(ក) ធនាគារ អេស៊ីលីដា ឡាវ លីមីតធីត

(ខ) ក្រុមហ៊ុន អេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី

(គ) វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ឯ.ក និង

(ឃ) ស្ថាប័នមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា មីយ៉ាន់ម៉ា

ស្ថិតក្នុងមជ្ឈដ្ឋានអាជីវកម្មដែលមានការប្រកួតប្រជែង ការវិវត្ត និងការរីកលូតលាស់យ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យា និងការផ្លាស់ប្តូរ ឬភាពខុសគ្នានៃច្បាប់យុត្តាធិការ ដូច្នេះសម្ព័ន្ធ-ធនាគារ និងធនាគារចាំបាច់ត្រូវមានការគ្រប់គ្រងហានិភ័យប្រកបដោយប្រសិទ្ធភាព ដើម្បីគ្រប់គ្រង និងធានាថាហានិភ័យទាំងអស់ ដែលស្ថិតនៅក្នុងរង្វង់កម្រិតរីសអាប់ភែថាយ (Risk Appetite) និងរីសថលើរែន (Risk Tolerance) ដើម្បីសម្រេចគោលដៅរបស់សម្ព័ន្ធធនាគារ និងធនាគារ។

## ៣៨. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### (ក) សេចក្តីផ្តើម និង ទស្សនៈទូទៅ (ត)

ក្របខណ្ឌគ្រប់គ្រងហានិភ័យត្រូវបានបង្កើតឡើង ដោយមានធាតុចាំបាច់ដូចជា៖ ១) អភិបាលកិច្ច និងការត្រួតពិនិត្យដោយក្រុមប្រឹក្សាភិបាល និងថ្នាក់គ្រប់គ្រងជាន់ខ្ពស់ ២) ការអនុវត្តរីសអាប់ភែថាយ (Risk Appetite) និងរីសថលើរែន (Risk Tolerance) ៣) ការអនុវត្តដំណើរការគ្រប់គ្រងហានិភ័យប្រកបដោយប្រសិទ្ធភាព និង ៤) ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យា និងទិន្នន័យ។ ក្របខណ្ឌនេះ ត្រូវបានរួមបញ្ចូលក្នុងដំណើរការគ្រប់គ្រងអាជីវកម្ម និងប្រតិបត្តិការប្រចាំថ្ងៃ ដើម្បីផ្តល់នូវការគ្រប់គ្រងហានិភ័យ ប្រកបដោយតម្លាភាព និងសង្គតិភាពទូទាំងធនាគារ និងសម្ព័ន្ធធនាគារ។

សម្ព័ន្ធធនាគារ និងធនាគារបង្កើតឱ្យមានដំណើរការគ្រប់គ្រងហានិភ័យដែលអាចការពារហានិភ័យបានទុកជាមុន ដោយដាក់បញ្ចូលវប្បធម៌នៃការទទួលខុសត្រូវ និងភាពជាម្ចាស់-ហានិភ័យក្នុងការគ្រប់គ្រងហានិភ័យនៅគ្រប់កម្រិត ដោយរាប់បញ្ចូលទាំងក្រុមប្រឹក្សាភិបាល ថ្នាក់គ្រប់គ្រងជាន់ខ្ពស់ រហូតដល់កម្មករនិយោជិតគ្រប់លំដាប់ថ្នាក់របស់សម្ព័ន្ធធនាគារ និងធនាគារ។ វប្បធម៌គ្រប់គ្រងហានិភ័យនេះត្រូវបានគាំទ្រដោយ (១) គោលនយោបាយនានាទាក់ទងនឹងកម្មករនិយោជិតធនាគារ (ការគ្រប់គ្រងធនធានមនុស្ស និងក្រមសីលធម៌ ក្រមប្រតិបត្តិ ទំនាស់ផលប្រយោជន៍ ការតែងតាំង និងលាភការ កំណារពារនិវេទនជន និងការគ្រប់គ្រងរបាយការណ៍ស្តីពីកំហុស កម្មករនិយោជិត។ល។) (២) គោលការណ៍ផ្តល់អត្ថប្រយោជន៍នានា ដោយស្រប ជាមួយនឹងកម្រិតរីសអាប់ភែថាយ (RiskAppetite) និងរីសថលើរែន (RiskTolerance) និង (៣) ការបណ្តុះបណ្តាលអំពីហានិភ័យ នៅទូទាំងសម្ព័ន្ធធនាគារ និង ធនាគារ។

ការគ្រប់គ្រងហានិភ័យរបស់សម្ព័ន្ធធនាគារ និងធនាគារ ត្រូវអនុវត្តតាមម៉ូដែលខ្សែបន្ទាត់ទាំងបី ដែលគាំទ្រដោយភាពគ្រប់គ្រាន់នៃបុគ្គលិកជំនាញ នៅក្នុងការគ្រប់គ្រងហានិភ័យនៅគ្រប់ផ្នែកទាំងអស់នៃម៉ូដែលនេះ។

## ៣៨. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### (ខ) គោលបំណង និង គោលការណ៍

គោលបំណងនៃការគ្រប់គ្រងហានិភ័យរបស់សម្ព័ន្ធធនាគារ និងធនាគាររួមមាន៖

- ដើម្បីធានាថាហានិភ័យ ឱ្យស្ថិតនៅក្នុងរង្វង់កម្រិតវិសអាប់ភែថាយ (Risk Appetite) និងរីសថលើរែន (Risk Tolerance) និង ដើម្បីផ្តល់នូវការធានាដ៏សមហេតុផលក្នុងការសម្រេចគោលដៅ។
- ដើម្បីគ្រប់គ្រងហានិភ័យឱ្យមានប្រសិទ្ធភាព និងដើម្បីកំណត់អត្តសញ្ញាណហានិភ័យមុនពេលវាកើតមានឡើង និងកាត់បន្ថយហានិភ័យជាសារវន្តឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលា។
- ដើម្បីរក្សាតុល្យភាពក្នុងការគ្រប់គ្រងហានិភ័យ និងការបង្កើនតម្លៃដល់សម្ព័ន្ធធនាគារ និងធនាគារ។

រីសអាប់ភែថាយ (Risk Appetite) គឺជាចំនួន និងប្រភេទនៃហានិភ័យ ក្នុងកម្រិតទាំងមូលដែល សម្ព័ន្ធធនាគារ និងធនាគារទទួលយកដើម្បីរក្សាបានតម្លៃភាគហ៊ុនិករយៈពេល-វែង។ រីសថលើរែន (Risk Tolerance) គឺជាកម្រិតបម្រែបម្រួលនៃហានិភ័យជាអតិបរមាដែលអាចទទួលយកបាន ព្រមទាំងចាត់វិធានការណ៍សមស្របដើម្បីកាត់បន្ថយហានិភ័យ។

របាយការណ៍រីសអាប់ភែថាយ (Risk Appetite) និងរីសថលើរែន (Risk Tolerance) របស់សម្ព័ន្ធធនាគារ និងធនាគារ ត្រូវបានបង្កើតឡើងដោយស្របទៅនឹងយុទ្ធសាស្ត្រអាជីវកម្ម និងតួនាទីរបស់ធនាគារនៅក្នុងវិស័យហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាល ធ្វើការត្រួតពិនិត្យ និងអនុម័តរបាយការណ៍រីសអាប់ភែថាយ (Risk Appetite) និងរីសថលើរែន (Risk Tolerance) របស់សម្ព័ន្ធធនាគារ និងធនាគារ ជាមួយនឹងការពិចារណាទៅលើហានិភ័យសំខាន់ៗ ដោយផ្តោតទៅលើប្រភេទ លក្ខណៈ និងកម្រិតនៃហានិភ័យទាំងនោះ ដែលសម្ព័ន្ធធនាគារ និងធនាគារ សុខចិត្តសន្មត និងផ្តល់នូវអនុសាសន៍ក្នុងការគ្រប់គ្រងហានិភ័យទាំងនេះ។

# ធនាគារ អេស៊ីលីដា ភីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)**
**នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និង សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់**

## ៣៨. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### (ខ) គោលបំណង និង គោលការណ៍ (ត)

គោលនយោបាយគ្រប់គ្រងហានិភ័យ បានចែងអំពីប្រភេទហានិភ័យ ដោយស្របទៅតាមប្រភេទហានិភ័យ ដែលបានកំណត់ដោយគណៈកម្មការ Basel និងស្របតាមលក្ខណៈ និងបរិបទអាជីវកម្មរបស់សម្ព័ន្ធធនាគារ និងធនាគារ។ គោលនយោបាយនេះបាន ចែងអំពីវិសថលើវែន (Risk Tolerance) និងកម្រិតកំណត់ផ្ទៃក្នុង (Internal Targets) ទៅតាមប្រភេទហានិភ័យនីមួយៗ។

នៅគ្រប់ពេលទាំងអស់ សម្ព័ន្ធធនាគារ និងធនាគារត្រូវប្រកាន់ខ្ជាប់នូវអនុលោមភាពអនុបាតប្រុងប្រយ័ត្ន និងតម្រូវការនានា កំណត់ដោយធនាគារជាតិ នៃ កម្ពុជា។

នៅគ្រប់ពេលទាំងអស់ សម្ព័ន្ធធនាគារ និងធនាគារត្រូវប្រកាន់ខ្ជាប់នូវអនុលោមភាព វិសអាប់ភែថាយ (Risk Appetite) និងវិសថលើវែន (Risk Tolerance) និងកម្រិត កំណត់ផ្ទៃក្នុង (Internal Targets) ដែលបានអនុមតិដោយក្រុមប្រឹក្សាភិបាលនៅក្នុងគោលនយោបាយគ្រប់គ្រងហានិភ័យ ដើម្បីកាត់បន្ថយការខាតបង់ជាសារវន្តដរាបណាមានការលើកឡើងច្បាស់លាស់ផ្សេងពីនេះ។

សកម្មភាពអាជីវកម្មរបស់សម្ព័ន្ធធនាគារ និងធនាគារ អាចប្រឈមនឹងហានិភ័យហិរញ្ញវត្ថុផ្សេងៗមួយចំនួនដូចជា ហានិភ័យឥណទាន ហានិភ័យទីផ្សារ (រួមមានហានិភ័យអត្រាប្តូរប្រាក់បរទេស និងហានិភ័យអត្រាការប្រាក់) និងហានិភ័យសន្ទនីយភាព។ ទោះបីជាយ៉ាងណា សម្ព័ន្ធធនាគារ និងធនាគារមិនប្រឈមនឹងហានិភ័យ ថ្លៃភាគហ៊ុន និងថ្លៃទំនិញទេ ដោយសារសម្ព័ន្ធធនាគារ និងធនាគារមិនមានធ្វើការវិនិយោគ (ជួញ-ដូរ) លើភាគហ៊ុន ឬទំនិញណាមួយនោះទេ។

## ៣៨. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

(ខ) គោលបំណង និង គោលការណ៍ (ត)

សម្ព័ន្ធធនាគារ និងធនាគារ កាន់កាប់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុដូចខាងក្រោមៈ

ក. ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុត្រូវបានវាស់វែងតាមថ្លៃដើមបានរំលស់

| | សម្ព័ន្ធធនាគារ | | | | ធនាគារ | | | |
|---|---|---|---|---|---|---|---|---|
| | ២០២៣ ដុល្លារអាមេរិក | ២០២២ ដុល្លារអាមេរិក | ២០២៣ ពាន់រៀល (កំណត់សម្គាល់ ៥) | ២០២២ ពាន់រៀល (កំណត់សម្គាល់ ៥) | ២០២៣ ដុល្លារអាមេរិក | ២០២២ ដុល្លារអាមេរិក | ២០២៣ ពាន់រៀល (កំណត់សម្គាល់ ៥) | ២០២២ ពាន់រៀល (កំណត់សម្គាល់ ៥) |
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | | | | | | | |
| សាច់ប្រាក់ក្នុងដៃ | ៤៩៥.៧៩៣.៥៦៨ | ៤៩៧.០២៧.០៤១ | ២.០២៥.៣១៦.៧២៥ | ២.០៤៦.២៦០.៣២៨ | ៤៨៦.៥៨៤.៣១៧ | ៤៨៦.៦៦៥.៤៨៣ | ១.៩៨៧.៦៩៦.៩៣៥ | ២.០០៣.៦០១.៧៩៤ |
| ប្រាក់បញ្ញើនៅធនាគារផ្សេងៗ-សុទ្ធ | ១.៥០៩.៥៤៣.១៧៨ | ៨៤៦.៦០២.១៧៥ | ៦.១៦៦.៤៨៣.៨៨២ | ៣.៩៨៥.៤៦១.១៥៤ | ១.៤៧៨.៨៨២.០២១ | ៨២៨.៣៩៦.៤២៥ | ៦.០៤១.២៣៣.០៥៦ | ៣.៤១០.៥០៨.០៨២ |
| ប្រាក់បញ្ញើតាមច្បាប់ | ៥៤៨.៦២៧.១០៩ | ៤៨២.៣៣០.៩៩៣ | ២.២៤១.១៩១.៧៤០ | ១.៩៨៥.៧៥៦.៦៩៨ | ៥៤៣.៣០២.១០៤ | ៤៧៩.៥៥៦.០៧៦ | ២.២១៩.៣៨៩.០៩៥ | ១.៩៧៤.៣៣២.៣៦៥ |
| ការវិនិយោគហិរញ្ញវត្ថុ | ៣៥៧.៣៥៤.៧១៤ | ៥៥៥.៨៤៧.៨៦២ | ១.៤៥៩.៧៩៤.០០៧ | ២.២៨៨.៤២៥.៦៤៨ | ៣៥៧.៣៥៤.៧១៤ | ៥៥៥.៨៤៧.៨៦២ | ១.៤៥៩.៧៩៤.០០៧ | ២.២៨៨.៤២៥.៦៤៨ |
| ឥណទាន និងបុរេប្រទាន-សុទ្ធ | ៦.៦០១.៦៦៥.២៣១ | ៦.៣៧៩.៤០៦.០៩៣ | ២៦.៩៦៧.៨០២.៤៦៩ | ២៦.២៦៤.០១៤.៨៨៥ | ៦.៤៥៧.០៤៣.២៨៨ | ៦.២៤៦.២៦៩.៤៨៥ | ២៦.៣៧៧.០២១.៨៣១ | ២៥.៧១៥.៨៩១.៤៧០ |
| ទ្រព្យសកម្មផ្សេងៗ | ៨.៥៥០.៦៤៩ | ៩៤.៧៧៧.៩៦៥ | ៣៤.៩២៩.៤០១ | ១៨៤.៣៥០.៨៨២ | ៨.១៦០.៥៩១ | ៩៤.៧២៤.៨១៥ | ៣៣.៣៣៦.០១៤ | ១៨៤.១៣២.០៦៣ |
| **ទ្រព្យសកម្មហិរញ្ញវត្ថុសរុប** | ៩.៥២១.៥៣៤.៤៤៩ | ៨.៨០៥.៩៩២.១២៩ | ៣៨.៨៩៥.៤៦៨.២២៤ | ៣៦.២៥៤.២៦៩.៥៩៥ | ៩.៣៣១.៣២៧.០៣៥ | ៨.៦៤១.៤៦០.១៤៦ | ៣៨.១១៨.៤៧០.៩៣៨ | ៣៥.៥៧៦.៨៩១.៤២២ |
| **បំណុលហិរញ្ញវត្ថុ** | | | | | | | | |
| ប្រាក់បញ្ញើរបស់ធនាគារនិងស្ថាប័ន ហិរញ្ញវត្ថុផ្សេងៗ | ៤១៩.៧៩២.៦២០ | ៤១៧.៨២៦.៣៩៩ | ១.៧១៤.៨៥២.៨៥៣ | ១.៧២០.១៩១.២៨៥ | ៣៨៦.៤០៥.៩២៧ | ៣៩០.៦១១.៦៤៤ | ១.៥៧៨.៤៦៨.២១២ | ១.៦០៨.១៤៨.១៣៨ |
| ប្រាក់បញ្ញើរបស់អតិថិជន | ៦.៨០៨.០២០.៤១៩ | ៥.៩៧១.១៦៤.៣០២ | ២៧.៨១០.៧៦៣.៤១២ | ២៤.៥៨៣.២៨៣.៤៣១ | ៦.៧១៥.២៨៩.០២៥ | ៥.៨៨៩.៤៣៣.៤១០ | ២៧.៤៣១.៩៥៥.៦៦៧ | ២៤.២៤៦.៧៩៧.៣៤៩ |
| បំណុលភតិសន្យា | ៣២.៥២៧.៦៨៧ | ២៨.៤៤៨.៧៧០ | ១៣២.៨៧៥.៦០១ | ១១៧.១២៣.៥៨៦ | ៣០.៥៤៧.៣៤៨ | ២៦.៤៥៧.៦៣៥ | ១២៤.៧៨៥.៩១៧ | ១០៨.៩២៦.០៨៣ |
| ប្រាក់កម្ចី | ៨៥៩.៨១៣.៥៥០ | ៩៥៧.៣៣៥.៨៦៨ | ៣.៥១២.៣៣៨.៣៥២ | ៣.៩៤១.៣៥១.៧៦៩ | ៨៤៣.៤១៨.៥៩១ | ៩៤៤.២៧៥.៨៥៧ | ៣.៤៤៥.៣៦៤.៩៤៤ | ៣.៨៨៧.៥៨៣.៧០៣ |
| បំណុលបន្ទាប់បន្សំ | ១១៧.០៥៣.៨៨២ | ១២៧.៧៦២.៣២៨ | ៤៧៨.១៦៥.១០៨ | ៥២៥.៩៩៧.៥០៤ | ១១៧.០៥៣.៨៨២ | ១២៧.៧៦២.៣២៨ | ៤៧៨.១៦៥.១០៨ | ៥២៥.៩៩៧.៥០៤ |
| បំណុលផ្សេងៗ | ៤៣.៥៩១.០០៨ | ៩៥.៨៣០.២១៥ | ១៧៨.០៦៩.២៦៨ | ៣៩៤.៥៣២.៩៩៥ | ៤២.៤៨៩.៩១៨ | ៩៥.៥៩៣.០៩៣ | ១៧៣.៥៧១.៣១៥ | ៣៩៣.៥៥៦.៧៦៤ |
| **បំណុលហិរញ្ញវត្ថុសរុប** | ៨.២៨០.៧៩៩.១៦៦ | ៧.៥៩៨.៣៦៧.៨៨២ | ៣៣.៨២៧.០៦៤.៥៩៤ | ៣១.២៨២.៤៨០.៥៧០ | ៨.១៣៥.២០៤.៦៩១ | ៧.៤៧៤.១៣៣.៩៦៧ | ៣៣.២៣២.៣១១.១៦៣ | ៣០.៧៧១.០០៩.៥៤១ |
| **ឧបករណ៍ហិរញ្ញវត្ថុសុទ្ធ** | ១.២៤០.៧៣៥.២៨៣ | ១.២០៧.៦២៤.២៤៧ | ៥.០៦៨.៤០៣.៦៣០ | ៤.៩៧១.៧៨៩.០២៥ | ១.១៩៦.១២២.៣៤៤ | ១.១៦៧.៣២៦.១៧៩ | ៤.៨៨៦.១៥៩.៧៧៥ | ៤.៨០៥.៨៨១.៨៨១ |

# ធនាគារ អេស៊ីលីដា ភីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និង សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់

## ៣៨. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

(ខ) គោលបំណង និង គោលការណ៍ (ត)

ខ. ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុត្រូវបានវាស់វែងតាមតម្លៃសមស្រប

| | សម្ព័ន្ធធនាគារ | | | | ធនាគារ | | | |
|---|---|---|---|---|---|---|---|---|
| | ២០២៣ | ២០២២ | ២០២៣ | ២០២២ | ២០២៣ | ២០២២ | ២០២៣ | ២០២២ |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៥) | ពាន់រៀល (កំណត់សម្គាល់ ៥) | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៥) | ពាន់រៀល (កំណត់សម្គាល់ ៥) |
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | | | | | | | |
| ការវិនិយោគហិរញ្ញវត្ថុ | ១៨៩.៦៧០ | ១៨៩.៦៧០ | ៧៧៤.៨០២ | ៧៨០.៨៧១ | ១៨៩.៦៧០ | ១៨៩.៦៧០ | ៧៧៤.៨០២ | ៧៨០.៨៧១ |
| ឧបករណ៍ហិរញ្ញវត្ថុនិស្សន្ទ | ៥.៧៤៦.៦៨៦ | ៩.៦៣០.៥៩៣ | ២៣.៤៧៥.២១២ | ៣៩.៦៤៩.១៥១ | ៥.៧៤៦.៦៨៦ | ៩.៦៣០.៥៩៣ | ២៣.៤៧៥.២១២ | ៣៩.៦៤៩.១៥១ |
| **ទ្រព្យសកម្មហិរញ្ញវត្ថុសរុប** | ៥.៩៣៦.៣៥៦ | ៩.៨២០.២៦៣ | ២៤.២៥០.០១៤ | ៤០.៤៣០.០២២ | ៥.៩៣៦.៣៥៦ | ៩.៨២០.២៦៣ | ២៤.២៥០.០១៤ | ៤០.៤៣០.០២២ |
| **ឧបករណ៍ហិរញ្ញវត្ថុសុទ្ធ** | ៥.៩៣៦.៣៥៦ | ៩.៨២០.២៦៣ | ២៤.២៥០.០១៤ | ៤០.៤៣០.០២២ | ៥.៩៣៦.៣៥៦ | ៩.៨២០.២៦៣ | ២៤.២៥០.០១៤ | ៤០.៤៣០.០២២ |

# ធនាគារ អេស៊ីលីដា ភីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និង សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់

## ៣៨. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### ៣៨.១ ហានិភ័យឥណទាន

ហានិភ័យឥណទាន គឺជាហានិភ័យជាសក្តានុពល ដែលភាគីម្ខាងទៀតនៃកិច្ចសន្យា ខកខានក្នុងការបំពេញកាតព្វកិច្ចទូទាត់សងរបស់ខ្លួនអនុលោមតាមលក្ខខណ្ឌដែលបានព្រមព្រៀងគ្នា។ ទន្ទឹមនឹងឥណទាន គឺជាប្រភពសំខាន់បំផុតនៃហានិភ័យឥណទានប្រភពផ្សេងទៀតនៃហានិភ័យឥណទាន ដែលអាចកើតមានតាមរយៈសកម្មភាពប្រតិបត្តិការរបស់សម្ព័ន្ធធនាគារ និងធនាគារ រួមមាន នៅក្នុងបញ្ជិកាធនាគារ (Banking Book) និងបញ្ជិកាជួញដូរ (Trading Book) ទាំងក្នុងនិងក្រៅតារាងតុល្យការ។ សម្ព័ន្ធធនាគារ និងធនាគារ អាចប្រឈមនឹងហានិភ័យឥណទានលើឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀតក្រៅពីឥណទានដូចជាការធ្វើស៊ីការ (Acceptances) ហិរញ្ញប្បទានពាណិជ្ជកម្ម ការសន្យាផ្តល់ឥណទាន និងលិខិតធានាធនាគារ ប្រតិបត្តិការអន្តរធនាគារ ប្រតិបត្តិការទូទាត់ ប្រតិបត្តិការប្តូររូបិយប័ណ្ណបរទេស មូលបត្រប៉ំណុល មូលបត្រកម្មសិទ្ធិ និងឧបករណ៍ហិរញ្ញវត្ថុនិស្សន្ទផ្សេងៗទៀត។

គោលការណ៍ហានិភ័យឥណទាន៖

- ក្រុមប្រឹក្សាភិបាលទទួលស្គាល់ថា ឥណទាន គឺជាប្រភពដ៏សំខាន់នៃប្រាក់ចំណេញរបស់សម្ព័ន្ធធនាគារ និងធនាគារ តែផ្ទុយទៅវិញ ឥណទាន ក៏បង្កឱ្យមាននូវហានិភ័យនៃការខាតបង់ដ៏ធ្ងន់ធ្ងរផងដែរ។
- ក្រុមប្រឹក្សាភិបាល យល់ថាការផ្តល់ឥណទានទៅកាន់ចំណែកទីផ្សារតូចៗបានផ្តល់គោលនយោបាយមានស្រាប់ដែលត្រូវបានអនុវត្តត្រឹមត្រូវ ដូចជាការផ្តល់កម្ចីឥណទាន ខ្នាតតូច គឺទទួលរងនូវហានិភ័យឥណទាន ក្នុងកម្រិតទាបជាងការផ្តល់កម្ចីឥណទានដែលមានទំហំធំៗ។ ក្រុមប្រឹក្សាភិបាលយល់ថា តុល្យភាពហានិភ័យ និងចំណូលដែលជាទីពេញចិត្ត គឺការផ្តល់ឥណទានខ្នាតតូចនេះ និងព្រមទាំងបានចាត់ទុកថា ឥណទានខ្នាតតូចទាំងនេះ ជាផលិតផលស្នូលរបស់សម្ព័ន្ធធនាគារ និង ធនាគារផងដែរ។
- ក្រុមប្រឹក្សាភិបាល យល់ថាថ្នាក់គ្រប់គ្រងមានសិទ្ធិគ្រប់គ្រាន់ក្នុងការកែតម្រូវ ផ្លាស់ប្តូរតាមស្ថានភាពជាក់ស្តែងនូវការអភិវឌ្ឍផលិតផល ឬខ្សែសង្វាក់ផលិតផលដែលមានស្រាប់ប៉ុន្តែខ្សែសង្វាក់ផលិតផលថ្មីគឺតម្រូវឱ្យមានការអនុម័តពីក្រុមប្រឹក្សាភិបាល។
- ការទទួលខុសត្រូវប្រចាំថ្ងៃសម្រាប់ហានិភ័យឥណទាន គឺជាការទទួលខុសត្រូវរបស់អ្នកគ្រប់គ្រងជាន់ខ្ពស់នៃនាយកដ្ឋានគ្រប់គ្រងសេវាឥណទាន និងសាខា។
- ហានិភ័យឥណទានគឺត្រូវបានវាស់វែងជាប្រចាំ ដោយការគណនាការខាតបង់ឥណទានរំពឹងទុក ("ECL") តាមរយៈប្រូបាប៊ីលីតេនៃការខកខានសងត្រឡប់ ការខាតបង់ដែលបណ្តាលមកពីការខកខានសងត្រឡប់ ("LGD") របស់អតិថិជន ដោយផ្អែកទៅលើចំណាត់ថ្នាក់ឥណទាន (Credit Scoring) ដែលបានដាក់ឱ្យអនុវត្តប្រើប្រាស់។

## ៣៨. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### ៣៨.១ ហានិភ័យឥណទាន (ត)

គោលការណ៍ហានិភ័យឥណទាន (ត)

- ក្រុមប្រឹក្សាភិបាលតម្រូវថាហានិភ័យឥណទានគួរតែត្រូវបានបំបែក ទៅតាមវិស័យផ្សេងៗ (ដូចជា វិស័យពាណិជ្ជកម្ម កសិកម្ម សេវាកម្ម ឧស្សាហកម្ម និង ហេដ្ឋារចនាសម្ព័ន្ធជាដើម...) និងផលិតផលផ្សេងទៀត ដើម្បីចៀសវាងការប្រឈមផលប៉ះពាល់ធ្ងន់ធ្ងរពីវិស័យជាក់លាក់មួយ។
- ហានិភ័យជាប្រព័ន្ធ គឺជាហានិភ័យដែលកើតឡើងដោយសារការខូចខាត ឬប៉ះពាល់ជាប្រព័ន្ធ នៅក្នុងវិស័យហិរញ្ញវត្ថុទាំងមូល។ ក្រុមប្រឹក្សាភិបាលយល់ឃើញថា ហានិភ័យឥណទានទៅលើដៃគូភាគី ស្ថាប័នហិរញ្ញវត្ថុគួរតែជាកម្មវត្ថុនៃការវាយតម្លៃដ៏ប្រុងប្រយ័ត្ន និងត្រួតពិនិត្យដូចទៅនឹងទម្រង់នៃការផ្តល់កម្ចីឥណទានដទៃទៀត ហើយកម្រិតកំណត់ គួរតែត្រូវបានធ្វើឡើង ដើម្បីការពារយ៉ាងគ្រប់គ្រាន់ចំពោះសម្ព័ន្ធធនាគារ និងធនាគារពីហានិភ័យជាប្រព័ន្ធ។

*កម្រិតកំណត់ផ្ទៃក្នុង នៃហានិភ័យឥណទាន*

កម្រិតកំណត់ផ្ទៃក្នុង លើផលិតផលឥណទាន គួរតែបង្កើតឡើងដោយគណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងបច្ចេកវិទ្យាព័ត៌មាននៃក្រុមប្រឹក្សាភិបាល ("BRIC") និងមានការអនុម័តដោយក្រុមប្រឹក្សាភិបាល។ កម្រិតកំណត់ផ្ទៃក្នុង ត្រូវបានបង្កើត និងកំណត់ដោយស្របទៅតាមកម្រិតរីសអាប់ភែថាយ (Risk Appetite) នៃក្រុមប្រឹក្សាភិបាល។

នាយកដ្ឋានគ្រប់គ្រងហានិភ័យត្រូវត្រួតពិនិត្យជាប្រចាំ ទៅលើរាល់កម្រិតកំណត់ផ្ទៃក្នុង ដែលបានកំណត់ និងអនុម័តដោយក្រុមប្រឹក្សាភិបាល និងផ្តល់អនុសាសន៍ទៅលើការផ្លាស់ប្តូរផ្សេងៗប្រសិនបើចាត់ទុកថាជាការចាំបាច់។

ដើម្បីរក្សាកំណើនឥណទាន ដោយប្រុងប្រយ័ត្ន និងសមស្រប ក៏ដូចជាដើម្បីរក្សាគុណភាពឥណទានកម្រិតកំណត់ផ្សេងៗបានកំពុងដាក់ទៅលើផលិតផលឥណទាន និងត្រូវអនុវត្តតាមយ៉ាងខ្ជាប់ខ្ជួនដូចខាងក្រោមៈ

- អនុបាតហានិភ័យឥណទាន (Loan Exposure Ratio) បានកំណត់ចំនួនសរុបនៃឥណទានមានសំពៀតឥណទានដែលខកខានសងធំជាងសាមសិបថ្ងៃ ដកនឹងសំវិធានធនសម្រាប់ឥណទានបាត់បង់ចែកជាមួយមូលនិធិទ្រព្យ-សម្បត្តិសុទ្ធ អនុបាតនេះ ត្រូវតិចជាង ២៥%។
- កម្រិតកំណត់ ពិដានឥណទាន (Ceilings) ចំពោះវិស័យផ្សេងៗ និងផលិតផល ត្រូវបានកំណត់ ដើម្បីការពារហានិភ័យប្រមូលផ្តុំ។
- សំពៀតឥណទានអតិបរមាសរុប (Maximum Exposure) ចំពោះអតិថិជនម្នាក់ ឬក្រុមអតិថិជន ត្រូវបានកំណត់កម្រិតរហូតដល់ ៥% នៃមូលនិធិទ្រព្យសម្បត្តិសុទ្ធ។
- កម្រិតកំណត់ផ្សេងៗទៀតចំពោះ ស្ថាប័នហិរញ្ញវត្ថុដែលជាសមភាគី។

# ធនាគារ អេស៊ីលីដា ភីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)**
**នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និង សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់**

## ៣៨. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### ៣៨.១ ហានិភ័យឥណទាន (ត)

(ក) ការគ្រប់គ្រងហានិភ័យឥណទាន

ក្រុមប្រឹក្សាភិបាល បានផ្តល់ការទទួលខុសត្រូវក្នុងការត្រួតពិនិត្យទៅលើហានិភ័យឥណទានទៅគណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងបច្ចេកវិទ្យាព័ត៌មាននៃក្រុមប្រឹក្សាភិបាល។ នាយកដ្ឋានឥណទាន ទទួលខុសត្រូវលើការគ្រប់គ្រងហានិភ័យឥណទាន ដូចមានចែងដូចខាងក្រោម៖

- ការបែងចែកតួនាទីដាច់ដោយឡែករវាងអ្នកដែលពាក់ព័ន្ធក្នុងការប្រាស្រ័យជាមួយអតិថិជន ដែលដាក់ពាក្យសុំខ្ចីឥណទាន និង អ្នកដែលពាក់ព័ន្ធក្នុងការអនុម័តឥណទាន។
- ការបែងចែកតួនាទីដាច់ដោយឡែករវាងអ្នកដែលពាក់ព័ន្ធក្នុងការប្រាស្រ័យជាមួយអតិថិជនដោយផ្ទាល់ និង អ្នកទទួលខុសត្រូវក្នុងការគ្រប់គ្រងឥណទាន។
- គោលការណ៍នៃការអនុម័តពីរលំដាប់ថ្នាក់ផ្សេងគ្នា ដើម្បីធានាឱ្យមានតុល្យភាពនៃអត្ថប្រយោជន៍របស់អតិថិជន និងកម្មវត្ថុនៅក្នុងដំណើរការវាយតម្លៃហានិភ័យ។
- ការរៀបចំឯកសារបានព្រមព្រៀងជាមួយអតិថិជនឱ្យបានគ្រប់គ្រាន់ និងទាន់ពេលវេលា រួមជាមួយព័ត៌មានដែលត្រូវការទាំងអស់ ដែលទាក់ទងនឹងដំណើរការការវាយតម្លៃ និងត្រួតពិនិត្យឥណទាន។
- ប្រព័ន្ធត្រួតពិនិត្យឥណទាន ដែលមានការប្រុងប្រយ័ត្ន គួបផ្សំនឹងការពិនិត្យសមាយិកភាពដែលអាចកំណត់សម្គាល់សញ្ញាណទាន់ពេលនូវព័ត៌មានពាក់ព័ន្ធនឹងការគ្រប់គ្រងហានិភ័យ។
- ការត្រួតពិនិត្យដោយឯករាជ្យ ដើម្បីធានាឱ្យមាននូវអនុលោមភាពទៅតាមនីតិវិធី និងនិយ័តកម្មទាក់ទងនឹងដំណើរការឥណទាន (formal control) និងត្រួតពិនិត្យតាមដានគុណភាពទាក់ទងនឹងហានិភ័យ និងការត្រួត-ពិនិត្យឥណទានឱ្យបានទាន់ពេលវេលា (material control)។
- សម្ព័ន្ធធនាគារ និងធនាគារ នឹងរក្សាឱ្យបានល្អនូវសមតុល្យឥណទានតាមវិស័យផ្សេងៗដូចជាវិស័យឧស្សាហកម្ម តំបន់ភូមិសាស្ត្រ រូបិយប័ណ្ណ និងទំហំឥណទាន។
- ការវិភាគឥណទានធ្វើឡើងដោយផ្តោតសំខាន់លើសមត្ថភាពអតិថិជន និងឆន្ទៈរបស់អតិថិជនក្នុងការសងឥណទានតាមរយៈការវាយតម្លៃពីអត្តចរិត និងលំហូរសាច់ប្រាក់ និងការអនុវត្តតាម Green-Lining Methodology។

សំពៀតឥណទានអតិបរមាសរុបរបស់សម្ព័ន្ធធនាគារ និងធនាគារដែលផ្តល់ឱ្យអតិថិជនម្នាក់ ឬក្រុមអតិថិជនតែមួយ (អត្តគាហកតែមួយ) មិនត្រូវលើស ៥% នៃទ្រព្យសម្បត្តិសុទ្ធរបស់ធនាគារ។ “សំពៀតឥណទាន” (Exposure) គឺរួមមានបរិមាណសរុបនៃ (i) ចំនួនទឹកប្រាក់នៃទ្រព្យរបស់អ្នកខ្ចី ដែលអ្នកខ្ចីនោះជាកូនបំណុល (ii) ប្រាក់ដែលអ្នកខ្ចីជំពាក់ (ឥណទេយ្យ) តាមរយៈការផ្តល់ហិរញ្ញប្បទាន ឬឥណទានទៅឱ្យ ឬជំនួសឱ្យបុគ្គលនោះ ដែលរួមមានដូចជាការធានាបំណុល លិខិតឥណទាន និងឧបករណ៍និស្សន្ទ (Derivatives)។

## ៣៨. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### ៣៨.១ ហានិភ័យឥណទាន (ត)

#### (ខ) កម្រិតកំណត់ផ្ទៃក្នុង និង គោលនយោបាយកាត់បន្ថយហានិភ័យ

សម្ព័ន្ធធនាគារ និងធនាគារធ្វើប្រតិបត្តិការ និងផ្តល់ឥណទាន និងបុរេប្រទានជូនអតិថិជនជាឯកត្តជន ឬ សហគ្រាសនានា នៅក្នុងព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងសាធារណរដ្ឋសហភាព មីយ៉ាន់ម៉ា។ សម្ព័ន្ធធនាគារ និងធនាគារគ្រប់គ្រងកម្រិតកំណត់ និងហានិភ័យឥណទានប្រមូលផ្តុំ នៅពេលដែលហានិភ័យត្រូវបានកំណត់អត្តសញ្ញាណ និងរកឃើញ។ ឥណទានធំ (Large Exposure) ត្រូវបានកំណត់និយមន័យដោយធនាគារជាតិ នៃ កម្ពុជា ថាជាចំនួនសរុបនៃឥណទាន ឬការសន្យាតាមហត្ថលេខាដែលកើតចេញពីប្រតិបត្តិការរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុមួយ ជាមួយនឹងអត្ថគាហកតែមួយ ដែលមានចំនួនទឹកប្រាក់លើសពីដប់ភាគរយ ១០% នៃមូលនិធិផ្ទាល់សុទ្ធរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនោះ។

យោងតាមលក្ខខណ្ឌនៃប្រកាសលេខ ធ៧-០៦-២២៦ប្រ.ក. របស់ធនាគារជាតិ នៃ កម្ពុជា តម្រូវឱ្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ត្រូវរក្សាជានិច្ចនូវអនុបាតឥណទានធំសរុប ដែលកើតចេញពីប្រតិបត្តិការជាមួយអត្ថគាហកតែមួយមិនឱ្យលើសពី ២០%នៃមូលនិធិផ្ទាល់សុទ្ធរបស់របស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។ ហើយត្រូវរក្សាឥណទានធំៗសរុបមិនត្រូវឱ្យលើស ៣០០% នៃមូលនិធិផ្ទាល់សុទ្ធរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុឡើយ។

យោងតាមលិខិតលេខ ២៩៦ របស់ធនាគារជាតិ នៃ ឡាវ តម្រូវឱ្យធនាគារ អេស៊ីលីដា ឡាវ លីមីធីត ត្រូវរក្សា ជានិច្ចនូវអនុបាតអតិបរមា ដែលកើតចេញពីប្រតិបត្តិការជាមួយអត្ថគាហកតែមួយមិនឱ្យលើសពី ២៥% មូលនិធិផ្ទាល់សុទ្ធរបស់ខ្លួន។ ហើយត្រូវរក្សាអនុបាតឥណទានធំសរុបមិនត្រូវឱ្យលើស ៥០០% នៃមូលនិធិផ្ទាល់សុទ្ធរបស់ខ្លួន។ យ៉ាងណាមិញ មិនមានតម្រូវការនៃអនុបាតឥណទានធំពីនាយកដ្ឋានគ្រប់គ្រង បទប្បញ្ញត្តិហិរញ្ញវត្ថុនៃប្រទេសមីយ៉ាន់ម៉ា សម្រាប់ស្ថាប័នមីក្រូ-ហិរញ្ញវត្ថុ អេស៊ីលីដា មីយ៉ាន់ម៉ាឡើយ។

សម្ព័ន្ធធនាគារ និងធនាគារបានដាក់ឱ្យប្រើប្រាស់គោលការណ៍នានា សម្រាប់ការអនុវត្ត និងដើម្បីកាត់បន្ថយហានិភ័យឥណទាន។ ការកាត់បន្ថយហានិភ័យដែលត្រូវបានអនុវត្តទូទៅ និងមានប្រសិទ្ធភាពបំផុតក្នុងចំណោមគោលការណ៍ទាំងអស់ គឺការធានាដោយដាក់ទ្រព្យធានាលើឥណទាន និងបុរេប្រទាន។ សម្ព័ន្ធធនាគារ និងធនាគារអនុវត្តគោលការណ៍ណែនាំស្តីពី ការទទួលយកទ្រព្យធានាដោយផ្អែកតាមចំណាត់ថ្នាក់ ឬការកាត់បន្ថយហានិភ័យឥណទាន។ ប្រភេទនៃទ្រព្យធានាសំខាន់ៗដើម្បីធានាឥណទាន និងបុរេប្រទាន មានដូចជា៖

- ទ្រព្យធានាជាទ្រព្យសម្បត្តិក្នុងលក្ខណៈជាលំនៅដ្ឋាន (មានដីធ្លី អគារ និង ទ្រព្យសម្បត្តិផ្សេងៗ)
- កម្រៃផ្សេងៗលើទ្រព្យសកម្មក្នុងអាជីវកម្ម ដូចជាដីធ្លី អគារ និង
- សាច់ប្រាក់ក្នុងទម្រង់ជាប្រាក់បញ្ញើមានកម្រិត។

# ធនាគារ អេស៊ីលីដា ភីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)**
**នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និង សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់**

## ៣៨. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### ៣៨.១ ហានិភ័យឥណទាន (ត)

(គ) ការប្រឈមហានិភ័យឥណទានអតិបរមាដោយមិនគិតពីទ្រព្យធានា ឬការកាត់បន្ថយហានិភ័យឥណទានផ្សេងៗ

ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុដែលបានឆ្លុះបញ្ចាំងនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ទំហំហានិភ័យឥណទាន គឺស្មើនឹងតម្លៃយោងរបស់វា។ ចំពោះកិច្ចសន្យាធានាហិរញ្ញវត្ថុ និងកិច្ចសន្យាផ្សេងៗ ដែលមានលក្ខណៈស្រដៀងគ្នា ទំហំហានិភ័យឥណទាន គឺស្មើនឹងចំនួនទឹកប្រាក់អតិបរមាដែលសម្ព័ន្ធធនាគារ និងធនាគារ នឹងត្រូវទូទាត់ ប្រសិនបើសមភាគីទាមទារការអនុវត្តលិខិតធានាទាំងនោះ។ ចំណែកឯឥណទានដែលទាក់ទងនឹងកិច្ចសន្យា និងយថាភាព ដែលមិនអាចបដិសេធបាន (នៅពេញអាយុកាលនៃកិច្ចសន្យានេះ) ជាទូទៅ គឺស្មើនឹងចំនួនទឹកប្រាក់ទាំងអស់ដែលមានក្នុងកិច្ចសន្យា។

# ធនាគារ អេស៊ីលីដា ភីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និង សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់

## ៣៨. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### ៣៨.១ ហានិភ័យឥណទាន (ត)

(គ) ការប្រឈមហានិភ័យឥណទានអតិបរមាដោយមិនគិតពីទ្រព្យធានា ឬ ការកាត់បន្ថយហានិភ័យឥណទានផ្សេងៗ (ត)

| | សម្ព័ន្ធធនាគារ | | | | ធនាគារ | | | |
|---|---|---|---|---|---|---|---|---|
| | ២០២៣ ដុល្លារអាមេរិក | ២០២២ ដុល្លារអាមេរិក | ២០២៣ ពាន់រៀល (កំណត់សម្គាល់ ៥) | ២០២២ ពាន់រៀល (កំណត់សម្គាល់ ៥) | ២០២៣ ដុល្លារអាមេរិក | ២០២២ ដុល្លារអាមេរិក | ២០២៣ ពាន់រៀល (កំណត់សម្គាល់ ៥) | ២០២២ ពាន់រៀល (កំណត់សម្គាល់ ៥) |
| **ការប្រឈមឥណទានទាក់ទិននឹងទ្រព្យសកម្មហិរញ្ញវត្ថុក្នុងតារាងតុល្យការ៖** | | | | | | | | |
| សាច់ប្រាក់ក្នុងដៃ | ៤៩៥.៧៩៣.៥៦៨ | ៤៩៧.០២៧.០៤១ | ២.០២៥.៣១៦.៧២៥ | ២.០៤៦.២៦០.៣២៨ | ៤៨៦.៥៨៤.៣១៧ | ៤៨៦.៦៦៥.៤៨៣ | ១.៩៨៧.៦៩៦.៩៣៥ | ២.០០៣.៦០១.៧៩៤ |
| ប្រាក់បញ្ញើនៅធនាគារផ្សេងៗ-សុទ្ធ | ១.៥០៩.៥៤៣.១៧៨ | ៨៤៦.៦០២.១៧៥ | ៦.១៦៦.៤៨៣.៨៨២ | ៣.៤៨៥.៤៦១.១៥៤ | ១.៤៧៨.៨៨២.០២១ | ៨២៨.៣៩៦.៤២៥ | ៦.០៤១.២៣៣.០៥៦ | ៣.៤១០.៥០៨.០៨២ |
| ប្រាក់បញ្ញើតាមច្បាប់ | ៥៤៨.៦២៧.១០៩ | ៤៨២.៣៣០.៩៩៣ | ២.២៤១.១៤១.៧៤០ | ១.៩៨៥.៧៥៦.៦៩៨ | ៥៤៣.៣០២.១០៤ | ៤៧៩.៥៥៦.០៧៦ | ២.២១៩.៣៨៩.០៩៥ | ១.៩៧៤.៣៣២.៣៦៥ |
| ការវិនិយោគហិរញ្ញវត្ថុ | ៣៥៧.៥៤៤.៣៨៤ | ៥៥៦.០៣៧.៥៣២ | ១.៤៦០.៥៦៨.៨០៩ | ២.២៨៩.២០៦.៥១៩ | ៣៥៧.៥៤៤.៣៨៤ | ៥៥៦.០៣៧.៥៣២ | ១.៤៦០.៥៦៨.៨០៩ | ២.២៨៩.២០៦.៥១៩ |
| ឥណទាន និងបុរេប្រទាន-សុទ្ធ | ៦.៦០១.៦៦៥.២៣១ | ៦.៣៧៩.៤០៦.០៩៣ | ២៦.៩៦៧.៨០២.៤៦៩ | ២៦.២៦៤.០១៤.៨៨៥ | ៦.៤៥៧.០៤៣.២៨៨ | ៦.២៤៦.២៦៩.៤៨៥ | ២៦.៣៧៧.០២១.៨៣១ | ២៥.៧១៥.៨៩១.៤៧០ |
| ឧបករណ៍ហិរញ្ញវត្ថុនិស្សន្ទ | ៥.៧៤៦.៦៨៦ | ៩.៦៣០.៥៩៣ | ២៣.៤៧៥.២១២ | ៣៩.៦៤៩.១៥១ | ៥.៧៤៦.៦៨៦ | ៩.៦៣០.៥៩៣ | ២៣.៤៧៥.២១២ | ៣៩.៦៤៩.១៥១ |
| ទ្រព្យសកម្មផ្សេងៗ | ៨.៥៥០.៦៤៩ | ៤៤.៧៧៧.៩៦៥ | ៣៤.៩២៩.៤០១ | ១៨៤.៣៥០.៨៨២ | ៨.១៦០.៥៩១ | ៤៤.៧២៤.៨១៥ | ៣៣.៣៣៦.០១៤ | ១៨៤.១៣២.០៦៣ |
| | ៩.៥២៧.៤៧០.៨០៥ | ៨.៨១៥.៨១២.៣៩២ | ៣៨.៩១៩.៧១៨.២៣៨ | ៣៦.២៩៤.៦៩៩.៦១៧ | ៩.៣៣៧.២៦៣.៣៩១ | ៨.៦៥១.២៨០.៤០៩ | ៣៨.១៤២.៧២០.៩៥២ | ៣៥.៦១៧.៣២១.៤៤៤ |
| **ការប្រឈមឥណទានទាក់ទិននឹងសមាសធាតុក្រៅតារាងតុល្យការ៖** | | | | | | | | |
| កិច្ចសន្យាផ្តល់ឥណទានដែលមិនបានប្រើប្រាស់ | ២០៩.៨៥៤.៦៦៩ | ១៧៥.១៣២.៤៨៩ | ៨៥៧.២៥៦.៣២៣ | ៧២១.០២០.៤៥៧ | ២០៩.៤០៥.០៥២ | ១៧៤.៧១៦.៧៣១ | ៨៥៥.៤១៩.៦៣៧ | ៧១៩.៣០៨.៧៨២ |
| លិខិតធានារបស់ធនាគារ | ៦៧.០១៤.០០៥ | ៦២.៨៧៣.៣២៩ | ២៧៣.៧៥២.២១០ | ២៥៨.៨៤៩.៤៩៥ | ៦៦.៨៨០.៩២៣ | ៦២.៧៤១.៩៨៤ | ២៧៣.២០៨.៥៧០ | ២៥៨.៣០៨.៧៤៨ |
| លិខិតឥណទាន | ២.៣០៣.០៦២ | ៩.១៧៦.១៣០ | ៩.៤០៨.០០៨ | ៣៧.៧៧៨.១២៧ | ២.៣០៣.០៦២ | ៩.១៧៦.១៣០ | ៩.៤០៨.០០៨ | ៣៧.៧៧៨.១២៧ |
| | ២៧៩.១៧១.៧៣៦ | ២៤៧.១៨១.៩៤៨ | ១.១៤០.៤១៦.៥៤១ | ១.០១៧.៦៤៨.០៧៩ | ២៧៨.៥៨៩.០៣៧ | ២៤៦.៦៣៤.៨៤៥ | ១.១៣៨.០៣៦.២១៥ | ១.០១៥.៣៩៥.៦៥៧ |
| **ហានិភ័យឥណទានអតិបរមាសរុប** | ៩.៨០៦.៦៤២.៥៤១ | ៩.០៦២.៩៩៤.៣៤០ | ៤០.០៦០.១៣៤.៧៧៩ | ៣៧.៣១២.៣៤៧.៦៩៦ | ៩.៦១៥.៨៥២.៤២៨ | ៨.៨៩៧.៩១៥.២៥៤ | ៣៩.២៨០.៧៥៧.១៦៧ | ៣៦.៦៣២.៧១៧.១០១ |

# ធនាគារ អេស៊ីលីដា ភីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និង សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់

## ៣៨. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### ៣៨.១ ហានិភ័យឥណទាន (ត)

#### (គ) ការប្រឈមហានិភ័យឥណទានអតិបរមា ដោយមិនគិតពីទ្រព្យធានា ឬ ការកាត់បន្ថយហានិភ័យឥណទានផ្សេងៗ (ត)

តារាងនៅទំព័រមុនបង្ហាញពីហានិភ័យឥណទានរបស់សម្ព័ន្ធធនាគារ និងធនាគារ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និង ឆ្នាំ២០២២ ក្នុងសេណារីយ៉ូស្ថានភាពអាក្រក់បំផុត ដោយមិនគិតពីទ្រព្យធានា ឬលិខិតធានា និងការកាត់បន្ថយហានិភ័យឥណទានផ្សេងៗទេ។ ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុក្នុងតារាងតុល្យការ ការប្រឈមហានិភ័យដែលបានបង្ហាញខាងលើគឺផ្អែកទៅលើតម្លៃយោងសុទ្ធ។

ដូចបានបង្ហាញខាងលើ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ៦៧,៣២%នៃការប្រឈមហានិភ័យ អតិបរមាសរុបចំពោះ សម្ព័ន្ធធនាគារ និង៦៧,១៥% ចំពោះធនាគារនៃការប្រឈមហានិភ័យអតិបរមាសរុបចំពោះធនាគារ គឺកើតមកពីឥណទាន និងបុរេប្រទាន (ឆ្នាំ២០២២៖ ៧០,៣៩%ចំពោះសម្ព័ន្ធធនាគារ និង ៧០,២០%ចំពោះធនាគារ) ។

អ្នកគ្រប់គ្រងមានជំនឿថា ខ្លួនមានលទ្ធភាពបន្តការគ្រប់គ្រង និងទ្រទ្រង់ហានិភ័យឥណទានរបស់សម្ព័ន្ធធនាគារ និងធនាគារ ដែលបណ្តាលមកពីឥណទាន និងបុរេប្រទាន ឱ្យស្ថិតក្នុងកម្រិតអប្បបរមា។ ហានិភ័យឥណទានសំខាន់ៗ គឺជាផលប៉ះពាល់ដែលកើតឡើងពីឥណទាន និងបុរេប្រទាន។ ដើម្បីកាត់បន្ថយផលប៉ះពាល់ពីហានិភ័យឥណទានដែលកើតឡើងពីឥណទាន និងបុរេប្រទាន រាល់ទំហំឥណទានដែលបានអនុម័ត ត្រូវតែមិនលើសពី៧៥%នៃតម្លៃដែលអាចលក់ចេញដែលបានប៉ាន់ស្មានទុករបស់វត្ថុបញ្ចាំនោះទេ លើកលែងតែឥណទានផ្សេងទៀតដែលបានអនុម័តដោយគណៈកម្មាធិការគ្រប់គ្រងឥណទាន ដែលទំហំឥណទានធៀបទៅនឹងទ្រព្យបញ្ចាំមានតម្លៃលើសពី ៧៥%។ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ប្រមាណ ៩៨,១៦% (ឆ្នាំ២០២២៖ ប្រមាណ ៩៦,៥២%) នៃឥណទាន និងបុរេប្រទានទាំងនេះត្រូវបានដាក់បញ្ចាំ។

#### (ឃ) ការប្រមូលផ្តុំទ្រព្យសកម្មហិរញ្ញវត្ថុធៀបនឹងការប្រឈមហានិភ័យឥណទាន

ការប្រមូលផ្តុំហានិភ័យឥណទានកើតឡើងនៅពេលមានភាគីដៃគូមួយចំនួន ដែលមានសកម្មភាពអាជីវកម្មប្រហាក់ប្រហែលគ្នា និងមានស្ថានភាពផ្នែកសេដ្ឋកិច្ចស្រដៀងគ្នា ដែលអាចបណ្តាលឱ្យពួកគេពុំមានលទ្ធភាពបំពេញកាតព្វកិច្ចសងបំណុលបាន នៅពេលដែលពួកគេជួបប្រទះនឹងផលប៉ះពាល់នៃបម្រែបម្រួលផ្នែកសេដ្ឋកិច្ច ឬលក្ខខណ្ឌផ្សេងៗទៀតស្រដៀងគ្នា។ សម្ព័ន្ធធនាគារ និងធនាគារ បានវិភាគលើហានិភ័យឥណទានប្រមូលផ្តុំដោយផ្អែកលើទីតាំងភូមិសាស្ត្រ និងប្រភេទអាជីវកម្មដូចមានក្នុងទំព័របន្ទាប់៖

## ៣៨. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### ៣៨.១ ហានិភ័យឥណទាន (ត)

(ឃ) ការប្រមូលផ្ដុំទ្រព្យសកម្មហិរញ្ញវត្ថុធៀបនឹងការប្រឈមហានិភ័យឥណទាន (ត)

*(i) វិភាគតាមទីតាំងភូមិសាស្ត្រ*

ការវិភាគអំពីការប្រមូលផ្ដុំហានិភ័យឥណទាន (ដោយមិនគិតពីទ្រព្យធានា ឬការកាត់បន្ថយហានិភ័យឥណទាន) ផ្អែកទៅតាមទីតាំងនៃប្រទេស ភាគីដៃគូ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និង ឆ្នាំ២០២២ មានដូចខាងក្រោម៖

| | សម្ព័ន្ធធនាគារ | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | កម្ពុជា<br>ដុល្លារអាមេរិក | បារាំង<br>ដុល្លារអាមេរិក | អាឡឺម៉ង់<br>ដុល្លារអាមេរិក | ឡាវ<br>ដុល្លារអាមេរិក | សិង្ហបុរី<br>ដុល្លារអាមេរិក | សហរដ្ឋអាមេរិក<br>ដុល្លារអាមេរិក | មីយ៉ាន់ម៉ា<br>ដុល្លារអាមេរិក | ប្រទេសផ្សេងៗ<br>ដុល្លារអាមេរិក | សរុប<br>ដុល្លារអាមេរិក |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣** | | | | | | | | | |
| **ការប្រឈមឥណទានទាក់ទិននឹងទ្រព្យសកម្មហិរញ្ញវត្ថុក្នុងតារាងតុល្យការ៖** | | | | | | | | | |
| សាច់ប្រាក់ក្នុងដៃ | ៤៨៦.៦០៤.៨៤៨ | - | - | ៨.៤៦២.៨៣០ | - | - | ៧២៥.៨៩០ | - | ៤៩៥.៧៩៣.៥៦៨ |
| ប្រាក់បញ្ញើនៅធនាគារផ្សេងៗ-សុទ្ធ | ១.៣៩០.២២៥.០៨៥ | ១.៨៨៦.៣៤២ | ១៤២.៦១៤ | ២៨.៩៩៤.៩៨៥ | ៦៦១.៥៤១ | ៧៩.១៥៤.៣៧០ | ៧១.១២៨ | ៨.៤០៧.១១៣ | ១.៥០៩.៥៤៣.១៧៨ |
| ប្រាក់បញ្ញើតាមច្បាប់ | ៥៤៣.៥៨៣.៦២២ | - | - | ៥.០៤៣.៤៨៧ | - | - | - | - | ៥៤៨.៦២៧.១០៩ |
| ការវិនិយោគហិរញ្ញវត្ថុ | ៣៥៧.៥៤៤.៣៨៤ | - | - | - | - | - | - | - | ៣៥៧.៥៤៤.៣៨៤ |
| ឥណទាន និងបុរេប្រទាន-សុទ្ធ | ៦.៤៥៧.០៤៣.២៨៨ | - | - | ១២៦.៤២២.០១៨ | - | - | ១៨.១៩៩.៩២៥ | - | ៦.៦០១.៦៦៥.២៣១ |
| ឧបករណ៍ហិរញ្ញវត្ថុនិស្សន្ទ | ៥.៧៤៦.៦៨៦ | - | - | - | - | - | - | - | ៥.៧៤៦.៦៨៦ |
| ទ្រព្យសកម្មផ្សេងៗ | ៧.៧៦១.៣៤២ | - | - | ៧៨៩.៣០៧ | - | - | - | - | ៨.៥៥០.៦៤៩ |
| | ៩.២៤៨.៥០៩.២៥៥ | ១.៨៨៦.៣៤២ | ១៤២.៦១៤ | ១៦៩.៧១២.៦២៧ | ៦៦១.៥៤១ | ៧៩.១៥៤.៣៧០ | ១៨.៩៩៦.៩៤៣ | ៨.៤០៧.១១៣ | ៩.៥២៧.៤៧០.៨០៥ |
| **ការប្រឈមឥណទានទាក់ទិននឹងសមាសធាតុក្រៅតារាងតុល្យការ៖** | | | | | | | | | |
| កិច្ចសន្យាផ្ដល់ឥណទានដែលមិនបានប្រើប្រាស់ | ២០៩.៤០៥.០៥២ | - | - | ៤៤៩.៦១៧ | - | - | - | - | ២០៩.៨៥៤.៦៦៩ |
| លិខិតធានារបស់ធនាគារ | ៦៦.៨៨០.៩២៣ | - | - | ១៣៣.០៨២ | - | - | - | - | ៦៧.០១៤.០០៥ |
| លិខិតឥណទាន | ២.៣០៣.០៦២ | - | - | - | - | - | - | - | ២.៣០៣.០៦២ |
| | ២៧៨.៥៨៩.០៣៧ | - | - | ៥៨២.៦៩៩ | - | - | - | - | ២៧៩.១៧១.៧៣៦ |
| **ការប្រឈមឥណទានអតិបរមាសរុប** | ៩.៥២៧.០៩៨.២៩២ | ១.៨៨៦.៣៤២ | ១៤២.៦១៤ | ១៧០.២៩៥.៣២៦ | ៦៦១.៥៤១ | ៧៩.១៥៤.៣៧០ | ១៨.៩៩៦.៩៤៣ | ៨.៤០៧.១១៣ | ៩.៨០៦.៦៤២.៥៤១ |
| *សមមូលនឹងពាន់រៀល (កំណត់សម្គាល់ ៥)* | ៣៨.៩១៨.១៩៦.៥២២ | ៧.៧០៥.៧០៧ | ៥៨២.៥៧៨ | ៦៩៥.៦៥៦.៤០៧ | ២.៧០២.៣៩៥ | ៣២៣.៣៤៥.៦០១ | ៧៧.៦០២.៥១២ | ៣៤.៣៤៣.០៥៧ | ៤០.០៦០.១៣៤.៧៧៩ |

## ៣៨. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### ៣៨.១ ហានិភ័យឥណទាន (ត)

(ឃ) ការប្រមូលផ្តុំទ្រព្យសកម្មហិរញ្ញវត្ថុធៀបនឹងការប្រឈមហានិភ័យឥណទាន (ត)

*(i) វិភាគតាមទីតាំងភូមិសាស្ត្រ (ត)*

| | សម្ព័ន្ធធនាគារ | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | កម្ពុជា ដុល្លារអាមេរិក | បារាំង ដុល្លារអាមេរិក | អាឡឺម៉ង់ ដុល្លារអាមេរិក | ឡាវ ដុល្លារអាមេរិក | សិង្ហបុរី ដុល្លារអាមេរិក | សហរដ្ឋអាមេរិក ដុល្លារអាមេរិក | មីយ៉ាន់ម៉ា ដុល្លារអាមេរិក | ប្រទេសផ្សេងៗ ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | | | | | | | | | |
| **ការប្រឈមឥណទានទាក់ទិននឹងទ្រព្យសកម្មហិរញ្ញវត្ថុក្នុងតារាងតុល្យការ៖** | | | | | | | | | |
| សាច់ប្រាក់ក្នុងដៃ | ៤៨៦.៧១៩.៤៧១ | - | - | ៩.៧០៥.១៥០ | - | - | ៦០២.៤២០ | - | ៤៩៧.០២៧.០៤១ |
| ប្រាក់បញ្ញើនៅធនាគារផ្សេងៗ-សុទ្ធ | ៥៦៦.៦១៨.០២៩ | ៣៥៦.០៨៤ | ៦៧៨.៧៣០ | ១៤២.១៩១.១៤២ | ១.៣៥៩.០១០ | ១២៣.៤៥៥.៣៨៦ | ៥៤.៩៧១ | ១១.៨៨៨.៨២៣ | ៨៤៦.៦០២.១៧៥ |
| ប្រាក់បញ្ញើតាមច្បាប់ | ៤៧៩.៧៩៨.៩៧១ | - | - | ២.៥៣២.០២២ | - | - | - | - | ៤៨២.៣៣០.៩៩៣ |
| ការវិនិយោគហិរញ្ញវត្ថុ | ៥៥៦.០៣៧.៥៣២ | - | - | - | - | - | - | - | ៥៥៦.០៣៧.៥៣២ |
| ឥណទាន និងបុរេប្រទាន-សុទ្ធ | ៦.២៤៦.២៦៩.៤៨៦ | - | - | ១១៧.៣៩៩.៧៣០ | - | - | ១៥.៧៣៦.៨៧៧ | - | ៦.៣៧៩.៤០៦.០៩៣ |
| ឧបករណ៍ហិរញ្ញវត្ថុនិស្សន្ទ | ៩.៦៣០.៥៩៣ | - | - | - | - | - | - | - | ៩.៦៣០.៥៩៣ |
| ទ្រព្យសកម្មផ្សេងៗ | ៤៤.៦០៥.៣០៩ | - | - | ១៧២.៦៥៦ | - | - | - | - | ៤៤.៧៧៧.៩៦៥ |
| | ៨.៣៨៩.៦៧៩.៣៩១ | ៣៥៦.០៨៤ | ៦៧៨.៧៣០ | ២៧២.០០០.៧០០ | ១.៣៥៩.០១០ | ១២៣.៤៥៥.៣៨៦ | ១៦.៣៩៤.២៦៨ | ១១.៨៨៨.៨២៣ | ៨.៨១៥.៨១២.៣៩២ |
| **ការប្រឈមឥណទានទាក់ទិននឹងសមាសធាតុក្រៅតារាងតុល្យការ៖** | | | | | | | | | |
| កិច្ចសន្យាផ្តល់ឥណទានដែលមិនបានប្រើប្រាស់ | ១៧៤.៧១៦.៧៣១ | - | - | ៤១៥.៧៥៨ | - | - | - | - | ១៧៥.១៣២.៤៨៩ |
| លិខិតធានារបស់ធនាគារ | ៦២.៧៤១.៩៨៤ | - | - | ១៣១.៣៤៥ | - | - | - | - | ៦២.៨៧៣.៣២៩ |
| លិខិតឥណទាន | ៩.១៧៦.១៣០ | - | - | - | - | - | - | - | ៩.១៧៦.១៣០ |
| | ២៤៦.៦៣៤.៨៤៥ | - | - | ៥៤៧.១០៣ | - | - | - | - | ២៤៧.១៨១.៩៤៨ |
| **ការប្រឈមឥណទានអតិបរមាសរុប** | ៨.៦៣៦.៣១៤.២៣៦ | ៣៥៦.០៨៤ | ៦៧៨.៧៣០ | ២៧២.៥៤៧.៨០៣ | ១.៣៥៩.០១០ | ១២៣.៤៥៥.៣៨៦ | ១៦.៣៩៤.២៦៨ | ១១.៨៨៨.៨២៣ | ៩.០៦២.៩៩៤.៣៤០ |
| *សមមូលនឹងពាន់រៀល (កំណត់សម្គាល់ ៥)* | ៣៥.៥៥៥.៧០៥.៧០៩ | ១.៤៦៥.៩៩៨ | ២.៧៩៤.៣៣១ | ១.១២២.០៧៩.៣០៥ | ៥.៥៩៥.០៤៤ | ៥០៨.២៦៥.៨២៤ | ៦៧.៤៩៥.២០១ | ៤៨.៩៤៦.២៨៤ | ៣៧.៣១២.៣៤៧.៦៩៦ |

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)**
**នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និង សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់**

## ៣៨. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### ៣៨.១ ហានិភ័យឥណទាន (ត)

(ឃ) ការប្រមូលផ្តុំទ្រព្យសកម្មហិរញ្ញវត្ថុធៀបនឹងការប្រឈមហានិភ័យឥណទាន (ត)

*(i) វិភាគតាមទីតាំងភូមិសាស្ត្រ (ត)*

| | ធនាគារ | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | កម្ពុជា<br>ដុល្លារអាមេរិក | បារាំង<br>ដុល្លារអាមេរិក | អាល្លឺម៉ង់<br>ដុល្លារអាមេរិក | ឡាវ<br>ដុល្លារអាមេរិក | សិង្ហបុរី<br>ដុល្លារអាមេរិក | សហរដ្ឋអាមេរិក<br>ដុល្លារអាមេរិក | មីយ៉ាន់ម៉ា<br>ដុល្លារអាមេរិក | ប្រទេសផ្សេងៗ<br>ដុល្លារអាមេរិក | សរុប<br>ដុល្លារអាមេរិក |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣** | | | | | | | | | |
| **ការប្រឈមឥណទានទាក់ទិននឹងទ្រព្យសកម្មហិរញ្ញវត្ថុក្នុងតារាងតុល្យការ៖** | | | | | | | | | |
| សាច់ប្រាក់ក្នុងដៃ | ៤៨៦.៥៨៤.៣១៧ | - | - | - | - | - | - | - | ៤៨៦.៥៨៤.៣១៧ |
| ប្រាក់បញ្ញើនៅធនាគារផ្សេងៗ-សុទ្ធ | ១.៣៩០.១៦៨.៧០៩ | ១.៨៨៦.៣៩២ | ១៩២.៦១៤ | ១៥.៨៧១ | ៦៦១.៥៩១ | ៧៩.១៥៤.៣៧០ | ៤៦.៩៣៦ | ៦.៨០៥.៦៣៨ | ១.៤៧៨.៨៨២.០២១ |
| ប្រាក់បញ្ញើតាមច្បាប់ | ៥៤៣.៣០២.១០៤ | - | - | - | - | - | - | - | ៥៤៣.៣០២.១០៤ |
| ការវិនិយោគហិរញ្ញវត្ថុ | ៣៥៧.៥៤៤.៣៨៤ | - | - | - | - | - | - | - | ៣៥៧.៥៤៤.៣៨៤ |
| ឥណទាន និងបុរេប្រទាន-សុទ្ធ | ៦.៤៥៧.០៤៣.២៨៨ | - | - | - | - | - | - | - | ៦.៤៥៧.០៤៣.២៨៨ |
| ឧបករណ៍ហិរញ្ញវត្ថុនិស្សន្ទ | ៥.៧៤៦.៦៨៦ | | | | | | | | ៥.៧៤៦.៦៨៦ |
| ទ្រព្យសកម្មផ្សេងៗ | ៧.៩១៤.០៥០ | - | - | - | - | - | ២៤៦.៥៩១ | - | ៨.១៦០.៥៩១ |
| | ៩.២៤៨.៣០៣.៥៣៨ | ១.៨៨៦.៣៩២ | ១៩២.៦១៤ | ១៥.៨៧១ | ៦៦១.៥៩១ | ៧៩.១៥៤.៣៧០ | ២៩៣.៤៧៧ | ៦.៨០៥.៦៣៨ | ៩.៣៣៧.២៦៣.៣៩១ |
| **ការប្រឈមឥណទានទាក់ទិននឹងសមាសធាតុក្រៅតារាងតុល្យការ៖** | | | | | | | | | |
| កិច្ចសន្យាផ្តល់ឥណទានដែលមិនបានប្រើប្រាស់ | ២០៩.៤០៥.០៥២ | - | - | - | - | - | - | - | ២០៩.៤០៥.០៥២ |
| លិខិតធានារបស់ធនាគារ | ៦៦.៨៨០.៩២៣ | - | - | - | - | - | - | - | ៦៦.៨៨០.៩២៣ |
| លិខិតឥណទាន | ២.៣០៣.០៦២ | - | - | - | - | - | - | - | ២.៣០៣.០៦២ |
| | ២៧៨.៥៨៩.០៣៧ | - | - | - | - | - | - | - | ២៧៨.៥៨៩.០៣៧ |
| **ការប្រឈមឥណទានអតិបរមាសរុប** | ៩.៥២៦.៨៩២.៥៧៥ | ១.៨៨៦.៣៩២ | ១៩២.៦១៤ | ១៥.៨៧១ | ៦៦១.៥៩១ | ៧៩.១៥៤.៣៧០ | ២៩៣.៤៧៧ | ៦.៨០៥.៦៣៨ | ៩.៦១៥.៨៥២.៤២៨ |
| *សមមូលនឹងពាន់រៀល (កំណត់សម្គាល់ ៥)* | ៣៨.៩១៧.៣៥៦.១៦៩ | ៧.៧០៥.៧០៧ | ៥៨២.៥៧៨ | ៦៤.៨៣៣ | ២.៧០២.៣៩៥ | ៣២៣.៣៤៥.៦០១ | ១.១៩៨.៨៥៤ | ២៧.៨០១.០៣១ | ៣៩.២៨០.៧៥៧.១៦៨ |

# ធនាគារ អេស៊ីលីដា ភីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និង សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់

## ៣៨. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### ៣៨.១ ហានិភ័យឥណទាន (ត)

(ឃ) ការប្រមូលផ្តុំទ្រព្យសកម្មហិរញ្ញវត្ថុធៀបនឹងការប្រឈមហានិភ័យឥណទាន (ត)

*(i) វិភាគតាមទីតាំងភូមិសាស្ត្រ (ត)*

| | ធនាគារ | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | កម្ពុជា<br>ដុល្លារអាមេរិក | បារាំង<br>ដុល្លារអាមេរិក | អាល្លឺម៉ង់<br>ដុល្លារអាមេរិក | ឡាវ<br>ដុល្លារអាមេរិក | សិង្ហបុរី<br>ដុល្លារអាមេរិក | សហរដ្ឋអាមេរិក<br>ដុល្លារអាមេរិក | មីយ៉ាន់ម៉ា<br>ដុល្លារអាមេរិក | ប្រទេសផ្សេងៗ<br>ដុល្លារអាមេរិក | សរុប<br>ដុល្លារអាមេរិក |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | | | | | | | | | |
| **ការប្រឈមឥណទានទាក់ទិននឹងទ្រព្យសកម្មហិរញ្ញវត្ថុក្នុងតារាងតុល្យការ៖** | | | | | | | | | |
| សាច់ប្រាក់ក្នុងដៃ | ៤៨៦.៦៦៥.៤៨៣ | - | - | - | - | - | - | - | ៤៨៦.៦៦៥.៤៨៣ |
| ប្រាក់បញ្ញើនៅធនាគារផ្សេងៗ-សុទ្ធ | ៥៦២.៤៣៩.៨៤៧ | ៣៥៦.០៨៤ | ៦៧៨.៧៣០ | ១២៩.៩៦៤.៩៧៦ | ១.៣៥៩.០១០ | ១២៣.៤៥៥.៣៨៦ | ៤៦.៧៧៦ | ១០.០៩៥.៦១៦ | ៨២៨.៣៩៦.៤២៥ |
| ប្រាក់បញ្ញើតាមច្បាប់ | ៤៧៩.៥៥៦.០៧៦ | - | - | - | - | - | - | - | ៤៧៩.៥៥៦.០៧៦ |
| ការវិនិយោគហិរញ្ញវត្ថុ | ៥៥៦.០៣៧.៥៣២ | - | - | - | - | - | - | - | ៥៥៦.០៣៧.៥៣២ |
| ឥណទាន និងបុរេប្រទាន-សុទ្ធ | ៦.២៤៦.២៦៩.៤៨៥ | - | - | - | - | - | - | - | ៦.២៤៦.២៦៩.៤៨៥ |
| ឧបករណ៍ហិរញ្ញវត្ថុនិស្សន្ទ | ៩.៦៣០.៥៩៣ | - | - | - | - | - | - | - | ៩.៦៣០.៥៩៣ |
| ទ្រព្យសកម្មផ្សេងៗ | ៤៤.៤៦៤.៩០៥ | - | - | - | - | - | ២៥៩.៩១០ | - | ៤៤.៧២៤.៨១៥ |
| | ៨.៣៨៥.០៦៣.៩២១ | ៣៥៦.០៨៤ | ៦៧៨.៧៣០ | ១២៩.៩៦៤.៩៧៦ | ១.៣៥៩.០១០ | ១២៣.៤៥៥.៣៨៦ | ៣០៦.៦៨៦ | ១០.០៩៥.៦១៦ | ៨.៦៥១.២៨០.៤០៩ |
| **ការប្រឈមឥណទានទាក់ទិននឹងសមាសធាតុក្រៅតារាងតុល្យការ៖** | | | | | | | | | |
| កិច្ចសន្យាផ្តល់ឥណទានដែលមិនបានប្រើប្រាស់ | ១៧៤.៧១៦.៧៣១ | - | - | - | - | - | - | - | ១៧៤.៧១៦.៧៣១ |
| លិខិតធានារបស់ធនាគារ | ៦២.៧៤១.៩៨៤ | - | - | - | - | - | - | - | ៦២.៧៤១.៩៨៤ |
| លិខិតឥណទាន | ៩.១៧៦.១៣០ | - | - | - | - | - | - | - | ៩.១៧៦.១៣០ |
| | ២៤៦.៦៣៤.៨៤៥ | - | - | - | - | - | - | - | ២៤៦.៦៣៤.៨៤៥ |
| **ការប្រឈមឥណទានអតិបរមាសរុប** | ៨.៦៣១.៦៩៨.៧៦៦ | ៣៥៦.០៨៤ | ៦៧៨.៧៣០ | ១២៩.៩៦៤.៩៧៦ | ១.៣៥៩.០១០ | ១២៣.៤៥៥.៣៨៦ | ៣០៦.៦៨៦ | ១០.០៩៥.៦១៦ | ៨.៨៩៧.៩១៥.២៥៤ |
| *សមមូលនឹងពាន់រៀល (កំណត់សម្គាល់ ៥)* | ៣៥.៥៣៦.៧០៣.៨២១ | ១.៤៦៥.៩៩៨ | ២.៧៩៤.៣៣១ | ៥៣៥.០៦៥.៨០៦ | ៥.៥៩៥.០៤៤ | ៥០៨.២៦៥.៨២៤ | ១.២៦២.៦២៦ | ៤១.៥៦៣.៦៥១ | ៣៦.៦៣២.៧១៧.១០១ |

## ៣៨. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### ៣៨.១ ហានិភ័យឥណទាន (ត)

(ឃ) ការប្រមូលផ្តុំទ្រព្យសកម្មហិរញ្ញវត្ថុធៀបនឹងការប្រឈមហានិភ័យឥណទាន (ត)

*(ii) វិភាគតាមប្រភេទអាជីវកម្ម*

ការវិភាគអំពីការប្រមូលផ្តុំហានិភ័យឥណទាន (ដោយមិនគិតពីទ្រព្យធានា ឬការកាត់បន្ថយហានិភ័យឥណទាន) ទៅតាមតម្លៃយោង នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និងឆ្នាំ២០២២ ផ្អែកទៅតាមប្រភេទអាជីវកម្មរបស់ភាគីដៃគូមានដូចខាងក្រោម៖

| | សម្ព័ន្ធធនាគារ | | | | | | | |
|---|---|---|---|---|---|---|---|---|
| | គ្រឹះស្ថានហិរញ្ញវត្ថុ ដុល្លារអាមេរិក | ការលក់ដុំ និង លក់រាយ ដុល្លារអាមេរិក | សេវាកម្ម ដុល្លារអាមេរិក | គេហដ្ឋាន ដុល្លារអាមេរិក | ផលិតកម្ម ដុល្លារអាមេរិក | កសិកម្ម ដុល្លារអាមេរិក | អាជីវកម្មផ្សេងៗ ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣** | | | | | | | | |
| **ការប្រឈមឥណទានទាក់ទិននឹងទ្រព្យសកម្មហិរញ្ញវត្ថុក្នុងតារាងតុល្យការ៖** | | | | | | | | |
| សាច់ប្រាក់ក្នុងដៃ | ៤៩៥.៧៩៣.៥៦៨ | - | - | - | - | - | - | ៤៩៥.៧៩៣.៥៦៨ |
| ប្រាក់បញ្ញើនៅធនាគារផ្សេងៗ-សុទ្ធ | ១.៥០៩.៥៤៣.១៧៨ | - | - | - | - | - | - | ១.៥០៩.៥៤៣.១៧៨ |
| ប្រាក់បញ្ញើតាមច្បាប់ | - | - | - | - | - | - | ៥៤៨.៦២៧.១០៩ | ៥៤៨.៦២៧.១០៩ |
| ការវិនិយោគហិរញ្ញវត្ថុ | - | - | - | - | - | - | ៣៥៧.៥៤៤.៣៨៤ | ៣៥៧.៥៤៤.៣៨៤ |
| ឥណទាន និងបុរេប្រទាន-សុទ្ធ | ៦.៣៩៤.៩៦៦ | ២.១៥២.៤៤០.៧៨៣ | ១.៥៩៧.២១១.០៥៣ | ២០៤.៦១១.៧៩២ | ២៣៥.៧២០.៧៩០ | ១.៩០២.៥៦០.៦៩៦ | ១.០០២.៧២៥.១៥១ | ៦.៦០១.៦៦៥.២៣១ |
| ឧបករណ៍ហិរញ្ញវត្ថុនិស្សន្ទ | ៥.៧៤៦.៦៨៦ | - | - | - | - | - | - | ៥.៧៤៦.៦៨៦ |
| ទ្រព្យសកម្មផ្សេងៗ | ៤.២៣១.៧២៥ | - | - | - | - | - | ៤.៣១៨.៩២៤ | ៨.៥៥០.៦៤៩ |
| | ២.០២១.៧១០.១២៣ | ២.១៥២.៤៤០.៧៨៣ | ១.៥៩៧.២១១.០៥៣ | ២០៤.៦១១.៧៩២ | ២៣៥.៧២០.៧៩០ | ១.៩០២.៥៦០.៦៩៦ | ១.៩១៣.២១៥.៥៦៨ | ៩.៥២៧.៤៧០.៨០៥ |
| **ការប្រឈមឥណទានទាក់ទិននឹងសមាសធាតុក្រៅតារាងតុល្យការ៖** | | | | | | | | |
| កិច្ចសន្យាផ្តល់ឥណទានដែលមិនបានប្រើប្រាស់ | - | - | - | - | - | - | ២០៩.៨៥៤.៦៦៩ | ២០៩.៨៥៤.៦៦៩ |
| លិខិតធានារបស់ធនាគារ | - | - | - | - | - | - | ៦៧.០១៤.០០៥ | ៦៧.០១៤.០០៥ |
| លិខិតឥណទាន | - | - | - | - | - | - | ២.៣០៣.០៦២ | ២.៣០៣.០៦២ |
| | - | - | - | - | - | - | ២៧៩.១៧១.៧៣៦ | ២៧៩.១៧១.៧៣៦ |
| **ការប្រឈមឥណទានអតិបរមាសរុប** | ២.០២១.៧១០.១២៣ | ២.១៥២.៤៤០.៧៨៣ | ១.៥៩៧.២១១.០៥៣ | ២០៤.៦១១.៧៩២ | ២៣៥.៧២០.៧៩០ | ១.៩០២.៥៦០.៦៩៦ | ២.១៩២.៣៨៧.៣០៤ | ៩.៨០៦.៦៤២.៥៤១ |
| *សមមូលនឹងពាន់រៀល (កំណត់សម្គាល់ ៥)* | ៨.២៥៨.៦៨៥.៨៥១ | ៨.៧៩២.៧២០.៥៩៩ | ៦.៥២៤.៦០៧.១៥២ | ៨៣៥.៨៣៩.១៧០ | ៩៦២.៩១៩.៤២៧ | ៥.៧២៩.៤៦០.៤៤៣ | ៨.៩៥៥.៩០២.១៣៧ | ៤០.០៦០.១៣៤.៧៧៩ |

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
# នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និង សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់

## ៣៨. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### ៣៨.១ ហានិភ័យឥណទាន (ត)

(ឃ) ការប្រមូលផ្តុំទ្រព្យសកម្មហិរញ្ញវត្ថុធៀបនឹងការប្រឈមហានិភ័យឥណទាន (ត)

*(ii) វិភាគតាមប្រភេទអាជីវកម្ម (ត)*

| | សម្ព័ន្ធធនាគារ | | | | | | | |
|---|---|---|---|---|---|---|---|---|
| | គ្រឹះស្ថានហិរញ្ញវត្ថុ<br>ដុល្លារអាមេរិក | ការលក់ដុំ និង លក់រាយ<br>ដុល្លារអាមេរិក | សេវាកម្ម<br>ដុល្លារអាមេរិក | គេហដ្ឋាន<br>ដុល្លារអាមេរិក | ផលិតកម្ម<br>ដុល្លារអាមេរិក | កសិកម្ម<br>ដុល្លារអាមេរិក | អាជីវកម្មផ្សេងៗ<br>ដុល្លារអាមេរិក | សរុប<br>ដុល្លារអាមេរិក |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | | | | | | | | |
| ការប្រឈមឥណទានទាក់ទិននឹងទ្រព្យសកម្មហិរញ្ញវត្ថុក្នុងតារាងតុល្យការ | | | | | | | | |
| សាច់ប្រាក់ក្នុងដៃ | ៤៩៧.០២៧.០៤១ | - | - | - | - | - | - | ៤៩៧.០២៧.០៤១ |
| ប្រាក់បញ្ញើនៅធនាគារផ្សេងៗ-សុទ្ធ | ៨៤៦.៦០២.១៧៥ | - | - | - | - | - | - | ៨៤៦.៦០២.១៧៥ |
| ប្រាក់បញ្ញើតាមច្បាប់ | - | - | - | - | - | - | ៤៨២.៣៣០.៩៩៣ | ៤៨២.៣៣០.៩៩៣ |
| ការវិនិយោគហិរញ្ញវត្ថុ | - | - | - | - | - | - | ៥៥៦.០៣៧.៥៣២ | ៥៥៦.០៣៧.៥៣២ |
| ឥណទាននិងបុរេប្រទាន-សុទ្ធ | ១៥.៤២៥.៨៧៤ | ២.១១៤.៩៨២.៥១៣ | ១.៥៨៩.៧៣៥.៤២៣ | ២០៣.៧៤៨.៣២១ | ២២៥.០២១.៩៤២ | ១.៣៨៣.១៩៩.៩៤៨ | ៨៤៧.៣៩២.០៧២ | ៦.៣៧៩.៤០៦.០៩៣ |
| ឧបករណ៍ហិរញ្ញវត្ថុនិស្សន្ទ | ៩.៦៣០.៥៩៣ | - | - | - | - | - | - | ៩.៦៣០.៥៩៣ |
| ទ្រព្យសកម្មផ្សេងៗ | ២.៣៤៩.៨៤២ | - | - | - | - | - | ៤២.៤២៨.១២៣ | ៤៤.៧៧៧.៩៦៥ |
| | ១.៣៧១.០៣៥.៥២៥ | ២.១១៤.៩៨២.៥១៣ | ១.៥៨៩.៧៣៥.៤២៣ | ២០៣.៧៤៨.៣២១ | ២២៥.០២១.៩៤២ | ១.៣៨៣.១៩៩.៩៤៨ | ១.៩២៨.១៣៨.៧២០ | ៨.៨១៥.៨១២.៣៩២ |
| ការប្រឈមឥណទានទាក់ទិននឹងសមាសធាតុក្រៅតារាងតុល្យការ | | | | | | | | |
| កិច្ចសន្យាផ្តល់ឥណទានដែលមិនបានប្រើប្រាស់ | - | - | - | - | - | - | ១៧៥.១៣២.៤៨៩ | ១៧៥.១៣២.៤៨៩ |
| លិខិតធានារបស់ធនាគារ | - | - | - | - | - | - | ៦២.៨៧៣.៣២៩ | ៦២.៨៧៣.៣២៩ |
| លិខិតឥណទាន | - | - | - | - | - | - | ៩.១៧៦.១៣០ | ៩.១៧៦.១៣០ |
| | - | - | - | - | - | - | ២៤៧.១៨១.៩៤៨ | ២៤៧.១៨១.៩៤៨ |
| **ការប្រឈមឥណទានអតិបរមាសរុប** | ១.៣៧១.០៣៥.៥២៥ | ២.១១៤.៩៨២.៥១៣ | ១.៥៨៩.៧៣៥.៤២៣ | ២០៣.៧៤៨.៣២១ | ២២៥.០២១.៩៤២ | ១.៣៨៣.១៩៩.៩៤៨ | ២.១៧៥.៣២០.៦៦៨ | ៩.០៦២.៩៩៤.៣៤០ |
| *សមមូលនឹងពាន់រៀល (កំណត់សម្គាល់ ៥)* | ៥.៦៤៤.៥៥៣.២៥៥ | ៨.៧០៧.៣៨៣.០០៦ | ៦.៥៤៤.៩៤០.៧៣៦ | ៨៣៨.៨៣១.៨៣៨ | ៩២៦.៤១៥.៣៣៥ | ៥.៦៩៤.៤២៨.៣៣៦ | ៨.៩៥៥.៧៩៥.១៩០ | ៣៧.៣១២.៣៤៧.៦៩៦ |

# ធនាគារ អេស៊ីលីដា ភីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និង សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់

## ៣៨. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### ៣៨.១ ហានិភ័យឥណទាន (ត)

(ឃ) ការប្រមូលផ្តុំទ្រព្យសកម្មហិរញ្ញវត្ថុធៀបនឹងការប្រឈមហានិភ័យឥណទាន (ត)

*(ii) វិភាគតាមប្រភេទអាជីវកម្ម (ត)*

| | ធនាគារ | | | | | | | |
|---|---|---|---|---|---|---|---|---|
| | គ្រឹះស្ថានហិរញ្ញវត្ថុ ដុល្លារអាមេរិក | ការលក់ដុំ និង លក់រាយ ដុល្លារអាមេរិក | សេវាកម្ម ដុល្លារអាមេរិក | គេហដ្ឋាន ដុល្លារអាមេរិក | ផលិតកម្ម ដុល្លារអាមេរិក | កសិកម្ម ដុល្លារអាមេរិក | អាជីវកម្មផ្សេងៗ ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣** | | | | | | | | |
| **ការប្រឈមឥណទានទាក់ទិននឹងទ្រព្យសកម្ម ហិរញ្ញវត្ថុក្នុងតារាងតុល្យការ៖** | | | | | | | | |
| សាច់ប្រាក់ក្នុងដៃ | ៤៨៦.៥៨៤.៣១៧ | - | - | - | - | - | - | ៤៨៦.៥៨៤.៣១៧ |
